# របាយការណ៍ស្ដីពី សិក្ខាសាលាកាលពី ខែឧសភាឆ្នាំ២០២២

ពាក់ព័ន្ធនឹងសកម្មភាពជនរងគ្រោះ នៅក្នុងអំឡុង
ពេលអនុវត្តអាណត្តិសេសសល់របស់ អ.វ.ត.ក

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

ដោយ DAVID COHEN
DANIEL MATTES
SANGEETHA YOGENDRAN

# របាយការណ៍ស្តីពីសិក្ខាសាលាកាលពីខែឧសភាឆ្នាំ២០២២
# ពាក់ព័ន្ធនឹងសកម្មភាពជនរងគ្រោះ នៅក្នុងអំឡុងពេលអនុវត្ត
# អាណត្តិសេសសល់របស់ អ.វ.ត.ក

ដោយ David Cohen, Daniel Mattes, Sangeetha Yogendran

# របាយការណ៍ស្តីពីសិក្ខាសាលាកាលពីខែឧសភាឆ្នាំ២០២២ ពាក់ព័ន្ធនឹងសកម្មភាពជនរងគ្រោះ នៅក្នុងអំឡុងពេលអនុវត្តអាណត្តិសេសសល់របស់ អ.វ.ត.ក


អ្នកនិពន្ធ

David Cohen, Daniel Mattes, Sangeetha Yogendran



រចនាទំព័រ

Melany Vilchynska

របាយការណ៍ជាភាសាអង់គ្លេស

ISBN-១៣: ៩៧៨-៩៩២៤-៩៧៤៧-១-០

របាយការណ៍ជាភាសាខ្មែរ

ISBN-១៣: ៩៧៨-៩៩២៤-៩៧៤៧-០-៣



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អគារលេខ៨៤០ មហាវិថីសហព័ន្ធរុស្សី សង្កាត់មិត្តភាព
ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្រអប់សំបុត្រ ៧១

info@eccc.gov.kh

www.eccc.gov.kh



អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

# តារាងមាតិកា


សទ្ទានុក្រម ០០៨

បញ្ជីតួលេខ និងតារាង ០១០

បញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ និងអ្នករស់រានមានជីវិត ដែលបានចូលរួម ០១២

បញ្ជីឈ្មោះអង្គការនានាដែលបានចូលរួមសិក្ខាសាលា និងការពិគ្រោះយោបល់ ០១៤

បញ្ជីឧបសម្ព័ន្ធ ០១៦

សេចក្ដីសង្ខេប ០១៩

## I. សារតារ ០៣៣

អាណត្តិការងារដែលនៅសេសសល់សម្រាប់ អ.វ.ត.ក ០៣៦

តួនាទីរបស់ជនរងគ្រោះនៅក្នុងដំណើរការដែលនៅសេសសល់នៅ អ.វ.ត.ក និងគម្រោងសំណង ០៣៨

ដំណើរដើមទង និងគោលបំណងនៃសិក្ខាសាលាស្ដីពីជនរងគ្រោះ ០៥៤

## II. សិក្ខាសាលាខែឧសភា ឆ្នាំ២០២២ ស្ដីពីជនរងគ្រោះ៖ ការរចនា និងសកម្មភាព ០៦១

ដំណាក់កាលដំបូង៖ សេចក្ដីណែនាំ កាលវិភាគ ទីតាំង ផែនការត្រៀមបម្រុង កូវីដ-១៩ ០៦៤

ការពិគ្រោះយោបល់របស់អ្នកសម្របសម្រួលព្រឹត្តិការណ៍នៅមុនសិក្ខាសាលា ០៧០

លេខាធិការដ្ឋានសិក្ខាសាលា និងក្រុមការងារគាំទ្រ អ.វ.ត.ក ០៨០

របៀបវារៈ និងអ្នកចូលរួម ០៨៤

ក្រុមពិភាក្សា ០៨៩

វាគ្មិនកត្តិយស ០៩៣

## III. សេចក្តីសង្ខេបសំណើដែលបានទទួល ១០៧

សំណើឆ្លើយតបសហចៅក្រមរបាយការណ៍ និងរបកគំហើញរបស់សហចៅក្រមរបាយការណ៍ ១១០

ការពិភាក្សា និងសំណើក្នុងវគ្គពេញអង្គរបស់ក្រុមពិភាក្សានៅក្នុងសិក្ខាសាលា ១២០

សំណើដែលទទួលបានក្រោយសិក្ខាសាលា ១៥១

ក្រោយសិក្ខាសាលា៖ ការបន្តកិច្ចពិគ្រោះយោបល់បន្ទាប់ពីព្រឹត្តិការណ៍ ១៦៧

## IV. សេចក្តីសង្កេត ប្រធានបទរួម និងអនុសាសន៍ ១៨៧

ស្ថានភាពជនរងគ្រោះ ១៨៦

"មិនបង្កការឈឺចាប់" និងជៀសវាងរបួសផ្លូវចិត្តជាថ្មីដល់ជនរងគ្រោះ ១៨៩

ភាពជាម្ចាស់នៅថ្នាក់មូលដ្ឋាន និងជាបុគ្គល សមាហរណកម្ម និងចីរភាព ១៩១

ប្រធានបទរួម គោលការណ៍ និងចំណុចព្រមព្រៀង ១៨៤

ផែនការយុទ្ធសាស្រ្តសម្រាប់គំនិតផ្តួចផ្តើមផ្តោតលើជនរងគ្រោះក្នុងដំណាក់កាលដែលនៅសេសសល់ ១៩៩

## V. សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់ ២០៩

បញ្ជីឧបសម្ព័ន្ធ ២១៧

# សទ្ទានុក្រម

| | | |
|---|---|---|
| **C** | CMS | ផ្នែកគ្រប់គ្រងតុលាការ |
| | CPK | បក្សកុម្មុយនីស្តកម្ពុជា |
| | CPL | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| | CPLCL | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| | CRSV | អំពើហិង្សាពាក់ព័ន្ធនឹងជម្លោះ |
| | CSO | អង្គការសង្គមស៊ីវិល |
| **D** | DK | កម្ពុជាប្រជាធិបតេយ្យ |
| **E** | ECCC | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| **I** | ICC | តុលាការព្រហ្មទណ្ឌអន្តរជាតិ |
| | ICIJ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ |
| | ICP | សហព្រះរាជអាជ្ញាអន្តរជាតិ |
| | ICTR | សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសរ្វ៉ាន់ដា |
| | ICTY | សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី |
| | IGO | អង្គការអន្តររដ្ឋាភិបាល |
| | IR(S) | វិធានផ្ទៃក្នុងនៃ អ.វ.ត.ក |
| | ITU | អង្គភាពបកប្រែភាសា |
| **K** | KR | ខ្មែរក្រហម |
| | KRT | សាលាក្តីខ្មែរក្រហម |
| **N** | NGO | អង្គការមិនមែនរដ្ឋាភិបាល |

| | | |
|---|---|---|
| **O** | OCIJ | ការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ |
| | OCP | ការិយាល័យសហព្រះរាជអាជ្ញា |
| **P** | PAS | ផ្នែកកិច្ចការសាធារណៈ |
| | PTC | អង្គបុរេជំនុំជម្រះ |
| **R** | RAK | កងទ័ពបដិវត្តន៍កម្ពុជា |
| | RGC | រាជរដ្ឋាភិបាលកម្ពុជា |
| **S** | SCC | អង្គជំនុំជម្រះតុលាការកំពូល |
| | SCSL | តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន |
| | SGBV | អំពើហិង្សាផ្លូវភេទ និងយេនឌ័រ |
| **T** | TC | អង្គជំនុំជម្រះសាលាដំបូង |
| **U** | UN | អង្គការសហប្រជាជាតិ |
| | UNAKRT | ជំនួយអង្គការសហប្រជាជាតិដល់សាលាក្ដីខ្មែរក្រហម |
| **V** | VSS | ផ្នែកគាំពារជនរងគ្រោះ |
| **W** | WESU | អង្គភាពគាំពារសាក្សី និងអ្នកជំនាញ |

# បញ្ជីតួលេខ និងតារាង

ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ និង០០២ ០៤០

គម្រោងសំណងក្នុងសំណុំរឿង ០០១ និង០០២/០១ ០៤៥

គម្រោងសំណងក្នុងសំណុំរឿង ០០២/០២ ០៥០

សមាសភាព ប្រធានបទ និងក្រុមពិភាក្សាក្នុងសិក្ខាសាលា ០៩១

វាគ្មិនកិត្តិយស ០៩៥

សំណើឆ្លើយតបទៅនឹងសេចក្តីអំពាវនាវខែតុលា ឆ្នាំ២០២១ របស់សហចៅក្រមរបាយការណ៍ ១១៣

ប្រភេទនៃសំណើដែលបានដាក់មកសហចៅក្រមរបាយការណ៍ ១២០

អ្នកចូលរួមរៀបជាក្រុមខ្លឹមសារ ក្នុងសិក្ខាសាលាអ.វ.ត.ក ស្តីពីជនរងគ្រោះ ១២២

សំណើធ្វើឡើងដោយក្រុមទៅតាមប្រធានបទនៅក្នុងអំឡុងពេលសិក្ខាសាលាស្តីពីជនរងគ្រោះ អ.វ.ត.ក ១២៥

សំណើក្រុម ២ ស្តីពីការផ្តល់សេវាថែទាំដល់ជនរងគ្រោះ-អ្នករស់រានមានជីវិត ១៣៥

សំណើទទួលបានក្នុងខែឧសភា ឆ្នាំ២០២២ ក្រោយសិក្ខាសាលាជនរងគ្រោះ អ.វ.ត.ក ១៥៣

សំណើទទួលបានពីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦០នាក់ នៅក្នុងវេទិកា VSS-CPLCL
កាលពីថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០២២ ១៧៣

សំណើទទួលបានពីអ្នកចូលរួមនៅក្រៅប្រទេស ១៧៧

សំណើទទួលបានពីសហគមន៍ក្រៅប្រទេសក្រោយសិក្ខាសាលាជនរងគ្រោះ អ.វ.ត.ក ១៨៣

# បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងអ្នករស់រានមានជីវិត ដែលបានចូលរួម

**លោក ចាន់ សាត**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

**លោកស្រី ពេជ្រ ស្រីផល**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

**លោក ម៉ម ចន្ថា**
ជនរងគ្រោះ-អ្នករស់រានមានជីវិត

**លោក ម៉ន សុធា**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១

**លោក ឆែ ហៀប**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១

**លោកស្រី មាស ផល្លី**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២




**លោកស្រី ហ៊ុន សិត្ថានី**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

**លោកស្រី ញឹម គឹមហៀន**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១

**លោកស្រី កាន់ សុន្ទរ៉ា**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១

**លោកស្រី សៀង ចាន់ធី**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

**លោក ចៅ នី**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុង
សំណុំរឿង ០០២

**លោកស្រី អ៊ឹម វណ្ណៈ**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

**លោក ស៊ុំ រិទ្ធី**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

**លោកស្រី ហុង សាវ៉ាត**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១

**លោក ប៊ូម៉េង***
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១
និង ០០២ និងជាជនរងគ្រោះ-អ្នករស់រាន
មានជីវិតពីមន្ទីរសន្តិសុខ ស-២១

**លោក ជុំ ម៉ី***
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១
និង ០០២ និងជាជនរងគ្រោះ-អ្នករស់រាន
មានជីវិតពីមន្ទីរសន្តិសុខ ស-២១

**លោក នង ចាន់ផល***
កុមាររងគ្រោះ-អ្នករស់រានមានជីវិត
ពីមន្ទីរសន្តិសុខ ស-២១

**លោកស្រី យឹម សុវណ្ណ**
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

*បានចូលរួមវគ្គបើកសិក្ខាសាលា

# បញ្ជីឈ្មោះអង្គការនានាដែលបានចូលរួម សិក្ខាសាលា និងការពិគ្រោះយោបល់

| | | |
|---|---|---|
| A | ADHOC | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| | ASRIC | វិទ្យាស្ថានស្រាវស្រាវសង្គមអនុវត្តនៃកម្ពុជា |
| | AUPP | សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ |
| B | BAKC | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| | BOPHANA CENTER | មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា |
| C | CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| | CKGC | មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក |
| | CKS | មជ្ឈមណ្ឌលខេមរសិក្សា |
| | CJA | មជ្ឈមណ្ឌលយុត្តិធម៌ និងគណនេយ្យភាព |
| | CPS | សេវាសន្តិភាពពលរដ្ឋ |
| | CSHL | មជ្ឈមណ្ឌលសិក្សានីតិមនុស្សធម៌ |
| D | DC-CAM | មជ្ឈមណ្ឌលឯកសារកម្ពុជា |
| F | FUTURE FORUM | អង្គការវេទិកាអនាគត |
| G | GADC | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា |
| | GD ALLIANCE | អង្គការ GD Alliance |
| | GIZ | អង្គការអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| | GSF | អង្គការមូលនិធិអ្នករស់រានមានជីវិតសកល |
| H | HELPAGE | អង្គការមនុស្សចាស់កម្ពុជា |
| K | KDK | អង្គការក្ដីករុណា |
| L | LAC | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| | LDC | មជ្ឈមណ្ឌលឯកសារច្បាប់នៃ អ.វ.ត.ក |

| | | |
|---|---|---|
| **M** | MCFA | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| | MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| **N** | NGOF | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា |
| **O** | OSJI | អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សង្គមសេរី |
| **P** | PUC | សាកលវិទ្យាល័យបញ្ញាសាស្ត្រនៃកម្ពុជា |
| **R** | REDRESS | អង្គការ REDRESS |
| | RULE | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| | RWI | វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺក |
| **S** | SNB | ក្រុមហ៊ុនមេធាវី អេស អិន ប៊ី |
| | SNEHA CENTER | មជ្ឈមណ្ឌលស្នេហា |
| | STANFORD CENTER | មជ្ឈមណ្ឌលសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ សាកលវិទ្យាល័យស្ដេនហ្វត |
| | SWISSPEACE | អង្គការ Swisspeace |
| **T** | TPO | អង្គការចិត្តសង្គមអន្តរវប្បធម៌ |
| | TSGM | សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង |
| **U** | UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃ អ.ស.ប |
| | UNOHCHR | ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃ អ.ស.ប |
| | UNWOMEN | អង្គភាព អ.ស.ប សម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី |
| | UYFC | សហភាពសហព័ន្ធយុវជនកម្ពុជា |
| **W** | WPM | អង្គការនារីដើម្បីសន្តិភាព |
| **Y** | YFP | អង្គការយុវសន្តិភាព |
| | YRDP | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន |

# បញ្ជីឧបសម្ព័ន្ធ

| | | |
|---|---|---|
| I. | អត្ថបទកិច្ចព្រមព្រៀងបន្ថែមនៃកិច្ចព្រមព្រៀង UN-RGC | ២២១ |
| II. | សេចក្តីអំពាវនាវបង្ហាញចំណាប់អារម្មណ៍បំពេញមុខងារជាអ្នកសម្របសម្រួល អ្នកចាត់ចែង និងអ្នកជួយសម្រួលការងារ | ២២១ |
| III. | របៀបវារៈចុងក្រោយសម្រាប់សិក្ខាសាលាខែឧសភា ឆ្នាំ២០២២ | ២២១ |
| IV. | សេចក្តីប្រកាសសារព័ត៌មានចំនួនពីរ (ទាំងពីរភាសា) សម្រាប់សិក្ខាសាលាខែឧសភា ឆ្នាំ២០២២ | ២២១ |
| V. | ប្រតិចារឹកនៃសុន្ទរកថាក្នុងវគ្គសាធារណៈនៃសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ | ២២១ |
| VI. | សំណើទាំងអស់ឆ្លើយតបទៅនឹងសេចក្តីអំពាវនាវខែតុលា ឆ្នាំ២០២១ របស់សហចៅក្រមរបាយការណ៍ | ២២១ |
| VII. | សំណើទាំងអស់ដែលបានដាក់ជូនលេខាធិការដ្ឋានក្រោយសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ | ២២១ |

# សេចក្តីសង្ខេប

ខណៈកិច្ចដំណើរការនីតិវិធីតុលាការចុងក្រោយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០២២ ស្ថាប័ននេះស្ថិតក្នុងដំណាក់កាលអន្តរកាលដ៏សំខាន់មួយ។ ជំពូកថ្មីកំពុងរង់ចាំ មុខងារដែលនៅសេសសល់របស់ស្ថាប័នដូចបានកំណត់នៅក្នុងកិច្ចព្រមព្រៀងបន្ថែមរវាងរាជរដ្ឋាភិបាលកម្ពុជា (RGC) និងអង្គការសហប្រជាជាតិ (UN) ។ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះមុនពេលសាលាក្តីកំពុងឈានទៅរកដំណាក់កាលដែលនៅសេសសល់ អ.វ.ត.ក បានចាប់ផ្តើមខិតខំកិច្ចការសាធារណៈថ្មីៗ ដើម្បីប្រមូលគំនិត និងចែករំលែកព័ត៌មានជាមួយសាធារណជន អង្គការសង្គមស៊ីវិលពាក់ព័ន្ធ និងជនរងគ្រោះដែលនៅរស់រានមានជីវិត និងអ្នកតំណាងរបស់ពួកគេ។ របាយការណ៍នេះសង្ខេបវេទិកាពិគ្រោះយោបល់ដែលទើបរៀបចំកាលពីប៉ុន្មានខែថ្មីៗកន្លងទៅនេះនិងការត្រៀម លក្ខណៈសម្រាប់ដំណាក់កាលការងារដែលនៅសេសសល់ ដែលជិតចូលមកដល់ រួមទាំងសិក្ខាសាលាថ្មីៗស្តីពីជនរងគ្រោះដែលបានធ្វើឡើងចាប់ពីថ្ងៃទី៣ ដល់ ថ្ងៃទី៥ខែឧសភា ឆ្នាំ២០២២។

នៅក្នុងកិច្ចព្រមព្រៀងបន្ថែមរវាង UN-RGC ស្តីពី អ.វ.ត.ក ដែលបានចូលជាធរមានកាលពីខែសីហា ឆ្នាំ២០២១ មាត្រា ២ ចែងត្រង់ផ្នែកពាក់ព័ន្ធអំពីសកម្មភាពដែល ផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី...ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទាក់ទងនឹងអង្គជំនុំជម្រះ និងតាមដានការអនុវត្តសំណងដែលផ្តល់ដល់ដើម បណ្តឹងរដ្ឋប្បវេណី ស្របតាមលក្ខខណ្ឌតម្រូវ។ ក្រុមទាំងបួននៅក្នុងប្រយោគនេះ ពោលគឺ ជនរងគ្រោះ សាក្សី ដើម បណ្តឹងរដ្ឋប្បវេណី និងសាធារណជន បង្កើតជាទិដ្ឋភាពទូលំទូលាយនៃសកម្មភាពទាក់ទងនឹងជនរងគ្រោះ ដែលផុសចេញពីរបាយការណ៍ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមរបាយការណ៍ចាត់តាំងដោយ អ.វ.ត.ក ដើម្បីផ្តល់អនុសាសន៍អំពីកម្មវិធីដែលអាចអនុវត្តទិដ្ឋភាពនៃមុខងារដែលនៅសេសសល់។

ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបប DK គឺជាកម្លាំងជំរុញក្នុងអំឡុងពេលដំណើរការរយៈពេល ១៥ឆ្នាំចុងក្រោយនេះ។ មិនថាតាមរយៈការចូលរួមកិច្ចដំណើរការនីតិវិធីក្នុងដំណាក់ការស៊ើបអង្កេត និងការជំនុំជម្រះក្នុងនាមដើមបណ្តឹងបរិហារ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ឬ តាមរយៈការចូលរួមនៅក្នុងគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល លើការកសាងការផ្សះផ្សា និងការស្វែងរកការពិតនៅក្រៅតុលាការ ជនរងគ្រោះ និងអ្នករស់រានមានជីវិតបានចែករំលែករឿងរ៉ាវរបស់ពួកគេដើម្បីឱ្យបានឮសុះសាយ។ សក្ខីកម្មរបស់ពួកគេ ក៏ដូចជាភស្តុតាងឯកសារដែលប្រមូលបានដោយអ្នកស៊ើបអង្កេតដែលសម្ភាសជនរងគ្រោះ និងអ្នករស់រានមានជីវិត ត្រូវបានដាក់ដេញដោលក្នុងពេលជំនុំជម្រះ ហើយបច្ចុប្បន្ន អាចត្រូវបានប្រើប្រាស់ជាធនធានសម្រាប់ការអប់រំ និងផ្សព្វផ្សាយព័ត៌មានសម្រាប់មនុស្សជំនាន់ក្រោយ

ស្វែងយល់បន្ថែមអំពីការឈឺចាប់ក្នុងពេលអតីតកាល។ ជាការឆ្លើយតបទៅនឹងសំណើជាក់លាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណី គម្រោងសំណងសរុបចំនួន ២៦ ត្រូវបានទទួលស្គាល់ និងអនុវត្តក្នុងអំឡុងពេលសវនាការចំនួនបី ដែលបានធ្វើឡើងនៅ អ.វ.ត.ក។ ជនរងគ្រោះ និងអ្នករស់រានមានជីវិតនៅទូទាំងប្រទេសកម្ពុជា និងសហគមន៍នៅជុំវិញសកលលោក នឹងបន្តជាសសរស្តម្ភសម្រាប់ដំណាក់កាល អ.វ.ត.ក នាពេលបន្តបន្ទាប់។

ចៅក្រម អ.វ.ត.ក ចំនួនពីររូប ចៅក្រម យូ ឧត្តារ៉ា និង ចៅក្រម Claudia FENZ ត្រូវបានតែងតាំងដោយការិយាល័យរដ្ឋបាលកាលពីខែកក្កដា ឆ្នាំ២០២១ ជា សហចៅក្រមរបាយការណ៍អំពីមុខងារដែលនៅសេសសល់ទាក់ទងនឹងជនរងគ្រោះ។ ក្នុងចំណោមការងារផ្សេងទៀត របាយការណ៍ប្រឹក្សាយោបល់ដែលបានបោះពុម្ពកាលពីខែធ្នូ ឆ្នាំ២០២១ បានអំពាវនាវឱ្យ អ.វ.ត.ក រៀបចំកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធ។ អ.វ.ត.ក បានទទួលប្រកាន់យកអនុសាសន៍របស់សហចៅក្រមរបាយការណ៍ អ.វ.ត.ក ដោយបានសម្រេចរៀបចំសិក្ខាសាលាស្តីពីជនរងគ្រោះកាលពីខែឧសភា ឆ្នាំ២០២២ ក្រោមការរៀបចំដោយទីប្រឹក្សាឯករាជ្យពីខាងក្រៅចំនួនបីរូប ដែលបានរៀបចំរបាយការណ៍នេះឡើង។ បញ្ហាប្រឈមសម្រាប់អ្នករៀបចំគឺការបង្កើតក្របខ័ណ្ឌ សមស្របឱ្យត្រូវទៅតាមដែនកំណត់នៃអាណត្តិការងារដូចមានចែងក្នុងកិច្ចព្រមព្រៀងបន្ថែម ហើយក៏ត្រូវធានាឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីសង្គមស៊ីវិល និងដើម បណ្ដឹងរដ្ឋប្បវេណី ដើម្បីឱ្យបានឮសំឡេង គ្រប់ក្រុមភាគីពាក់ព័ន្ធ និងភាគីចាប់អារម្មណ៍ ទាំងជាតិ និងអន្តរជាតិ យកមកដាក់បញ្ចូលនៅក្នុងសំណើចូលរួម។ គោលដៅសំខាន់គឺដើម្បីលើកទឹកចិត្ត និងសម្រួលដល់ការបង្កើតសំណើគម្រោង និងគំនិតផ្ដួចផ្ដើមនានា ក្នុងន័យសកម្មនិងស្ថាបនា ដែលនឹងកំណត់តម្រូវការ និងឱកាសសំខាន់បំផុតសម្រាប់សកម្មភាពទាក់ទងនឹងជនរងគ្រោះ ហើយថែមទាំងផ្ដល់នូវវេទិកាមួយ ដែលតាមរយៈវេទិកានេះនឹងបង្កើតបានសំណើជាក់ស្តែង និងមានថវិកាដ៏សមស្របបំផុត។

អនុសាសន៍របស់សហចៅក្រមរបាយការណ៍អំពី កិច្ចសន្ទនា ត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដោយរួមបញ្ចូលកិច្ចសន្ទនាប្រកបដោយផ្លែផ្កាក្នុងចំណោមក្រុមភាគីពាក់ព័ន្ធ ក៏ដូចជាកិច្ចសន្ទនាជាមួយ អ.វ.ត.ក និងជាមួយម្ចាស់មូលនិធិសក្ដានុពល តំណាងដោយស្ថាប័ន RGC អង្គការផ្ដល់មូលនិធិអន្តរជាតិ និងស្ថានទូតតំណាងរដ្ឋជាសមាជិកក្រុម "មិត្តផ្ដល់ជំនួយនៃ អ.វ.ត.ក"។ សិក្ខាសាលាបានផ្ដល់ឱកាសបន្តការចូលរួមយ៉ាងស៊ីជម្រៅពីមុនរបស់ អ.វ.ត.ក ជាមួយជនរងគ្រោះ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈសកម្មភាពជាច្រើនឆ្នាំរបស់ខ្លួនជុំវិញការផ្ដល់សំណង ការចុះផ្សព្វផ្សាយនៅតាមសហគមន៍ និងការការពារសាក្សី និងជនរងគ្រោះ។

ការរៀបចំសិក្ខាសាលា ដំបូង ធ្វើឡើងក្រោមប្រធានបទចំបងៗចំនួនបីទាក់ទងនឹងជនរងគ្រោះ៖ ការទទួលស្គាល់ ការចងចាំ និងការផ្សះផ្សា។ ដើម្បីជាការទទួលស្គាល់ការឈឺចាប់ និងការរងគ្រោះ មានសំណួរបំផុសនិយមន័យអំពីស្ថានភាពជនរងគ្រោះ។ ចំពោះការផ្សះផ្សាក្នុងសង្គមសព្វថ្ងៃ យើងមិនត្រឹមពិចារណាសញ្ញាណប្រពៃណីស្តីពីជនរងគ្រោះ និងអតីតចារីប៉ុណ្ណោះនោះទេ យើងក៏ពិចារណានៅក្នុងក្របខ័ណ្ឌគ្រួសារ និងសហគមន៍ ឬ គ្រប់ជំនាន់ផងដែរ។ ហើយចំពោះសកម្មភាពនៃការចងចាំវិញ តើយើងអាចបង្ហាញប្រវត្តិសាស្ត្រលើសពីរចនាសម្ព័ន្ធរូបវន្ត ដែលយើង [ត្រូវការបំផុត] តែករណីនេះ ឬ រំលឹកអតីតកាលដោយមិនធ្វើឱ្យជនរងគ្រោះឈឺចាប់សាជាថ្មី ឬ បង្ខំឱ្យពួកគេនៅញាំញីក្នុងស្រមោលទុកសោកពីអតីតកាល

បន្តទៀត? ប្រធានបទចំបងទាំងបីនេះបានក្លាយជាចំណុចចាប់ផ្តើមសម្រាប់សិក្ខាសាលា ហើយត្រូវបានលើកឡើងក្នុងសុន្ទរកថាគន្លឹះ និងការពិភាក្សាក្រុម។

ដើម្បីផ្តល់ព័ត៌មានអំពីសិក្ខាសាលានាពេលខាងមុខ និងដើម្បីចាប់ផ្តើមការពិភាក្សាអំពីកម្មវិធីសក្តានុពលទាក់ទងនឹងជនរងគ្រោះ អ្នកសម្របសម្រួលសិក្ខាសាលា ចាប់ផ្តើមដំបូងដោយធ្វើការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលសំខាន់ៗ (CSOs) ស្ថាប័នរដ្ឋ និងអ្នកតស៊ូមតិ ឬ អ្នកស្រាវជ្រាវជាជនរងគ្រោះជាយូរមកហើយ ដែលចាប់អារម្មណ៍ចំពោះដំណើរការរបស់ អ.វ.ត.ក ក្នុងគោលបំណងដើម្បីកសាងការចូលរួម និងសុទិដ្ឋិនិយមសម្រាប់សិក្ខាសាលា និងដំណាក់កាលដែលនៅសេសសល់របស់ អ.វ.ត.ក ដើម្បីព្យាយាមកំណត់ការរំពឹងទុកសម្រាប់ព្រឹត្តិការណ៍នាពេលខាងមុខ និងលើកទឹកចិត្តអ្នកចូលរួមចាប់ផ្តើមរៀបចំព្រឹត្តិការណ៍នេះឱ្យបានល្អជាមុន។ ការពិគ្រោះយោបល់ទាំងនេះក៏បានផ្តល់ឱកាសរំលឹកឡើងវិញនូវការអះអាងដក់ក្នុងចិត្តជាយូរមកហើយថា អ.វ.ត.ក មិនទាន់បានធ្វើកិច្ចការគ្រប់គ្រាន់សម្រាប់ជនរងគ្រោះ ដោយដំបូងចាប់ផ្តើមជាមួយនឹងសំណួរថ្មីមួយ៖ តើជនរងគ្រោះ និងតំណាងពួកគេចង់បានអ្វីពី អ.វ.ត.ក ក្នុងដំណាក់កាលដែលនៅសេសសល់នេះ? តើការខកចិត្តពីមុនអាចប្រែក្លាយទៅជារបៀបវារៈថ្មីផ្តោតចំបងលើជនរងគ្រោះតាមវិធីណា? ទោះបីជាមានការសង្ស័យខ្លាំងមកហើយក៏ដោយ អ្នកចូលរួមដែលយើងបានពិគ្រោះយោបល់ ជាពិសេសអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលឈានមុខជាយូរមកហើយក្នុងការងារឆ្លើយតបនឹងសំណើរបស់ជនរងគ្រោះ - បន្តបង្ហាញអំពីសុទិដ្ឋិនិយម និងក្តីរំភើបយ៉ាងខ្លាំង។ នៅទីបញ្ចប់ ការបង្កើតចំណាប់អារម្មណ៍នៅក្នុងសិក្ខាសាលា និងដំណាក់កាលដែលនៅសេសសល់ ពុំមែនជាការប្រឈមណាស់ណានោះទេ។

បន្ទាប់ពីមានការងឿងឆ្ងល់ជាច្រើនឆ្នាំថាតើតុលាការនឹងឱ្យពួកគេចូលរួមដែរឬទេ ហើយបន្ទាប់ពីការងាររយាលមិនអាចជួបគ្នាបានដោយសារជំងឺរាតត្បាតរយៈពេលពីរឆ្នាំ យើងហាក់មើលឃើញថា ភាគីពាក់ព័ន្ធ និងអ្នក អនុវត្តផ្ទាល់ជាយូរមកហើយនោះ កំពុងពោរពេញដោយទស្សនៈ និងផែនការចែករំលែកនៅក្នុងព្រឹត្តិការណ៍នាពេលខាងមុខ និងក្នុងការរៀបចំផែនការជាប្រយោជន៍បំផុតសម្រាប់អាណត្តិការងារដែលសេសសល់នៅ អ.វ.ត.ក ដែលខិតជិតមកដល់។ ទោះជាយ៉ាងនេះក្តី ប្រធានបទនេះក៏ជំរុញឱ្យមានការលើកឡើងបញ្ហាប្រឈមសំខាន់ៗផ្សេងទៀត ជាថ្មីម្តងទៀត៖ ឧបសគ្គនៃការធ្វើឱ្យការឈឺចាប់ផើឡើងវិញ ភាពចាំបាច់ត្រូវអនុវត្ត "វិធីសាស្ត្រមិនបង្កការឈឺចាប់" និងបញ្ហាឯកជនភាព និងការការពារអ្នករស់រានមានជីវិត និងសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ អ្នកចូលរួមផ្សេងទៀតបានលើកបញ្ហាថាតុលាការមិនបានធ្វើទំនាក់ទំនងបានល្អ និងកិច្ចខិតខំប្រឹងប្រែងផ្តល់ព័ត៌មានដល់សាធារណជនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ មេធាវីមួយរូបបានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការអនុវត្ត "យុទ្ធសាស្ត្របីត្រូវ" ទំនាក់ទំនង សម្របសម្រួល និងសហការ ហើយបានអំពាវនាវឱ្យតុលាការចែករំលែកសម្ភារៈឯកសារទាំងអស់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាននៅក្នុងដំណាក់កាលអន្តរកាលដ៏សំខាន់នេះ។ សុទិដ្ឋិនិយមនេះត្រូវមានភាពច្បាស់លាស់ និងតម្លាភាពទាក់ទងនឹងអ្វីដែលដំណាក់កាលដែលនៅសេសសល់អាច និងមិនអាចសម្រេចបាន។ ការរំពឹងទុករបស់ជនរងគ្រោះមិនត្រូវលើកឡើងនៅពេលនេះទេ បើមិនដូច្នោះនឹងធ្វើឱ្យពួកគេខកចិត្តកាន់តែខ្លាំងថែម ទៀត។

ផ្អែកលើការសន្ទនាទាំងនេះ យើងហាក់ពិនិត្យឃើញថា CSOs ភាគច្រើនចង់ស្វែងយល់អំពីសំណើ និង ទស្សនៈទៅវិញទៅមក ជាពិសេសបន្ទាប់ពីរយៈពេលពីរឆ្នាំនៃជំងឺរាតត្បាតបានធ្វើឱ្យអង្គការដែលមានការគិតគូរដូចគ្នា កាន់តែធ្វើការងារដាច់ចេញពីគ្នាខ្លាំងឡើង។ បច្ចុប្បន្ននេះ អង្គការជាច្រើនបានចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការអភិវឌ្ឍការប្រែក្លាយការផ្លាស់ប្តូរសម្រាប់យុវជន ឱ្យមើលឃើញការប្រែក្លាយទាំងនេះនាពេលអនាគត ដែលចាក់ឫសគល់លើសន្តិភាព និងស្ថានការណ៍ក្រោយជម្លោះ ដែលពួកគេបានជំងឺងក្តី និងសម្រាប់ចាស់ៗជំនាន់មុនដែលនៅរស់រានមានជីវិត ដែលភាគច្រើនស្ថិតក្នុងភាពក្រីក្រ ឬកាលៈទេសៈលំបាកលំបិន។ ទោះបីជា CSOs សង្ឃឹមថានឹងប្រែក្លាយសង្គមនៅពេលមានការផ្លាស់ប្តូរជំនាន់ក៏ដោយ អង្គការផ្សេងទៀតបានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការប្រែក្លាយស្ថានភាពលំបាកដែលអ្នករស់រានមានជីវិតជាជនរងគ្រោះមានវ័យចំណាស់ កំពុងជួបប្រទះ។

នៅទីបំផុត អ.វ.ត.ក បានរៀបចំ "សិក្ខាសាលាស្តីពីជនរងគ្រោះ និងការផ្សព្វផ្សាយរបាយការណ៍ប្រឹក្សាយោបល់ស្តីពីសកម្មភាពពាក់ព័ន្ធជនរងគ្រោះនៃ អ.វ.ត.ក ក្នុងដំណាក់កាលដែលនៅសេសសល់" ក្នុងរយៈពេលបីថ្ងៃពេញ ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ នៅសណ្ឋាគារ Hyatt Regency ក្នុងរាជធានីភ្នំពេញ។ សិក្ខាសាលាបានចាប់ផ្តើម និងបញ្ចប់ជាមួយកម្មវិធីបើក និងបិទវគ្គជាសាធារណៈ ដោយអនុញ្ញាតឱ្យសាធារណជនចូលរួមតាមរយៈការផ្សាយផ្ទាល់តាមអ៊ីនធឺណិត និងមានសមាជិកសារព័ត៌មានចូលរួមផងដែរ។ ក្នុងពិធីបើកនៅថ្ងៃទី០៣ ខែឧសភា មានភ្ញៀវកិត្តិយសប្រមាណ ១២០នាក់ រួមទាំងឥស្សរជនមួយចំនួនមកពី RGC ស្ថានបេសកកម្មការទូតនៅទីក្រុងភ្នំពេញ និងអង្គការអន្តរជាតិនានា។ វាគ្មិនកិត្តិយសក្នុងពិធីបើក និងបិទ រួមមាន ឯកឧត្តម ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទី អ.វ.ត.ក ឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតបារាំង និងជាសហប្រធានមិត្ត អ.វ.ត.ក ឯកឧត្តម កែវ រ៉េមី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាអនុប្រធាន អចិន្ត្រៃយ៍នៃក្រុមការងាររាជរដ្ឋាភិបាលលើកិច្ចដំណើរការនីតិវិធី អ.វ.ត.ក. លោកបណ្ឌិត David Cohen អ្នកសម្របសម្រួលសិក្ខាសាលា លោកជំទាវ បណ្ឌិត Beth Van Schaack ឯកអគ្គរដ្ឋទូតសហរដ្ឋគោចរណ៍សហរដ្ឋអាមេរិកទទួលបន្ទុកយុត្តិធម៌ព្រហ្មទណ្ឌសកល (តាមរយៈសារវីដេអូ); លោក ហង្ស វណ្ណៈ ប្រធាន VSS; លោក ចាន់ សាត ដើមបណ្តឹងរដ្ឋប្បវេណី; លោកស្រី ពេជ្រ ស្រីផល ដើមបណ្តឹងរដ្ឋប្បវេណី; ឯកឧត្តម Mikami Masahiro ឯកអគ្គរដ្ឋទូតជប៉ុន និងជាសហប្រធានមិត្ត អ.វ.ត.ក និងលោក Knut Rosandhaug អនុប្រធានរដ្ឋបាលនៃ អ.វ.ត.ក។ សិក្ខាសាលារយៈពេលបីថ្ងៃនេះក៏មានវាគ្មិនសំខាន់ៗចំនួនប្រាំរូបចូលរួម រួមមាន លោកស្រី យឹម សុធារី; លោក Karim A.A. Khan, QC លោកវេជ្ជបណ្ឌិត Christoph Sperfeldt លោក Dato' Shyamala Alagendra និងឯកឧត្តម លី ច័ន្ទតុលា។ សុន្ទរកថាគន្លឹះសំខាន់ៗទាំងប្រាំត្រូវបានស្នើឱ្យឆ្លុះបញ្ចាំងលើបទពិសោធន៍របស់វាគ្មិន ដោយហេតុថាវាពាក់ព័ន្ធនឹងប្រធានបទ និងបញ្ហាសំខាន់ៗដែលសិក្ខាសាលានឹងធ្វើឡើង។

អ្នកចូលរួមពេញក្នុងរយៈពេល ០៣ថ្ងៃ មានចំនួនជាង ៩០នាក់ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥នាក់។ អ្នកចូលរួមមានទាំងតំណាង NGOs ក្នុងស្រុក និងអង្គការអន្តរជាតិ ស្ថាប័នរដ្ឋ និងសារមន្ទីរ មេធាវីតំណាងដើម បណ្តឹងរដ្ឋប្បវេណី អ្នកសិក្សាឯករាជ្យ មេធាវី និងអ្នកស្រាវជ្រាវ ព្រមទាំងភាគី និងបុគ្គលិក អ.វ.ត.ក។ លេខាធិការដ្ឋាននៃសិក្ខាសាលា

បានបង្កើត និងរៀបចំក្រុមការងារចំនួនប្រាំបីក្រុម ដើម្បីលើកជំរុញការពិភាក្សាស៊ីជម្រៅលើប្រធានបទចំនួនប្រាំបីដាច់ដោយឡែកពីគ្នាក្នុងព្រឹត្តិការណ៍រយៈពេលបីថ្ងៃនេះ។ អ្នកចូលរួមត្រូវបានបំបែកជាក្រុមមិនមែនទៅតាមចំណាប់អារម្មណ៍ និងជំនាញរបស់ពួកគេទាក់ទងនឹងប្រធានបទចំនួនប្រាំបី ជៀសវាងការបែងចែកតាមអង្គការស្ថាប័នរបស់ពួកគេ។ ការរៀបចំដូច្នេះក៏ជាវិធីមួយដើម្បីធានាថាអង្គការមានតំណាងចូលរួមច្រើននាក់ ត្រូវបានបែងចែកទៅតាមក្រុមទាំងនោះផងដែរ។ ប្រធានបទទាំង ៨ រួមមាន៖ មួយក្រុមដែលមានសមាជិកជាដើមបណ្តឹង រដ្ឋប្បវេណី ពិភាក្សាលើប្រធានបទសុខភាពផ្លូវចិត្ត ការព្យាបាលរបួស ភាពចាស់ជរា និងភារកិច្ចចំពោះជនរងគ្រោះ; បណ្ណសារដ្ឋាន និងឯកសារផ្តោតលើជនរងគ្រោះ និងការការពារសាក្សី និងជនរងគ្រោះ; ទីតាំងប្រវត្តិសាស្ត្រ បូជនីយដ្ឋាន និងសកម្មភាពនៃការចងចាំ; ជនជាតិភាគតិច និងសាសនា; សិទ្ធិទទួលបានយុត្តិធម៌ និងជំនួយផ្នែកច្បាប់; កិច្ចសន្ទនាអន្តរជំនាន់ យុវជន និងប្រវត្តិសាស្ត្រតាមការរៀបរាប់ដោយផ្ទាល់មាត់; ការទទួលស្គាល់ និងសំណងសម្រាប់អំពើហិង្សាផ្លូវភេទ និងយេនឌ័រ។ នៅពេលបញ្ចូលតំណាងអង្គការផ្សេងៗគ្នានៅក្នុងក្រុមការងារទាំងប្រាំបីនេះ លេខាធិការដ្ឋានសង្ឃឹមថានឹងអាចឱ្យមានការពិភាក្សាអំពីមហិច្ឆតារួម។ សមាសភាពចម្រុះនៃក្រុមនីមួយៗបើក លទ្ធភាពឱ្យអ្នកតស៊ូមតិសង្គមស៊ីវិលអាចនិយាយដោយផ្ទាល់ជាមួយស្ថាប័នរដ្ឋ ឬអង្គការអន្តរជាតិ ដើម្បីលើកកម្ពស់កិច្ចសន្ទនាឱ្យកាន់តែទូលំទូលាយ សំដៅបង្កើតលទ្ធភាពនៃកិច្ចសហប្រតិបត្តិការជាមួយអង្គការនានាដែលបំពេញការងារផ្សេងៗគ្នា។

ក្រោយពីបញ្ចប់វគ្គពេញអង្គនៃសិក្ខាសាលា ក្រុមពិភាក្សា និងវាគ្មិនសំខាន់ៗ របាយការណ៍នេះ សង្ខេបលម្អិតអំពីសំណូមពរ និងសំណើ ដែលបានទទួលក្នុងរយៈពេលមួយឆ្នាំចុងក្រោយនៃការពិគ្រោះយោបល់។ ដំបូង យើងពិភាក្សាសំណើនីមួយៗក្នុងចំណោមសំណើចំនួន ២០ ដែលបានដាក់ជូន ក្រោយសហចៅក្រមរបាយការណ៍អំពាវនាវកាលពីខែតុលា ឆ្នាំ២០២១ ហើយយើងរួមបញ្ចូលសំណូមពរ និងសំណើទាំងនេះនៅក្នុងរបាយការណ៍នេះ។ រាល់សំណូមពរ និងសំណើទាំងអស់មុនកាលបរិច្ឆេទសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ ត្រូវបានដាក់បញ្ចូលទាំងស្រុងនៅក្នុងឧបសម្ព័ន្ធទី VI។ យើងសង្ខេបមតិ និងលទ្ធផលនៃក្រុមការងារប្រធានបទទាំងប្រាំបី ដែលបានពិភាក្សាយ៉ាង ផុសផុលក្នុងសិក្ខាសាលារយៈពេលបីថ្ងៃ ហើយយើងពន្យល់ និងបូកសរុបសំណើចុងក្រោយដែលក្រុមទាំងប្រាំបីបានលើកឡើងនៅក្នុងកម្មវិធីពេញអង្គបិទសិក្ខាសាលានៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២។ បន្ទាប់មក យើងពិភាក្សាសំណូមពរ និងសំណើទាំងអស់ដែលយើងបានទទួលក្រោយសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ រួមទាំងសំណើ និងសំណូមពរចំនួនប្រាំមួយពីភាគីពាក់ព័ន្ធសំខាន់ៗដូចជា៖ មជ្ឈមណ្ឌលបុប្ផាណា មជ្ឈមណ្ឌលឯកសារកម្ពុជា (និងលោក Michael Karnavas) អង្គការក្តីករុណា សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង អង្គការយុវសន្តិភាព កម្មវិធីអភិវឌ្ឍន៍ជនជាន។ ជាចុងក្រោយ របាយការណ៍នេះក៏សង្ខេបសំណូមពរ និងសំណើដែលកើតចេញពីការបន្តពិភាក្សាជាមួយបុគ្គល និងអង្គការនានាដែលមិនមានលទ្ធភាពចូលរួមពេញលេញក្នុងសិក្ខាសាលាកាលពីខែឧសភា ឆ្នាំ២០២២ ផង ដែរ៖ ទីមួយ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមចំនួន ៦០នាក់ បានចូលរួមនៅក្នុងវេទិកា VSS-CPLCL នៅថ្ងៃទី១៣ ឧសភា ឆ្នាំ២០២២ បានដាក់សំណើចំនួន ០៤។ ទីពីរ ក្រុមអ្នកសង្កេតការណ៍ អ្នកស្រាវជ្រាវ និងអ្នកតស៊ូមតិនៅក្រៅប្រទេស ដែលបានជួបពិភាក្សាដោយឡែក ហើយបានដាក់សំណើសរុបចំនួន ០៣

ដោយឡែកពីគ្នា និងក្រុមសហគមន៍កម្ពុជា ដែលមិនចូលរួមសកម្មនៅក្នុងសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ បានដាក់សំណើបន្ថែមចំនួនពីរ រួមទាំងសំណើលម្អិតសម្រាប់កម្មវិធីអភិវឌ្ឍការសិក្សាវប្បធម៌កម្ពុជា និងការកសាងអត្តសញ្ញាណវិជ្ជមានបន្ថែមសម្រាប់ក្មេងជំនាន់ក្រោយ ដាក់ជូនដោយវិទ្យាស្ថានស្រាវជ្រាវសង្គមអនុវត្តនៅកម្ពុជា ដែលមានមូលដ្ឋាននៅទីក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា។ សំណើទាំងនេះក៏ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ទាំងស្រុងនៅក្នុងឧបសម្ព័ន្ធទី VII។ សរុបមក យើងបានសង្ខេបសំណើ និងសំណូមពរចំនួនប្រមាណ ៥០ ពីអង្គការ បុគ្គល ឬ ក្រុមបុគ្គល នៅមុន ក្នុងអំឡុងពេល និងក្រោយសិក្ខាសាលាខែឧសភា ឆ្នាំ២០២២។

យើងមើលឃើញច្បាស់ថា សំណើទាំងឡាយបានបង្ហាញអំពីឱកាសសហការ ហើយសំណើភាគច្រើនបានកំណត់អត្តសញ្ញាណអង្គការដៃគូសហការរួចហើយស្រាប់ ឈរលើមូលដ្ឋាននៃការសន្ទនានៅមុន ក្នុងអំឡុងពេល និងក្រោយសិក្ខាសាលា។ ជាពិសេស សំណើមួយចំនួនលើកឡើងប្រធានបទស្រដៀងគ្នា ពោលគឺការរក្សាទីតាំងនៅតាមមូលដ្ឋានជាកន្លែងចងចាំ និងការរៀនសូត្រ ហើយនឹងការបញ្ចូលការសន្ទនាអន្តរជំនាន់ជាមួយយុវជនជំនាន់ក្រោយនៅក្នុងកម្មវិធីទាំងនេះ។ សំណើភាគច្រើនក៏លើកឡើងអំពីភាពចាំបាច់ត្រូវការរាជរដ្ឋាភិបាលសហការលើគម្រោងទាំងនេះ ដើម្បីមាននិរន្តរភាពយូរអង្វែង និងមានភាពជាម្ចាស់នៅក្នុងប្រទេសកម្ពុជា។ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ ដូចៗគ្នាឱ្យបន្តការគាំទ្រដល់អ្នករស់រានមានជីវិត និងគំនិតផ្តួចផ្តើមផ្តោតសំខាន់លើអ្នករស់រានមានជីវិត ដោយមិនត្រូវបញ្ឈប់ត្រឹមសវនាការនៅ អ.វ.ត.ក នោះឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណី បានគូសបញ្ជាក់ដដែលៗអំពីការរងទុក្ខឈឺចាប់ និងរបួសផ្លូវចិត្តជាសាកលដោយសាររបប DK ហើយពួកគេបង្ហាញអំពីបំណងប្រាថ្នាមិនចង់ឱ្យការកើតមានសាជាថ្មី និងសង្ឃឹមថាអ្នកជំនាន់ក្រោយនឹងមិនអនុញ្ញាតឱ្យមានអំពើឃោរឃៅបែបនេះកើតឡើងម្តងទៀត។ ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនផ្តោតសំខាន់លើអ្នកជំនាន់ក្រោយ ដោយស្នើសុំឱ្យចែករំលែករឿងរ៉ាវរបស់ពួកគេជាមួយយុវជនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីលាតត្រដាងការពិត និងពង្រឹងការផ្សះផ្សា។ ក្រុម និងសំណើភាគច្រើនបានអំពាវនាវឱ្យ អ.វ.ត.ក លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មាន និងយុទ្ធសាស្ត្រទំនាក់ទំនងសាធារណជនឱ្យបានលឿន ដោយគូសបញ្ជាក់ថាក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះមានសភាពស្ងៀមស្ងាត់ជាហេតុនាំឱ្យជនរងគ្រោះ និងអ្នករស់រានមានជីវិត មានការខកចិត្ត និងមិនសប្បាយចិត្ត។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានអំពាវនាវឱ្យមានការពិគ្រោះយោបល់ជាទៀងទាត់ដើម្បីបន្តហួសពីក្របខ័ណ្ឌសិក្ខាសាលា ហើយនឹងកិច្ចប្រជុំប្រចាំត្រីមាសក្នុងកម្រិតអ្នកចូលរួមតិច ដើម្បីជជែកអំពីបញ្ហាបច្ចេកទេស ឬប្រធានបទជាក់លាក់។

ក្រៅពីបុគ្គលទាំងឡាយដែលរងទុក្ខវេទនាដោយផ្ទាល់ក្រោមការគ្រប់គ្រងរបស់របបខ្មែរក្រហម មិនថាជាមនុស្សពេញវ័យ ឬ កុមារ សំណើដាក់ជូនសហចៅក្រមរបាយការណ៍ដែលបានចែករំលែក និងបង្កើតឡើងនៅក្នុងពេលសិក្ខាសាលាស្តីពីជនរងគ្រោះ ហើយដាក់ជូននាពេលក្រោយមក សុទ្ធតែបានបង្ហាញច្បាស់ថា ទិដ្ឋភាពនៃជនរងគ្រោះអន្តរជំនាន់ ត្រូវឆ្លើយតបឱ្យបានពេញលេញ ដើម្បីសម្រេចគោលដៅសមស្របទៅនឹងដំណាក់កាលនៃសកម្មភាពដែលនៅសេសសល់ទាក់ទងនឹងជនរងគ្រោះ។

ទិដ្ឋភាពអន្តរជំនាន់ទាំងនេះរួមមានរបួសផ្លូវចិត្ត ដែលបន្តប៉ះពាល់ដល់គ្រួសារ និងពលរដ្ឋកម្ពុជាក្នុងរង្វង់ប្រមាណ ៧០% ធៀបនឹងប្រជាជនកើតក្រោយរបបខ្មែរក្រហម។ ចំណុច

នេះមានការទទួលស្គាល់ជារួមនៅក្នុង សិក្ខាសាលាថាមានសារៈសំខាន់បំផុត ហើយក៏បានគូសបញ្ជាក់ថាជាការងារអាទិភាពសម្រាប់ដំណាក់កាលដែលនៅសេសសល់។ ដូចបានបញ្ជាក់នៅក្នុងសុន្ទរកថាគន្លឹះ ក្រុមទាំងអស់ត្រូវទទួលបានអត្ថប្រយោជន៍ពីកម្មវិធីបែបនេះ ហើយការស្វែងរកការពិត ការផ្សះផ្សា និងសកម្មភាពដែលពាក់ព័ន្ធត្រូវ "ធ្វើមូលដ្ឋានីយកម្ម" ដើម្បីឱ្យមានប្រសិទ្ធ ភាព។ សំណើ និងសំណូមពរ ក៏ដូចជារបាយការណ៍របស់សហចៅក្រមរបាយការណ៍កាលពីខែធ្នូ ឆ្នាំ២០២១ ក៏បានអំពាវនាវជារួមឱ្យមានប្រើប្រាស់វិធីសាស្ត្រ "ជៀសវាងការបង្កការឈឺចាប់" និងដើម្បីធានាថាកម្មវិធីនៅក្នុងដំណាក់កាលដែលនៅសេសសល់ មិននាំឱ្យមានការប៉ះទង្គិចផ្លូវចិត្តជនរងគ្រោះ និងអ្នករស់រានមានជីវិត ជាថ្មីម្ដងទៀត។ វាគ្មិនសុធារីបានលើកឧទាហរណ៍អំពីការឈឺចាប់អាចកើតមានឡើងវិញនៅពេលដែលជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងអាពាហ៍ពិពាហ៍ដោយបង្ខំ បានលើកទឹកចិត្តឱ្យរៀបរាប់អំពីអ្វីដែលពួកគេបានរងទុក្ខឈឺចាប់ ដើម្បីជាវិធី "ព្យាបាលរបួសផ្លូវចិត្ត" ប៉ុន្តែលទ្ធផលទទួលបានគឺការមាក់ងាយទៅវិញ។ ដូចលោកស្រីបានលើកឡើង អ្នកទាំងនេះត្រូវទទួលបាន "ឱកាសប្រកបដោយសុវត្ថិភាពដើម្បីថ្លែង" ហើយឱកាសនេះអាចកើតឡើងទៅបានបានលុះត្រាតែអ្នកចូលរួមដដែក ដែលមានជំនាញ និងបទពិសោធន៍ចាំបាច់ បានបំពេញបុរេលក្ខខណ្ឌ និងមានការត្រៀមលក្ខណៈជាស្រេច ទើបអាចធានាសុវត្ថិភាពបែបនេះ។

អ្នកចូលរួម និងសំណើជាច្រើនក៏បានសង្កត់ធ្ងន់លើតម្រូវការរៀបចំកម្មវិធីទាក់ទងនឹងជនរងគ្រោះនៅតាមសហគមន៍មូលដ្ឋានដោយផ្ទាល់។ ចំណុចនេះប្រហែលភាគច្រើនលើកឡើងជាញឹកញាប់បំផុតដោយអំពាវនាវក្នុងទម្រង់ជាការសាងសង់ស្តូប ដែលយើងមិនគួរយល់ថាត្រឹមជាការចង់បាន "អគារស្តូប" នោះទេ ប៉ុន្តែជាទីតាំងកណ្តាល អាចថាជាមជ្ឈមណ្ឌលនៅជិតសហគមន៍ អាចឱ្យសហគមន៍មានការពិភាក្សា ការស្វែងរកការពិត និងការចងចាំ "តទល់មុខគ្នា" ជាជាងការរៀបចំនៅទីតាំងដែលពួកគេមិនសូវស៊ាំនៅរាជធានីភ្នំពេញ។ យើងត្រូវបញ្ជាក់ឱ្យច្បាស់ថា រាល់ក្រុមការងារនៅក្នុងសិក្ខាសាលា រាល់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេក្នុងនាមជាអ្នកតំណាង ហើយរាល់សំណើ ចាប់តាំងពីវេទិកា VSS កាលពីថ្ងៃទី១៣ ឧសភា ឆ្នាំ២០២២ បានអំពាវនាវឱ្យមានការសាងសង់ស្តូប និងទីតាំងរំលឹកការចងចាំនៅតាមមូលដ្ឋានទូទាំងប្រទេស។ ចំណុចនេះស្ទើរតែមានការឯកភាពជាឯកច្ឆន្ទ ហើយសំខាន់នោះគឺគួរទទួលយក និងឆ្លើយតបឱ្យបាន។

ដូចដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងយ៉ាងស្រួចស្រាវអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុង សិក្ខាសាលា ភាពជាម្ចាស់ជានៅតាមទីតាំងមូលដ្ឋានពិតជាមានសារៈសំខាន់ណាស់ ប្រសិនបើយើងចង់ឱ្យកម្មវិធីទាំងនេះទទួលបានជោគជ័យ។ ភាពជាម្ចាស់ ដូចបានគូសបញ្ជាក់ច្បាស់ គឺលេចចេញពីការសម្តែងមតិរបស់ពួកគេ និងរួមទាំងការដាក់បញ្ចូលពួកគេជាដៃគូនៅក្នុងដំណើរការនេះ។ របៀបដំណើរការបែបនេះ ក៏ជាកត្តាសំខាន់មួយដើម្បីសម្រេចបានចីរភាពផងដែរ។ ការធ្វើមូលដ្ឋានីយកម្មមិនគួរធ្វើតាមគំរូ "មួយត្រូវគ្រប់ស្ថានភាព" នោះទេ ប៉ុន្តែត្រូវធ្វើយ៉ាងណាឆ្លើយតបទៅតាមតម្រូវការ និងលទ្ធភាពនៃបរិការណ៍នីមួយៗ។

ធាតុផ្សំមួយទៀតនៃចីរភាព គឺការរួមបញ្ចូលការបង្កើតកម្មវិធី និងការកសាងក្របខ័ណ្ឌកិច្ចសហការ។ ការធ្វើសមាហរណកម្មបែបនេះអាចតាមពីររូបភាព៖ ទីមួយ ចាំបាច់ត្រូវរួមបញ្ចូលកម្មវិធីស្រដៀងគ្នា ឬ ពាក់ព័ន្ធក្នុងចំណោម CSOs និងស្ថាប័នដែលកំពុងធ្វើការលើបញ្ហា និងប្រធានបទ ឬ កម្មវិធីពាក់ព័ន្ធរួចហើយ ដើម្បីគាំទ្រដល់កិច្ចសហការ និងជៀសវាងការធ្វើការ

ជាន់គ្នា ឬ ដដែលលើគម្រោងទាំងនេះ។ ទីពីរគឺជាការធ្វើសមាហរណកម្មជាមួយ ស្ថាប័នរដ្ឋ ឬ កម្មវិធីពាក់ព័ន្ធ ដែលអាចផ្តោតយកចិត្តទុកដាក់ប្រកបដោយចីរភាពលើបញ្ហាទាំងនេះ ក្នុងរយៈពេលវែង។ គួរកត់សំគាល់ផងដែរថា ក្នុងករណីខ្លះ សមាហរណកម្មអាចរួមបញ្ចូលការកសាងទំនាក់ទំនងកិច្ចសហការជាមួយ ស្ថាប័នអន្តរជាតិ ក្រៅតែជាមួយស្ថាប័ន RGC ប៉ុន្តែអ្វីៗអាស្រ័យលើស្ថានភាព ឬ ប្រធានបទពាក់ព័ន្ធ។

ដោយសារធនធានថវិកាមានកំណត់សម្រាប់សកម្មភាពដែលនៅសេសសល់ និងមហិច្ឆិតានៃវិសាលភាពការងារ ដែលបានបង្ហាញនៅក្នុងបទបង្ហាញនៃសិក្ខាសាលា និងសំណើមានលក្ខណៈធំធេង ការប្រកួតប្រជែងក្នុងចំណោមភាគីពាក់ព័ន្ធ នឹងជះឥទ្ធិពលអវិជ្ជមានលើឱកាសរួម ហើយទំនងជាអាចនាំឱ្យកម្មវិធីទាំងនេះ ធ្វើដាច់ដោយឡែកជាដុំ ទីបំផុតធ្វើឱ្យខូចដល់ចីរភាពក្នុងរយៈពេលយូរ។ ដូចបានបញ្ជាក់ដោយក្រុមទី៧ នៅក្នុងវគ្គពេញអង្គ ចំណុចដែលជាប្រយោជន៍សម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ក៏ដូចជាប្រជាជនដែលនឹងទទួលសេវា គឺធ្វើយ៉ាងណាយកចំណេះដឹង បទពិសោធន៍ និងធនធាននៅក្នុងគំនិតផ្តួចផ្តើមធ្វើជាចំណុចខ្លាំងសម្រាប់ភាគីចូលរួមទាំងអស់។ ពួកគេបានអំពាវនាវឱ្យមានការបង្កើតវេទិកាកិច្ចសហការ ដោយត្រូវរួមបញ្ចូលសង្គមស៊ីវិល និងស្ថាប័នរដ្ឋ ដើម្បីលើកកម្ពស់ចីរភាពរយៈពេលវែង។

បញ្ហាទូទៅមួយទៀតដែលបានលើកឡើងគឺរបៀបដោះស្រាយស្ថានភាពដែលកើតឡើងនៅតាមសហគមន៍ជាច្រើន ដែលជនរងគ្រោះ និងជនល្មើសអាចរស់នៅជាមួយគ្នា ប៉ុន្តែ ដូចក្រុមទី៨ បានលើកឡើង មិនអាចឱ្យមានភាពសុខដុមជាមួយគ្នា។ ចំណុចនេះជាការពិតណាស់ទាក់ទងនឹងប្រធានបទនៃការធ្វើមូលដ្ឋានីយកម្មដូចបានរៀបរាប់ខាងលើ ប៉ុន្តែក៏លើកឡើងបញ្ហាកាន់តែស៊ីជម្រៅអំពីវិធីណាខ្លះដែលអាចសម្រេចបានល្អបំផុត។ ប្រធានអង្គភាព VSS គឺលោក ហង្ស វណ្ណៈ ស្នើថា ការអប់រំអាចផ្តោតលើការបង្កើតអត្តសញ្ញាណខ្មែរក្រោយរបបខ្មែរក្រហម ដែលករណីនេះអាចជួយលើកកម្ពស់ភាពសុខដុមរមនា និងទប់ស្កាត់ការកើតឡើងនៃអំពើហិង្សា។ ចំណុចនេះស្របនឹងការសិក្សា វប្បធម៌ និងអត្តសញ្ញាណវិជ្ជមានដែល ASRIC បានអំពាវនាវនៅក្នុងសំណើដែលសហគមន៍ក្រៅប្រទេសបានធ្វើឡើងនាពេលកន្លងមក។

តម្រូវការបានបង្ហាញទូទៅបំផុតដោយក្រុមនៅក្នុងសិក្ខាសាលា ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើជាច្រើន ដែលអាចជាភាពចាំបាច់បំផុតនោះគឺការថែទាំជនរងគ្រោះចាស់ៗដែលកាន់តែត្រូវការខ្លាំងឡើងជារៀងរាល់ឆ្នាំ។ តម្រូវការនេះបានបញ្ជាក់យ៉ាងខ្លាំងដោយក្រុមដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសេចក្តីថ្លែងបញ្ចប់ក្នុងសិក្ខាសាលា ដោយពួកគេបានអំពាវនាវឱ្យមានការបង្កើតសមាគមសម្រាប់ជនរងគ្រោះចាស់ៗក្រោមកិច្ចសហការគ្នាជាមួយដៃគូ ដើម្បីដាក់ចេញកម្មវិធី ឈានទៅបង្កើតមជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍មួយៗ ដោយបញ្ចូលវត្តអារាមនៅតាមមូលដ្ឋាន ឱ្យដើរតួនាទីដ៏សំខាន់នេះ និងរួមបញ្ចូលជនរងគ្រោះ ដែលមិនត្រូវបានទទួលស្គាល់ដោយផ្ទាល់ ឬ ចូលរួមដោយផ្ទាល់នៅ អ.វ.ត.ក ហើយនឹងផ្តល់ការថែទាំសុខភាព ព្រមទាំងបង្កលទ្ធភាពផ្ទេរចំណេះដឹង និងអប់រំយុវជនជំនាន់ក្រោយដែលមិនជឿរឿងរ៉ាវអំពីខ្មែរក្រហមដែលពួកគេបានឮនាពេលកន្លងមក។

ជាចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនាមក្រុម និងបុគ្គល មានឥទ្ធិពលច្រើន។ ពួកគេទទួលបានគោរព និងកោតសរសើរយ៉ាងទូលំទូលាយ ហើយគោលជំហរដ៏រឹងមាំក្នុងការសម្តែងមតិ និងចែករំលែកការពិតអំពីទុក្ខលំបាករបស់ពួកគេ បានផ្តល់ឱ្យពួកគេនូវអំណាច

ផ្លូវចិត្ត និងការបញ្ចុះបញ្ចូលយ៉ាងធំធេងសម្រាប់ពួកគេ។ ករណីនេះគួរតែត្រូវចាត់ទុកជាធនធានដ៏សំខាន់ដើម្បីបន្ត និងទ្រទ្រង់សហគមន៍ និងការងារ ជនរងគ្រោះរបស់សាលាក្តី។ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមទី២ ស្នើថា ដើមបណ្តឹងរដ្ឋប្បវេណីគួរអាចស្នើសុំការគាំទ្រឱ្យមានកម្មវិធីជាក់លាក់ពីអភិបាលខេត្តនៅថ្នាក់ក្រោមជាតិ។ អង្គការ ឬ សមាគមតស៊ូមតិជនរងគ្រោះជាក់លាក់ អាចតស៊ូមតិឱ្យបានខ្លាំងក្លា ទាមទារតម្រូវការរបស់ជនរងគ្រោះក្នុងទ្រង់ទ្រាយធំ និងរយៈពេលវែង។

លទ្ធភាពនេះទទួលបានការគាំទ្រនៅក្នុងសិក្ខាសាលា និងនៅក្នុងការពិគ្រោះយោបល់នាពេលក្រោយមក ដោយសំណើលម្អិតមួយចំនួនស្នើសុំឱ្យ VSS របស់ អ.វ.ត.ក ប្រែក្លាយទៅជាស្ថាប័នតស៊ូមតិអចិន្ត្រៃយ៍សម្រាប់ជន រងគ្រោះ។ ស្ថាប័ននេះអាចត្រូវបានចាត់ទុកជាស្ថាប័នតស៊ូមតិសាធារណៈ ឬ ការិយាល័យប្រជាពលរដ្ឋ ធ្វើការតំណាងជនរងគ្រោះនៅគ្រប់វិស័យសាធារណៈ និងឯកជន។ ស្ថាប័ននេះនឹងត្រូវមានឯករាជ្យភាពផ្នែកនយោបាយ ក៏ប៉ុន្តែត្រូវទទួលស្គាល់ និងអាចទទួលថវិកាពី RGC។ មូលនិធិបន្ថែម អាចទទួលបានតាមរយៈការអង្គាសថវិកាពីសប្បុរសជនក្នុងស្រុក និងអន្តរជាតិ ក៏ដូចជាការផ្តល់មូលនិធិពីម្ចាស់ជំនួយអន្តរជាតិនៅក្នុងដំណាក់កាលដំបូងរបស់ខ្លួន។ ដើម្បីឱ្យការផ្លាស់ប្តូរនេះអាចធ្វើទៅបាន អង្គភាព VSS ត្រូវការធនធានកាន់តែច្រើនជាងនេះនៅពេលនេះ រួមទាំងបុគ្គលិកមានធនធានពេញលេញ និងបេសកកម្ម និងវិសាលភាពការងារ ដែលត្រូវធ្វើបច្ចុប្បន្នភាព។ រយៈពេលដែលនៅសេសសល់ គួរតែត្រូវបានប្រើប្រាស់ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ស្ថាប័នតស៊ូមតិជនរងគ្រោះអចិន្ត្រៃយ៍នេះ ដែលនឹងបន្តដំណើរការ ឯករាជ្យពី អ.វ.ត.ក បន្ទាប់ពីដំណាក់កាលដែលនៅសេសសល់បានបញ្ចប់។

ក្រោយពីទស្សនៈទាំងនេះបានប្រមូលរួចហើយ និងក្រោយទទួលបានឱកាសសម្រាប់បន្តការពិគ្រោះយោបល់ដើម្បីអភិវឌ្ឍកម្មវិធីពាក់ព័ន្ធ អ្វីដែលមិនទាន់ច្បាស់នៅឡើយគឺផែនការថវិកា និងការចាត់ចែង សកម្មភាព និងកម្មវិធីមានតម្លៃនានាដែលបានស្នើឡើងនៅក្នុងទំព័រទាំងឡាយ ដែលសង្ខេបអំពីសិក្ខាសាលា និងសំណើ នៅមុន និងក្រោយព្រឹត្តិការណ៍នោះ។ សំឡេងរបស់ជនរងគ្រោះ និងភាគីពាក់ព័ន្ធគួររួមបញ្ចូលនៅក្នុងការពិភាក្សាបែបនេះ។ អ.វ.ត.ក គួរមានភាពច្បាស់លាស់ និងមានតម្លាភាពអំពីផែនការរបស់ខ្លួន។ ដូចបានបញ្ជាក់នៅក្នុងរបាយការណ៍នេះ យើងមិនប្រើប្រាស់វិធីសាស្ត្រ "កម្មវិធីមួយត្រូវគ្រប់ស្ថានភាព" ចំពោះការផ្តល់មូលនិធិ និងគ្រប់គ្រងកម្មវិធី ឬគម្រោងដែលបានស្នើឡើងនោះទេ ហើយគំរូដ៏ល្អបំផុតនឹងត្រូវកំណត់សម្រាប់កម្មវិធីនីមួយៗដោយឡែកៗពីគ្នា។ នៅក្នុងការអនុវត្តការងាររៀបចំ និងស្ថាប័ន ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់ជំនួយពីខាងក្រៅ RGC និង អ.វ.ត.ក ខ្លួនឯងគួរពិចារណាដោយបើកចំហនូវមធ្យោបាយដ៏ល្អបំផុត ដើម្បីបម្រើសេចក្តីត្រូវការរបស់ជនរងគ្រោះ។ តម្លាភាព និងគណនេយ្យភាពគួរបង្កើតឡើងនៅក្នុងដំណើរការនេះ។

មុនពេលការប្រកាសសាលដីកាស្ថាពរក្នុងសំណុំរឿង ០០២/០២ និងការបញ្ចប់ដំណាក់កាលតុលាការនៅ អ.វ.ត.ក សំខាន់បំផុតនោះគឺ អ.វ.ត.ក គួរចាប់ផ្តើមកំណត់សកម្មភាព និងរៀបចំកម្មវិធីតាមលំដាប់លំដោយដែលបានពិភាក្សានៅក្នុងរបាយការណ៍នេះ និងនៅក្នុងឯកសារផ្សេងទៀត។ អ.វ.ត.ក និងម្ចាស់ជំនួយត្រូវតែពិនិត្យមើលថាតើកម្មវិធីណាខ្លះដែលត្រៀមរួចជាស្រេចអាចអនុវត្តភ្លាមៗ ហើយកម្មវិធីណាខ្លះទៀតដែលត្រូវការពេលស្រាវជ្រាវបន្ត ឬ រៀបចំផែនការ។ កម្មវិធីជាច្រើនដែលបានបង្ហាញនៅក្នុងសិក្ខាសាលា និងនៅក្នុងសំណើ

បន្ថែមរួមមានដំណាក់កាលសាកល្បងដែលអាចចាប់ផ្តើមភ្លាមៗនៅពេលដំណាក់កាលនៅសេសសល់ចាប់ផ្តើម ពោលគឺ នៅដើមឆ្នាំ២០២៣ ហើយបន្ទាប់មក កម្មវិធីទាំងនេះបំណងពង្រីកវិសាលភាពទៅជាកម្មវិធីសក្តានុពលទូទាំងប្រទេសសម្រាប់ឆ្នាំទីពីរ និងទីបី នៃដំណាក់កាលដែលនៅសេសសល់។ យើងលើកទឹកចិត្តឱ្យម្ចាស់ជំនួយជាតិ ឬ អន្តរជាតិសក្តានុពល ដែលមិនអាចពិនិត្យមើលរបាយការណ៍នេះឱ្យបានពេញលេញនៅឡើយ សូមពិនិត្យឱ្យបានដិតដល់នូវសំណើលម្អិតនៅក្នុងឧបសម្ព័ន្ធទី VI និងទី VII។ តម្រូវការបន្ទាន់ជាក់លាក់ចំនួនពីរ ដែលបានលេចឡើងក្នុងពេលសិក្ខាសាលា និងនៅក្នុងសំណើដែលបានដាក់មុន និងក្រោយព្រឹត្តិការណ៍ ហើយដែលអាចប៉ះពាល់ដល់កម្មវិធីផ្សេងទៀត ក៏ត្រូវគូសបញ្ជាក់ និងត្រូវឆ្លើយតបភ្លាមៗផងដែរ។

តម្រូវការទីមួយ អ.វ.ត.ក តាមរយៈ VSS និង CPLCLs ត្រូវតែធ្វើយុទ្ធនាការគ្រប់ជ្រុងជ្រោយមួយ ដើម្បីតាមដានរាល់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដែលត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង ០០១ និង០០២ និងអ្នកដែលបាន អនុវត្តក្នុងសំណុំរឿង ០០៣, ០០៤, ០០៤/០១, និង ០០៤/០២។ ស្ថាប័ន និងអង្គភាពទាំងនេះ ត្រូវដឹងអំពីលទ្ធផលសម្រាប់ដំណើរការនីតិវិធីទាំងនោះ និងគម្រោងសំណងដែលបានធ្វើឡើងរហូតមកដល់ពេលនេះ ហើយត្រូវមាន ឱកាសធ្វើការសម្រេចចិត្តអំពីព័ត៌មានឯកជនរបស់ខ្លួន ដែលនឹងត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញជាចុងក្រោយលើឯកសារសំណុំរឿង។ ការងារទាំងនេះមិនមែនជាកិច្ចការតូចតាចនោះទេ ហើយគួរចាប់ផ្តើមភ្លាមៗ ជាជាងរង់ចាំឱ្យដំណាក់កាលដែលនៅសេសសល់ចាប់ផ្តើមជាមុនសិន។ ការងារដូចគ្នាគឺការគិតគូរការងារទាក់ទងនឹងម្ចាស់បណ្តឹង។ ការចងក្រងព័ត៌មានជនរងគ្រោះទាំងអស់គួរចាប់ផ្តើមឱ្យហើយ ដោយសារលេខទូរស័ព្ទ ឬអាសយដ្ឋានរបស់អ្នកនៅរស់រានមានជីវិតជាច្រើនអាចបានផ្លាស់ប្តូររួចទៅហើយ។ ប្រសិនបើ VSS និង CPLCLs ត្រូវការធនធានបន្ថែមទៀតដើម្បី អនុវត្តកិច្ចខិតខំប្រឹងប្រែងនេះ ធនធានទាំងនោះគួរតែត្រូវបានផ្តល់ជូន។ កិច្ចខិតខំប្រឹងប្រែងនេះចាំបាច់ធ្វើឡើងដើម្បីគោរពសិទ្ធិរបស់ជនរងគ្រោះដែលចូលរួមក្នុងដំណើរការនីតិវិធី ហើយក៏ដើម្បីបង្ហាញដល់ពួកគេថា ការចូលរួម និងបទពិសោធន៍របស់ពួកគេមិនត្រូវបានបំភ្លេចចោលឡើយ។ នេះគឺជាជំហានចាំបាច់មួយមុនពេល អ.វ.ត.ក ពង្រីកបេសកកម្មរបស់ខ្លួនឆ្ពោះទៅរកសកម្មភាព ឬ កិច្ចខិតខំប្រឹងប្រែងផ្តោតសំខាន់លើជនរងគ្រោះសំដៅស្វែងរកការផ្សះផ្សា និងការព្យាបាលរបួសផ្លូវចិត្ត។ នេះក៏ជាដំណើរការមួយដែលមានតែ អ.វ.ត.ក - មិនមែនស្ថាប័នខាងក្រៅ ពោលគឺ CSOs ពាក់ព័ន្ធ - នោះទេដែលអាចគ្រប់គ្រង និងអនុវត្តបាន។

ទីពីរ ដំណាក់កាលដែលនៅសេសសល់ដែលមានប្រសិទ្ធភាព និងមានន័យជាងនេះ គឺត្រូវអនុវត្តតាមទិន្នន័យដើមគ្រាអំពីការយល់ឃើញរបស់ អ.វ.ត.ក និងដំណើរការយុត្តិធម៌អន្តរកាលនៅកម្ពុជា។ ទិន្នន័យនេះគួរតែកំណត់គោលដៅមិនត្រឹមតែចំពោះជនរងគ្រោះ អ្នករស់រានមានជីវិត ឬដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ចំពោះយុវជនផងដែរ។ ការស្ទាបស្ទង់មតិពីក្នុងចំណោមប្រជាជនមិនបានធ្វើឡើងក្នុងរយៈពេលជាច្រើនឆ្នាំមកហើយ ហើយទាំង អ.វ.ត.ក និងភាគីសង្គមស៊ីវិលពាក់ព័ន្ធអាចទទួលបានអត្ថប្រយោជន៍ពីទិន្នន័យជាច្រើនដែលអាចទាញចេញពីការស្ទាបស្ទង់មតិនេះ។ កិច្ចខិតខំប្រឹងប្រែងបែបនេះក៏អាចត្រូវបានប្រើប្រាស់ដើម្បីសាកសួរសាធារណជនអំពីកម្មវិធី ឬគោលការណ៍ដែលពួកគេចង់ឃើញក្នុងដំណាក់កាលដែលនៅសេសសល់។

ក្នុងពេលជាមួយគ្នានេះ ដំណើរការពិគ្រោះយោបល់បើកចំហដែលមានការចូលរួមពីជនរងគ្រោះ និងតំណាងរបស់ពួកគេលើសំណើ និងលើសំណួរអំពីការផ្តល់មូលនិធិ និងការគ្រប់គ្រង នឹងពង្រឹងកម្មវិធី និងទទួលបាន "ការយល់ព្រម" ផ្នែកនយោបាយ និងសង្គម។ ការសម្រេចចិត្តផ្សេងទៀតត្រូវធ្វើឡើងបន្ថែមទៀត ពោលគឺ ហេតុផលបង្កើតឱ្យមានសិក្ខាសាលាក្រុមការងារបច្ចេកទេស ឬ ការពិគ្រោះយោបល់បន្ថែម។ នៅទីបំផុត វាអាស្រ័យលើសង្គមស៊ីវិល ឬតួអង្គរដ្ឋក្នុងការកំណត់ថាតើខ្លួនចង់ធ្វើអ្វី និងរបៀបដែលខ្លួននឹងអនុវត្តការងារទាំងនេះ។ ការជួបប្រជុំរួម ដែល ផ្តួចផ្តើមដោយ អ.វ.ត.ក និងផ្តោតលើទស្សនៈរបស់ជនរងគ្រោះ នឹងជួយជាប្រយោជន៍ដល់អង្គការទាំងអស់នេះបានប្រសើរជាងមុន ជំរុញឱ្យមានកិច្ចសហការជាជាងការប្រកួតប្រជែង និងរៀបចំរចនាសម្ព័ន្ធដំណាក់កាលសេសសល់របស់ អ.វ.ត.ក រយៈពេលបីឆ្នាំប្រកបដោយជោគជ័យ និងផ្លែផ្កា។

អ្វីដែលបានលេចឡើងក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ ពាក់ព័ន្ធបទពិសោធន៍នៃការចូលរួមពីភាគីពាក់ព័ន្ធ លើសកម្មភាពទាក់ទងនឹងជនរងគ្រោះ គឺលទ្ធភាពដ៏វិសេសវិសាលលើការងារកសាងកេរ្តិ៍ដំណែលរបស់ អ.វ.ត.ក។ នៅពេលដែលតុលាការឈានចូលដំណាក់កាលដែលនៅសេសសល់ ដំណាក់កាលនេះគឺជាឱកាសប្រមូលកម្លាំង ការប្តេជ្ញាចិត្ត និងជំនាញដែលបានស្តែងចេញនៅក្នុងដំណើរការដែលកើតចេញពីការអំពាវនាវរបស់សហចៅក្រមរបាយការណ៍ឱ្យដាក់សំណើជូនអង្គសិក្ខាសាលា។ សំណើដែលបានដាក់ជូនសហចៅក្រមរបាយការណ៍ គំនិតផ្តួចផ្តើមដែលបានពិភាក្សានៅក្នុងសិក្ខាសាលា និងសំណើ សំណូមពរដែលបង្កើតឡើងក្នុងអំឡុងពេល និងនាពេលក្រោយមក ជារួមបានបង្ហាញឱ្យឃើញលទ្ធផលនៃការចូលរួមរបស់សង្គមស៊ីវិលជាមួយតុលាការ និងស្ថាប័នរដ្ឋ ក្នុងរយៈពេល ១៦ឆ្នាំកន្លងមកនេះ។ នៅពេលឆ្លុះបញ្ចាំងពីអ្វីដែលយើងបានសិក្សា និងសង្កេតឃើញ នាពេលកន្លងមក ធ្វើឱ្យយើងយល់ច្បាស់អំពីអ្វីដែលអាចសម្រេចបាន ប្រសិនបើបទពិសោធន៍ដ៏សម្បូរបែបនេះអាចត្រូវបានដកពិសោធន៍ប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅតាមតម្រូវការ គោលដៅ និងប្រធានបទសំខាន់ៗដែលបានកំណត់នៅក្នុងសិក្ខាសាលា។ បញ្ហាប្រឈមគឺធ្វើដូចម្តេចដើម្បីឱ្យសក្តានុពលទាំងនេះលេចចេញជាផ្លែផ្កា។ សិក្ខាសាលានេះគ្រាន់តែជាដំណាក់ការចាប់ផ្តើមមួយតែប៉ុណ្ណោះ ប៉ុន្តែដោយសារតែការចូលរួមយ៉ាងផុសផុល និងស្មារតីនៃកិច្ចសហការស្តែងចេញតាមរយៈអ្នកចូលរួម វាបានផ្តល់នូវពន្លឺនៃក្តីសង្ឃឹមឆ្ពោះទៅមុខ ដែលអាចបញ្ចូលដំណាក់កាលដែលនៅសេសសល់ជាមួយនឹងកម្មវិធីនានា ជាប្រយោជន៍ដល់សង្គមកម្ពុជាសម្រាប់បន្តដំណើរទៅមុខ។ ចំណុចនេះជាតំណាងនូវកេរ្តិ៍ដំណែលដ៏យូរអង្វែង និងមានតម្លៃចំពោះការងារទាំងអស់ដែល អ.វ.ត.ក សម្រេចបាននៅក្នុងកម្មវិធីផ្សព្វផ្សាយនៅតាមសហគមន៍ដែលទទួលបានជោគជ័យខ្ពស់ និងមានការចូលរួមជាមួយដើមបណ្តឹងរដ្ឋប្បវេណី។ នេះជាឱកាសមួយដែលមិនគួរមើលរំលង។

ដូចបានបញ្ជាក់នៅក្នុងរបាយការណ៍នេះ សំឡេងរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវដើរតួនាទីស្នូលក្នុងការកំណត់រូបរាង និងអនុវត្តកម្មវិធីទាក់ទងនឹងជនរងគ្រោះដូចបានពិភាក្សាខាងលើ។ ដោយទទួលបាន ឱកាសដើម្បីចូលរួមប្រកបដោយអត្ថន័យនៅក្នុងសិក្ខាសាលា ដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងជាឱឡារិក និងប្រកបដោយថាមពលអំពីតម្រូវការរបស់សហគមន៍របស់ពួកគេ។ ការស្តាប់សម្លេង និងការចូលរួមរបស់ពួកគេមិនត្រឹមតែមានសារៈសំខាន់ប៉ុណ្ណោះទេ វាក៏ជាមធ្យោបាយដ៏ល្អបំផុតដើម្បីធានាថាតម្រូវការកម្មវិធីត្រូវបាន

បង្កើតយ៉ាងត្រឹមត្រូវ និងដោះស្រាយប្រកបដោយប្រសិទ្ធភាព។ នៅចុងបញ្ចប់នៃសិក្ខាសាលាខែឧសភា ឆ្នាំ ២០២២ ដើមបណ្តឹងរដ្ឋប្បវេណី ពេជ្រ ស្រីផល បានធ្វើសុន្ទរកថាបិទក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិត-ជនរងគ្រោះផ្សេង ទៀត។ លោកស្រីបានពន្យល់ថា ប្រសិនបើដំណាក់កាលដែលនៅសេសសល់នៃ អ.វ.ត.ក មានប្រសិទ្ធភាព នោះអ្នករស់រានមានជីវិតនឹងរួមគ្នាដើម្បីលើកថ្មដែលពួកគេបានកាន់នៅក្នុងទ្រូងរបស់ពួកគេក្នុងរយៈពេល ៤០ ឆ្នាំចុងក្រោយនេះ។ អ.វ.ត.ក រាជរដ្ឋាភិបាល និងម្ចាស់ជំនួយអន្តរជាតិឥឡូវនេះមានគំនិត ឧបករណ៍ ធនធាន និងបណ្តាញនៅចំពោះមុខពួកគេ ដើម្បីធានាថាដំណាក់កាលដែលនៅសេសសល់នេះមានប្រសិទ្ធភាពបំផុតក្នុងការលើកកម្ពស់ និងបង្កើតកម្មវិធីដែលបានពិភាក្សានៅក្នុងរបាយការណ៍នេះ និងការដាក់បញ្ចូលឯកសារភ្ជាប់របស់វា។ នេះជាឱកាសមួយដើម្បីដណ្តើមយកក្នុងនាមអ្នករស់រានមានជីវិត-ជនរងគ្រោះ និងមនុស្សជំនាន់ក្រោយ។

យើងសង្ឃឹមថារបាយការណ៍នេះផ្តល់នូវផែនទីបង្ហាញផ្លូវសម្រាប់ អ.វ.ត.ក ក្នុងដំណាក់កាលដែលនៅសេសសល់ និងក្របខ័ណ្ឌជាក់ស្តែងសម្រាប់អ្នកផ្តល់មូលនិធិក្នុងការផ្តល់ការគាំទ្រក្នុងការកសាងសមិទ្ធិផលកន្លងមក ដើម្បីបង្កើតកេរ្តិ៍ដំណែលពិតប្រាកដសម្រាប់ អ.វ.ត.ក នៃតម្លៃយូរអង្វែងសម្រាប់កម្ពុជា។

# I.

# សាវតារ


០៣៦ អាណត្តិការងារដែលនៅសេសសល់សម្រាប់ អ.វ.ត.ក

០៣៨ តួនាទីរបស់ជនរងគ្រោះនៅក្នុងដំណើរការដែលនៅសេសសល់នៅ អ.វ.ត.ក និងគម្រោងសំណង

០៥៤ ដំណើរដើមទង និងគោលបំណងនៃសិក្ខាសាលាស្ដីពីជនរងគ្រោះ



អស់រយៈពេលជាង ១៥ឆ្នាំចាប់តាំងពីការបង្កើតឡើង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានឈានមកដល់ដំណាក់កាលអន្តរកាលដ៏សំខាន់មួយនៅពេលនេះ។ កិច្ចដំណើរការនីតិវិធីចុងក្រោយរបស់សាលាក្ដីនេះ នឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០២២ បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលប្រកាសសាលដីកាស្ថាពរក្នុងសំណុំរឿង ០០២/០២ ប្រឆាំង ខៀវ សំផន ដែលជាមេដឹកនាំជាន់ខ្ពស់ចុងក្រោយរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (DK) ដែលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ទណ្ឌិតចំនួនពីរនាក់ គឺ កាំង ហ្គេកអ៊ាវ ហៅ ឌុច និង នួន ជា បានទទួលមរណភាព ចំណែកជនជាប់ចោទពីរនាក់ទៀត ទទួលមរណភាពមុនពេលសម្រេចពិរុទ្ធភាព ហើយ ០៥នាក់ទៀតពុំត្រូវបានស៊ើបសួរក្រោយសេចក្ដីសន្និដ្ឋានបឋម និងចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ។ ជនរងគ្រោះ និងអ្នករស់រានមានជីវិតពី DK គឺជាចលករជំរុញដំណើរការទាំងនេះក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះ។ មិនថាតាមរយៈការចូលរួមនីតិវិធីរបស់ពួកគេក្នុងការស៊ើបអង្កេត និងការជំនុំជម្រះក្នុងនាមជាដើមបណ្ដឹងបរិហារ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ឬ តាមរយៈការចូលរួមរបស់ពួកគេនៅក្នុងគំនិតផ្ដួចផ្ដើមសង្គមស៊ីវិលក្នុងការកសាងការផ្សះផ្សា និងការស្វែងរកការពិតនៅខាងក្រៅបន្ទប់សវនាការ ជនរងគ្រោះ និងអ្នករស់រានមានជីវិត បានចែករំលែករឿងរ៉ាវរបស់ពួកគេ និងបន្លឺសំឡេងរបស់ពួកគេ។ សព្វថ្ងៃនេះ ខណៈ អ.វ.ត.ក កំពុងពិចារណាបិទបញ្ចប់ដំណើរការជំនុំជម្រះរបស់ខ្លួន ជំពូកថ្មីមួយកំពុងរង់ចាំបើកដំណើរការនៅក្នុងមុខងារដែលនៅសេសសល់របស់ស្ថាប័ននេះ ដែលត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) និងអង្គការសហប្រជាជាតិ (UN)។ ជន រងគ្រោះ និងអ្នករស់រានមានជីវិតនៅទូទាំងប្រទេសកម្ពុជា និងសហគមន៍នៅជុំវិញពិភពលោក នឹងបន្តជាសសរស្ដម្ភគ្រឹះសម្រាប់ដំណាក់កាលបន្ទាប់នេះ។ នៅប៉ុន្មានខែចុងក្រោយខាងមុខ មុនពេល អ.វ.ត.ក ផ្លាស់ប្ដូរទៅដំណាក់កាលដែលនៅសេសសល់ អ.វ.ត.ក បានចាប់ផ្ដើមកិច្ចខិតខំប្រឹងប្រែងជាសាធារណៈថ្មីមួយ ដើម្បីប្រមូលគំនិត និងចែករំលែកព័ត៌មានជាមួយសាធារណជន អ្នកពាក់ព័ន្ធសង្គមស៊ីវិល និងអ្នករស់រានមានជីវិត ជនរងគ្រោះ និងតំណាងរបស់ពួកគេ។ របាយការណ៍នេះសង្ខេបការពិគ្រោះយោបល់ និងការរៀបលក្ខណៈក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះត្រៀមសម្រាប់ដំណាក់កាលដែលនៅសេសសល់ ដែលជិតមកដល់ រួមទាំងសិក្ខាសាលាថ្មីៗស្ដីពីជនរងគ្រោះដែលបានធ្វើឡើងកាលពីខែឧសភា ឆ្នាំ២០២២។ របាយការណ៍នេះមានគោលបំណងផ្ដល់នូវការយល់ដឹង ការវិភាគ និងផែនទីបង្ហាញផ្លូវ រួមជាមួយគម្រោងជាក់លាក់ ដែលបានស្នើបង្កើតឡើងដោយភាគីពាក់ព័ន្ធ និងជនរងគ្រោះសកម្មនៅក្នុងដំណើរការពិគ្រោះយោបល់ជាបន្តបន្ទាប់ ដើម្បីធានាថា អាណត្តិដែលនៅសេសសល់របស់ អ.វ.ត.ក បំពេញតាម ស្តង់ដារខ្ពស់ដែលជនរងគ្រោះ អ្នករស់រានមានជីវិត សមនឹងទទួលបាន។

← លោក ខៀវ សំផន នៅក្នុងថ្ងៃទី៣ នៃសវនាការបណ្ដឹងក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១។

# អាណត្តិការងារដែលនៅសេសសល់ សម្រាប់ អ.វ.ត.ក

កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ មហាសន្និបាតនៃអង្គការសហប្រជាជាតិបានស្នើឱ្យអគ្គលេខាធិការចាប់ផ្តើមដំណើរការពិគ្រោះយោបល់ជាមួយ អ.វ.ត.ក និងរាជរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍសកម្មភាពដំណាក់កាលដែលនៅសេសសល់បន្ទាប់ពីតុលាការបិទបញ្ចប់ដំណើរការ[1]។ អគ្គលេខាធិការបានដាក់របាយការណ៍ជូនមហាសន្និបាត ដោយពិពណ៌នាអំពីផែនការសម្រាប់ដំណាក់កាលដែលនៅសេសសល់ និងរៀបរាប់លម្អិត ក្នុងនោះរួមមានដំណើរការដែលសេចក្តីព្រាងកិច្ចព្រមព្រៀងបន្ថែមត្រូវបានបង្កើតឡើង[2]។ ក្របខ័ណ្ឌដែលបានអភិវឌ្ឍ ក្នុងទម្រង់ជាសេចក្តីព្រាងកិច្ចព្រមព្រៀងបន្ថែមរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់ កម្ពុជា នូវបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានអគ្គលេខាធិការ ដាក់ជូនមហាសន្និបាតអនុម័តកាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១។ សេចក្តីព្រាងកិច្ចព្រមព្រៀងបន្ថែម ត្រូវបានអនុម័ត និងចូលជាធរមាននៅពេលចុះហត្ថលេខារៀងៗខ្លួន ដោយតំណាងអង្គការសហប្រជាជាតិ (UN) និង RGC កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ និងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១។ អត្ថបទនៃកិច្ចព្រមព្រៀងបន្ថែមត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ I នៃរបាយការណ៍នេះ។

មាត្រា ២ នៃឧបសម្ព័ន្ធស្តីពី "មុខងារដែលនៅសេសសល់" ចែងអំពីក្របខ័ណ្ឌនៃសកម្មភាពដែលនៅសេសសល់ទាំងអស់ទាក់ទងនឹងជនរងគ្រោះ។ បទប្បញ្ញត្តិនៃមាត្រា ២ ដូចដែលយើងនឹងឃើញ ទាមទារការបកស្រាយហ្មត់ចត់ ប្រសិនបើចង់ឱ្យសកម្មភាពដែលនៅសេសសល់ទាក់ទងនឹងជនរងគ្រោះ មានអត្ថន័យ និងទទួលបានលទ្ធផលស្របតាមអាណត្តិការងារដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងបន្ថែម។

ដូចបានរៀបរាប់នៅក្នុងរបាយការណ៍របស់អគ្គលេខាធិការ "គេរំពឹងទុកថា អង្គជំនុំជម្រះវិសាមញ្ញនឹងបន្ត អនុវត្តមុខងារដែលនៅសេសសល់សម្រាប់រយៈពេលបីឆ្នាំដំបូង"[3]។ ទាក់ទងនឹងមុខងារនៅសេសសល់ទាក់ទងនឹងជនរងគ្រោះ មាត្រា ២ អំពាវនាវត្រង់ផ្នែកពាក់ព័ន្ធឱ្យធ្វើសកម្មភាព ដែល "ផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី។ [...] ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទាក់ទងនឹងអង្គជំនុំជម្រះ និងតាមដានការអនុវត្តសំណង ដែលផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីតាមលក្ខខណ្ឌតម្រូវ"។ ក្រុមទាំងបួនដូចមានចែងនៅក្នុងឧប្បញ្ញត្តិទាំងនេះ - ជនរងគ្រោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន - បង្កើតជាវិសាលភាពសកម្មភាពដ៏ទូលំទូលាយទាក់ទងនឹងជនរងគ្រោះ ដែលលេចចេញពីរបាយការណ៍ខែធ្នូ ឆ្នាំ

១ សេចក្តីសម្រេចមហាសន្និបាត (UNGA) ៧៣/២៧៩ A, ប្រធានបទពិសេសទាក់ទងនឹងថវិកាកម្មវិធីសម្រាប់រយៈពេលពីរឆ្នាំ ២០១៨-២០១៩ (ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨) ទំព័រ ៣-៤។ សូមមើលផងដែរ សេចក្តីសម្រេចក្រោយ បន្តដំណើរការពិគ្រោះយោបល់៖ សេចក្តីសម្រេច UNGA ៧៤/២៦៣, កម្មវត្ថុពិសេសទាក់ទងនឹងសំណើសុំថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២០ (ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩) ទំព័រ ២-៣; សេចក្តីសម្រេច UNGA ៧៥/២៥៧ A, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មុខងារដែលនៅសេសសល់ (ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០) និង សេចក្តីសម្រេច UNGA ៧៥/២៥៧ B អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មុខងារដែលនៅសេសសល់ (ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១)។

២ UNGA, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មុខងារដែលនៅសេសសល់៖ របាយការណ៍អគ្គលេខាធិការ A/៧៥/៨០៩ (ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១)។

៣ ដូចខាងលើ ទំព័រ ៧-៨។

២០២១ របស់សហចៅក្រមរបាយការណ៍ ដែលចាត់តាំងដោយ អ.វ.ត.ក ដើម្បីផ្តល់អនុសាសន៍កម្មវិធីដែលអាចអនុវត្តទិដ្ឋភាពនៃមុខងារដែលនៅសេសសល់។

យើងគួរពិចារណាទិដ្ឋភាពនៃមាត្រា ២ ដែលអាចហាក់ដូចជាមិនជាប់ពាក់ព័ន្ធផ្ទាល់ជាមួយជនរងគ្រោះ៖ មុខងារបណ្ណសារ។ មាត្រា ២ នៃឧបសម្ព័ន្ធនេះ ក៏កំណត់អាណត្តិរបស់ អ.វ.ត.ក ក្នុងការ "គ្រប់គ្រង ថែរក្សា និងចាត់ចែងបណ្ណសាររបស់ខ្លួន... និងឆ្លើយតបទៅនឹងសំណើចូលប្រើមើលឯកសារ"។ ទោះបីមាត្រា ២ មិនជាប់ទាក់ទងមុខងារដែលនៅសេសសល់លើការងារបណ្ណសារពាក់ព័ន្ធនឹងជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និង សាធារណជនក៏ដោយ វាមិនតម្រូវឱ្យមានការវិភាគការបកស្រាយស៊ីជម្រៅអំពីការពិនិត្យមើលវិធី ដែលក្រុមទាំងនោះនឹងធ្វើសំណើសុំឯកសារ ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមទាក់ទងនឹងជនរងគ្រោះ។ ជាការពិតណាស់ ក្រុមទាំងនេះអាចជាក្រុមដែលបទប្បញ្ញត្តិមានបំណងចែងបញ្ចូល។ កាន់តែច្បាស់ជាងនេះទៅទៀតគឺ មុខងារដែលនៅសេសសល់ស្នូលនៃ "ការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន" អាច និងគួរ រួមបញ្ចូល "ការចូលមើលឯកសារ" ដែលមានចែងក្នុងមាត្រា ២។ តាមការពិត មាត្រា ៣ នៃឧបសម្ព័ន្ធ "បណ្ណសារ" ចែងយ៉ាងច្បាស់ថា សម្រាប់គោលបំណងនៃការលើកកម្ពស់កេរដំណែល អ.វ.ត.ក បណ្ណសារគួរ "បើកឱ្យចូលប្រើមើលឱ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន"។ មាត្រានេះចែងបន្ថែមទៀតថា ជាផ្នែកមួយនៃមុខងារដែលនៅសេសសល់របស់ខ្លួន អ.វ.ត.ក គួរ "បើកឱ្យចូលមើលតាមប្រព័ន្ធអេឡិចត្រូនិក និងសំណៅថតចម្លងឯកសារសាធារណៈដល់សាធារណជន"។ ត្រង់ផ្នែកនៃអាណត្តិដែលនៅសេសសល់នេះហើយទើបការផ្សព្វផ្សាយឯកសារបណ្ណសាររបស់ អ.វ.ត.ក ត្រូវបានទទួលស្គាល់ថាជាធនធានសម្រាប់សកម្មភាពទាក់ទងនឹងជនរងគ្រោះ ដោយសារសារៈសំខាន់ និងភាពពាក់ព័ន្ធនៃព័ត៌មានដែលឯកសារទាំងនេះមានសម្រាប់ជនរងគ្រោះ គ្រួសារ សហគមន៍របស់ពួកគេ និងសម្រាប់សាធារណជនកម្ពុជា នាពេលបច្ចុប្បន្ន និងទៅអនាគត។

# តួនាទីរបស់ជនរងគ្រោះនៅក្នុងដំណើរការដែលនៅសេសសល់នៅ អ.វ.ត.ក និងគម្រោងសំណង

នវានុវត្តន៍ដ៏សំខាន់មួយរបស់ អ.វ.ត.ក គឺការពង្រឹងការទទួលស្គាល់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីរបស់ខ្លួន ពោលគឺ ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានផ្តល់តួនាទីជា មូលដ្ឋាន។ ជនរងគ្រោះត្រូវបាន អ.វ.ត.ក កំណត់ថាជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានទទួលព្យសនកម្មដោយសារការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក[៤]។

ការការពារ និងការធានាផលប្រយោជន៍ជនរងគ្រោះ គឺជាការងារស្នូលនៃអាណត្តិរបស់ អ.វ.ត.ក ហើយវិធានផ្ទៃក្នុងចែងថា ច្បាប់ អ.វ.ត.ក ជាធរមាន វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទប្បញ្ញត្តិរដ្ឋបាលត្រូវបកស្រាយ ដើម្បីការពារផលប្រយោជន៍ជនរងគ្រោះ ក៏ដូចជាជនជាប់ចោទ[៥]។

[៤] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) វិធានផ្ទៃក្នុង (វិ.លើកទី៩) (ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ [ចាប់ពីពេលនេះតទៅហៅថា "វិធានផ្ទៃក្នុង"] សទ្ធានុក្រម។

[៥] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ២១។

## VSS និងគម្រោងដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ០១

ការចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីមានប្រភពចេញពីច្បាប់ជាតិកម្ពុជា យោងតាមក្រមច្បាប់របស់ប្រទេសបារាំង ហើយដែលអនុញ្ញាតឱ្យជនរងគ្រោះដាក់ពាក្យសុំអន្តរាគមន៍ក្នុងដំណើរការនីតិវិធីជាដើម បណ្តឹងរដ្ឋប្បវេណី។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីគឺដើម្បីទាមទារសំណងចំពោះព្យសនកម្មដល់ជនរងគ្រោះនៃបទល្មើស ហើយក្នុងគោលបំណងនេះ អនុញ្ញាតឱ្យជនរងគ្រោះទទួលបានសំណងដែលឆ្លើយតបទៅនឹងព្យសនកម្មដែលពួកគេបានទទួលរង"[៦]។

អ.វ.ត.ក បានបង្កើតផ្នែកគាំពារជនរងគ្រោះ (VSS) និងការិយាល័យសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ការរៀបចំការចូលរួមរបស់ជនរងគ្រោះ[៧]។ ទោះបីជា VSS មិនត្រូវបានលើកឡើងនៅក្នុងឯកសារមូលដ្ឋាន មុនៗរបស់ អ.វ.ត.ក ដូចជា ច្បាប់ អ.វ.ត.ក ឬ កិច្ចព្រមព្រៀង អ.វ.ត.ក ក៏ដោយ វិធានផ្ទៃក្នុងចែងអំពីការណែនាំ ពាក់ព័ន្ធនឹងការរៀបចំការចូលរួមរបស់ជនរងគ្រោះ និងតួនាទីរបស់ VSS រួមជាមួយនឹងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។ វិធានជាក់លាក់ទាក់ទងនឹង VSS ត្រូវបានអនុម័តដាក់បញ្ចូលទៅក្នុងវិធានផ្ទៃក្នុង បន្ទាប់ពីកិច្ចប្រជុំពេញអង្គកាលពីខែកុម្ភៈ ឆ្នាំ២០១០។

តួនាទីរបស់ VSS គឺ៖

- ជួយជនរងគ្រោះដាក់ពាក្យបណ្ដឹង ក្រោមការត្រួតពិនិត្យរបស់សហព្រះរាជអាជ្ញា។;
- ជួយជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្រោមការត្រួតពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត។;
- រក្សាបញ្ជីឈ្មោះមេធាវីទាំងបរទេស និងខ្មែរ ដែលបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) និងដែលមានបំណងចង់ការពារជនរងគ្រោះ ឬ សមាគមជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក។;
- ទទួល ផ្ទៀងផ្ទាត់ និងបកប្រែពាក្យសុំរបស់មេធាវីបរទេសដែលមានបំណងចង់ការពារដើមបណ្ដឹងរដ្ឋប្បវេណី និងបញ្ជូនពាក្យសុំដែលបានបំពេញរួចរាល់ជូនទៅ BAKC ដើម្បីចុះឈ្មោះ។;
- ចាត់ចែងពាក្យសុំតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅក្នុងបញ្ជីសមាគមជនរងគ្រោះដែលត្រូវបានឯកភាពឱ្យតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។;
- ផ្ដល់ព័ត៌មានទូទៅដល់ជនរងគ្រោះ និងជាពិសេសដើមបណ្ដឹងរដ្ឋប្បវេណី។
- បង្ហាញបញ្ជីឈ្មោះ និងព័ត៌មានស្ដីពីមេធាវី និងសមាគមជនរងគ្រោះដល់ជនរងគ្រោះ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ក្រោម ការត្រួតពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ និងជួយសម្រួលដល់ការតំណាងផ្លូវច្បាប់។;
- ជួយ និងគាំទ្រវត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងដើមបណ្ដឹងបរិហារនៅក្នុងដំណើរការនីតិវិធីរបស់ តុលាការ។;
- ធ្វើសកម្មភាពចុះផ្សព្វផ្សាយទាក់ទងនឹងជនរងគ្រោះជាពិសេស ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការពិគ្រោះយោបល់ជាមួយផ្នែកកិច្ចការសាធារណៈ និងសហមេធាវីនាំមុខដើមដើមបណ្ដឹងរដ្ឋប្បវេណី។ និង,
- ធ្វើសកម្មភាពចុះផ្សព្វផ្សាយទាក់ទងនឹងជនរងគ្រោះជាពិសេស ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការពិគ្រោះយោបល់ជាមួយផ្នែកកិច្ចការសាធារណៈ និងសហមេធាវីនាំមុខដើមដើមបណ្ដឹងរដ្ឋប្បវេណី។ និង;
- អនុម័តបទប្បញ្ញត្តិរដ្ឋបាលតាមតម្រូវការដើម្បីផ្ដល់ប្រសិទ្ធភាពលើការងារខាងលើ[៨]។

VSS គឺជាអង្គភាពទំនាក់ទំនងបង្គោលរវាង អ.វ.ត.ក ជនរងគ្រោះ និងតំណាងរបស់ពួកគេ។ ទោះបីជាពុំមានចែងជាក់លាក់នៅក្នុងវិធានផ្ទៃក្នុងក៏ដោយ VSS ដើរតួជាអ្នករៀបចំការប្រជុំ និងអ្នកអញ្ជើញជនរងគ្រោះ មេធាវី អង្គការអន្តរការី និងអ្នកដែលមកពីអង្គភាពផ្សេងទៀតនៃតុលាការ[៩]។

[៦] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧) មាត្រា ២។

[៧] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ១២។

[៨] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ១២ស្ទួន។

[៩] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គភាពជនរងគ្រោះ (មើលចុងក្រោយថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២) តាមរយៈគេហទំព័រ៖ https://www.eccc.gov.kh/en/victims-support-section ។

ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក សំអាងផ្លូវច្បាប់ និងអង្គហេតុនៅក្នុងសំណុំរឿង តម្រូវឱ្យមានការកែប្រែលើគម្រោងដើមដំបូងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ចំណុចនេះមួយផ្នែកដោយសារជាលទ្ធផលនៃការកើនឡើងចំនួនដើមបណ្តឹងរដ្ឋប្បវេណីរវាងសំណុំរឿង ០០១ ដែលមានជនជាប់ចោទម្នាក់ និងភាគច្រើនប្រមូលផ្តុំលើទីតាំងឧក្រិដ្ឋកម្មមួយតែប៉ុណ្ណោះ និងសំណុំរឿង ០០២ ដែលមានជនជាប់ចោទចំនួនបួននាក់ពីដំបូង និងទីតាំងឧក្រិដ្ឋកម្មនៅទូទាំងប្រទេស។ ចំនួនពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់រវាងសំណុំរឿងទាំងពីរ។ តារាងខាងក្រោមបង្ហាញអំពីភាពខុសគ្នារវាងចំនួនអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ និង ០០២។

## សំណុំរឿង ០០១

ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៣នាក់ បានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០១

- ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៣នាក់បានដកពាក្យសុំ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើភាពអាចទទួលយកបាន និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩០ នាក់។
- ក្នុងចំណោម ៩០នាក់ អង្គជំនុំជម្រះសាលាដំបូងបានតម្កល់ភាពអាចទទួលយកបានចំនួន ៦៤ នាក់។

## សំណុំរឿង ០០២

VSS បានបញ្ជូនពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤,១២៨។ ស.ច.ស បានសម្រេចទទួលស្គាល់ពាក្យសុំចំនួន ៣,៨៦៦។

- អ្នកដាក់ពាក្យសុំចំនួន ១៣៣ រស់នៅក្រៅប្រទេស ១០៤នាក់ បានប្តូរឋានៈមកជាដើមបណ្តឹងបរិហារ ១៩នាក់ ជាពាក្យសុំជាន់គ្នា និង ០៦នាក់ បានដាក់ពាក្យសុំសាជាថ្មី តាមសំណើរបស់ជនរងគ្រោះ។
- ស.ច.ស ត្រូវសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំចំនួន ៣,៩៨៨ ហើយគិតត្រឹមដំណាក់កាលនោះ មានអ្នកដាក់ពាក្យសុំចំនួន ១៨នាក់ បានទទួលមរណភាព។

ក្នុងសំណុំរឿង ០០១ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៣នាក់ បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ មុនពេលវិសោធនកម្មលើវិធានស្តីពីការចូលរួម ដែលត្រូវបានពិភាក្សាបន្ថែមនៅក្នុងផ្នែកខាងក្រោម ភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលប្រកាសសាលក្រម។ ដើម បណ្តឹងរដ្ឋប្បវេណីចំនួន ០៣នាក់ បានដកពាក្យសុំគិតត្រឹមពេលនោះ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងមានភារកិច្ចសម្រេចលើភាពអាចទទួលយកបាន និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩០នាក់។ អង្គជំនុំជម្រះសាលាដំបូងបានតម្កល់ពាក្យសុំចំនួន ៦៤ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩០នាក់ ដែលដើមឡើយត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០១។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២នាក់ បានប្តឹងឧទ្ធរណ៍ប្រឆាំងការបដិសេធរបស់អង្គជំនុំជម្រះ

សាលាដំបូងលើពាក្យសុំរបស់ពួកគេនៅក្នុងសាលក្រម។ អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) បានពិចារណាថាតើអង្គជំនុំជម្រះមានកំហុសក្នុងសេចក្តីសម្រេចរបស់ខ្លួនលើអង្គសេចក្តីនៃពាក្យសុំរបស់ពួកគេដែរឬទេ។ អ.ជ.ត.ក បានកត់សម្គាល់ថាមានការភាន់ច្រឡំជាមូលដ្ឋានរវាងអង្គជំនុំជម្រះសាលាដំបូង និងដើមបណ្តឹងរដ្ឋប្បវេណីអំពីអង្គសេចក្តី និងអានុភាពផ្លូវច្បាប់នៃការពិនិត្យដំបូងលើពាក្យសុំរបស់ពួកគេ។ អ.ជ.ត.ក ក៏បានសន្និដ្ឋានបន្ថែមទៀតថា "ក្រោយពីបានពិចារណាអំពីចរិតលក្ខណៈថ្មីនៃក្របខ័ណ្ឌទាក់ទិនទៅនឹងការរៀបចំជាក់លាក់អំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់នូវលទ្ធភាពដែលអាចកើតមានឡើងថា អាចមានម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមានការយល់ច្រឡំចំពោះបញ្ហាថាតើនៅតែមានការទាមទារឱ្យពួកគេដាក់ភ័ស្តុតាងបន្ថែមទៀតដែរឬយ៉ាងណា"[10]។ អ.ជ.ត.ក ក៏បានកត់សម្គាល់បន្ថែមទៀតថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់ឋានៈដល់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី នឹងបង្កការឈឺចាប់ និងការខកចិត្តដោយសារការខិតខំជាក់ស្តែង និងអារម្មណ៍របស់ពួកគេនៅក្នុងកិច្ចដំណើរការនីតិវិធី[11]។

ដើម្បីជួសជុលឱកាសខកខាន អ.ជ.ត.ក បានសម្រេចទទួលយកសំណើរបស់អ្នកដាក់ពាក្យសុំ ស្នើសុំដាក់ ភ័ស្តុតាងបន្ថែម។ ទោះយ៉ាងនេះក្តី អ.ជ.ត.ក បានគោរពតាមលក្ខណៈវិនិច្ឆ័យរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីចំណងពិសេសនៃការស្រលាញ់ ឬ ភាពក្នុងបន្ទុកជាមួយជនរងគ្រោះផ្ទាល់នៅពេលកំណត់អំពីភាពអាចទទួលយកបាននៃពាក្យសុំពីជនរងគ្រោះដោយប្រយោល។ អ.ជ.ត.ក បានសម្រេចថា "លក្ខណៈវិនិច្ឆ័យនៃចំណងពិសេសនៃក្តីស្រលាញ់ ឬការរស់នៅក្នុងបន្ទុកដែលជាប់ទាក់ទងរវាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងជនរងគ្រោះផ្ទាល់គឺគ្រប់ដណ្តប់ទៅលើសារៈសំខាន់នៃទំនាក់ទំនងផ្ទាល់ទៅវិញទៅមក ហើយការបំផ្លាញទំនាក់ទំនងនេះនាំឱ្យមានព្យសនកម្មដែលប៉ះពាល់ដល់ជនរងគ្រោះមិនផ្ទាល់"[12]។ អ.ជ.ត.ក បានបញ្ជាក់ថា ចំណុចនេះអនុវត្តចំពោះគ្រប់បុគ្គលដែលអះអាងថាជាជនរងគ្រោះដោយប្រយោល មិនថាពួកគេជាគ្រួសារមែនឬមិនមែននោះឡើយ។

អ.ជ.ត.ក បានទទួលយកបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០នាក់ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២នាក់ ដែលបណ្តឹងទាមទាររបស់ពួកគេត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធ។ ករណីនេះបានធ្វើឱ្យចំនួនដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលយកចុងក្រោយក្នុងសំណុំរឿង ០០១ ឡើងដល់ចំនួន ៧៤ រួមទាំង ពាក្យសុំចំនួន ៦៤ ដែលទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង និងពាក្យសុំចំនួន ១០ ផ្សេងទៀតត្រូវបានទទួលយកដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងដំណាក់កាលនៃបណ្តឹងសាទុក្ខ។

ការវិវឌ្ឍទាំងនេះនៅក្នុងសំណុំរឿង ០០១ ចាំបាច់ត្រូវតែមានការកែប្រែនៅមុនពេលចាប់ផ្តើមនៃសំណុំរឿង ០០២ ដើម្បីជៀសវាងស្ថានភាពមួយ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានច្រានចោលបន្ទាប់ពីកិច្ចដំណើរការនីតិវិធីអស់រយៈពេលជាច្រើនឆ្នាំ ជាពិសេស នៅពេលពិចារណាឃើញថាអ្នកដាក់ពាក្យសុំនៅក្នុងសំណុំរឿងក្រោយមានចំនួនជាង ៤,០០០។ ដូច្នេះ កិច្ចប្រជុំពេញអង្គបានធ្វើវិសោធនកម្មវិធានផ្ទៃក្នុងកាលពីខែកុម្ភៈ ឆ្នាំ២០១០ ដែលចែងថា ការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវសម្រេចនៅពេលចុងបញ្ចប់នៃកិច្ចស៊ើបសួររបស់អង្គបុរេជំនុំជម្រះ។

[10] អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសង្ខេបសាលដីកា៖ សំណុំរឿង ០០១/១៨-០៧-២០០៧-ECCC/SC (កាំង ហ្គេកអ៊ាវ) (ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F២៦/៣ កថាខណ្ឌ ៥៩។

[11] ដូចខាងលើ។

[12] ដូចខាងលើ កថាខណ្ឌ ៥៣។

ដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី បុគ្គលម្នាក់ត្រូវតែបង្ហាញថាខ្លួនបានទទួលរងព្យសនកម្មមួយចំនួន ដោយសារលទ្ធផលផ្ទាល់នៃឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងករណីជាក់លាក់ណាមួយនៅចំពោះមុខ អ.វ.ត.ក។ នៅពេលបុគ្គលម្នាក់ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី បុគ្គលនោះនឹងក្លាយជា "ភាគី" នៅក្នុងកិច្ចដំណើរការនីតិវិធី។

ទោះបីជាការចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីមានប្រភពចេញពីច្បាប់ជាតិកម្ពុជាក៏ដោយ ក៏ប្រព័ន្ធនេះ ដូចបានចែងនៅក្នុងនីតិវិធីជាតិ ពុំមែនយកមកអនុវត្តចំពោះការជំនុំជម្រះក្តីធំៗដែលទាក់ទងនឹងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ដូចនៅ អ.វ.ត.ក នោះទេ។ កិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក បានកែប្រែវិធានផ្ទៃក្នុងជាច្រើនដង ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ វិធានផ្ទៃក្នុងនេះត្រូវបានធ្វើវិសោធនកម្មចំនួន ០៩លើក គិតចាប់ពីពេលសរសេរវិធានផ្ទៃក្នុងនេះឡើង ហើយការធ្វើវិសោធនកម្មដ៏សំខាន់បំផុតមួយគឺទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងកិច្ចប្រជុំពេញអង្គកាលពីខែកុម្ភៈ ឆ្នាំ២០១០។

បញ្ហាប្រឈមធំមួយនៅក្នុងសំណុំរឿង ០០១ គឺការធ្វើឱ្យមានតុល្យភាពរវាងសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួម និងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌។ ដើមបណ្តឹងរដ្ឋប្បវេណីសំអាងលើសិទ្ធិរបស់ពួកគេ អាចសួរសំណួរដល់សាក្សី និងជនជាប់ចោទ ដែលពីមុនបានអូសបន្លាយរយៈពេលនៃកិច្ចដំណើរការនីតិវិធីយ៉ាងច្រើន ហើយអង្គជំនុំជម្រះបានកំណត់ជាបណ្តើរៗ សមត្ថភាពសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការអន្តរាគមន៍ក្នុងសំណុំរឿង ០០១[១៣]។ បញ្ហាប្រឈមផ្សេងទៀត ដូចបានកត់សម្គាល់ដោយ ចៅក្រម Jean-Marc Lavergne ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងមតិជំទាស់កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩[១៤]ថា អាណត្តិរបស់ អ.វ.ត.ក មានកំណត់ពេលវេលា ហើយ អ.វ.ត.ក ពុំមានមូលនិធិស្ម័គ្រចិត្ត, ភ័ស្តុតាងនៃឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ខុសពីភ័ស្តុតាងរបស់ឧក្រិដ្ឋកម្មនីមួយៗរាប់ពាន់, ការដំណើរការសវនាការក្នុងពេលវេលាសមហេតុផលមានវិសមភាពជាមួយនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំ ហើយចំណុចសំខាន់ គឺការបញ្ជាក់អំពីភាពអាចទទួលយកបាននៃពាក្យសុំជាច្រើនដែលអាចប្តឹងដាក់មក។

នៅក្នុងកិច្ចប្រជុំពេញអង្គកាលពីខែកុម្ភៈ ឆ្នាំ២០១០ វិសោធនកម្មមួយចំនួនត្រូវបានអនុម័ត ដើម្បីធានាឱ្យកាន់តែមានប្រសិទ្ធភាព និងទទួលស្គាល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះ វិធានផ្ទៃក្នុងបានចែងបន្ថែម វិធាន ១២ស្ទួនពីរ និងវិធាន ២៣ស្ទួនពីរ។ នីតិវិធីថ្មីនេះមានគោលបំណង "ធ្វើឱ្យមានតុល្យភាពសិទ្ធិរបស់ភាគីទាំងអស់ ដើម្បីការពារលទ្ធភាពរបស់ អ.វ.ត.ក ក្នុងការសម្រេចបាននូវអាណត្តិរបស់ខ្លួន ខណៈរក្សាបាននូវការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងលើកកម្ពស់គុណភាពនៃការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី" ។ ការកែប្រែនេះបានបញ្ចូលភាពខុសគ្នារវាងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គលក្នុងដំណាក់កាលត្រៀមរៀបចំ និងដំណាក់កាលជំនុំជម្រះ ដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នឹងបង្កើតជាក្រុមរួមតែមួយ មានផលប្រយោជន៍តំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (CPLCLs)។ ការផ្លាស់ប្តូរនេះត្រូវបានបញ្ជាក់បន្ថែមដោយអង្គជំនុំជម្រះសាលាដំបូងនៅដើមដំបូងនៃសំណុំរឿង ០០២ ដោយបានសម្រេចថា៖

[១៣] អង្គជំនុំជម្រះសាលាដំបូង ប្រតិចារឹកកិច្ចដំណើរការនីតិវិធីជំនុំជម្រះ - កាំង ហ្គេកអ៊ាវ ហៅ "ឌុច" (សាធារណៈ) (ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩) ឯកសារ E១/៣៥.១, ទំព័រ ៩៨។

[១៤] អង្គជំនុំជម្រះសាលាដំបូង 'មតិជំទាស់របស់ចៅក្រម Lavergne ចៅក្រមអង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំចេញដីកាសម្រេចស្តីពីឋានៈមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដាក់សេចក្តីសន្និដ្ឋានលើការកំណត់ទោស និងសេចក្តីណែនាំឲ្យចេញដីកាណែនាំពាក់ព័ន្ធនឹងការចោទសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលផ្តល់សក្ខីកម្មអំពី អត្តចរិក (ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩) ឯកសារ E៧២/៣ ទំព័រ ១៣-២៦។

[១៥] អ.វ.ត.ក សេចក្តីប្រកាសព័ត៌មាន៖ សម័យប្រជុំពេញអង្គលើកទី ៧ នៃកិច្ចដំណើរការនីតិវិធីបានបញ្ចប់ (ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០) ដែលអាចចូលមើលនៅលើ៖ http://www.eccc.gov.kh/sites/default/files/media/Press_Release_Conclusion_7th_Plenary_Session_%28ENG%29.pdf ។

[១៦] ដូចខាងលើ។

[១៧] អង្គជំនុំជម្រះសាលាដំបូង ដីកាបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៨៩ស្ទួនពីរ (សំណុំរឿង ០០២) (ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១) ឯកសារ E១២៤ កថាខណ្ឌ ៨។

ផ្អែកលើបទប្បញ្ញត្តិជាធរមាន ដើមបណ្តឹងរដ្ឋប្បវេណី មិនចូលរួមជាលក្ខណៈបុគ្គលដោយផ្អែកលើមូលដ្ឋាននៃព្យសនកម្ម ជាក់លាក់ដែលខ្លួនបានទទួលរងនោះឡើយ ផ្ទុយទៅវិញដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះរួមបញ្ចូលជាបណ្តុំ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយដែលផលប្រយោជន៍សមូហភាពរបស់ពួកគេ នឹងត្រូវតំណាងដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលជំនុំជម្រះ និងដំណាក់កាលក្រោយៗមកទៀត។ ហេតុដូច្នេះ ការកម្រិតវិសាលភាពនៃអង្គហេតុ ដែលគ្រោងនឹងយកមកជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនេះពុំមានផលប៉ះពាល់ចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលជំនុំជម្រះនេះឡើយ។ ចំណែកការទាមទារសំណងដែលធ្វើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

យោងតាមបទប្បញ្ញត្តិដែលបានកែសម្រួល ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ត្រូវបន្តតំណាងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ពេលវេលា ចាប់ពីថ្ងៃចេញដីកាដំណោះស្រាយ ។ ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីចង់បាន ពួកគេអាចបង្កើតជាក្រុម និងជ្រើសរើសតំណាងដោយមេធាវីរួមគ្នា ចេញពីក្នុងបញ្ជីឈ្មោះកាន់កាប់ដោយ VSS។ VSS រួមជាមួយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ចាត់វិធានការសមហេតុផលទាំងអស់ ដើម្បីធានាថា នៅក្នុងការជ្រើសរើសមេធាវីរួមគ្នា ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងរួម ហើយត្រូវជៀសវាងទំនាស់ផលប្រយោជន៍ ។ ក្នុងដំណាក់កាលបុរេជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ជាលក្ខណៈបុគ្គល ហើយពួកគេមានសិទ្ធិតំណាងដោយមេធាវីដើម បណ្តឹងរដ្ឋប្បវេណី។ យោងតាមវិធានវិសោធនកម្ម នៅពេលសំណុំរឿងឈានដល់ដំណាក់កាលជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងបង្កើតជា "ក្រុមរួម" មួយដែលផលប្រយោជន៍របស់ពួកគេនឹងត្រូវបានតំណាងរួមគ្នាដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០២រូប (CPLCLs)។ ចាប់ពីដំណាក់កាលនេះទៅ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រការងាររបស់ CPLCLs ហើយពួកគេក៏ជាជនបង្គោលក្នុងការធ្វើទំនាក់ទំនងជំនួសដើមបណ្តឹង រដ្ឋប្បវេណីនីមួយៗផងដែរ។

យោងតាមវិធានវិសោធនកម្ម CPLCLs តំណាងផលប្រយោជន៍នៃ "ក្រុមរួម" នៃដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខ រួមមាន CPLCL កម្ពុជាមួយរូប និងអន្តរជាតិមួយរូប ដែលត្រូវបានជ្រើសរើស និងផ្តល់មូលនិធិដោយ អ.វ.ត.ក ។ CPLCLs បំពេញភារកិច្ចរបស់ខ្លួនដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រ CPLCLs ក្នុងការតំណាងផលប្រយោជន៍របស់ក្រុមរួម។ ការគាំទ្របែបនេះអាចរួមបញ្ចូលការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ការពិនិត្យកូនក្តី និងសាក្សីរបស់ពួកគេ និងកិច្ចនីតិវិធីផ្សេងទៀត។ CPLCLs ខិតខំស្វែងរកប្រមូលការយល់ឃើញរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឈានដល់ការឯកភាពគ្នា សំដៅសម្របសម្រួលការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលជំនុំជម្រះ ។ CPLCLs ទទួលខុសត្រូវចុងក្រោយចំពោះមុខតុលាការនេះ លើការងារតស៊ូមតិ យុទ្ធសាស្ត្រ និងការធ្វើជាតំណាងនៅចំពោះមុខតុលាការអំពីផលប្រយោជន៍របស់ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ទាំងអស់ ដែលត្រូវបានចាត់ទុកជាបន្តបន្ទាប់ថាជាអង្គភាពតែមួយ។ មុខនាទីរបស់សហមេធាវីនាំមុខចាប់ផ្តើមមានអានុភាពនៅពេលអង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង ហើយត្រូវតែបំពេញកិច្ចរួមគ្នាលើគ្រប់ការងារ លើកលែងតែ

បានសម្រេចរួមគ្នាធ្វើប្រតិភូកម្មអំណាចទៅឱ្យ CPLCL តែម្នាក់ ដើម្បីចាត់ចែងបញ្ហាជាក់លាក់ណាមួយ ។ ដើម្បីធានានូវការរៀបចំប្រកបដោយប្រសិទ្ធភាពនៃការតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាលជំនុំជម្រះ និងដំណាក់កាលក្រោយមកទៀត CPLCLs ត្រូវធ្វើឱ្យមានតុល្យភាពសិទ្ធិរបស់ភាគីទាំងអស់ និងចាំបាច់ត្រូវជំរុញការជំនុំជម្រះឱ្យបានឆាប់រហ័ស ។

ក្នុងអំឡុងពេលសវនាការ CPLCLs អាចបង្ហាញអញ្ញត្រកម្ម និងឆ្លើយតបទៅនឹងការជំទាស់បឋមដែលភាគីបានលើកឡើង និងស្នើសុំអង្គជំនុំជម្រះកោះហៅ ឬ ស្តាប់សាក្សីណាមួយ និងទទួលភ័ស្តុតាងថ្មី ដែលពួកគេយល់ថាចាំបាច់ ។ CPLCLs អាចសួរជនជាប់ចោទ សាក្សី និងអ្នកជំនាញ ទៅតាមការបង្គាប់របស់ប្រធានអង្គជំនុំជម្រះ តាមលំដាប់លំដោយរបស់ភាគី ។ លើសពីនេះ ពួកគេអាចដាក់សារណាជាលាយលក្ខណ៍អក្សរ ធ្វើសេចក្តីថ្លែងការណ៍បិទនៅចុងបញ្ចប់នៃសំណុំរឿង និងធ្វើប្តឹងឧទ្ធរណ៍ប្រឆាំងសាលក្រម និងសេចក្តីសម្រេចលើសំណង ។ ក្នុងករណីសហព្រះរាជអាជ្ញាប្តឹងសាទុក្ខ ដើមបណ្តឹងរដ្ឋប្បវេណីដែលបំពេញកិច្ចតាមរយៈ CPLCLs អាចប្តឹងសាទុក្ខលើ សាលក្រម ប៉ុន្តែមិនអាចប្តឹងសាទុក្ខលើការកំណត់ទោសបាននោះទេ ។

ខាងក្រៅសិទ្ធិរបស់ CPLCLs នៅក្នុងការទទួលបានការជំនុំជម្រះ ពួកគេអាចជ្រើសរើសធ្វើសំណើ និងករណីខ្លះអាចចេញសេចក្តីប្រកាសព័ត៌មានអំពីបញ្ហាមួយចំនួន។ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនអនុញ្ញាតឱ្យ CPLCLs មានឱកាសធ្វើសេចក្តីសន្និដ្ឋានបើកដោយសង្ខេប ក្នុងអំឡុងពេលដែលពួកគេសង្ឃឹមថានឹងអាចធ្វើជាតំណាងសមាសភាពនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួម។ ជាការឆ្លើយតប មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខអន្តរជាតិ នៅពេលនោះ បានចេញសេចក្តីប្រកាសព័ត៌មានមួយរិះគន់ជំហររបស់ អង្គជំនុំជម្រះ និងសង្កត់ធ្ងន់លើតម្លៃជានិមិត្តរូប ក្នុងករណីខ្លួនបានធ្វើអន្តរាគមន៍ ។

ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិផ្តល់ភ័ស្តុតាងជាឯកសារ និងសក្ខីកម្មនៅក្នុងបន្ទប់សវនាការ ដូចសាក្សី ឬអ្នកជំនាញដទៃទៀត។ ឆ្លងតាមរយៈការជំនុំជម្រះទាំងពីរវគ្គក្នុងសំណុំរឿង ០០២ បុគ្គលសរុបចំនួន ២៧៨ នាក់បានផ្តល់សក្ខីកម្មនៅក្នុងដំណើរការសវនាការ ក្នុងនោះរួមមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៥នាក់ ឬ ប្រហែល ៣៤% នៃសក្ខីកម្មទាំងអស់ ។ ពួកគេបានផ្តល់សក្ខីកម្មនៅគ្រប់វគ្គនៃការជំនុំជម្រះ រួមទាំងទាក់ទងនឹងការចោទប្រកាន់នៃបទប្រល័យពូជសាសន៍លើជនជាតិភាគតិច និងសាសនា និងអំពើហិង្សាយេនឌ័រក្នុងទម្រង់នៃការរៀបការដោយបង្ខំ។ ដំណើរការស៊ើបសួររបស់តុលាការដែលមានលក្ខណៈលម្អិត និងរយៈពេលយូរ - រួមទាំងក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលមិនបានបន្តដល់ដំណាក់ការជំនុំជម្រះ - ចាំបាច់ត្រូវប្រមូលឯកសាររាប់រយរាប់ម៉ឺនទំព័រ រួមទាំងសក្ខីកម្មរបស់ជនរងគ្រោះ និងអ្នកនៅរស់រានមានជីវិត ដែលចូលរួមជាសាក្សីអង្គហេតុ ដើមបណ្តឹងរដ្ឋប្បវេណី ឬ ដើមបណ្តឹងបរិហារ។ សក្ខីកម្មទាំងនេះក៏ដូចជាភ័ស្តុតាងឯកសារប្រមូលបានដោយអ្នកស៊ើបអង្កេត ដែលសម្ភាសជនរងគ្រោះ និងអ្នកនៅរស់រានមានជីវិត ត្រូវបានដាក់ឱ្យជូនពិនិត្យក្នុងពេលជំនុំជម្រះ ហើយបច្ចុប្បន្ន អាចនឹងត្រូវបានប្រើប្រាស់ជាធនធានអប់រំ និងព័ត៌មានសម្រាប់មនុស្សជំនាន់ក្រោយដើម្បីស្វែងយល់បន្ថែមអំពីការឈឺចាប់ពីអតីតកាល។

---

[១៨] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ២៣ស្ទួនពីរ (១)។

[១៩] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ២៣ស្ទួនពីរ (៣)(គ)។

[២០] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ១២ស្ទួនពីរ (៤)។

[២១] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ១២ស្ទួនពីរ (៣)។

[២២] ដូចខាងលើ។

[២៣] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ១២ស្ទួនពីរ (១)។

[២៤] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ៨៩។

[២៥] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ៨៧(៤)។

[២៦] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ៩០(២)។

[២៧] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ៩២។

[២៨] អ.វ.ត.ក វិធានផ្ទៃក្នុង វិធាន ១០៥(១)។

[២៩] ដូចខាងលើ។

[៣០] សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខអន្តរជាតិ សេចក្តីប្រកាសព័ត៌មាន៖ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបំបិទមាត់ជាថ្មីម្តងទៀតនៅចំពោះមុខ អ.វ.ត.ក (ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១) ដូចបានពិភាក្សានៅក្នុង Marie Guiraud, សិទ្ធិជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក៖ កំណត់ត្រាចម្រុះសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី (ខែវិច្ឆិកា ឆ្នាំ ២០១២), FIDH, ទំព័រ ៤៧។

[៣១] Caitlin McCaffrie និង Daniel Mattes, សវនាការមួយទៀត៖ ការពិនិត្យឡើងវិញលើសំណុំរឿង ០០២/០២ (ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨), មជ្ឈមណ្ឌល WSD HANDA សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ នៅសាកលវិទ្យាល័យ Stanford និងមជ្ឈមណ្ឌល East-West ទំព័រ ២៦។

គម្រោងសំណងសរុបចំនួន ២៦ ត្រូវបានទទួលស្គាល់ និងអនុវត្តនៅក្នុងការជំនុំជម្រះចំនួនបីសំណុំរឿង ដែលបានបញ្ចប់នៅ អ.វ.ត.ក។ ក្នុងសំណុំរឿង ០០១ គម្រោងសំណងចំនួនពីរ ត្រូវបានទទួលយកមកអនុវត្ត។ ក្នុងសំណុំរឿង ០០២/០១ គម្រោងសំណងចំនួន ១១ ត្រូវបានទទួលស្គាល់យកមកអនុវត្ត ហើយក្នុងសំណុំរឿង ០០២/០២ គម្រោងចំនួន ១៣ ត្រូវបានទទួលស្គាល់យកមកអនុវត្ត។ សេចក្តីសង្ខេបនៃសុន្ទរកថាគន្លឹះរបស់បណ្ឌិត Christoph Sperfeldt នៅក្នុងសិក្ខាសាលា កាលពីខែឧសភា ឆ្នាំ២០២២ នៅក្នុងផ្នែកខាងក្រោយនៃរបាយការណ៍នេះ ក៏លើកឡើងគម្រោងទាំងនេះលម្អិតផងដែរ។ គម្រោងទាំង ២៦នេះ ត្រូវបានរៀបរាប់លម្អិតនៅក្នុងតារាងខាងក្រោម រួមជាមួយ អង្គការ ឬ ស្ថាប័នដែលបានអនុវត្តគម្រោងនីមួយៗ ព្រមទាំងម្ចាស់ជំនួយដែលបានផ្តល់មូលនិធិដល់គម្រោងនីមួយៗនេះ។

## សំណុំរឿង ០០១

### ● បញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងសាលក្រមសំណុំរឿង ០០១

ដៃគូអនុវត្ត: ECCC

ម្ចាស់ជំនួយ: n/a

### ● ចងក្រង និងបោះពុម្ពសេចក្តីសុំខមាលទោសរបស់ កាំង ហ្គេកអ៊ាវ និងការទទួលស្គាល់ការទទួលខុសត្រូវ

ដៃគូអនុវត្ត: ECCC

ម្ចាស់ជំនួយ: ការិយាល័យបរទេសសហព័ន្ធអាល្លឺម៉ង់ / GIZ

## ● ទិវាជាតិនៃការចងចាំ

ដៃគូអនុវត្ត

រាជរដ្ឋាភិបាល

ម្ចាស់ជំនួយ

n/a

## ● ការចងចាំជនរងគ្រោះខ្មែរក្រហម៖ "ជូនចំពោះអ្នកដែលលែងនៅទីនេះតទៅទៀត"

ដៃគូអនុវត្ត

Sera ING,
សមាគម ANVAYA,
ស្ថានទូតបារាំង,
OUBA SAS,
ACYC SARL Architects

ម្ចាស់ជំនួយ

សាធារណរដ្ឋបារាំង,
Ms. Catherine Quere
(French MP),
Mr. Avi Assouly
(French MP),
សមាគម ANVAYA,
ស្ថានទូតបារាំង,
OUBA SAS,
ACYC SARL Architects

## ● ពិពណ៌ចល័តស្តីពីការជម្លៀសដោយបង្ខំ និងទួលពោធិ៍ជ្រៃ

ដៃគូអនុវត្ត

ក្តីករុណា និង យុវសន្តិភាព

ម្ចាស់ជំនួយ

BMZ/GIZ
វិទ្យាស្ថានអាល្លឺម៉ង់
សម្រាប់ទំនាក់ទំនងបរទេស,
Narrowcasters Pty. Ltd.

## ● ជំពូកថ្មី ស្តីពីការជម្លៀសដោយបង្ខំ និងទួលពោធិ៍ជ្រៃនៅក្នុងសៀវភៅណែនាំគ្រូបង្រៀន

ដៃគូអនុវត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា

ម្ចាស់ជំនួយ

BMZ/GIZ

## ● ការបោះពុម្ពផ្សាយ និងការចែកចាយសាលដីកាសំណុំរឿង ០០២/០១

ដៃគូអនុវត្ត

VSS,
ផ្នែកកិច្ចការសាធារណៈ

ម្ចាស់ជំនួយ

BMZ/GIZ
ផ្នែកកិច្ចការសាធារណៈ,
ឯកអគ្គរដ្ឋទូត David Scheffer

- ការព្យាបាលដោយសក្តិកម្ម
- ក្រុមជួយខ្លួនឯងសម្រាប់ការស្តានីតិសម្បទា

ដៃគូអនុវត្ត

អង្គការអន្តរវប្បធម៌ ចិត្តសង្គម

ម្ចាស់ជំនួយ

BMZ/GIZ, Stiftung Kriegstrauma Therapie, Commonwealth នៃប្រទេសអូស្ត្រាលី

- ការតាំងពិពណ៌អចិន្ត្រៃយ៍ស្តីពីការជម្លៀសដោយបង្ខំ និងទួលពោធិ៍ជ្រៃ

ដៃគូអនុវត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា

ម្ចាស់ជំនួយ

BMZ/GIZ

- មជ្ឈមណ្ឌលសិក្ខាសន្តិភាពសហគមន៍នៅសំរោងក្នុង

ដៃគូអនុវត្ត

យុវសន្តិភាព

ម្ចាស់ជំនួយ

ទីភ្នាក់ងារស្វីសសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ

- សៀវភៅដើមបណ្តឹងរដ្ឋប្បវេណី

ដៃគូអនុវត្ត

អង្គការសមាគមការពារសិទ្ធិមនុស្សនៅកម្ពុជា

ម្ចាស់ជំនួយ

BMZ/GIZ

- ការបោះពុម្ពផ្សាយឈ្មោះដើម្បីបណ្តឹងរដ្ឋប្បវេណីនៅលើគេហទំព័រ អ.វ.ត.ក

ដៃគូអនុវត្ត

VSS, ផ្នែកកិច្ចការសាធារណៈ

ម្ចាស់ជំនួយ

n/a



ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អ៊ឹម វណ្ណៈផ្តល់សក្ខីកម្មអំពីទុក្ខលំបាករបស់គាត់ ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន កាលពី ថ្ងៃទី៣ ខែមេសា ឆ្នាំ ២០១៥។



សហព្រះរាជអាជ្ញា នាថ្ងៃចុងក្រោយនៃសវនាការបឋមក្នុងសំណុំរឿង០០២/០២ នាថ្ងៃទី ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១១។



អ្នករស់រានមានជីវិតពីមន្ទីរសន្តិសុខ ស-២១ និង ដើមបណ្តឹងរដ្ឋប្បវេណី ទទួលសាលដីកាក្នុងសំណុំរឿង ០០១ និងការចងក្រងនូវពាក្យសូមអភ័យទោសរបស់កាំង ហ្គេកអ៊ាវហៅ ឌុច នៅក្នុងអំឡុងពេលសវនាការកន្លងមក នៅឯសារមន្ទីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២។

នៅក្នុងការជំនុំជម្រះចុងក្រោយបំផុតក្នុងសំណុំរឿង ០០២/០២ គម្រោងសំណងចំនួន ១៤ ត្រូវបានស្នើឡើង ដោយផ្អែកលើប្រភពមូលនិធិពីខាងក្រៅ និងគម្រោងជាច្រើនត្រូវបានអនុវត្តមុនពេលចេញសាលក្រមលើសំណុំរឿងនេះទៅទៀត[៣២]។ គម្រោងទាំង ១៤នេះ ផ្តោតលើប្រធានបទជាច្រើនទាក់ទងនឹងការរំលឹកការចងចាំ ការស្តារ នីតិសម្បទា ការធានាមិនឱ្យមានការកើតឡើងឧក្រិដ្ឋកម្មសាជាថ្មីក្នុងទម្រង់នៃការអប់រំ និងការចងចាំ។ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលដីកាសម្រេចថា នួន ជា និងខៀវ សំផន មានពិរុទ្ធភាព ហើយបានផ្តន្ទាទោសពួកគេម្នាក់ៗដាក់ពន្ធនាគារអស់មួយជីវិត។ នៅក្នុងសាលដីកានោះ គម្រោងសំណងចំនួន ១៣ ក្នុងចំណោមគម្រោងចំនួន ១៤ ត្រូវបានអនុម័ត។ គម្រោងតែមួយគត់ដែលមិនត្រូវបានអនុម័តគឺគម្រោងដែលផ្តោតលើបទពិសោធន៍របស់ជនជាតិដើមភាគតិចក្រោមរបប DK ដែលអង្គជំនុំជម្រះមិនពាក់ព័ន្ធគ្រប់គ្រាន់ជាមួយឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានផ្តន្ទាទោសក្នុងសំណុំរឿង ០០២/០២។ គម្រោងផ្សេងទៀតដែលត្រូវបានស្នើឡើងនៅដំណាក់កាលដំបូងនៃការជំនុំជម្រះ ត្រូវបានដកចេញពីការទាមទារចុងក្រោយដោយ CPLCLs មូលហេតុចម្បងដោយសារតែគម្រោងទាំងមូលមិនមានមូលនិធិពេញលេញ។

[៣២] នៅក្នុងការពិគ្រោះយោបល់ជាមួយតំណាងសង្គមស៊ីវិលពាក់ព័ន្ធមុន កំឡុងពេល និងក្រោយសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ អ្នកនិពន្ធនៃរបាយការណ៍បានដឹងថា គម្រោងសំណង ១២ ដែលមានរាយក្នុងតារាងខាងក្រោមមានចំណងជើងថា "ការអប់រំផ្នែកច្បាប់ និងពលរដ្ឋសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីភាគតិច" មិនត្រូវបានអនុវត្តទេ។ អ.វ.ត.ក មានកាតព្វកិច្ចក្នុងដំណាក់កាលដែលនៅសេសសល់របស់ខ្លួន យោងតាមមាត្រា ២ នៃឧបសម្ព័ន្ធដើម្បីធ្វើការត្រួតពិនិត្យ និងតាមដានរាល់គម្រោងសំណងដែលសម្រេចដោយតុលាការ រួមទាំងគម្រោងសំណង ១២ នៃសំណុំរឿង ០០២/០២។ .

## ● កម្មវិធីសិក្សាស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម

ដៃគូអនុវត្ត

មជ្ឈមណ្ឌលបុប្ផាណា

ម្ចាស់ជំនួយ

EU តាមរយៈ UNOPS,
មូលនិធិ Rei

## ● ការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈសិក្ខាសាលា ការបណ្តុះបណ្តាលគ្រូបង្រៀន និងគ្រូសាកលវិទ្យាល័យ

ដៃគូអនុវត្ត

DC-Cam

ម្ចាស់ជំនួយ

EU តាមរយៈ UNOPS

## ● ផ្កាស្លាក្រោមអង្គការ៖ អាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបខ្មែរក្រហម

ដៃគូអនុវត្ត

Khmer Arts,
KDK,
TPO,
Bophana

ម្ចាស់ជំនួយ

កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ស្វីស,
BMZ/GIZ,
USAID

## ● សម្លេងជនជាតិដើមភាគតិច៖ ជំរុញការយល់ដឹងជាសាធារណៈអំពីការប្រព្រឹត្តលើជនជាតិភាគតិច នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម

ដៃគូអនុវត្ត

KDK

ម្ចាស់ជំនួយ

GIZ-CPS,
ស្ថានទូតស្វីសនៅទីក្រុងបាងកក

## ● គម្រោងគំនូរចងចាំក្រាំងតាចាន់

ដៃគូអនុវត្ត

YFP និង PIC

ម្ចាស់ជំនួយ

សម្ព័ន្ធអន្តរជាតិនៃទីតាំងមនសិការ

- គម្រោងអណ្ដើកក្លាហាន៖ គម្រោងសារព័ត៌មានច្នៃប្រឌិត ជំរុញការលើកកម្ពស់ការយល់ដឹងប្រវត្តិសាស្ត្រ និងសេចក្ដីក្លាហានរបស់ពលរដ្ឋ

ដៃគូអនុវត្ត

សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់

ម្ចាស់ជំនួយ

EU តាមរយៈ UNOPS, វិទ្យាស្ថានអាល្លឺម៉ង់ សម្រាប់ទំនាក់ទំនងបរទេស (IFA)

- គម្រោងសហគមន៍សារព័តមាន៖ ប្រជាជនចាម និងខ្មែរក្រហម

ដៃគូអនុវត្ត

សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់

ម្ចាស់ជំនួយ

ស្ថានទូតស្វីសនៅទីក្រុងបាងកក, មូលនិធិ Heinrich Böll

- រឿងរ៉ាវដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមនៅក្នុងសំណុំរឿង ០០២/០២ នៅ អ.វ.ត.ក ដែលពុំធ្លាប់បានឮ

ដៃគូអនុវត្ត

CHRAC

ម្ចាស់ជំនួយ

មូលនិធិ Heinrich Böll

- ពេលត្រូវចងចាំ៖ ការប្រលងនិពន្ធចម្រៀងឆ្នាំ២០១៦ មានការចូលរួមពីយុវជននៅក្នុងការផលិតចម្រៀងអំពីការចងចាំនៅកម្ពុជា

ដៃគូអនុវត្ត

YRDP

ម្ចាស់ជំនួយ

GIZ-CPS

- ការចូលមើលកំណត់ហេតុតុលាការនៃការជំណុំជម្រះតុលាការខ្មែរក្រហម និងសម្ភារដើមបណ្ដឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារពាក់ព័ន្ធនឹង អ.វ.ត.ក (LDC)

ដៃគូអនុវត្ត

ទីស្ដីការគណៈរដ្ឋមន្ត្រីនៃ RGC

ម្ចាស់ជំនួយ

RGC, ជាមួយនឹងការសាងសង់ដែលឧបត្ថម្ភដោយស្ថានទូតជប៉ុន

## ● ការលើកកម្ពស់ការព្យាបាលរបួសផ្លូវចិត្តនៅកម្ពុជា និងការផ្សះផ្សាតាមរយៈការអន្តរាគមន៍ចិត្តសង្គម

| ដៃគូអនុវត្ត | ម្ចាស់ជំនួយ |
|---|---|
| TPO | USAID |

## ● ការអប់រំច្បាប់ និងពលរដ្ឋ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិភាគតិច

| ដៃគូអនុវត្ត | ម្ចាស់ជំនួយ |
|---|---|
| អង្គការសិទ្ធិជនជាតិភាគតិច | GIZ-CPS |

## ● ការលើកកម្ពស់សុខមាលភាពសុខភាពផ្លូវចិត្ត និងការកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការផាត់ចោលនៅក្នុងសង្គម របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងមនុស្សចាស់ងាយរងគ្រោះផ្សេងទៀតនៅកម្ពុជា [ទទួលស្គាល់មួយផ្នែក]

| ដៃគូអនុវត្ត | ម្ចាស់ជំនួយ |
|---|---|
| HelpAge Cambodia | EU តាមរយៈ UNOPS, កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ស្វីស |

VSS ក៏បានអនុវត្តវិធានការក្រៅប្រព័ន្ធតុលាការមួយចំនួនដូចមានចែងក្នុងវិធានផ្ទៃក្នុង។ វិធានការទាំងនេះគឺជាគំនិតផ្ដួចផ្ដើម និងកម្មវិធីដែលត្រូវបានកំណត់ និងអនុវត្តសម្រាប់ផលប្រយោជន៍ទូលំទូលាយជូនជនរងគ្រោះក្នុងរបបខ្មែរក្រហម ហើយត្រូវបានអនុវត្តនៅខាងក្រៅកិច្ចដំណើរនីតិវិធីតុលាការរបស់ អ.វ.ត.ក។ ដូច្នេះ វាខុសដោយឡែកពីគម្រោងសំណងស្នើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានអនុម័ត ដោយអង្គជំនុំជម្រះសាលាដំបូងនៅពេលសម្រេចសាលក្រមក្នុងសំណុំរឿង។

គម្រោងមួយ "ការលើកកម្ពស់សមភាពយេនឌ័រ និងការកែលម្អលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី និងអំពើហិង្សាយេនឌ័រ (GBV) ចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម" អនុវត្តពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩។ គម្រោងនេះត្រូវបានអនុវត្តដោយ VSS ក្រោមកិច្ចសហការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ អង្គការ (TPO) និងត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុដោយមូលនិធិស្ម័គ្រចិត្ត អ.ស.ប ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។ គម្រោងនេះផ្ដោតលើសិទ្ធិទទួលបានយុត្តិធម៌ និងការចូលរួមរបស់ជនរងគ្រោះ អន្តរាគមន៍ផ្លូវចិត្ត ការលើកកម្ពស់ការយល់ដឹង និងការ កសាងសមត្ថភាពលើយេនឌ័រ។ ជារួម គម្រោងនេះបានជួយដើមបណ្ដឹងរដ្ឋប្បវេណីជាស្ត្រីចំនួន ២,២០០នាក់ និងអ្នករស់រានមានជីវិតពី GBV ផ្សេងទៀត ឱ្យចូលរួមក្នុងដំណើរការកាត់ក្ដីរបស់ អ.វ.ត.ក

បានផ្តល់ការព្យាបាលផ្លូវចិត្តដល់អ្នករស់រានមានជីវិតពី GBV ប្រហែល ៣០០នាក់ បានធ្វើសកម្មភាពផ្សព្វផ្សាយ និងអប់រំដល់មនុស្សរាប់ពាន់នាក់ ជាពិសេសក្មេងជំនាន់ក្រោយ និងផ្តល់ការបណ្តុះបណ្តាលស្តីពីការយល់ដឹងអំពីយេនឌ័រដល់មេធាវី មន្ត្រីច្បាប់ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលរាប់រយនាក់ ។

អ.វ.ត.ក ក៏បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាកាលពីឆ្នាំ២០១៤ ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីបង្កើតស្តូបអនុស្សាវរីយ៍ស្ថិតនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (TSGM) រំលឹកការចងចាំដល់ជនរងគ្រោះដែលបានស្លាប់នៅទីនោះក្នុងរបបខ្មែរក្រហម។ ស្តូបអនុស្សាវរីយ៍នេះត្រូវបានដាក់សម្ពោធកាលពីខែមីនា ឆ្នាំ២០១៥ ដោយទទួលថវិកាពីក្រសួងសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចអាល្លឺម៉ង់ និង GIZ តាមរយៈ VSS ។




សិក្ខាសាលា ស្តីពី សំណងសំរាប់ជនរងគ្រោះនៃរបបខ្មែរក្រហម នៅសណ្ឋាគារ សាន់វេ ភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៨។

[៣៣] Julian Poluda, Sineth Siv និង Sotheary Yim របាយការណ៍វាយតម្លៃចុងក្រោយ៖ ការលើកកម្ពស់សមភាពយេនឌ័រ និងការកែលម្អលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតជាស្ត្រី និងជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រក្រោមរបបខ្មែរក្រហម៖ ការវាយតម្លៃចុងក្រោយនៃគម្រោងយេនឌ័រក្រៅប្រព័ន្ធតុលាការរបស់ អ.វ.ត.ក (ដំណាក់កាលទី ២) (ខែកញ្ញា ឆ្នាំ២០១៩) VSS/ECCC អាចចូលមើលនៅលើគេហទំព័រដូចខាងក្រោម៖ http://www.eccc.gov.kh/sites/default/files/reports/UNTFVAW_Cambodia_VSS_TPO_Final%20Evaluation%20Report%207Oct2019.pdf

[៣៤] អ.វ.ត.ក សេចក្តីប្រកាសព័ត៌មាន៖ ពិធីសម្ពោធស្តូបសម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (ថ្ងៃទ២៤ ខែមីនា ឆ្នាំ២០១៥) អាចចូលមើលតាមរយៈ៖ https://www.eccc.gov.kh/sites/default/files/media/VSS%20Press%20Release%20TuolSleng%20Memorial%20EN.pdf

# ដំណើរដើមទង និងគោលបំណងនៃសិក្ខាសាលាស្តីពីជនរងគ្រោះ

តួនាទីដ៏លេចធ្លោនេះសម្រាប់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ពោលគឺចាប់ពីពេលពួកគេដាក់ពាក្យស្នើសុំរហូតដល់វិធានការសំណង និងវិធានការក្រៅប្រព័ន្ធតុលាការ គឺជាមូលដ្ឋានគ្រឹះសម្រាប់បន្តការងារគាំទ្រជនរងគ្រោះ នៅពេលដែលដំណើរការតុលាការបានខិតជិតមកដល់ទីបញ្ចប់ និងដំណាក់ការផ្លាស់ប្តូរឈានទៅចាប់ ផ្តើមអាណត្តិការងារដែលនៅសេសសល់របស់ អ.វ.ត.ក។ ដើម្បីអនុវត្តអាណត្តិដែលនៅសេសសល់ដូចមានចែងក្នុងកិច្ចព្រមព្រៀងបន្ថែម អ.វ.ត.ក បានបង្កើតដំណើរការមួយឈានដល់ការបង្កើតសិក្ខាសាលាស្តីពីជនរងគ្រោះ ដែលជាកម្មវត្ថុនៃរបាយការណ៍នេះ។ ដំណើរការនោះបានអនុវត្តតាមដំណាក់កាលមួយចំនួននៃការរៀបចំយ៉ាងប្រុងប្រយ័ត្ន ដើម្បីធានាបានទាំងតម្លាភាព និងការពិគ្រោះយោបល់ទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបានក្នុងដែនកំណត់នៃពេលវេលា និងធនធាន។ ក្រៅពីការធ្វើផែនការផ្ទៃក្នុង ការងារទីមួយក្នុងចំណោមការងារទាំងនេះគឺការរៀបចំរបាយការណ៍ជាមួយនឹងអនុសាសន៍ស្តីពីទិដ្ឋភាពនៃដំណាក់កាលដែលនៅសេសសល់ ដែលនឹងអនុវត្តចំពោះបញ្ហាទាក់ទងនឹងជនរងគ្រោះ។

ដូច្នេះ ក្នុងពេលរំពឹងទុកនៃការបញ្ចប់ការងារតុលាការនៅ អ.វ.ត.ក ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ចៅក្រម អ.វ.ត.ក ពីររូប គឺចៅក្រម យូ ឧត្តរ៉ា និងចៅក្រម Claudia FENZ ត្រូវបានតែងតាំងដោយការិយាល័យរដ្ឋបាលកាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ ជា "សហចៅក្រមរបាយការណ៍អំពីមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជន រងគ្រោះ"។ នៅក្នុងផ្នែកពាក់ព័ន្ធ អាណត្តិរបស់សហចៅក្រមគឺដាក់ចេញអនុសាសន៍ស្តីពីសកម្មភាព និងគំនិតផ្តួចផ្តើមនៅក្នុងដំណាក់កាលដែលនៅសេសសល់ នៃ អ.វ.ត.ក ដែល "មានលក្ខណៈសមស្រប និងអត្ថន័យសម្រាប់ជន រងគ្រោះស្ថិតក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ"។ ដោយពិនិត្យលើលក្ខណៈទូទៅ ការបង្កើតយន្តការបែបបទនេះបានធ្វើឱ្យចៅក្រមទាំងពីរមានសេរីភាពជំជេងក្នុងការអនុវត្តអាណត្តិការងារនេះ។ មិនតែប៉ុណ្ណោះ ការងារនេះទុកជូនចៅក្រមជាអ្នកកំណត់ពាក្យគន្លឹះ ដូចជា "ជនរងគ្រោះ" ឬ "គំនិតផ្តួចផ្តើម"។ តាមពិត ពាក្យទាំងនេះត្រូវបានកំណត់ដោយចៅក្រមក្នុងវិធីមួយដើម្បីបង្កើតឱកាសទូលំទូលាយសម្រាប់ CSOs ចូលរួមនៅក្នុងដំណាក់កាលដែលនៅសេសសល់។ ពាក្យ "ជនរងគ្រោះ" ដូចបានបញ្ជាក់នៅក្នុងការអញ្ជើញដាក់សំណើ គឺត្រូវ "បកស្រាយក្នុងន័យទូលាយ" និង "មិនកម្រិតកំណត់ត្រឹមតែអ្នកដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់នៅចំពោះមុខ អ.វ.ត.ក ឡើយ" ។

៣៥ អ.វ.ត.ក សហចៅក្រមរបាយការណ៍៖ ការអំពាវនាវឱ្យមានការចូលរួមចំណែកជាគំនិត (ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១) ដែលអាចចូលមើលនៅលើគេហទំព័រ <https://www.eccc.gov.kh/sites/default/files/publications/Co-RapporteursVictimsCallForContribution_compressed.pdf>. p. 2. ទំព័រ ២។

៣៦ ដូចខាងលើ ទំព័រ ២។

ដើម្បីអនុវត្តអាណត្តិរបស់ខ្លួន សហចៅក្រមរបាយការណ៍កាលពីខែកញ្ញា ឆ្នាំ២០២១ បានអញ្ជើញអង្គការសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ និងបុគ្គលនានាឱ្យធ្វើការដាក់សំណើ ដើម្បីសរុបរបាយការណ៍របស់ពួកគេ និងដើម្បីផ្តល់ជាចំណុចចាប់ផ្តើមសម្រាប់សំណើគម្រោងជាក់លាក់ ដែលអាចអនុវត្តតាមរយៈដំណើរការនេះដូចបានលើកឡើងលម្អិតនៅក្នុងអនុសាសន៍របស់ខ្លួន។ បញ្ហាប្រឈមចំពោះអ្នកដាក់សំណើ គឺត្រូវពន្យល់អំពីរបៀបដែលសំណើរបស់ពួកគេនឹង "មានអត្ថន័យ និងជាជំនួយរយៈពេលវែងដោយរបៀបណាចំពោះបណ្តឹងរដ្ឋប្បវេណីជនរងគ្រោះនៃរបបខ្មែរក្រហម និងសាធារណជនទូទៅ" ។ ក្រុមទាំងបី ដំណើរការបានល្អហួសពីវិសាលភាពជាក់ស្តែងស្តីពី "ជនរងគ្រោះ" ដែលបានលើកឡើងនៅក្នុងអាណត្តិការងារ និងហួសវិសាលភាពនៃពាក្យពេចន៍កាន់តែរឹតត្បិតដូចមានចែងនៅក្នុងមាត្រា ២ នៃឧបសម្ព័ន្ធដែលបានយោងខាងលើ។ ដោយសារមានការខិតខំពីសហចៅក្រមរបាយការណ៍ និងដើម្បីដាក់បញ្ចូលសង្គមស៊ីវិលតាមរយៈការស្នើសុំការបញ្ចូនសំណើ សហចៅក្រមបានបំពេញការងារនេះក្នុងលក្ខណៈមួយដែលអាចផ្តល់នូវក្របខ័ណ្ឌដ៏រឹងមាំ ដែលអាចមានសារៈសំខាន់យូរអង្វែង មិនត្រឹមតែសម្រាប់ប្រជាជនកម្ពុជាពីមួយជំនាន់ទៅមួយជំនាន់ ដែលបានស៊ូទ្រាំនឹងទុក្ខវេទនាបណ្តាលមកពីរបបខ្មែរក្រហម ប៉ុន្តែក៏សម្រាប់គ្រួសាររបស់ពួកគេ និងសង្គមកម្ពុជាជារួមផងដែរ។

ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួម និងដើម្បីឱ្យវិសាលភាពនៃសំណើដែលទំនងបានដាក់កាន់តែមានភាពច្បាស់លាស់ សហចៅក្រមរបាយការណ៍បានរៀបរាប់កត្តាមួយចំនួនដែលអ្នកដាក់សំណើ "អាចគិតពិចារណា"។ សូម្បីការពិចារណាត្រួសៗអំពីកត្តានានា ក៏បានបង្ហាញអំពីវិធីដែលចៅក្រមបានបើកទ្វារចំហឱ្យមានការចូលរួមពេញលេញលើការងារកេរដំណែលនៃរបបខ្មែរក្រហម ដោយហេតុថាវាមានឥទ្ធិពលដល់ប្រជាជនកម្ពុជា។ កត្តាដែលត្រូវចងចាំរួមមាន៖

**វិសាលភាពនៃហេតុការណ៍ និងលក្ខណៈនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត ដែលប៉ះពាល់ទៅលើ ប្រជាជនភាគច្រើននៅពេលនោះ ហើយដែលផលវិបាកនៃឧក្រិដ្ឋកម្ម នោះ នៅតែបន្តមានក្នុងអារម្មណ៍របស់ពួកគាត់មកទល់បច្ចុប្បន្ន ។ ការពិតដែលថាជាងពាក់កណ្តាលនៃប្រជាជនកម្ពុជាបច្ចុប្បន្ន គឺកើតក្រោយហេតុការណ៍ទាំងនោះ។ អត្ថិភាពនៃគម្រោងដែលអាចបង្កើតឡើង រួមទាំងគម្រោងដែលបានអនុវត្តរួចហើយថា ជាការផ្តល់សំណង និងវិធានការក្រៅផ្លូវតុលាការ។ រយៈពេលដំបូងសម្រាប់មុខងារដែលនៅសេសសល់ គឺប្រមើលទុកថាមានរយៈពេលបីឆ្នាំ។**

ក្នុងចំណោមចំណុចផ្សេងទៀតដែលលេចធ្លោចេញពីការបង្កើតនេះគឺការរួមបញ្ចូលសំណងដែលមានស្រាប់។ ក្នុងករណីចង់គូសបញ្ជាក់ និងពង្រីកបន្ថែមនូវទំហំនៃសំណើទៅតាមការចង់បាន ការអំពាវនាវឱ្យដាក់សេចក្តីសន្និដ្ឋានលើកឡើងបន្ថែមថា "ក្រុមគោលដៅ

នៃគំនិតផ្តួចផ្តើម រួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែជនរងគ្រោះផ្ទាល់ និងកូនចៅរបស់ពួកគេ គ្រូបង្រៀន សិស្ស និស្សិតជំនាញផ្សេងៗគ្នា ទាំងជាតិ និងអន្តរជាតិ សាធារណជនទូទៅ និងប្រព័ន្ធផ្សព្វផ្សាយ" ។ ពាក្យពេចន៍នេះបង្ហាញក្រុមចំនួនបី (សង្គមស៊ីវិល ជនរងគ្រោះ និងសាធារណជន) ដែលបានលើកឡើងពីមុននៅក្នុងការអំពាវនាវឱ្យដាក់សំណើ និង ជាពិសេសបញ្ជាក់យ៉ាងច្បាស់ថា ស្ថាប័នអប់រំជាតិ និងអន្តរជាតិ ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានរួមបញ្ចូលនៅក្នុងសកម្មភាពដែលនៅសេសសល់ដូចបានគ្រោងសម្រាប់ជនរងគ្រោះ។

ទោះបីសំណើ និងរបាយការណ៍របស់សហចៅក្រមរបាយការណ៍នឹងយកមកពិចារណាលម្អិតខាងក្រោមក៏ដោយ ក្របខ័ណ្ឌទូលំទូលាយដែលបង្កើតឡើងដោយសហចៅក្រមរបាយការណ៍ ដែលបានជូនដំណឹងអំពីការរចនារៀបចំសិក្ខាសាលាស្តីពីជនរងគ្រោះ នឹងត្រូវពន្យល់ដូចទៅ។

របាយការណ៍របស់សហចៅក្រមរបាយការណ៍បានដាក់ជូនកាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១។ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២២ អ.វ.ត.ក សហចៅក្រមរបាយការណ៍ស្តីពីមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ បានចេញផ្សាយរបាយការណ៍ពិគ្រោះយោបល់អំពីមុខងារដែលនៅសេសសល់ទាក់ទងនឹងជនរងគ្រោះ។ របាយការណ៍ពិគ្រោះយោបល់ រួមជាមួយនឹងឧបសម្ព័ន្ធដែលដាក់បញ្ចូលការរួមចំណែកពីភាគីពាក់ព័ន្ធ អាចទទួលបានពេញលេញតាមរយៈតំណភ្ជាប់ក្នុងជើងទំព័រ ។ សំណើសុំដាក់ជូនសហចៅក្រមរបាយការណ៍ ក៏ត្រូវបានពិភាក្សាលម្អិតនៅក្នុងរបាយការណ៍នេះនាពេលខាងមុខ ក្នុងផ្នែកទី III.១ ហើយត្រូវបានដាក់ភ្ជាប់ទាំងស្រុងជាឧបសម្ព័ន្ធនៅក្នុង របាយការណ៍ III ពោលគឺ ឧបសម្ព័ន្ធ VI។

ក្នុងចំណោមករណីផ្សេងទៀត របាយការណ៍ប្រឹក្សាយោបល់បានអំពាវនាវឱ្យ អ.វ.ត.ក ចូលរួមកិច្ចសន្ទនាជាមួយអ្នកពាក់ព័ន្ធ។ អ.វ.ត.ក បានទទួលយកអនុសាសន៍របស់សហចៅក្រមរបាយការណ៍ ដោយបានសម្រេចរៀបចំសិក្ខាសាលាស្តីពីជនរងគ្រោះដែលបានប្រព្រឹត្តទៅកាលពីខែឧសភា ឆ្នាំ២០២២។ ការរចនារៀបចំសិក្ខាសាលានេះ ត្រូវបានលើកឡើងនៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍ និងឯកសារដែលសហចៅក្រមរបាយការណ៍បានទទួល បន្ទាប់ពីបានអំពាវនាវឱ្យដាក់សំណើ។ ដើម្បីផ្តល់ជាតុចូលឯករាជ្យសម្រាប់ការបង្កើតរៀបចំគ្រោង សិក្ខាសាលា និងរបៀបវារៈ អ.វ.ត.ក បានទទួលពាក្យសុំឱ្យមានទីប្រឹក្សាជំនាញចំនួនបីរូប៖ អ្នកសម្របសម្រួល អ្នកចាត់ចែង និងអ្នកជួយសម្រួលការងារ (សូមមើលឧបសម្ព័ន្ធ II ស្តីពីការអំពាវនាវដំបូងសុំការបង្ហាញចំណាប់អារម្មណ៍លើមុខតំណែងទាំងបីនេះ)។ ជាលទ្ធផលនៃការបើកទទួលទទួលពាក្យសុំដោយចំហ David Cohen, Daniel Mattes និង Sangeetha Yogendran ត្រូវបានជ្រើសរើសសម្រាប់មុខតំណែងទាំងបីនេះ។ អ្នកចាត់ចែងគឺលោក Daniel Mattes ទទួលខុសត្រូវចម្បងលើការរៀបចំសិក្ខាសាលាប្រចាំថ្ងៃ ទាក់ទងជាមួយរដ្ឋបាល អ.វ.ត.ក បន្តពិគ្រោះយោបល់ជាមួយ NGOs ដើមបណ្តឹងរដ្ឋប្បវេណី ក្រុម និងបុគ្គលផ្សេងទៀតដែលគ្រោងនឹងចូលរួម។ អ្នកជួយសម្រួលគឺ លោកស្រី Sangeetha Yogendran ផ្អែកតាមបទពិសោធន៍ជំនាញជាមួយសង្គមស៊ីវិលកម្ពុជា និងដើម បណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ក៏បានចូលរួមផុសផុលក្នុងដំណើរការរៀបចំ និងមើលការខុសត្រូវក្រុមអ្នកជួយសម្រួលការងារចំនួនប្រាំបីនាក់ផ្សេងទៀត ដែលដឹកនាំការពិភាក្សាក្រុមក្នុងអំឡុងពេលសិក្ខាសាលា។ នៅដំណាក់កាលនេះ អ្នកសម្របសម្រួលគឺលោក David Cohen បានចូលរួមជាចម្បងក្នុងការពិភាក្សាអំពីការកំណត់របៀបវារៈ ការជ្រើសរើសវាគ្មិនសំខាន់ៗ និង

៣៧ ដូចខាងលើ ទំព័រ ៣។

៣៨ ចៅក្រម យូ ឧត្តារ៉ា និង Claudia Fenz របាយការណ៍ប្រឹក្សាយោបល់៖ សកម្មភាពទាក់ទងនឹងជនរងគ្រោះនៃ អ.វ.ត.ក ក្នុងដំណាក់កាលដែលនៅសេសសល់ (ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១) អ.វ.ត.ក អាចចូលមើលបានតាមរយៈ៖ <https://eccc.gov.kh/sites/default/files/publications/EN-Advisory-Report-2022_web_2.pdf>.

ការកែលម្អគោលដៅនៃសិក្ខាសាលាដែលបានកំណត់ និងរិះរកវិធីធ្វើយ៉ាងណាឱ្យ សម្រេចការងារទាំងនេះបានល្អបំផុត។

គោលបំណងធំនៃសិក្ខាសាលាគឺដើម្បីអនុវត្តអនុសាសន៍របស់សហចៅក្រមរបាយការណ៍សំដៅបើកឱ្យមានកិច្ចសន្ទនាជាមួយអ្នកពាក់ព័ន្ធអំពីការចូលរួមរបស់ពួកគេក្នុងដំណាក់កាលដែលនៅសេសសល់ នៃ អ.វ.ត.ក ទាក់ទងនឹងជនរងគ្រោះដូចដែលបានកំណត់ខាងលើ។ ក្របខ័ណ្ឌនៃការចូលរួមបែបនេះ គឺជាលក្ខខណ្ឌនៃអាណត្តិការងារដែលត្រូវបានពិភាក្សារួចហើយ។ បញ្ហាប្រឈមសម្រាប់អ្នករៀបចំគឺត្រូវបង្កើតក្របខ័ណ្ឌដែលសមស្របតាមដែនកំណត់នៃអាណត្តិការងារ ដូចបានបកស្រាយដោយសហចៅក្រមរបាយការណ៍ ប៉ុន្តែត្រូវជានាឱ្យសង្គមស៊ីវិល និងដើមបណ្ដឹងរដ្ឋប្បវេណី ចូលរួមឱ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យសំឡេងទាំងអស់ ក្រុមពាក់ព័ន្ធ ភាគីដែលចាប់អារម្មណ៍ ទាំងជាតិ និងអន្តរជាតិ បានឮនៅក្នុងសំណើដែលពួកគេចូលរួមលើកឡើង។ គោលដៅរួមគឺដើម្បីលើកទឹកចិត្ត និងសម្រួលដល់ការបង្កើត សំណើគម្រោង និងគំនិតផ្ដួចផ្ដើម ឱ្យបានសកម្ម និងក្នុងន័យស្ថាបនាដែលអាចកំណត់អត្តសញ្ញាណតម្រូវការ និងឱកាសសំខាន់បំផុតសម្រាប់សកម្មភាពទាក់ទងនឹងជនរងគ្រោះ និងផ្តល់នូវវេទិកាមួយ ដែលសំណើជាក់ស្តែង និងមានថវិកា អាចបង្កើតឡើងសមស្របបំផុត។ គោលដៅរួមគ្នាគឺដើម្បីរៀបចំសិក្ខាសាលាតាមរបៀបមួយ ដែលក្រុមភាគីពាក់ព័ន្ធអាចធ្វើការរួមគ្នាជាជាងប្រកួតប្រជែងគ្នាក្នុងការកំណត់ អត្តសញ្ញាណតម្រូវការ និងបង្កើតសំណើដើម្បីឆ្លើយតបទៅនឹងសំណើទាំងនោះ។

អនុសាសន៍របស់សហចៅក្រមរបាយការណ៍អំពី "កិច្ចសន្ទនា" ត្រូវបានបកស្រាយយ៉ាងទូលំទូលាយថារួមបញ្ចូលកិច្ចសន្ទនាប្រកបដោយផ្លែផ្កាជាមួយក្រុមភាគីពាក់ព័ន្ធ ក៏ដូចជាកិច្ចសន្ទនាជាមួយ អ.វ.ត.ក និងជាមួយម្ចាស់មូលនិធិសក្តានុពល ដែលតំណាងដោយស្ថាប័ន RGC អង្គការផ្តល់មូលនិធិអន្តរជាតិ និងស្ថានទូតតំណាងរដ្ឋជាសមាជិក នៃក្រុមប្រទេសផ្តល់ជំនួយ ដែលជា "មិត្តនៃ អ.វ.ត.ក"។ ដើម្បីឱ្យកិច្ចសន្ទនា និងសិក្ខាសាលាទាំងមូលមានលក្ខណៈស្ថាបនា និងប្រកបដោយផ្លែផ្កាតាមដែលអាចធ្វើទៅបាន អ្នកសម្របសម្រួល អ្នកចាត់ចែង និងអ្នកសម្រួលការងារ បានធ្វើការយ៉ាងជិតស្និទ្ធជាបន្តបន្ទាប់ជាមួយការិយាល័យរដ្ឋបាល អ.វ.ត.ក។ ការងារនេះគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃការរៀបចំ និងការរចនា រួមទាំងការជ្រើសរើសទីកន្លែង ការរៀបចំកន្លែងអង្គុយ ដែលអំណោយផលបំផុតសម្រាប់ការពិភាក្សា ប្រធានបទសំខាន់ៗដើម្បីរៀបចំក្រុមអ្នកចូលរួម វាគ្មិនសំខាន់ៗ វិធីក្នុងការចូលរួមជាមួយ ភាគីពាក់ព័ន្ធពីខាងក្រៅ (ឧ. មន្ត្រីរដ្ឋាភិបាល ស្ថានទូត។ល។) ជាដើម។ ការសម្រេចចិត្តរបស់ អ.វ.ត.ក ឱ្យភាគីខាងក្រៅចូលរួម ដើម្បីដឹកនាំការរៀបចំ និងរចនាសិក្ខាសាលានេះ បានជំរុញឱ្យមានការពិចារណា និងពិភាក្សាយ៉ាងមុតមាំ អំពីវិធីណាដែលល្អបំផុតដើម្បីសម្រេចបាននូវគោលដៅដូចបានកំណត់ និងបំពេញអាណត្តិការងារនៃការផ្សព្វផ្សាយព័ត៌មានដោយមានការចូលរួម និងជាប្រយោជន៍សម្រាប់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងសាធារណជន ដូចបានបកស្រាយ និងកំណត់ក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍។

តាមទស្សនៈយល់ឃើញនេះ សិក្ខាសាលាបានផ្តល់ឱកាសបន្តការចូលរួមស៊ីជម្រៅពីមុនរវាង អ.វ.ត.ក ជាមួយជនរងគ្រោះ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសកម្មភាពជាច្រើនឆ្នាំជុំវិញការផ្តល់សំណង ការចុះផ្សព្វផ្សាយ និងការការពារសាក្សី និងជនរងគ្រោះ។

វិសាលភាពនៃសំណងដែលបានអនុវត្តដោយផ្អែកលើមូលដ្ឋាននៃគម្រោងដែលទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១, ០០២/០១, និង ០០២/០២ ហើយភាពស្រដៀងគ្នានៅក្នុងសិក្ខាសាលានឹងត្រូវបានពិចារណាដូចខាងក្រោម។ ក្រៅពីគម្រោងសំណងរបស់ អ.វ.ត.ក និងការប្រចាប់បញ្ចូលជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងដំណើរការនីតិវិធីរបស់ខ្លួន អ្វីៗដែលប្លែកក្នុងចំណោមសាលាក្តីមុនៗគឺ អ.វ.ត.ក ចាប់តាំងពីដំណាក់កាលដំបូងបំផុត បានបង្កើតកម្មវិធីដ៏មានប្រសិទ្ធភាពបំផុតមួយ គឺការចុះផ្សព្វផ្សាយនៅតាមសហគមន៍ ដែលការងារនេះមិនទាន់មានតុលាការអន្តរជាតិ ឬ សាលាក្តីចម្រុះណាមួយធ្វើបាននោះទេ។ សាធារណជនជាង ៥០០,០០០នាក់ បានចូលរួមសវនាការសាធារណៈ ទស្សនកិច្ចសិក្សា ឬ បឋកថានៅតាមសាលារៀន ដែលរៀបចំដោយផ្នែកកិច្ចការសាធារណៈរបស់ អ.វ.ត.ក (PAS) ក្នុងអំឡុងពេលដំណើរការកិច្ចនីតិវិធីសវនាការនៅ អ.វ.ត.ក ។ ដូច្នេះ អ.វ.ត.ក មានបទពិសោធន៍ច្រើនលើការងារផ្សព្វផ្សាយកិច្ចដំណើរការនីតិវិធីរបស់ខ្លួនដល់សាធារណជនកម្ពុជា និងការចូលរួមជាមួយដើមបណ្តឹងរដ្ឋប្បវេណី។

ដោយសារសកម្មភាពជាច្រើននៅក្នុងវិស័យទាំងនេះត្រូវបានអនុវត្តតាមរយៈការសហការ និងភាពជាដៃគូ រវាង អ.វ.ត.ក និងអង្គការសង្គមស៊ីវិល សិក្ខាសាលាអាចទទួលបានអត្ថប្រយោជន៍ និងពឹងផ្អែកលើបទពិសោធន៍ក្រាស់ក្រែលក្នុងវិស័យពាក់ព័ន្ធ។ អ្នកសម្របសម្រួល អ្នកចាត់ចែង និងអ្នកជួយសម្រួលការងារ បានចូលរួមយ៉ាងច្រើននៅក្នុងសកម្មភាពបែបនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ដូច្នេះវាផ្តល់នូវមូលដ្ឋានរឹងមាំសម្រាប់កិច្ចសហប្រតិបត្តិការលើការរចនាសិក្ខាសាលា និងការអនុវត្តការងារ។ លទ្ធផលនៃកិច្ចសហប្រតិបត្តិការនេះ ត្រូវបានឆ្លុះបញ្ចាំងលម្អិតនៅក្នុងការរចនា និងរបៀបវារៈនៃសិក្ខាសាលាក៏ដូចជានៅក្នុងកិច្ចដំណើរការ ដែលយើងនឹងលើកឡើងក្នុងពេលនេះតែម្តង។

[៣៩] អ.វ.ត.ក Public Affairs Outreach Figures ២០០៩ - ២០១៧ (៣០ September ២០១៧), អ.វ.ត.ក អាចចូលមើលបានតាមរយៈ៖ <https://www.eccc.gov.kh/sites/default/files/Outreach%20statestics%20as%20of%20September%202017. pdf>.

# II.

# សិក្ខាសាលាខែឧសភា ឆ្នាំ២០២២ ស្តីពីជនរងគ្រោះ៖ ការរចនា និងសកម្មភាព


០៦៤ ដំណាក់កាលដំបូង៖ សេចក្តីណែនាំ កាលវិភាគ ទីតាំង ផែនការត្រៀមបម្រុង កូវីដ-១៩

០៧០ ការពិគ្រោះយោបល់របស់អ្នកសម្របសម្រួលព្រឹត្តិការណ៍នៅមុនសិក្ខាសាលា

០៨១ លេខាធិការដ្ឋានសិក្ខាសាលា និងក្រុមការងារគាំទ្រ អ.វ.ត.ក

០៨៥ របៀបវារៈ និងអ្នកចូលរួម

០៩០ ក្រុមពិភាក្សា

០៩៥ វាគ្មិនកិត្តិយស



ដូចបានពិភាក្សារួចមកហើយ ការអំពាវនាវរបស់សហចៅក្រមរបាយការណ៍ ចៅក្រម យូ ឧត្តារ៉ា និង ចៅក្រម Claudia Fenz ឱ្យ អ.វ.ត.ក រៀបចំដំណើរការប្រឹក្សាយោបល់ដោយបើកចំហរដើម្បីដាក់ចេញសកម្មភាពទាក់ទងនឹងជនរងគ្រោះនៅមុនអាណត្តិការងារដែលនៅសេសសល់ខិតជិតចូលមកដល់ បាននាំឱ្យ អ.វ.ត.ក សម្រេចចិត្តរៀបចំសិក្ខាសាលារយៈពេលបីថ្ងៃជាមួយជនរងគ្រោះ តំណាងរបស់ពួកគេនៅក្នុងសង្គមស៊ីវិល និងបន្ទប់សវនាការ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។ អ.វ.ត.ក បានកំណត់ថា កិច្ចព្រមព្រៀងបន្ថែមនេះប្រគល់ភារកិច្ចឱ្យខ្លួ នឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម និងផ្សព្វផ្សាយព័ត៌មានអំពីដំណើរការយុត្តិធម៌អន្តរកាលដល់សាធារណជន។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងជាចំណុចចាប់ផ្តើមសម្រាប់ដំណើរការបង្កើតកម្មវិធីថ្មីៗ និងពង្រឹងកម្មវិធីដែលមានស្រាប់ ឬកម្មវិធីពីមុនដោយផ្តោតលើតម្រូវការរបស់ជនរងគ្រោះ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធានាការរៀបចំព្រឹត្តិការណ៍មិនឱ្យមានភាពលំអៀង និងដោយបើកចំហ អ.វ.ត.ក បានជួលទីប្រឹក្សាជំនាញខាងក្រៅចំនួនបីនាក់ ដើម្បីរចនាកម្មវិធី រៀបចំព្រឹត្តិការណ៍ដោយខ្លួ នឯង និងរាយការណ៍អំពីសំណើ និងលទ្ធផល។ ទីបំផុត អ.វ.ត.ក បានរៀបចំ "សិក្ខាសាលាស្តីពីជនរងគ្រោះ និងការផ្សព្វផ្សាយរបាយការណ៍ប្រឹក្សាយោបល់ស្តីពីសកម្មភាពពាក់ព័ន្ធជនរងគ្រោះនៃ អ.វ.ត.ក ក្នុងដំណាក់កាលដែលនៅសេសសល់" ក្នុងរយៈពេលបីថ្ងៃពេញ ចាប់ពីថ្ងៃទី០៣ ដល់ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ នៅសណ្ឋាគារ Hyatt Regency ក្នុងរាជធានីភ្នំពេញ។

← ពិធីប្រកាសបើកសិក្ខាសាលាស្តីពីជនរងគ្រោះ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២។

# ដំណាក់កាលដំបូង៖ សេចក្ដីណែនាំ កាលវិភាគ ទីតាំង ផែនការត្រៀមបម្រុង កូវីដ-១៩

អ្នកចាត់ចែងសិក្ខាសាលា លោក Daniel Mattes បានចាប់ផ្ដើមធ្វើការពេញម៉ោងលើការងាររៀបចំព្រឹត្តិការណ៍នេះជាមួយការិយាល័យរដ្ឋបាលរបស់ អ.វ.ត.ក នៅថ្ងៃចុងក្រោយក្នុងខែកុម្ភៈ ឆ្នាំ២០២២។ លោកទទួលបានតុមួយនៅ អ.វ.ត.ក ការចូលមើលឯកសារជនជាន អ.វ.ត.ក ទាំងស្រុង និងការគាំទ្រពី អ.វ.ត.ក និង បុគ្គលិក UNAKRT ក្នុងគោលបំណងសម្របសម្រួលសិក្ខាសាលា។ ទោះបីជាមានមូលដ្ឋាននៅក្រៅប្រទេស អ្នកសម្របសម្រួល David Cohen និងអ្នកជួយសម្រួលការងារ Sangeetha Yogendran បានធ្វើទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអ្នកចាត់ចែងតាមប្រព័ន្ធអនឡាញ និងតាមរយៈការប្រជុំប្រចាំសប្តាហ៍ជាទៀងទាត់ជាមួយអ្នកចាត់ចែង សិក្ខាសាលា និងជាមួយការិយាល័យរដ្ឋបាល (OA) តំណាងដោយ Knut Rosandhaug ដែលជាអនុប្រធានការិយាល័យរដ្ឋបាល និង Milan Jovančević មន្ត្រីគ្រប់គ្រងកម្មវិធី។ កិច្ចប្រជុំបន្ថែមទៀតបានរៀបចំឡើងម្ដងម្កាលជាមួយភាគីជាតិនៃ OA ទោះបីជាភាគីជាតិបានបង្ហាញទស្សនៈយល់ឃើញជូនអ្នកចាត់ចែងតាមរយៈភាគីអន្តរជាតិនៃ OA រួចហើយក៏ដោយ។ អ្នកសម្របសម្រួល និងអ្នកចាត់ចែង បានចាប់ផ្ដើមការងារដោយផ្ទាល់នៅពេលមកដល់ រាជធានីភ្នំពេញមួយសប្ដាហ៍មុនពេលសិក្ខាសាលានៅដើមខែឧសភា។

ទោះបីជា OA នៅតែបន្តជាប់ពាក់ព័ន្ធនឹងការងារនេះតាមរយៈការប្រជុំសម្របសម្រួលជាទៀងទាត់ក៏ដោយ នៅដំណាក់កាលដំបូង យើងបានគូសបញ្ជាក់ម្ដងហើយម្ដងទៀតនាពេលក្រោយមកថា អ្នកសម្របសម្រួល និងអ្នកចាត់ចែងសិក្ខាសាលា (ជាពិសេស) ត្រូវមានកាព្វកិច្ចកំណត់ផែនការ និងព័ត៌មានលម្អិតទាំងអស់សម្រាប់ព្រឹត្តិការណ៍នេះ។ OA មិនដែលគៀបសង្កត់ ឬ បង្គាប់បញ្ជាមិនសមហេតុផលទាក់ទងនឹងការរចនា ឬ ការចាត់ចែងសិក្ខាសាលានោះទេ។ OA បានលើកឡើងម្ដងហើយម្ដងទៀតអំពីបំណងប្រាថ្នាចង់ឃើញតម្លាភាព និងភាពមិនលំអៀង នៅក្នុងការជួលទីប្រឹក្សាជំនាញខាងក្រៅមករៀបចំសិក្ខាសាលា។ OA គ្រប់គ្រងដំណើរការរដ្ឋបាល ថវិកា និងលទ្ធកម្មដោយខ្លួន ឯង។ ក៏ប៉ុន្តែ OA បានប្រគល់ការរៀបចំផែនការព្រឹត្តិការណ៍នេះទៅក្រុមហ៊ុនខាងក្រៅ ដោយសង្ឃឹមថា ភាពមិនលំអៀងតាមរយៈការធ្វើបែបនេះអាចឱ្យមាន "ការឯកភាព" កាន់តែច្រើនពីដៃគូសង្គមស៊ីវិលសំខាន់ៗ និងតំណាងជនរងគ្រោះ។ អ្នកសម្របសម្រួលសិក្ខាសាលា អ្នកចាត់ចែង និងអ្នកជួយសម្រួលការងារ (ចាប់ពីពេលនេះតទៅហៅថា "លេខាធិការដ្ឋាន") ពឹងផ្អែកលើបណ្ដាញរបស់ពួកគេក្នុងចំណោម

តួអង្គសង្គមស៊ីវិលដែលកំពុងធ្វើការអំពី អ.វ.ត.ក ហើយពួកគេចង់កសាងទំនុកចិត្តដែលបានបង្កើតឡើងនៅក្នុងទំនាក់ទំនងផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់ពួកគេ។ ការណែនាំពី OA គឺសាមញ្ញ៖ គោលដៅនៃព្រឹត្តិការណ៍នេះគឺដើម្បីបើក "ការពិភាក្សាដោយសេរី បើកចិត្ត ទូលាយ និងពិតប្រាកដ ដែលនឹងធ្វើឱ្យអ្នកចូលរួមគិត"។ គោលដៅគឺដើម្បី "រៀបចំសំឡេង" និង "មិនមែនជាការចម្រោះសម្លេងនោះទេ"។ មានការបញ្ជាក់យ៉ាងច្បាស់ថា អ្នកចូលរួមសិក្ខាសាលា មិនត្រូវបានចាត់ទុកជាភ្ញៀវនោះទេ ប៉ុន្តែជាអ្នកចូលរួមសកម្មដើម្បីចែករំលែកនៅក្នុងដំណើរការ និងធ្វើឱ្យសំឡេងរបស់ពួកគេបានឮនៅដំណាក់កាលដ៏សំខាន់នេះ។

OA ក៏បានស្នើប្រធានបទសំខាន់ៗចំនួនបីទាក់ទងនឹងជនរងគ្រោះ៖ ការទទួលស្គាល់ ការរំលឹកការចងចាំ និងការផ្សះផ្សា។ ការជំរុញប្រធានបទទាំងនេះសម្រាប់ការរចនាសិក្ខាសាលា បានបង្កើតនូវសំណួរមូលដ្ឋានមួយចំនួននៃការស៊ើបអង្កេតដែលលេខាធិការដ្ឋាននឹងទាញមកក្នុងការរៀបចំផែនការ និងការដំណើរការជាក់ស្តែងនៃសិក្ខាសាលា៖ ក្នុងការទទួលស្គាល់ការឈឺចាប់ និងជនរងគ្រោះ មានសំណួរនិយមន័យនៃស្ថានភាពជនរងគ្រោះ។ នៅក្នុងការផ្សះផ្សាក្នុងសង្គមសព្វថ្ងៃនេះ មានសក្តានុពលក្នុងការពិចារណាមិនត្រឹមតែរវាងសញ្ញាណប្រពៃណីរបស់ជនរងគ្រោះ និងអតីតជនល្មើសប៉ុណ្ណោះទេ ប៉ុន្តែក៏មាននៅក្នុងគ្រួសារ និងសហគមន៍ ឬគ្រប់ជំនាន់ផងដែរ។ ហើយជាមួយនឹងសកម្មភាពនៃការចងចាំ តើយើងអាចបង្ហាញប្រវត្តិសាស្ត្រលើសពី [តម្រូវការច្រើន] រចនាសម្ព័ន្ធរូបវន្តតែម្នាក់ឯង ឬរំលឹកអតីតកាលដោយមិនធ្វើឱ្យជនរងគ្រោះឈឺចាប់ឡើងវិញ ឬបង្ខំពួកគេឱ្យនៅតែជាប់គាំងក្នុងភាពវេទនាអតីតកាលរបស់ពួកគេ? ប្រធានបទសំខាន់ទាំងបីនេះ បានក្លាយជាការណែនាំសម្រាប់លេខាធិការដ្ឋានក្នុងការរៀបចំផែនការ និងសម្របសម្រួលព្រឹត្តិការណ៍នេះ។ ទោះបីជា OA បានលើកឡើងប្រធានបទទាំងបីដំបូងក៏ដោយ លេខាធិការដ្ឋានក៏ត្រូវបានផ្តល់សេរីភាពពេញលេញក្នុងការគូរលើប្រធានបទដែលសមស្រប។ ដូចនេះ មានការកំណត់ថា ព្រឹត្តិការណ៍ទាំងបីថ្ងៃនេះ មិនត្រូវបានបំបែកនៅក្រោមប្រធានបទនីមួយៗ ក្នុងចំណោមប្រធានបទទាំងបីនោះទេ ដោយសារតែលេខាធិការដ្ឋានយល់ថា គោលការណ៍ទាំងបីគឺជាប់ទាក់ទងគ្នា និងពាក់ព័ន្ធវិញទៅមក ហើយមិនចង់រារាំងការពិភាក្សារបស់អ្នកចូលរួមឱ្យផ្តោតលើតែគោលការណ៍មួយនៅក្នុងថ្ងៃនីមួយៗ។ ជាងនេះទៅទៀត ប្រធានបទទាំងនេះមានខ្លឹមសារអត្ថន័យជាក់លាក់ដែលអ្នកចូលរួមទាំងអស់ប្រហែលជាមិនយល់ព្រមដូចៗគ្នា។ ផ្ទុយទៅវិញ ប្រធានបទទាំងបីបានក្លាយជាចំណុចចាប់ផ្តើមសម្រាប់សិក្ខាសាលា ហើយត្រូវបានលើកឡើងក្នុងគ្រប់សុន្ទរកថា និងកិច្ចពិភាក្សាជាក្រុម។

ទាក់ទងនឹងរបាយការណ៍ចុងក្រោយនេះ លេខាធិការដ្ឋានត្រូវបានជូនដំណឹងនៅដើមដំបូងថា របាយការណ៍ចុងក្រោយនេះគួរតែផ្តល់ព័ត៌មានលម្អិតឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីជាព័ត៌មានសង្ខេបនៃសិក្ខាសាលា និងគម្រោងទាក់ទងនឹងជនរងគ្រោះ សម្រាប់យកទៅពិចារណានាពេលខាងមុខ។ យើងកំពុងរង់ចាំពិនិត្យលទ្ធផលដែលបានមកពីរបាយការណ៍ចុងក្រោយនេះ ប៉ុន្តែយើងសង្ឃឹមថា អ.វ.ត.ក រាជរដ្ឋាភិបាល និងម្ចាស់ជំនួយអន្តរជាតិយល់អំពីឱកាសបច្ចុប្បន្នក្នុងការកសាងបណ្តាញដែលបានបង្កើតឡើងនៅក្នុងសិក្ខាសាលា និងទស្សនៈអំពីកម្មវិធី ដែលបានរៀបរាប់លម្អិតនៅក្នុងរបាយការណ៍នេះ។

## កាលវិភាគ ០១

ដោយទទួលបានភារកិច្ចផ្ទួនៗចំនួនពីរ "ក្នុងការរៀបចំសំឡេង" និងការអភិវឌ្ឍគម្រោង "ឱ្យបានលម្អិតតាមដែលអាចធ្វើទៅបាន" ពីក្រុមជនរងគ្រោះ អង្គការសង្គមស៊ីវិល និងស្ថាប័នរដ្ឋជាច្រើនជាច្រើន យើងបានកំណត់ភ្លាមៗថា សិក្ខាសាលាត្រូវធ្វើឡើងរយៈពេលបីថ្ងៃ។ ការរៀបចំយូរថ្ងៃបែបនេះ គឺដោយសារត្រូវពេលពិភាក្សា និងបង្កើតគម្រោង និងពិនិត្យពិចារណាទស្សនៈពីគ្នាទៅវិញទៅមក និងពីវាគ្មិននៅក្នុងព្រឹត្តិការណ៍នេះ។ ការរៀបចំយូរបែបនេះទៀតសោតក៏ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សា ដោយត្រូវទុកចន្លោះពេលវេលានៅក្នុងកាលវិភាគសម្រាប់វាគ្មិនកិត្តិយស និងវាគ្មិនជំនាញជាច្រើននាក់ ថ្លែងសុន្ទរកថាទូទៅ បង្ហាញប្រធានបទជាក់លាក់ ឬ មតិយោបល់ក្នុងកម្មវិធីនេះ អំពីអាណត្តិការងារដែលនៅសេសសល់របស់តុលាការ។

ជាងនេះទៅទៀត អ្នករៀបចំបានកំណត់ថា សិក្ខាសាលានេះដើរតួជាថ្នាលថ្មីមួយសម្រាប់ដំណាក់កាលដែលនៅសេសសល់ ដើម្បីបម្រើគោលបំណងជានិមិត្តរូបដ៏សំខាន់មួយតាមបីទម្រង់ចាំបាច់ត្រូវផ្តល់ពេលវេលា និងទីកន្លែងគ្រប់គ្រាន់។ ទីមួយ សិក្ខាសាលានេះ គឺជាឱកាសមួយដើម្បីរំលេច និងអបអរសាទរការងារដែលជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកតំណាង ព្រមទាំងអ្នកតស៊ូមតិរបស់ពួកគេនៅក្នុងចំណោមអង្គការសង្គមស៊ីវិល សម្រេចបាននាពេលកន្លងមក ស្របជាមួយនឹងកិច្ចដំណើរការតុលាការរយៈពេលជាង ១៥ឆ្នាំ នៅ អ.វ.ត.ក។ ទីពីរ សិក្ខាសាលានេះគឺជាឱកាសដំបូងអាចឱ្យភាគីពាក់ព័ន្ធជាច្រើនចូលរួមជួបប្រជុំគ្នាដោយផ្ទាល់ម្តងទៀតនៅក្នុងសន្និសីទនេះបន្ទាប់ពីអាក់ខានរយៈពេលពីរឆ្នាំដោយសារជំងឺរាតត្បាតកូវីដ-១៩។ ចំណុចចុងក្រោយ ព្រឹត្តិការណ៍នេះគឺជាលើកទីមួយក្នុងប្រវត្តិសាស្រ្តរយៈពេល ១៥ឆ្នាំ ដែល អ.វ.ត.ក ខ្លួនឯងបានរៀបចំសិក្ខាសាលាសាធារណៈជាពិសេស ដោយផ្តោតលើតម្រូវការជនរងគ្រោះ និងគំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិល និងស្ថាប័នរដ្ឋ។

យើងក៏បានកំណត់ភ្លាមៗថា ព្រឹត្តិការណ៍នេះនឹងត្រូវធ្វើឡើងក្នុងសប្តាហ៍ដំបូងនៃខែឧសភា ឆ្នាំ២០២២ ដោយសារតែកាលវិភាគទំនេររបស់អ្នករៀបចំសិក្ខាសាលា និងដើម្បីរៀបចំព្រឹត្តិការណ៍នេះឱ្យបានមុនថ្ងៃបុណ្យជាតិកម្ពុជា នៅពាក់កណ្តាលខែឧសភា និងមុនកាលបរិច្ឆេទបោះឆ្នោតឃុំ-សង្កាត់នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២។ ដូច្នេះ សិក្ខាសាលានេះត្រូវបានកំណត់រយៈពេលបីថ្ងៃ ចាប់ពីថ្ងៃអង្គារ ទី០៣ ខែឧសភា ឆ្នាំ ២០២២ ដល់ ថ្ងៃព្រហស្បតិ៍ ទី០៥ ខែឧសភា ឆ្នាំ២០២២។ ដើម្បីជាការងារត្រៀម អ្នកសម្របសម្រួលបានកំណត់ថា របៀបវារៈមួយត្រូវដាក់ចេញផែនការលម្អិតឱ្យបានត្រឹមពាក់កណ្តាលខែមីនា បញ្ជីរាយនាមភ្ញៀវចូលរួមនឹងត្រូវពិនិត្យបញ្ចប់នៅចុងខែមីនា ហើយលិខិតអញ្ជើញឥស្សរជនជាតិ ឬ អន្តរជាតិ ត្រូវចេញឱ្យបាននៅដើមខែមេសា មុនថ្ងៃឈប់សម្រាកចូលឆ្នាំខ្មែរដែលមានរយៈពេលយូរថ្ងៃ។ លិខិតអញ្ជើញអ្នកចូលរួមផ្សេងទៀតត្រូវផ្ញើចេញតាមទម្រង់ឌីជីថលនៅចុងខែមេសា យ៉ាងយូរ បំផុត។

## ការជ្រើសរើសទីតាំង ០២

ដំណើរការលទ្ធកម្មដើម្បីជ្រើសរើសទីតាំងសិក្ខាសាលាបានចាប់ផ្តើមភ្លាមៗផងដែរ។ ជាក់ស្តែង អ្នកចូលរួមភាគច្រើននៅរាជធានីភ្នំពេញ ប៉ុន្តែមានអ្នកសង្កេតការណ៍ អ្នកតស៊ូមតិ និងអ្នកស្រាវជ្រាវជាយូរមកហើយ ដែលចាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍នេះមកពីប្រទេសក្រៅ។ ដូច្នេះ យើងបានសម្រេចថា ទីតាំងត្រូវបំពេញតាមស្តង់ដារអប្បបរមាសម្រាប់ល្បឿនអ៊ីនធឺណិត និងសមត្ថភាពបច្ចេកវិទ្យាព័ត៌មានដែលនឹងដំណើរការជាមួយឧបករណ៍អង្គភាពសោតទស្សន៍ (AV) និងអង្គភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) របស់តុលាការ។ ចំណុចសំខាន់មួយទៀតគឺផែនការត្រៀមបម្រុងចំពោះស្ថានភាពជំងឺរាតត្បាតកូវីដ-១៩ ដែលទោះបីជាវាមានភាពសភាពធូរស្រាលគួរច្រើននៅក្នុងប្រទេសកម្ពុជាគិតត្រឹមខែមីនា ឆ្នាំ២០២២ ដោយសារយុទ្ធនាការចាក់វ៉ាក់សាំងដ៏ជោគជ័យ

នៅក្នុងប្រទេសក៏ដោយ ក៏បញ្ហានេះនៅតែជាការទទួលខុសត្រូវមួយដដែលនៅពេលរៀបចំព្រឹត្តិការណ៍ទ្រង់ទ្រាយធំដោយផ្ទាល់ដែលមានរយៈពេលច្រើនថ្ងៃនៅក្នុងសាលបន្ទប់ប្រជុំបិទជិត។ ដោយយើងកំណត់ផែនការទទួលឥស្សរជនជាន់ខ្ពស់ដែលគ្រោងនឹងចូលរួមក្នុងសិក្ខាសាលានេះក្នុងនាមជាវាគ្មិនកិត្តិយស ឬ ថ្លែងសុន្ទរកថាគន្លឹះ (ក្នុងតួនាទីច្រើនទៀតដូចខាងក្រោម) យើងមើលឃើញច្បាស់ថា ការងារសុវត្ថិភាពនៅទីតាំងត្រូវវាយតម្លៃក្នុងអំឡុងពេលដំណើរការលទ្ធកម្មផងដែរ។ ក្រៅពីតម្រូវការចាំបាច់ទាំងនោះសម្រាប់ ICT និងសន្តិសុខ ទីតាំងក៏ត្រូវមានលទ្ធភាពទទួលអ្នកចូលរួមរហូតដល់ ១៥០នាក់ រួមទាំងមានអាហារ និងអាហារសម្រន់សម្រាប់សន្និសីទការងាររយៈពេលមួយថ្ងៃពេញផងដែរ។ នៅទីបំផុត យើងបានកំណត់ថា ការពិភាក្សាការងារជាក្រុមតូចៗនឹងត្រូវធ្វើឡើងនៅតាមតុក្នុងសាលតែមួយប្រើប្រាស់សម្រាប់វគ្គពេញអង្គដូចគ្នា ប៉ុន្តែក្នុងដំណាក់កាលរៀបចំផែនការលេខាធិការដ្ឋានបានពិចារណាអំពីតម្រូវការស្វែងរកទីតាំងដែលមាន "បន្ទប់ដាច់ដោយឡែក" ក្រៅពីសាលសន្និសីទធំ។ នៅទីបំផុត យើងបានកំណត់ថា សិក្ខាសាលាត្រូវធ្វើឡើងនៅរាជធានីភ្នំពេញ ដើម្បីធានាថា អ្នកចូលរួមអាចចូលរួមកម្មវិធីសិក្ខាសាលានេះបានពេញរយៈពេលបីថ្ងៃ។ អាស្រ័យហេតុនេះ លេខាធិការដ្ឋានបានកំណត់ថា បរិវេណសាលា អ.វ.ត.ក ដែលមានទីតាំងស្ថិតនៅឆ្ងាយរាជធានី ពុំសមស្របជាទីតាំងប្រជុំនោះទេ។

បន្ទាប់ពីលេខាធិការដ្ឋានស្រាវជ្រាវដំបូង ដំណើរការលទ្ធកម្ម UNAKRT បានចាប់ផ្តើមស្របតាមនីតិវិធី ស្តង់ដារប្រតិបត្តិការរបស់ខ្លួន។ នៅទីបំផុត យើងបានសម្រេចថា សណ្ឋាគារ Hyatt Regency Phnom Penh បានដាក់សំណើដេញថ្លៃល្អបំផុត និងបំពេញតាមតម្រូវការទាំងអស់ឆ្លើយតបទៅតាមលក្ខខណ្ឌ។ ដំបូង នៅពេលលេខាធិការដ្ឋានមានចម្ងល់អំពីសាលដ៏ប្រណិតថាតើអាចងងឹត ឬ អាចបំភិតបំភ័យអ្នកចូលរួមសិក្ខាសាលាដែរឬទេនោះ លេខាធិការដ្ឋានក៏បានឮពីអ្នកចូលរួមជាច្រើនថា Hyatt Regency ជាទីតាំងស្ថិតនៅកណ្តាលក្រុង ទើបបង្កើតថ្មី និង



អ្នកសម្របសម្រួល លោក ដេវីដ ជេ. ខូហិន ធ្វើបទបង្ហាញណែនាំពីកម្មវិធី នៅថ្ងៃទី១ នៃសិក្ខាសាលា។

មានគុណភាពសេវាជាទីដែលពួកគេចាប់អារម្មណ៍ចង់ចូលរួមសិក្ខាសាលារយៈពេលបីថ្ងៃ មិនមែនចង់ចូលរួមតែមួយថ្ងៃនោះឡើយ។ បរិវេណជុំវិញមានផ្ទះសំណាក់តម្លៃសមរម្យជាច្រើន ដែលអាចធានាថា អ្នកចូលរួមមកពីតាមបណ្តាខេត្តមកចូលរួមនៅរាជធានីភ្នំពេញ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីដែលមកចូលរួមក្រោមការចាត់ចែងដោយ អ.វ.ត.ក. អាចរកកន្លែងស្នាក់នៅតម្លៃសមរម្យ នៅជិតៗទីតាំងសិក្ខាសាលា។

ទីបំផុត សណ្ឋាគារ Hyatt គឺជាទីតាំងល្អបំផុតសម្រាប់សិក្ខាសាលាមួយនេះ៖ បុគ្គលិកសណ្ឋាគារជាច្រើននាក់យកចិត្តទុកដាក់នៅពេលយើងត្រូវការសេវានានា, ឧបករណ៍ ICT ម៉ាកថ្មីៗ ដែលមានគុណភាពខ្ពស់ អាចឱ្យ កម្មវិធីដំណើរការស្ទើរតែមិនមានភាពរអាក់រអួល (លើកលែងតែវគ្គចុងក្រោយនៅថ្ងៃបញ្ចប់) និងអាចបន្តការផ្សាយតាមប្រព័ន្ធអនឡាញ, ប្រព័ន្ធខ្យល់ចេញចូលថ្មីឱ្យបន្ទប់ស្អាត និងមានអនាម័យត្រឹមត្រូវ ក្នុងស្ថានភាពអំឡុងពេលមានជំងឺរាតត្បាតនេះ, ទីតាំងនៅក្បែរកន្លែងហូបអាហារសម្រន់ភោជនីយដ្ឋាន សណ្ឋាគារ និងបន្ទប់ទឹកអនុញ្ញាតឱ្យអ្នកចូលរួមវ័យចំណាស់មិនចាំបាច់ដើរឆ្ងាយពីកន្លែងរៀបចំព្រឹត្តិការណ៍នោះឡើយ ហើយសាលសន្និសីទបានផ្តល់កន្លែងគ្រប់គ្រាន់សម្រាប់ការរក្សាគម្លាតសមស្រប សម្រាប់ប្តូរទម្រង់កន្លែងអង្គុយពីវគ្គពេញអង្គទៅជាក្រុមពិភាក្សាការងារនៅតាមតុ។

## ផែនការត្រៀមពាក់ព័ន្ធនឹងជំងឺរាតត្បាតកូវីដ-១៩ ០៣

ដូចបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលបានគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេសជូនប្រជាពលរដ្ឋកម្ពុជា និងនិវេសនជនទាំងអស់ រហូតធ្វើឱ្យការចាក់វ៉ាក់សាំងមានអត្រាខ្ពស់ប្រហែល ៩៥% នៃចំនួនប្រជាជន ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញយ៉ាងហោចណាស់ពីរដូស។ នៅពេលស្ថានភាពជំងឺរាតត្បាតបានចាប់ផ្តើមកាន់រាលដាលខ្លាំងឡើងៗនៅក្នុងប្រទេសកម្ពុជាកាលពីខែកុម្ភៈ ឆ្នាំ២០២១ រាជរដ្ឋាភិបាលក៏បានដាក់ចេញ និងកែប្រែវិធានការ និងនីតិវិធីស្តង់ដារប្រតិបត្តិជាច្រើនទាក់ទងនឹងព្រឹត្តិការណ៍រៀបចំនៅក្នុងសាលធំៗ ដូចជាអាពាហ៍ពិពាហ៍ សន្និសីទ និងកិច្ចប្រជុំការងារជាដើម។ រាជរដ្ឋាភិបាលក៏បានរឹតបន្តឹង និងបន្ធូរបន្ថយវិធានការជាហូរហែពាក់ព័ន្ធនឹងការធ្វើដំណើរចូលប្រទេសរបស់ពលរដ្ឋខ្មែរ និងជនបរទេសពីក្រៅប្រទេស។ ទោះបីជាស្ថានការណ៍កូវីដ-១៩ និងការកែប្រែបទបញ្ជាបានបន្ថែមឧបសគ្គមួយចំនួនដល់ការរៀបចំព្រឹត្តិការណ៍ទ្រង់ទ្រាយធំនេះ ដែលមានអ្នកចូលរួមជាង ១០០នាក់ រួមទាំងភ្ញៀវអន្តរជាតិឥស្សរជនជាន់ខ្ពស់ និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានវ័យចំណាស់ជាភព្វសំណាង ស្ថានភាពជំងឺរាតត្បាតបានភាពធូរស្រាលជាលំដាប់នៅពេលកាលបរិច្ឆេទនៃព្រឹត្តិការណ៍បានឈានចូលជិតមកដល់ ហើយវិធានការក៏មានការបន្ធូរបន្ថយ។ ទោះជាយ៉ាងនេះក្តី យើងត្រៀមរៀបចំផែនការបម្រុងសបង្វែរទៅជាព្រឹត្តិការណ៍តាមប្រព័ន្ធអនឡាញ ប្រសិនបើចាំបាច់ ដោយប្រើថ្នាល KUDO ដែលនឹងពិពណ៌នានៅក្នុងផ្នែកបន្ទាប់ស្តីពីបច្ចេកវិទ្យា ព័ត៌មាន។ សំណាងល្អយើងពុំចាំបាច់ប្រើថ្នាលអនឡាញនេះ។

គិតត្រឹមខែមីនា ឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអនុញ្ញាតឱ្យមានព្រឹត្តិការណ៍ក្នុងទីបិទជិតៗ រៀបចំឡើងដរាបណាគោរពតាមលក្ខខណ្ឌរក្សាគម្លាតសង្គម និងការពាក់ម៉ាស់ ហើយព្រឹត្តិការណ៍បុណ្យចូលឆ្នាំខ្មែរនៅពាក់កណ្តាលខែមេសា ឆ្នាំ២០២២ បានប្រព្រឹត្តទៅដោយគ្មានការកើនឡើងគួរឱ្យកត់សម្គាល់នៃការឆ្លងកូវីដ-១៩។ គិតត្រឹមខែឧសភា ឆ្នាំ២០២២ ភ្ញៀវអន្តរជាតិដែលបានចាក់វ៉ាក់សាំងពេញលេញអាចធ្វើដំណើរចូលកម្ពុជាបានដោយពុំតម្រូវឱ្យធ្វើចត្តាឡីស័ក ឬ បង្ហាញលទ្ធផលនៃការធ្វើតេស្ត PCR អវិជ្ជមាន ឬ ការធានារ៉ាប់រងពិសេសលើករណី កូវីដ-១៩។ ព្រឹត្តិការណ៍ក្នុងទីបិទជិតធំៗក៏អនុញ្ញាតឱ្យរៀបចំឡើងដរាបណាភ្ញៀវចូលរួមគោរពការរក្សាគម្លាតសង្គម និងពាក់ម៉ាស់ក្នុងពេលនៅក្នុងបន្ទប់បិទជិត លើកលែងពេលថ្លែង ពិសាអាហារ ឬ ហូបទឹក។ សណ្ឋាគារក៏បានកំណត់គោលការណ៍ផ្ទាល់ខ្លួន រៀបចំទឹកអាល់កុលសម្រាប់មេរោគនៅតាមទីតាំងជាច្រើនកន្លែង និងធានាឱ្យបានការគោរពនីតិវិធីស្តង់ដារប្រតិបត្តិ ស្តីពីការរក្សាគម្លាតសង្គមនៅក្នុងសាល។ ជាការប្រុងប្រយ័ត្នបន្ថែម ដោយសារកម្មវិធីនេះមានអ្នកចូលរួមក្នុងកម្រិតខ្ពស់ និងវត្តមានដើមបណ្តឹងរដ្ឋប្បវេណីដែលមានវ័យចំណាស់ អ្នកចូលរួមទាំងអស់តម្រូវឱ្យបង្ហាញភស្តុតាងនៃការទទួលថ្នាំវ៉ាក់សាំងបង្ការនៅពេលចុះឈ្មោះ។ ផ្នែកសន្តិសុខ

និងសុវត្ថិភាពរបស់ អ.វ.ត.ក ដែលដឹកនាំដោយមន្ត្រីបង្គោលទទួលបន្ទុកការងារជំងឺកូវីដ-១៩ ឈ្មោះ Leo Fetiza របស់ UNAKRT បានបំពេញការងារគួរឱ្យស្ញប់ស្ញែង និងរហ័សរហួនលើកិច្ចការនេះ។ អ្នកចូលរួមទាំងអស់ក៏ត្រូវបានណែនាំឱ្យធ្វើតេស្តរហ័សរកមេរោគ កូវីដ-១៩ ដោយខ្លួនឯងមុន និងក្រោយសិក្ខាសាលា។ តាមដែលលេខាធិការដ្ឋានបានដឹង នៅពេលសរសេរ របាយការណ៍នេះក្នុងខែកក្កដា ឆ្នាំ២០២២ មិនមានឧប្បត្តិហេតុនៃការឆ្លងកូវីដ-១៩ ក្នុងចំណោមអ្នកចូលរួម ហើយក៏មិនមានហេតុការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ បានកើតឡើងនៅក្នុងព្រឹត្តិការណ៍នោះដែរ។

# ការពិគ្រោះយោបល់របស់ អ្នកសម្របសម្រួលព្រឹត្តិការណ៍នៅមុន សិក្ខាសាលា

ដើម្បីផ្តល់ព័ត៌មានអំពីសិក្ខាសាលានាពេលខាងមុខ និងដើម្បីចាប់ផ្តើមការពិភាក្សាអំពីកម្មវិធីសក្តានុពលទាក់ទងនឹងជនរងគ្រោះ អ្នកសម្របសម្រួល Daniel Mattes ដំបូងបានធ្វើការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលសំខាន់ៗ ស្ថាប័នរដ្ឋ និងអ្នកតស៊ូមតិ ឬអ្នកស្រាវជ្រាវជនរងគ្រោះធ្លាប់ប្រឡូកការងារនេះជាយូរមកហើយ ដែលយកចិត្តទុកដាក់លើដំណើរការសាលាក្តីខ្មែរក្រហម។ អ្នកសម្របសម្រួលក៏បានជួបជាមួយភាគី អ.វ.ត.ក និងជាមួយមន្ត្រីទូតក្នុងអំឡុងពេលពិគ្រោះយោបល់។ គោលបំណងគឺដើម្បីកសាងការចូលរួម និងបង្កើតគំនិតសុទ្ធិដ្ឋិនិយមអំពីសិក្ខាសាលា និងដំណាក់ការដែលនៅសេសសល់នៅ អ.វ.ត.ក ដើម្បីកំណត់ការរំពឹងទុកចំពោះព្រឹត្តិការណ៍នាពេលខាងមុខ និងដើម្បីលើកទឹកចិត្តអ្នកចូលរួមដែលមានសក្តានុពលឱ្យចាប់ផ្តើមការងារត្រៀមរៀបចំព្រឹត្តិការណ៍នេះឱ្យបានល្អជាមុន។

នៅដំណាក់កាលត្រៀមដំបូង ការពិគ្រោះយោបល់ទាំងនោះអនុញ្ញាតឱ្យអ្នកសម្របសម្រួលស្តាប់ និងសង្កេតមើលបញ្ហាចោទសំខាន់ៗមួយចំនួន ដែលបន្តកើតមានម្តងទៀតក្នុងចំណោមអង្គការសង្គមស៊ីវិល ដែលខានផ្តល់យោបល់ផ្ទាល់ជូន អ.វ.ត.ក ជាយូរមកហើយ។ អង្គការទាំងនេះជាច្រើនបានសម្តែងនូវមន្ទិលសង្ស័យស្រដៀងៗគ្នាថា៖ "ហេតុអ្វីបានជាបែរមកចាប់អារម្មណ៍លើជនរងគ្រោះបន្ទាន់បែបនេះ? ហេតុអ្វីនៅដំណាក់កាលនេះ? ការឆ្លើយតបជាផ្លូវការគឺថា ដំណើរការចរចារហូតដាក់បញ្ចូលក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងបន្ថែមនៃកិច្ចព្រមព្រៀង UN-RGC កើតឡើងជាយូរមកហើយ ហើយចំណាប់អារម្មណ៍ទាំងអស់គឺការគាំទ្រជនរងគ្រោះ និងការចែករំលែកព័ត៌មានជា សាធារណៈ ប៉ុន្តែមិនអាចអនុវត្តបានរហូតមកដល់ពេលទើបតែមានកិច្ចព្រមព្រៀងចុងក្រោយនេះប៉ុណ្ណោះ។ ចំណុចបង្ហាញច្បាស់នោះគឺថា ដំណាក់កាលនេះពោលគឺ ពាក់កណ្តាលឆ្នាំ២០២២ គឺជាចំណុចប្រសព្វលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រ ដែលទើបរៀបចំព្រឹត្តិការណ៍បែបនេះ ខណៈអាណត្តិមុនៗរបស់តុលាការតែងតែផ្តោតលើដំណើរការតុលាការ ហើយត្រូវការជានានូវអព្យាក្រឹតភាពពេញលេញ និងការគោរពកិច្ចដំណើរការនីតិវិធីនេះសិន។ អ្នកសម្របសម្រួលបានព្យាយាមផ្សព្វផ្សាយសារនេះ ប៉ុន្តែក៏បានព្យាយាមជំរុញបន្ថែមការងារនេះ ក្នុងនោះផ្តោតសំខាន់លើឱកាសសម្រាប់តំណាងជនរងគ្រោះ និងអង្គការសង្គមស៊ីវិល។

ដំណាក់កាលអន្តរកាលឈានទៅដំណាក់កាល អ.វ.ត.ក ដែលនៅសេសសល់ផ្តល់ឱកាសឱ្យភាគីពាក់ព័ន្ធមិនត្រឹមតែឆ្លុះបញ្ចាំងមេរៀនដែលបានទទួលបាននៅ អ.វ.ត.ក ក្នុងរយៈពេលជាង ១៥ឆ្នាំ ចុងក្រោយប៉ុណ្ណោះទេ ថែមទាំងបានបង្កើតទស្សនៈវិស័យរួមគ្នា

លើកម្មវិធីឆ្លើយតបតាមតម្រូវការរបស់ជនរងគ្រោះ ដែលយើងជាច្រើននាក់បានមើលឃើញ ក៏ប៉ុន្តែ ត្រូវបានបំភ្លេចចោល ឬ បន្ថយសារៈសំខាន់។ វាក៏ជាឱកាសមួយក្នុងការរៀបចំឡើងវិញ នូវការទាមទារដែលមានជាយូរមកហើយ ដែល អ.វ.ត.ក មិនបានបំពេញការងារនេះឱ្យបាន គ្រប់គ្រាន់សម្រាប់ជនរងគ្រោះ ដោយចាប់ផ្តើមនូវសំណួរថ្មីមួយៈ តើជនរងគ្រោះ និងអ្នកតំណាង ចង់បានអ្វីពី អ.វ.ត.ក ក្នុងដំណាក់កាល ដែលនៅសេសសល់ នេះ? តើការខកចិត្តកន្លងមកអាច ប្រែក្លាយទៅជារបៀបវារៈថ្មីដែលផ្តោតលើជនរងគ្រោះដោយរបៀបណា?

ទោះបីជាមានការសង្ស័យខ្លាំងក៏ដោយ អ្នកចូលរួមបានពិគ្រោះយោបល់ ជាពិសេស អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានដឹកនាំយូរមកហើយលើការងារឆ្លើយតបទៅនឹង សំណើរបស់ជនរងគ្រោះ នៅតែបន្តសម្តែងសុទិដ្ឋិនិយម និងក្តីរំភើបយ៉ាងខ្លាំង។ នៅទីបញ្ចប់ វាពុំមានបញ្ហាប្រឈមក្នុងការបង្កើតឱ្យមានចំណាប់អារម្មណ៍នៅក្នុងសិក្ខាសាលា និង ដំណាក់កាលដែលនៅសេសសល់នោះទេ។ បន្ទាប់ពីមានការងឿងឆ្ងល់ជាច្រើនឆ្នាំថាតើតុលាការ នឹងឱ្យពួកគេចូលរួមដែរឬទេ ហើយបន្ទាប់ពីការខកខានមិនបានជួបជុំគ្នាដោយសារជំងឺរាតត្បាត រយៈពេលពីរឆ្នាំ វាហាក់បង្ហាញថា អ្នកពាក់ព័ន្ធ និងអ្នកអនុវត្តការងារជាយូរមកហើយ ពោរពេញ ដោយទស្សនៈ និងផែនការដើម្បីចែករំលែកនៅក្នុងព្រឹត្តិការណ៍នាពេលខាងមុខ និងក្នុងការរៀបចំ ផែនការដើម្បីទាញប្រយោជន៍ឱ្យបានច្រើនបំផុតពីអាណត្តិការងារ អ.វ.ត.ក ដែលនៅសេសសល់ ដែលខិតជិតមកដល់។

ផ្នែកនេះសង្ខេបរបកគំហើញគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលពិគ្រោះយោបល់ ដែល បានរៀបចំឡើងមុន សិក្ខាសាលា ទាំងដោយផ្ទាល់នៅរាជធានីភ្នំពេញ ឬ តាមប្រព័ន្ធអន ឡាញ។ យើងបានសំយោគចំណុចព្រមព្រៀងរួមនៅក្នុងពេលពិគ្រោះយោបល់ ដោយមិន សង្ខេបចំណុចលើកឡើងជាលក្ខណៈបុគ្គល ឬអង្គការនីមួយៗ ដែលអ្នកសម្របសម្រួលបាន ជួបពិគ្រោះយោបល់នោះឡើយ។

ចំណុចទីមួយ មានការរំភើបចិត្ត និងយល់ដឹងជាក់លាក់អំពីឱកាសក្នុងការពង្រីក និយមន័យនៃជនរងគ្រោះលើសពីនិយមន័យផ្លូវច្បាប់ ក្នុងក្របខ័ណ្ឌគម្រោងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ នៅពេលកិច្ចដំណើរការតុលាការ អ.វ.ត.ក បញ្ចប់ និងការបង្កើតកម្មវិធីថ្មីសម្រាប់ដំណាក់កាលដែលនៅសេសសល់នាពេលខាងមុខ តំណាង សង្គមស៊ីវិល និងភាគី នៃ អ.វ.ត.ក បានលើកឡើងអំពីឱកាសឱ្យ "ជនរងគ្រោះ" ផ្សេងទៀត ក្រៅពីអ្នកត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីទាំងនេះ ចូលរួម។ អ្នកខ្លះ បានអំពាវនាវឱ្យមានការយកចិត្តទុកដាក់បន្ថែមលើអ្នកដាក់ពាក្យបណ្តឹងនៅក្នុងសំណុំរឿង និងការសម្របសម្រួលតាមដានជាពិសេសជាមួយពួកគេ។ អ្នកផ្សេងទៀតបានកត់សម្គាល់ថា យុវជនទទួលរងនូវរបួសផ្លូវចិត្តដោយប្រយោល ដែលជាកំអែលបន្សល់ពីឪពុកម្តាយ ជីដូនជីតា ជាពិសេសនៅក្នុងគ្រួសារដែលឪពុកម្តាយត្រូវបានបង្ខំឱ្យរៀបការក្នុងរបប DK។ អ្នក តស៊ូមតិមួយចំនួនបានសង្កេតឃើញថា ជនល្មើសនៅថ្នាក់ក្រោមៗ និងជាពិសេសកូនចៅរបស់ពួកគេ អាចបញ្ចូលក្នុងកម្មវិធីដើម្បីជាដំណើរផ្លូវបន្តឆ្ពោះទៅរកការផ្សះផ្សាកាន់តែទូលំទូលាយរវាង បុគ្គលម្នាក់ៗ និងក្នុងក្របខ័ណ្ឌទូទាំងប្រទេស។

ទោះជាយ៉ាងណាក៏ដោយ ប្រធានបទនេះក៏បានបង្កើតជាបញ្ហាប្រឈមធំៗផ្សេងទៀត ដែលត្រូវបានលើកឡើងម្តងហើយម្តងទៀតៈ ឧបសគ្គនៃការធ្វើឱ្យរបួសផ្លូវចិត្តរើឡើងវិញ តម្រូវការនៃ "វិធីសាស្ត្រមិនបង្កការឈឺចាប់" និងបញ្ហាឯកជនភាព និងការការពារអ្នករស់រាន

មានជីវិត និងសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី។ លោកស្រី ស៊ុយ ហ៊ាងគ្រី នាយិកា CWP បានធ្វើអត្ថាធិប្បាយអំពីរបួសផ្លូវចិត្តដោយប្រយោល ដែលសង្កេតឃើញកើតឡើងក្នុងស្រទាប់យុវវ័យដែលអង្គការបានធ្វើការងារជាមួយនាពេលកន្លងមក។ លោកស្រីបានពន្យល់ថា នៅពេលនេះ អង្គការ CWP កំពុងបង្កើតសៀវភៅណែនាំស្តីពីរបួសផ្លូវចិត្ត និងរបួសផ្លូវចិត្តដោយប្រយោល និងស្វ័យថែទាំខ្លួន សម្រាប់ចែកចាយ និងជាមូលដ្ឋានបង្កើតកម្មវិធីសន្ទានកម្មក្នុងចំណោមអ្នកក្នុងជំនាន់ជាមួយគ្នានៅតាមសាលារៀន ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ ដោយដំបូងផ្តោតលើវិទ្យាល័យក្នុងខេត្តព្រៃវែង ខេត្តកណ្តាល និងរាជធានីភ្នំពេញ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិមួយរូប ដែលធ្វើការងារពីក្រៅប្រទេសបានកត់សម្គាល់ការព្រួយបារម្ភរបស់គាត់ថា ការប្រកាសអំពីដំណាក់កាលដែលនៅសេសសល់ថ្មីនេះ អាចជាក្តីសង្ឃឹមសម្រាប់កូនក្តីគាត់ និងអ្នករស់រានមានជីវិតផ្សេងទៀតយល់ថា អ.វ.ត.ក នឹងអនុវត្តកម្មវិធីពួកគាត់កាន់តែពេញចិត្តជាងមុន ប៉ុន្តែធ្វើយ៉ាងណាជៀសវាងកុំឱ្យពួកគេខកចិត្តនៅពេលក្រោយ។ លោកបានបញ្ជាក់អំពីតម្រូវការដែលតុលាការត្រូវអនុវត្តតាមផែនការដែលបានប្រកាស និងបង្កើតមូលដ្ឋានគាំទ្រដល់កម្មវិធីដើម្បីធានាថាមិនបង្កការឈឺចាប់បន្ថែមដល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតដែលបានរងការឈឺចាប់រួចមកហើយ។ លោកស្រី Megan Hirst និងលោក ពេជ្រ អង្គ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី (CPLCLs) ក្នុងសំណុំរឿង ០០២ ក៏បានដាក់ឯកសារយ៉ាងច្រើន ស្នើសុំធ្វើចំណាត់ប្រភេទថ្នាក់ឡើងវិញនូវឯកសារកំណត់ត្រាតុលាការ និងភាពចាំបាច់ត្រូវពិនិត្យមើលឱ្យបានលម្អិតចំពោះឯកសារកំណត់ហេតុទាំងអស់នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងរដ្ឋប្បវេណី និងសាក្សី ។ សហមេធាវីនាំមុខ បានជំរុញឱ្យទាក់ទង និងជាពិសេសសួរដើម បណ្តឹងរដ្ឋប្បវេណីទាំងអស់ថាតើមានព័ត៌មានឯកជនណាមួយនៅក្នុងពាក្យសុំរបស់ពួកគេ ឬទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដូចជា ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ ឬសេចក្តីថ្លែងការណ៍អង្គហេតុណាមួយ ដែលពួកគេចង់ឱ្យកោសលុបមុនពេលឯកសារទាំងអស់នោះផ្សព្វផ្សាយជាសាធារណៈ។ សហមេធាវីនាំមុខសង្កេតឃើញថា ជនរងគ្រោះជាច្រើនលើកឡើងពីអតីតចារី ដែលសព្វថ្ងៃរស់នៅក្បែរគ្នាក្នុងសហគមន៍តែមួយ។ ឯកសារថ្មីៗរបស់ CPLCLs នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល នឹងត្រូវសម្រេចនៅចុងឆ្នាំនេះ រួមជាមួយពេលប្រកាសសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីអះអាងថា គួរធ្វើការងារលើសពីនេះបន្ថែមទៀតនៅពេលនេះ ដើម្បីដោះស្រាយការងារដ៏ច្រើនសន្ធឹកសន្ធាប់នៅមុនពេលចេញសាលដីកា។ យើងបានលើកឡើងជាមួយភាគីជាច្រើននៅក្នុងតុលាការ អ្នកសង្កេតការណ៍ អ.វ.ត.ក និងអ្នកតស៊ូមតិតំណាងជនរងគ្រោះក្នុងចំណោមអង្គការសង្គមស៊ីវិល ដែលអ្នកទាំងអស់មានការយល់ស្របដូចគ្នា។

បញ្ហានៃការចាត់ប្រភេទឯកសារឡើងវិញក៏ត្រូវជាប់ពាក់ព័ន្ធទៅនឹងបញ្ហាចោទបើកចំហមួយថាតើ នឹងមានអ្វីកើតឡើងចំពោះបណ្ណសាររបស់ អ.វ.ត.ក ហើយនឹងយកទៅដាក់កន្លែងណា។ សំណួរនេះត្រូវបានលើកឡើងដោយ ស្ថាប័នជាច្រើន ភាគី អ.វ.ត.ក និងអ្នកសង្កេតការណ៍តុលាការ។ ទោះជាយ៉ាងណាក៏ដោយ OA បានពន្យល់ម្តងហើយម្តងទៀតទៅកាន់អ្នកសម្របសម្រួលថា សំណួរអំពីទីតាំងរយៈពេលវែង និងការគ្រប់គ្រងបណ្ណសារនឹងត្រូវសម្រេចដោយឡែកដាក់ចេញពីសិក្ខាសាលាស្តីពីជនរងគ្រោះ និងការអភិវឌ្ឍកម្មវិធីស្តីពីដំណាក់កាលដែលនៅសេសសល់ថ្មីអំពីជនរងគ្រោះ។ ការសម្រេចអំពីបណ្ណសារស្ថិតនៅ

៤០ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី សំណើសុំសេចក្តីណែនាំទាក់ទងនឹងការធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារដើមបណ្តឹងរដ្ឋប្បវេណី (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១) ឯកសារ F71។

ក្រៅវិសាលភាពនៃសិក្ខាសាលា និងរបាយការណ៍នេះ។ ទោះបីជាមជ្ឈមណ្ឌលឯកសារច្បាប់ (LDC) សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (TSGM) និងមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) សុទ្ធតែត្រូវបានពិគ្រោះយោបល់ និងអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលានេះក៏ដោយ ក៏ស្ថាប័នទាំងនេះត្រូវបានអញ្ជើញចូលរួមក្នុងក្របខ័ណ្ឌការងាររបស់ខ្លួនពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះ និងការងារផ្សព្វផ្សាយ មិនមែនដើម្បីសម្រេចលើការកំណត់ផែនការស្តីពីបណ្ណសាររយៈពេលវែងនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការពិគ្រោះយោបល់មុនរៀបចំសិក្ខាសាលា និងការពិភាក្សាក្នុងពេលសិក្ខាសាលាបានបង្ហាញឱ្យឃើញសារៈសំខាន់នៃបណ្ណសារ មិនត្រឹមតែសម្រាប់អ្នកសង្កេតការណ៍ និងអ្នកអនុវត្តការងារជាយូរមកហើយប៉ុណ្ណោះទេ វាក៏មានសារៈសំខាន់សម្រាប់ជនរងគ្រោះផ្ទាល់ ដែលមើលឃើញថា បណ្ណសារជាតំណាងនៃការចងចាំ ដែលជាបេតិកភណ្ឌជាតិ និងជាធនធានសម្រាប់ការអប់រំមនុស្សជំនាន់ក្រោយ។

នត្ថិភាពនៃភាពច្បាស់លាស់ទាក់ទងនឹងបណ្ណសារ មិនមែនជាចំណុចតែមួយគត់ ដែលអ្នកតស៊ូមតិត្រូវបានពិគ្រោះយោបល់ លើកឡើងថាគឺកើតចេញដោយសារទំនាក់ទំនង និងការចែករំលែកព័ត៌មានរបស់តុលាការនោះទេ។ តំណាងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានធ្វើអត្ថាធិប្បាយថា ពួកគេមិនបានដឹងថា អ.វ.ត.ក នៅបន្តដំណើរការសកម្មភាពនៅឡើយ។ យើងគួរកត់សម្គាល់ត្រង់នេះថា ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ ដែលធ្វើការងារពាក់ព័ន្ធនឹងខ្មែរក្រហមមិនបានដឹងផងនោះ សាធារណជន ទំនងមើលទៅ កាន់តែមិនបានដឹងថា អ.វ.ត.ក កំពុងបំពេញការងារបញ្ចប់កិច្ចដំណើរការតុលាការរបស់ខ្លួន ឬ ត្រៀមចាប់ផ្តើមដំណាក់កាលដែលសេសសល់។ សង្គមស៊ីវិលតស៊ូមតិចំនួនពីរ ដែលធ្វើការងារលើការកសាងសន្តិភាពនៅទូទាំងសហគមន៍ជនជាតិភាគតិច បានកត់សម្គាល់ថា សាលក្រមសំណុំរឿង ០០២/០២ ខកខានមិនបានចែករំលែកសំអាងហេតុសំខាន់ៗស្តីពីការកំណត់គោលដៅរបស់ខ្មែរក្រហមលើជនជាតិភាគតិចវៀតណាម ឬ សហគមន៍ចាមឥស្លាម។ ថ្នាក់ដឹកនាំអង្គការមិនមែនរដ្ឋាភិបាលមួយរូបបានកត់សម្គាល់ថា សេចក្តីថ្លែងការណ៍ចុងក្រោយរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២ ពិតណាស់បានប្រើប្រាស់ខុសគោលដៅទៅជាការឃោសនា ដើម្បីបំផុសមនោសញ្ចេតនាប្រឆាំងវៀតណាមនៅលើបណ្តាញទំនាក់ទំនងសង្គមដ៏ពេញនិយមទៅវិញ។ អ.វ.ត.ក ខកខានក្នុងការធ្វើអត្ថាធិប្បាយជាសាធារណៈនាពេលនោះ ដូច្នេះជ្រុះបាត់ឱកាសអប់រំសាធារណជនអំពីអតីតកាល ក៏ដូចជាសំអាងហេតុរបស់ខ្លួន។ អ្នកស្រាវជ្រាវឯករាជ្យ Laura McGrew បានសង្កេតឃើញថា ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីនៅតាមតំបន់ជនបទនៃប្រទេស ដែលលោកស្រីបានជួបក្នុងដំណើរទស្សនកិច្ចនាពេលថ្មីៗនេះ មិនបានឮព័ត៌មានថ្មីៗណាមួយពី អ.វ.ត.ក ជាយូរមកហើយ ដែលធ្វើឱ្យពួកគាត់សោះសស់ និងខឹងនឹងតុលាការ។ អ្នកស្រាវជ្រាវ និងអ្នកសង្កេតការណ៍ជាច្រើនទៀតបានបញ្ចេញមតិថា កង្វះព័ត៌មានសាធារណៈ ជាពិសេស ក្នុងអំឡុងពេលពីរឆ្នាំនៃការរាតត្បាត ជំងឺកូវីដ-១៩ ចាប់តាំងពីដើមឆ្នាំ២០២០ បានធ្វើឱ្យរាំងស្ទះដល់កេរដំណែលចុងក្រោយរបស់តុលាការខណៈកំពុងត្រៀមទៅបញ្ចប់សំណុំរឿង ០២/០២ មុនឈានចូលដល់ដំណាក់កាលដែលនៅសេសសល់។ មេធាវីរបស់តុលាការមួយរូប បានសង្កត់ធ្ងន់លើតម្រូវការអនុវត្តតាម "យុទ្ធសាស្ត្រស៊ីបីដើម" គឺទំនាក់ទំនង សម្របសម្រួល និងសហការ ហើយបានអំពាវនាវឱ្យតុលាការចែករំលែក សម្ភារៈឯកសារទាំងអស់ជូនដល់សាធារណជន ឱ្យបានច្រើនតាមដែលអាចធ្វើ



លោក ចាន់ សាត ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ មានប្រសាសន៍ទៅកាន់សិក្ខាកាម ក្នុងពិធីបិទសិក្ខាសាលា នៅថ្ងៃទី៣នៃសិក្ខាសាលា ។




ឯកសារបោះពុម្ពផ្សាយរបស់អ.វ.ត.ក ដាក់តាំងនៅផ្លូវចូលសិក្ខាសាលា ។



ប្រធានស្តីទីការិយាល័យរដ្ឋបាល ឯ.ឧ ក្រាញ់ តូនី (ស្តាំ) និងអនុប្រធានការិយាល័យរដ្ឋបាល លោក ឃ្នុត រ៉ូហ្សិនហក កំពុងស្តាប់វាគ្មិន នៅថ្ងៃទី៣ នៃសិក្ខាសាលា ។

ទៅបានក្នុងដំណាក់កាលអន្តរកាលដ៏សំខាន់នេះ។ សុទិដ្ឋិនិយមនេះត្រូវកើតចេញពីភាពច្បាស់លាស់ និងតម្លាភាពទាក់ទងនឹងអ្វីដែលដំណាក់កាលដែលនៅសេសសល់អាច និងមិនអាចសម្រេចបាន។ ការរំពឹងទុករបស់ជនរងគ្រោះមិនត្រូវលើកឡើងនៅពេលនេះ បើមិនដូច្នេះធ្វើឱ្យពួកគេកាន់តែខកចិត្តថែមទៀត។

ទោះជាយ៉ាងណាក៏ដោយ យើងក៏ត្រូវបញ្ជាក់ផងដែរថា ព័ត៌មានសាធារណៈ និងការងារផ្សព្វផ្សាយមានភាពខុសគ្នាពីព័ត៌មានអង្គច្បាប់ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលលើកឡើងដោយមេធាវីតំណាងពួកគេ។ ជាពិសេស ចំណុចនេះត្រូវបានលើកឡើងដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី Megan Hirst ហើយក៏ត្រូវបានបញ្ជាក់ជាថ្មីម្តងទៀតដោយបុគ្គលជាច្រើនផ្សេងទៀត រួមទាំងអ្នកសង្កេតការណ៍ និងអ្នកឃ្លាំមើលតុលាការម្ចាស់ជំនួយ អន្តរជាតិ និងមេធាវីផ្សេងទៀត អ្នកស្រាវជ្រាវ ឬបុគ្គលិកដែលបំពេញការងារលើបញ្ហានីតិរដ្ឋ។ ក្នុងនាមជាភាគីនៃកិច្ចដំណើរការនីតិវិធី និងកូនក្តី ដែលមេធាវីតំណាងផ្លូវច្បាប់ក្នុងកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីជិត ៤,០០០នាក់ (ឬ សិទ្ធិវន្តរបស់ពួកគេប្រសិនបើពួកគេទទួលមរណភាព) បានជួបជជែកសន្ទនាជាមួយមេធាវីរបស់ពួកគេ។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវធ្វើឡើងភ្លាមៗនៅពេលចេញសាលដីកាសំណុំរឿង ០០២/០២ ប៉ុន្តែបុគ្គលភាគច្រើនបានសង្កេតឃើញនូវការបាត់បង់ ឱកាសអស់រយៈពេលបីឆ្នាំចុងក្រោយនេះ មិនបានជូនព័ត៌មានដល់អ្នករស់មានជីវិតឱ្យកាន់តែបានច្រើននាក់ថា កិច្ចដំណើរការផ្លូវច្បាប់ក្នុងរឿងក្តីរបស់ខ្លួនកំពុងដើរទៅមុខ។ ម្ចាស់បណ្តឹងក៏ចាំបាច់ត្រូវផ្តល់ព័ត៌មានវឌ្ឍនភាព ដែលពួកគេសមនឹងទទួលបាន ហើយអ្នកសង្កេតការណ៍ជាច្រើនមិនយល់ច្បាស់ថាតើមានអ្វីបានកើតឡើងចំពោះពួកគេ ឬរបៀបស្វែងរកព័ត៌មានទាំងនេះ។ ខណៈ VSS ទទួលខុសត្រូវការងារគ្រប់គ្រង និងតាមដានដើមបណ្តឹងរដ្ឋប្បវេណី យើងមិនដឹងច្បាស់ថានរណាបានធ្វើកិច្ចការនេះ ឬនឹងធ្វើឱ្យដូចៗគ្នាចំពោះដើមបណ្តឹង។

ពាក់ព័ន្ធនឹងការស៊ើបអង្កេតសម្ងាត់នៅក្នុងសំណុំរឿង ០០៣ ០០៤ ០០៤/០១ និង ០០៤/០២ ដែលគ្មានសំណុំរឿងណាមួយបញ្ជូនទៅជំនុំជម្រះដោយសារតែហេតុផលនីតិវិធីខុសគ្នា អ្នកសង្កេតការណ៍ជាច្រើននាក់បានកត់សម្គាល់ថា ពួកគេបានឮអំពីការខកចិត្ត និងព័ត៌មានប្រឫកប្រឫលចំពោះលទ្ធផលនៃសំណុំរឿងទាំងនេះ។ យើងមិនដឹងច្បាស់ថាតើដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងក្នុងសំណុំរឿងទាំងនោះដូចកាលពីឆ្នាំ២០១៧ បានទទួលដំណឹងថាសំណុំរឿងទាំងនេះបានបន្តទៅជំនុំជម្រះ ឬ សំណុំរឿង ០០២/០២ គឺជាកិច្ចដំណើរការនីតិវិធីចុងក្រោយរបស់តុលាការ។ តំណាងសហគមន៍ជនជាតិដើមភាគតិចខ្មែរក្រោមបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីជនជាតិវៀតណាម ឬ ខ្មែរក្រោមជាច្រើននាក់មានអារម្មណ៍សោកស្តាយ ដែលសំណុំរឿងទាំងនោះមិនដំណើរការទៅមុខ ហើយក្នុងចំណោមនោះ មានដើមបណ្តឹងមួយចំនួនតូចប៉ុណ្ណោះដែលដឹងអំពីលទ្ធផលនៃសំណុំរឿងទាំងនេះ។ ពួកគេមានអារម្មណ៍ឯកោ តែលតោល និងតានតឹង។ សហគមន៍ជនជាតិដើមភាគតិច វៀតណាមក៏បានលើកឡើងអំពីការបន្តផ្តល់ព័ត៌មានអំពីគម្រោងសំណងដែលត្រូវបានទទួលស្គាល់ពីក្នុងសំណុំរឿង ០០២/០២ ក្នុងគោលបំណងគាំទ្រដល់ការផ្តល់ឯកសារអត្តសញ្ញាណសម្រាប់ជនជាតិវៀតណាមដែលកើត និង/ឬរស់នៅក្នុងប្រទេសកម្ពុជា (គម្រោងទី ១២ បានពិភាក្សាខាងលើក្នុងលេខយោងជើងទំព័រ ៣៣)។ បច្ចុប្បន្ននេះគម្រោងជាច្រើនកំពុងស្ថិតក្នុងហានិភ័យនៃភាពគ្មាននរណាគាំទ្រ ហើយ អ.វ.ត.ក មិនបាន

តាមដានបន្តដើម្បីជានាថាគម្រោងសំណងទាំងនេះដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់នៅក្នុងសំណុំរឿងនោះត្រូវបានអនុវត្តទាំងស្រុង។ ពិសោធន៍ទាំងអស់នេះបាននាំឱ្យទំនុកចិត្តមានការថយចុះថា អ.វ.ត.ក អាចនឹងបន្សល់ទុកនូវកេរដំណែលយូរអង្វែង ឬ សម្រេចបានលទ្ធផលខុសពីមុនក្នុងដំណាក់កាលដែលនៅសេសសល់របស់ខ្លួន ខណៈព្យាយាមចូលរួមការងារនេះកាន់តែច្រើនទៅតាមតម្រូវការរបស់ជនរងគ្រោះ។

ភាគីជាច្រើនមកពី អ.វ.ត.ក ក៏ដូចជាម្ចាស់ជំនួយអន្តរជាតិ ដែលធ្លាប់បានជួបពិគ្រោះយោបល់ បានស្នើថា តុលាការគួរកសាងគណនេយ្យភាព តម្លាភាព និងការត្រួតពិនិត្យលើមុខងារដែលនៅសេសសល់របស់ខ្លួន។ អ្នកសង្កេតការណ៍ខាងក្រៅម្នាក់បានចោទសួរថាតើវាអាចទៅរួចទេថាកំណត់មុខងារដែលនៅសេសសល់ឱ្យតិចបំផុតតាមដែលអាចធ្វើទៅបាន និងកម្រិតការបកស្រាយទូលំទូលាយនៃវិសាលភាពរបស់វានៅក្នុងកិច្ចព្រមព្រៀងបន្ថែម។ ក្រៅពីការបង្ហាញបុរេសកម្មដល់សាធារណជនអំពីការទទួលខុសត្រូវរបស់ខ្លួន អ្នកសង្កេតការណ៍ និងអ្នកតស៊ូមតិ បានអំពាវនាវឱ្យ អ.វ.ត.ក ចូលរួមបំពេញការងារនៅក្នុងកម្មវិធី ឬ គំនិតផ្តួចផ្តើមច្រើនជាងមុន តាំងពីពេលចាប់ផ្តើមដំបូង។ ថ្វីបើបុគ្គលជាច្រើនបានលើកឡើងជាញឹកញាប់អំពីភារកិច្ចជាន់គ្នា ឬ ការងារច្រំដែលជាមួយគម្រោងអង្គការសង្គមស៊ីវិលជាច្រើននៅកម្ពុជាក៏ដោយ ការធ្វើការដាច់ចេញពីគេម្នាក់ឯង និងការបែងចែកការងារដាច់ពីគ្នាអាចដោះស្រាយបានប្រសិនបើស្ថាប័នកណ្តាល ដូចជា អ.វ.ត.ក ប្រើប្រាស់អំណាចកោះប្រជុំ និងចែករំលែកធនធាន និងចក្ខុវិស័យរបស់ខ្លួននៅដំណាក់កាលអភិវឌ្ឍន៍ដំបូង។ តាមយោបល់ពួកគេបានលើកឡើងថា អ.វ.ត.ក ពេលខ្លះ ភ្លេចសុភាសិតមួយដែលលើកឡើងថា "ភាពសម្បូរបែបគឺជាសត្រូវនៃសេចក្តីល្អ"។

យោងតាមទស្សនៈទាំងនេះ អ.វ.ត.ក ពេលខ្លះ បាត់បង់ឱកាសចូលរួមក្នុងគម្រោងខ្នាតតូចៗ ដំណាក់កាលដំបូង ឬ គម្រោងសាកល្បង ដោយសារកម្មវិធីនេះប្រហែលជាមិនទាន់ត្រូវបានអនុវត្តទូទាំងប្រទេស ឬ ស្ថាប័នមិនទាន់ប្រាប់បញ្ចូលជាមួយដៃគូ ឬគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល។ ចំណុចនេះគឺជាការយល់ខុសអំពីកាលានុវត្តភាព និងតម្លៃដែលអង្គការសង្គមស៊ីវិលជឿជាក់ថា អ.វ.ត.ក អាចទទួលបានតម្លៃបន្ថែមច្រើន។ ជាជាងរង់ចាំឱ្យកម្មវិធីដ៏ល្អឥតខ្ចោះមកដល់មុខខ្លួនសុំការឯកភាព អ.វ.ត.ក គួរបំពេញការងារនៅខាងក្រៅសហការជាមួយកម្មវិធីល្អៗជាច្រើន ដើម្បីពង្រឹងកម្មវិធីទាំងនោះ និងផ្តល់ធនធាន (មនុស្ស បច្ចេកទេស ឬហិរញ្ញវត្ថុ) ដែលត្រូវការបំផុតដើម្បីឈានទៅទទួលបានជោគជ័យ។ អ.វ.ត.ក គួរប្រើប្រាស់អំណាចកោះប្រជុំរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពជាងមុន ដើម្បីប្រមូលផ្តុំអង្គការមិនមែនរដ្ឋាភិបាលមកសហការជាមួយអង្គភាពរដ្ឋ ឬ បង្កើតកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលណា ដែលមានទស្សនៈដូចខ្លួន។ អង្គការក្តីករុណា បានអំពាវនាវឱ្យមានការពិគ្រោះយោបល់ជាទៀងទាត់ទៅតាមកាលវិភាគជាមួយភាគីពាក់ព័ន្ធទាំងអស់។ សិក្ខាសាលាជនរងគ្រោះអាចជាសិក្ខាសាលាលើកទីមួយនៃព្រឹត្តិការណ៍តូចៗជាច្រើនផ្សេងទៀត ដែលរៀបចំឡើងដើម្បីចែករំលែកព័ត៌មានក្នុងស្មារតីសហប្រតិបត្តិការ។ ចំណុចនេះអាចកាត់បន្ថយការងារជាន់គ្នា ឬ នត្ថិភាពនៃនិរន្តរភាព និងចីរភាព ដែលជារឿងៗជាបញ្ហាសម្រាប់បណ្តាញសង្គមស៊ីវិល រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ។

អ្នកសង្កេតការណ៍ក៏បានលើកឡើងអំពីភាពចាំបាច់នៃការកសាងស្ថាប័នល្អ និងទំនាក់ទំនងជាមួយស្ថាប័នដែលមានស្រាប់សំដៅឱ្យមាននិរន្តរភាព និងការរួមបញ្ចូលគ្នា។

អង្គការមួយបានពន្យល់អំពីការទទួលបានភាពងាយស្រួលនៅពេលសហការធ្វើការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) ប៉ុន្តែភាគច្រើន គឺដោយសារតែប្រធានគណៈមេធាវីបច្ចុប្បន្ន ឯកឧត្តម លី ច័ន្ទតុលា ចាប់អារម្មណ៍ និងបុរេសកម្ម។ តើអង្គការសង្គមស៊ីវិលអាចបង្កើតទំនាក់ទំនងប្រកបដោយនិរន្តរភាពដោយពុំពឹងផ្អែកលើចំណាប់អារម្មណ៍របស់សហគ្រិន ឬ អ្នកដឹកនាំមាន ឥទ្ធិពលដោយរបៀបណា? បច្ចុប្បន្ន អង្គការជាច្រើនកំពុងបង្វែរការចាប់អារម្មណ៍របស់ពួកគេមកលើយុវជនជំនាន់ក្រោយ ដូច្នេះ ពួកគេចង់កសាង ឬ ពង្រីកទំនាក់ទំនង ជាមួយក្រសួងអប់រំ យុវជន និងកីឡា (MOEYS)។ CWP, TSGM, KDK, និង DC-Cam គឺជាអង្គការ ឬស្ថាប័នមួយចំនួនតូចប៉ុណ្ណោះ ដែលបានបង្កើតទំនាក់ទំនងជាមួយ MOEYS។ អង្គការផ្សេងទៀតពឹងផ្អែកលើម្ចាស់ជំនួយអន្តរជាតិ ដូចជាវិទ្យាស្ថាន Raoul Wallenberg (RWI) ដែលមានឆន្ទៈផ្តល់មូលនិធិដល់កិច្ចខិតខំប្រឹងប្រែងលើការងារពង្រឹងវិស័យសិក្សាធិការជាបណ្តើរៗ និងការចូលរួមរបស់សង្គមស៊ីវិលលើនីតិរដ្ឋ។ ទោះជាយ៉ាងនេះក្តី នៅពេល អ.វ.ត.ក លើកឡើងអំពីការរួមសហការគ្នាលើការងារជាមួយអង្គការសង្គមស៊ីវិល ឬ រវាងអង្គការសង្គមស៊ីវិល និងស្ថាប័នរដ្ឋ កាន់តែច្រើន វានឹងជួយជំរុញដល់ការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការកាន់តែច្រើនឡើង។ នាយកអង្គការយុវសន្តិភាព (YFP) អន្ទះសារចង់មើលឃើញថាតើសិក្ខាសាលាជនរងគ្រោះអាចលើកទឹកចិត្តដល់ដៃគូសក្តានុពលមួយចំនួនឱ្យចាប់ផ្តើមកិច្ចសហប្រតិបត្តិការ ដែលពួកគេបានគ្រោងទុកជាយូរមកហើយជាមួយគ្នានោះកើតឡើងដែរឬអត់។

ផ្អែកលើការសន្ទនាទាំងនេះ វាហាក់បីដូចជាអង្គការសង្គមស៊ីវិលភាគច្រើនចង់ដឹងអំពីសំណើ និងទស្សនៈរបស់គ្នាទៅវិញទៅមក ជាពិសេសបន្ទាប់ពីជំងឺរាតត្បាតរយៈពេល ០២ឆ្នាំបានធ្វើឱ្យការបែកខ្ញែកគ្នា តាមអំពើចិត្តកាន់តែខ្លាំងឡើង ក្នុងចំណោមអង្គការដែលមានទស្សនៈដូចគ្នា។ KDK ស្នើឱ្យមានកិច្ចប្រជុំប្រចាំត្រីមាសជាមួយតួអង្គរដ្ឋ និងសង្គមស៊ីវិលដែលកន្លងមកបានចូលរួមការងារអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ អង្គការមិនមែនរដ្ឋាភិបាលក៏បានប្រមូលផ្តុំអង្គការទាំងនេះនៅក្នុងការពិភាក្សាដំបូងមួយអំពីសក្តានុពលនៃការបង្កើតមជ្ឈមណ្ឌលសិក្សាធិការ និងការចងចាំ (Memory and Learning Center) ដែលនឹងក្លាយជាទីសុវត្ថិភាពសម្រាប់កិច្ចសន្ទនាអន្តរជំនាន់ និងកម្មវិធីរួមគ្នាដើម្បីប្រមូលរឿងរ៉ាវផ្ទាល់មាត់នៅតាមអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការនៅក្នុងវិស័យការងារនេះ។ អង្គការជាច្រើនទៀត ដូចជា KDK, YFP, និងមជ្ឈមណ្ឌលបុប្ផាណា បានបង្កើត ឬកំពុងបង្កើតទំនាក់ទំនងជាមួយ TSGM ដើម្បីប្រែក្លាយជាមជ្ឈមណ្ឌលកណ្តាលសម្រាប់ការអប់រំ ការស្រាវជ្រាវ និងផ្សព្វផ្សាយប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហម។ ក៏ប៉ុន្តែ TSGM បានកត់សម្គាល់ថា ទោះបីជាខ្លួនបានបង្កើតទំនាក់ទំនងកាន់តែច្រើនជាមួយអង្គការផ្សេងទៀត និងពង្រឹងតួនាទីរបស់ខ្លួននៅក្នុងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (MCFA) ទៅជាធនធានសម្រាប់ការងារបុរាណវិទ្យាក្នុងសម័យ DK នៅទូទាំងប្រទេសក៏ដោយ ក៏ខ្លួនទទួលរងនូវបញ្ហាប្រឈមចំបងមួយគឺកង្វះធនធានមនុស្ស។ TSGM មានចំណាប់អារម្មណ៍ និងជំនាញក្នុងការពង្រីកវិសាលភាព និង ឥទ្ធិពលរបស់ខ្លួន ប៉ុន្តែតើដំណាក់កាលដែលនៅសេសសល់នៃ អ.វ.ត.ក អាចជួយខ្លួនស្វែងរក និងជួលបុគ្គលិកបន្ថែមទៀត ដើម្បីអនុវត្តកម្មវិធីស្រាវជ្រាវដែលត្រូវការយ៉ាងច្រើនតាមវិធីណា? ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរបស់ DC-Cam បានបង្កើតចំណងដោយជោគជ័យ មិនត្រឹមតែជាមួយអ្នកផ្តល់មូលនិធិធំ ពោល

គឺ USAID ប៉ុណ្ណោះទេ មជ្ឈមណ្ឌលនេះក៏បានបង្កើតទំនាក់ទំនងជាមួយឯកអគ្គរដ្ឋទូតនៃបណ្ដាប្រទេសសមាជិកអាស៊ាន និងក្រសួង សំខាន់ៗចំនួនប្រាំមួយរបស់ RGC គឺ៖ ក្រសួងការពារជាតិ ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងមុខងារសាធារណៈ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងដែនដី។ តើពួកគេបានទទួលបទពិសោធន៍អ្វីខ្លះដែលអាចចែករំលែកជាមួយអង្គការផ្សេងទៀត?

នៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ ឬអ្នកសហការផ្សេងទៀត អ្នកពាក់ព័ន្ធជាច្រើន ដែលអ្នកសម្របសម្រួលបានពិគ្រោះយោបល់ ក៏បានសង្កត់ធ្ងន់ទៅលើការយកចិត្តទុកដាក់របស់ពួកគេចំពោះតម្រូវការរបស់យុវជន និងចលនាមួយដែលផ្ដោតលើតម្រូវការនាពេលបច្ចុប្បន្នច្រើនជាងអតីតកាល។ ចំណុចនេះពាក់ព័ន្ធនឹងការពិភាក្សាមុននេះអំពីការពង្រីកនិយមន័យ "ជនរងគ្រោះ" ព្រោះថាឥឡូវនេះមានការសង្កត់ធ្ងន់កាន់តែខ្លាំងលើភាពចាំបាច់របស់ជនរងគ្រោះជំនាន់ក្រោយៗ និងញាតិសន្ដានរបស់ពួកគេ។ CWP បានសង្កត់ធ្ងន់លើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបង្កើតឱ្យមនុស្សចេះត្រិះរិះគិតទៅក្នុងកម្មវិធីសិក្សាអប់រំស្ដីពីប្រវត្តិសាស្ត្រ អំពើប្រល័យពូជសាសន៍ និងសន្តិភាព។ CWP បានពន្យល់ថា ដើម្បីបំពេញតាមតម្រូវការដដែលៗរបស់អ្នករស់រានមានជីវិត ដែលចង់កុំឱ្យអំពើឃោរឃៅកើតឡើង "ម្ដងទៀត" ការងារចាំបាច់បំផុតគឺការចងក្រងអង្គហេតុប្រវត្តិសាស្ត្រដែលបានរៀបចំចម្រុះខុសៗគ្នា ការអប់រំសន្តិភាព និងការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ តាំងពីនៅកម្រិតបឋម។

YFP បានសង្កេតឃើញគម្លាតដ៏ធំរវាងយុវវ័យ និងអ្នករស់រានមានជីវិត និងជនរងគ្រោះវ័យចំណាស់ ទោះបីជាបានរកឃើញនៅក្នុងការស្ទង់មតិមុនៗថា មនុស្សចាស់មានអារម្មណ៍ធូរស្បើយបន្ទាប់ពីបានចែករំលែករឿងរ៉ាវរបស់ខ្លួននៅតាមទីកន្លែងប្រវត្តិសាស្ត្រ ដែល YFP បានរៀបចំ។ នេះក៏ជាការផ្ដល់ឱកាសដល់យុវជនសួរសំណួរ និងយល់កាន់តែច្បាស់អំពីមូលហេតុដែលព្រឹត្តិការណ៍ប្រវត្តិសាស្ត្របានកើតឡើង។ YFP ក៏បានកត់សម្គាល់ផងដែរថា ការធ្វើមូលដ្ឋានីយកម្មការងាររបស់ខ្លួននៅក្នុងសហគមន៍ និងទីតាំងជាក់លាក់ ដែលឧក្រិដ្ឋកម្មបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រ បានបង្កើនចំណាប់អារម្មណ៍ក្នុងចំណោមសហគមន៍ទាំងនោះ។ ចំណុចនេះក៏ស្របនឹងការងារលំបាកលំបិនជាច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅសហគមន៍អន្លង់វែង ដើម្បីកសាងសន្តិភាព និងការយល់ដឹងឱ្យបានកាន់តែទូលំទូលាយអំពីអតីតកាលមិនត្រឹមក្នុងក្របខ័ណ្ឌទូទាំងប្រទេស ក៏ប៉ុន្តែក៏ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះអតីតតំបន់កាន់កាប់ដោយខ្មែរក្រហម និងការចូលរួមរបស់កូនចៅរបស់អតីតកម្មាភិបាលខ្មែរក្រហមរស់នៅទីនោះ។ ថ្នាក់ដឹកនាំមជ្ឈមណ្ឌលបុប្ផាណា និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបរាប់អំពីរឿងនេះដូចគ្នា ហើយពួកគេបាន ផ្ដល់នូវឧទាហរណ៍អំពីកម្មវិធីនានា ដោយដំបូងលើកឡើងអំពីវគ្គបណ្ដុះបណ្ដាលការផលិតខ្សែភាពយន្ត រហូតដល់ការអប់រំពលរដ្ឋជាសាធារណៈ ដើម្បីព្យាយាមជំរុញយុវជនចូលរួមពិនិត្យមើលប្រវត្តិសាស្ត្ររបស់ខ្លួន។ អ្នកតំណាង YRDP បានពន្យល់ថា យុវជនដែលគាត់ធ្វើការជាមួយ លែងមានចិត្តចង់អង្គុយស្ដាប់បឋកថាបង្ហាញដោយ អ.វ.ត.ក អំពីដំណើរការកាត់ក្ដី ឬ សំអាងផ្លូវច្បាប់ទៀតហើយ។ លោកបានពន្យល់ថា អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដែលព្យាយាមជំរុញឱ្យយុវជណចូលរួមការងារអប់រំ ឬ កម្មវិធីផ្សព្វផ្សាយ ដើម្បីជួបជុំជាមួយអ្នករស់រានមានជីវិត ដែលត្រូវរកភាសាទាក់ទាញ និងប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធផ្សព្វផ្សាយប្រកបដោយភាពច្នៃប្រឌិតដើម្បីទិញចិត្ត យុវជន។

អង្គការជាច្រើនបានយកចិត្តទុកដាក់កាន់តែខ្លាំងលើការអភិវឌ្ឍការផ្លាស់ប្តូរ និងការប្រែក្លាយនានា សម្រាប់យុវជនដើម្បីឱ្យពួកគេមើលឃើញក្តីស្រមៃឈានទៅផ្លាស់ប្តូរនាពេលអនាគតឈរលើមូលដ្ឋានសន្តិភាព និងស្ថានភាពក្រោយជម្លោះ ដែលពួកគេបានជំដឹងក្តី និងសម្រាប់មនុស្សជំនាន់ចាស់ដែលនៅរស់រានមានជីវិត។ អ្នកទាំងនេះភាគច្រើនជាប់ផុងក្នុងភាពក្រីក្រ ឬកាលៈទេសៈប្រឈម។ ទោះបីជាអង្គការសង្គមស៊ីវិលសង្ឃឹមថានឹងផ្លាស់ប្តូរសង្គមនៅពេលមានការផ្លាស់ប្តូរជំនាន់ក៏ដោយ អ្នកផ្សេងទៀតបានសង្កត់ធ្ងន់លើតម្រូវការផ្លាស់ប្តូរស្ថានភាពលំបាកដែលជនរងគ្រោះវ័យចំណាស់ជាច្រើនកំពុងជួបប្រទះ ។ KDK និងអង្គការតស៊ូមតិអន្តរជាតិ REDRESS និង Global Survivors Fund ដែលបានធ្វើការស្ទង់មតិជនរងគ្រោះនិងអ្នករស់រានមានជីវិតពីឧក្រិដ្ឋកម្ម SGBV នៅកម្ពុជា បានអំពាវនាវឱ្យមាន សេវាសង្គមដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នករស់រានមានជីវិតចាស់ៗ។ ពួកគេស្នើសុំវិភាគទានថវិកា ឬការទទួលបានបណ្ណ "IDPoor" របស់រដ្ឋាភិបាល ដែលលើកលែងថ្លៃព្យាបាល និងបញ្ចុះថ្លៃអាហារសម្រាប់ពលរដ្ឋក្រីក្របំផុតនៅក្នុងប្រទេស ។ ការពង្រីកកម្មវិធីទាំងនេះដល់អ្នករស់រានមានជីវិតពី SGBV និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាទូទៅគឺពឹងផ្អែកខ្លាំងលើការគាំទ្រផ្នែកស្ថាប័នពីស្ថាប័នសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា ក្រសួងសង្គមកិច្ច ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិគាំពារសង្គម ឬ មូលនិធិសន្តិសុខសង្គម។ គំនិតផ្តួចផ្តើមរយៈពេលវែងទាំងនេះក៏ឆ្លើយតបកាន់តែមានប្រសិទ្ធភាពចំពោះការរិះគន់តូចតាចកន្លងមកអំពី "ការព្យាករណ៍" របស់ អ.វ.ត.ក លើគម្រោងសំណងតាមផ្លូវតុលាការរបស់ អ.វ.ត.ក។ បញ្ហានេះត្រូវបានពិភាក្សានៅក្នុងការសិក្សាស្រាវជ្រាវ ដែលបានដាក់ជាឯកសារយោងនៅក្នុងការពិគ្រោះយោបល់របស់យើងផងដែរ។

ទោះបីជាការពង្រីកទម្រង់ស្ថាប័ននៃរបបសន្តិសុខសង្គម ឬ កម្មវិធីសុខុមាលភាព នៅឆ្ងាយក៏ដោយ អង្គការសង្គមស៊ីវិលមួយចំនួនបានអនុវត្តការងារមួយចំនួនរួចហើយនៅក្នុងកម្មវិធីសាកល្បងតូចៗ។ KDK បានធ្វើគម្រោងសាកល្បងស្តីពីការថែទាំខ្លួនឯងនៅតាមសហគមន៍ និងការបណ្តុះបណ្តាលស្តីពីការប្រឹក្សាជាមូលដ្ឋាន និងបញ្ហាសុខភាពផ្លូវចិត្តសម្រាប់ក្រុមអ្នករស់រានមានជីវិត។ អង្គការ HelpAge Cambodia ដែលមានមូលដ្ឋាននៅខេត្តបាត់ដំបងបានបន្តអភិវឌ្ឍ និងគាំទ្រដល់ការបង្កើតសមាគមមនុស្សចាស់ (OPAs) ស្របជាមួយសមាគមជនរងគ្រោះ ដែលលើកទឹកចិត្តក្មេងៗជំនាន់ក្រោយឱ្យមើលថែមនុស្សចាស់ និងប្រយុទ្ធប្រឆាំងការរើសអើងនៅក្នុងសហគមន៍ជួយខ្លួនឯងអន្តរជំនាន់។ ដូចគ្នានេះដែរ DC-Cam បានបង្កើត "CamboCorps" នៃបណ្តាញយុវជនស្ម័គ្រចិត្តទូទាំងប្រទេស ដើម្បីត្រួតពិនិត្យសុខភាព និងការស្ទង់មតិអ្នករស់រានមានជីវិត និងជួយបញ្ជូនពួកគេទៅព្យាបាលតាមតម្រូវការ។

ការអភិវឌ្ឍន៍កម្មវិធីស្រដៀងគ្នានៅក្នុងចំណោមសង្គមស៊ីវិល ដោយមានគោលដៅឧត្តមគតិទូលំទូលាយសម្រាប់ប្រែក្លាយការផ្លាស់ប្តូរអនាគត គឺពិតជាមានសារៈសំខាន់ និងជាការបំផុសគំនិត ប៉ុន្តែវានៅតែជាឱកាសដែលទាមទារឱ្យមានការរួមបញ្ចូលគ្នា និងសមាហរណកម្មឱ្យបានកាន់តែច្រើន។ ដូច ជា សុភាព មកពីមជ្ឈមណ្ឌល បុប្ផាណា បានពន្យល់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់របស់យើង ការផ្សះផ្សាអាចគ្រាន់តែជា "សុបិន្ត" សម្រាប់អ្នករស់រានមានជីវិតមួយចំនួន ហើយការអភ័យទោសគឺជាធំមួយ ប៉ុន្តែទាំងនេះគឺជា "លទ្ធភាពពិត" សម្រាប់ក្មេងជំនាន់ក្រោយ។ ក្រោយការពិភាក្សាទាំងអស់នេះបានបញ្ចប់ អ្នកសម្របសម្រួល និងលេខាធិការដ្ឋានឈានចូលទៅសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ ជាមួយបំណងដ៏ពុះកញ្ជ្រោល និងចង់ចូលរួមខ្លាំង។

៤១ Melanie Hyde, Emma Palmer និង Sarah Williams សំណងផ្លាស់ប្តូរសម្រាប់អំពើហិង្សាផ្លូវភេទ និងយេនឌ័រនៅ អ.វ.ត.ក: ការឆ្លុះបញ្ចាំង អនុសាសន៍ និងជំហានបន្ទាប់ (២០១៤) មជ្ឈមណ្ឌលសិទ្ធិមនុស្សអូស្រ្តាលី និងគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរជាតិអាស៊ី។

៤២ REDRESS ប្រទេសកម្ពុជា៖ ឱកាសសម្រាប់សំណងសម្រាប់អ្នករស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះ (រង់ចាំការបោះពុម្ពផ្សាយត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២); អង្គការ REDRESS, មូលនិធិអ្នករស់រានមានជីវិតសកល និង អង្គការក្តីករុណា, សំណងសម្រាប់អ្នករស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះ៖ សង្ខេបអំពីប្រទេស៖ ប្រទេសកម្ពុជា (ខែកញ្ញា ឆ្នាំ២០២១) អាចចូលមើលបាននៅ៖ https://drive.google.com/file/d/1dm1XHmUg_tp8YTFTb4kDIDrJmn 5tlzcQ/view ។

៤៣ Christoph Sperfeldt និង Rachel Hughes, ការព្យាករណ៍នៃសំណង ទិនានុប្បវត្តិនៃការអនុវត្តសិទ្ធិមនុស្ស ១២(៣) (ខែវិច្ឆិកា ឆ្នាំ២០២០), ទំព័រ៥៤៥-៥៦៥។

# លេខាធិការដ្ឋានសិក្ខាសាលា និង ក្រុមការងារគាំទ្រ អ.វ.ត.ក

បន្ថែមលើការពិគ្រោះជាបន្តបន្ទាប់ ដែលរៀបចំមុន និងកើតចេញជាសិក្ខាសាលារយៈពេលបីថ្ងៃនេះ ទាំងភាគីជាតិ និងអន្តរជាតិនៃ OA បានគាំទ្រលេខាធិការដ្ឋានសិក្ខាសាលានៅសប្តាហ៍ចុងក្រោយ មុនពេលសិក្ខាសាលាទទួលបានការចាត់តាំង និងការបញ្ជូនបុគ្គលិកចំនួន ៣៤នាក់ពី អ.វ.ត.ក ទៅចូលរួមគាំទ្រព្រឹត្តិការណ៍នេះ។ កិច្ចប្រជុំសម្របសម្រួលសំខាន់ៗជាមួយប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល និងក្រុមការងារ ដែលបានគាំទ្រយ៉ាងពេញទំហឹង បានធ្វើឡើងប្រហែលពីរសប្តាហ៍មុនសិក្ខាសាលា ហើយក្រុមការងារបានអនុវត្តការងារត្រៀមរៀបចំយ៉ាងសកម្មចុងក្រោយចាប់ពីចំណុចនោះមក ក្នុងស្មារតីសហការ និងគាំទ្រយ៉ាងខ្លាំង។

លោក ហង្ស វណ្ណៈ ប្រធានផ្នែកគាំពារជនរងគ្រោះនៃតុលាការ (VSS) បានធ្វើជាសហប្រធាននៃវគ្គពេញអង្គនៃសិក្ខាសាលា រួមជាមួយនឹងអ្នកសម្របសម្រួល និងប្រធានក្រុមអ្នកសម្របសម្រួល។ VSS ក៏បានរៀបចំឱ្យមានការចូលរួម និងវគ្គមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១រូប សម្រាប់រយៈពេលបីថ្ងៃ ក៏ដូចជាការចូលរួមរបស់ជនរងគ្រោះទាំងបីនាក់ ដែលនៅរស់រានមានជីវិតពីមន្ទីរសន្តិសុខ ស-២១ ក្នុងពិធីបើកសិក្ខាសាលាផងដែរ។ លោក កើត សុខា ដែលជាធម្មតាជាមន្ត្រីទទួលបន្ទុកអង្គភាពគាំពារសាក្សី និងអ្នកជំនាញរបស់តុលាការ (WESU) បានក្លាយជាសហមន្ត្រីសម្របសម្រួល ធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកសម្របសម្រួលសិក្ខាសាលាគឺ លោក Daniel Mattes ដើម្បីឆ្លើយតបរាល់ព័ត៌មានលម្អិតសំខាន់ៗពាក់ព័ន្ធនឹងការងាររៀបចំមុន និងអំឡុងពេលព្រឹត្តិការណ៍។ អ្នកសម្របសម្រួលចំនួនប្រាំបីនាក់ត្រូវបានបញ្ជូនមកពីការិយាល័យផ្សេងៗគ្នានៃ អ.វ.ត.ក ដើម្បីជួយដឹកនាំ និងគាំទ្រការពិភាក្សានៅក្នុងក្រុមពិភាក្សាប្រធានបទចំនួនប្រាំបី ដែលបានជួបប្រជុំពេញរយៈពេលសិក្ខាសាលាចំនួនបីថ្ងៃ (ក្រៅពីក្រុមការងារខាងក្រោម)។ អ្នកសម្របសម្រួលទាំងប្រាំបីនាក់នេះបានរៀបចំវិធីសាស្ត្រពិភាក្សា សំណួរ និងការបំផុសគំនិតក្រោមការដឹកនាំ និងការត្រួតពិនិត្យរបស់ប្រធានក្រុមអ្នកសម្របសម្រួល Sangeetha Yogendran។

បុគ្គលិកមកពីផ្នែកជាតិនៃការិយាល័យរដ្ឋបាលបានជួយការងារចុះឈ្មោះ និងការងារពិធីសារៈសំខាន់ៗជូនឥស្សរជនដែលចូលរួមក្នុងវគ្គបើក និងវគ្គបិទ ដើម្បីធានាថាអ្នកចូលរួមទាំងអស់អង្គុយត្រឹមត្រូវ និងមានសីលធម៌។ អ្នកបកប្រែបន្ទប់សវនាការចំនួន ០៣ នាក់ បានចូលរួមជារៀងរាល់ថ្ងៃសិក្ខាសាលា ដើម្បីបកប្រែភាសាខ្មែរ និងអង់គ្លេស សម្រាប់វគ្គពេញអង្គទាំងអស់ ហើយប្តូរវេនជួយបកប្រែភាសាខ្មែរ និងអង់គ្លេសជូនក្រុមពិភាក្សាតាមតម្រូវការ។

អ្នកបកប្រែក៏បានបំពេញការងារបកប្រែក្នុងករណីចាំបាច់នៅពេលមានតម្រូវការភ្លាមៗ ដូចជាក្នុងពេលពិសាអាហារថ្ងៃត្រង់។ ការបកប្រែក៏ត្រូវការនៅពេលចាក់ផ្សាយព្រឹត្តិការណ៍តាមអ៊ីនធឺណិត ដូចដែលបានពិពណ៌នាខាងក្រោមនៅក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា។ អ្នកបកប្រែឯកសារ និងអ្នកប្រតិចារឹករបស់តុលាការក៏បានផ្តល់ការ គាំទ្រសំខាន់ៗមុន និងក្រោយសិក្ខាសាលាផងដែរ ដូចក្រុមការងារផ្នែកសេវាទូទៅ ដែលជួយការងារដឹកជញ្ជូន និងផ្គត់ផ្គង់ឧបករណ៍សំខាន់ៗពីបរិវេណ អ.វ.ត.ក និងទីតាំងសណ្ឋាគារ។

ផ្នែកកិច្ចការសាធារណៈ (PAS) គ្រប់គ្រងយុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយសម្រាប់ព្រឹត្តិការណ៍នេះ។ លោក នេត្រ ភក្ត្រា ប្រធាន PAS បានចាប់ផ្តើមសិក្ខាសាលាក្នុងនាមជាអ្នកកាន់កម្មវិធីក្នុងវគ្គបើកដំបូង ដើម្បីឧទ្ទេសនាមវាគ្មិនកិត្តិយសមកពី RGC អ.វ.ត.ក និងសហគមន៍ការទូត។ PAS បានរៀបចំសន្និសីទសារព័ត៌មានតាមរយៈ Zoom នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ មួយថ្ងៃមុនពេលបើកសិក្ខាសាលា ដើម្បីផ្តល់ព័ត៌មានសង្ខេបជូនប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកអំពីកិច្ចព្រមព្រៀងបន្ថែម កាលបរិច្ឆេទរំពឹងទុកសម្រាប់ការប្រកាសសាលដីកាចុងក្រោយក្នុងសំណុំរឿង ០០២/០២ ផែនការសម្រាប់ដំណាក់កាលដែលនៅសេសសល់ និងគោលដៅសិក្ខាសាលាស្តីពីជនរងគ្រោះ។ ប្រធាន VSS លោក ហង្ស វណ្ណៈ និងអ្នកសម្របសម្រួលសិក្ខាសាលា លោក Daniel Mattes បានចូលរួមសន្និសីទ និងសង្ខេបគោលបំណងនៃព្រឹត្តិការណ៍ និងឆ្លើយតបសំណួរនានា។ បុគ្គលិក PAS ក៏បានរៀបចំឱ្យមានការចូលរួមពីប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក អ្នកសារព័ត៌មាន ឬ ក្រុមការងារវីដេអូ ដើម្បីចូលរួមវគ្គសម្រាប់សាធារណៈនៅពេលបើក និងបិទសិក្ខាសាលា។ អ្នកសារព័ត៌មាន អ្នកថតរូប និងអ្នកថតវីដេអូប្រមាណ ១០នាក់ មកពីប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនបានចូលរួមក្នុងវគ្គបើកសិក្ខាសាលានៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ហើយ ០៣នាក់បានវិលត្រឡប់មកចូលរួម វគ្គបិទនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ ២០២២។ បុគ្គលិក PAS ក៏បានថតរូបព្រឹត្តិការណ៍ទាំងមូលសម្រាប់សិក្ខាសាលា ហើយចាត់ចែងបច្ចុប្បន្នភាពជាប្រចាំនៅលើគេហទំព័រ អ.វ.ត.ក និងទំព័រ Facebook និង Twitter ដើម្បីជូនដំណឹងដល់សាធារណជនអំពីសកម្មភាពរបស់ព្រឹត្តិការណ៍នេះ។ PAS ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកសម្របសម្រួលដើម្បីផ្តល់សេចក្តីប្រកាសព័ត៌មានបន្ទាប់ពីថ្ងៃដំបូង និងថ្ងៃចុងក្រោយនៃសិក្ខាសាលា ជាភាសាខ្មែរ និងភាសាអង់គ្លេស (ដែលសេចក្តីប្រកាសព័ត៌មានទាំងអស់ត្រូវបានរួមបញ្ចូលនៅក្នុងឧបសម្ព័ន្ធទី IV នៃរបាយការណ៍នេះ) ដើម្បីឱ្យមានការផ្សព្វផ្សាយព័ត៌មាននៃសិក្ខាសាលានៅតាមសារព័ត៌មានក្នុងប្រទេស។

ក្រៅពីផែនការសុវត្ថិភាពកូវីដ-១៩ និងការបញ្ជាក់ការចាក់វ៉ាក់សាំងដែលបានពិពណ៌នាខាងលើ ផ្នែកសន្តិសុខ និងសុវត្ថិភាពរបស់តុលាការបានធ្វើការវាយតម្លៃបន្ថែមអំពីគោលការណ៍សុវត្ថិភាពនៃទីកន្លែង ហើយបានរៀបចំជូនតំណាង RGC ឯកអគ្គរដ្ឋទូត និងឥស្សរជនជាន់ខ្ពស់ និងមន្ត្រីការទូតដទៃទៀត ចូលរួមទាំងកម្មវិធីបើក និងបិទ សិក្ខាសាលា។ សមាជិកក្រុមចំនួន ១០នាក់ មានវត្តមានពេញរយៈពេលបីថ្ងៃ ហើយបានជួយចុះឈ្មោះអ្នកចូលរួម ផ្តល់បណ្ណជូនអ្នកចូលរួម និងចាត់ចែងសម្របសម្រួលអ្នកចូលរួមនៅតាមទីតាំងអង្គុយ។

បុគ្គលិកអង្គភាពសោតទស្សន៍ (AV) និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) របស់តុលាការ ចំនួន ០៤រូប បានរៀបចំជាច្រើនសប្តាហ៍មុនព្រឹត្តិការណ៍ និងគ្រប់គ្រងតម្រូវការបច្ចេកវិទ្យាព័ត៌មានស្មុគស្មាញនៅទីតាំង សិក្ខាសាលា។ អង្គភាព AV បានរៀបចំ និងសម្របសម្រួលការផ្តល់ឧបករណ៍បកប្រែប្រដេញចំនួន ២០០ ឧបករណ៍ និងប្រព័ន្ធចាប់រលក



↑ មន្ត្រីបច្ចេកទេស លោក ឌិត និមល (ស្ដាំ) លោក ឃ្លោក សួសសូឡាលីន (កណ្ដាល) និង លោក ហេង វិចិត្រ (ឆ្វេង) ។

សញ្ញាអ៊ីនហ្វ្រារ៉េដ ដែលត្រូវការសម្រាប់ការងារបកប្រែ។ អង្គភាព AV និង ICT ក៏បានចាត់ចែងការតម្លើង និងការកាន់កាម៉េរ៉ាចំនួន ០៣ នៅក្នុងសាលសិក្ខាសាលា ដើម្បីថតទុកព្រឹត្តិការណ៍ទាំងស្រុងសម្រាប់កំណត់ត្រាតុលាការ។ ការថតរូបភាពសម្លេងទាំងនេះក៏ត្រូវបានចាក់ផ្សាយផ្ទាល់ជាសាធារណៈនៅលើទំព័រ Youtube និង Facebook របស់ អ.វ.ត.ក ក្នុងអំឡុងពេលបើក និងបិទសិក្ខាសាលា ហើយបានបន្តផ្សាយជូនអ្នកចូលរួមក្នុងព្រឹត្តិការណ៍នេះតាមប្រព័ន្ធអនឡាញ KUDO។ អង្គភាព AV និង ICT ក៏បានចាត់ចែងវាគ្មិនសំខាន់ពីររូបដែលចូលរួមក្នុងព្រឹត្តិការណ៍នេះពីក្រៅប្រទេស អាចថ្លែងសុន្ទរកថាផ្ទាល់ជូនដល់ទស្សនិកជនតាមរយៈថ្នាល KUDO។

អង្គភាព AV និង ICT បានត្រៀមលក្ខណៈជាច្រើនសប្តាហ៍ជាមុន ដើម្បីរៀបចំ និងសាកល្បងប្រព័ន្ធ ដើម្បីធានាថា សុន្ទរកថានឹងមិនមានបញ្ហាបច្ចេកទេសធំដុំ ហើយដើម្បីធានាថាព្រឹត្តិការណ៍នេះដំណើរការដោយរលូន។ អង្គភាព AV ក៏បាន "ចាត់ចែងឆាក" ព្រឹត្តិការណ៍នេះផងដែរ ដើម្បីអាចឱ្យកាម៉េរ៉ាទាំង០៣ ផ្ដិតយករូបភាពវាគ្មិន មិនថានៅពេលឈរលើឆាក ឬ នៅតាមតុ។ វាគ្មិន នឹងត្រូវបានបង្ហាញនៅលើអេក្រង់ LCD ចំនួន ០៤ ក្នុងសាលប្រជុំដែលបានថតទុកសម្រាប់កំណត់ត្រាព្រឹត្តិការណ៍ និងបង្ហាញនៅលើ KUDO ជូនអ្នកចូលរួមទស្សនាតាមប្រព័ន្ធអនឡាញដែលបានអញ្ជើញឱ្យចូលរួម។ អង្គភាព AV ក៏បានគ្រប់គ្រងវីដេអូ ឬបទបង្ហាញ ដែលចាំបាច់ត្រូវបញ្ចាំងនៅលើអេក្រង់ក្នុងអំឡុងពេលព្រឹត្តិការណ៍ក្នុងសប្តាហ៍

នេះ។ យើងខ្ញុំសូមអរគុណចំពោះការងារដ៏រលូនរបស់អង្គភាព AV និង ICT មកពីតុលាការ បើទោះជាសិក្ខាសាលាមានភាពរអាក់រអួលតិចតួចបំផុតក៏ដោយក្តី ហើយសិក្ខាសាលាអាចផ្សាយបន្តទៅអ្នកទស្សនាបន្ថែមចំនួន ៨៦ នាក់នៅលើថ្នាល KUDO ដែលបានចូលរួមគ្រប់វគ្គ ឬ វគ្គខ្លះក្នុងព្រឹត្តិការណ៍រយៈពេលបីថ្ងៃ។ អង្គភាពទាំងនេះក៏បានអនុញ្ញាតឱ្យ PAS ទាញយកខ្លឹមសារសោតទស្សន៍សម្រាប់តម្រូវការកិច្ចការសាធារណៈនាពេលអនាគត ហើយថែមទាំងធានាថាសិក្ខាសាលានឹងត្រូវបានកត់ត្រាទុកសម្រាប់កូនចៅជំនាន់ក្រោយ។

ទោះបីជាឧបករណ៍ និងសម្ភារៈមួយចំនួនត្រូវបានជូននៅទីតាំងសណ្ឋាគារក៏ដោយ ឧបករណ៍ជំនួយដែលប្រើសម្រាប់ការបកប្រែភាសា ឬ សម្រាប់តម្រូវការ AV និង ICT ត្រូវបានដកយកចេញពីបញ្ជីសារពើភ័ណ្ឌ អ.វ.ត.ក មកប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនៅក្នុងសិក្ខាសាលា ដើម្បីជៀសវាងការបន្ថែមការចំណាយទៅលើថវិកាសរុបសម្រាប់ព្រឹត្តិការណ៍នោះ។ យើងបានជាវថ្នាល KUDO មុនព្រឹត្តិការណ៍នេះ ដូច្នេះការចំណាយបន្ថែមសម្រាប់ការប្រើប្រាស់ថ្នាលអនឡាញ មានកំណត់។

# របៀបវារៈ និងអ្នកចូលរួម

របៀបវារៈនៃសិក្ខាសាលា ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងគោលដៅដែលមានចែងក្នុងរបាយការណ៍រហូតមកដល់ពេលបច្ចុប្បន្ន។ ព្រឹត្តិការណ៍នេះប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី ៥ ខែឧសភា ឆ្នាំ២០២២ ចាប់ពីម៉ោង ៩ព្រឹក ដល់៥ល្ងាច ជារៀងរាល់ថ្ងៃ។ សិក្ខាសាលានេះបើកចូលជាសាធារណៈនៅក្នុងពេលបើក និងបិទសិក្ខាសាលា។ ការចូលរួមរបស់សាធារណជនត្រូវបានអនុញ្ញាតតាមរយៈការផ្សាយបន្តផ្ទាល់នៃព្រឹត្តិការណ៍តាមប្រព័ន្ធអ៊ីនធឺណិត ហើយអ្នកសារព័ត៌មានត្រូវបានអញ្ជើញឱ្យចូលរួម ពិធីបើកព្រឹត្តិការណ៍នៅថ្ងៃទី៣ ខែឧសភា ដែលមានភ្ញៀវចូលរួមប្រមាណ ១២០ នាក់ រួមទាំងឥស្សរជនមួយចំនួនមកពីរាជរដ្ឋាភិបាលកម្ពុជា បេសកកម្មការទូតនៅទីក្រុងភ្នំពេញ និងអង្គការអន្តរជាតិនានា។ អ្នករៀបចំសិក្ខាសាលាបានជ្រើសរើសវាគ្មិនកិត្តិយសដែលតំណាងឱ្យ ភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងដំណាក់កាលដែលនៅសេសសល់របស់ អ.វ.ត.ក ហើយដែលអាចដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទាក់ទងនឹងជនរងគ្រោះ ស្របតាមក្របខ័ណ្ឌនៃឧបសម្ព័ន្ធ និងរបាយការណ៍របស់សហចៅក្រមរបាយការណ៍។ ពិធីបើករួមមានសុន្ទរកថាស្វាគមន៍របស់ ឯកឧត្តម ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទី អ.វ.ត.ក, ឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតបារាំង និងជាសហប្រធាននៃមិត្ត អ.វ.ត.ក និង ឯកឧត្តម កែវ រ៉េមី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាអនុប្រធានអចិន្ត្រៃយ៍នៃក្រុមការងាររាជ រដ្ឋាភិបាលលើដំណើរការនីតិវិធី អ.វ.ត.ក។ អ្នកសម្របសម្រួលសិក្ខាសាលា បណ្ឌិត David Cohen ក៏បានណែនាំខ្លួនដល់អ្នកចូលរួម បន្ទាប់មកណែនាំសារពិសេសតាមប្រព័ន្ធវីដេអូរបស់ លោកជំទាវ បណ្ឌិត Beth Van Schaack ឯកអគ្គរដ្ឋទូតគោចរសហរដ្ឋអាមេរិកសម្រាប់យុត្តិធម៌ឧក្រិដ្ឋកម្មសកល។

នៅក្នុងសុន្ទរកថាជាវីដេអូខ្លីរបស់លោកជំទាវឯកអគ្គរដ្ឋទូត Van Schaack បានកត់សម្គាល់ថា "ជាមួយនឹងការបង្កើតមុខងារដែលនៅសេសសល់របស់ អ.វ.ត.ក និងជាមួយនឹងការលើកទឹកចិត្តនៅក្នុងអនុសាសន៍របាយការណ៍ប្រឹក្សាយោបល់ លោក-អ្នកមានឱកាសដ៏កម្រមួយនេះដើម្បីធានាថា កិច្ចខិតខំប្រឹងប្រែងនឹងបន្តទៅមុខដើម្បីព្យាបាលរបួសផ្លូវចិត្តជូនអ្នកដែលទទួលរង" ។

សិក្ខាសាលារយៈពេលបីថ្ងៃនេះមានអ្នកចូលរួមទៀងទាត់ជាង ៩០នាក់ក្នុងមួយថ្ងៃ ក្នុងនោះមានដើមបណ្តឹង រដ្ឋប្បវេណីចំនួន ១៥នាក់។ មានការថយចុះតិចតួចបំផុតក្នុងចំណោមអ្នកចូលរួមសរុប។ ស្ទើរតែគ្រប់គ្នាបានចូលរួមសិក្ខាសាលារយៈពេលបីថ្ងៃ។ បន្ទាប់ពីពិធីបើកនៅពីថ្ងៃទី៣ ខែឧសភា សិក្ខាសាលាបានឈានចូលវគ្គបិទ ដោយមិនមានការផ្សាយផ្ទាល់នៅលើគេហទំព័រ អ.វ.ត.ក ឬបណ្តាញទំនាក់ទំនងសង្គមនោះទេ ហើយអាចចូលបានសម្រាប់តែ

៤៤ ខ្សែវីដេអូនៃចំណាប់អារម្មណ៍របស់ឯកអគ្គរដ្ឋទូត Van Schaack អាចមើលនៅលើទំព័រ Youtube អ.វ.ត.ក៖ <https://youtu.be/8PW14gKI_WY> ។

អ្នកដែលត្រូវបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាតែប៉ុណ្ណោះ។ វគ្គបិទនេះបានសម្របសម្រួលការពិភាក្សាយ៉ាងស៊ីជម្រៅរវាងអ្នកចូលរួមនៅក្នុងក្រុមការងារតូចៗ ដើម្បីធានាថាជនរងគ្រោះ-អ្នកនៅរស់រានមានជីវិតដែលចូលរួមក្នុងព្រឹត្តិការណ៍នេះមានអារម្មណ៍សុខស្រួល និងសុវត្ថិភាពក្នុងការចែករំលែករឿងរ៉ាវរបស់ពួកគេ និងទទួលបាននូវភាពឯកជនខ្លះសម្រាប់អ្នកថ្លែងសុន្ទរកថាដើម្បីបើកឱ្យមានការលើកឡើងកាន់តែមានសេរីភាពថែមទៀត។

ទោះបីជាលទ្ធផលចម្បងនៃសិក្ខាសាលាកើតចេញពីការពិភាក្សាក្រុមក៏ដោយ យើងមើលឃើញថាចំណុចសំខាន់គឺការផ្ដល់ឱ្យអ្នកចូលរួមយល់ដឹងអំពីឯករាជ្យបុគ្គលពីសិក្ខាសាលា និងជាមួយបទពិសោធន៍យ៉ាងស៊ីជម្រៅនៅ អ.វ.ត.ក និងស្ថាប័នផ្សេងទៀតទាក់ទងនឹងប្រធានបទកំណត់សិក្ខាសាលា។ របៀបវារៈ បុគ្គលទាំងប្រាំនាក់ដែលត្រូវបានជ្រើសរើសជាវាគ្មិនកិត្តិយសត្រូវបានស្នើសុំឱ្យឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ខ្លួន ដោយសារវាពាក់ព័ន្ធជាពិសេសទៅនឹងប្រធានបទ និងបញ្ហាសំខាន់ៗដែលសិក្ខាសាលានឹងធ្វើឡើង។ គំនិតសំខាន់នោះគឺថា សុន្ទរកថាសំខាន់ៗទាំងនេះនឹងផ្ដល់នូវទស្សនៈ និងការបំផុសគំនិតបន្ថែម ឬ ថ្មីសម្រាប់អ្នកចូលរួម ដែលអាចជួយពួកគេក្នុងការងារជាក្រុមបាន។ វាគ្មិនកិត្តិយស និងបទបង្ហាញរបស់ពួកគេនឹងត្រូវបានពិភាក្សាខាងក្រោមនៅក្នុងផ្នែកទី II.៦។ ដើម្បីធ្វើសមាហរណកម្មសុន្ទរកថាសំខាន់ៗ និងការងារក្រុមពិភាក្សា សុន្ទរកថាបានបញ្ចប់ដោយបន្ទាប់មកមានការពិភាក្សាជាក្រុមលើប្រធានបទ។ សរុបមក វគ្គការងារពិភាក្សាប្រាំក្រុមបានធ្វើឡើង ហើយវគ្គនីមួយៗមានគោលដៅដែលបានកំណត់ឡើង ដើម្បីនៅចុងក្រោយ រៀបចំបង្កើតជាបទបង្ហាញរបស់ក្រុមនីមួយៗអំពីលទ្ធផលរបស់ខ្លួន។ ក្រុមពិភាក្សាបានប្រមូលផ្ដុំគ្នាជាលើកដំបូងនៅរសៀលថ្ងៃទី៤ ខែឧសភា ដើម្បីលើកយកចំណុចដែលបានលើកឡើងក្នុងពេលដំណើរការ សិក្ខាសាលាបានពាក់កណ្ដាលផ្លូវ មកចែករំលែកដើម្បីពិភាក្សា និងសំណួរដែលកំពុងបន្តចោទសួរពីអ្នកចូលរួមទាំងអស់ចំពោះបទបង្ហាញខ្លីៗពីក្រុមការងារនីមួយៗ។ សុន្ទរកថាគន្លឹះចំនួនពីរ និងកិច្ចពិភាក្សាពីរបន្ថែមទៀតបានធ្វើឡើងបន្ទាប់ពីកិច្ចប្រជុំពេញ និងមុនពេលកិច្ចប្រជុំពេញអង្គចុងក្រោយនៅរសៀលថ្ងៃទី០៥ ខែឧសភា។

ទោះបីជាមិនអនុញ្ញាតឱ្យសាធារណៈជនចូលរួមស្ទើរតែពេញកម្មវិធីក៏ដោយ រាល់សុន្ទរកថាបន្តផ្ទាល់ និងបទបង្ហាញនៅក្នុងវគ្គពេញអង្គអាចចូលមើលបានតាមថ្នាល KUDO សម្រាប់អ្នកចូលរួមអន្តរជាតិមួយចំនួនតូច ដែលត្រូវបានអញ្ជើញដោយលេខាធិការដ្ឋាន។ មានអ្នកទស្សនាចំនួន ៨៦នាក់នៅលើថ្នាល KUDO ក្នុងរយៈពេលបីថ្ងៃនេះ រួមទាំងនិស្សិតកម្ពុជាមួយចំនួនធំនៅក្នុងផ្នែកច្បាប់ ប្រវត្តិសាស្ត្រ និងសិទ្ធិមនុស្សនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (PUC) និងនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE)។ ភ្ញៀវក៏បានចូលរួមតាម អនឡាញពីស្ថាប័ន និងអង្គការអន្តរជាតិឈានមុខ រួមមានគំនិតផ្ដួចផ្ដើមនីតិរដ្ឋនៃសមាគមគណមេធាវី American Bar Association Rule of Law Initiative, Swisspeace, Global Survivors Fund, REDRESS, GD Alliance, Asia Justice Coalition, University of Melbourne, La Trobe University, European Union Institute, សាលាច្បាប់ Harvard, USAID, និងស្ថានទូតស្វីសនៅទីក្រុងបាងកក។

នៅរសៀលថ្ងៃទី៥ ខែឧសភា សិក្ខាសាលាបានបន្តទៅសម័យប្រជុំពេញអង្គចុងក្រោយរបស់ខ្លួន ដែលក្រុមពិភាក្សាត្រូវបានស្នើឱ្យធ្វើបទបង្ហាញក្រោយពិភាក្សាក្រុម និងចែករំលែកសំណើគម្រោងណាមួយដែលត្រូវចង់ដាក់ជូនសម្រាប់ការពិចារណានៅដំណាក់កាលដែលនៅ

សេសសល់របស់ អ.វ.ត.ក។ សំណើទាំងនេះត្រូវបានពិភាក្សាលម្អិតខាងក្រោមនៅក្នុងផ្នែកទី II.៥។ កិច្ចប្រជុំនៅរសៀលនោះ បានបើកជូនសាធារណជនដោយមានការផ្សាយផ្ទាល់តាមប្រព័ន្ធអ៊ីនធឺណេតម្តងទៀត និងមានការចូលរួមពីភ្ញៀវបន្ថែម រួមទាំងតំណាងមួយចំនួនមកពីស្ថានបេសកកម្មការទូតនៅទីក្រុងភ្នំពេញ ក៏ដូចជាអ្នកសារព័ត៌មានមួយចំនួនផងដែរ។ លេខាធិការដ្ឋានសិក្ខាសាលាបានសម្រេចបើកសម័យប្រជុំពេញអង្គដល់សមាជិកអង្គទូត និងសាធារណជន ដើម្បីបង្ហាញសំណើសំខាន់ៗដែលអ្នកចូលរួមនឹងចែករំលែក និងអញ្ជើញតំណាងម្ចាស់ជំនួយមកពីដៃគូសក្តានុពល ឬ ភ្នាក់ងារអនុវត្តក្នុងចំណោមអ្នកចូលរួមសិក្ខាសាលាមកស្តាប់ដោយផ្ទាល់។ កិច្ចប្រជុំពេញអង្គនេះ ធ្វើឡើងមុនសុន្ទរកថាចុងក្រោយរបស់អ្នកសម្របសម្រួល បណ្ឌិត David Cohen សហប្រធានពេញអង្គ និងសហប្រធាន VSS លោក ហង្ស វណ្ណៈ និងសុន្ទរកថាបិទពីដើមបណ្តឹងរដ្ឋប្បវេណីពីររូបដែលចូលរួមសិក្ខាសាលា គឺ លោក ចាន់ សាត និងលោកស្រី ពេជ្រ ស្រីផល។ បន្ទាប់មក សិក្ខាសាលាបានបិទដោយសុន្ទរកថាដ៏កក់ក្តៅទទួលបានការគាំទ្ររបស់ ឯកឧត្តម Mikami Masahiro ឯកអគ្គរដ្ឋទូតជប៉ុន និងជាសហប្រធាននៃមិត្ត អ.វ.ត.ក និងសុន្ទរកថាចុងក្រោយរបស់ លោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល អ.វ.ត.ក។ ពិធីបិទវគ្គទាំងនេះក៏មានការចូលរួមពីប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) ឯកឧត្តម លី ច័ន្ទតុលា ឯកអគ្គរដ្ឋទូតអង់គ្លេស Tina Redshaw និងលោក Jacques Pellet ឯកអគ្គរដ្ឋទូតបារាំង។ តំណាងស្ថានទូត និងការិយាល័យតំណាងទូតនៃប្រទេសអូស្ត្រាលី សហរដ្ឋអាមេរិក អាល្លឺម៉ង់ សហភាពអឺរ៉ុប ស្វីស ទួរគី ថៃ និងវៀតណាម តំណាងអង្គការយូណេស្កូ UNOHCHR និងអង្គការ UNWOMEN ក៏បានចូលរួមផងដែរ។

អ្នកចូលរួមចំនួន ៩០នាក់ដែលបានចូលរួមសិក្ខាសាលាជារៀងរាល់ថ្ងៃនោះ រួមមានតំណាងអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក និងអង្គការអន្តរជាតិ ស្ថាប័នរដ្ឋ និងសារមន្ទីរ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អ្នកសិក្សាឯករាជ្យ មេធាវី និងអ្នកស្រាវជ្រាវ ព្រមទាំងភាគី អ.វ.ត.ក និងបុគ្គលិក ដែលជាតំណាងអង្គការ និងស្ថាប័នជាច្រើន ដូចបានរៀបរាប់នៅដើមដំបូងនៃរបាយការណ៍នេះ។ អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនដែលធ្វើការងារលើបញ្ហាទាក់ទងនឹង អ.វ.ត.ក បានបញ្ជូនសមាជិកក្រុមពី ២ ទៅ ៤ នាក់មកចូលរួម។ ប្រសិនបើមានតំណាងលើសពី ០១រូប មកពីតាម អង្គការ ឬស្ថាប័នមួយចូលរួម ពួកគេត្រូវបានបំបែកចេញពីគ្នាឱ្យទៅចូលរួមក្រុមការងារផ្សេង ដើម្បីជានាថាក្រុមនីមួយៗបានឮសំឡេង និងទស្សនៈចម្រុះ។ អ្នកចូលរួមប្រហែល ២៩នាក់មកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬអន្តរជាតិ ០៦នាក់មកពីស្ថាប័នសិក្សាស្រាវជ្រាវ (ជាពិសេស មជ្ឈមណ្ឌល CSHL នៅ RULE) និង ០៨នាក់ ជាអ្នកស្រាវជ្រាវឯករាជ្យ ទីប្រឹក្សា ឬមេធាវី។ មានការចូលរួមពីស្ថាប័នរដ្ឋចំនួន ១៦ រួមមាន សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (TSGM) មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក (CKGC) BAKC និងមជ្ឈមណ្ឌលឯកសារច្បាប់ អ.វ.ត.ក (LDC)។ លោកជំទាវ ធន សាអឹម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ក៏បានចូលរួមពិភាក្សាស៊ីជម្រៅផងដែរក្នុងសិក្ខាសាលាថ្ងៃទី២ និងទី៣។ CPS នៃ GIZ ក៏បានបញ្ជូនសមាជិកជាច្រើននាក់មក ចូលរួមក្នុងព្រឹត្តិការណ៍ផ្តល់ដំបូន្មាន និងការគាំទ្រយ៉ាងច្រើនក្នុងព្រឹត្តិការណ៍នេះទាំងមូល។

ភាគី ឬបុគ្គលិក អ.វ.ត.ក ចំនួន ១៣រូប បានចូលរួមសិក្ខាសាលាទាំងបីថ្ងៃនេះ រួមមានសហព្រះរាជអាជ្ញាអន្តរជាតិ លោកស្រី Brenda Hollis សហព្រះរាជអាជ្ញារងជាតិ លោក

ស្រ៊ី រតន: សហមេធាវីនាំមុខដើមបណ្តឹង រដ្ឋប្បវេណី លោក ពេជ្រ អង្គ និងលោកស្រី Megan Hirst និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហុង គឹមសួន, ឡោ ឈុនធី, ស៊ិន ស៊ីវ៉ន, ទី ស្រ៊ីណា, និង វ៉េន ពៅ។ បុគ្គលិក អ.វ.ត.ក ទាំង ១៣ នាក់នេះ ត្រូវបានអញ្ជើញចូលរួមក្នុងព្រឹត្តិការណ៍នេះទាំងបីថ្ងៃ រួមជាមួយនឹងបុគ្គលចំនួន ៨០នាក់ផ្សេងទៀត ហើយបានចូលទៅតាមក្រុមពិភាក្សាទាំងប្រាំបីក្រុម និងដើរតួនាទីយ៉ាងសកម្មក្នុងការពិភាក្សា។

គោលបំណងសំខាន់មួយទៀតក្នុងការរៀបចំសិក្ខាសាលាគឺដើម្បីធានាថា សំឡេងជនរងគ្រោះ-អ្នករស់រានមានជីវិត និងដើមបណ្តឹងរដ្ឋប្បវេណី បានឮសុះសាយនៅគ្រប់ដំណាក់កាលនៃសិក្ខាសាលា។ ចំណុចសំខាន់មួយទៀតគឺត្រូវជៀសវាងការបញ្ចូលពួកគ្រាន់ជានិមិត្តរូប ដោយធ្វើយ៉ាងបង្កើតតួនាទីមួយអាចឱ្យពួកគេផ្តល់ជាតុចូលសំខាន់ៗក្នុងការពិភាក្សា និងលទ្ធផលក្រុម។ ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ១៤នាក់ និងជនរងគ្រោះ-អ្នករស់រានមានជីវិតម្នាក់បានចូលរួមយ៉ាងសកម្មនៅក្នុងសិក្ខាសាលានេះ។ ឈ្មោះរបស់ពួកគេត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឈ្មោះនៅទំព័រដំបូងក្នុងរបាយការណ៍នេះ ដើម្បីជាការទទួលស្គាល់នូវការរួមចំណែកសកម្មរបស់ពួកគេ។ ដើមបណ្តឹង រដ្ឋប្បវេណីចំនួន ១១នាក់ ត្រូវបានអញ្ជើញមកពីគ្រប់ទិសទីនៅក្នុងប្រទេស និងគាំទ្រដោយ VSS ផ្តល់កន្លែងស្នាក់នៅ ដឹកជញ្ជូន និងម្ហូបអាហារ។ ជនរងគ្រោះ-អ្នករស់រានមានជីវិតចំនួន ០៤នាក់ផ្សេងទៀត ក្នុងនោះរួមទាំងដើមបណ្តឹង រដ្ឋប្បវេណីចំនួន ០៣នាក់ ត្រូវបានអញ្ជើញចូលរួម និងគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកក្តីករុណា (KDK)។ ជនរងគ្រោះទាំងបីនាក់ដែលនៅរស់រានមានជីវិតពីមន្ទីរសន្តិសុខ ស-២១ លោក ប៊ូ ម៉េង លោក ជុំ ម៉ី និងលោក នង ចាន់ផល ក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងពិធីបើកសិក្ខាសាលានៅថ្ងៃទី៣ ខែឧសភា ផងដែរ។

លេខាធិការដ្ឋាននៃសិក្ខាសាលាបានពិចារណាតាំងពីដើមដំបូងអំពីវត្តមានចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសិក្ខាសាលា ដើម្បីធានាថាពួកគេអាចថ្លែងដោយខ្លួនឯងអំពីអ្វីដែលពួកគេចង់ឃើញក្នុងដំណាក់កាលដែលនៅសេសសល់ នៃ អ.វ.ត.ក ដែលខិតជិតមកដល់។ ព្រឹត្តិការណ៍ដោយផ្ទាល់នេះផ្តល់ភាពងាយស្រួល និងសាមញ្ញជាងមុន ដើម្បីរួមបញ្ចូលសំឡេងជនរងគ្រោះ-អ្នករស់រានមានជីវិត ខុសពីដំណើរការដាក់សំណើផ្លូវការឆ្លើយតបទៅនឹងរបាយការណ៍ប្រឹក្សារបស់សហចៅក្រមរបាយការណ៍ ឬរបាយការណ៍នេះ។ ការជំរុញឱ្យមានការចូលរួមពីដើម បណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់នៅក្នុងព្រឹត្តិការណ៍នេះកាន់តែប្រសើរបន្ទាប់ពីការពិគ្រោះយោបល់របស់អ្នកសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធក្នុងស្រុក និងអន្តរជាតិដូចបានពិពណ៌នាខាងលើ។ ជាពិសេស វាបានកើតចេញពីសំណើរបស់អង្គការអន្តរជាតិ REDRESS ដែលបានរៀបចំរបាយការណ៍ស្តីពីសំណងសម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះនៅកម្ពុជា ក្រោមកិច្ចសហការជាមួយ KDK។ នៅក្នុងការពិគ្រោះយោបល់មុនសិក្ខាសាលា REDRESS បានសង្កត់ធ្ងន់ទៅកាន់អ្នកសម្របសម្រួលថា ការចូលរួមរបស់ជនរងគ្រោះផ្ទាល់នឹងអាចឱ្យសិក្ខាសាលាកាន់តែមានភាពត្រឹមត្រូវ។ ទស្សនៈនេះត្រូវបានគាំទ្រផងដែរនៅក្នុងការពិភាក្សាជាមួយអ្នកតស៊ូមតិសង្គមស៊ីវិលឈានមុខ និងអ្នកព្យាបាលរោគផ្លូវចិត្ត យឹម សុជារី និងអ្នកស្រាវជ្រាវ Christoph Sperfeldt ដែលបានចូលរួមក្នុងព្រឹត្តិការណ៍នេះក្នុងនាមជាវាគ្មិនពីររូបក្នុងចំណោមវាគ្មិនសំខាន់ទាំងប្រាំរូប។

ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់ VSS និង KDK ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥ អាចចូលរួមសិក្ខាសាលាយ៉ាងពេញលេញនៅក្នុងព្រឹត្តិការណ៍នេះ។ ការ

ស្តាប់ពីដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ និងម្តងហើយម្តងទៀត បានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងចំណោមអ្នកចូលរួមព្រឹត្តិការណ៍ ជាជាងពេលដែលមានតែតំណាងជនរងគ្រោះនៅក្នុងបន្ទប់ ដោយអវត្តមានជនរងគ្រោះខ្លួនឯង។

# ក្រុមពិភាក្សា

ដូចបានពិភាក្សារួចហើយ ក្រុមការងារចំនួនប្រាំបីត្រូវបានបង្កើតឡើង និងរៀបចំដោយលេខាធិការដ្ឋាន សិក្ខាសាលាដើម្បីលើកកម្ពស់ការពិភាក្សាកាន់តែស៊ីជម្រៅសំដៅគ្របដណ្ដប់លើប្រធានបទចំនួនប្រាំបីដាច់ដោយឡែកពីគ្នាក្នុងរយៈពេលព្រឹត្តិការណ៍ចំនួនបីថ្ងៃ។ ការពិភាក្សារបស់ក្រុមនីមួយៗត្រូវបានសម្របសម្រួលដោយបុគ្គលិក អ.វ.ត.ក ដែលត្រូវបានជ្រើសរើសឱ្យជួយការងារក្នុងព្រឹត្តិការណ៍ពិសេសនេះ ហើយក្រុមនីមួយៗត្រូវបានស្នើសុំឱ្យជ្រើសរើសអ្នកកត់ត្រា ដែលកំណត់ហេតុសង្ខេបត្រូវបានប្រើប្រាស់ក្នុងការតាក់តែងរបាយការណ៍នេះ។ ក្រុមពិភាក្សាក៏ត្រូវបានផ្តល់ក្រដាសក្តាខៀនសម្រាប់ដាក់បញ្ចូលគំនិតរបស់ខ្លួន ដែលត្រូវបានចម្លងយកមកប្រើប្រាស់ក្នុងការ សរសេររបាយការណ៍នេះផងដែរ។ អ្នកសម្របសម្រួលបានសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន ហើយភារកិច្ចចម្បងរបស់ពួកគេគឺដើម្បីធានាថាអ្នកចូលរួមទាំងអស់មានឱកាសលើកឡើងក្នុងអំឡុងពេលពិភាក្សា ដើម្បីសង្កេតមើល និងប្រមូលផ្តុំចំណុចនៃដូចគ្នា និងចំណុចខុសគ្នា ក៏ដូចជាបញ្ហាប្រឈម និងចំណុចដែលគួរឱ្យចាប់អារម្មណ៍។

ម៉្យាងវិញទៀត អាទិភាពចម្បងគឺការលើកទឹកចិត្ត និងសម្រួលឱ្យមានការចូលរួមការពិភាក្សា និងកិច្ចសហការតាមដែលអាចធ្វើទៅបាន ដោយផ្តល់ឱ្យអ្នកចូលរួមនូវតួនាទីស្នូល និងសកម្ម។ ដោយសារភាពចម្រុះនៃក្រុម និងសំណើដែលបានលើកឡើងដោយអ្នកចូលរួម ការងារសំខាន់ផងដែរគឺការកំណត់អត្តសញ្ញាណប្រធានបទទូទៅ ដើម្បីជាទម្រង់សម្រាប់ផ្តោតការពិភាក្សាជុំវិញប្រធានបទនេះ។ ចំណុចនេះបាននាំដល់ការសម្រេចចិត្តរៀបចំអ្នកចូលរួមជាក្រុម មិនមែនទៅតាមអង្គការដែលពួកគេមកតំណាង ប៉ុន្តែទៅតាមចំណាប់អារម្មណ៍ និងជំនាញរបស់ពួកគេទាក់ទងនឹងប្រធានបទចំនួនប្រាំបី។ ការធ្វើដូច្នេះគឺដើម្បីធានាថាអង្គការដែលមានតំណាងចូលរួមច្រើននាក់ត្រូវបានបែងចែកទៅក្រុមខុសៗគ្នា ក្នុងគោលបំណងពីរ គឺដើម្បីជៀសវាងអង្គការមានតំណាងចូលរួមគ្របឥទ្ធិពលលើក្រុមមួយឱ្យស្របទៅតាមផលប្រយោជន៍របស់ខ្លួន ហើយក៏ដើម្បីធានាថាធាតុចូលរបស់ពួកគេត្រូវបានចែករំលែកក្នុងចំណោមក្រុមផ្សេងៗគ្នា ជាជាងការចែករំលែកត្រឹមមនុស្សតែម្នាក់។ លក្ខណៈប្រទាក់ក្រឡាគ្នានៃប្រធានបទ ចាត់ទុកថាជាវិធីសាស្ត្រល្អមួយ។

ក្រុមមួយក្នុងចំណោមក្រុមទាំងប្រាំបីមានដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំពីរនាក់ ដែលចូលរួមក្នុង សិក្ខាសាលានេះ ខណៈជនរងគ្រោះ-អ្នករស់រានមានជីវិតទាំងប្រាំបីនាក់ផ្សេងទៀតដែលមានវត្តមាន បានចូលរួមក្នុងក្រុមពិភាក្សាលើប្រធានបទផ្សេងគ្នា។ ការសម្រេចដូច្នេះដើម្បីដើម្បីធានាថា ក្រុមពិភាក្សាមួយ ក្រុមនេះមានសុទ្ធតែសមាជិកក្រុមដើមបណ្ដឹងរដ្ឋប្បវេណី អាចទទួលបានឱកាសងាយស្រួលបង្កើតទស្សនៈ សម្រាប់គំនិតផ្តួចផ្តើមដែលផ្តោតលើជនរងគ្រោះ

ហើយពួកគេអាចផ្តល់មតិត្រឡប់ និងផ្តល់យោបល់លើសំណើរបស់ក្រុមការងារផ្សេងទៀតក្នុងអំឡុងពេលវគ្គពេញអង្គ។ ការរៀបចំនេះបានជោគជ័យក្នុងការធានាថាពួកគេបានដើរតួនាទីសំខាន់ក្នុងការពិភាក្សា និងរៀបចំលទ្ធផលនៃសិក្ខាសាលា។ បុគ្គលិក VSS ពីរនាក់ បានសម្របសម្រួលការពិភាក្សារបស់ក្រុមនេះ។

ក្រុមការងារចំនួនប្រាំពីរផ្សេងទៀតមានសមាសភាពចូលរួមចម្រុះ មកពីទូទាំងសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ អង្គការអន្តរជាតិ ស្ថាប័នរដ្ឋ និង អ.វ.ត.ក។ ក្រុមទាំងប្រាំពីរនេះត្រូវបានរៀបចំឡើងដើម្បីពិភាក្សាអំពីប្រធានបទផ្សេងគ្នា ដោយផ្តោតលើគំនិតផ្តួចផ្តើមសម្រាប់ជនរងគ្រោះនាពេលបច្ចុប្បន្ន និងអនាគត។ ប្រធានបទបានទាញចេញយកចេញពីការវិភាគដំបូងលើឯកសារដាក់ជូនសហចៅក្រមរបាយការណ៍ (សង្ខេបនៅពេលក្រោយក្នុង III.១) និងតាមរយៈការពិគ្រោះយោបល់ ដែលអ្នកសម្របសម្រួលបានរៀបចំឡើងប៉ុន្មានសប្តាហ៍មុនសិក្ខាសាលា។

លេខាធិការដ្ឋានមានគោលបំណងជ្រើសរើសសមាជិកសម្រាប់ក្រុមនីមួយៗចេញពីបញ្ជីភ្ញៀវដែលបានចុះឈ្មោះចូលរួម ដើម្បីប្រមូលផ្តុំតំណាងអង្គការ ក្រុម និងស្ថាប័នផ្សេងៗ ដែលធ្វើការលើវិស័យ និងប្រធានបទស្រដៀងគ្នា។ គោលដៅគឺដើម្បីបង្កើតក្រុមបំពេញបន្ថែមដែលអាចលើកតម្កើងសំឡេងថ្មី ខណៈផ្តោត និងពឹងផ្អែកលើជំនាញរបស់អ្នកអនុវត្តយូរមកហើយ និងឈានមុខ និងអ្នកពាក់ព័ន្ធ។ សមាជិកខ្លះនៅក្នុងក្រុមនីមួយៗធ្លាប់ស្គាល់គ្នា ឬ ធ្លាប់ជាសហការីពីមុនមក។ អ្នកផ្សេងទៀតបានធ្វើការងារដោយឡែកពីគ្នាជាយូរមកហើយ ប៉ុន្តែយល់ស្របដូចគ្នាលើបញ្ហាស្រដៀងគ្នា។ លេខាធិការដ្ឋានសង្ឃឹមថានឹងប្រមូលអ្នកចូលរួមមកពីមជ្ឈដ្ឋានផ្សេងគ្នា មកជួបជុំគ្នា និងបំបែកតំណាងមកពីតាមស្ថាប័នចូលទៅគ្រប់ក្រុមតូចៗដើម្បីគាំទ្រដល់ការពិភាក្សាប្រកបដោយភាពច្នៃប្រឌិត និងកិច្ចសហប្រតិបត្តិការបន្ថែមទៀត។

អ្នកចូលរួមត្រូវបានបែងចែកជាប្រាំបីក្រុម ដោយមានអង្គការ និងស្ថាប័នដែលបានចុះឈ្មោះតំណាងនៅក្នុងក្រុមនីមួយៗដូចខាងក្រោម៖

| | | |
|---|---|---|
| ០១ | ផ្តោតលើដើមបណ្តឹងរដ្ឋប្បវេណី | ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៧ |
| ០២ | សុខភាពផ្លូវចិត្ត ការព្យាបាលរបួសផ្លូវចិត្ត ភាពចាស់ជរា និងភារកិច្ចចំពោះជនរងគ្រោះក្នុងរយៈពេលវែង | TPO, YFP, HelpAge, NGOF, GADC, GIZ-CPS, ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០២ |
| ០៣ | បណ្ណសារ និងឯកសារផ្តោតសំខាន់លើជនរងគ្រោះ និងការការពារសាក្សី និងជនរងគ្រោះ | TSGM, CKGC, LDC, BAKC, CSHL/RULE, KDK, LAC, GIZ-CPS, ភាគី /បុគ្គលិក អ.វ.ត.ក |
| ០៤ | ទីតាំងប្រវត្តិសាស្ត្រ និងសកម្មភាពនៃការចងចាំ | TSGM, CKGC, LDC, CSHL/RULE, RWI, YFP, DC-Cam, ភាគី /បុគ្គលិក អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០២នាក់ |

| | | |
|---|---|---|
| **០៥** | ជនជាតិភាគតិច និងសាសនា | WPM, DC-Cam, KDK, CSHL/RULE, MOEYS, GIZ-CPS, ភាគី /បុគ្គលិក អ.វ.ត.ក អ្នកស្រាវជ្រាវឯករាជ្យជាច្រើននាក់ ដើម បណ្តឹងរដ្ឋប្បវេណីចំនួន ០២នាក់ |
| **០៦** | ការទទួលបានយុត្តិធម៌ និងជំនួយផ្លូវច្បាប់សម្រាប់ជនរងគ្រោះ និងអ្នករស់រានមានជីវិត | BAKC, RWI, CCHR, LAC, SNB, GD Alliance, CSHL/RULE, ភាគី /បុគ្គលិក អ.វ.ត.ក |
| **០៧** | កិច្ចសន្ទនាអន្តរជំនាន់ | TSGM, LDC, WPM, Bophana, KDK, YFP, YRDP, UYFC, Future Forum, ភាគី /បុគ្គលិក អ.វ.ត.ក ជនរងគ្រោះ-អ្នករស់រានមានជីវិតចំនួន ០២នាក់ |
| **០៨** | ការទទួលស្គាល់ និងសំណងសម្រាប់អំពើហិង្សាផ្លូវភេទ និងយេនឌ័រ | KDK, ADHOC, UNWOMEN, BAKC, WPM, GADC, REDRESS, AUPP, UNOHCHR, ភាគី /បុគ្គលិក អ.វ.ត.ក |

ទោះបីក្រុមទាំងនេះត្រូវបានបង្កើតឡើងតាមប្រធានបទមួយៗដោយឡែកពីគ្នាក៏ដោយ ក្រុមទាំងអស់ក៏ត្រូវបានស្នើឱ្យលើកឡើងជុំវិញប្រធានបទទាំងអស់នេះផងដែរ ដោយទទួលស្គាល់ថាតើបញ្ហាជាច្រើនមានទំនាក់ទំនងគ្នាទៅវិញទៅមក។ អ្នកចូលរួមនៅគ្រប់ក្រុមត្រូវបានស្នើសុំឱ្យពិនិត្យមើលការពិភាក្សារបស់ពួកគេតាមរយៈការឆ្លុះបញ្ចាំងនូវភាពស្មុគស្មាញទាក់ទងនឹងយេនឌ័រ សាសនា ពិការភាព ភេទ និងអាយុ។ ការទទួលស្គាល់ និងការចងចាំអំពីប្រល័យពូជសាសន៍នៃក្រុមជនជាតិភាគតិច ឬសកម្មភាពផ្លូវភេទ ឬយេនឌ័រ ក្នុងអំឡុងពេលរបប DK ពាក់ព័ន្ធបញ្ហាជាច្រើនទៀត ហើយទាមទារវិធីសាស្ត្រពហុភាគី។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការពិគ្រោះយោបល់ពីមុនជាមួយអង្គការសង្គមស៊ីវិល មានការកត់សម្គាល់ថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះ ក៏បានអំពាវនាវឱ្យមានការទទួលស្គាល់ដោយឡែកលើបទពិសោធន៍របស់ពួកគេ ដែលមិនមាននរណាម្នាក់ចាប់អារម្មណ៍ ឬមិនបានលើកឡើងជាយូរមកហើយ។ ចំណុចនេះក៏បានបង្ហាញនៅក្នុងសំណើមួយចំនួនដែលបានដាក់ជូនសហចៅក្រមរបាយការណ៍។ ដូច្នេះ លេខាធិការដ្ឋានបានសម្រេចចិត្តបង្កើតក្រុមពិភាក្សាចំនួនពីរ ផ្តោតជាក់លាក់លើបទពិសោធន៍នៃក្រុមជនជាតិភាគតិច និងការទទួលស្គាល់ និងឆ្លើយតបចំពោះឧក្រិដ្ឋកម្ម SGBV នៅក្នុង DK ដើម្បីរំលេចបទពិសោធន៍ទាំងនោះ និងផ្តល់ឱកាសឱ្យជនរងគ្រោះ និងអ្នករស់រានមានជីវិត ផ្តោតលើចំណុចដែលពួកគេសមនឹងទទួលបាន។

ក្រុមទាំងអស់មិនថាពិភាក្សាលើប្រធានបទណាមួយនោះទេ ត្រូវបានស្នើឱ្យធ្វើតាមការណែនាំដូចៗនៅគ្រប់វគ្គទាំងប្រាំ។ ពួកគេក៏ត្រូវបានស្នើឱ្យអភិវឌ្ឍរួមគ្នានូវសំណើគម្រោងមួយ ឬច្រើន ដែលផ្តោតលើបញ្ហាប្រធានបទរបស់ពួកគេ។ ក្នុងប្រាំវគ្គ ពួកគេត្រូវបានគេរំពឹងថានឹងបញ្ចូលគ្នានូវព័ត៌មានលម្អិតនៃកម្មវិធី សមស្របទៅក្នុងអាណត្តិដែលនៅសេសសល់របស់

អ.វ.ត.ក និងស្របតាមគោលដៅ និងសេចក្តីប្រាថ្នារបស់ពួកគេ។ នៅក្នុងវគ្គពេញអង្គថ្ងៃទី៤ ខែឧសភា ដែលត្រូវពិនិត្យមើល និងធ្វើបច្ចុប្បន្នភាពគ្នាទៅវិញទៅមក ហើយនៅក្នុងវគ្គពេញអង្គ ចុងក្រោយពោលគឺនៅថ្ងៃទី៥ ខែឧសភា លេខាធិការដ្ឋានមានបំណងស្តាប់ និងពិភាក្សា យ៉ាងហោចណាស់ប្រាំបីគម្រោងជាក់លាក់ និងលម្អិត ដែលគ្របដណ្តប់លើវិស័យផ្សេងៗគ្នា។ កិច្ចពិភាក្សាទាំងនេះ និងកិច្ចប្រជុំពេញអង្គនាពេលក្រោយមក ក៏បានបង្ហាញ ឱកាសសម្រាប់ អង្គការ និងស្ថាប័ននីមួយៗ អាចចូលរួមចែករំលែកគ្នាទៅវិញទៅមកនូវអ្វីដែលពួកគេ សង្ឃឹមថានឹងសម្រេចបានដោយខ្លួនឯង ឬ រួមគ្នាក្នុងនាមជនរងគ្រោះ ក្នុងរយៈពេល ០៣ ឆ្នាំខាងមុខ ឬ ច្រើនជាងនេះ នៅពេល អ.វ.ត.ក ចាប់ផ្តើមថយសកម្មភាពឈានទៅបញ្ចប់។

ក្នុងការប្រមូលផ្តុំតំណាងអង្គការផ្សេងៗគ្នានៅក្នុងក្រុមទាំងប្រាំបី លេខាធិការដ្ឋាន សង្ឃឹមថានឹងអនុញ្ញាតឱ្យមានការពិភាក្សាអំពីមហិច្ឆតារួម។ សមាសភាពចម្រុះនៃក្រុមនីមួយ ៗបានជានាថា អ្នកតស៊ូមតិសង្គមស៊ីវិល អាចនិយាយដោយផ្ទាល់ជាមួយស្ថាប័នរដ្ឋ ឬ អង្គការ អន្តរជាតិ ក្នុងការលើកកម្ពស់កិច្ចសន្ទនាឱ្យកាន់តែទូលំទូលាយ និងអាចមានកិច្ចសហប្រតិបត្តិ ការរវាងអង្គការដែលធ្វើការលើវិស័យផ្សេងគ្នា។ លេខាធិការដ្ឋាន ក៏ដូចជាអ្នកចូលរួមជាច្រើន នាក់ បានសង្កេតឃើញគម្រោងជាន់គ្នា ឬ ស្ទួនគ្នាដែលបានអនុវត្តនៅក្នុងការងារទាក់ទងនឹង អ.វ.ត.ក នាពេលកន្លងមក។ ការអភិវឌ្ឍកម្មវិធីថ្មីទៅតាមកាលកំណត់នៅក្នុងដំណាក់កាល ដែលនៅសេសសល់ នៃ អ.វ.ត.ក បង្ហាញអំពីឱកាសដែលអង្គការជាដៃគូនាពេលខាងមុខមក ជួបជុំគ្នា ជាជាងនៅស្ងៀមស្ងាត់ ធ្វើការងារដាច់ចេញពីគ្នា និងប្រកួតប្រជែងគ្នាដើម្បីទទួល បានមូលនិធិកម្មវិធី។ ដូច្នេះ លេខាធិការដ្ឋានបានព្យាយាមគូសបញ្ជាក់ពីតម្រូវការឱ្យមានភាព ស៊ីសង្វាក់គ្នាកាន់តែខ្លាំងរវាងអង្គការដែលមានគំនិតដូចគ្នា និងការរួមបញ្ចូលជាមួយស្ថាប័ន ទាំងអស់ ដើម្បីជានាបាននូវនិរន្តរភាពនៃកម្មវិធីទាំងនេះក្នុងរយៈពេលយូរ។ សារៈសំខាន់នៃ វិធីសាស្ត្រនេះសំដៅជានានិរន្តរភាព នឹងត្រូវបានពិភាក្សាលម្អិតបន្ថែមនៅក្នុងចំណុចខាងក្រោម។

ការអនុវត្តគ្រោងការណ៍របស់អង្គការ នាំឱ្យមានការពិភាក្សា និងការចូលរួមយ៉ាងសកម្ម នៅក្នុងក្រុមនីមួយៗ។ នៅព្រឹកថ្ងៃទី២ និងទី៣ អ្នកចូលរួមស្ទើរតែទាំងអស់នៅក្នុងក្រុមធ្វើការ ជាមួយគ្នាយ៉ាងរលូនមុនពេលចាប់ផ្តើមដំណើរការជាផ្លូវការនៅម៉ោង ៩:០០ ព្រឹក។ ដូចគ្នា នេះដែរ នៅចុងបញ្ចប់ថ្ងៃទី ២ អ្នកចូលរួមតិចតួចណាស់បានចាកចេញនៅម៉ោង ៥:០០ ល្ងាច នៅពេលវគ្គចុងក្រោយនៃថ្ងៃនោះបានបញ្ចប់ទៅហើយ។ អ្នកចូលរួមនៅតែអង្គុយក្នុងក្រុមបន្ត ការពិភាក្សា និងរៀបចំបទបង្ហាញរបស់ក្រុមបានយ៉ាងល្អរហូតដល់ពេលល្ងាច។ ភាពរីករាយ ដូចគ្នានេះក៏បានឃើញនៅក្នុងការពិភាក្សាទូទៅ និងវគ្គសំនួរចម្លើយ ក្រោយវាគ្មិនធ្វើបទ បង្ហាញ។ លទ្ធផលគឺនៅក្នុងកិច្ចប្រជុំពេញអង្គនៅចុងបញ្ចប់នៃថ្ងៃទី៣ ក្រុមទាំងអស់បាន ត្រៀមខ្លួនរួចជាស្រេចធ្វើបទបង្ហាញដែលបានរៀបចំយ៉ាងល្អអំពីលទ្ធផលពិភាក្សា ដោយផ្តល់ អនុសាសន៍អំពីប្រភេទកម្មវិធី និងគំនិតផ្តួចផ្តើមជាក់លាក់ដល់អ្នកចូលរួមយ៉ាងច្រើន ដែល រួមមានសមាជិកសហគមន៍ការទូត RGC និងអ្នកពាក់ព័ន្ធផ្សេងទៀត។ សេចក្តីសង្ខេបនៃការ បំផុសគំនិតជាក់ស្តែង ប្រធានបទ និង ខ្លឹមសារនៃការពិភាក្សាក្រុមទាំងប្រាំវគ្គ ដាក់ជូនភ្ជាប់ នៅទំព័រក្រោយៗនៅក្នុងរបាយការណ៍ ពោលគឺ ក្នុងផ្នែកទី III.២ ដោយបានសង្ខេបសំណើ ដាក់ជូនដោយអ្នកចូលរួមសិក្ខាសាលា។

# វាគ្មិនកិត្តិយស

អ្នករៀបចំសិក្ខាសាលាបានជ្រើសរើសវាគ្មិនសំខាន់ៗដោយផ្អែកលើការងារចូលរួមផុសផុលរបស់ពួកគេកន្លងមកជាមួយជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ឬបទពិសោធន៍ផ្សេងទៀតដែលអាចផ្តល់ជាព័ត៌មាន និងបំផុសគំនិតដល់ការពិភាក្សាក្រុម និងវគ្គអង្គ។ វាគ្មិនកត្តិយសក៏បានយល់ព្រមចូលរួមក្នុងវគ្គសំណួរចម្លើយបន្ទាប់ពីបានធ្វើបទបង្ហាញ ដើម្បីឱ្យអ្នកចូលរួមអាចជជែកជាមួយវាគ្មិនផ្ទាល់។ វាគ្មិនខាងក្រោមត្រូវបានរៀបចំទៅតាមតាមលំដាប់ដែលបានធ្វើបទបង្ហាញ។

| | | |
|---|---|---|
| ០១ | លោកស្រី យឹម សុធារី | អ្នកជំនាញផ្នែកចិត្តសាស្ត្រ អ្នកព្យាបាលចិត្តសាស្ត្រ និងជាអ្នកសម្របសម្រួលលើជម្លោះ និងការកសាងសន្តិភាព។ |
| ០២ | លោក KARIM A.A. KHAN, QC | អតីតមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងប្រធានរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ |
| ០៣ | បណ្ឌិត CHRISTOPH SPERFELDT | និស្សិតកិត្តិយសនៅមហាវិទ្យាល័យនីតិសាស្ត្រ MELBOURNE |
| ០៤ | DATO’ SHYAMALA ALAGENDRA | មេធាវីអន្តរជាតិដ៏ល្បីល្បាញមួយរូបមានដើម |
| ០៥ | ឯកឧត្តម លី ច័ន្ទតុលា | ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) |

# ០១



## លោកស្រី យឹម សុធារី ជាអ្នកជំនាញផ្នែកចិត្តសាស្ត្រ អ្នកព្យាបាលចិត្តសាស្ត្រ និងជាអ្នកសម្របសម្រួលលើជម្លោះ និងការកសាងសន្តិភាព។

ក្រៅពីបទពិសោធន៍ជាង ១៨ឆ្នាំនៅក្នុងវិស័យការងារពាក់ព័ន្ធនឹងរបួសផ្លូវចិត្ត ការព្យាបាល និងការផ្សះផ្សា លោកស្រីក៏មានបទពិសោធន៍វិជ្ជាជីវៈយ៉ាងទូលំទូលាយជាមួយអ្នករស់រានមានជីវិតពីរបួសផ្លូវក្នុងរបបខ្មែរក្រហម។ ការងាររបស់លោកស្រីជាមួយជនរងគ្រោះក៏បានផ្តោតលើអំពើហិង្សាលើយេនឌ័រ ដែលជាប្រធានបទសំខាន់នៅក្នុងសិក្ខាសាលា។ សុធារី ធ្លាប់សរសេរសៀវភៅណែនាំដ៏ទូលំទូលាយដែលមានចំណងជើងថា "ការយល់ដឹងអំពីរបួសផ្លូវចិត្តនៅកម្ពុជា" និងសៀវភៅមួយទៀតចំណងជើងថា "អតីតកាល និងបច្ចុប្បន្ននៃអ្នករស់រានមានជីវិតពីអាពាហ៍ពិពាហ៍ដោយបង្ខំ៖ បទពិសោធន៍ឆ្ពោះទៅរកការព្យាបាលរបួសផ្លូវចិត្ត" បន្ទាប់ពីលោកស្រីបានឆ្លុះបញ្ចាំងលើការងារជាមួយអ្នករស់រានមានជីវិតពីការរៀបការដោយបង្ខំ។ លោកស្រីក៏បានសហការនិពន្ធរបាយការណ៍វាយតម្លៃលើដំណាក់កាលទីពីរនៃវិធានការមិនមែនតុលាការរបស់ អ.វ.ត.ក ដែលគាំទ្រដោយមូលនិធិ Trust Fund អ.ស.ប ដើម្បីបញ្ចប់ហិង្សាលើស្រី។ ដោយសារលោកស្រីមានជំនាញ និងបទពិសោធន៍ច្រើនធ្លាប់ធ្វើការជាមួយអង្គការ និងបុគ្គលជាច្រើនដែលចូលរួមក្នុងសិក្ខាសាលានេះ។ ដូច្នេះ លោកស្រីជាវាគ្មិនស័ក្តិសមក្នុងការថ្លែងសុន្ទរកថាគន្លឹះដំបូង ដែលរៀបចំឡើងជាសាធារណៈនៅព្រឹកថ្ងៃទី៣ ខែឧសភា។

លោកស្រី យឹម បានឆ្លើយសំណួរសំខាន់ៗ ដែលបង្ហាញពីបទពិសោធន៍របស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។ លោកស្រីបានចាប់ផ្តើមដោយរៀបរាប់អំពីការចូលរួមដំបូងបំផុតរបស់លោកស្រីជាមួយជនរងគ្រោះក្នុងនាមជាជំនួយការចិត្តវិទូវ័យក្មេង ដែលលោកស្រីមានជីវិតផ្ទាល់ខ្លួនទទួលរងឥទ្ធិពលដោយរបបខ្មែរក្រហម។ នៅក្នុងពេលនោះ ជនរងគ្រោះបានលើកជាសំណួរ និងយោបល់ដូចជា "តើការផ្សះផ្សាមានន័យដូចម្តេច? តើខ្ញុំមានសិទ្ធិទាមទារសំណងដែរឬទេ? តើវាជាកម្មផលដ៏អកុសលក្នុងជីវិតខ្ញុំ ហើយខ្ញុំត្រូវទទួលយកវា។" លោកស្រីភាន់ភាំងនឹងភាពអស់សង្ឃឹមរបស់ជនរងគ្រោះ និងមិនមានលទ្ធភាពបង្ហាញហេតុផលឬពន្យល់អំពីការឈឺចាប់ និងទុក្ខសោករបស់ពួកគេ។ លោកស្រីបានពន្យល់លម្អិតថា ការបង្កើត អ.វ.ត.ក បានផ្លាស់ប្តូរបញ្ហានេះយ៉ាងម៉េច ហើយបានបង្កើតឱកាសមួយដើម្បីលើកឡើងអំពីអារម្មណ៍ដែលនៅបៀមជាប់ជាយូរមកហើយ៖ "យើងបានឮសំឡេងនៃការទួញសោក ការឈ្លានពាន ការស្តីបន្ទោស ការស្រែកគំហក ពាក្យសងសឹក ការអភ័យទោស ភាពស្ងៀមស្ងាត់ ហើយនឹងការ អរគុណដែលអនុញ្ញាតឱ្យពួកគេនិយាយ"។

មេរៀនដ៏សំខាន់មួយ ដែលលោកស្រីបានសិក្សាពីបទពិសោធន៍គឺតម្រូវការចូលរួមជាមួយជនរងគ្រោះ ក្នុងវិធីមួយដែលអាចឱ្យ

**មេរៀនដ៏សំខាន់មួយ ដែលលោកស្រីបានសិក្សាពីបទពិសោធន៍ គឺតម្រូវការចូលរួមជាមួយជនរងគ្រោះក្នុងវិធីមួយដែលអាចឱ្យពួកគេបំបែកភាពស្ងៀមស្ងាត់ និងរៀបរាប់រឿងរ៉ាវនៃអំពើហិង្សាដែលពួកគេបានឃើញ៖ "ជារឿយៗ វាជារឿងរ៉ាវនៃការឃើញហេតុការសម្លាប់ ឬមរណភាព មនុស្សជាទីស្រឡាញ់ត្រូវបានគេបៀតបៀនផ្លូវភេទ ការរំលោភបំពាន និង/ឬ រំលោភ"។**

ពួកគេបំបែកភាពស្ងៀមស្ងាត់ និងរៀបរាប់រឿងរ៉ាវនៃអំពើហិង្សាដែលពួកគេបានឃើញ៖ "ជារឿយៗ វាជារឿងរ៉ាវនៃការឃើញហេតុការសម្លាប់ ឬមរណភាព មនុស្សជាទីស្រឡាញ់ត្រូវបានគេបៀតបៀនផ្លូវភេទ ការរំលោភបំពាន និង/ឬ រំលោភ"។ លោកស្រីបានប្រើឧទាហរណ៍ដើម្បីណែនាំប្រធានបទសំខាន់មួយ នាំឱ្យមានការបន្ទរសម្លេងលើកឡើងក្នុងអង្គសិក្ខាសាលា ហើយបង្ហាញហេតុផលមួយចំនួនគាំទ្រអនុសាសន៍លើកឡើងដោយជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី និងអង្គការមិនមែនរដ្ឋាភិបាល។ អ្វីដែលបន្តប៉ះពាល់ដល់ការរស់នៅរបស់ជនរងគ្រោះ និងគ្រួសារពួកគេគឺថា "ក្នុងករណីខ្លះ ជនល្មើសជាអ្នកជិតខាងរស់នៅទីនោះជាមួយគ្នា"។ លោកស្រីបានពន្យល់ថា ការរស់នៅក្បែរគ្នានេះ រួមចំណែកដល់ការកើតមានរបួសផ្លូវចិត្ត ហើយវាបន្តទៅមួយជំនាន់ទៅមួយជំនាន់។ ការព្យាបាលរបួសផ្លូវចិត្តអន្តរជំនាន់ គឺជាប្រធានបទសំខាន់ក្នុងបទបង្ហាញរបស់លោកស្រី ហើយវាបានបន្តជជែកផុសផុលក្នុងថ្ងៃសិក្ខាសាលាបន្តបន្ទាប់។

ប្រធានបទសំខាន់មួយទៀត លោកស្រី ឃឹម បានលើកឡើងគឺសារៈសំខាន់ស្នូលនៃការអនុញ្ញាតឱ្យជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមនៅគ្រប់ដំណាក់កាលនៃដំណើរការព្យាបាលរបួសផ្លូវចិត្តនេះ និងស្ដាប់ការយល់ដឹងរបស់ពួកគេថាតើយុត្តិធម៌ការព្យាបាលរបួសផ្លូវចិត្ត និងការផ្សះផ្សាមានន័យ និងទាមទារលក្ខខណ្ឌយ៉ាងម៉េចខ្លះ។ ប្រធានបទនេះបានលើកឡើងក្នុងអង្គសិក្ខាសាលាតាមរយៈសំឡេងជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមគ្រប់ដំណាក់កាល។ ទោះជាយ៉ាងណាក៏ដោយ លោកស្រីក៏បានសង្កត់ធ្ងន់ថា រាល់ការចូលរួមជាមួយជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែ "យល់ដឹងច្បាស់អំពីរបួសផ្លូវចិត្ត" តាមរយៈការបណ្ដុះបណ្ដាល និងការរៀបចំសមស្រប។

ក្នុងចំណោមចំណុចសំខាន់ៗផ្សេងទៀតដែលលោកស្រី ឃឹម ផ្ដោតពិភាក្សាគឺផលវិបាកនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រក្រោមរបបខ្មែរក្រហម។ ប្រធានបទនេះត្រូវបានលាក់ទុកជាយូរមកហើយក្នុងភាពស្ងៀមស្ងាត់ ឬ ការយល់ច្រលំ ហើយមិនត្រូវបានស៊ើបអង្កេតយ៉ាងទូលំទូលាយ ដោយសារហេតុផលជាច្រើន ដូច្នេះនៅពេលដែលការស្រាវជ្រាវបានបង្ហាញថា SGBV ប្រភេទនេះមានផលប៉ះពាល់យ៉ោងម៉េចនោះ ជារឿយ វាជះឥទ្ធិពលអវិជ្ជមានដល់ជនរងគ្រោះ។ ដូចលោកស្រីបានពន្យល់ "ជំនួសឱ្យការទទួលបានការថែទាំ និងការគាំទ្រ ជនរងគ្រោះ-អ្នករស់រានមានជីវិតទទួលបានការរិះគន់ និងការមាក់ងាយ។ ជំនួសឱ្យការចាប់ជនល្មើសយកមកទទួលខុសត្រូវ ជនរងគ្រោះទទួលបន្ទុកបង្ហាញហេតុផល [ដោយខ្លួនឯង] ទៅវិញ។ លោកស្រីបានកត់សម្គាល់ថា ជនរងគ្រោះនៃការរៀបការដោយបង្ខំ និងផលវិបាករបស់វា គឺស្ថិតក្នុងចំណោមអ្នកចូលរួមសិក្ខាសាលា ហើយពួកគេនឹងលើកឡើងនៅពេលក្រោយតាម រយៈបទពិសោធន៍ផ្ទាល់របស់ពួកគេ ដូចលោកស្រី ឃឹម បានលើកឡើង។ លោកស្រីបានបញ្ចប់ចំណាប់អារម្មណ៍ដោយបានកត់សម្គាល់អំពីសារៈសំខាន់ ដោយមិនគ្រាន់តែផ្ដោតលើការឈឺចាប់ និងទុក្ខសោករបស់ពួកគេនៅពេលរកដំណោះស្រាយជូនជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែផ្ទុយទៅវិញគឺត្រូវផ្ដោតលើភាពរឹងមាំ និងភាពធន់របស់ពួកគេក្នុងនាមជាអ្នកនៅរស់រានមានជីវិត ដើម្បីជៀសវាងការប៉ះទង្គិចផ្លូវចិត្តឡើងវិញ ហើយត្រូវជំរុញពួកគេឱ្យធ្វើការព្យាបាលរបួសដោយខ្លួនឯង។

# ០២



## លោក KARIM A. A. KHAN, QC ត្រូវបានជ្រើសរើសជាប្រធានរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក្នុងសម័យប្រជុំលើកទី ១៩ នៃសន្និបាតភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម នៅទីក្រុងញូវយ៉ក ក្នុងខែកុម្ភៈ ឆ្នាំ២០២១ ។

លោក Karim Khan បានស្បថចូលកាន់តំណែងនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។ ពីមុនធ្លាប់ជាឧបការីអគ្គលេខាធិការអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាពិសេសទីមួយ និងជាប្រធានក្រុមស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយក្រុម Da'esh/ISIL នៅអ៊ីរ៉ាក់ (UNITAD) ចន្លោះឆ្នាំ២០១៨ ដល់ឆ្នាំ២០២១។ បទពិសោធន៍វិជ្ជាជីវៈរបស់លោករួមមានការងារនៅ ICC តុលាការឧក្រិដ្ឋកម្ម អន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន តុលាការពិសេសសម្រាប់ប្រទេសលីបង់ និង អ.វ.ត.ក។ នៅ អ.វ.ត.ក លោកបានបម្រើការជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១។ លោកត្រូវបានអញ្ជើញឱ្យថ្លែងសុន្ទរកថាគន្លឹះនៅក្នុងសិក្ខាសាលានៅរសៀលថ្ងៃដំបូង តាមរយៈការផ្សាយផ្ទាល់តាមប្រព័ន្ធអ៊ីនធឺណិត ហើយលោកត្រូវបានស្នើឱ្យឆ្លុះបញ្ចាំងបទពិសោធន៍ការងារដែលធ្លាប់ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្របខ័ណ្ឌទស្សនៈនៃបទពិសោធន៍អន្តរជាតិដ៏ទូលំទូលាយរបស់លោក។

លោក Karim Khan បានចាប់ផ្តើមចំណាប់អារម្មណ៍ដោយឆ្លុះបញ្ចាំងពីថ្ងៃការងារដំបូងនៅក្នុងប្រទេសកម្ពុជាក្នុងនាមមេធាវីតំណាងក្រុមដែលមានដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ច្រើនជាងគេ។ លោកបានរំលឹកថា វាជាបទពិសោធន៍ថ្មីមួយនៅពេលតំណាងក្រុមភាគីនៃកិច្ចដំណើរការនីតិវិធី និងដំបូងបំផុត ពេលលោកជួបជាមួយពួកគេជាលើកដំបូង លោកអាចយល់អារម្មណ៍អំពីសារៈសំខាន់ដែលពួកគេភ្ជាប់ទៅនឹងឱកាសជាប្រវត្តិសាស្ត្រនេះ។ លោកបានរៀបរាប់បទពិសោធន៍របស់លោកបន្ទាប់ពីសវនាការថ្ងៃដំបូងមុនសវនាការលើកអង្គសេចក្តីបានចាប់ផ្តើម៖

ខ្ញុំជួបមនុស្សជាច្រើនដែលរត់មករកខ្ញុំទាំងទឹកភ្នែកហូររហាម [...] ហើយពួកគាត់អោបខ្ញុំយំ ហើយភ្លាមនោះ ខ្ញុំយល់ពីអារម្មណ៍នេះ បើទោះជាខ្ញុំមិនយល់ អាចមើលឃើញថាវាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ពួកគេ ហើយវាបានធ្វើឱ្យមានការផ្លាស់ប្តូរ។ ដើមបណ្តឹងជាច្រើនបាននិយាយថា នេះគឺជាការចាប់ផ្តើមនៃការបិទដំពូកចាស់។ នេះគឺជាការចាប់ផ្តើម។ យើងសង្ឃឹមថា នឹងទទួលបានយុត្តិធម៌ [...] អារម្មណ៍បែបនេះចេញមកពីប្រជាពលរដ្ឋ ពីដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្ញុំបានជជែកជាមួយ ដោយពួកគេបានលើកឡើងថា អព្ភូតហេតុបានកើត ឡើង។

នៅពេលលោកបន្តរៀបរាប់អំពីសារៈសំខាន់នៃតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធី លោកក៏បានកត់សម្គាល់ផងដែរថា ទោះថាវាបានរួមចំណែកដ៏មានតម្លៃ ក៏វាមិនអាចបំពេញតម្រូវការរបស់ដើមបណ្តឹង រដ្ឋប្បវេណីបានពេញលេញនោះដែរ។ ត្រង់ហេតុផលនេះ លោកបានពន្យល់ថា "ជានិច្ចកាលនៅក្នុង

យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ យើងត្រូវមានការប្រុងប្រយ័ត្នខ្ពស់អំពីការបង្ហើបក្តីរំពឹងទុកខ្ពស់ពេក ហើយបន្ទាប់មក ការអនុវត្តជាក់ស្តែងយើងមិនអាចបំពេញការរំពឹងទុកទាំងនោះ... បុគ្គលណាក៏ដោយដែលគិតថាយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិអាចដោះស្រាយគ្រប់បញ្ហាគាត់នឹងប្រឈមការបរាជ័យ"។ លោកបន្តថា អ្វីដែលយើងត្រូវធ្វើគឺត្រូវបញ្ជាក់ឱ្យច្បាស់ថាតើច្បាប់ព្រហ្មទណ្ឌអន្តរជាតិអាចធ្វើអ្វីបានខ្លះ និងមិនអាចធ្វើអ្វីបានខ្លះ។ យោងតាមចំណាត់អារម្មណ៍ដែលលោកបានលើកឡើង ចំណុចនេះគឺយើងចាំបាច់ឱ្យមានការផ្តួចផ្តើមគំនិតនៅក្រៅបន្ទប់សវនាការ និងលើសពីការងារបញ្ចប់នៃការកាត់ក្តីនៅតុលាការ ប្រសិនបើយើងចង់បំពេញតាមតម្រូវការជនរងគ្រោះ។

ប្រធានបទសំខាន់មួយទៀត ដែលលោក Khan បានលើកឡើងនៅក្នុងបទបង្ហាញរបស់លោក គឺតម្រូវការសម្រាប់សហគមន៍អន្តរជាតិ និងអ្នកអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដើម្បីបន្តឆ្លុះបញ្ចាំងនូវអ្វីដែលបានរៀនពីចំណុចខ្វះខាត និងភាពបរាជ័យក៏ដូចជាជោគជ័យ ដែលជៀសមិនផុតពីកេរដំណែលក្នុងការប៉ុនប៉ងដើម្បីសម្រេចបាននូវយុត្តិធម៌ និងការផ្សះផ្សាក្រោយអំពើឃោរឃៅដ៏ធំកើតឡើង។ ដោយពិនិត្យលើបញ្ហាមួយចំនួនដែលកើតឡើងក្រោយចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ និងវិសាលភាពនៃសំណងមានកម្រិតក្នុងសំណុំរឿងនោះ លោកក៏បានគូសបញ្ជាក់អំពីសារៈសំខាន់ដែលសម្រេចបាននៅ អ.វ.ត.ក។ នេះជាមរតកដែលយើងត្រូវរៀន និងកែលម្អ។ លោកបានសន្និដ្ឋានថា៖

ខ្ញុំគិតថា កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជា សហគមន៍អន្តរជាតិ ជនរងគ្រោះ និងមេធាវីការពារក្តី និងរដ្ឋអាជ្ញា ហើយភាគច្រើនបំផុត - មានតែប្រជាជនកម្ពុជា ដែលយល់ច្រើនជាងអ្នកដទៃទៅទៀតអំពីអ្វីទៅជាសារៈសំខាន់នៃយុត្តិធម៌ វាពិតជាផ្តល់ក្តីសង្ឃឹមមួយឱ្យយើងបន្តតោងបេះវា ហើយធ្វើការងារដើម្បី [យុត្តិធម៌] យុត្តិធម៌នៅថ្ងៃស្អែកនឹងប្រសើរជាងម្សិលមិញ។

---

**ជួបមនុស្សជាច្រើនដែលរត់មករកខ្ញុំទាំងទឹកភ្នែកហូរហោម [...] ហើយពួកគាត់អោបខ្ញុំយំ ហើយភ្លាមនោះ ខ្ញុំយល់ពីអារម្មណ៍នេះ បើទោះជាខ្ញុំមិនយល់ អាចមើលឃើញថាវាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ពួកគេ ហើយវាបានធ្វើឱ្យមានការផ្លាស់ប្តូរ។ ដើមបណ្តឹងជាច្រើនបាននិយាយថា នេះគឺជាការចាប់ផ្តើមនៃការបិទជំពូកចាស់។ នេះគឺជាការចាប់ផ្តើម។ យើងសង្ឃឹមថា នឹងទទួលបានយុត្តិធម៌ [...] អារម្មណ៍បែបនេះចេញមកពីប្រជាពលរដ្ឋ ពីដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្ញុំបានជជែកជាមួយ ដោយពួកគេបានលើកឡើងថា អព្ភូតហេតុបានកើត ឡើង។**

---

# ០៣



## បណ្ឌិត CHRISTOPH SPERFELDT ជាអតីតនិស្សិតនៅមជ្ឈមណ្ឌលសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិនៃសាកលវិទ្យាល័យ STANFORD និងជាសាស្ត្រាចារ្យរងនៅមជ្ឈមណ្ឌលសិក្សាច្បាប់មនុស្សធម៌នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច ប្រទេសកម្ពុជា។

ថ្មីៗនេះ លោកបណ្ឌិតជាសមាជិកកិត្តិយសនៅមជ្ឈមណ្ឌល Peter McMullin ស្តីពីភាពគ្មានរដ្ឋ នៅសាលាច្បាប់ Melbourne។ មុនពេលចូលរួមក្នុងវិស័យសិក្សាស្រាវជ្រាវ លោកបានធ្វើការងារយ៉ាងទូលំទូលាយជាង ១៥ឆ្នាំ លើវិស័យសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី និង អាស៊ាន។ ក្នុងនាមជាទីប្រឹក្សាជាន់ខ្ពស់ជាមួយទីភ្នាក់ងារអភិវឌ្ឍន៍អាឡឺម៉ង់ (GIZ) អស់រយៈពេលប្រាំឆ្នាំនៅក្នុងប្រទេសកម្ពុជា លោកបានផ្តល់យោបល់ប្រឹក្សាជូន អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា និង VSS នៃ អ.វ.ត.ក.។ ផ្អែកតាមបទពិសោធន៍ចូលរួមរបស់លោកបណ្ឌិតជាច្រើនឆ្នាំជាមួយ អ.វ.ត.ក និងសង្គមស៊ីវិលនៅកម្ពុជា លោកបណ្ឌិតបានក្លាយជាអ្នកប្រាជ្ញឈានមុខម្នាក់លើសំណងនៅសាលាក្តីខ្មែរក្រហម ក៏ដូចជានៅក្នុងវិស័យសំខាន់មួយទៀតដែលលោកបានបោះពុម្ពផ្សាយស្តីពីភាពគ្មានរដ្ឋនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងវិស័យផ្សេងទៀត។ លោក បណ្ឌិតត្រូវបានស្នើឱ្យធ្វើបទបង្ហាញលម្អិតនៅព្រឹកថ្ងៃទី៤ ខែឧសភា។

លោកបណ្ឌិត Sperfeldt បានចាប់ផ្តើមបទបង្ហាញដោយសង្កត់ធ្ងន់ថា ចំណុចសំខាន់ដែលលោកបណ្ឌិតចង់បង្ហាញនោះគឺថា នៅពេលបង្កើតការងារផ្តោតលើជនរងគ្រោះក្នុងដំណាក់កាលដែលនៅសេសសល់ "យើងគួរតែទាញបទពិសោធន៍លើមេរៀន និងកម្មវិធីអតីតកាល និងកម្មវិធីដែលមានស្រាប់ទាក់ទងនឹង អ.វ.ត.ក"។ លោកបណ្ឌិតបានបង្ហាញចំណុចនេះ ដោយផ្តោតលើគម្រោងសំណង និងវិធានការមិនមែនតុលាការ ដែលបានអនុវត្តក្នុងប៉ុន្មានឆ្នាំកន្លងមក ពាក់ព័ន្ធនឹង អ.វ.ត.ក។

លោកបណ្ឌិតបានចង្អុលបង្ហាញចំណុចខ្វះខាតក្នុងវិធានការសំណងដែលអនុវត្តក្នុងសំណុំរឿង ០០១ ទាក់ទងនឹងការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទោះជាយ៉ាងណាក៏ដោយ លោកបណ្ឌិតបានកត់សម្គាល់ភ្លាមៗថា ដោយពិនិត្យមើលការរិះគន់នៃលទ្ធផលក្នុងសំណុំរឿង ០០១ "យើងបានឆ្លងកាត់ការកែទម្រង់គម្រោងសំណងសំខាន់មួយនៅ អ.វ.ត.ក ដែលអនុញ្ញាតឱ្យផ្តល់មូលនិធិពីខាងក្រៅដល់គម្រោងដែលផ្អែកគាំទ្រជនរងគ្រោះអាចបង្កើតឡើងក្រោមកិច្ចសហការជាមួយនឹងតួអង្គសង្គមស៊ីវិលបាន"។ ជាលទ្ធផល លោកបានបន្តទៀតថា គម្រោងសំណងចំនួន ២៤ ត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២ ទាំងពីរវគ្គ។ លើសពីនេះ VSS ត្រូវបាន "ផ្តល់អាណត្តិឱ្យអនុវត្តវិធានការមិនមែនតុលាការ ក្រៅមុខងារសំណង ដែលមិនមានការចំណាយនៅពេលអនុវត្តវិធានការទាំងនេះ ដើម្បីផលប្រយោជន៍ទូលំទូលាយរបស់ជនរងគ្រោះ មិនត្រឹមតែដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះទេ"។ វិធានការសំខាន់ៗចំនួនពីរដែលលទ្ធផលគ្រាន់តែជាការចងចាំនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងគម្រោងពហុដំណាក់កាលដែលដឹកនាំដោយ VSS ដើម្បីដោះស្រាយផលវិបាក

នៃ SGBV កើតឡើងក្រោមរបបខ្មែរក្រហម។ លោកបណ្ឌិតក៏បានសង្កេតឃើញការសង្កត់ធ្ងន់នៃនីតិវិធីរបស់តុលាការគឺលើវិធានការសមូហភាព និងជានិមិត្តរូប បើប្រៀបធៀបទៅនឹងវិធានការបុគ្គលសម្រាប់ជនរងគ្រោះ។ ក្នុងសំណុំរឿង ០០២/០១ សំណើដំបូងត្រូវបានចាត់ថ្នាក់ទៅជាប្រធានបទ៖ ការរំលឹកវិញ្ញាណក្ខន្ធ និងការចងចាំ ការស្តារនីតិសម្បទា ការចងក្រងឯកសារ ការអប់រំ និងការងារផ្សេងៗទៀត។

បន្ទាប់មក លោកបណ្ឌិតបានផ្តល់យោបល់លើគម្រោងជាច្រើនទាក់ទងនឹងប្រធានបទសិក្ខាសាលាចំនួនបី៖ ការទទួលស្គាល់ ការចងចាំ និងការផ្សះផ្សាជាតិ។ ទោះបីចំណុចដែលគាត់បានលើកឡើងពាក់ព័ន្ធនឹងករណីនេះ មានចំណុចជាច្រើនមិនអាចដោះស្រាយបានពេញលេញនោះ ចំណុចមួយលេចធ្លោមួយចំនួនលោកបណ្ឌិតបានសង្កត់ធ្ងន់។ ឧទាហរណ៍ លោកបណ្ឌិតបានកត់សម្គាល់ថា "មានការរីកចំរើនយ៉ាងសំខាន់ក្នុងការគាំទ្រផ្នែកផ្លូវចិត្ត និងសេវាសុខភាពផ្លូវចិត្ត បើប្រៀបធៀបទៅនឹងអ្វីដែលមាននៅមុន អ.វ.ត.ក"។ លោកបណ្ឌិតបានសង្កត់ធ្ងន់ជាពិសេសតួនាទីរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) ដែលជំរុញសេវាសុខភាពផ្លូវចិត្ត "ទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង" សម្រាប់អ្នករស់រានមានជីវិតពីអំពើហិង្សាដែលប្រព្រឹត្តដោយរបបខ្មែរក្រហម។ តួនាទីរបស់ TPO ក៏បង្ហាញពីការរួមចំណែកសួលរបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះគម្រោងសំណងដែលត្រូវបានទទួលស្គាល់។ លោកបណ្ឌិតបានបញ្ជាក់ថា វិធានការសំណងចំនួន ២០ ក្នុងចំណោមវិធានការចំនួន ២៤ ត្រូវបានដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាល ក្នុងនោះ ១៦ ពាក់ព័ន្ធនឹងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា។

ការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល បានគ្រប់ដណ្តប់លើសពីគម្រោងជាក់លាក់ដែលបានអនុវត្ត ឬរួមចំណែក។ លោកបណ្ឌិតបានកត់សម្គាល់ថា បទពិសោធន៍រួមនេះ "បានពង្រីកឱកាសជួយជនរងគ្រោះ និងរួមចំណែកក្នុងការបន្តធ្វើមូលដ្ឋានីយកម្មនូវដំណើរការយុត្តិធម៌របស់ អ.វ.ត.ក"។ ការងារនេះមិនអាចសម្រេចបាននៅតាមសាលាក្តីផ្សេងទៀតដែលបង្កើតឡើងដើម្បីបម្រើប្រជាជន ក៏ប៉ុន្តែនៅដាច់ឆ្ងាយពីប្រជាជន។ លោកបណ្ឌិតកត់សម្គាល់ថា អត្ថប្រយោជន៍ជារួមមួយទៀតកើតឡើងពីវិធីដែលអង្គការមិនមែនរដ្ឋាភិបាលបានធ្វើសកម្មភាពរយៈពេល ១៥ឆ្នាំ លើការងារ អ.វ.ត.ក បានប្រមូលអ្នកជំនាញកម្ពុជាយ៉ាងច្រើននៅក្នុងវិស័យផ្សេងៗទាក់ទងនឹងយុត្តិធម៌ អន្តរកាល និងការដោះស្រាយតម្រូវការរបស់ជនរងគ្រោះ។ ចំណុចចុងក្រោយនេះនាំឱ្យដល់ការពិចារណាមួយចំនួនអំពីបញ្ហាពាក់ព័ន្ធ ដែលជាប្រធានបទនៃការពិភាក្សាលើទិដ្ឋភាពជាច្រើននៅក្នុងសិក្ខាសាលា ហើយត្រូវបានពិភាក្សានៅពេលក្រោយនៅក្នុងរបាយការណ៍នេះ ពោលគឺរបៀបកំណត់ "ជនរងគ្រោះ"។ លោកបណ្ឌិត Sperfeldt បានលើកឡើងការស្ទង់មតិដែលបង្ហាញថា "ប្រជាជនភាគច្រើនរស់នៅក្រោមរបបខ្មែរក្រហមចាត់ទុកខ្លួនថាជាជនរងគ្រោះ។ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍ ប្រជាជនដែលមិនបន្ទាប់រស់នៅក្រោមរបបខ្មែរក្រហម ជាងពាក់កណ្តាល បានចាត់ទុកខ្លួនឯងថាជាជនរងគ្រោះនៃរបបខ្មែរក្រហមដូចគ្នា។ ដូច្នេះ យើងឃើញទិដ្ឋភាពនៃទស្សនៈទានអន្តរជំនាន់អំពីជនរងគ្រោះនៅកម្ពុជា" ។ ទិដ្ឋភាពអន្តរជំនាន់នេះ និងសំណួរអំពីរបៀបដោះស្រាយតម្រូវការរបស់បុគ្គល និងសហគមន៍ បានបន្តដើរតួយ៉ាងសំខាន់ក្នុងការពិភាក្សាសិក្ខាសាលា។

ដោយសារ អ.វ.ត.ក ផ្តោតជាសំខាន់លើដើមបណ្តឹងរដ្ឋប្បវេណី បញ្ហាប្រឈមមួយគឺរួមបញ្ចូលសំឡេងរបស់ជនរងគ្រោះឱ្យបានច្រើន។ ចាំបាច់យើងត្រូវមានការគាំទ្រពីសមាគមជនរងគ្រោះកាន់តែច្រើន និងការរៀបចំឱ្យកាន់តែប្រសើរឡើងអំពីមធ្យោបាយកំណត់ និងឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ។ បន្ថែមលើការសង្កត់ធ្ងន់អំពីការប្រាស្រ័យទាក់ទង "ពីររបៀប" ជាមួយជនរងគ្រោះ យើងត្រូវការខ្លាំងជាងមុននូវ "ការចូលរួមរបស់អ្នករស់រានមានជីវិត កាន់តែមានលក្ខណៈរចនាសម្ព័ន្ធជាងមុននៅពេល

---

**លោកបណ្ឌិត Sperfeldt បានលើកឡើងការស្ទង់មតិដែលបង្ហាញថា "ប្រជាជនភាគច្រើនរស់នៅក្រោមរបបខ្មែរក្រហមចាត់ទុកខ្លួនថាជាជនរងគ្រោះ។ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍ ប្រជាជនដែលមិនបន្ទាប់រស់នៅក្រោមរបបខ្មែរក្រហម ជាងពាក់កណ្តាល បានចាត់ទុកខ្លួនឯងថាជាជនរងគ្រោះនៃរបបខ្មែរក្រហមដូចគ្នា។ ដូច្នេះ យើងឃើញទិដ្ឋភាពនៃទស្សនៈទានអន្តរជំនាន់អំពីជនរងគ្រោះនៅកម្ពុជា" ។**

---

[...] រចនា និងអនុវត្តគម្រោង។" លោកបណ្ឌិតបានកត់សម្គាល់អំពីរបៀបដែលជនរងគ្រោះ-អ្នកនៅរស់រានមានជីវិតគួរតែត្រូវបានចាត់ទុកជាអ្នកពាក់ព័ន្ធសកម្មដែលត្រូវចូលរួមក្នុងការរចនាកម្មវិធី ហើយមិនមែនគ្រាន់តែជាអ្នកទទួលផលអកម្មពីកម្មវិធីដែលអ្នកផ្សេងបង្កើតឡើងសម្រាប់ពួកគេនោះទេ។ លោកបណ្ឌិតបានសង្កត់ធ្ងន់លើតម្រូវការក្នុងការប្រាស្រ័យទាក់ទងជាទៀងទាត់ជាមួយអ្នករស់រានមានជីវិត ហើយនឹងឱកាស និងភាពចាំបាច់ក្នុងការបង្កើតកម្មវិធីដ៏មានអត្ថន័យ ដើម្បីឆ្លើយតបនឹងប្រជាជនកម្ពុជាភាគច្រើនដែលកើតក្រោយការដួលរលំនៃរបបខ្មែរក្រហម។ ការពិតណាស់ គោលដៅនៃការចូលរួមរបស់ដើមបណ្ដឹង រដ្ឋប្បវេណីនៅក្នុងសិក្ខាសាលាបែបរចនាសម្ព័ន្ធ ដើម្បីបង្កើតគម្រោង និងអនុវត្តគម្រោងទាំងនោះ។

ប្រសិនបើយើងងាកទៅប្រធានបទនៃការចងចាំ លោកបណ្ឌិត Sperfeldt បានសង្កត់ធ្ងន់លើទំនាក់ទំនងខាងក្នុងរវាងការចងចាំ ការអប់រំ និងការស្វែងរកការពិត។ ត្រង់ចំណុចនេះ លោកបណ្ឌិតបានលើកឡើងម្ដងទៀតនូវគំនិតមួយដែលបានលេចចេញជាចំណុចស្នូលនៃការរួមចំណែកជាច្រើនរបស់អ្នកចូលរួមក្នុងផ្នែកនេះ៖ តម្រូវការធ្វើមូលដ្ឋានីយកម្មការចងចាំទៅក្នុងសហគមន៍នីមួយៗជាជាងតាមរយៈការរំលឹកវិញ្ញាណក្ខន្ធនៅរាជធានីភ្នំពេញ។ នេះក៏មានន័យថា ការអភិរក្សសំឡេង និងបទពិសោធន៍របស់ជនរងគ្រោះនៅក្នុងសហគមន៍មូលដ្ឋាន គឺជាគោលដៅសំខាន់មួយក្នុងការស្វែងរកការពិត។ ដូចលោកបណ្ឌិតមានប្រសាសន៍ថា "មនុស្សភាគច្រើននៅក្នុងប្រទេសកម្ពុជាជឿថាចាំបាច់ក្នុងការស្វែងរកការពិតអំពីអ្វីដែលបានកើតឡើង។ មនុស្សភាគច្រើនក៏ជឿថា អ្នកមិនអាចផ្សះផ្សាបាននោះទេប្រសិនបើមិនបានដឹងថាមានរឿងអ្វីកើតឡើង ហើយមនុស្សភាគច្រើនក៏និយាយថា ពួកគេមិនអាចមានអារម្មណ៍ធូរស្បើយជាងមុននោះដែរប្រសិនបើមិនដឹងអំពីអ្វីដែលបានកើតឡើងចំពោះមនុស្សជាទីស្រលាញ់របស់ពួកគេ។"

នៅពេលបញ្ចប់បទបង្ហាញគន្លឹះរបស់លោកបណ្ឌិតលើប្រធានបទនៃការផ្សះផ្សាជាតិ លោកបណ្ឌិតបានកត់សម្គាល់ថា បន្ថែមលើគំនិតនៃការផ្សះផ្សាជាតិ ដែលជាការផ្ដោតសំខាន់របស់រាជរដ្ឋាភិបាល និង អ.វ.ត.ក ចំណុចសំខាន់គឺត្រូវស្វែងយល់អំពីការផ្សះផ្សានៅកម្រិតបុគ្គល និងសហគមន៍។ ចំណុចនេះភ្ជាប់ទៅប្រធានបទដែលបានលើកឡើងរួចហើយ ដែលជាបញ្ហាប្រឈមនៃការផ្សះផ្សា ដែលជនរងគ្រោះ និងជនល្មើសរស់នៅជាមួយគ្នាក្នុងសហគមន៍តែមួយ។ ចំណុចនេះត្រូវបានលើកឡើងម្ដងហើយម្ដងទៀតដោយដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ នៅពេលពួកគេធ្វើបទបង្ហាញ ឬ ចូលរួមក្នុងសិក្ខាសាលាពេញអង្គ និងពិភាក្សាជាក្រុម។

[៩៥] (២០១១) មជ្ឈមណ្ឌលសិទ្ធិមនុស្ស សាកលវិទ្យាល័យ California Berkeley School of Law អាចចូលមើលបាននៅ៖ https://www.law.berkeley.edu/files/HRC/Publications_After-the-First-Trial_06-2011.pdf ។

# ០៤

ក្នុងតួនាទីជាន់ខ្ពស់បច្ចុប្បន្ននៅក្នុងយន្តការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសមីយ៉ាន់ម៉ា និងស្រីលង្កា លោកស្រី DATO' SHYAMALA ALAGENDRA គឺជាមេធាវីអន្តរជាតិដ៏ល្បីល្បាញមួយរូបមានដើមកំណើតមកពីប្រទេសម៉ាឡេស៊ី។



លោកស្រីបានចោទប្រកាន់សំណុំរឿងល្បីៗនៅក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត តុលាការពិសេសសម្រាប់សេរ៉ាឡេអូន (SCSL) និងនៅ ICC រួមទាំងសំណុំរឿងប្រឆាំងលោក Charles Taylor អតីតប្រធានាធិបតីប្រទេសលីបេរីយ៉ា និងលោក Omar Al-Bashir ប្រធានាធិបតីស៊ូដង់។ លោកស្រីក៏បានដើរតួជាមេធាវីការពារក្តីតំណាងឱ្យអនុប្រធានាធិបតីនៃប្រទេសកេនយ៉ាលើការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចំពោះមុខ ICC។ លោកស្រីក៏តំណាងឱ្យក្រុមជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនៅតាមយុត្តាធិការជាច្រើន និងជាអ្នកជំនាញល្បីម្នាក់លើការស៊ើបអង្កេត SGBV និងការការពារស្ត្រី និងកុមារក្រោយសម័យជម្លោះ។ ដូច្នេះ លោកស្រីបាននាំយកទស្សនៈទូលំទូលាយអន្តរជាតិ និងប្រៀបធៀបបញ្ហាពាក់ព័ន្ធជនរងគ្រោះនៅ អ.វ.ត.ក។ Dato' Alagendra បានថ្លែងទៅកាន់សិក្ខាសាលានៅរសៀលថ្ងៃទីពីរតាមរយៈការផ្សាយផ្ទាល់តាមអ៊ីនធឺណិត។

ដោយឆ្លុះបញ្ចាំងពីបទពិសោធន៍ជាង ២០ឆ្នាំរបស់លោកស្រីនៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌ អន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿងនៅអាស៊ីខាងត្បូង និងអាគ្នេយ៍ អាហ្វ្រិក និងអឺរ៉ុប លោកស្រី Dato' Alagendra បានគូសបញ្ជាក់អំពី សារៈសំខាន់នៃ អ.វ.ត.ក ក្រៅពីនៅក្នុងប្រទេសកម្ពុជា៖

"នៅពេលយើងនិយាយអំពីលទ្ធភាព និងសារៈសំខាន់នៃគណនេយ្យភាពក្នុងតំបន់អាស៊ានថ្ងៃនេះ អ.វ.ត.ក គឺជាតុលាការដែលយើងត្រូវយកជាគំរូ [...] ជាមួយនឹងសមិទ្ធផលដ៏អស្ចារ្យគួរជាទីមោទនៈ។ ការងារលេចធ្លោជាងគេនោះគឺ អ.វ.ត.ក គឺជាតុលាការតែមួយគត់ដែលជនរងគ្រោះអាចចូលរួមដោយផ្ទាល់ជាភាគីក្នុងដំណើរការនីតិវិធីនៅដំណាក់កាលស៊ើបអង្កេត កាត់ក្តី និង បណ្តឹងឧទ្ធរណ៍។ ជនរងគ្រោះមានសំឡេងនៅក្នុងដំណាក់កាលទាំងអស់នេះ ហើយមាន លទ្ធភាពពិតប្រាកដក្នុងការអូសទាញលទ្ធផលនៃការជំនុំជម្រះទាំងនេះ"។

បន្ទាប់មក លោកស្រីបានផ្តល់ការសង្កេត និងយោបល់ដោយផ្អែកលើការងារផ្ទាល់ខ្លួនពាក់ព័ន្ធនឹងជនរងគ្រោះនៅក្នុងបរិបទផ្សេងៗគ្នា។ ដោយទទួលស្គាល់ថា គោលបំណងសំខាន់នៃដំណើរការយុត្តិធម៌អន្តរជាតិ គឺបង្ហាញពិរុទ្ធភាព ឬ ភាពគ្មានទោសរបស់ជនជាប់ចោទលើសពីវិមតិសង្ស័យ លោកស្រីបានបន្តទៀតថា ការកាត់ក្តីបែបនេះក៏តំណាងឱ្យឱកាសមួយ - ឱកាសសំខាន់ - សម្រាប់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ តួនាទី សំឡេង និងផលប្រយោជន៍របស់ពួកគេ គឺជាសរសៃឈាមនៃគំរូផ្លូវច្បាប់ដែលសង្ឃឹមថាជួយឱ្យសាធារណជនមានទំនុកចិត្តលើនីតិរដ្ឋ និងដើម្បីអាចជាការសន្យាថានឹងមិនមានអំពើទាំងនេះជាថ្មីម្តងទៀត"។ ជាលទ្ធផល លោកស្រីបានបន្តទៀតថា "យើងត្រូវប្រឹងឱ្យអស់ពី

**"នៅពេលយើងនិយាយអំពីលទ្ធភាព និងសារៈសំខាន់នៃគណនេយ្យភាពក្នុងតំបន់អាស៊ានថ្ងៃនេះ អ.វ.ត.ក គឺជាតុលាការដែលយើងត្រូវយកជាគំរូ [...] ជាមួយនឹងសមិទ្ធផលដ៏អស្ចារ្យគួរជាទីមោទនៈ។ ការងារលេចធ្លោជាងគេនោះគឺ អ.វ.ត.ក គឺជាតុលាការតែមួយគត់ដែលជនរងគ្រោះអាចចូលរួមដោយផ្ទាល់ជាភាគីក្នុងដំណើរការនីតិវិធីនៅដំណាក់កាលស៊ើបអង្កេត កាត់ក្តី និង បណ្តឹងឧទ្ធរណ៍។ ជនរងគ្រោះមានសំឡេងនៅក្នុងដំណាក់កាលទាំងអស់នេះ ហើយមាន លទ្ធភាពពិតប្រាកដក្នុងការអូសទាញលទ្ធផលនៃការជំនុំជម្រះទាំងនេះ។**

សមត្ថភាព ដើម្បីធានាថា នៅពេលយើងចាប់ផ្តើមការងារដើមដំបូង ក្រុមជនរងគ្រោះជាច្រើនមានអ្នកតំណាង និងមានតួនាទីនៅក្នុងដំណើរការនេះ"។ លោកស្រីក៏បានសង្កត់ធ្ងន់ថា ក្រុមជនរងគ្រោះទាំងអស់ត្រូវតែគោរពដោយស្មើភាពគ្នា ហើយយើងត្រូវតែជៀសវាងការសន្មត់ថា សមាជិកជនរងគ្រោះទាំងអស់ ដូចជា កុមារ ឬ ស្ត្រី មានបទពិសោធន៍ដូចៗគ្នា។

ផ្តើមចេញពីការយល់ដឹងទាំងនេះ លោកស្រីបានផ្តល់នូវអនុសាសន៍មួយដល់អ្នកចូលរួមស្តាប់ថា "នៅពេលយើងរចនាដំណាក់កាលដែលនៅសេសសល់បន្ទាប់ សូមនឹកដល់សំឡេងរបស់អ្នកដែលមិនត្រូវបានទទួលស្គាល់។" បន្ទាប់ពីចំណុចនេះ លោកស្រីបានលើកយកបញ្ហាមួយដែលត្រូវបានពិភាក្សាជាញឹកញាប់នៅក្នុងសិក្ខាសាលាផងដែរ "ការយល់ដឹងថាការប៉ះទង្គិចផ្លូវចិត្ត និងឥទ្ធិពលផ្លូវចិត្តនៃការបញ្ចូលរឿងរ៉ាវ និងការរងទុក្ខវេទនាទៅក្នុងការរៀបរាប់ជូនតុលាការអំពីការទទួលខុសត្រូវ គឺជាចំណុចសំខាន់ចំពោះអ្នកដែលរងផលប៉ះពាល់"។ អ្នកដែលសំឡេងរបស់ខ្លួនត្រូវបានគេស្តាប់ឮតាមនីតិវិធីនេះ បានលើកឡើងថា ពួកគេមានអារម្មណ៍ថា បានត្រដាងឱ្យគេឃើញ ដោយមានគេ ស្តាប់ និងតំណាងពួកគេ"។ ទោះជាយ៉ាងណាក៏ដោយ លោកស្រីក៏បានស្នើឱ្យភាគីពាក់ព័ន្ធ ត្រូវយល់ដឹងអំពីហានិភ័យនៃការអូសបន្លាយពេលវេលាក្នុងការកំណត់អំពីភាពជាជនរងគ្រោះ តាមរយៈដំណើរការដែលនៅសេសសល់។ សូមយើងអនុញ្ញាតឱ្យ [ជនរងគ្រោះ] បន្តដំណើរទៅមុខទៀត"។ នេះគឺជាចំណុចសំខាន់មួយដែលបានលើកឡើងអំពីបញ្ហាប្រឈមនៃកិច្ចខិតខំប្រឹងប្រែងក្នុងការរក្សាចងចាំដូចបានពិភាក្សាខាងលើ៖ តើធ្វើម្តេចដើម្បីឱ្យកម្មវិធីទាក់ទងនឹងអំពើឃោរឃៅពីអតីតកាលអាចឱ្យជនរងគ្រោះចូលរួមយ៉ាងសកម្ម ក្នុងពេលជាមួយគ្នាអាចឱ្យដំណើរផ្លូវព្យាបាលរបួសផ្លូវចិត្ត ជាសះស្បើយពិតប្រាកដ?

នៅពេលពន្យល់អំពីរបៀបដែលការចូលរួមបែបនេះអាចជាបញ្ហាប្រឈមជាពិសេសចំពោះជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ លោកស្រីបានពន្យល់យ៉ាងលម្អិតលើប្រធានបទមួយដែលបានលើកឡើងរួចហើយដោយលោកស្រី យឹម នៅក្នុងសុន្ទរកថាមួយថ្ងៃមុន។ ផ្អែកតាមបទពិសោធន៍ស៊ើបអង្កេតជាច្រើនឆ្នាំរបស់លោកស្រីលើអំពើហិង្សាផ្លូវភេទ និងយេនឌ័រ លោកស្រី Dato' Alagendra បានលើកឡើងអំពីកត្តាដូចជា ភាពអាម៉ាស់ ការមាក់ងាយ ឬបញ្ហាផ្សេងទៀតដែលរារាំងស្ត្រីមិនឱ្យចូលរួមក្នុងការស៊ើបអង្កេត។ ជាជាងការសន្មត់ថា ពួកគេមិនហ៊ាននិយាយ "តាមពិត យើងគួរតែពិគ្រោះយោបល់ឱ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបានដើម្បីស្វែងយល់អំពីតម្លៃរបស់ពួកគេ ហើយយើងត្រូវអនុវត្តវិធីសាស្ត្រដែលអាចធានាថាជនរងគ្រោះអាចជួបយើង និងចូលរួមនៅក្នុងដំណើរការរបស់យើងប្រកបដោយសុវត្ថិភាព ផាសុកភាព និងសម្ងាត់ ប្រសិនបើចង់នោះ។"

លោកស្រីបានបញ្ជាក់ជាថ្មីម្តងទៀតអំពីប្រធានបទពិភាក្សាសំខាន់ៗនៅក្នុងសិក្ខាសាលា លោកស្រីបាន អត្ថាធិប្បាយអំពីរបៀបដែលបុគ្គលដែលបានចូលរួម គួរជួយរចនាកម្មវិធីសម្រាប់ដំណាក់កាលដែលនៅសេសសល់ ដូច្នេះ ពួកគេអាច "ផ្តល់យោបល់លើអ្វីដែលមានអត្ថន័យបំផុតសម្រាប់ពួកគេ [...] របៀបជួយពួកគេឱ្យជំនះអតីតកាល និងបន្តដំណើរទៅមុខឱ្យបានដាច់ខាត"។ ចំណុចចុងក្រោយ លោស្រីបានសន្និដ្ឋានថា សំឡេង ការរួមចំណែក បទពិសោធន៍ និងសក្ខីកម្មរបស់ពួកគេ មិនត្រឹមតែត្រូវរក្សាទុកក្នុងបណ្ណសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចឱ្យគេចូលអានបាន ដើម្បី

ឱ្យអ្នកជំនាន់ក្រោយ ទាំងប្រជាជនកម្ពុជា ក៏ដូចជាអ្នកក្រៅប្រទេសបានដឹង។ លោកស្រីបានបញ្ចប់បទបង្ហាញដោយរំលឹកដល់អ្នកចូលរួមថា ទោះបីជាការងារនេះអាចជាជំពូកចុងក្រោយក៏ដោយ ដំណាក់កាលដែលនៅសេសសល់នេះមិនអាចថាមិនសូវសំខាន់ក្នុងចំណោមដំណើរការរបស់ អ.វ.ត.ក នោះឡើយ។

# ០៥



**ឯកឧត្តម លី ច័ន្ទតុលា គឺជាប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)។**

ឯកឧត្តមមានចំណេះដឹងផ្ទាល់ខ្លួន និងវិជ្ជាជីវៈយ៉ាងច្រើនអំពី អ.វ.ត.ក បន្ទាប់ពីបានចំណាយពេលមួយផ្នែកនៃអាជីព នៅទីនោះក្នុងនាមជាក្រឡាបញ្ជីនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត។ ឯកឧត្តមត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធាន BAKC សម្រាប់អាណត្តិទី១៣ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០។ ផ្អែកតាមបទពិសោធន៍នៅ អ.វ.ត.ក និងកន្លែងផ្សេងទៀត សុន្ទរកថារបស់ឯកឧត្តមបានលើកឡើងអំពីវិធីលើកកម្ពស់យុត្តិធម៌ក្នុងចំណោមជនរងគ្រោះ និងរបៀបរួមបញ្ចូលគោលការណ៍ច្បាប់ និងវិជ្ជាជីវៈនៅ អ.វ.ត.ក ទៅក្នុងប្រព័ន្ធតុលាការ និងច្បាប់កម្ពុជា។ ទស្សនវិស័យរបស់ឯកឧត្តមបានចក្ខុវិស័យអំពីការកសាងស្ថាប័នរួមបញ្ចូលគ្នាប្រកបដោយនិរន្តរភាព ដោយបង្កើតយុទ្ធសាស្ត្ររយៈពេលវែង។

ឯកឧត្តម បានលើកឡើងបីចំណុចនៅក្នុងសុន្ទរកថានៅព្រឹកថ្ងៃចុងក្រោយនៃសិក្ខាសាលា៖ "ទីមួយ គោលការណ៍ច្បាប់សំខាន់ៗទាក់ទងនឹងការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការកាត់ក្តីរបស់ អ.វ.ត.ក។ ទីពីរ ការប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពី អ.វ.ត.ក សម្រាប់ដឹកនាំគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការផ្តល់សេវាដល់ជនរងគ្រោះ។ ទីបី បទពិសោធន៍របស់ អ.វ.ត.ក ទាក់ទងនឹងជនរងគ្រោះ ដែលគួរត្រូវបានពិចារណាសម្រាប់ដាក់បញ្ចូលក្នុងប្រព័ន្ធច្បាប់ជាតិ"។

ទាក់ទងនឹងចំណុចទី១ ឯកឧត្តម បានលើកឡើងថា "ក្រៅពីសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានយុត្តិធម៌ ជន រងគ្រោះក្នុងក្របខ័ណ្ឌ អ.វ.ត.ក មានសិទ្ធិមានតំណាងផ្លូវច្បាប់នៅចំពោះមុខច្បាប់។ ពួកគេត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក និងតំណាងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី"។ ឯកឧត្តមយល់ឃើញថា តាមរយៈការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក បានបង្កើតយុត្តិសាស្ត្រពាក់ព័ន្ធ ដែលមានលក្ខណៈខុសប្លែកពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឬ សាលាក្តីចម្រុះផ្សេងទៀត។

នៅពេលលើកឡើងចំណុច ដែលក្របខ័ណ្ឌ អ.វ.ត.ក ស្តីពីជនរងគ្រោះ គួរបញ្ចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិតាមវិធីណា ឯកឧត្តមបានចង្អុលបង្ហាញអំពីការផ្តល់សេវាដោយ VSS។ ដោយផ្អែកលើបទពិសោធន៍នេះ ឯកឧត្តមបានបន្តទៀតថា "ការិយាល័យគាំពារជនរងគ្រោះ និងសាក្សី គួរតែត្រូវបានបង្កើតឡើងនៅក្នុងតុលាការជាតិ ក្នុងគោលបំណងការពារជនរងគ្រោះ រួមមានស្ត្រី កុមារី កុមារ ជនពិការ ឬមនុស្សចាស់ ដែលមានសិទ្ធិទទួលបានការការពារ"។ ការិយាល័យបែបនេះគួរតែត្រូវបានបង្កើតឡើងនៅក្នុងតុលាការកម្ពុជាទាំងអស់ ហើយដោយសង្កេតឃើញវត្តមានរបស់ TPO ក្នុងអំឡុងពេលដំណើរការនៃ អ.វ.ត.ក យើងគួរតែផ្តល់សេវាផ្លូវចិត្ត-សង្គម ដល់អ្នកស្វែងរកជំនួយ និងការគាំទ្រផងដែរ។

**"ការិយាល័យគាំពារជនរងគ្រោះ និងសាក្សី គួរតែត្រូវបានបង្កើតឡើងនៅក្នុងតុលាការជាតិ ក្នុងគោលបំណងការពារជនរងគ្រោះ រួមមានស្ត្រី កុមារី កុមារ ជនពិការ ឬមនុស្សចាស់ ដែលមានសិទ្ធិទទួលបានការការពារ"**

ឯកឧត្តមបន្ថែមថា លើសពីនេះ តុលាការគួរតែអនុវត្តវិធានការ
ការពារសាក្សី ដោយធ្វើតាមបទពិសោធន៍របស់ អ.វ.ត.ក។

# III.

# សេចក្តីសង្ខេបសំណើដែលបានទទួល


១១២ សំណើឆ្លើយតបសហចៅក្រមរបាយការណ៍ និងរបកគំហើញរបស់សហចៅក្រមរបាយការណ៍

១២២ ការពិភាក្សា និងសំណើក្នុងវគ្គពេញអង្គរបស់ក្រុមពិភាក្សានៅក្នុងសិក្ខាសាលា

១៥៣ សំណើដែលទទួលបានក្រោយសិក្ខាសាលា

១៦៩ ក្រោយសិក្ខាសាលា៖ ការបន្តកិច្ចពិគ្រោះយោបល់បន្ទាប់ពីព្រឹត្តិការណ៍



នៅក្នុងផ្នែកនេះ របាយការណ៍នឹងពិភាក្សាលម្អិតអំពីសំណើដែលបានទទួលនៅក្នុងឆ្នាំចុងក្រោយនៃការពិគ្រោះយោបល់។ ដំបូង យើងពិភាក្សា និងវិភាគរបាយការណ៍ប្រឹក្សាយោបល់ខែធ្នូ ឆ្នាំ២០២១ របស់សហចៅក្រមរបាយការណ៍ជាមុនសិន ដែលជាមូលដ្ឋានជំរុញឱ្យមានការរៀបចំសិក្ខាសាលាស្តីពីជនរងគ្រោះក្នុងខែឧសភា ឆ្នាំ២០២២។ យើងរៀបចំ និងសង្ខេបសំណើនីមួយៗក្នុងចំណោមសំណើទាំង ២០ ដែលធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការអំពាវនាវរបស់សហចៅក្រមរបាយការណ៍នៅខែតុលា ឆ្នាំ២០២១។ ហើយយើងរួមបញ្ចូលសំណើមុនៗនៅក្នុងរបាយការណ៍នេះ។ សំណើទាំងមុនសិក្ខាសាលាខែឧសភា ឆ្នាំ ២០២២ ត្រូវបានរួមបញ្ចូលទាំងស្រុងនៅក្នុងឧបសម្ព័ន្ធទី VI។ បន្ទាប់មកយើងសង្ខេបមតិ និងលទ្ធផលនៃក្រុមពិភាក្សាប្រធានបទទាំងប្រាំបី ដែលបានពិភាក្សាយ៉ាងទូលំទូលាយក្នុង សិក្ខាសាលារយៈពេលបីថ្ងៃ ហើយយើងពន្យល់ និងបូកសរុបសំណើចុងក្រោយដែលបានចែករំលែកដោយក្រុមទាំងប្រាំបីនៅក្នុងកិច្ចប្រជុំពេញអង្គនៃសិក្ខាសាលាដែលធ្វើឡើងនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២។

បន្ទាប់មក យើងពិភាក្សាសំណើទាំងអស់ដែលបានទទួលបន្ទាប់ពីសិក្ខាសាលាខែឧសភា ឆ្នាំ ២០២២ រួមទាំងសំណើចំនួន ០៦ ទទួលបានពីភាគីពាក់ព័ន្ធសំខាន់ៗ៖ KDK, YFP, YRDP, Bophana Center, TSGM, និង DC-Cam។ ក្នុងអំឡុងពេលសិក្ខាសាលា លេខាធិការដ្ឋានបានកំណត់កាលបរិច្ឆេទកំណត់សម្រាប់ការដាក់សំណើបន្ថែមលើសំណើដាក់លាក់សម្រាប់ដំណាក់កាលដែលនៅសេសសល់នៅ អ.វ.ត.ក ដែលត្រូវដាក់ជូនលេខាធិការដ្ឋានក្នុងរយៈពេលដប់ថ្ងៃ ត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។ កាលបរិច្ឆេទកំណត់នេះអាចបត់បែនបានសម្រាប់អ្នកដែលត្រូវការពេលវេលាបន្ថែម។ ជាចុងក្រោយ ផ្នែកនេះក៏សង្ខេបសំណើបន្ថែមដែលលេចចេញមកពីការបន្តពិភាក្សាជាមួយបុគ្គល និងអង្គការនានាដែលមិនមានលទ្ធភាពចូលរួមពេញលេញក្នុងសិក្ខាសាលាខែឧសភា ឆ្នាំ២០២២៖ ទីមួយ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមចំនួន ៦០នាក់បានចូលរួមនៅក្នុងវេទិកា VSS-CPLCL នៅថ្ងៃទី១៣ ឧសភា ឆ្នាំ២០២២ ដែលបានដាក់សំណើចំនួន ០៤។ ទីពីរ ក្រុមសង្កេតការណ៍នៅក្រៅប្រទេស អ្នកស្រាវជ្រាវ និងអ្នកតស៊ូមតិដែលបានជួបពិភាក្សាដោយឡែកពីគ្នា ហើយបានសំណើសរុបចំនួន ០៣ផ្សេងគ្នា។ ចុងក្រោយសំឡេងពីសហគមន៍កម្ពុជានៅក្រៅប្រទេស ដែលមិនបានចូលរួមនៅក្នុងសិក្ខាសាលា ខែឧសភា ឆ្នាំ២០២២ ដែលបានដាក់សំណើបន្ថែមចំនួន ០២។

ដូច្នេះ យើងបានទទួលសំណើពីអង្គការ បុគ្គល ឬក្រុមបុគ្គលសរុបចំនួន ១៥ បន្ទាប់ពីសិក្ខាសាលាខែឧសភា ឆ្នាំ២០២២។ សំណើទាំងស្រុងអាចមើលលម្អិតនៅក្នុងឧបសម្ព័ន្ធទី VII ដោយសារពុំមានការកោសលុប។ យើងបានស្នើឱ្យរដ្ឋបាល អ.វ.ត.ក បោះពុម្ពផ្សាយឯកសារទាំងនេះ ក៏ដូចជារបាយការណ៍របស់សហចៅក្រមរបាយការណ៍នៅក្នុងឧបសម្ព័ន្ធទី VI រួមជាមួយនឹងរបាយការណ៍នេះ ដើម្បីអាចងាយចូលអាន និងពិនិត្យមើលសំណើដើមទាំងអស់ឡើង វិញ។ ឯកសារទាំងនេះគួរញែកដាច់ពីគ្នាដោយប្រើ QR ឬ តំណភ្ជាប់ក្នុងគេហទំព័រ ប៉ុន្តែគួរតែត្រូវបានចាត់ទុកថាជាផ្នែកសំខាន់នៃរបាយការណ៍នេះ និងអនុសាសន៍។

← ការពិភាក្សាជាក្រុមៗ នៅថ្ងៃទី២ នៃសិក្ខាសាលា ។

# សំណើឆ្លើយតបសហចៅក្រមរបាយការណ៍ និងរបកគំហើញរបស់សហចៅក្រមរបាយការណ៍

ដូចបានកត់សម្គាល់ក្នុង I.ដំណើរដើមទង និងគោលបំណងនៃសិក្ខាសាលាស្ដីពីជនរងគ្រោះ សហចៅក្រមរបាយការណ៍ចេញសេចក្ដីអំពាវនាវឱ្យដាក់សំណូមពរត្រឹមថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។ សេចក្ដីអំពាវនាវបានជូនដំណឹងដល់ភាគីដែលធ្វើការដាក់ស្នើថា "ទស្សនៈ" ដែលប្រមូលបានតាម រយៈដំណើរការនេះ នឹងត្រូវបាន "ពិចារណា និងដាក់បញ្ចូល" នៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍រួមជាមួយនឹងអនុសាសន៍។ ការងារសំខាន់ត្រូវកត់សម្គាល់គឺ សហចៅក្រមរបាយការណ៍ បានភ្ជាប់លក្ខខណ្ឌគុណវុឌ្ឍិសំខាន់ៗអំពីនីតិវិធីដែលសំណើនឹងយកមកពិចារណា ដោយគូសបញ្ជាក់ថា គោលបំណងនៃការអំពាវនាវនេះគឺដើម្បីប្រមូល "គំនិត"។ សេចក្ដីអំពាវនាបានលើកឡើងថា "គំនិតទាំងអស់ត្រូវបានពង្រីកបន្ថែម សម្រួល ឬ រួមបញ្ចូលគ្នា ដូច្នេះ មិនគួររំពឹងទុកអំពីភាពជាម្ចាស់នៃគំនិតផ្ដួចផ្ដើមណាមួយនោះឡើយ ប្រសិនបើត្រូវបានអនុវត្ត។" ដើម្បីស្វែងយល់លទ្ធផលនៃក្របខ័ណ្ឌសំណើ យើងងាកមកមើលទិដ្ឋភាពទូទៅនៃសំណើ និងអនុសាសន៍របស់សហចៅក្រមរបាយការណ៍។

ទីបំផុត សហចៅក្រមរបាយការណ៍មិនបានពង្រីក ឬ សម្រួលសំណើឡើងវិញដើម្បីកំណត់លម្អិតអំពីគំនិតផ្ដួចផ្ដើមដែលបានស្នើឡើង។ អត្ថបទនៃរបាយការណ៍ប្រឹក្សាយោបល់មិនបានពិភាក្សាអំពីសំណើ ឬ គម្រោង និងគំនិតផ្ដួចផ្ដើមណាមួយលម្អិតនោះឡើយ។ ផ្ទុយទៅវិញ របាយការណ៍សង្ខេបអ្វីដែលសហចៅក្រមរបាយការណ៍មើលឃើញថាជា "ប្រភេទ" ទូទៅមួយចំនួននៅក្នុងសំណើ ហើយបន្ទាប់មកបន្ថែមយោបល់ខ្លីៗមួយចំនួនទៀតទាក់ទងនឹងសកម្មភាពដែលមិនមាននៅក្នុងសំណើ។ សហចៅក្រមរបាយការណ៍សរុបផ្នែក "ពិភាក្សា" នៅក្នុងរបាយការណ៍ដោយលើកឡើងអនុសាសន៍ ០៤ចំណុច ដែលបាន "ឯកភាព"។ ឧបសម្ព័ន្ធភ្ជាប់របាយការណ៍របស់សហចៅក្រមរបាយការណ៍ "ប្រមូល" គំនិតដែលឃើញលើកឡើងនៅក្នុងសំណើចំនួន ២០ ដែលទទួលបាន។ ការចម្រាញ់ ការវាយតម្លៃ និងការពង្រីកលើគំនិតទាំងនេះទៅជា "គំនិតផ្ដួចផ្ដើម" ដែលហួសពីលក្ខខណ្ឌនៃសំណើនីមួយ ហេតុដូច្នេះ សំណើមិនមែនជា "កម្មសិទ្ធិ" របស់អ្នកស្នើនោះទេ វាហាក់បីដូចថាសំណើទាំងនោះបានជ្រុះនៅតាមផ្លូវ។ បើទោះជាចូលទៅមើលឧបសម្ព័ន្ធ និងអានសំណើគួរឱ្យចាប់អារម្មណ៍ជាច្រើននោះ អ្នកអាននឹងយល់តិចតួចថាតើសកម្មភាពជាក់ស្ដែងប្រភេទណាដែលបានស្នើឡើង ឬ ជារបស់នរណាអ្នកណា។ ផ្អែកលើបទពិសោធន៍ដ៏វិសេសវិសាល និងជ្រៅជ្រះរបស់បុគ្គល និងអង្គការជាច្រើនដែលបានដាក់សំណើ ការខកខានមិនបានពិភាក្សានេះធ្វើឱ្យមានការងឿងឆ្ងល់។ ការពិភាក្សាពិតប្រាកដលើសំណើជាក់ស្ដែងមិនបានធ្វើឡើងនោះទេ។

នៅពេលនេះ យើងបង្វែរទៅមើលសេចក្តីសង្ខេបសំណើនៅក្នុងតារាងខាងក្រោម ហើយ បន្ទាប់មក ការពិភាក្សាអំពីសង្ខេបរួមលើ "ប្រភេទ" សំណើ ដែលកំណត់ដោយសហចៅក្រម របាយការណ៍។

## ឯកអគ្គរដ្ឋទូត DAVID SCHEFFER ០១

- ការតាមដានសាលាក្តីនៅកម្ពុជាត្រូវបានថតទុក ដោយបកប្រែពីអង់គ្លេសទៅខ្មែរ និងអភិរក្សជាប្រព័ន្ធឌីជីថលនៅក្នុងបណ្ណសារ អ.វ.ត.ក និងសាកលវិទ្យាល័យ និងបណ្ណាល័យសាធារណៈនៅកម្ពុជា

## មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង / មជ្ឈមណ្ឌលឯកសារកម្ពុជា ០២

- ការការពារជនរងគ្រោះ និងអ្នករស់រានមានជីវិត
- ការផ្សព្វផ្សាយព័ត៌មាន
- ការគ្រប់គ្រង និងការអភិរក្សបណ្ណសារ អ.វ.ត.ក

## សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ០៣

- ការបែងចែកមូលនិធិ "សម្រាប់អ្នកតំណាងស្របច្បាប់របស់ដើមបណ្តឹង រដ្ឋប្បវេណីដើម្បីជួបជាមួយកូនក្តីរបស់ពួកគេ"
- ការផលិតសម្ភារៈដែលអនុញ្ញាត និងគម្រោងចូលប្រើប្រាស់ពន្យល់ និងថែរក្សាការងាររបស់ អ.វ.ត.ក
- ការសាងសង់ចេតិយ
- នៅពេលដែលគំនិតផ្តួចផ្តើមផ្អែកលើគម្រោងសំណងដែលបានអនុវត្តរួចហើយនោះ ការពិចារណានោះត្រូវគិតគូរថាតើមានតម្លៃបន្ថែមក្នុងការពង្រីក ឬអភិវឌ្ឍគម្រោងទាំងនោះបន្ថែមទៀតដែរឬទេ
- ការចូលប្រើប្រាស់ប្រកបដោយអត្ថន័យនៃដើមបណ្តឹងរដ្ឋប្បវេណី មើល LDC និងបណ្ណសារ

## GIZ CIVIL PEACE SERVICE ០៤

- ការចងក្រងឯកសារសមិទ្ធផលរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកំឡុង អ.វ.ត.ក ដំណើរការ តាមរយៈការតាំងពិព័រណ៍អន្តរកម្ម
- ការចូលរួមរបស់និស្សិតសន្តិភាពជាមួយនឹងដំណាក់កាលសេសសល់ អ.វ.ត.ក
- កម្មវិធីសាកល្បងដើម្បីគាំទ្រយុវជន
- មជ្ឈមណ្ឌលព័ត៌មាន អ.វ.ត.ក ដែលរចនាដោយនិស្សិត
- ការថែរក្សាបរិវេណរបស់ អ.វ.ត.ក និងប្តូរទៅជាមជ្ឈមណ្ឌលអប់រំ
- កម្មវិធីសិក្សាសន្តិភាពថ្នាក់ឧត្តមសិក្សានៅសាកលវិទ្យាល័យជាតិបាត់ដំបង តាមរយៈកម្មវិធី GIZ-CPS ដែលគាំទ្រដោយកម្មវិធីភាពជាដៃគូរបស់សាកល វិទ្យាល័យអាស៊ីអាគ្នេយ៍ (SAUP)
- ការបង្កើតមូលដ្ឋានទិន្នន័យទូទាំងប្រទេសស្តីពីមនុស្សបាត់ខ្លួន បូកនឹងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយ
- ការកសាងសមត្ថភាពនៅបណ្ណសាររបស់ LDC
- ការផ្សះផ្សាសហគមន៍

## HELEN JARVIS ០៥

- ការរៀបចំសម្រាប់ការផ្ទេរឯកសារពី អ.វ.ត.ក ទៅ LDC ដើម្បីគាំទ្របណ្ណសារ និងព័ត៌មានដែលត្រូវឆ្លងកាត់ LDC
- ពិនិត្យស្ថានភាពបច្ចុប្បន្ននៃគម្រោងសំណងទាំងអស់

## អង្គការក្ដីករុណា ០៦

- ការសន្ទនាអន្តរជំនាន់
- បន្តការប្រមូលប្រវត្តិសាស្ត្រផ្ទាល់មាត់ និងការអភិរក្ស
- ស្រាវជ្រាវលើផលប៉ះពាល់នៃរបួស SGBV លើកូន និងចៅ
- បង្កើតមជ្ឈមណ្ឌលសម្រាប់ការសម្របសម្រួលការសន្ទនា
- ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ
- សហគមន៍ថែទាំខ្លួនឯងសម្រាប់អ្នករស់រានមានជីវិតពី SGBV
- ការសន្ទនារវាងអ្នករស់រានមានជីវិត និងតួអង្គរដ្ឋ

## សាកលវិទ្យាល័យ LA TROBE ០៧

- ការកសាងលើគំនិតផ្ដួចផ្ដើមពីមុន ឬដែលមានស្រាប់
- ចូលរួមចំណែកក្នុងការលើកកម្ពស់កេរដំណែលអប់រំរបស់ អ.វ.ត.ក សម្រាប់ប្រទេសកម្ពុជា
- ពង្រឹងគោលការណ៍នៃការងារដឹកនាំដោយកម្ពុជា
- រៀនពីបទពិសោធន៍កន្លងមក
- លើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងមុខងារដែលនៅសេសសល់ និងអ្នកស្រាវជ្រាវសិក្សា

## មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ០៨

- កិច្ចព្រមព្រៀងផ្លូវការដើម្បីផ្ទេរកំណត់ត្រា និងបណ្ណសាររបស់ អ.វ.ត.ក ទាំងអស់ទៅ LDC
- វិចិត្រសាលនិងសាលតាំងពិពណ៌អចិន្ត្រៃយ៍
- ពង្រីកកម្មវិធីផ្សព្វផ្សាយ
- បង្កើតសកម្មភាពផ្សព្វផ្សាយ និងសិក្ខាសាលា
- គាំទ្រ LDC ក្នុងការរៀបចំសិក្ខាសាលា និងវគ្គខ្លីៗ
- កម្មវិធីទូរស័ព្ទដែលមានមូលដ្ឋានទិន្នន័យស្រាវជ្រាវទូលំទូលាយសម្រាប់ឯកសារសំណុំរឿងសាធារណៈទាំងអស់
- សវនាការប្រឌិត និងបន្ទប់សវនាការប្រឌិតនៅ LDC
- ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសម្រាប់ LDC និង អ.វ.ត.ក សម្រាប់ការពិនិត្យ និងកាតាឡុកឯកសារ
- ធ្វើការសម្ភាសន៍ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងទៀត

## MARIE WILMET វិទ្យាស្ថានសាកលវិទ្យាល័យអឺរ៉ុប ០៩

- សេវាសុខភាពផ្លូវចិត្ត និងរាងកាយ
- ព័ត៌មានអំពី អ.វ.ត.ក ដំណើរការនីតិវិធី និងសំណង
- ចេតិយ និងពិធីព្រះពុទ្ធសាសនា
- ឯកសារ និងការផ្សព្វផ្សាយចំណេះដឹងអំពីសម័យខ្មែរក្រហម

## NATHAN J. CHAN ១០

- អនុស្សាវរីយ៍ ឧ. monolith, ជញ្ជាំងដែលមានឈ្មោះជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម

## REDRESS ១១

- កម្មវិធីសំណងរដ្ឋបាលទូទាំងប្រទេស
- គាំទ្រដល់ TPO និងការបណ្តុះបណ្តាលអ្នកចិត្តសាស្ត្រទូទាំងប្រទេស
- កម្មវិធីអត្តសញ្ញាណប័ណ្ណទូទាំងប្រទេសភ្ជាប់ទៅនឹងកម្មវិធីសំណង
- ពិធីអាពាហ៍ពិពាហ៍សម្រាប់អ្នករស់រានមានជីវិតក្រោយការរៀបការដោយបង្ខំដែលប្រាថ្នាចង់បាន
- កម្មវិធីសន្ទនាអន្តរជំនាន់
- គំនិតផ្តួចផ្តើមរំលឹក

## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (មហាវិទ្យាល័យចិត្តវិទ្យា) ១២

- "ការស្រាវជ្រាវលើស្ថានភាពសុខភាពផ្លូវចិត្តនៅកម្ពុជា"៖ ការស្ទង់មតិផ្អែកលើប្រជាជនសុខភាពផ្លូវចិត្ត ដើម្បីផ្តល់ព័ត៌មានដល់ស្ថាប័ន និងអង្គការក្រៅ រដ្ឋាភិបាល ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រសម្រាប់ការលើកកម្ពស់សុខភាពផ្លូវចិត្តនៅកម្ពុជា ដើម្បីវាយតម្លៃកាន់តែច្បាស់អំពីតម្រូវការរបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម និងស្វែងយល់ពីផលប៉ះពាល់នៃរបួស

## លោក សឹម សុរិយ៉ា ១៣

- "គ្មានការមាក់ងាយ" លើកកម្ពស់ការផ្សះផ្សាតាមរយៈការសន្ទនាជនរងគ្រោះ-ជនល្មើស
- "ការព្យាបាលរបួស" តាមរយៈកម្មវិធីផ្លូវចិត្តចំនួនប្រាំបួនដែលបានរាប់បញ្ចូល
- ការអភិវឌ្ឍផ្នែកសិក្សា និងកេរដំណែលផ្លូវច្បាប់របស់ អ.វ.ត.ក តាមរយៈគម្រោងចំនួនប្រាំ រួមមាន អ.វ.ត.ក សង្ខេបនៃអង្គហេតុ និងបញ្ហាច្បាប់សំខាន់ៗ តុលាការព្រហ្មទណ្ឌអន្តរជាតិ ថ្នាក់ច្បាប់ព្រហ្មទណ្ឌកម្ពុជា ការកែលម្អបច្ចេកទេស និងបច្ចេកវិទ្យាតុលាការកម្ពុជា

## អង្គការចិត្តសង្គម អន្តរវប្បធម៌ ១៤

- ព្រឹត្តិការណ៍/សិក្ខាសាលាជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងជាមួយការរៀបចំផ្លូវចិត្ត។ ការគាំទ្រនៅនឹងកន្លែង និងមិត្តភាពផ្លូវចិត្តនៅ អ.វ.ត.ក
- ការព្យាបាលផ្លូវចិត្ត និងការបញ្ជូនបន្តសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី
- សេវាប្រឹក្សាយោបល់តាមទូរស័ព្ទទាន់ហេតុការណ៍
- ផលិតសម្ភារ IEC ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសុខភាពផ្លូវចិត្ត
- ការបណ្តុះបណ្តាលសម្រាប់ដៃគូរបស់អង្គការក្រៅរដ្ឋាភិបាលស្តីពី PFA ការគាំទ្រផ្នែកអារម្មណ៍ ការគ្រប់គ្រងភាពតានតឹង

## ហង្ស វណ្ណៈ ផ្នែកគាំពារជនរងគ្រោះ អ.វ.ត.ក ១៥

- វិធានការការពារសាក្សី និងអ្នកផ្សេងទៀតដែលបានផ្តល់សក្ខីកម្មនៅក្នុងដំណើរការរបស់តុលាការ
- ការការពារដើមបណ្តឹងរដ្ឋប្បវេណី

## ផ្នែកគាំទ្រសាក្សី និងអ្នកជំនាញ អ.វ.ត.ក ១៦

- ស្រាវជ្រាវដើម្បីវាយតម្លៃសេវាការពារ និងគាំទ្រដែលផ្តល់ដោយ WESU
- កំណត់អត្តសញ្ញាណប្រព័ន្ធ និងនីតិវិធីដែលរួមចំណែកដល់សាក្សីអាចផ្តល់សក្ខីកម្មនៅក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិដោយមិនជួបប្រទះនូវផលវិបាកអវិជ្ជមាន

## សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ១៧

- កម្មវិធីទីបន្ទាល់ប្រចាំថ្ងៃនៅ TSGM ដោយអ្នករស់រានមានជីវិតរបស់ KR
- បាឋកថាសាធារណៈប្រចាំឆ្នាំស្តីពីសំណុំរឿង ០០១ និងសំណុំរឿង ០០២
- "ដានប្រល័យពូជសាសន៍"តភ្ជាប់ TSGM ជើងឯក និងទីតាំងបុរាណវត្ថុ ម-១៣
- ការបញ្ចប់ការធ្វើឌីជីថលនៃទំព័រដែលនៅសេសសល់ចំនួន ៣០០,០០០ នៅក្នុងបណ្ណសារ TSGM (ក្នុងចំណោម ៧០០,០០០ សរុប)
- ការផ្ទៀងផ្ទាត់បញ្ជីជនរងគ្រោះ និងព័ត៌មានពេញលេញនៅលើបណ្ណសារ TSGM / គេហទំព័រ
- ការអភិរក្សបណ្ណសារ រួមទាំងការថែទាំអគារ និងការគាំទ្របុគ្គលិក
- ស្វែងរកឯកសារ ស-២១ ផ្សេងទៀត
- រៀបចំពិព័រណ៍បណ្តោះអាសន្នស្តីពីកេរដំណែលរបស់ អ.វ.ត.ក
- គម្រោងផ្សព្វផ្សាយអំពីសារៈសំខាន់នៃទីតាំងប្រវត្តិសាស្ត្ររបស់ KR និងការធ្វើបច្ចុប្បន្នភាពទីតាំងនៃទីតាំងឧក្រិដ្ឋកម្មរបស់ KR និងការអភិរក្ស
- ការអភិរក្ស និងការអភិរក្សវត្ថុដែលមានសារៈសំខាន់ជាប្រវត្តិសាស្ត្រ

## អ្នកកសាងសន្តិភាពស្រ្តី ១៨

- គំនិតផ្តួចផ្តើម "ប្រវត្តិសាស្ត្ររបស់ពួកគេ អនាគតរបស់យើង" ដើម្បីជំរុញការនិយាយជាសាធារណៈអំពីការចងចាំ ធ្វើការជាមួយអ្នករស់រានមានជីវិតរបស់ KR និងផ្តល់កន្លែងដើម្បីពិភាក្សាបទពិសោធន៍ជាមួយមនុស្សជំនាន់ក្រោយ និងជួយអ្នកដឹកនាំវ័យក្មេងនៃក្រុមជនជាតិចម្រុះ និងផ្តល់ឱ្យពួកគេនូវជំនាញ និងការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ
- ការព្យាបាលសិល្បៈច្នៃប្រឌិត

## អង្គការយុវសន្តិភាព ១៩

- សន្ទនាអន្តរជំនាន់ជាមួយសិស្ស/យុវជនប្រមូល និងចែករំលែកការរៀបរាប់រឿងអ្នករស់រានមានជីវិត
- ការអភិរក្សទីតាំងឧក្រិដ្ឋកម្ម
- គម្រោងចំនួនប្រាំពីរ រួមទាំងការបណ្តុះបណ្តាលប្រវត្តិសាស្ត្រ។ ដំណើរកំសាន្តទៅកាន់អន្លង់វែង ទៅ អ.វ.ត.ក និង LDC; ការសន្ទនាសហគមន៍ជាមួយអ្នករស់រានមានជីវិតពីខ្មែរក្រហម សម្រាប់ការផ្សះផ្សា និងការកសាងសន្តិភាព។ កម្មវិធីប្រាប់ការពិតនៅក្នុងគ្រួសារ; កម្មវិធីជជែកតាមវិទ្យុ

## កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន ២០

- ការបណ្តុះបណ្តាលក្នុង និងនៅនឹងកន្លែង ស្តីពីប្រវត្តិ និងការផ្សះផ្សា KR
- ដំណើរកំសាន្តទៅកាន់ អ.វ.ត.ក ស្រុកអន្លង់វែង និង LDC
- ការសន្ទនាសហគមន៍ជាមួយអ្នករស់រានមានជីវិតរបស់ KR
- ការសន្ទនាអន្តរជំនាន់
- ពិព័រណ៍គ្រួសារ
- កម្មវិធីវិទ្យុពិភាក្សាអំពីបញ្ហាកង្វល់

ដូចបានរៀបរាប់ខាងលើ អង្គការ និងបុគ្គលចំនួន ២០ បានឆ្លើយតបទៅនឹងការអំពាវនាវឱ្យដាក់សំណើ។ សរុបមក សំណើសុំបានគ្របដណ្ដប់លើគម្រោងដែលបានស្នើដោយឡែកប្រហែល ៨៥ ដែលមានវិសាលភាពខុសប្លែកគ្នាជំពេង និងព័ត៌មានលម្អិតនៃសំណើមានជាការពិពណ៌នាសង្ខេប ការពិពណ៌នាទូទៅ រហូតដល់ឯកសារគម្រោងលម្អិត។ សំណើនេះបានមកពីបុគ្គល មន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិ

អង្គការ និងស្ថាប័នកម្ពុជា និងសាកលវិទ្យាល័យ។ សំណើក៏បានកំណត់មហិច្ឆិតារយៈពេល វិសាលភាព ការចំណាយ លទ្ធភាព និងការអនុវត្តជាក់ស្ដែងផងដែរ។ សំណើរួមគ្នាការឆ្លុះបញ្ចាំងអំពីការចាប់អារម្មណ៍យ៉ាង

ទូលំទូលាយក្នុងការធានាថាការងាររបស់ អ.វ.ត.ក ត្រូវបានយកទៅធ្វើជាមរតកដ៏យូរអង្វែងដែលនឹងផ្ដល់ផលប្រយោជន៍ដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេនៅថ្ងៃនេះ និងអនាគត។ សំណើក៏តំណាងឱ្យភាពសម្បូរបែបនៃបទពិសោធន៍ និងធនធានមនុស្សដែលប្រសិនបើមានការគាំទ្រ និងបណ្ដាញត្រឹមត្រូវ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគោលបំណងនៃដំណាក់កាលដែលនៅសេសសល់នៃ អ.វ.ត.ក ដូចដែលបានរៀបរាប់នៅក្នុងកិច្ចព្រមព្រៀងបន្ថែម ព្រមទាំងដូចបានបានបកស្រាយនៅក្នុងរបាយការណ៍សហចៅក្រម និងដាក់បញ្ចូលនៅក្នុងសិក្ខាសាលាបច្ចុប្បន្ន។

ទិដ្ឋភាពសង្ខេបរបស់សហចៅក្រមរបាយការណ៍អំពីសំណើ បានកំណត់ប្រភេទទូទៅចំនួនប្រាំបី ដែលតាមការរៀបរាប់ សំណើទាំងអស់ស្ថិតនៅក្រោម៖

| | |
|---|---|
| ● គោលការណ៍ណែនាំស្ដីពីគំនិតផ្តួចផ្ដើមទាក់ទងនឹងជនរងគ្រោះក្នុងដំណាក់កាលដែលនៅសេសសល់ | ● ការអប់រំអំពីយុត្តិធម៌អន្តរកាល និង អ.វ.ត.ក |
| ● ព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ អំពី អ.វ.ត.ក/ដល់សាធារណជនទូទៅអំពី អ.វ.ត.ក. | ● ការចងក្រងទិន្នន័យ ការវាយតម្លៃ និងការរក្សាទុក |
| ● ការផ្សះផ្សានៅតាមសហគមន៍ សក្ខីកម្ម ការសម្រុះសម្រួល/ដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ | ● ការសិក្សាស្រាវជ្រាវក្នុងវិស័យផ្សេងៗ និង |
| ● ការសិក្សាស្រាវជ្រាវក្នុងវិស័យផ្សេងៗ និង | ● បូជនីយដ្ឋាន, ចេតិយ, ពិធីបុណ្យ |

យើងអាចនិយាយបានថា ទោះបីជាប្រភេទទាំងនេះ ជាទូទៅ រួមបញ្ចូលសំណើស្ទើរតែទាំងអស់ ក៏ដោយ វាមិនបានផ្តល់យុត្តិធម៌ចំពោះទិដ្ឋភាពសំខាន់ៗដែលមានលក្ខណៈខុសប្លែកគ្នាជាច្រើននោះទេ។ ជាឧទាហរណ៍ ប្រភេទទីមួយ "គោលការណ៍ណែនាំសម្រាប់គំនិតផ្តួចផ្តើមទាក់ទងនឹងជនរងគ្រោះ" មិនឆ្លុះបញ្ចាំងវិធីដែលសំណើបង្ហាញគោលការណ៍ ប៉ុន្តែផ្តោតលើវិធីច្នៃប្រឌិតដែលអាចអនុវត្តជាក់ស្តែង។ វាក៏ដូចគ្នាចំពោះប្រភេទនៃ "ការអប់រំ" "គំនិតផ្តួចផ្តើមសុខភាពផ្លូវចិត្ត" និងកិច្ចការផ្សេងៗទៀត។ ប្រសិនបើសហចៅក្រមរបាយការណ៍ មានបំណងសំយោគសំណើទៅក្នុងបណ្តុំគំនិតផ្តួចផ្តើមដែលតំណាងផ្លូវឆ្ពោះទៅមុខ និងក្របខ័ណ្ឌសកម្មភាពសេសសល់នាពេលអនាគត នោះការវិភាគ និងការពិភាក្សាសំណើល្អ ឱ្យបានលម្អិតបន្ថែមទៀត គឺភាពសមស្រប និងចាំបាច់ត្រូវធ្វើឡើង។

ទាក់ទងនឹងចំណុចដែលសហចៅក្រមរបាយការណ៍លើកឡើងជា "អនុសាសន៍ទូទៅ" ដែលរួមបញ្ចូលនៅក្នុងសំណើ របាយការណ៍គាំទ្រកិច្ចការជាក់លាក់ចំនួន ០៤៖

- ការអនុវត្តគោលការណ៍ "មិនបង្កការឈឺចាប់" ឆ្លុះបញ្ចាំងអំពីការជៀសវាងការប៉ះទង្គិចផ្លូវចិត្តសាជាថ្មី និងការគោរពឯកជនភាពរបស់ជនរងគ្រោះ

- ការកំណត់អាទិភាពនៃគម្រោងផ្អែកលើការងារពីមុន

- ការលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការរវាងស្ថាប័នសិក្សា និងគម្រោងសហគមន៍ និង

- ការប្រមូលផ្តុំ ការអភិរក្ស និងការបោះពុម្ពផ្សាយព័ត៌មានទាំងអស់អំពីជនរងគ្រោះ ដើម្បីរក្សាទុក។

អនុសាសន៍ទាំងនេះកំណត់បញ្ហាសំខាន់ៗដែលសំណើ និងសិក្ខាសាលាបានលើកឡើងថាចាំបាច់ត្រូវដោះស្រាយក្នុងពេលរចនា និងអនុវត្តដំណាក់កាលនៅសេសសល់។ វានឹងមានប្រយោជន៍ ប្រសិនបើសហចៅក្រមរបាយការណ៍ បានយកមកបញ្ចូលទៅក្នុងការវិភាគនៃខ្លឹមសារជាក់ស្តែងនៅក្នុងសំណើ។ ការវិភាគសំណើដែលបានធ្វើឡើងក្នុងអំឡុងពេល និងបន្ទាប់ពីសិក្ខាសាលា ដូចបង្ហាញខាងក្រោម នឹងផ្តោតលើរបៀបដែលបញ្ហាទាំងនោះត្រូវបានយកមកបញ្ចូលនៅក្នុងការពិភាក្សាក្នុងសិក្ខាសាលា និងអនុសាសន៍ដែលលើកឡើងនាពេលក្រោយមក។

# ការពិភាក្សា និងសំណើក្នុងវគ្គពេញអង្គ របស់ក្រុមពិភាក្សានៅក្នុងសិក្ខាសាលា

ក្នុងសិក្ខាសាលានេះ អ្នកចូលរួមប្រមាណ ៩០នាក់ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី មេធាវី និងភាគីនៃ អ.វ.ត.ក តំណាងអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងអ្នកសិក្សាស្រាវជ្រាវ ត្រូវបានបែងចែកទៅជាក្រុមចំនួនប្រាំបីដើម្បីផ្តោតលើប្រធានផ្សេងៗគ្នា ដើម្បីអភិវឌ្ឍ និងពង្រឹងកម្មវិធីផ្តោតលើជនរងគ្រោះ។ អ្នកចូលរួមត្រូវបានបែងចែកជាក្រុម និងទៅតាមប្រធានបទផ្សេងៗគ្នា ដើម្បីអនុញ្ញាតឱ្យចូលរួមសកម្ម អាចឱ្យអ្នកចូលរួមផ្តោតលើប្រធានបទរបស់ពួកគេលើសពីក្របខ័ណ្ឌការងារបុគ្គល និងអង្គការរបស់ខ្លួន។

| | |
|---|---|
| ០១ | ដើមបណ្តឹងរដ្ឋប្បវេណី |
| ០២ | សុខភាពផ្លូវចិត្ត ការព្យាបាលរបួសផ្លូវចិត្ត វ័យចាស់ជរា និងកាតព្វកិច្ចរយៈពេលវែងចំពោះជនរងគ្រោះ |
| ០៣ | បណ្ណសារ និងឯកសារ ការការពារសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី |
| ០៤ | ទីតាំងប្រវត្តិសាស្ត្រ បូជនីយដ្ឋាន និងសកម្មភាពនៃការចងចាំ |
| ០៥ | ជនជាតិភាគតិច និងសាសនា |
| ០៦ | សិទ្ធិទទួលបានយុត្តិធម៌ និងជំនួយផ្នែកច្បាប់ |

## ០៧ ការសន្ទនាអន្តរជំនាន់ និងយុវជន

## ០៨ ការទទួលស្គាល់ និងសំណងសម្រាប់អំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះ (CRSV)

សរុបមាន វគ្គធ្វើការងារជាក្រុមចំនួន ៥វគ្គ ក្នុងពេលសិក្ខាសាលារយៈពេល ០៣ថ្ងៃ។ វគ្គនីមួយៗត្រូវបានដឹកនាំដោយអ្នកសម្របសម្រួលមកពី អ.វ.ត.ក ហើយត្រូវបានការណែនាំសម្របសម្រួលឱ្យជជែកលើសំណួរ និងបញ្ហាដែលត្រូវលើកឡើងក្នុងវគ្គនីមួយៗ ដើម្បីឱ្យការពិភាក្សាមានលក្ខណៈជារចនាសម្ព័ន្ធ។

នៅក្នុងវគ្គធ្វើការងារជាក្រុមដំបូង នៅរសៀលថ្ងៃទី៣ ខែឧសភា ក្រុមពិភាក្សាត្រូវបានស្នើឱ្យណែនាំខ្លួន និងចែករំលែកអំពីសាវតារ គម្រោង និងអង្គការ។ បន្ទាប់ពីការណែនាំ និងលំហាត់ចាប់ផ្តើម អ្នកចូលរួមត្រូវបានស្នើឱ្យពិភាក្សាលើប្រធានបទចំនួន ០៣ ការទទួលស្គាល់ ការចងចាំ និងការផ្សះផ្សា។ វគ្គប្រជុំដំបូង ក៏ត្រូវបានឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមជួបពិភាក្សាដំបូងជាមួយមេធាវី និងជាមួយ CPLCLs ដែលមានវត្តមាន ដើម្បីជាឱកាសជួបជុំជាក្រុម និងស្តាប់មេធាវីអំពីគោលបំណងសិក្ខាសាលាក្នុងសប្តាហ៍នេះ និង សាវតារខ្លះៗអំពីអាណត្តិការងារថ្មីរបស់អ.វ.ត.ក។

បន្ទាប់ពីសុន្ទរកថាគន្លឹះជាបន្តបន្ទាប់របស់លោក Karim A.A. KHAN, QC ដែលជាប្រធានព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ អ្នកចូលរួមបានជួបជុំគ្នាម្តងទៀតនៅក្នុងក្រុមរបស់ពួកគេចាប់ផ្តើមវគ្គការងារជាក្រុមលើកទីពីរ ដោយផ្តោតលើមេរៀនបទពិសោធន៍ពីមុនដែលធ្វើការជាមួយជនរងគ្រោះ-អ្នករស់រានមានជីវិត និងជាមួយ អ.វ.ត.ក និងបង្កើតគោលការណ៍ និងតម្លៃរួមសម្រាប់កម្មវិធីនាពេលអនាគត។

អ្នកចូលរួមត្រូវបានស្នើឱ្យពិចារណាអំពីវិធីចងចាំ និងចៀសវាងការកើតឡើងសាជាថ្មី និងផ្តល់អត្ថន័យដល់ឃ្លា "មិនដែលបំភ្លេច"។ អ្នកចូលរួមបានរៀបរាប់អ្វីដែលពួកគេគិតថាជនរងគ្រោះត្រូវការបំផុត ឬអ្វីដែលពួកគេចង់ឃើញបំផុតចំពោះបញ្ហារបស់ក្រុមពួកគេ។ អ្នកចូលរួមបានចូលរួមយ៉ាងល្អលើការងារនេះដោយសារមានបទពិសោធន៍ធ្វើការងារជាមួយជនរងគ្រោះ និងអ្នករស់រានមានជីវិតជាច្រើនឆ្នាំក្នុងតួនាទីជាច្រើនជាមួយ និងក្រៅពី

អ.វ.ត.ក។ អ្នកចូលរួមបានពិភាក្សាមិនត្រឹមតែអំពីអ្វីដែលជនរងគ្រោះចង់បាននោះទេ ប៉ុន្តែថែមទាំងធ្វើដូចម្តេចដើម្បីធ្វើឱ្យវាកើតឡើង និងបញ្ហាប្រឈមទូទៅដែលពួកគេបានជួបប្រទះក្នុងការអនុវត្តការងារនេះរហូតមកដល់ពេលនេះ។ ពួកគេក៏ត្រូវបានស្នើឱ្យពិចារណាថាគួរអាចធ្វើអ្វីដើម្បីប្រសើរជាងមុន ហើយនឹងគោលការណ៍ និងគុណតម្លៃរួមគួរបញ្ចូលទៅក្នុងកម្មវិធីនាពេលអនាគត។

នៅក្នុងពេលសិក្ខាសាលាថ្ងៃទី២ អ្នកចូលរួមបានបន្តជជែកនៅក្នុងក្រុមរបស់ពួកគេទាក់ទងនឹងបំណង និងប្រធានបទផ្សេងៗគ្នា សម្រាប់ការរៀបចំគំនិតផ្តួចផ្តើមជនរងគ្រោះសម្រាប់ដំណាក់កាលដែលនៅសេសសល់របស់

អង្គជំនុំជម្រះវិសាមញ្ញ។ បន្ទាប់ពីសុន្ទរកថាគន្លឹះដោយលោកបណ្ឌិត Christoph Sperfeldt ក្រុមនានាបានបន្តវគ្គការងារជាក្រុមរបស់ពួកគេឡើងវិញ ដោយផ្តោតលើការជំរុញ

ឱ្យមាននិរន្តរភាព ការរួមបញ្ចូលគ្នា និងការធ្វើសមាហរណកម្មរយៈពេលវែងនៃកិច្ចខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិលដើម្បីឱ្យការផ្សះផ្សាកាន់តែទូលំទូលាយ។ អ្នកចូលរួមត្រូវបានស្នើឱ្យពិចារណាអំពីវិធីកសាងស្ថាប័នកម្ពុជាដើម្បីមានអំណាចបន្ត និងធ្វើជាគំរូសម្រាប់តំបន់ និងពិភពលោក។ ការពិភាក្សាផ្តោតលើការកសាងភាពចាំបាច់ និការចង់បាននៅក្នុងវគ្គការងារជាក្រុមទីពីរមួយថ្ងៃមុន ហើយអ្នកចូលរួមត្រូវបានស្នើឱ្យពិចារណាអំពីកម្មវិធី ឬសំណើប្រភេទណាដែលអាចឆ្លើយតបទៅនឹងតម្រូវការដូចបានរៀបរាប់។ អ្នកចូលរួមក៏ត្រូវបានស្នើសុំឱ្យពិចារណាផងដែរថាតើកម្មវិធីដែលមានស្រាប់មួយចំនួន ដូចបានកំណត់នៅក្នុងវគ្គការងារជាក្រុមមុន អាចយកមកពង្រីកដើម្បីបំពេញតម្រូវការទាំងនេះបានដែរឬទេ។

នៅក្នុងវគ្គនេះ អ្នកចូលរួមបានបំពេញភារកិច្ចបន្ថែមដោយត្រូវព្រាងសេចក្តីថ្លែងគោលបំណងនៃសំណើ ដោយផ្អែកលើប្រធានបទក្រុមរបស់ពួកគេ។ សេចក្តីថ្លែងសង្ខេបនេះរួមបញ្ចូលកថាខណ្ឌស្តីពី ការរួមចំណែកដល់កម្ពុជាទាំងមូល និងវិធីធ្វើយ៉ាងណាឱ្យវាជាគំរូសម្រាប់តំបន់ និងពិភពលោក ដើម្បីត្រៀមសម្រាប់វគ្គប្រជុំពេញអង្គលើកទី១ ដែលបានប្រព្រឹត្តទៅបន្ទាប់ពីសម្រាកអាហារថ្ងៃត្រង់នៅថ្ងៃទី២។

នៅរសៀលនោះ អ្នកចូលរួមបានចូលរួមក្នុង "វគ្គប្រជុំពេញអង្គ" ដោយបានបង្ហាញសង្ខេបនូវអ្វីដែលក្រុមបានពិភាក្សាកន្លងមក និងបានលើកឡើងអំពីតម្រូវការ និងកង្វល់សំខាន់ៗនៅក្នុងប្រធានបទរបស់ពួកគេ។ អ្នកចូលរួមបានធ្វើបច្ចុប្បន្នភាពគ្នាទៅវិញទៅមក ហើយបានចាប់ផ្តើមផ្តល់យោបល់សម្រាប់កម្មវិធី ទស្សនៈលើគោលការណ៍ និងតម្លៃរួមគ្នា និងមតិយោបល់លើបទបង្ហាញរបស់គ្នាទៅវិញទៅមក។ ដើមបណ្តឹងរដ្ឋប្បវេណី បានចែករំលែកយោបល់ និងបង្ហាញប្រតិកម្មរបស់ខ្លួនផងដែរ។

នៅក្នុងវគ្គការងារជាក្រុមលើកទី៤ នៅថ្ងៃទី ២ អ្នកចូលរួមបានបន្តការពិភាក្សាលើសំណើរបស់ពួកគេ ហើយជាពិសេសត្រូវបានស្នើឱ្យគិតគូរអំពីការបញ្ជ្រាបយេនឌ័រ និងវិធីធ្វើយ៉ាងណាបញ្ចូលសំឡេងដែលមិនទាន់បានដាក់ចូលនៅក្នុងសំណើរបស់ពួកគេ។ វគ្គនេះផ្តោតលើប្រធានបទនៃការដាក់បញ្ចូល និងការទទួលស្គាល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតទាំងអស់។ ការសង្កត់ធ្ងន់គឺលើការយកចិត្តទុកដាក់ចំពោះជនជាតិភាគតិច និងសាសនា និងពង្រីកការចូលរួម និងលទ្ធផលសម្រាប់ក្មេងជំនាន់ក្រោយ។

នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ មួយព្រឹកនៃថ្ងៃសិក្ខាសាលាចុងក្រោយ បានផ្តោតលើការត្រៀមធ្វើបទបង្ហាញជាក្រុមចុងក្រោយនៅពេលរសៀលនោះក្នុងវគ្គពេញអង្គរយៈពេលច្រើនម៉ោង។ នៅពេលរសៀល ក្រុមទាំង ០៧ ដែលបានផ្តោតលើប្រធានបទជាក់លាក់ចំនួន ០៧ បានធ្វើបទបង្ហាញចុងក្រោយអំពីសំណើលើប្រធានបទរបស់ពួកគេ ដោយផ្អែកលើកិច្ចពិភាក្សាការងារជាក្រុមយ៉ាងសកម្មរបស់ពួកគេក្នុងរយៈពេលសិក្ខាសាលាចំនួនបីថ្ងៃ។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់ឱកាសឆ្លើយតបទៅនឹងសំណើទាំងនេះ និងចែករំលែកអារម្មណ៍ និងក្តីសង្ឃឹមរបស់ពួកគេសម្រាប់ដំណាក់កាលដែលនៅសេសសល់របស់ អ.វ.ត.ក នាពេលខាងមុខ។ ការចូលរួមយ៉ាងសកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការពិភាក្សាក្រុមរបស់ពួកគេ និងនៅក្នុងវគ្គប្រជុំពេញអង្គ បានបង្ហាញឱ្យឃើញនូវតម្លៃដែលមិនអាចកាត់ថ្លៃបានក្នុងការផ្តល់ចក្ខុវិស័យអំពីអ្វីដែលជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី សង្ឃឹមថានឹងឃើញលេចចេញជារូបរាងតាមរយៈដំណាក់កាលដែលនៅសេសសល់ ដោយធានាថាសំឡេងរបស់ពួកគេត្រូវបានស្តាប់ និងដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងសំណើ។ នៅក្នុងផ្នែកបន្ទាប់នៃ

របាយការណ៍នេះ យើងនឹងរៀបរាប់លម្អិតអំពីការពិភាក្សារបស់ក្រុមនីមួយៗ អំពីវគ្គការងារជាក្រុម វគ្គពេញអង្គ និងបទបង្ហាញចុងក្រោយរបស់ក្រុមនៅថ្ងៃសិក្ខាសាលាចុងក្រោយ។ ដំបូងយើងខ្ញុំនឹងសង្ខេបសំណើពីក្រុមផ្សេងៗគ្នាក្នុងតារាងខាងក្រោម (ហើយក្នុងករណីក្រុមទីមួយដែលមានដើមបណ្តឹងរដ្ឋប្បវេណី បញ្ជីនៃតម្រូវការ និងគំនិតដែលពួកគេប្រមូលបាន)៖

## ● ដើមបណ្តឹងរដ្ឋប្បវេណី ០១

- បង្កើតសមាគមសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម ដែលគាំទ្រគោលនយោបាយសម្រាប់អ្នករស់រានមានជីវិតពីវ័យចំណាស់ ហើយត្រូវតែមាននិរន្តរភាពសម្រាប់រយៈពេលយូរ
- ប័ណ្ណសមធម៌ដែលត្រូវចែកចាយដល់ដើមបណ្តឹងរដ្ឋប្បវេណី - កាតសម្រាប់សេវា/ការព្យាបាលសុខភាពដោយឥតគិតថ្លៃ ឬ បញ្ចុះតម្លៃ
- ព័ត៌មានត្រូវតែផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី - រួមទាំងការបណ្តុះបណ្តាលជំនាញជីវិតសម្រាប់កូនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ការព្យាបាលតាមវេជ្ជសាស្រ្តទាក់ទងនឹងបញ្ហាសុខភាពផ្លូវចិត្តជាពិសេស សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានវ័យចំណាស់
- ចូលរួមក្នុងសិក្ខាសាលាណាមួយអំពីជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី - ពីរ ឬ បីដងក្នុងមួយឆ្នាំ
- ឱសថបុរាណ និងវិធីព្យាបាលដែលត្រូវសរសេរក្នុងសៀវភៅណែនាំ (ឧ. ការប្រើប្រាស់ផ្លែឈើ និងរុក្ខជាតិ។ល។)
- រឿងរ៉ាវដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលា
- ការពារកេរដំណែលនៃសក្ខីកម្ម និងឯកសាររបស់ អ.វ.ត.ក
- ទិវាចងចាំ ២០ ឧសភា

## សុខភាពផ្លូវចិត្ត ការព្យាបាលរបួសផ្លូវចិត្ត ០២

- ការលើកកម្ពស់សុខភាព និងគុណភាពជីវិតរបស់ជនរងគ្រោះ/អ្នករស់រានមានជីវិតក្នុងរបបខ្មែរក្រហម តាមរយៈការពង្រឹងរចនាសម្ព័ន្ធគាំទ្រសង្គម និង SDGs កម្ពុជា
- ស្វែងយល់ពីក្របខ័ណ្ឌ យន្តការ សមាហរណកម្ម ការបញ្ជ្រាបយេនឌ័រ និងជនជាតិភាគតិចដែលមានស្រាប់
- សហការជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គជបជ ក្រសួងមហាផ្ទៃ
- ធ្វើការរួមគ្នាជាមួយសមាគមមនុស្សចាស់ដែលមានរួចហើយ រៀបចំ និងបង្កើតឡើងដោយក្រសួងសង្គមកិច្ច ដែលមាននៅថ្នាក់មូលដ្ឋាន

## បណ្ណសារ និងឯកសារ ការការពារសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ០៣

- បណ្ណសាររបស់ អ.វ.ត.ក ត្រូវតែរៀបចំតាមរបៀបងាយស្រួលប្រើ ដើម្បីអនុញ្ញាតឱ្យចូលប្រើបានទូលំទូលាយបំផុតទៅកាន់អ្នកប្រើប្រាស់ដ៏ធំទូលាយបំផុត ដោយរួមបញ្ចូលនូវចំនួនឯកសារច្រើនបំផុតដែលអាចធ្វើទៅបាន អាស្រ័យលើការចាត់ថ្នាក់ឡើងវិញដោយចៅក្រមដោយមានជំនួយពីមន្ត្រីច្បាប់ និងអ្នកបច្ចេកទេសដែលគ្រប់គ្រងដោយផ្ទាល់ដោយចៅក្រម ហើយត្រូវតែជាផ្នែកមួយនៃគម្រោងភ្ជាប់ប័ណ្ណសារ
- ទូលំទូលាយ។
- ការចាត់ថ្នាក់ឡើងវិញសម្រាប់ការចូលប្រើប្រាស់ឯកសាររបស់ អ.វ.ត.ក យ៉ាងទូលំទូលាយបំផុត - ដោយមានគោលការណ៍មិនបង្កគ្រោះថ្នាក់
- ការបង្កើតតំណភ្ជាប់ទៅកាន់បណ្ណសារដែលមានស្រាប់ ដើម្បីធានាបាននូវការចូលប្រើប្រាស់ទាំងអស់។ ការបន្ថែម និងការភ្ជាប់សក្ខីកម្ម និងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹងគំនិតផ្តួចផ្តើមរបស់អង្គការមិនមែនរដ្ឋាភិបាលសម្រាប់គម្រោងអន្តរកម្ម
- គាំទ្រមេធាវីដើមបណ្តឹងរដ្ឋប្បវេណី, CPLCLs, VSS ដើម្បីទាក់ទងទៅ ដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់ និងជនរងគ្រោះផ្សេងទៀត អំពីការបញ្ចប់ការងាររបស់ អ.វ.ត.ក
- គាំទ្រ WESU/VSS ក្នុងការបន្ត/បន្តកម្មវិធីការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

## ទីតាំងប្រវត្តិសាស្ត្រ បូជនីយដ្ឋាន និងសកម្មភាពនៃការចងចាំ ០៤

- ការគូសផែនទីទីតាំងខ្មែរក្រហមនៅកម្ពុជា (ត្រូវបានអភិវឌ្ឍបន្ថែមទៀតបន្ទាប់ពីសិក្ខាសាលា សូមមើលផ្នែកបន្ទាប់សម្រាប់សំណើដែលទទួលបានបន្ទាប់ពីសិក្ខាសាលា)
- ការប្រមូលប្រវត្តិសាស្ត្រ និងរឿងរ៉ាវពីអ្នករស់រានមានជីវិត រួមទាំងពីអតីតអ្នកជាប់ឃុំនៅមជ្ឈមណ្ឌលសន្តិសុខ
- ផ្សព្វផ្សាយកេរដំណែលរបស់ អ.វ.ត.ក - ផ្អែកលើបទពិសោធន៍ជាមួយ Nuremberg ដែលត្រូវបានរក្សាទុកជាទីតាំងប្រវត្តិសាស្ត្រ និងសារមន្ទីរ ដែលដូចគ្នានេះដែរសម្រាប់ អ.វ.ត.ក
- LDC អាចដើរតួនាទីយ៉ាងសំខាន់លើការរំលឹកការចងចាំ។

## ជនជាតិភាគតិច និងសាសនា ០៥

- មជ្ឈមណ្ឌលឯកសារផ្តោតលើខ្មែរក្រោម និងវៀតណាម - ផ្តោតលើ ទីតាំងឧក្រិដ្ឋកម្មនៅជិតពួកគេនៅតាកែវ ក្នុងវត្តប្រាសាទ - នៅជិត
- សហគមន៍របស់ពួកគេ
- សមាគមអ្នករស់រានមានជីវិតសម្រាប់អតីតជនរងគ្រោះនៃរបប ខ្មែរក្រហម
- ការសន្ទនាអន្តរជំនាន់ស្តីពីការអប់រំសន្តិភាព ដើម្បីអភិវឌ្ឍជំនាញ ក្នុងការដោះស្រាយជម្លោះដោយអហិង្សា
- ការការពារសង្គម ការចូលទៅកាន់ឯកសារអត្តសញ្ញាណ

## សិទ្ធិទទួលបានយុត្តិធម៌ និងជំនួយផ្នែកច្បាប់

- ការបង្កើតសមាគមជនរងគ្រោះ
- ស្ថាប័នស្រាវជ្រាវ និងមជ្ឈមណ្ឌលច្បាប់ ដើម្បីលើកកម្ពស់សកម្មភាព ស្រាវជ្រាវ
- កសាងចេតិយគ្រប់ខេត្ត ក្រុង
- ការព្យាបាលវេជ្ជសាស្ត្រ និងជំនួយសុខភាពផ្លូវចិត្ត ត្រូវបានធ្វើឡើង ដោយឥតគិតថ្លៃដល់អ្នករស់រានមានជីវិតទាំងអស់

## ការសន្ទនាអន្តរជំនាន់ និងយុវជន ០៧

- មជ្ឈមណ្ឌលសម្រាប់កិច្ចសន្ទនាអន្តរជំនាន់ ដែលដៃគូនីមួយៗ (អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋ) អាចនាំមកនូវចំណេះដឹង ជំនាញ និងជំនាញក្នុងវិស័យរបស់ពួកគេ និងគាំទ្រគ្នាទៅវិញទៅមក ដោយផ្អែកលើវិស័យផ្សេងៗគ្នា
- កម្មវិធីឆ្លើយតបសម្រាប់ការគាំទ្រសុខភាពផ្លូវចិត្ត និងការពន្យល់អំពី របួសសម្រាប់ទាំងអ្នករស់រានមានជីវិត និងយុវជន

## ការទទួលស្គាល់ និងសំណងសម្រាប់អំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះ (CRSV) ០៨

- ការអប់រំអំពីប្រវត្តិរបស់របបខ្មែរក្រហម - ការរួមបញ្ចូលទៅក្នុង កម្មវិធីសិក្សារបស់សាលា ប៉ុន្តែចាំបាច់ត្រូវរួមបញ្ចូលការផ្តោត ទៅលើ SGBV
- ការសន្ទនាអន្តរជំនាន់នៅកម្រិតសហគមន៍ និងគ្រួសារ ដោយ ផ្តោតលើជំនាញ និងការកសាងសមត្ថភាព

# ០១

ក្នុងវគ្គប្រជុំពេញអង្គកំណាត់ថ្ងៃទី២ ក្នុងពេលសិក្ខាសាលា ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់ឱកាសដំបូង និងសំខាន់បំផុត ចែករំលែកជាមួយអ្នកចូលរួមគ្រប់គ្នានូវលទ្ធផលពិភាក្សារបស់ពួកគេរហូតមកដល់ពេលនេះ។



ឯ.ឧ កែវ រ៉េមី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និង អនុប្រធានអចិន្ត្រៃយ៍ក្រុមការងារ អ.វ.ត.ក របស់ រាជរដ្ឋាភិបាល ថ្លែងសុន្ទរកថាបើក នៅថ្ងៃ ទី១ នៃសិក្ខាសាលា ។

ទោះបីជាពួកគេមិនត្រូវបានរំពឹងថាឱ្យរៀបចំគម្រោងជាក់លាក់មួយ ឬ ធ្វើបទបង្ហាញ ក៏ប៉ុន្តែ ចំណុចសំខាន់គឺត្រូវ

ស្តាប់ពួកគេដោយផ្ទាល់អំពីតម្រូវការ និងការចង់បាន និងសេចក្តីរំពឹងទុកពីការចូលរួមសិក្ខាសាលានេះ។ ក្រុមនេះបានឆ្លៀតឱកាសចែករំលែកជាមួយសិក្ខាសលាអំពីបញ្ជីការងារអាទិភាពចំនួនប្រាំបី និងតម្រូវការដែលពួកគេសង្ឃឹមថានឹងត្រូវបានឆ្លើយតបតាមរយៈសិក្ខាសាលា និងបន្តការអភិវឌ្ឍ តាមរយៈមុខងារដែលនៅសេសសល់របស់ អ.វ.ត.ក។

ទីមួយ ពួកគេចង់ឃើញការបង្កើតសមាគមជនរងគ្រោះសម្រាប់ជនរងគ្រោះក្នុងរបបខ្មែរក្រហម។ ពួកគេទទួលស្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណីកាន់តែចាស់ ហើយមនុស្សជាច្រើនមានអារម្មណ៍ថាពួកគេហាក់ដូចជាមិនបានទទួលយុត្តិធម៌ ហើយបានបន្តរស់នៅដោយមន្ទិលសង្ស័យថាតើពួកគេនឹងធ្វើយ៉ាងដូចម្តេច។ ពួកគេបានស្នើសុំឱ្យមានសមាគមជនរងគ្រោះចុះបញ្ជីជាផ្លូវការ (អាចជាជាមួយរដ្ឋាភិបាល) ក្នុងគោលបំណងផ្តល់វេទិកាសម្រាប់សំឡេងដើមបណ្តឹងរដ្ឋប្បវេណី។ ពួកគេបានចែករំលែកថា គោលនយោបាយណាមួយត្រូវតែមាននិរន្តរភាពក្នុងរយៈពេលវែង ដោយសារពួកគេមានអាយុកាន់តែច្រើន។

ទី២ ដើមបណ្តឹងរដ្ឋប្បវេណីបានអំពាវនាវឱ្យមាន "ប័ណ្ណសមធម៌" ដើម្បីចែកជូនដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្នុងគោលបំណងថា កាតនេះនឹងត្រូវបានប្រើប្រាស់សម្រាប់សេវាសុខភាព និងការព្យាបាលវេជ្ជសាស្ត្រ ក្នុងតម្លៃទាប ឬ ឥតគិតថ្លៃ។ ប្រព័ន្ធអត្តសញ្ញាណប័ណ្ណបែបនេះក៏ត្រូវបានលើកឡើងនៅក្នុងឯកសារមួយចំនួនដែលបានទទួលមុនសិក្ខាសាលា ដូចនៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីបានទទួលស្គាល់ថា ដើម្បីឱ្យគំនិតផ្តួចផ្តើមបែបនេះអាចកើតឡើង ចាំបាច់ត្រូវមានការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬ កញ្ចប់ថវិកាដែលជាក្របខ័ណ្ឌជំនួយដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីបានចែករំលែកថា គំនិតផ្តួចផ្តើមបែបនេះនឹងលើកទឹកចិត្តពួកគេបន្ថែមទៀត តាមរយៈការផ្តល់វិភាគទានដល់ពួកគេដែលបានចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី និងចែករំលែករឿងរ៉ាវនៃអ្នករស់រានមានជីវិត។

ទស្សនៈទីបី ដែលបានចែករំលែកគឺការបន្តចូលរួមសិក្ខាសាលាអំពីជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ ពួកគេបានបង្ហាញក្តីរីករាយដែលបានចូលរួមសិក្ខាសាលា ដែលប្រើប្រាស់ជាវេទិកាតំណាងឱ្យតម្រូវការដើមបណ្តឹងរដ្ឋប្បវេណី ហើយចង់ឃើញសិក្ខាសាលាបែបនេះកើតឡើងកាន់តែច្រើន ជាពិសេសក្នុងពេញមួយអាណត្តិនៃការងារដែលនៅសេសសល់។ ចំណុចល្អបំផុត ពួកគេបានផ្តល់យោបល់ថាសិក្ខាសាលាបែបនេះធ្វើឡើងពីរ ឬ បីដងក្នុងមួយឆ្នាំ ព្រោះនេះនឹងផ្តល់ឱកាសឱ្យមានការចូលរួមជាទៀងទាត់ និងអនុញ្ញាតឱ្យមានអ្នកចូលរួមកាន់តែច្រើនក្នុងសិក្ខាសាលា។ ក្រៅពីនេះក៏មានការស្នើឡើងផងដែរថា សិក្ខាសាលអាចភ្ជាប់ជាមួយឱកាសចូលរួមក្នុងទិវាចងចាំ ២០ ឧសភាផងដែរ។

ដើមបណ្តឹងរដ្ឋប្បវេណីក៏បានចែករំលែកថា ពួកគេចង់ទទួលបានព័ត៌មានបន្ថែមទៀត។ ជាទូទៅ ពួកគេបានបង្ហាញអំពីការខ្វះខ្នែងទំនាក់ទំនងជាមួយ អ.វ.ត.ក មេធាវីរបស់ពួកគេ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។ ដោយសារកូវីដ និងកត្តាផ្សេងទៀត ពួកគេមិនបានចូលរួមច្រើនជាមួយ អ.វ.ត.ក ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយមានបំណងចង់ចូលរួមជាបន្តបន្ទាប់។ ពាក់ព័ន្ធនឹងការចូលរួមនេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានចែករំលែកថា ពួកគេចង់ឃើញឱកាសកាន់តែច្រើនសម្រាប់កូនៗរបស់ពួកគេ ដោយទទួលស្គាល់អំពីសារៈសំខាន់នៃអ្នកជំនាន់ក្រោយ ដោយសារខ្លួនកាន់តែចាស់។ ជាឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឱ្យរៀបចំការបណ្តុះបណ្តាលជំនាញបំណិនជីវិតដល់កូនៗដើមបណ្តឹងរដ្ឋប្បវេណី។

ក្នុងសំណូមពរទី៥ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឱ្យបញ្ចូលរឿងរ៉ាវរបស់ពួកគេទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន។ ចំណុចនេះបានបង្ហាញជាថ្មីម្តងទៀតនូវការខ្វះខ្នែងក្នុងការរៀបរាប់រឿងរ៉ាវរបស់ពួកគេ ជាពិសេសដល់យុវជនខ្មែរជំនាន់ក្រោយដែលបានកើតមកស្រណុកសុខស្រួលបន្ទាប់ពីការដួលរលំរបបខ្មែរក្រហម។ ពួកគេសង្ឃឹមថានឹងឃើញប្រវត្តិសាស្ត្រនៃសម័យខ្មែរក្រហមបន្ថែមលើកម្មវិធីសិក្សាដែលមានស្រាប់ និងការដាក់បញ្ចូលរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេក្នុងកម្មវិធីសិក្សានៅតាមសាលារៀន ដើម្បីឱ្យសិស្សានុសិស្សទូទាំងប្រទេសអាចរៀនពីរឿងរ៉ាវទាំងនេះ។

តម្រូវការទីប្រាំមួយ ដែលក្រុមដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញគឺ ការព្យាបាលវេជ្ជសាស្ត្រ ហើយមិនដូចការលើកឡើងទីពីរខាងលើនោះទេ សម្រាប់ការព្យាបាលនេះ គឺផ្តោតលើបញ្ហាសុខភាពផ្លូវចិត្ត ជាពិសេសសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានវ័យចំណាស់ និងចាស់ៗ ដោយសារពួកគេកាន់តែមានតម្រូវការសេវាបែបនេះ។ អ្នកខ្លះបានសម្តែងយោបល់ថា ពួកគេបានជជែកជាមួយ TPO ក្នុងអំឡុងពេលដែលទៅទស្សនកិច្ចសាលាក្តី ឬ អ្នកដទៃហើយក៏បានលើកឡើងថា ចំណុចសំខាន់ខ្លាំងសម្រាប់ពួកគេគឺការស្វែងយល់បទពិសោធន៍ក្នុងនាមជាអ្នករស់រានមានជីវិត និងដោះស្រាយបញ្ហាដែលពួកគេបន្តប្រឈម។

សំណើទី៧ គឺបង្កើតសៀវភៅណែនាំដែលចងក្រងឯកសារឱសថបុរាណ និងរុក្ខជាតិ ដែលគេប្រើជាទូទៅក្នុងប្រទេសកម្ពុជា។ ហេតុផលនៅពីក្រោយនេះគឺដើម្បីឱ្យមានសៀវភៅណែនាំបែបនេះសម្រាប់មនុស្សវ័យចំណាស់នៅក្នុងប្រទេសកម្ពុជា ដែលផ្តល់ភាពងាយស្រួលសម្រាប់ពួកគេក្នុងការប្រើប្រាស់ និងធ្វើការយកផ្លែឈើ ឬ រុក្ខជាតិមកប្រើក្នុងការព្យាបាល កាន់តែងាយស្រួលដល់មនុស្សចាស់ទូទាំងប្រទេស។

ជាចុងក្រោយ សំណូមពរទីប្រាំបីគឺអំពីការរក្សាកេរដំណែល អ.វ.ត.ក។ ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីដែលដាក់ឯកសារជូន អ.វ.ត.ក បំពេញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបានចែករំលែកសក្ខីកម្មរបស់ពួកគេ ពួកគេបានចែករំលែកថា ពួកគេចង់ឃើញកេរដំណែលនេះត្រូវបានរក្សាទុក និងរៀបចំចងក្រង។ ពួកគេស្នើឱ្យ

សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដើម្បីធ្វើការងារនេះ។ កេរដំណែលនេះនឹងទទួលស្គាល់ពួកគេថាជា "មរតករស់" ដែលសមស្របត្រូវធ្វើមូលដ្ឋានីយកម្មសមស្រប។

ចំណុចចុងក្រោយ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីបានចែករំលែកការឆ្លុះបញ្ចាំងមួយចំនួននៅលើបញ្ជីតម្រូវការដែលពួកគេបានកំណត់។ ពួកគេបានសួរអំពីតួនាទីរបស់ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រោយពីអាណត្តិបីឆ្នាំនៃយន្តការដែលនៅសេសសល់។ ពួកគេក៏បានលើកឡើងអំពីរបៀបដែលរដ្ឋាភិបាលបង្កើតសមាគមនៅថ្នាក់ឃុំ ប៉ុន្តែដោយសារ

កង្វះការអនុវត្ត និងការចូលរួម វាហាក់បីដូចជាមិនមានប្រសិទ្ធភាព។ ពួកគេបានស្នើថាអាចចូលរួមជួយមន្ត្រីមូលដ្ឋានផ្សេងទៀត ក្នុងការបង្កើតសមាគមជនរងគ្រោះ ដូចបានរៀបរាប់ខាងលើ នៅក្នុងសំណូមពរដំបូង។ ក្នុងនាមជាអ្នកចូលរួមសិក្ខាសាលា ដើមបណ្តឹងរដ្ឋប្បវេណីយល់ថា ពួកគេអាចបំពេញការងារប្រកបដោយប្រសិទ្ធភាព ជួយអនុវត្តសមាគមឃុំបែបនេះ ហើយពួកគេចង់ឱ្យរដ្ឋាភិបាល និងអង្គការនានាចូលរួមក្នុងការងារនៅថ្នាក់មូលដ្ឋាន ដោយដឹងថា ថ្នាក់មូលដ្ឋានមានកម្រិតសមត្ថភាព។

# ០២

## នៅក្នុងវគ្គការងារជាក្រុមដំបូង ក្រុមទី ២ បានឆ្លុះបញ្ចាំងថាការទទួលស្គាល់ ការរំលឹក និងការផ្សះផ្សាមានន័យចំពោះពួកគេយ៉ាងដូចម្តេច និងសម្រាប់ជនរងគ្រោះ។



លោកស្រី ឃឹម សុជារី អ្នកឯកទេសព្យាបាលតាមចិត្តសាស្ត្រ អ្នកប្រឹក្សាការខាងសន្តិភាពនិងវិវាទ និង ស្ថាបនិក/នាយកប្រតិបត្តិ នៃ ស្នេហា ថ្លែងសុន្ទរកឋាគន្លឹះ ក្រោមចំណងជើងថា "ដំណើរនៃការព្យាបាលជនរងគ្រោះ-អ្នកនៅរស់រានមានជីវិត," នៅថ្ងៃទី១ នៃសិក្ខាសាលា ។

ក្រុមនេះក៏បានរួមបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីពីររូប ដែលបានចូលរួមក្នុងការពិភាក្សាជាក្រុម និងបានបង្ហាញចក្ខុវិស័យអំពីប្រធានបទនេះ ដែលបានជួយបង្កើតទស្សនៈរបស់ក្រុម និងបទបង្ហាញគម្រោងចុងក្រោយនៅក្នុងវគ្គពេញអង្គកាលពីថ្ងៃទី៥ ខែឧសភា។

ចំពោះប្រធានបទនៃការទទួលស្គាល់ អ្នកចូលរួមបានចែករំលែកថា ការទទួលស្គាល់មានន័យថាការទទួលស្គាល់ព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងអតីតកាល និងការទទួលស្គាល់នូវបទពិសោធន៍ដ៏ឈឺចាប់ដែលអ្នករស់រានមានជីវិតបានជួបប្រទះ។ វាក៏មានន័យថា តម្រូវការក្នុងការទទួលស្គាល់ និងទទួលយកនូវអ្វីដែលបានកើតឡើង ហើយការទទួលស្គាល់នេះក៏ចាំបាច់ត្រូវមានប្រភពមកពីស្ថាប័នច្បាប់ផងដែរ។ ការទទួលស្គាល់ក៏រួមបញ្ចូលនូវការចែករំលែករឿងរ៉ាវបុគ្គលពីអតីតកាល និងការចែករំលែកការកាត់ទោសពីអតីតកាលជាមួយសង្គមកម្ពុជាដែលនៅសេសសល់។ ការទទួលស្គាល់នេះក៏ត្រូវការដើម្បីឈានទៅដល់កម្រិតមូលដ្ឋានបន្ថែមទៀត រួមទាំងការទទួលស្គាល់ពីក្រុមគ្រួសារផងដែរ និងឱកាសដើម្បីចែករំលែកនូវអ្វីដែលពួកគេជាជនរងគ្រោះ ចង់ចែករំលែក។ ការទទួលស្គាល់សម្រាប់អ្នកចូលរួមក្នុងក្រុមនេះក៏មានន័យថាជាទម្រង់ផ្លូវការនៃការទទួលស្គាល់តាមរយៈអត្តសញ្ញាណប័ណ្ណជនរងគ្រោះផ្តល់ជូនដោយរដ្ឋាភិបាល និងតាមរយៈវិញ្ញាបនបត្រជនរងគ្រោះផ្តល់ជូនដោយ អ.វ.ត.ក។

សម្រាប់ក្រុមនេះ ការផ្សះផ្សាបានបង្ហាញពីការព្យាបាលរបួសផ្លូវចិត្ត និងការដោះស្រាយបញ្ហាដូចជាការផ្តាច់ទំនាក់ទំនងជាមួយខ្លួនយើង និងសមាជិកគ្រួសាររបស់យើង។ ការព្យាបាលរបួសផ្លូវចិត្តក្នុងន័យនេះមានន័យថាការប្រាស្រ័យទាក់ទងជាមួយអ្នកនៅរស់រានមានជីវិត និងរក្សាទិដ្ឋភាពព្យាបាលនេះសម្រាប់ក្មេងជំនាន់ក្រោយផងដែរ។ ពួកគេបានពន្យល់ថា ការផ្សះផ្សាអាចជួយមនុស្សឱ្យជួបជុំគ្នាឡើងវិញ និងអនុញ្ញាតឱ្យពួកគេរស់នៅជាមួយគ្នាដោយសន្តិភាព។ នៅកម្រិតបុគ្គល វាមានន័យថាការផ្សះផ្សាខ្លួនឯង និងការផ្សះផ្សាគ្រួសារ ប៉ុន្តែក៏ចំពោះក្របខ័ណ្ឌធំ ការផ្សះផ្សាជាតិ។ ការផ្សះផ្សានេះសំដៅសន្តិភាពយូរអង្វែង តាមរយៈការផ្តោតលើការយល់ដឹងជាវិជ្ជមាន ឬ សន្តិភាព និងភាពសុខដុមរមនា។ ក្រុមក៏បានកត់សម្គាល់ផងដែរអំពីតម្រូវការក្នុងការបញ្ចូលជនល្មើស

នៅក្នុងការសន្ទនា ប្រសិនបើវាជួយសម្រាលទុក្ខលំបាកជនរងគ្រោះ និងគាំទ្រការយល់ដឹងអំពីសកម្មភាពកន្លងមកកាន់តែប្រសើរឡើង។

ចំពោះប្រធានបទនៃការចងចាំ ក្រុមបានពិភាក្សាគ្នាថា វាមានន័យថា ការចងចាំពីអតីតកាល ហើយវាអាចរួមបញ្ចូលទាំងការចងចាំល្អ និងអាក្រក់។ ការចងចាំចាប់ផ្ដើមថតទុកនៅពេលការចងចាំរយៈពេលវែងបានដំណើរការ ប៉ុន្តែចំណុចនេះក៏អាចបង្កើតការរងទុក្ខ និងរបួសផ្លូវចិត្តផងដែរ នៅពេលចងចាំរឿងរ៉ាវអាក្រក់។ សមាជិកក្រុមបានចែករំលែកថា ការចងចាំគួរតែរួមបញ្ចូលទាំងចំណេះដឹង និងតម្រូវការក្នុងការព្យាបាលរបួសដោយសារការចងចាំមួយចំនួនផងដែរ។ ការចងចាំក៏មានន័យថា ការចែករំលែកអារម្មណ៍ទាំងនេះពីអតីតកាល ហើយប្រើប្រាស់ដើម្បីចងចាំរឿងអតីតកាល និងចែករំលែកទៅកាន់ក្មេងៗជំនាន់ក្រោយ។

សមាជិកក្រុមបានពិភាក្សាអំពីអ្វីដែលពួកគេអាចធ្វើបានសម្រាប់ជនរងគ្រោះ ហើយបានងាកទៅរកដើម

បណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុម ដើម្បីចែករំលែកនូវអ្វីដែលពួកគេចង់ឃើញទាក់ទងនឹងគោលការណ៍រួម និងតម្លៃសម្រាប់កម្មវិធីនាពេលអនាគត។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរនាក់ក្នុងក្រុម (ពេជ្រ ស្រីផល និង ម៉ន សុជា) ចែករំលែកថា ពួកគេចង់ឃើញការផ្សព្វផ្សាយបន្ថែមទៀតទៅកាន់តំបន់ដាច់ស្រយាល ដើម្បីបង្កើតនិរន្តរភាព ហើយកម្មវិធីណាក៏ដោយគួរមានភាពពាក់ទាក់ជាមួយជនរងគ្រោះ ដើម្បីអាចឱ្យពួកគេចែករំលែករឿងរ៉ាវបន្ថែមទៀត។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានចែករំលែកផងដែរថា ពួកគេអាចជួយជូនដំណឹងដល់ជនរងគ្រោះអំពី អ.វ.ត.ក និងដំណើរការយុត្តិធម៌បាន។ តម្រូវការសំខាន់របស់ជនរងគ្រោះដែលពួកគេបានកំណត់គឺការថែទាំសុខភាព និងសុខុមាលភាព។ ការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ជនរងគ្រោះត្រូវបានគូសបញ្ជាក់ថា ការធ្វើបែបនេះជួយសម្រួលស្ថានភាពប្រចាំថ្ងៃរបស់ពួកគេ ហើយអាចផ្ដល់ឱ្យពួកគេនូវអារម្មណ៍សន្តិភាព និងឱកាសរីករាយនឹងជីវិតម្ដងទៀត។

ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុមនេះក៏បានលើកឡើងអំពីតម្រូវការរបស់ជនរងគ្រោះក្នុងការទទួលស្គាល់ទម្រង់មួយចំនួនជាពិសេសប្រសិនបើពួកគេបានចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណី។ ឧទាហរណ៍ របៀបដែលដើម

បណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ បានទទួលលិខិតពីតុលាការបានបង្ហាញឱ្យឃើញពីទម្រង់នៃការទទួលស្គាល់ ហើយការអនុវត្តល្អបែបនេះគួរមានការទទួលស្គាល់នេះម្ដងទៀតនៅក្នុងសំណុំរឿង ០០២។ ការងារនេះអាចអនុវត្តតាម

រយៈកិច្ចប្រជុំដែលរៀបចំជាមួយរដ្ឋាភិបាលដើម្បីជួប និងសម្ដែងការទទួលស្គាល់ជនរងគ្រោះ ជាពិសេសនៅថ្នាក់

មូលដ្ឋាន។ ពួកគេបានផ្ដល់អនុសាសន៍ឱ្យបន្តការប្រមូល និងចងក្រងឯកសារសក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី និង

សក្ខីកម្មជនរងគ្រោះ និងតម្រូវការក្នុងការតស៊ូមតិសម្រាប់ស្ថាប័នផ្សេងទៀត ដើម្បីផ្ដោតលើខ្លឹមសារនៃរឿងរ៉ាវទាំងនេះ សំដៅជានាបាននូវការរក្សាទុកនូវបទពិសោធន៍របស់ពួកគេ។ ឯកសារនេះមានសារៈសំខាន់ ដោយសារដើម

បណ្ដឹងរដ្ឋប្បវេណីបានកត់សម្គាល់ថា ក្មេងជំនាន់ក្រោយមិនសូវជឿរឿងរ៉ាវអ្នករស់រានមានជីវិតទាំងនេះទេ ហើយការរក្សាទុកនូវរឿងរ៉ាវបែបនេះនឹងជួយឱ្យពួកគេជឿ ហើយបន្ទាប់មកយល់ពីអ្វីដែលបានកើតឡើង។ ការដាក់បន្ថែមរឿងរ៉ាវទាំងនេះជាមួយរូបថតនឹងមានប្រយោជន៍ ហើយអាចមិនឱ្យមានការបំភ្លេចរឿងរ៉ាវទាំងនេះបាន។

អ្នកចូលរួមផ្សេងទៀតបានបន្ថែមលើការពិភាក្សានេះ ហើយបានចែករំលែកថា សកម្មភាពក្នុងអំឡុងពេលអាណត្តិដែលនៅសេសសល់អាចផ្ដោតលើសេវាថែទាំសុខភាពកម្រិតខ្ពស់សម្រាប់ជនរងគ្រោះ ហើយវាអាចភ្ជាប់ជាមួយគំនិតផ្ដួចផ្ដើមផ្សេងទៀតដូចជាវិធានការជំនួយសង្គម (ឧទាហរណ៍ ការផ្ទេរសាច់ប្រាក់)។ ក្រុមក៏បានកំណត់អំពីតម្រូវការក្នុងការចងក្រងឯកសារ និងចែករំលែករឿងរ៉ាវជនរងគ្រោះ ស្រដៀងនឹងអ្វីដែលដើមបណ្ដឹងរដ្ឋប្បវេណីបានចែករំលែក និងដើម្បីអភិវឌ្ឍកម្មវិធីសិក្សាបន្ថែមទៀត ដោយរួមបញ្ចូលទិដ្ឋភាពដ៏រស់រវើកបន្ថែមទៀត ដូចជា រូបភាព (ប្រសិនបើពួកគេមិន [ប៉ះទង្គិចផ្លូវចិត្ត] ឡើងវិញនោះទេ)។ ស្រដៀងទៅនឹងអ្វីដែលដើមបណ្ដឹងរដ្ឋប្បវេណីបានចែករំលែកដែរ ពួកគេបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការជួយជនរងគ្រោះ-អ្នករស់រានមានជីវិត តាមរយៈការថែទាំសុខភាពទូទៅ និងការព្យាបាលផ្លូវចិត្ត ជាពិសេស នៅតំបន់ដាច់ស្រយាល និងតម្រូវការក្នុងការជួយជនរងគ្រោះព្យាបាលនូវការចងចាំមិនល្អ ដើម្បីឱ្យពួកគេជាសះស្បើយផ្លូវចិត្ត។

ក្នុងការកំណត់គោលការណ៍ និងតម្លៃរួមគ្នាសម្រាប់កម្មវិធីនាពេលអនាគត អ្នកចូលរួមបានកំណត់ការងារដូចខាងក្រោម។ ជាគោលការណ៍ យើងត្រូវគាំទ្រដល់ដំណើរការនៃការបញ្ចប់ការងាររបស់ អ.វ.ត.ក ឬ ការបង្រួមសកម្មភាពសម្រាប់ជនរងគ្រោះ ដោយសារថាការរំពឹងទុកទាំងអស់នឹងមិនបានសម្រេចនោះទេ។ យើងត្រូវការពិចារណាលើមនុស្សជំនាន់ក្រោយ ហើយមុខងារដែលនៅសេសសល់ត្រូវការយកចិត្តទុកដាក់ខ្លាំងទៅលើនិរន្តរភាព។ ជំនួយសុខភាពផ្លូវចិត្តក៏ត្រូវបានកំណត់ថាជាតម្លៃរួមដ៏សំខាន់មួយ ហើយតម្រូវការ

នេះត្រូវមាន ទោះក្រោយ អ.វ.ត.ក បញ្ចប់។ ដើម្បីសម្រេចបានចំណុចនេះ ក្រុមការងារបានកំណត់លទ្ធភាពជំរុញវិស័យសុខភាពសាធារណៈ តម្រូវការការងារផ្សព្វផ្សាយ និងការអប់រំឱ្យបានទូលំទូលាយអំពីសុខភាពផ្លូវចិត្ត និងការរៀបចំឱ្យមានភាពងាយស្រួលចូលមើលនៃសម្ភារៈទាំងនោះសម្រាប់ធ្វើលំហាត់ថែទាំខ្លួនឯង។

លើសពីនេះ ក្រុមក៏បានលើកឡើងនូវចំណុចសំខាន់មួយនៅក្នុងដំណើរការនេះ គឺការទំនាក់ទំនង។ ពួកគេបានគូសបញ្ជាក់ថា ការស្តាប់ជនរងគ្រោះនៅតែមានសារៈសំខាន់ ហើយវិធី និងរបៀបនៃការទំនាក់ទំនងជាមួយអ្នករស់រានមានជីវិតមានលក្ខណៈ និងមានឥទ្ធិពលខ្លាំង ឧទាហរណ៍ របៀបនិយាយជាមួយពួកគេ ប្រាប់ពួកគេ ស្តាប់ពួកគេ ឆ្លើយតបទៅនឹងសំណើ និងតម្រូវការរបស់ពួកគេ និងសូម្បីតែនៅក្នុងរបៀបដែលយើងនិយាយអំពីពួកគេ។ ការប្រាស្រ័យទាក់ទងក៏មានសារៈសំខាន់ផងដែរក្នុងការទាក់ទងអង្គការពាក់ព័ន្ធ ហើយនៅក្នុងក្រុមនេះ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលមិនបានឆ្លើយតបទៅនឹងការអំពាវនាវពីមុននៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍បានចែករំលែកថា ពួកគេមានអារម្មណ៍ថាត្រូវបានផាត់ចោល ឬថាប្រធានបទក្រុមដែលពួកគេត្រូវបានគេចាត់តាំងនៅក្នុងសិក្ខាសាលា ហាក់មិនសមស្របនឹងសមត្ថភាព និងចំណាប់អារម្មណ៍ក្នុងការគាំទ្រដំណើរការនោះទេ។

ចំពោះកម្មវិធីនាពេលអនាគតទំនងមានលក្ខណៈយ៉ាងម៉េចនោះ ក្រុមបានបំផុសគំនិតជាច្រើន។ គំនិតដំបូងគឺលើការលើកកម្ពស់ជីវភាពរស់នៅ ដែលជាជាដំណើរផ្លូវសម្រាប់ការថែទាំសុខភាពផ្លូវចិត្ត។ ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ន សុជា បានសម្តែងថា ជីវភាពរបស់គាត់នឹងប្រសើរឡើង (តាមការស្រមើលស្រមៃ) ប្រសិនបើឪពុក

ម្តាយរបស់គាត់នៅរស់រានមានជីវិត ដូច្នេះជីវភាពដែលប្រសើរឡើងនឹងផ្តល់យុត្តិធម៌ដល់គាត់សម្រាប់ការខាតបង់របស់គាត់ ហើយយ៉ាងហោចណាស់ក៏ផ្តល់ក្តីសុខដល់គាត់បន្តិចដែរ។ កម្មវិធីលើកកម្ពស់ជីវភាពបែបនេះអាចអមជាមួយជំនួយសង្គមដើម្បីធ្វើឱ្យវាពាក់ព័ន្ធគ្នា ទោះបីជាយ៉ាងណាក៏ដោយ អ្នកចូលរួមបាននិយាយថា វាគួររួមបញ្ចូលក្រុមមានជីវភាពមធ្យមផងដែរ។ ជម្រើសមួយផ្សេងគឺបង្កើតកម្មវិធីនេះសម្រាប់ជនរងគ្រោះ ប្រសិនបើពួកគេទទួលបានឋានៈពិសេស ឬការកំណត់អត្តសញ្ញាណដូចនេះ ស្របជាមួយកម្មវិធី "បណ្ណសមធ៌"។

ចំពោះបញ្ហានៃការព្យាបាលរបួសផ្លូវចិត្ត ក្រុមការងារបានបំផុសគំនិតថា ការផ្តោតលើការព្យាបាលផ្លូវចិត្តជារឿងសំខាន់ ដើម្បីឆ្លើយតបនឹងទុក្ខលំបាករបស់ប្រជាជនកម្ពុជា ហើយការព្យាបាលជាពិសេសចំពោះបញ្ហារ៉ាំរ៉ៃ ដូចជា ការភ័យស្លន់ស្លោ ដែលមិនអាចព្យាបាលបានដាច់សម្រាប់មនុស្សជាច្រើន ទាមទារជំនួយពីថ្នាំសង្កត់ម្តងម្កាល ដើម្បីបានធូរស្រាល។ នេះពាក់ព័ន្ធនឹងការភ័យស្លន់ស្លោ ប៉ុន្តែក៏កត់សម្គាល់ផងដែរថា តម្រូវការព្យាបាលផ្នែកវិកលចរិកផ្សេងទៀតនឹងត្រូវការនាពេលខាងមុខផងដែរ។

ចំពោះនិរន្តរភាពបន្តពី អ.វ.ត.ក ក្រុមនេះបានស្នើឱ្យមានកម្មវិធីមេធាវីចុះផ្សព្វផ្សាយថ្មីមួយ ជាមួយដើមបណ្តឹងរដ្ឋប្បវេណីថ្មី។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបបានចែករំលែកថា នៅតំបន់របស់គាត់ក្នុងខេត្តពោធិសាត់ មានដើម

បណ្តឹងរដ្ឋប្បវេណីចំនួន ១១៤ នាក់ ហើយពួកគេពិតជាទទួលបានអត្ថប្រយោជន៍ពីកម្មវិធីកសាងសន្តិភាព ដើម្បីឈានទៅដល់បង្កើតសង្គមសន្តិភាព និងការព្យាបាលរបួសផ្លូវចិត្តតាមរយៈការទទួលស្គាល់ជនរងគ្រោះកាន់តែច្រើន។ ជាឧទាហរណ៍ លោកស្រីបានចែករំលែកថា ដំណើរទស្សនកិច្ចរបស់មេធាវីដែលទទួលស្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមចំណែកយ៉ាងច្រើនក្នុងការព្យាបាលរបួសផ្លូវចិត្តគឺជារឿងសំខាន់ ហើយនៅក្នុងកិច្ចប្រជុំបែបនេះ ការផ្តល់ប្រាក់ឧបត្ថម្ភ និងអាហារពេលប្រជុំមានសារៈសំខាន់។ ការបន្តដំណើរទស្សនកិច្ចបែបនេះមានសារៈសំខាន់ខ្លាំងណាស់ (រួមទាំងការសួរសុខទុក្ខពីអ្នកដទៃក្រៅពីមេធាវី) ព្រោះវាបង្កើតអារម្មណ៍ថាគេមិនបានបំភ្លេចដើមបណ្តឹងរដ្ឋប្បវេណី។ ក្រុមក៏បានស្នើឱ្យពិចារណាអារម្មណ៍របស់អ្នករស់រានមានជីវិត ដែលមិនបានទទួលឱកាសបើកចំហនៅមុខតុលាការ ហើយបានកត់សម្គាល់ថា មានតែ ៣៨០ នាក់ បានថ្លែងនៅតុលាការខណៈមានច្រើនពាន់នាក់ទៀតនៅតែមិនទាន់បានថ្លែងក្នុងវេទិកាផ្លូវការបែបនេះ។

ក្នុងការធានានិរន្តរភាពកម្មវិធីណាមួយក្នុងចំណោមកម្មវិធីទាំងនេះ ក្រុមបានចែករំលែកថា ចំណុចនេះទាមទារឱ្យមានការចូលរួមប្រកបដោយនិរន្តរភាពពីតួអង្គពាក់ព័ន្ធផ្សេងទៀត។ ក្រុមនេះបានកំណត់យក ក្រសួង

សុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ ក្រុមប្រឹក្សាជាតិគាំពារសង្គម និងអង្គភាពផ្សេងៗទៀត ជាឧទាហរណ៍ពាក់ព័ន្ធ។

ក្រុមក៏បានឆ្លុះបញ្ចាំងផងដែរអំពីឧត្តមានុវត្តន៍សម្រាប់សុខភាពផ្លូវចិត្ត ដែលពាក់ព័ន្ធសម្រាប់ការពិភាក្សា

ក្រុម។ នៅពេលឆ្លុះបញ្ចាំងគំរូនៃការងារស្របគ្នារបស់ TPO សម្រាប់អ្នកអនុវត្តសុខភាពផ្លូវចិត្តដែលធ្វើការរួមគ្នាជាមួយ TPO ក្រុមនេះបានផ្តល់យោបល់ថា នេះអាចធ្វើជាគំរូដើម្បីចូលរួមបន្ថែមជាមួយមន្ទីរពេទ្យរដ្ឋ និងក្នុងការ

បណ្តុះបណ្តាលបុគ្គលិកគ្លីនិក វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា។ ពួកគេក៏បានឆ្លុះបញ្ចាំងផងដែរអំពីការប្រើប្រាស់វិធីសាស្ត្ររបស់ TPO ដូចជាការព្យាបាលរបួសតាមរយៈសក្ខីកម្ម។

ក្រុមបានចាប់ផ្តើមអភិវឌ្ឍគម្រោងរបស់ពួកគេលើសុខភាពផ្លូវចិត្ត ដោយពិចារណាលើការអភិវឌ្ឍប្រកបដោយចីរភាពនៃគម្រោងបែបនេះសម្រាប់ជនរងគ្រោះក្នុងរបបខ្មែរក្រហម។ ពួកគេបានផ្តោតលើប្រវត្តិសាស្ត្រ ការចងចាំ ការផ្តល់សេវា (TPO បច្ចុប្បន្ន ធ្វើការតែម្នាក់ឯង ប៉ុន្តែមិនអាចគ្រប់គ្រាន់ទេ) និងរបៀបនៃកិច្ចសហការចាំបាច់ ជាពិសេសជាមួយក្រសួងសុខាភិបាល។ គម្រោងលើប្រធានបទនេះក៏ត្រូវផ្តោតលើការសន្ទនាអន្តរជំនាន់ និងថាតើវាគាំទ្រដល់សុខភាពផ្លូវចិត្ត និងតម្រូវការសម្រាប់ការអប់រំ និងការផ្សព្វផ្សាយតាមវិធីណា ដើម្បីឱ្យជនរងគ្រោះ និងអ្នករស់រានមានជីវិតដឹងពីវិធីជួយខ្លួនឯង និងទទួលបានការអប់រំអំពីការថែទាំខ្លួនឯងទាំងផ្លូវកាយ និងផ្លូវចិត្ត។ ពួកគេបានកំណត់តម្រូវការក្នុងការរួមបញ្ចូលគ្នា ដោយមានការជួយជ្រោមជ្រែងពីរដ្ឋាភិបាលកម្ពុជា ហើយមានស្ថាប័នអភិវឌ្ឍន៍នានាចូលរួមកាន់តែច្រើន ដើម្បីជាការពង្រឹកតួនាទីរបស់រដ្ឋាភិបាលក្នុងការបង្កើនការគាំទ្រដល់ជនរងគ្រោះ។

ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរបានចែករំលែកថា ការចុះទៅដល់ខេត្តទាំង ២៤ ក្នុងប្រទេសកម្ពុជាមានសារៈសំខាន់ខ្លាំងណាស់ ក៏ដូចជាការធ្វើសមាហរណកម្មសកម្មភាពនៅក្នុងផែនការអភិវឌ្ឍន៍សហគមន៍ ដើម្បីបញ្ចូលការចូលរួមរបស់រដ្ឋាភិបាល។ ពួកគេចង់បានគោលដៅរួមមួយសម្រាប់រយៈពេលបីឆ្នាំខាងមុខ ដែលជាផ្នែកមួយនៃអាណត្តិដែលនៅសេសសល់ ជាពិសេស ការពិគ្រោះយោបល់ផ្នែកជំនួយសុខភាព និងការស្តារឡើងវិញនូវរាងកាយ ជាពិសេសសម្រាប់ជនរងគ្រោះដែលមានវ័យចំណាស់។ ពួកគេបានសង្កត់ធ្ងន់លើតម្រូវការជានាភាពជាម្ចាស់នៅក្នុងដំណើរការនេះ ដោយដាក់ចេញឱ្យច្បាស់ថាដើមបណ្តឹងរដ្ឋប្បវេណីអាចបង្ហាញអំពីតម្រូវការរបស់ពួកគេ និងមាន

ឥទ្ធិពលខ្លះទាក់ទងនឹងថវិកានៅពេលណាបាន និងតាមរបៀបណា (ឧ. តាមរយៈ VSS ឬតាមរយៈគណៈកម្មាធិការវិនិយោគ) ដើម្បីវិភាជថវិកាតាមទំហំសហគមន៍ និងបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍សហគមន៍។ ការអនុវត្តដោយជោគជ័យក៏អាចរួមបញ្ចូលសកម្មភាពសហគមន៍មូលដ្ឋានដូចជាការ កសាងស្តូប ឬ ធ្វើពិធីសាសនានៅស្តូបទាំងនេះ។

បន្ទាប់មកក្រុមនេះបានពិភាក្សាអំពីចំណុចសំខាន់ៗនៅក្នុងសំណើរបស់ពួកគេលើប្រធានបទនេះ ហើយបានឯកភាពថា ក្រុមគោលដៅនឹងរួមបញ្ចូលជនរងគ្រោះ និងអ្នករស់រានមានជីវិត ដែលមានន័យថាសម្រាប់ពួកគេគឺសំដៅលើប្រជាជនកម្ពុជាទាំងអស់ដែលបានជួបប្រទះ និងឆ្លងកាត់របបខ្មែរក្រហម។ ក្រុមគោលដៅក៏នឹងរួមបញ្ចូលសមាជិកគ្រួសាររបស់ពួកគេផងដែរ។ ពួកគេបានកំណត់ពីតម្រូវការក្នុងការបង្កើតកិច្ចព្រមព្រៀងផ្លូវការមួយ ដែលគូសបញ្ជាក់ការចូលរួមរបស់រដ្ឋាភិបាល និងឱ្យ អ.វ.ត.ក សហការជាមួយស្ថាប័នរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ ជាពិសេស ការចូលរួមជាមួយរដ្ឋាភិបាលតាមរយៈក្រសួងសុខាភិបាលត្រូវបានកំណត់ថាមានសារៈសំខាន់ក្នុងកិច្ចពិភាក្សានេះ រួមជាមួយនឹងគណៈកម្មាធិការជាតិគាំពារសង្គម។ យើងក៏ត្រូវមានការចូលរួមគាំទ្រពីអង្គការមិនមែន

រដ្ឋាភិបាលនានា ជាពិសេសអ្នកបានបំពេញការងារគាំទ្រដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះរួចហើយ។ មុននឹងដាក់ឱ្យដំណើរការគម្រោងបែបនេះ ចាំបាច់ត្រូវមានការស្រាវជ្រាវសាកល្បងមួយចំនួន ហើយផែនការតស៊ូមតិណាមួយអាចរួមបញ្ចូលការកាត់បន្ថយភាពក្រីក្រផងដែរ។

ពួកគេបានបំបែកគោលដៅរបស់ពួកគេជាបួនប្រធានបទ ដោយរួមបញ្ចូលការផ្តល់យោបល់របស់សមាជិកក្រុមទាំងអស់៖

- ការពង្រឹកតួនាទីរបស់រដ្ឋាភិបាលក្នុងការស្តារនីតិសម្បទា គាំទ្រ និងលើកកម្ពស់ការអភិវឌ្ឍមនុស្សចាស់ដល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

- ការលើកកម្ពស់ និងបញ្ជ្រៀបការថែទាំសុខភាពផ្លូវចិត្ត ចិត្តសាស្ត្រ និងរាងកាយនៅក្នុងរចនាសម្ព័ន្ធ

គាំទ្រសង្គមផ្អែកលើតម្រូវការសម្រាប់អនាគតជនរងគ្រោះ និងអ្នករស់រានមានជីវិតក្នុងរបបខ្មែរក្រហមនៅក្នុងខេត្តទាំង ២៤ នៃប្រទេសកម្ពុជា។

- ការអនុវត្តកម្មវិធីរដ្ឋប្រកបដោយចីរភាព ដើម្បីលើកកម្ពស់សុខភាពផ្លូវចិត្ត និងការព្យាបាលរបួសតាមរយៈការអភិវឌ្ឍការ

កសាងសន្តិភាព ជំនួយសង្គម និងជំនួយផ្លូវចិត្តសម្រាប់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងមនុស្សជំនាន់ក្រោយ។

- ការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ជនរងគ្រោះ និងអ្នករស់រានមានជីវិតក្នុងរបបខ្មែរក្រហម តាមរយៈការទទួលស្គាល់ ការចងចាំ ការផ្សះផ្សា និងការស្តារនីតិសម្បទា។

ក្រុមក៏បានគូរឡើងនូវតារាងដ៏មានប្រយោជន៍ដូចបង្ហាញខាងក្រោម ដែលផ្តល់នូវទិដ្ឋភាពទូទៅ (ដោយបានពន្យល់រចនាសម្ព័ន្ធមួយចំនួន) នៃគំនិតគម្រោងស្នូលដែលបានបង្កើតឡើង។ តារាងខាងក្រោមនេះក៏បង្ហាញអំពី

សក្តានុពលអានុភាពនៃគម្រោង ឬតម្រូវការបន្ថែមដែលមានសក្តានុពលផងដែរ ដែលមានសញ្ញាសួរសម្គាល់៖

អង្គការសង្គមស៊ីវិល អ.វ.ត.ក និង VSS មានសារៈសំខាន់ក្នុងការផ្តល់ការគាំទ្រដល់ជនរងគ្រោះ លើបញ្ហាសុខភាពផ្លូវចិត្ត និងផ្លូវកាយ ក៏ដូចជាភាពក្រីក្រ ហើយបញ្ហានេះគួរតែត្រូវបានដោះស្រាយតាមរយៈការសន្ទនាដើម្បីពិភាក្សាអំពីភាពចាំបាច់ និងតម្រូវការរបស់ជនរងគ្រោះ ការតស៊ូមតិសម្រាប់មនុស្សចាស់ និងការសន្ទនាជាមួយអ្នកពាក់ព័ន្ធទាំងអស់ ការចូលរួម និងការលើកឡើងពីការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ (ជាពិសេសក្រសួងសុខាភិបាល) ក្រុមជួយខ្លួនឯងសម្រាប់មនុស្សចាស់ និងការផ្តោតលើនិរន្តរភាព។

ក្រុមក៏បានកំណត់ចំណុចខ្វះខាត ដែលត្រូវការការដោះស្រាយផងដែរ ក្នុងនោះរួមបញ្ចូលតម្រូវការស្វែងយល់អំពីរចនាសម្ព័ន្ធសុខភាពដែលមានស្រាប់ កំណត់អំពីរបៀបចូលរួមជាមួយសាធារណជន របៀបបញ្ចូលកម្មវិធីជីវភាពក្នុងរចនាសម្ព័ន្ធកម្មវិធីសុខភាពទ្រង់ទ្រាយធំ របៀបកំណត់ការជួយខ្លួនឯងយ៉ាងទូលំទូលាយដែលនឹងផ្តល់អត្ថប្រយោជន៍ជាច្រើន របៀបឱ្យបានទៅអ្នកទទួលផលនៅថ្នាក់មូលដ្ឋាន និងរបៀបធានាការចូលប្រើកម្មវិធីបែបនេះ និងផ្តល់យុទ្ធនាការព័ត៌មានលើការងារនេះផងដែរ។

នៅក្នុងវគ្គចុងក្រោយនៃការងារជាក្រុម ក្រុមនេះក៏បានពិចារណាលើគំនិតចុងក្រោយមួយចំនួន ដូចជាការធានាសមភាព

ក្នុងចំណោមសហគមន៍លើការងារដោះស្រាយបញ្ហាសុខភាពផ្លូវចិត្ត និងតម្រូវការសម្រាប់ចំណុចស្នូលដើម្បីជួយផ្សព្វផ្សាយព័ត៌មាន។ ការងារនេះអាចតាមរយៈសមាគមមនុស្សចាស់ ហើយធ្វើការរួមគ្នាជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីសុំការគាំទ្រពីរដ្ឋបាលមូលដ្ឋាន។ ដើមបណ្ដឹងរដ្ឋប្បវេណីបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការរួមបញ្ចូលរដ្ឋាភិបាលក្នុងដំណើរការនេះ ប៉ុន្តែដើម្បីរក្សាតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធានាការចូលរួមនៅថ្នាក់មូលដ្ឋាន និងផ្ដល់សិទ្ធិអំណាចដល់ពួកគេតាមរយៈការចូលរួមនេះ។

ដើម្បីធានាការសម្រេចបានសេវាបែបនេះសម្រាប់ទាំងអស់គ្នា ក្រុមក៏បានកំណត់ពីតម្រូវការឱ្យមានប្រភេទវេទិកា ឬយន្តការមួយចំនួនដើម្បីបញ្ចូលផែនការទាំងនេះទៅក្នុងផែនការសហគមន៍។ វេទិកាបែបនេះក៏អាចទៅតាមទម្រង់ និងទីកន្លែងត្រូវនឹងជនរងគ្រោះ និងអ្នករស់រានមានជីវិត អាចចូលប្រើសេវាទាំងនេះបាន។ ពួកគេបានកំណត់ថា វាអាចមានប្រយោជន៍ក្នុងការបង្កើតបញ្ជីឈ្មោះជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលសហការជាមួយសេវាសុខភាព ធានាបាននូវការទទួលសេវា ហើយអាចចែករំលែកជាមួយអភិបាលខេត្ត ដើម្បីរួមផ្សំជាមួយប្រាក់ឧបត្ថម្ភសម្រាប់អ្នកដែលមានអាយុលើសពី ៦០ឆ្នាំ។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបក្នុងក្រុមនេះបានសង្កត់ធ្ងន់ថា វត្តមានដើមបណ្ដឹងរដ្ឋប្បវេណី នឹងជួយឱ្យអ្នកផ្សេង ចូលរួម និងបានផ្ដល់ព័ត៌មានដល់អ្នកដទៃ។ មានការទទួលស្គាល់អំពី

ហានិភ័យថា ពេលខ្លះនៅពេលប្រជុំជាក្រុម ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានចោទប្រកាន់ថាបានចូលរួមការងារនយោបាយ ប៉ុន្តែជារឿយៗនៅថ្នាក់ស្រុក ពួកគេទទួលបានការជឿទុកចិត្ត និងអាជ្ញាធរស្គាល់ ដូច្នេះហានិភ័យនេះមានតិចតួច។

# ០៣

## ក្រុមទី៣ ផ្តោតលើបណ្ណសារ និងឯកសារជនរងគ្រោះ និងការការពារសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។



លោកស្រី សូ ហ្វារីណា មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ធ្វើបទបង្ហាញទៅកាន់សិក្ខាកាម នៅថ្ងៃទី២ នៃសិក្ខាសាលា ។

អ្នកចូលរួមនៅក្នុងក្រុមនេះបានចង្អុលបង្ហាញពីដើមដំបូងថា ពួកគេចង់ឃើញមានបណ្ណសារជាច្រើនកន្លែង មិនមែនមានតែមួយកន្លែង សំដៅសម្រេចគោលបំណងរួមមួយក្នុងការផ្តល់ព័ត៌មាន និងទិន្នន័យអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ពួកគេបានស្នើឱ្យមានប្រព័ន្ធមួយដែលបណ្ណសារ អ.វ.ត.ក អាចភ្ជាប់ទៅនឹងបណ្ណសារផ្សេងទៀត ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងសម្របសម្រួលរវាងអង្គភាពបណ្ណសារផ្សេងៗគ្នា។

ក្រុមទី៣ មិនបានផ្តោតលើការបង្កើតបណ្ណសារបន្ថែម ឬអង្គភាពរក្សាទុកឯកសារបន្ថែមនោះទេ ប៉ុន្តែចង់ឱ្យមានការសម្របសម្រួលរវាងអង្គការមិនមែនរដ្ឋាភិបាលដែលមានស្រាប់ និងអ្នកកាន់កាប់ប័ណ្ណសារ។ អ្នកចូលរួមបានស្នើឱ្យបង្កើតស្ថាប័នអចិន្ត្រៃយ៍ ឬ វេទិកាពិភាក្សាអំពីខ្លឹមសារបណ្ណសារ ការរៀបចំ និងការចូលប្រើប្រាស់ ការចងក្រងឯកសារ និងបញ្ហាផ្សេងទៀតពាក់ព័ន្ធនឹងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើបញ្ហាខ្មែរក្រហម។ ការងារនេះក៏នឹងរួមបញ្ចូលអាជ្ញាធរពាក់ព័ន្ធដែលបានផ្តល់អាណត្តិរយៈពេលបីឆ្នាំសម្រាប់មុខងារដែលនៅសេសសល់របស់ អ.វ.ត.ក។

ពួកគេមានអារម្មណ៍ថា មធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការធានាបាននូវការចូលប្រើប្រាស់ព័ត៌មានពាក់ព័ន្ធទាំងអស់នៅទូទាំងបណ្ណសារដែលមានស្រាប់ផ្សេងៗគ្នា គឺបង្កើតការតភ្ជាប់ និងបណ្តាញនៃបណ្ណសារផ្តោតលើរបបខ្មែរក្រហម។ ការផ្តោតសំខាន់គឺពឹងផ្អែកលើបណ្តាញអ៊ីនធឺណិត និងមជ្ឈមណ្ឌលសិក្សាដែលមានស្រាប់នៅទូទាំងប្រទេស ជាទីតាំងសម្រាប់ការចូលមើលបណ្ណសារ និងបង្កើតទីតាំងនៅតាមខេត្តដើម្បីអាចចូលប្រើបណ្ណសារផងដែរ។ ចំពោះវិសាលភាពបណ្ណសារវិញ ក៏អាចបញ្ចូលការប្រើប្រាស់កន្លែងរំលឹកការចងចាំជាកន្លែងប្រមូលផ្តុំ ដោយបើកឱ្យចូលប្រើតំណភ្ជាប់បណ្ណសារ និងធ្វើឱ្យទៅជាកន្លែងជួបជុំ ដើម្បីរួមបញ្ចូលឯកសារអប់រំផងដែរ។ ការធ្វើដូច្នេះក៏នឹងផ្តល់នូវទីតាំងកណ្តាលមួយសម្រាប់ការផ្តល់សេវា និងព័ត៌មានអំពីប្រភពនៃសេវាកម្ម និងវិធីដើម្បីចូលប្រើប្រាស់បណ្ណសារ។

ចំពោះការងារសម្របសម្រួល និងប្រតិបត្តិការ ក្រុមទី៣ បានពិភាក្សាអំពីការសម្របសម្រួលរវាង អ.វ.ត.ក អង្គការមិនមែនរដ្ឋាភិបាល និងរាជរដ្ឋាភិបាល ដើម្បីចែករំលែកតំណភ្ជាប់ដែលពាក់ព័ន្ធទៅនឹងបណ្ណសារ។ អង្គការមិនមែនរដ្ឋាភិបាល អ.វ.ត.ក និងអង្គការពាក់ព័ន្ធផ្សេងទៀតក៏អាចផ្តល់ច្បាប់ចម្លងនៃបណ្ណសារដល់រដ្ឋាភិបាលក្នុងរយៈពេលយូរ ខណៈនៅបន្តរក្សាបណ្ណសារច្បាប់ដើមនៅក្នុងស្ថាប័នរៀងៗខ្លួន។ ប្រសិនបើអ្នកពាក់ព័ន្ធមិនសូវ

ខ្វល់ខ្វាយអំពីបញ្ហាកម្មសិទ្ធិ ក្រុមក៏បានពិចារណាអំពីលទ្ធភាពនៃការបង្កើតបណ្ណសារ "ពិសេស" ស្តីពីរបបខ្មែរក្រហម ជាមួយនឹង

ទីតាំងនៅតាមខេត្តដូចបានរៀបរាប់ខាងលើ តាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីឱ្យបុគ្គលដែលគ្មានជម្រើសផ្សេងចូលប្រើប្រាស់បាន នៅតែមានលទ្ធភាពចូលពីចម្ងាយ។

ក្តីបារម្ភដែលកើតឡើងក្នុងអំឡុងពេលពិភាក្សាជាក្រុមគឺតម្រូវការក្នុងការបញ្ជាក់ពីបញ្ហាឯកជនភាព និងការយល់ព្រមពីជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្ណសាររបស់ អ.វ.ត.ក។ ក្រុមនេះបានយល់ស្របថា គោលដៅគឺចង់ឱ្យមានការចូលប្រើបានទូលំទូលាយរហូតដល់ចំនួនឯកសារតុលាការជាអតិបរមា ដរាបណាវាស្របជាមួយនឹងភាពឯកជន និងផលប្រយោជន៍ផ្សេងទៀតដូចជាសិទ្ធិអ្នកប្រើប្រាស់។ ដូច្នេះ នេះមានន័យថា ការចាត់ថ្នាក់ឡើងវិញមានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវគោលដៅនេះ ហើយគួរតែត្រូវបានចាត់ទុកថាជាការងារអាទិភាពខ្ពស់សម្រាប់ចៅក្រម បន្ទាប់ពីចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០២។ ការចាត់ថ្នាក់ឡើងវិញបែបនេះគួរតែផ្អែកលើការវិភាគជាប្រព័ន្ធ និងស៊ីសង្វាក់គ្នាចំពោះឯកសារដែលបច្ចុប្បន្នត្រូវបានចាត់ថ្នាក់ជាការសម្ងាត់ ដើម្បីថ្លឹងថ្លែងការចូលប្រើប្រាស់ជាអតិបរមាដោយសាធារណជន ជាមួយចំនួនឯកសារច្រើនបំផុតដែលអាចធ្វើទៅបាន តែនៅតែរក្សាបានភាពឯកជន និងផលប្រយោជន៍ស្របច្បាប់ផ្សេងទៀត។ ការងារនេះគួរធ្វើឡើងដោយមន្ត្រីច្បាប់ និងអ្នកបច្ចេកទេស ក្រោមការត្រួតពិនិត្យផ្ទាល់របស់ចៅក្រម។

ពួកគេបានលើកហេតុផលបន្ថែមទៀតថា សំណុំរឿងដែលមិនបានបញ្ជូនទៅជំនុំជម្រះ ហើយត្រូវបាន "បោះត្រាបិទស្លាក" គួរចៅក្រម "ហែកបើក" ដើម្បីអនុញ្ញាតឱ្យមានការវិភាគ និងចាត់ថ្នាក់ឡើងវិញជាសាធារណៈនូវ

ឯកសារទាំងនោះឱ្យបានច្រើនបំផុត នៅក្នុងសំណុំរឿងទាំងនោះតាមដែលអាចធ្វើទៅបាន ហើយសំណើពីភាគី រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី គួរតែជាផ្នែកនៃដំណើរការនេះផងដែរ។

គោលការណ៍ណែនាំទាំងមូលគួរតែជាគោលការណ៍ "កុំបង្កការឈឺចាប់ ដើម្បីធានាថា ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះត្រូវបានផ្តល់ភាពអង់អាចនៅក្នុងដំណើរការនេះ។ ពួកគេបានពិចារណាពីលទ្ធភាពដែលដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះអាចចង់ឱ្យផ្នែកខ្លះនៃសក្ខីកម្ម សេចក្តីថ្លែងការណ៍ និងពាក្យសុំតាំងខ្លួនរបស់ពួកគេ ដែលត្រូវបានរក្សាទុកជាសម្ងាត់រហូតមកដល់ពេលនេះ (ឧទាហរណ៍ រឿងរ៉ាវនៃអំពើហិង្សាផ្លូវភេទ ឬការចោទប្រកាន់លើសមាជិកសហគមន៍) នៅតែរក្សាការសម្ងាត់។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការស្នើសុំការយល់ព្រមពីពួកគេ ឬប្រសិនបើមិនអាចធ្វើបាន ត្រូវកោសលុបជាប្រព័ន្ធ នូវព័ត៌មានអត្តសញ្ញាណ មុនពេលដាក់ឯកសារទាំងនោះជាសាធារណៈ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី CPLCLs, VSS, និង WESU អាចជាតួអង្គសមបំផុតក្នុងការធ្វើទំនាក់ទំនងជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។

ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងនេះ ក្រុមការងារបានពិចារណាលើដំណោះស្រាយរយៈពេលខ្លី និងរយៈពេលវែង។ ស្របតាមមុខងារដែលនៅសេសសល់ ពួកគេបានពិចារណាថា អ.វ.ត.ក គួរចូលរួម អាចថាក្នុងតួនាទីជាស្ថាប័នតស៊ូមតិសុំឱ្យផ្តល់ហិរញ្ញប្បទានដល់គម្រោងផ្សេងទៀតក្រៅពីមុខងារដែលនៅសេសសល់។ ពួកគេបានផ្តល់អនុសាសន៍ឱ្យដាក់បញ្ចូលសកម្មភាពទាក់ទងនឹងបណ្ណសារនៅក្នុងផែនការសកម្មភាពហិរញ្ញវត្ថុជាតិរយៈពេលប្រាំឆ្នាំ ក្រោមការសម្របសម្រួលរបស់ អ.វ.ត.ក។ ពួកគេក៏បានកំណត់អំពីតម្រូវការក្នុងការបង្កើត ឬ ពង្រឹងក្របខ័ណ្ឌច្បាប់ និងកិច្ចព្រមព្រៀងសម្រាប់និរន្តរភាពនៃបណ្ណសារ និងដើម្បីសម្របសម្រួលជាមួយក្រសួងវប្បធម៌ និងក្រសួងអប់រំ លើការងារនេះ។ ក្រុមនេះបានស្នើឱ្យរៀបចំកិច្ចប្រជុំផ្តោតលើបណ្ណសារ ដើម្បីពិនិត្យមើលជម្រើសអំពីរបៀបតភ្ជាប់

បណ្ណសារ ហើយក៏បានស្នើសុំឱ្យបញ្ចូលមូលនិធិថវិកាស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិក្នុងការគាំទ្រជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន មូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិសម្រាប់ជនរងគ្រោះនៃការធ្វើទារុណកម្ម និងមូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។

ក្រុមនេះបានគាំទ្រដល់ការរៀបចំរចនាសម្ព័ន្ធ ការចងក្រង និងនិយតកម្មការចូលទៅប្រើប្រាស់បណ្ណសារខ្មែរក្រហមទាំងអស់ ដើម្បីឱ្យមានលក្ខណៈរួម និងងាយស្រួលប្រើសម្រាប់អ្នកប្រើប្រាស់គ្រប់កម្រិត។ ក្រុមនេះបានពិភាក្សាថា ការងារនេះមានន័យថាឱ្យជនរងគ្រោះចូលរួមរចនាបណ្ណសារ ទាក់ទងនឹងប្រភេទព័ត៌មានបន្ថែមដែលគួរត្រូវប្រមូលយកមករក្សាទុក ដូចជារឿងរ៉ាវផ្ទាល់ខ្លួនជាច្រើនទៀត។ ការងារនេះអាចពាក់ព័ន្ធនឹងការធ្វើការសិក្សាដើមគ្រាជាមួយជនរងគ្រោះ ដើម្បីអាចពិចារណាថាការងារអ្វីខ្លះដែលត្រូវផ្តោតលើជនរងគ្រោះ។

ការងារអាទិភាពខ្ពស់ផងដែរនោះគឺការធានាថា បណ្ណសារមានជាភាសាខ្មែរ។ ការងារក៏មានន័យថា ចាំបាច់ត្រូវមានកម្មវិធី IT ដែលអានឯកសារស្កេនជាភាសាខ្មែរ និងអាចបកប្រែឯកសារទៅជាភាសាខ្មែរ។ ការអាចចូលប្រើប្រាស់បណ្ណសារពីទីតាំងផ្សេងមានន័យថាធ្វើយ៉ាងណាបានបង្ហោះនៅលើអ៊ីនធឺណិតសម្រាប់បុគ្គល និងនៅកន្លែង

ផ្សេងៗសម្រាប់អ្នកដែលមិនមានសិទ្ធិចូលប្រើប្រាស់នៅទីតាំងកណ្តាល និង បណ្ណសារជាឯកសារក្រដាស។ បណ្ណសារជាឯកសារក្រដាស អាចត្រូវបានរក្សាទុកនៅ អ.វ.ត.ក ឬ មជ្ឈមណ្ឌលឯកសារច្បាប់ (LDC) ដែលអាចធានានូវការចូលប្រើប្រាស់បណ្ណសារបានទូលំទូលាយបំផុតសម្រាប់សាធារណជនទាំងអស់។ ប្រសិនបើឱ្យចូលប្រើប្រាស់តាមវិធីនេះ គួរតែមានកម្រិតចូលប្រើប្រាស់បណ្ណសារទាំងនោះ (ឧទាហរណ៍ ទាក់ទងនឹងកុមារ ឬ មនុស្សចាស់)។ បណ្ណសាររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ត្រូវបានប្រើប្រាស់ជាឧទាហរណ៍នៅក្នុងចំណុចនេះ ដើម្បីឱ្យអ្នកប្រើប្រាស់មានភាពងាយស្រួលចូលមើល ឬ ចូលប្រើប្រាស់តាមវិធីទំនើប។

ដើម្បីធានាបាននូវការចូលប្រើប្រាស់បណ្ណសារ ក្រុមនេះបានស្នើឱ្យបន្ថែម និងភ្ជាប់សក្ខីកម្ម និងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងគំនិតផ្តួចផ្តើមរបស់អង្គការមិនមែនរដ្ឋាភិបាលសម្រាប់គម្រោងអន្តរកម្ម។ យើងគួរមានកម្មវិធីដាក់ដំណើរការគម្រោងដើម្បីទាក់ទាញសាធារណជននៅក្នុងផ្នែកផ្សេង ជាពិសេសយុវជន ចូលមកមើលសម្ភារៈនៅក្នុងបណ្ណសារ។ ការចូលប្រើប្រាស់បណ្ណសារក៏អាចរួមបញ្ចូលនៅក្នុងការពិភាក្សារបស់សាលារៀនអំពីសម័យកាល DK ឬ ក្រុមសកម្មភាពយុវជនក៏អាចត្រូវបានបង្កើតឡើងផងដែរ។

ពាក់ព័ន្ធនឹងការរៀបចំខ្លឹមសារ ក្រុមបានកំណត់តម្រូវការដូចខាងក្រោម៖ ធានាថា មាតិកាឌីជីថល និងរូបវន្ត អាចរកបានដើម្បីបង្កើតសន្ទស្សន៍ពេញលេញអំពីសម្ភារៈដែលមានស្រាប់ និងតាមលទ្ធភាពដែលអាចធ្វើបាន រៀបចំ

បណ្ណសារដោយផ្អែកលើលំដាប់លំដោយ បង្កើតគេហទំព័រ ឬ ទំព័រងាយស្រួលស្រែងរកបណ្ណសារ កំណត់របៀបស្វែងរកទូលំទូលាយ ដើម្បីធានាបាននូវការចូលប្រើជាអតិបរមា និងចំណុចចុងក្រោយធានាបច្ចុប្បន្នភាពជាប្រចាំ។

ក្រុមក៏បានពិភាក្សាយ៉ាងខ្លីអំពីវិធានការការពារសាក្សី និងជនរងគ្រោះ ព្រមទាំងបានកំណត់អំពីតម្រូវការក្នុងការបញ្ជាក់វិសាលភាពនៃការវាយតម្លៃ និងលក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើសម្រាប់ការការពារជនរងគ្រោះ និងសាក្សី និងរបៀបវាយតម្លៃការគំរាមកំហែងផ្នែកសន្តិសុខ (ការវាយតម្លៃដោយអត្តនោម័ត និងសត្យានុម័ត) ស្របពេលជាមួយគ្នា មានការព្រួយបារម្ភអំពីភាពឯកជន សុខុមាលភាព និងសេចក្តីថ្លៃថ្នូរ។ ចំណុចនេះក៏អាចភ្ជាប់ទៅនឹងបណ្ណសារផងដែរ។ ក្រុមបានកំណត់អំពីតម្រូវការក្នុងការគាំទ្រ WESU និង VSS នៅក្នុងកម្មវិធីការពារ CPs និងសាក្សី និងដើម្បីគាំទ្រដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និង VSS ក្នុងការងារទាក់ទងជាមួយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ និងជនរងគ្រោះផ្សេងទៀត អំពីការបញ្ចប់ការងាររបស់តុលាការ។

ជាចុងក្រោយ ក្រុមនេះបានលើកឡើងថា ពួកគេជឿថាកម្មវិធីជាច្រើនដែលកំណត់អត្តសញ្ញាណជនរងគ្រោះ មិនអាចគ្រប់គ្រងបាន និងហួសដែនអាណត្តិដែលនៅសេសសល់របស់ អ.វ.ត.ក។ ការងារចាំបាច់គឺជៀសវាង "ការជ្រៀតជែកបេសកកម្ម"។ ពួកគេបានកំណត់ថា តួនាទីរបស់ អ.វ.ត.ក ក្នុងគម្រោងដ៏ច្រើនទាំងនេះ អាចត្រូវធ្វើការតស៊ូមតិសុំផ្តល់មូលនិធិ និងការពង្រីកសកម្មភាពរបស់អង្គភាពផ្សេងទៀត។ ឧទាហរណ៍ អ.វ.ត.ក អាចតស៊ូមតិជាមួយ

រដ្ឋាភិបាលលើការពង្រីកសេវា និងអនុញ្ញាតឱ្យតភ្ជាប់ជាមួយបណ្ណសាររដ្ឋាភិបាលដើម្បីជាផ្នែកមួយនៃគម្រោងតភ្ជាប់បណ្ណសារឱ្យបានទូលំទូលាយ និងរួមទាំងការតភ្ជាប់ជាមួយបណ្ណសាររបស់ខ្លួ ផ្សេងទៀត និងចងក្រងបញ្ជីនៃតម្រូវការរបស់ជនរងគ្រោះ និងអ្នកផ្តល់សេវា តម្រូវការ រួមជាមួយព័ត៌មានទំនាក់ទំនងរបស់អ្នកផ្តល់សេវាទាំងនោះ។ ពាក់ព័ន្ធបណ្ណសារដដែល បណ្ណសាររបស់ អ.វ.ត.ក ចាំបាច់ត្រូវរៀបចំតាមរបៀបងាយស្រួលចូលប្រើប្រាស់ ដើម្បីអនុញ្ញាតឱ្យមានលទ្ធភាពចូលប្រើប្រាស់ទូលំទូលាយបំផុតជូនអ្នកប្រើប្រាស់ ដោយរួមបញ្ចូលនូវចំនួនឯកសារឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន អាស្រ័យលើការចាត់ថ្នាក់ឡើងវិញដោយចៅក្រម ក្រោមការជួយជ្រោមជ្រែងពីមន្ត្រីច្បាប់ និងអ្នកបច្ចេកទេសដែលចៅក្រមគ្រប់គ្រងដោយផ្ទាល់ ហើយត្រូវតែជាផ្នែកនៃគម្រោងតភ្ជាប់បណ្ណសារឱ្យបានទូលំទូលាយ។

# ០៤

## ក្រុមនេះដំបូងបានចែករំលែកការរំពឹងទុករបស់ពួកគេចំពោះប្រធានបទរបស់ពួកគេ។ អ្នកខ្លះចង់បង្កើតការអប់រំប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជាអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងដើម្បីទទួលស្គាល់តម្លៃនៃទីតាំងប្រវត្តិសាស្ត្រខ្មែរក្រហម។



អ.វ.ត.ក រៀបចំវេទិកាសាធារណៈ នៅប៉ៃលិនអតីតតំបន់ឈរជើងរឹងមាំរបស់ខ្មែរក្រហមនៅភាគពាយ័ព្យនៃកម្ពុជា ចម្ងាយប្រហែល៤០០គ.ម.ពីភ្នំពេញ អតីតទាហានខ្មែរក្រហម នគរបាល អ្នកភូមិ មន្ត្រីអាជ្ញាធរមូលដ្ឋាន ប្រហែល៣០០នាក់ ចូលរួមក្នុងវេទិកា។

ពួកគេក៏ចង់ឱ្យមានការពិភាក្សា និងចង់បានការអនុវត្តតាមសំណើរបស់ពួកគេ ដើម្បីលើកទឹកចិត្តយុវជនឱ្យសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម និងការងាររបស់ អ.វ.ត.ក។

នៅក្នុងវគ្គទីមួយ អ្នកចូលរួមរបស់ក្រុមនេះបានពិពណ៌នាអំពី "អ៊ែរ បី" ដែលវាមានន័យសម្រាប់ពួកគេ។ ការទទួលស្គាល់មានន័យសម្រាប់ពួកគេថា អ.វ.ត.ក ទទួលស្គាល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ហើយអង្គហេតុ និងប្រវត្តិសាស្ត្រជុំវិញរឿងរ៉ាវទាំងនេះក៏ត្រូវបានទទួលស្គាល់ផងដែរ។ ចំណុចនេះនឹងនាំមកនូវអ្វីដែលគេហៅថា "ការយល់ដឹងអំពីប្រវត្តិសាស្ត្រ"។ កិច្ចការនេះក៏នឹងអនុញ្ញាតឱ្យមានការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតថាជា "មរតករស់" ដែលជាការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីថាបានចូលរួមនៅក្នុងការចែករំលែករឿងរ៉ាវរបស់ពួកគេក្នុងវគ្គពេញអង្គលើកដំបូង និងដូចបានកត់សម្គាល់ខាងលើ។ ចំពោះការផ្សះផ្សា ក្រុមបានកត់សម្គាល់ថាវាជាវេទិកា ដែលការសន្ទនាអន្តរជំនាន់មានតួនាទីសំខាន់ ដូចជាការសន្ទនារវាងជនរងគ្រោះ និងជនល្មើស។ ការព្យាបាលផ្លូវចិត្ត ក៏មានសារៈសំខាន់ផងដែរក្នុងការផ្សះផ្សា ព្រោះវានឹងផ្តល់ការគាំទ្រផ្នែកសុខភាពផ្លូវចិត្តដល់ជនរងគ្រោះ ដែលនៅតែញាំញីជាមួយនឹងសេចក្តីទុក្ខសោករបស់ខ្លួន។ ចំពោះប្រធានបទនៃការចងចាំ អ្នកចូលរួមជាក្រុមបានកត់សម្គាល់ថា ចំណុចនេះបង្ហាញឱ្យយើងឃើញអំពីការរងទុក្ខឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តដែលអ្នករស់រានមានជីវិតទទួលរង។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការចងក្រងបង្ហាញ និងផ្សព្វផ្សាយសក្ខីកម្មជនរងគ្រោះ សង្កេត និងរំលឹកដល់ទិវានៃការចងចាំ។ ការសាងសង់ស្តូបត្រូវបានគូសបញ្ជាក់ថាជាកន្លែងចងចាំដ៏សំខាន់ ហើយមានសារៈសំខាន់ក្នុងការថែរក្សា និងអភិរក្សទីតាំងឧក្រិដ្ឋកម្មប្រវត្តិសាស្ត្រខ្មែរក្រហម។

ក្រុមនេះបានស្នើថា ក្នុងការចងចាំរបប DK និងប្រវត្តិសាស្ត្រនៃរបបនេះ ទិវាចងចាំ ២០ ឧសភា គួរតែគោរពដាក់បញ្ចូលជាថ្ងៃបុណ្យជាតិ ហើយនៅថ្ងៃនេះ ត្រូវប្រារព្ធពិធីនៅកន្លែងឧក្រិដ្ឋកម្ម និងបូជនីយដ្ឋានផ្សេងទៀត។ ទីតាំងឧក្រិដ្ឋកម្មទាំងនេះក៏អាចផ្តល់កន្លែងសម្រាប់បង្កើតកម្មវិធីផ្សព្វផ្សាយផងដែរ ហើយចាំបាច់ត្រូវមានការវិភាជថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយប្រចាំឆ្នាំ។ កម្មវិធី

ទាំងនេះក៏អាចបញ្ចូលមេរៀននៃកេរដំណែលប្រវត្តិសាស្ត្រខ្មែរក្រហម ហើយគួរបញ្ចូលទៅក្នុងកម្មវិធីអប់រំសិក្សាថ្នាក់ជាតិផងដែរ។ ទីតាំងឧក្រិដ្ឋកម្មក៏ចាំបាច់ត្រូវរក្សាទុកតាមរយៈការដាក់បង្ហាញភស្តុតាងជាក់ស្តែង និងធ្វើបច្ចុប្បន្នភាពទីតាំងឧក្រិដ្ឋកម្មឱ្យបានត្រឹមត្រូវ។ សំណើលើប្រធានបទនេះអាចផ្តោតលើវិស័យអាទិភាពមួយចំនួន និងការរក្សាអដ្ឋិធាតុ និងទីតាំង។ ការធ្វើបែបនេះក៏ត្រូវការសហគមន៍ពាក់ព័ន្ធ និងរដ្ឋាភិបាល ចូលរួមអភិរក្សទីតាំងឧក្រិដ្ឋកម្ម។ យើងចាំបាច់ត្រូវបញ្ជាក់ជាសាធារណៈអំពីសារៈសំខាន់នៃការចងចាំជនរងគ្រោះក្នុងរបបខ្មែរក្រហម និងដើម្បីបង្កើតស្តូបអនុស្សាវរីយ៍នៅគ្រប់ខេត្ត-ក្រុងជុំវិញប្រទេសកម្ពុជា។ ជាពិសេស ត្រូវយកចិត្តទុកដាក់អំពីការរំលឹកការចងចាំសហគមន៍ជនជាតិដើមភាគតិចផងដែរ។ ចំពោះការចងក្រងឯកសារ ក្រុមនេះបានពិភាក្សាអំពីសារៈសំខាន់នៃការបន្តប្រមូលផ្តុំ និងបញ្ចូនឯកសារពាក់ព័ន្ធនឹងរបបនេះទៅ LDC។

ដើម្បីអនុវត្តសំណើរបស់ពួកគេ អ្នកចូលរួមបានស្នើឱ្យចាប់ផ្តើមធ្វើបច្ចុប្បន្នភាពទីតាំងឧក្រិដ្ឋកម្មដែលមានស្រាប់នៅជុំវិញប្រទេស។ ពួកគេបានកត់សម្គាល់ថា មានទីតាំងពន្ធនាគារចំនួន ១៩៦ ក្នុងអំឡុងរបប DK ហើយទីតាំងទាំងនេះ និងទីតាំងផ្សេងទៀតចាំបាច់ត្រូវធ្វើផែនទីលម្អិត។ ការថែរក្សា និងការពារទីតាំងទាំងនេះមានសារៈសំខាន់ ហើយអាចធ្វើទៅបានលុះត្រាមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងវប្បធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលធ្វើការលើការអភិរក្សទីតាំងឧក្រិដ្ឋកម្ម។ ការងារនេះក៏ត្រូវមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ហើយមិនមែនបង្កើតទីតាំងដើម្បីចេះតែបង្កើតនោះទេ។ ការងារនេះអាចសម្រេចបានប្រសិនបើមានការចូលរួមពីប្រជាជននៅតាមសហគមន៍ និងការបណ្តុះបណ្តាលអ្នករស់នៅក្នុងសហគមន៍ដើម្បីរក្សាទីតាំងដែលបានបង្កើតឡើង។

ក្រុមនេះក៏មានបំណងចង់បង្កើតទីតាំងទាំងនេះទៅជាសារមន្ទីរ និងមជ្ឈមណ្ឌលតាំងពិព័រណ៍ ដែលនៅទីនោះព្រឹត្តិការណ៍ផ្សព្វផ្សាយអាចត្រូវបានរៀបចំឡើងសម្រាប់ក្រុមគោលដៅ។ ទីតាំងនេះនឹងផ្តល់កន្លែងសម្រាប់យុទ្ធនាការផ្សព្វផ្សាយប្រកបដោយនិរន្តរភាព សំដៅជានាបាននូវនិរន្តរភាព ហើយមិនមែនជាព្រឹត្តិការណ៍តែម្តងហើយចប់នោះទេ។ ក្រុមនេះក៏បានកត់សម្គាល់ផងដែរអំពីតម្រូវការក្នុងការបញ្ជ្រាបការយល់ដឹងអំពីយេនឌ័រនៅក្នុងកម្មវិធីណាមួយនាពេលអនាគត និងត្រូវយកចិត្តទុកដាក់ចំពោះជនជាតិភាគតិច និងសាសនា។ នៅពេលពិចារណាលើការបញ្ជ្រាបយេនឌ័រ ពួកគេបានគូសបញ្ជាក់អំពីតម្រូវការក្នុងការគិតគូរអំពីបញ្ហាប្រឈមនៃការគ្រប់គ្រងពេលវេលា និងពេលវេលាសម្រាប់ស្ត្រី និងអ្នកមើលថែទាំគ្រួសារ ដើម្បីអាចឱ្យពួកគេចូលរួម (ឧទាហរណ៍ អាចនាំកូនរបស់ពួកគេទៅជាមួយ)។ នៅពេលពិចារណាលើជនជាតិភាគតិច និងសាសនា, ទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍រំលឹកការចងចាំ អាចផ្តល់ឱកាសសម្រាប់ជនជាតិភាគតិច និងសាសនា ចូលរួមអនុវត្តសកម្មភាពផ្សេងៗនៅទីតាំងឧក្រិដ្ឋកម្មទាំងនោះ។ ការចូលរួមរបស់ពួកគេអាចត្រូវបានលើកទឹកចិត្តដោយជ្រើសរើសតំណាងសហគមន៍ឱ្យចូលរួមក្នុងដំណើរការអភិរក្សទីតាំងឧក្រិដ្ឋកម្ម។ យុវជនក៏គួរតែបញ្ចូលទៅក្នុងការងារនៅកន្លែងឧក្រិដ្ឋកម្ម តាមរយៈការផ្តល់ការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងលើកទឹកចិត្តយុវជនឱ្យធ្វើការងារស្ម័គ្រចិត្តលើការអភិរក្សទីតាំងឧក្រិដ្ឋកម្មទាំងនោះ។

សរុបសេចក្តីមក ក្រុមនេះបានសម្រេចដាក់ឈ្មោះគម្រោងរបស់ពួកគេថា "ការរំលឹកការចងចាំដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម៖ ការកំណត់អត្តសញ្ញាណ និងការអភិរក្សទីតាំងប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់ការផ្សះផ្សា និងការទទួលស្គាល់"។ ក្រុមនេះក៏បានស្នើឱ្យរៀបចំបញ្ជីឈ្មោះជនរងគ្រោះនៅ ស-២១ និងសៀវភៅរំលឹកវិញ្ញាណក្ខន្ធរបបខ្មែរក្រហម។ អ្នកចូលរួមបានលើកឡើងអំពីការផ្តល់ប្រវត្តិសាស្ត្រ និងព័ត៌មានអំពីទីតាំងឧក្រិដ្ឋកម្ម ទៅឱ្យថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ និងការចងក្រងឯកសារទីតាំងទាំងនេះជាមធ្យោបាយនៃការទទួលស្គាល់រឿងរ៉ាវរបស់អ្នករស់រានមានជីវិត។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានចាត់ទុកថាអាចធ្វើជាដៃគូអនុវត្ត ដែលអាចជួយការងារគូសរៀសផែនទីទីតាំង និងការចុះបញ្ជីឈ្មោះជនរងគ្រោះជាបញ្ជីថ្នាក់ជាតិ។ អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតនឹងសហការលើការចងក្រងឯកសារស្តីពីទីតាំង រួមជាមួយនឹងការបណ្តុះបណ្តាលយុវជន និងគ្រូបង្រៀន និងបញ្ចូលរឿងរ៉ាវនៅទីតាំងទាំងនេះទៅក្នុងកម្មវិធីអប់រំ។ ពួកគេបានកំណត់អំពីតម្រូវការធ្វើបច្ចុប្បន្នភាពទីតាំងដែលមានស្រាប់ និងសាងសង់កន្លែងរំលឹកវិញ្ញាណក្ខន្ធនៅទីតាំងមួយចំនួនផ្សេងទៀត ដោយផ្អែកតាមតម្រូវការជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ ពួកគេក៏បានស្នើឱ្យមានការសន្ទនាថ្នាក់ជាតិមួយ អំពីរបៀបគ្រប់គ្រងអដ្ឋិធាតុ ដូចជា ឆ្អឹង និងគ្រោងឆ្អឹងផ្សេងៗទៀត។ ជាចុងក្រោយ អ្នកចូលរួមបានស្នើឱ្យរៀបចំពិធីអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលគាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលនេះជាទម្រង់សំខាន់មួយនៃការទទួលស្គាល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

# ០៥

## ក្រុមទី៥ បានចំណាយពេលពិភាក្សានៅក្នុងសិក្ខាសាលាដោយផ្តោតលើជនជាតិភាគតិច និងសាសនា។ អ្នកចូលរួមជាច្រើនបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមជនជាតិភាគតិច ហើយអាចនាំយកទស្សនៈ និងបទពិសោធន៍ដ៏អស្ចារ្យរបស់ពួកគេមកពិភាក្សា។



ព្រះសង្ឃមកពីខេត្តកំពង់ស្ពឺ គង់នៅកន្លែងរង់ចាំរបស់អ.វ.ត.ក មុនចូលស្តាប់អង្គជំនុំជម្រះតុលាការកំពូលប្រកាសសាលដីកាក្នុងសំណុំរឿង០០២/០២ ប្រឆាំង ខៀវ សំផន នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២២។

ពួកគេបាននិយាយអំពីរបៀបដែលពួកគេបានឆ្លុះបញ្ចាំងនៅក្នុងសហគមន៍ និង អ.វ.ត.ក តាំងពីឆ្នាំ២០០៦ នៅពេលដែលដំណើរការបង្កើត អ.វ.ត.ក បានចាប់ផ្តើមដំបូង ហើយចំណុចសំខាន់ត្រូវស្វែងយល់អំពីសេចក្តីរំពឹងទុកបន្ទាប់ពីតុលាការបញ្ចប់ ដោយសារយើងមិនអាចរំពឹងឱ្យតុលាការដោះស្រាយគ្រប់បញ្ហា។

ដោយទទួលស្គាល់ថា អ.វ.ត.ក បានបោះជំហានលឿនលើទិដ្ឋភាពនេះ នៅក្នុងការរកឃើញរបស់ខ្លួនអំពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម សហគមន៍ផ្សេងទៀតដូចជាខ្មែរក្រោមមិនត្រូវលើកឡើងនៅក្នុងសាលដីកាបស់តុលាការនោះទេ។ ក្រុមនេះមានការយល់ដឹងរួមរួមទាំង ពីដើមបណ្តឹងរដ្ឋប្បវេណី ០២ក្រុម និងពីអនុរដ្ឋលេខាធិការក្រសួងអប់រំ ទាក់ទងនឹងអ្វីដែលបានកើតឡើងនៅក្នុងសហគមន៍ទាំងនេះ។ ក្រុមនេះបានកត់សម្គាល់ថា មានទីតាំងឧក្រិដ្ឋកម្មនៅជិតក្រុមជនជាតិភាគតិច ហើយមជ្ឈមណ្ឌលឯកសារមួយចំនួនមានរួចហើយនៅកន្លែងនោះ ដូចជា ក្រាំងតាចាន់។ ទីតាំងដែលមានស្រាប់ទាំងនេះក៏អាចធ្វើជាទីតាំងសម្រាប់ការជួបជុំ និងថ្ងៃរំលឹកការចងចាំផងដែរ។ សមាជិកក្រុមមួយចំនួនបានចែករំលែកថា មានបុគ្គលដែលមានឆន្ទៈបរិច្ចាគដីសម្រាប់ការសាងសង់កន្លែងគោរពវិញ្ញាណក្ខន្ធនាពេលអនាគត។ តម្រូវការផ្សេងទៀតដែលត្រូវបានកំណត់ទាក់ទងនឹងសេវាសុខភាព ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ជនរងគ្រោះ និងតម្រូវការសម្រាប់ការអប់រំ ការស្តារនីតិសម្បទា និងសេវាសង្គមសម្រាប់ក្រុមជនជាតិភាគតិច។ ក្រុមនេះបានកំណត់បន្ថែមទៀតអំពីតម្រូវការសម្រាប់សេវាសង្គមដោយស្មើភាពគ្នា និងតម្រូវការក្នុងការផ្តោតលើការកសាងឡើងវិញនូវវប្បធម៌ទាក់ទងនឹងសាលារៀនសហគមន៍ និងបានលើកទឹកចិត្តឱ្យក្រសួងអប់រំទទួលយកពាក្យសុំបើកសាលា។

សំណើចុងក្រោយរបស់ក្រុមផ្តោតលើការបង្កើតមជ្ឈមណ្ឌលឯកសារសហគមន៍ ដែលនឹងរួមបញ្ចូលកម្មវិធីសុខភាពផ្លូវកាយ និងផ្លូវចិត្ត រួមជាមួយនឹងកម្មវិធីស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់យុវជន។ ពួកគេបានជ្រើសរើសតំបន់គោលដៅក្នុងខេត្តតាកែវ ហើយសំណើរបស់ពួកគេបានលើកចំមជ្ឈមណ្ឌលឯកសារ ដោយផ្តោតលើសមាជិកសហគមន៍ខ្មែរក្រោម និងវៀតណាម ហើយផ្តោតលើទីតាំងឧក្រិដ្ឋកម្មដែលនៅជិតពួកគេក្នុងខេត្តតាកែវ។ ពួកគេបានកំណត់ទីតាំង វត្តព្រះធាតុ ភូមិក្បាលដំរី

ឃុំគោកព្រិច ស្រុកគិរីវង់ ខេត្តតាកែវ។ ការបង្ហាញទីតាំងបែបនេះ នៅជិតសហគមន៍របស់ពួកគេ មានន័យថាវាក៏អាចធ្វើជាកន្លែងសម្រាប់រក្សាប្រវត្តិសាស្ត្រផ្ទាល់មាត់ កិច្ចសន្ទនា រំលឹកការចងចាំនៅថ្ងៃ២០ ឧសភា និងអាចប្រើប្រាស់សម្រាប់ក្មេងៗជំនាន់ក្រោយសិក្សា និងធ្វើការស្រាវជ្រាវ និងសម្រាប់ការសន្ទនាអន្តរជំនាន់។ ទីតាំងបែបនេះក៏នឹងបម្រើជាកន្លែងសហគមន៍សម្រាប់ជំនួយផ្លូវចិត្ត និងជាកន្លែងតាំងពិព័រណ៍សម្រាប់ប្រជាជនទូទៅ និងសម្រាប់ជនជាតិភាគតិចផងដែរ។ ការធ្វើដូច្នេះគឺដើម្បីជៀសវាងការផ្តល់អាទិភាពដល់ក្រុមជាក់លាក់ណាមួយ ហើយផ្ទុយទៅវិញជានាបាននូវការផ្តោតអារម្មណ៍លើសាធារណជន។ ចំណុចនេះទាមទារឱ្យមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងយុវជន និងថ្នាក់ដឹកនាំសាសនា។ ក្រៅពីនេះក៏មានតម្រូវការក្នុងការរួមបញ្ចូលសាលារៀនដើម្បីជួយសម្រួលដល់ការចុះសួរសុខទុក្ខ និងកម្មវិធីអប់រំ។ សំណើនេះបានប៉ាន់ស្មាននូវពេលវេលាកំណត់រយៈពេល ០៣ឆ្នាំ លើការងារសាងសង់ ហើយថវិកាចាប់ផ្តើមដែលបានប៉ាន់ស្មានគឺ ១៥០,០០០ដុល្លារអាមេរិក ក៏ដូចជា ៥០,០០០ដុល្លារអាមេរិក ក្នុងករណីលើសខ្ទង់ចំណាយ។

និរន្តរភាពនៃឱកាសក៏សំខាន់ផងដែរ ហើយដោយសារវានឹងស្ថិតក្នុងទីតាំងនៅក្នុងវត្ត ក៏អាចជាការស្វាគមន៍ដល់ការរួមចំណែកពីសហគមន៍មូលដ្ឋានផងដែរ។ សមាគមអ្នករស់រានមានជីវិតក៏អាចជួយលើកទឹកចិត្តដល់ការគាំទ្រសម្រាប់គេលើទីតាំង និងអាចជួយបង្កើតមូលនិធិផងដែរ។

ក្រុមនេះបានលើកឡើងបន្ថែមទៀតអំពីការគ្រប់គ្រងហានិភ័យនៅក្នុងបទបង្ហាញចុងក្រោយរបស់ពួកគេ និងតម្រូវការដើម្បីធានានូវទំនុកចិត្ត និងតម្លាភាពអំពីរបៀបដែលគម្រោងនេះនឹងត្រូវបានផ្តល់មូលនិធិសម្រាប់ការងារគ្រប់គ្រង។ ពួកគេបានលើកទឹកចិត្តឱ្យមានបទប្បញ្ញត្តិផ្ទៃក្នុងដើម្បីគ្រប់គ្រងបញ្ហា ឬ អ្វីដែលអាចកើតមាន និងតម្រូវការសម្រាប់និរន្តរភាពនៃមូលនិធិ។ ក្រុមនេះក៏បានពិភាក្សាខ្លីអំពីគម្រោងមួយផ្សេងទៀតដែលផ្តោតលើការទទួលបានការអប់រំ និងការស្តារវប្បធម៌ឡើងវិញ។ ហេតុផលចង់ឱ្យមានគម្រោងនេះគឺដោយសារតែកង្វះលទ្ធភាពទទួលបានការអប់រំក្នុងចំណោមក្រុមជនជាតិភាគតិចក្នុងពេលបច្ចុប្បន្ន ហើយគម្រោងបែបនេះនឹងជួយធានាបាននូវឱកាសត្រឹមត្រូវចូលរួមអប់រំមនុស្សពាក់ព័ន្ធគ្រប់គ្នា និងទទួលបានការអប់រំ។ ការងារនេះអាចធ្វើទៅបានក្រោមកិច្ចសហការជាមួយក្រសួងអប់រំ និងសហគមន៍មូលដ្ឋាន ហើយសៀវភៅសិក្សានឹងត្រូវបានបង្កើត និងបោះពុម្ពជាភាសាសហគមន៍ទាំងនេះផងដែរ។ អ្នកទទួលផលដែលត្រូវបានកំណត់នឹងមានយ៉ាងហោចណាស់ ១,០០០ នាក់ ហើយតំបន់គោលដៅមានខេត្តកំពង់ឆ្នាំង កំពង់ចាម និងមណ្ឌលគិរី។

# ០៦

## មុនដំបូង ក្រុមទី៦ អាចទទួលបានអត្ថប្រយោជន៍ពីអ្នកចូលរួមដែលធ្វើការដោយផ្ទាល់លើសិទ្ធិទទួលបានយុត្តិធម៌ និងជំនួយផ្នែកច្បាប់។



លោកស្រី គុម សុម៉ាលី មកពី មជ្ឈមណ្ឌលសិក្សាច្បាប់មនុស្សធម៌ នៃសាកល វិទ្យាល័យនីតិសាស្ត្រនិង សេដ្ឋកិច្ចធ្វើបទបង្ហាញទៅកាន់សិក្ខាកាមនៅថ្ងៃទី២នៃសិក្ខាសាលា ។

ពួកគេបានផ្តោតការពិភាក្សារបស់ពួកគេលើរបៀបពង្រីកសេវាដែលមានស្រាប់ និងវិធីដោះស្រាយចន្លោះប្រហោងពីព្រោះមិនចាំបាច់មានស្ថាប័នថ្មី ឬគំនិតដែលផ្តល់ឱ្យស្ថាប័នដែលកំពុងដំណើរការ។

ពួកគេបានពិភាក្សាអំពីការរំពឹងទុកសម្រាប់អ្វីដែលកើតឡើងសូម្បីតែបន្ទាប់ពីករណីមួយបានបញ្ចប់ ហើយតម្រូវការសម្រាប់អ្នករស់រានមានជីវិត និងជនរងគ្រោះដើម្បីយល់ពីរឿងនេះ និងដើម្បីគ្រប់គ្រងការរំពឹងទុក។ ក្រុមនេះបានកំណត់តម្រូវការជាក់លាក់ដែលដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតមាន ហើយបានស្នើគំនិតមួយចំនួនដើម្បីដោះស្រាយតម្រូវការទាំងនេះ។ ពួកគេបានស្នើឱ្យកសាងស្តូបនៅទូទាំងប្រទេស ហើយយកទីតាំងទាំងនេះធ្វើជាកន្លែងសម្រាប់ការជួបជុំ ការផ្សះផ្សា និងការចងចាំ។ ការផ្តល់ហិរញ្ញប្បទានគឺជាឧបសគ្គរារាំងការសាងសង់ស្តូប និងកន្លែងរំលឹកវិញ្ញាណក្ខន្ធ ហើយក្រុមបានកំណត់អំពីតម្រូវការទទួលការគាំទ្រពីរដ្ឋាភិបាលលើការងារនេះ។ ពួកគេបានស្នើថា ចេតិយអាចទទួលបានមូលនិធិពីថវិកាបញ្ចូលគ្នានៃការគាំទ្រពីរដ្ឋាភិបាល ប៉ុន្តែក៏អាចជាការរៃអង្គាសថវិកាពីប្រជាជន និងសហគមន៍ផងដែរ។

អ្នកចូលរួមក៏បានស្នើថា ការប្រារព្ធទិវាចងចាំ ២០ ឧសភាគួរតែបន្ត ហើយស្តូបបែបនេះអាចប្រើជាកន្លែងសម្រាប់រំលឹកការចងចាំ និងជួបជុំជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ ការប្រមូលផ្តុំទាំងនេះក៏អាចកើតឡើងតាមតំបន់ផងដែរ។ អ្នកចូលរួមក៏បានទទួលស្គាល់អំពីតម្រូវការរបស់ជនរងគ្រោះចង់បាន ការព្យាបាលដោយឥតគិតថ្លៃ។ តាមការណែនាំ ការងារនេះអាចត្រូវបានធ្វើឡើងតាមរយៈការចេញប័ណ្ណសម្រាប់អ្នកដែលមានជីវភាពក្រីក្រ មិនមានលទ្ធភាពទទួលបានសេវាព្យាបាលដោយសារហេតុផលហិរញ្ញវត្ថុ។ ការងារនេះអាចធ្វើឡើងក្រោមកិច្ចសហការជាមួយបេឡាជាតិសន្តិសុខសង្គម ហើយប័ណ្ណបែបនេះអាចពង្រីកដល់ជនរងគ្រោះ និងមនុស្សចាស់ទូទៅដែលត្រូវការសេវាថែទាំសុខភាព និងសេវាផ្សេងទៀត។ ការទទួលបានសេវាបែបនេះអាចពង្រីកបន្ថែមដើម្បីផ្តល់សេវាសុខភាពផ្លូវចិត្ត និងការព្យាបាល ក្រោមការគាំទ្រពី TPO។

ចំពោះបញ្ហានៃការទប់ស្កាត់អំពើឃោរឃៅ អ្នកចូលរួមបានចែករំលែកថា តម្រូវការនៃការព្យាបាល និងការថែទាំសុខភាពផ្លូវចិត្តនៅតែមានសារៈសំខាន់ ហើយ អ.វ.ត.ក គឺជាមេរៀនសម្រាប់មនុស្ស

ជំនាន់ក្រោយ និងផ្តល់បទពិសោធន៍ជាច្រើន។ មេរៀន និងបទពិសោធន៍ទាំងនេះគួរតែត្រូវបានចែករំលែកនៅក្នុងវេទិកាផ្សព្វផ្សាយមួយ ដើម្បីឱ្យអ្នកផ្សេងទៀតអាចរៀនពី អ.វ.ត.ក។ ការពិភាក្សា និងកម្មវិធីជជែកអាចរៀបចំឡើងដើម្បីពិភាក្សា និងផ្លាស់ប្តូរគំនិតស្តីពីការទប់ស្កាត់អំពើឃោរឃៅផងដែរ។ វេទិកាសិក្សាបែបនេះក៏អាចត្រូវបានបង្កើតឡើង និងសម្របសម្រួលនៅក្នុងសាកលវិទ្យាល័យ ដើម្បីបង្កើនឱកាសសិក្សាសម្រាប់យុវជន។

បទបង្ហាញសំណើរបស់ក្រុមនេះផ្តោតលើគំនិតជាច្រើន ជាពិសេសការផ្តល់យោបល់ក្នុងការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ជនរងគ្រោះ ដែលអាចបង្កើត និងផ្តល់ឱកាសវែអង្គាសប្រាក់ក្នុងរយៈពេលវែង។ អ្នកចូលរួមបានស្នើឱ្យយកបណ្តាញ "មិត្តរបស់ អ.វ.ត.ក" ដែលមានស្រាប់ជាម្ចាស់ជំនួយអន្តរជាតិ ហើយបំប្លែងវាទៅជា "មិត្តជនរងគ្រោះ"។ ជំនួយផ្នែកច្បាប់នៅក្នុងប្រទេសកម្ពុជាអាចគាំទ្រដល់ការបង្កើតសមាគមបែបនេះ ហើយ LDC មានបន្ទប់ដែលអាចប្រើជាបន្ទប់ និងកន្លែងប្រជុំរបស់សមាគម។ ការបង្កើតសមាគមថ្មីសម្រាប់ជនរងគ្រោះក៏អាចបន្តផ្តល់ឱកាស និងការងារផងដែរ។

ចំពោះបញ្ហាជំនួយផ្នែកច្បាប់វិញ អ្នកចូលរួមក្រុមបានទទួលស្គាល់ថា ដោយសារឃើញមានជំនួយនេះ រដ្ឋាភិបាលគួរប្រែក្លាយជាការពិតសម្រាប់ជនរងគ្រោះ ដើម្បីឱ្យកាន់ពួកគេមានសិទ្ធិទទួលតំណាងស្របច្បាប់កាន់តែច្រើន។ ចំណុចនេះកើតឡើងបន្ទាប់ពី អ.វ.ត.ក បិទដំណើរការ ដោយសារជំនួយផ្នែកច្បាប់នៅតែត្រូវការសម្រាប់អ្នករស់រានមានជីវិត ហើយសិទ្ធិទទួលបានយុត្តិធម៌ត្រូវតែមាន បើទោះបីជា អ.វ.ត.ក លែងដំណើរការក៏ដោយ។

អ្នកចូលរួមក៏បានស្នើឱ្យមានគ្លីនិកស្របច្បាប់ អាចថានៅក្នុងសាកលវិទ្យាល័យដែលមានស្រាប់ និងសាលាច្បាប់ ដើម្បីពិគ្រោះយោបល់លើការស្រាវជ្រាវផ្នែកច្បាប់ សូម្បីតែពីជនរងគ្រោះខ្លួនឯងក៏ដោយ។ ការងារនេះនឹងផ្តល់ឱកាសក្នុងការបណ្តុះបណ្តាល និងចូលរួមជាមួយមនុស្សជំនាន់ក្រោយ រួមទាំងនិស្សិតច្បាប់ផងដែរ។

# ០៧

## សម្រាប់អ្នកចូលរួមពិភាក្សាប្រធានបទ យុវជន និងកិច្ចសន្ទនាអន្តរជំនាន់ មានអត្ថប្រយោជន៍ជាច្រើនដែលបានកើតចេញពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយក្នុងនោះអត្ថប្រយោជន៍មួយគឺពាក់ព័ន្ធនឹងកិច្ចសន្ទនាអន្តរជំនាន់។



↑ សកម្មភាពចុះផ្សព្វផ្សាយ នៅខេត្តព្រៃវែង។

ពួកគេបានទទួលស្គាល់ថាបញ្ហាមួយក្នុងរឿងនេះគឺថា យុវជនជាច្រើននៅតែមិនជឿអ្វីដែលបានកើតឡើងក្រោមរបបខ្មែរក្រហម ដោយអ្នកខ្លះនៅតែចាត់ទុកថាវាគ្រាន់តែជាបញ្ហាទ្រឹស្តីតែប៉ុណ្ណោះ មិនមែនជាអ្វីដែលបានកើតឡើងនៅក្នុងជីវិតពិតនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមនេះ បានចែករំលែកថា ពួកគេចង់ឱ្យទ្រឹស្តីនេះក្លាយជាការពិតតាមរយៈការសន្ទនាអន្តរជំនាន់ដោយអូសទាញនិស្សិតឱ្យចូលរួមក្នុងការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រ KR។ ដើមបណ្តឹងរដ្ឋប្បវេណីបានចែករំលែកថា ការសិក្សាបែបនេះសម្រាប់និស្សិតគួរតែរួមបញ្ចូលប្រធានបទ ដែលជាធម្មតាមិនត្រូវបានបញ្ចូល ដូចជាការរៀបការដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ និងជនរងគ្រោះជាជនជាតិភាគតិច ដោយសារការចូលរួមរបស់ពួកគេនៅមានកម្រិតនៅឡើយ។

ចំពោះការចងចាំ អ្នកចូលរួមបានចែករំលែកអំពីសារៈសំខាន់នៃការប្រមូលរឿងរ៉ាវអ្នករស់រានមានជីវិត និងជនរងគ្រោះ និងភាពចាំបាច់ត្រូវរក្សារឿងរ៉ាវទាំងនេះ។ ពួកគេក៏បានទទួលស្គាល់អំពីតម្រូវការក្នុងការថែរក្សាអតីតទីតាំងឧក្រិដ្ឋកម្ម និងសាងសង់ស្តូបរំលឹកវិញ្ញាណក្ខន្ធនៅទីតាំងឧក្រិដ្ឋកម្ម (ស្រដៀងនឹងសំណើដែលធ្វើឡើងដោយក្រុមទី៤)។ អ្នកចូលរួមក៏បានស្នើឱ្យមានការកសាងនិងបង្កើតមជ្ឈមណ្ឌលចងចាំ និងមជ្ឈមណ្ឌលសិក្សា ដែលកុមារនិងចៅៗរបស់អ្នកនៅរស់រានមានជីវិតអាចជ្រើសរើសឱ្យធ្វើការងារនៅទីនោះ។ ចំណុចនេះត្រូវបានបញ្ជាក់បន្ថែមនៅក្នុងសំណើរបស់ KDK ដាក់ជូននៅក្រោយសិក្ខាសាលា ដែលអាចមើលនៅក្នុងផ្នែកបន្ទាប់ខាងក្រោម។ ការតាំងពិព័រណ៍ក៏គួររៀបចំឡើងដោយបើកឱ្យមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិត ហើយទិវាចងចាំ ២០ ឧសភា បានលើកយកមកធ្វើជាឧទាហរណ៍។

អ្នកចូលរួមបានពិភាក្សាអំពីសារៈសំខាន់នៃការប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិត យកមកថែរក្សាទុក។ ការផ្សព្វផ្សាយរឿងរ៉ាវសម្រាប់សិស្សានុសិស្ស និងនៅតាមសាលារៀននឹងផ្តល់ជាមូលដ្ឋានគគ្រឹះសម្រាប់ការសន្ទនាអន្តរជំនាន់ ហើយនឹងអនុញ្ញាតឱ្យអ្នកនៅរស់រានមានជីវិតដែលមិនទាន់មានឱកាសចែករំលែករឿងរ៉ាវទាំងនេះ។ និរន្តរភាពសម្រាប់កិច្ចសន្ទនាអន្តរជំនាន់ និងការចូលរួមជាមួយយុវជន តម្រូវឱ្យមានកិច្ចសហការគ្នាក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជៀសវាងការងារជាន់គ្នា និងការប្រកួតប្រជែងរវាងគ្នា។ ដើម្បីដោះស្រាយបញ្ហានេះ អ្នកចូលរួមបានស្នើឱ្យបង្កើតវេទិកាកិច្ចសហការរវាងអង្គការមិនមែន

រដ្ឋាភិបាល ដែលអាចជាប្រភេទនៃកិច្ចសន្ទនាណាមួយ ឬ វេទិកាស្តីពីការសន្ទនា។

នៅក្នុងបទបង្ហាញនៅថ្ងៃចុងក្រោយនៃសន្និសីទ អ្នកចូលរួមនៅក្នុងក្រុមបានចែករំលែកសំណើរបស់ពួកគេ សុំបង្កើតមជ្ឈមណ្ឌលសម្រាប់កិច្ចសន្ទនាអន្តរជំនាន់ ដែលដៃគូនីមួយៗ - អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋ - អាចពាំនាំចំណេះដឹងជំនាញ និងបទពិសោធន៍ និងគាំទ្រគ្នាទៅវិញទៅមកក្នុងវិស័យផ្សេងៗគ្នា។ ការបង្កើតកម្មវិធីដែលឆ្លើយតបកាន់តែច្រើនមានន័យថាជាផ្តល់ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងជួយសម្រាលរបួសដល់អ្នករស់រានមានជីវិត និងមនុស្សជំនាន់ក្រោយផងដែរ។ ក្រុមគោលដៅអាចជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម យុវជន សិស្សវិទ្យាល័យ និងសាកលវិទ្យាល័យ និងគ្រូបង្រៀន អ្នកដឹកនាំសហគមន៍ (រួមទាំង យុវជន មេដឹកនាំសាសនា និងស្ត្រី) សមាជិកក្រុមប្រឹក្សានៅថ្នាក់មូលដ្ឋាន និងបុគ្គលិកសុខាភិបាលនៅថ្នាក់មូលដ្ឋាន។ ដើម្បីធានាបាននូវនិរន្តរភាព ក្រុមការងារបានកំណត់ក្រសួងពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ និងក្រសួងពាណិជ្ជកម្ម រួមជាមួយនឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ។ ពួកគេបានស្នើឱ្យបង្កើតយន្តការគ្រប់គ្រងចំណេះដឹង ដើម្បីផ្ទេរជូនស្ថាប័នរដ្ឋ ឱ្យបន្តការងារបន្ទាប់ពីអាណត្តិដែលនៅសេសសល់រយៈពេលបីឆ្នាំ។ មជ្ឈមណ្ឌលដែលពួកគេបានស្នើឡើង ក៏អាចបង្កើតប្រាក់ចំណូលដែលអាចយកមកបញ្ចូលទៅក្នុងសកម្មភាព និងគម្រោងផ្ទាល់របស់ខ្លួនវិញ។ ចំណុចចុងក្រោយ ក្រុមនេះបានស្នើឱ្យបង្កើតមូលនិធិស្ម័គ្រចិត្តស្តីពីជនរងគ្រោះ តាមរយៈការខិតខំរៃអង្គាសថវិកាក្នុងស្រុក។

# ០៨



អ្នកចូលរួមនៅក្នុងក្រុមទី ៨ បានចាប់ផ្តើមដំបូងដោយកំណត់អត្តសញ្ញាណតម្រូវការរបស់អ្នករស់រានមានជីវិតពី SGBV។ ពួកគេបានលើកឡើងថា ជនរងគ្រោះត្រូវការយុត្តិធម៌ និងត្រូវការឱ្យជនជាប់ចោទ និងជនល្មើស មានការទទួលខុសត្រូវ។

ប្រជាពលរដ្ឋខ្មែរមកពីតាមភូមិ កំពុងអង្គុយនៅសាលសាធារណៈក្នុងពេលតុលាការធ្វើសេចក្តីសន្និដ្ឋានបិទ ក្នុងសំណុំរឿង០០២/០២។

ពួកគេត្រូវការការអនុវត្តសំណងឱ្យបានពេញលេញ និងចង់ឃើញការបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋ។ ជនរងគ្រោះត្រូវការការគាំទ្រផ្នែកច្បាប់ ផ្លូវចិត្ត និងការប្រឹក្សាយោបល់ រួមជាមួយនឹងកន្លែងសុវត្ថិភាព ឬ ទីជំរកសម្រាប់ការប្រជុំ និងការប្រមូលផ្តុំ។ ឯកសារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយពហុបំណង ក៏បានលើកឡើងថាជាតម្រូវការមួយ យកមកអនុវត្តរួមជាមួយតម្រូវការក្នុងការជូនដំណឹងឱ្យបានទាន់ពេលវេលាដល់សាធារណជនអំពី អ.វ.ត.ក និងអំពីការឈានទៅបញ្ចប់ការងារ។

ខណៈដែលអ្នកចូលរួមបានទទួលស្គាល់ថា មានការអប់រំមួយចំនួនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនាពេលបច្ចុប្បន្ន ហើយក៏ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមសាលាផងដែរនោះ យើងត្រូវការផ្តោតការយកចិត្តទុកកាន់តែច្រើនលើ SGBV ក្នុងរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីឧក្រិដ្ឋកម្មពុំមានឱកាសច្រើនបង្ហាញរឿងរ៉ាវរបស់ពួកគេនោះទេ ហើយអ្នកនៅរស់មួយចំនួនប៉ុណ្ណោះដែលអាចបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ក្រុមនេះបានពិចារណាចង់ឱ្យមានក្រុមជនរងគ្រោះកាន់តែច្រើនជាងចំនួនក្រុមជនរងគ្រោះមួយចំនួនតូច ដែលបានបង្ហាញខ្លួននៅចំពោះមុខតុលាការ ហើយបានទទួលស្គាល់ថា ជនរងគ្រោះមួយចំនួនដែលបានផ្តល់សក្ខីកម្មត្រូវបានកំណត់ចេញពីតំបន់ភូមិសាស្ត្រមួយចំនួនប៉ុណ្ណោះ។ ដូច្នេះ ការផ្តល់ឱកាសដល់ជនរងគ្រោះបង្ហាញរឿងរ៉ាវរបស់ពួកគេគឺជារឿងសំខាន់។ កូនចៅរបស់ជនរងគ្រោះក៏ត្រូវការឱកាសដើម្បីទទួលបានជំនាញបំណិនជីវិត ឬជំនាញដោះស្រាយជម្លោះផងដែរ។

ក្នុងការបង្កើតទស្សនៈ និងគំនិតផ្តួចផ្តើមសម្រាប់ដោះស្រាយតម្រូវការ ក្រុមនេះបានលើកយោបល់ដូចខាងក្រោម។ ទីមួយ បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋ និងរួមបញ្ចូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិត ហើយក្នុងពេលជាមួយគ្នារក្សាបានគោលការណ៍មិនបង្កគ្រោះថ្នាក់ និងធ្វើយ៉ាងណាអនុវត្តវិធីសាស្ត្រកុមារមេត្រី។ ក្រុមក៏បានស្នើផងដែរនូវតម្រូវការទទួលស្គាល់ជាសាធារណៈអំពីព្យសនកម្មដែលបានទទួលរង និង “ការសារភាព” ដោយជនល្មើសផ្ទាល់។ ការងារនេះនឹងអនុញ្ញាតឱ្យមានការផ្សះផ្សា ប៉ុន្តែត្រូវការវេទិកាសម្រាប់កិច្ចការនេះ ដូចជាទីតាំងសម្រាប់យន្តការស្វែងរកការពិត និងយន្តការអនុញ្ញាតឱ្យមានការសន្ទនា និងការសុំទោសពីជនល្មើសម្នាក់ៗ។ គំនិតផ្តួចផ្តើមមួយផ្សេងទៀតដែលត្រូវបានកំណត់ឃើញគឺការផ្តល់សេវាប្រឹក្សាផ្នែកច្បាប់ និងផ្លូវចិត្ត និងកិច្ចខិតខំប្រឹងប្រែង

ស្រាវជ្រាវបន្ថែមអំពីផលប៉ះពាល់នៃការរៀបការដោយបង្ខំ និង SGBV លើបុរស និងស្ត្រី ដើម្បីកំណត់រកដោះស្រាយឆ្លើយតបតម្រូវការជាក់លាក់របស់ពួកគេ។

គំនិតផ្តួចផ្តើមមួយទៀតដែលបានស្នើឡើងគឺការផ្តល់លទ្ធភាពទទួលបាននូវការថែទាំសុខភាពសម្រាប់ស្ត្រីដែលទទួលរង SGBV និងព្យសនកម្មលើរូបរាងកាយដោយសារការរៀបការដោយបង្ខំ និងដំណើរការសន្ទនាអន្តរជំនាន់ (ដោយផ្តោតលើបុគ្គលទូទៅ ការដាក់បញ្ចូលជនជាតិភាគតិច និងការសន្ទនាតាមប្រធានបទជាក់លាក់ ដូចជាការផ្តោតលើ SGBV ជាដើម ឬ ការរៀបការដោយបង្ខំ) ហើយធានាថា បញ្ហាទាំងនេះត្រូវបានកត់ត្រាតាមមធ្យោបាយផ្សេងទៀត និងរួមបញ្ចូលនៅតាមទីកន្លែងតាំងពិពណ៌។ ការធ្វើដូច្នេះនឹងជួយបង្កើតទម្លាប់នៃការសន្ទនា ជាយានតភ្ជាប់គម្លាតរវាងមនុស្ស និងដើម្បីយកជំនាញទាំងនេះទៅប្រើប្រាស់សម្រាប់ប្រភេទនៃការសន្ទនាផ្សេងទៀត។ ការរៀបចំកិច្ចសន្ទនានេះជាប្រព័ន្ធនឹងធានាបាននូវនិរន្តរភាព។

ចំពោះគោលការណ៍ណែនាំ ក្រុមនេះយល់ស្របថា គំនិតផ្តួចផ្តើម និងកម្មវិធីនានា មិនគួរផ្តោតតែលើអ្នករស់រានមានជីវិតប៉ុណ្ណោះទេ ហើយគួរផ្តោតលើក្មេងជំនាន់ក្រោយផងដែរ ដែលរងផលប៉ះពាល់ដោយសារខ្មែរក្រហម សូម្បីក្នុងពេលសព្វថ្ងៃ។ ចំពោះនិរន្តរភាព ការផ្តោតលើយន្តការដែលនៅសេសសល់គឺធ្វើយ៉ាងណាឱ្យបញ្ចូលជំនាញទាំងនេះនៅក្នុងសហគមន៍ (ឧទាហរណ៍ គួរផ្តោតគំនិតផ្តួចផ្តើមដែលភ្ជាប់ទៅនឹងកិច្ចសន្ទនាអន្តរជំនាន់ និងការប្រមូលប្រវត្តិសាស្ត្រ)។ កម្មវិធីគួរតែធានាដល់ការកសាងជំនាញនៅក្នុងចំណោមពួកគេ និងសកម្មភាពដើម្បីឱ្យពួកគេអាចទ្រទ្រង់ខ្លួនឯងបាន។ ភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក៏ចាំបាច់ត្រូវមានផងដែរ ដើម្បីឱ្យកម្មវិធីមាននិរន្តរភាព ដោយមិនគួរឱ្យរាជរដ្ឋាភិបាលជាអ្នកទទួលខុសត្រូវទាំងស្រុងក្នុងការអនុវត្តគម្រោងនោះទេ ដោយហេតុថាការងារនេះគួរធ្វើឡើងក្នុងភាពជាដៃគូជាមួយអ្នកសហការផ្សេងទៀត។ មុននឹងបង្កើតកម្មវិធីណាមួយ ចាំបាច់ត្រូវធ្វើការស្ទង់មតិជាមុន និងកំណត់កម្មវិធីជំនួយរបស់រដ្ឋាភិបាលដែលមានស្រាប់ និងការភ្ជាប់គំនិតផ្តួចផ្តើមទាក់ទងនឹងអ្នករស់រានមានជីវិតជាមួយកម្មវិធីទាំងនោះតាមវិធីដែលធានាបាននូវនិរន្តរភាព។ សមាគមអ្នករស់រានមានជីវិតគួរតែចូលរួមក្នុងសកម្មភាពទាំងអស់ខាងលើ។ ជារួម អ្នកចូលរួមបានលើកឡើងថា គួរមានស្ថាប័នកណ្តាលមួយ ដើម្បីទទួលតួនាទីសម្របសម្រួល និងសម្របសម្រួលរាល់គំនិតផ្តួចផ្តើមទាក់ទងនឹងខ្មែរក្រហម និងធានាការអនុវត្តនៅក្រោយដំណាក់កាលដែលនៅសេសសល់នៃ អ.វ.ត.ក។

បញ្ហាប្រឈម និងឧបសគ្គដែលត្រូវពិចារណារួមមានតម្រូវការក្នុងការកសាងទំនុកចិត្តបន្ថែមទៀតនៅក្នុងចំណោមស្ថាប័នសាធារណៈដែលនៅពុំទាន់មាននៅឡើយ ហើយអ្នករស់រានមានជីវិតដែលមានវ័យចំណាស់កាន់តែតិចទៅៗ មានលទ្ធភាពផ្ទេរចំណេះដឹង និងបទពិសោធន៍របស់ពួកគេកាន់អ្នកដទៃ។

នៅក្នុងបទបង្ហាញចុងក្រោយរបស់ពួកគេ ក្រុមទី៨ បានកំណត់កម្មវិធី និងសកម្មភាពដែលបានស្នើឡើងចំនួន ០៣។ កម្មវិធីដំបូងដែលបានបង្ហាញគឺ ការសន្ទនាអន្តរជំនាន់ និងអន្តរបុគ្គលនៅកម្រិតគ្រួសារ និងសហគមន៍។ កម្មវិធីនេះនឹងធានាបាននូវការរួមបញ្ចូលក្រុមនៃ SGBV និងការរៀបការដោយបង្ខំ។ ការសន្ទនាបែបនេះក៏នឹងរួមបញ្ចូលក្រុមយេនឌ័រ រួមទាំងក្រុមជនជាតិភាគតិច និងក្រុមជាក់លាក់ (LGBTQI) ផងដែរ។ កម្មវិធីនេះនឹងបង្កើតជំនាញដោះស្រាយជម្លោះដោយអហិង្សា។ ដើម្បីផ្តួចផ្តើមការសន្ទនា ក្រុមនេះបានស្នើឱ្យបង្កើតវិធីច្នៃប្រឌិតតាមរយៈការប្រើប្រាស់រូបភាព និងរូបថត ឬការប្រើប្រាស់កម្មវិធី។ ជាងនេះទៅទៀត ក្រុមនេះបានស្នើថា ការពន្យល់អំពីសាលក្រមរបស់ អ.វ.ត.ក លើអំពើហិង្សាផ្លូវភេទ គឺជាវិធីមួយដើម្បីបញ្ចប់និទណ្ឌភាព ហើយមានភាពចាំបាច់ត្រូវរៀនចែករំលែករឿងរ៉ាវតាមវិធីណាមួយដែលមិនបង្កគ្រោះថ្នាក់ដល់គ្រួសារ និងសហគមន៍។ ការកសាងជំនាញក៏ត្រូវបានគេកំណត់ថាជាទិដ្ឋភាពមួយនៃកម្មវិធីនេះផងដែរ ដែលជាមធ្យោបាយមួយដើម្បីធានាបាននូវនិរន្តរភាព។ ក្នុងករណីមូលនិធិមានកម្រិតតាំងពីដំបូង កម្មវិធីនេះអាចផ្តោតលើដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្ទាប់មកពង្រីកដល់ក្រុមផ្សេងទៀតឱ្យបានទូលំទូលាយ។

កម្មវិធីទីពីរដែលបានបង្ហាញគឺ យន្តការដែលនៅសេសសល់គួរភ្ជាប់ជាមួយការងារដែលបានធ្វើរួចហើយ ដើម្បីគាំទ្រជនរងគ្រោះនៃ SGBV នៅក្នុងសហគមន៍។ ឧទាហរណ៍ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាមានគម្រោងជំនួយផ្នែកច្បាប់សម្រាប់ស្ត្រី និងកុមារ។ គម្រោងនេះអាចពង្រីកបន្ថែម ដើម្បីធានាថាជំនួយផ្នែកច្បាប់ក៏ត្រូវបានផ្តល់ជូនជនរងគ្រោះនៃការរៀបការដោយបង្ខំ ដែលបច្ចុប្បន្នស្ថិតក្នុងស្ថានភាពនេះដដែល ហើយចង់លែងលះ ឬ កំពុងប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារ។ កម្មវិធីដែលមានស្រាប់លើការផ្តល់ជំនួយ (ផ្នែកច្បាប់ ផ្លូវចិត្ត សុខភាព និងសេដ្ឋកិច្ច និងសង្គម) ដល់ស្ត្រីរងគ្រោះដោយសារ SGBV អាចត្រូវបានពង្រីកដើម្បីពិនិត្យមើលរបៀបដែលអំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះអាចត្រូវបានដោះស្រាយ តាមរយៈគម្រោងដែលមានស្រាប់។

ទីបី សកម្មភាពអប់រំ និងលើកកម្ពស់ការយល់ដឹងគួរតែត្រូវបានធ្វើឡើងក្នុងចំណោមមនុស្សជំនាន់ក្រោយ និងសាធារណជន

ទូទៅអំពី SGBV ក្រោមរបប DK។ សកម្មភាពនេះអាចធ្វើឡើងដោយប្រើឧបករណ៍ វិធីសាស្ត្រ និងសកម្មភាពដែលមានស្រាប់ ដូចជា ការតាំងពិព័រណ៍ចល័ត សិល្បៈ ភាពយន្ត ល្ខោន និងគម្រោងសំណងទាំងអស់។ សកម្មភាពទាំងនេះគួរតែបញ្ចូលទៅក្នុងសហគមន៍មូលដ្ឋាន និងសាលារៀន ដើម្បីធានាបាននូវនិរន្តរភាព និងចីរភាព។ ជាចុងក្រោយ សកម្មភាពអប់រំ និងលើកកម្ពស់ការយល់ដឹងបែបនេះអាចសម្រេចបានតាមរយៈការតាំងពិព័រណ៍អចិន្ត្រៃយ៍ ហើយមជ្ឈមណ្ឌលចងចាំ និងស្ថាប័នដែលមានស្រាប់ (ដូចជា មជ្ឈមណ្ឌលបុប្ផាណា LDC មជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរទួលស្លែង និងសាកលវិទ្យាល័យ) បន្តប្រើប្រាស់ឧបករណ៍ទាំងនេះ។

○

# សំណើដែលទទួលបានក្រោយសិក្ខាសាលា

អ្នកចូលរួម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្តល់ឱកាសឱ្យបន្តដាក់សំណើ សូម្បីនៅក្រោយបញ្ចប់សិក្ខាសាលា ដែលការងារនេះជាការឆ្លើយតបជាក់លាក់ចំពោះក្តីរីករាយដែលបានបង្ហាញក្នុងសិក្ខាសាលា ដោយអ្នកចូលរួមមួយចំនួន ចង់បន្តកែសម្រួលសំណើ និងគំនិតនានា ដោយផ្អែកលើការពិភាក្សាក្នុងពេលសិក្ខាសាលា ព្រមទាំងសម្រាប់អ្នកចូលរួមដែលចង់ដាក់សំណើ ប៉ុន្តែមិនបានធ្វើឡើងរហូតដល់ពេលនេះ ហើយក៏ជាឱកាសមួយទៀតសម្រាប់ អ្នកដែលចាប់អារម្មណ៍ ប៉ុន្តែមិនបានដាក់សំណើទាន់ពេលវេលាស្របតាមរបាយការណ៍ប្រឹក្សាយោបល់ឆ្នាំ២០២១ របស់សហចៅក្រមរបាយការណ៍។ វាក៏ជាឱកាសមួយសម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានា ដែលបានចូលរួមសិក្ខាសាលា ហើយត្រូវបានបំបែកចេញពីក្រុមពិភាក្សាទាំងប្រាំបី បន្ទាប់មកត្រលប់មករួមគ្នាវិញ ហើយដាក់សំណើតំណាងឱ្យការខិតខំប្រឹងប្រែង និងគោលដៅរបស់អង្គការរៀងៗខ្លួន។ សំណើចំនួនប្រាំមួយបន្ថែមទៀតត្រូវបានទទួលបន្ទាប់ពីសិក្ខាសាលា គិតត្រឹមថ្ងៃទី១៥ ខែឧសភា ដែលជាថ្ងៃផុតកំណត់របស់លេខាធិការដ្ឋាននៃសិក្ខាសាលា។

តារាងខាងក្រោមសង្ខេបសំណើចំនួនប្រាំមួយទទួលបាន ដែលត្រូវបានរួមបញ្ចូលផងដែរនៅក្នុងឧបសម្ព័ន្ធ VII ទាំងស្រុង៖

## មជ្ឈមណ្ឌលបុប្ផាណា 09

- ដើម្បីបង្កើនការយល់ដឹងរបស់យុវជនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការប្រើប្រាស់បទពិសោធន៍អប់រំពហុប្រព័ន្ធផ្សព្វផ្សាយប្រកបដោយភាពច្នៃប្រឌិត ផ្អែកលើគម្រោង ដែលជំរុញឱ្យមានការស្វែងរកការពិត និងការសន្ទនាអន្តរជំនាន់ ដើម្បីជំរុញការផ្សះផ្សា ការព្យាបាល និងយុត្តិធម៌អន្តរកាល ស្របតាមគោលដៅរបស់ អ.វ.ត.ក និងក្រសួងអប់រំ។

## មជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក MICHAEL KARNAVAS ០២

- ការផ្តល់គ្រោងការណ៍ទូទាំងប្រទេសនៃការថែទាំសុខភាព និងការថែទាំសុខភាពផ្លូវចិត្តសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម (Michael Karnavas នៅក្នុងកាសែតដែលបោះពុម្ពដោយ DC-Cam)
- ការអភិរក្សទីតាំងឧក្រិដ្ឋកម្មប្រវត្តិសាស្ត្រ ជាមូលដ្ឋានសម្រាប់ការចងចាំ និងការអប់រំ (DC-Cam)

## អង្គការក្តីករុណា ០៣

- ការបង្កើតមជ្ឈមណ្ឌលចងចាំ និងសិក្សា ដើម្បីផ្តល់កន្លែងសម្រាប់ការសិក្សា ការឆ្លុះបញ្ចាំង និងការព្យាបាលសម្រាប់ក្រុមគោលដៅជាច្រើនដូចជា ជនរងគ្រោះ និងយុវជនជំនាន់ក្រោយ សិស្សានុសិស្ស និងគ្រូបង្រៀន អង្គការដែលធ្វើការលើយុត្តិធម៌អន្តរកាល អ្នកស្រាវជ្រាវ អ្នកសារព័ត៌មាន និងសាធារណជនទូទៅ។

## TSGM ០៤

- តម្រាយផ្លូវចងចាំ សម្រាប់និស្សិតសាកលវិទ្យាល័យ ទស្សនាទួលស្លែង ជើងឯក អ.វ.ត.ក/អិលឌីស៊ី និង ម-១៣
- កម្មវិធីយុវជនជាតិស្តីពីការស្វែងយល់អំពីរបបខ្មែរក្រហម
- គូសផែនទីទីតាំងខ្មែរក្រហមនៅកម្ពុជា
- ការគាំទ្រនៃការស្រាវជ្រាវ S-21 នៅ TSGM
- មជ្ឈមណ្ឌលអ្នកទស្សនា និងការិយាល័យនៅ TSGM

## យុវជនដើម្បីសន្តិភាព ០៥

- ការអភិរក្សទីតាំងប្រវត្តិសាស្ត្រខ្មែរក្រហមនៅអតីតភូមិភាគពាយ័ព្យ តាមរយៈការផ្សះផ្សា អនុស្សាវរីយ៍ និងការអប់រំ។ នេះផ្តល់ឱកាស និងទីកន្លែងដើម្បីភ្ជាប់ទំនាក់ទំនងជាមួយអតីតកាលឡើងវិញ ចែករំលែកបទពិសោធន៍ និងបង្កើតការសន្ទនាបើកចំហ។

## ● អង្គការអភិវឌ្ឍន៍ធនធានយុវជន ០៦

- ចក្ខុវិស័យប្រកបដោយនិរន្តរភាពកាន់តែខ្លាំងឡើងក្នុងរយៈពេលដប់ឆ្នាំ គួរតែត្រូវបានគិតគូរ និងសម្របសម្រួល ជាដំបូងដោយ អ.វ.ត.ក មុននឹងផ្លាស់ប្តូរទៅកាន់ទីភ្នាក់ងារពាក់ព័ន្ធបំផុតរបស់អង្គការសហប្រជាជាតិ ជាមួយនឹងអាណត្តិសម្របសម្រួល នៅពេលដែល អ.វ.ត.ក បញ្ចប់។ ប្រហែលជាការិយាល័យអ្នកសម្របសម្រួល។
- រចនាសម្ព័ន្ធមូលនិធិអន្តរកាល រួមទាំងការផ្លាស់ប្តូរថវិកាបន្តិចម្តងៗ និងមួយផ្នែកដល់រាជរដ្ឋាភិបាលកម្ពុជាលើប្រធានបទមួយចំនួន។

សំណើបានទទួលបន្ទាប់ពីសិក្ខាសាលា ជាទូទៅ ផ្អែកលើគំនិត និងការពិភាក្សានៅក្នុងពេលសិក្ខាសាលា។ សំណើទាំងអស់បានទទួលពីអ្នកចូលរួមយ៉ាងសកម្មក្នុងសិក្ខាសាលារយៈពេល ០៣ថ្ងៃ ហើយបានផ្អែកលើគំនិតមួយចំនួនដែលត្រូវបានស្នើឡើងក្នុងអំឡុងពេលព្រឹត្តិការណ៍នេះ។ នេះគឺជាការលើកទឹកចិត្ត ដោយសារសំណើទាំងនេះបង្ហាញសក្តានុពលនៃការសហការដ៏អស្ចារ្យរវាងអង្គការដែលស្នើសំណូមពរទាំងនោះ។ ពួកគេក៏បានលើកឡើងអំពីចំណុចសំខាន់ៗមួយចំនួនដែលត្រូវបានគូសបញ្ជាក់តាំងពីការចាប់ផ្តើមនៃដំណើរការនេះ នៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍ និងតាមរយៈវគ្គសិក្ខាសាលា។

# ០១

## សំណើរបស់បុប្ផាណា ផ្តោតលើការបង្កើនចំណេះដឹងដល់យុវជនជំនាន់ក្រោយនៅកម្ពុជា ដែលកើតក្រោយការដួលរលំរបបខ្មែរក្រហម ហើយបានដឹងតិចតួចអំពីរបបនោះ និងខ្វះប្រភព និងគំនិតផ្តួចផ្តើមសម្រាប់ការសិក្សា។



និស្សិតខ្មែរ ចូលរួមក្នុងពេលតុលាការធ្វើសេចក្តីសន្និដ្ឋានបិទ ក្នុងសំណុំរឿង០០២/០២។

គោលបំណងនៃគម្រោងរបស់ពួកគេគឺដើម្បីបង្កើនការយល់ដឹងរបស់យុវជនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការប្រើប្រាស់បទពិសោធន៍អប់រំប្រព័ន្ធផ្សព្វផ្សាយចំរុះប្រកបដោយភាពច្នៃប្រឌិតផ្អែកលើគម្រោង ដែលជំរុញឱ្យមានការស្វែងរកការពិត និងការសន្ទនាអន្តរជំនាន់ សំដៅជំរុញការផ្សះផ្សា ការព្យាបាលរបួស និងយុត្តិធម៌អន្តរកាល ស្របតាមគោលដៅរបស់ អ.វ.ត.ក និង MOEYS។ ជាពិសេស ពួកគេចង់បំពេញការងារនេះដោយបង្កើតបណ្ណសារសាធារណៈបើកចំហ ដែលមានការចូលរួមអន្តរសកម្មនៅក្នុងកម្មវិធីប្រវត្តិសាស្ត្រខ្មែរក្រហមមានស្រាប់របស់ បុប្ផាណា សំដៅជំរុញការសន្ទនាអន្តរជំនាន់រវាងយុវជន និងអ្នករស់រានមានជីវិត។ ពួកគេក៏បានកំណត់អំពីតម្រូវការធ្វើបច្ចុប្បន្នភាព និងធ្វើកំណែកម្មវិធីស្មាតហ្វូន ដែលជាគម្រោងសំណងទទួលស្គាល់ក្នុងសំណុំរឿង 002/02 ពោលគឺ ដើម្បីបង្កើនការចូលរួមរបស់អ្នកប្រើប្រាស់។ លើសពីនេះ បុប្ផាណា បានកំណត់ឱកាសបណ្តុះបណ្តាលយុវជនកម្ពុជាក្នុងការផលិតភាពយន្តឯកសារ និងប្រព័ន្ធផ្សព្វផ្សាយចំរុះប្រកបដោយភាពច្នៃប្រឌិត និងផ្តល់ឱ្យពួកគេនូវការយល់ដឹងស៊ីជម្រៅអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការចូលរួម និងចងក្រងឯកសារអតីតកាលតាមរយៈការសន្ទនាអន្តរជំនាន់ និងការសន្ទនានៅតាមសហគមន៍។ ចំណុចចុងក្រោយដើម្បីបង្កើនការប្រើប្រាស់កម្មវិធីប្រវត្តិសាស្ត្រខ្មែរក្រហម និងវេទិកាបណ្ណសារសាធារណៈ ពួកគេស្នើឱ្យដំណើរការការផ្សព្វផ្សាយទ្រង់ទ្រាយធំ និងការបណ្តុះបណ្តាលគ្រូបង្រៀន និងសិស្ស-និស្សិតវិទ្យាល័យ និងសាកលវិទ្យាល័យ តាមរយៈសិក្ខាសាលា និងគំនិតផ្តួចផ្តើមការអប់រំតាមទូរស័ព្ទនៅទូទាំងប្រទេសកម្ពុជា ដោយសង្កត់ធ្ងន់ជាពិសេសលើសហគមន៍ជនជាតិដើមភាគតិច។

បុប្ផាណា បានកំណត់លទ្ធផលរំពឹងទុកចំនួន ០៤ នៅក្នុងសំណើនេះ៖ ទីមួយ វេទិកាបណ្ណសារសាធារណៈដែលមានការចូលរួម ត្រូវបានបង្កើតឡើងនៅលើកម្មវិធីប្រវត្តិសាស្ត្រខ្មែរក្រហម។ និងទីពីរ ការបង្កើតសំណួរចំនួន ៤០០ និងការជូនដំណឹងចំនួន ១៥០ សម្រាប់កម្មវិធីដោយផ្អែកលើកាលបរិច្ឆេទ និងគេហទំព័រប្រវត្តិសាស្ត្រ។ វីដេអូខ្លីៗ និងសៀវភៅមគ្គុទ្ទេសក៍ឌីជីថលនឹងផ្តល់ការណែនាំអំពីរបៀបប្រើប្រាស់បណ្ណសារ របៀបចូលរួមការសន្ទនាអន្តរជំនាន់ និងផលិតឯកសារនៃការសន្ទនាដើម្បីដាក់បញ្ចូលក្នុងបណ្ណសារ។ លទ្ធផលរំពឹងទុកទីបីគឺការផលិតវីដេអូចំនួន ៣០ អំពីកិច្ចសន្ទនាអន្តរជំនាន់ របាយការណ៍ស្រាវជ្រាវអំពីកន្លែងឧក្រិដ្ឋកម្មចំនួន ០៦ និងភាពយន្តឯកសារខ្លីចំនួន ១៥ អំពីប្រវត្តិសាស្ត្រ

ខ្មែរក្រហម ដែលផលិតដោយសិស្សផលិតករភាពយន្តចំនួន ១៥នាក់ បន្ទាប់ពីបានបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់រយៈពេលវែងដោយប៉ុប្បាណា និងអង្គការយុវសន្តិភាព។ ភាពយន្តយុវជនទាំងនេះនឹងត្រូវបានប្រើជាឧបករណ៍សម្រាប់កិច្ចសន្ទនាសហគមន៍។ ទី៤ ប៉ុប្បាណា មានបំណងរៀបចំសិក្ខាសាលាបណ្តុះបណ្តាលគ្រូចំនួន ២៤០នាក់ មកពីសាលាចំនួន ១២០ ក្នុងការប្រើប្រាស់បណ្ណសារសាធារណៈរបស់កម្មវិធី និងសម្រាប់ក្រុមអប់រំចល័តដើម្បីធ្វើយុទ្ធនាការផ្សព្វផ្សាយ ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន ១២.០០០ នាក់ លើការងារប្រើប្រាស់បណ្ណសារសាធារណៈ។ ការងារនេះនឹងអនុញ្ញាតឱ្យពួកគេទទួលបានសំណើយ៉ាងហោចណាស់ ១,២០០ នៃខ្លឹមសារផលិតដោយសិស្ស កើតចេញពីការសន្ទនាជាមួយសមាជិកគ្រួសារ និង/ឬសហគមន៍ ដែលបានបង្ហោះទៅក្នុងបណ្ណសារសាធារណៈ។

○

# ០២

## DC-CAM បានដាក់សំណើជាទម្រង់ក្រដាសសរសេរដោយលោក MICHAEL KARNAVAS អតីតមេធាវីការពារក្ដីនៅ អ.វ.ត.ក ឱ្យ អៀង សារី និង មាស មុត អំពីការផ្ដល់សំណងដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មខ្មែរក្រហម ជាមួយនឹងការថែទាំសុខភាពប្រកបដោយនិរន្តរភាព តាមរយៈសំណង ឬគោលការណ៍យុត្តិធម៌អន្តរកាល។



លោក ផៃ ហ៊ាប ដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តពោធិ៍សាត់ ចូលរួមក្នុងសិក្ខាសាលាស្ដីពីជនរងគ្រោះ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២។

ឥទ្ធិពលនៃសម័យកាល DK មកលើប្រជាជនកម្ពុជា និងប្រព័ន្ធថែទាំសុខភាពនៅតែបន្តរហូតមកដល់សព្វថ្ងៃនេះ។ រាជរដ្ឋាភិបាលនៅតែពឹងផ្អែកលើការផ្ដល់មូលនិធិពីបរទេសសម្រាប់ការផ្ដល់សេវាសុខភាពគ្រប់គ្រាន់ ហើយជាអកុសលគុណភាពនៃសេវាថែទាំសុខភាព ជាពិសេសនៅតំបន់ជនបទនៅតែមានកម្រិតទាប ជាមួយនឹងវិសមភាពធំធេងនៅបន្តកើតឡើង។

ឯកសារនេះលើកឡើងអំពីសិទ្ធិដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់ជនរងគ្រោះនៃអំពើឃោរឃៅដ៏ធំធេងតាមរយៈសំណងបុគ្គល ឬសមូហភាព ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិ និងសាលាក្ដីមិនអាចបង្គាប់ការផ្ដល់សេវាថែទាំសុខភាពជាវិធានការសំណង ដោយសារតែភាពព្រងើយកន្តើយរបស់ជនជាប់ចោទ។ ដូច្នេះ ការថែទាំសុខភាពសម្រាប់ជនរងគ្រោះនៅក្នុងប្រទេសកម្ពុជាគឺមានភាពប្រាកដនិយមជាង ដែលជាវិធានការយុត្តិធម៌អន្តរកាលដាច់ដោយឡែកមួយ។ ដើម្បីឱ្យមាននិរន្តរភាព កម្មវិធីនេះមិនចាំបាច់ដឹកនាំដោយរដ្ឋទេ ប៉ុន្តែទាមទារជំនួយពីរដ្ឋ ហើយអង្គការមិនមែនរដ្ឋាភិបាលក៏ដើរតួនាទីសំខាន់ផងដែរ។ ដូច្នេះ តាមសំណើ ដំបូង ចាំបាច់ត្រូវមានការវាយតម្លៃលើតម្រូវការ និងភាពជាដៃគូ ហើយត្រូវបង្កើតរួមជាមួយអង្គការដែលផ្ដល់សេវាសុខភាពផ្លូវចិត្តនៅកម្ពុជា (ដូចជា TPO)។ ឯកសារនេះក៏កត់សម្គាល់ផងដែរថា រឿងសំខាន់គឺត្រូវពិចារណាអំពីរបៀបដែលប្រជាជនកម្ពុជាស្វែងរកជំនួយសម្រាប់ខ្លួន ហើយដើម្បីធ្វើការងារនេះ ត្រូវបញ្ចូលវិធីប្រពៃណី និងខាងស្មារតីនៃការដោះស្រាយរបួសផ្លូវចិត្ត ដើម្បីឱ្យសេវាអាចសម្របតាមការយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីសុខភាព។ សំណើនេះក៏ស្នើឱ្យបង្កើតកម្មវិធីបណ្ដុះបណ្ដាលសុខភាពផ្លូវចិត្តជាក់លាក់អំពីខ្មែរក្រហម ឧទាហរណ៍ ដោយផ្ដល់សិក្ខាសាលា និងថ្នាក់រៀនដោយឥតគិតថ្លៃស្ដីពីជំនួយសុខភាពផ្លូវចិត្តជាមូលដ្ឋាន។ កម្មវិធីទាំងនេះក៏គួរតែបញ្ចូលសមាសធាតុអប់រំដល់ពួកគេ ដើម្បីជូនដំណឹងដល់ជនរងគ្រោះអំពីសិទ្ធិទទួលបានអត្ថប្រយោជន៍ អំពីរបួសដែលជនរងគ្រោះផ្សេងទៀតប្រឈមមុខ និងតម្លៃនៃការបង្ហាញតម្រូវការរបស់ពួកគេឱ្យមន្ត្រីថែទាំសុខភាពបានដឹង។

ដោយឡែក មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានដាក់សំណើជាលាយលក្ខណ៍អក្សររបស់លោក ឆាំង យុ ផងដែរ ស្នើសុំឱ្យសាងសង់ស្តូបអនុស្សាវរីយ៍ខ្មែរក្រហម នៅជិតវិមានឯករាជ្យ ក្នុងរាជធានីភ្នំពេញ។

# ០៣

## សំណើដាក់ជូនដោយ ក្ដីករុណា គឺសុំឱ្យមានមជ្ឈមណ្ឌលចងចាំ និងសិក្សាសម្រាប់គំនិតផ្ដួចផ្ដើមសង្គមស៊ីវិល។



លោក ទឹម មិនា នាយកប្រតិបត្តិអង្គការក្ដីករុណា ធ្វើបទបង្ហាញទៅកាន់សិក្ខាកាម នៅថ្ងៃទី២ នៃសិក្ខាសាលា។

ដោយបានដឹងថា អ.វ.ត.ក កំពុងដំណើរការបង្កើតមុខងារដែលនៅសេសសល់របស់ខ្លួន ហើយដំណើរការតុលាការកំពុងឈានទៅដល់ទីបញ្ចប់ KDK បានកំណត់តម្រូវការសម្រាប់ដំណើរការក្រៅប្រព័ន្ធតុលាការចំពោះសំណងដើម្បីបន្តអត្ថិភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា។ បង្កើតចេញពីតម្រូវការដែលបានលើកឡើងក្នុងសិក្ខាសាលា KDK បានកំណត់ថា អ្នកនៅរស់រានមានជីវិតនៅតែត្រូវចែករំលែកបទពិសោធន៍របស់ពួកគេ ហើយបន្តរងទុក្ខពីបទពិសោធន៍នៃភាពស្ងៀមស្ងាត់របស់ពួកគេកន្លងមក។ ចំណុចនេះបណ្ដាលឱ្យមានអាកប្បកិរិយាមួយ ដែលជារឿយៗក្មេងជំនាន់ក្រោយមិនយល់ ដូច្នេះចាំបាច់ត្រូវបិទគម្លាតនៃចំណេះដឹង និងការយោគយល់គ្នាទៅវិញទៅមករវាងអ្នកនៅរស់ និងមនុស្សជំនាន់ក្រោយ។ យុវជនក៏ត្រូវកសាងសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីចាប់ផ្ដើមសន្ទនាជាមួយអ្នករស់រានមានជីវិតអំពីអ្វីដែលបានកើតឡើងនៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ ហើយទោះបីជាយុវជនចាប់អារម្មណ៍ក្នុងការស្វែងយល់ពីអតីតកាលក៏ដោយ ក៏ពួកគេស្ទាក់ស្ទើរក្នុងការជជែកសន្ទនានៅក្នុងគ្រួសាររបស់ពួកគេ។ KDK បានកត់សម្គាល់ថា អ្នករស់រានមានជីវិតបានបង្ហាញតម្រូវការឱ្យមានកន្លែងចងចាំនៅខេត្តរបស់ពួកគេ និងបំណងប្រាថ្នាចង់រក្សាអគារ អ.វ.ត.ក ទុកជាអនុស្សាវរីយ៍សម្រាប់ការសិក្សាក្នុងស្រុក និងអន្តរជាតិ។ សំណងផ្ទាល់នៅកម្រិតបុគ្គលក៏ត្រូវបានកំណត់ផងដែរ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅ ការថែទាំវេជ្ជសាស្ត្រ និងផ្លូវចិត្ត។ អ្នករស់រានមានជីវិតក៏បង្ហាញតម្រូវការចង់ឱ្យជួសជុលផលប៉ះពាល់អវិជ្ជមានលើជំនាន់ទី ២ និងទី ៣ ផងដែរ ឧទាហរណ៍ តាមរយៈការគាំទ្រការអប់រំវិជ្ជាជីវៈល្អ និងសន្តិសុខការងារ។ តម្រូវការក្នុងការផ្ដោតលើការមិនកើតឡើងវិញតាមទស្សនៈក្នុងស្រុកក៏ត្រូវបានកំណត់អត្តសញ្ញាណផងដែរ ដើម្បីការពារប្រវត្តិសាស្ត្រពីការកើតឡើងម្ដងទៀត។ ដោយទទួលស្គាល់ថា ខណៈពេលដែលប្រវត្តិសាស្ត្រផ្ទាល់មាត់ជាច្រើនត្រូវបានប្រមូល នៅតែមានតម្រូវការក្នុងការចងក្រងនូវបទពិសោធន៍អ្នករស់រានមានជីវិត ដែលបានលាក់បាំង ដូចជាបទពិសោធន៍ពីក្រុមងាយរងគ្រោះ និងពីអតីតកម្មាភិបាលខ្មែរក្រហម ក៏ដូចជាផលប៉ះពាល់លើកូន និងចៅរបស់ពួកគេ។

គោលបំណងនៃការបង្កើតមជ្ឈមណ្ឌលចងចាំ និងមជ្ឈមណ្ឌលសិក្សាគឺផ្ដល់កន្លែងសម្រាប់សិក្សា ឆ្លុះបញ្ចាំង និងព្យាបាលដល់ក្រុមគោលដៅមួយចំនួន ជាពិសេស ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ យុវជនកម្ពុជា សិស្ស គ្រូបង្រៀន អ្នក

រៀបចំ អ្នកស្រាវជ្រាវ និងអ្នកសារព័ត៌មាន និងសាធារណជនទូទៅ។ KDK ក៏បានរៀបចំវគ្គពិគ្រោះយោបល់ចំនួនពីរលើសំណើគម្រោងនេះកាលពីពេលថ្មីៗ ជាមួយនឹងក្រុមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាមួយក្រុមអង្គការមិនមែនរដ្ឋាភិបាល និងអង្គការរដ្ឋ ដែលការពិគ្រោះយោបល់ទាំងពីរនេះបាននាំមកនូវមតិវិជ្ជមានសម្រាប់ការបង្កើតមជ្ឈមណ្ឌលបែបនេះ។ អង្គការជាច្រើនបានបង្កើតក្រុមការងារសម្រាប់សំណើនេះ ហើយសមាជិកក្រុមការងាររួមមាន KDK, TSGM, CKGC និង YFP។ GIZ-Civil Peace Service កំពុងគាំទ្រដំណើរការអភិវឌ្ឍបង្កើតមជ្ឈមណ្ឌលចងចាំនិងសិក្សា។

មជ្ឈមណ្ឌលនេះអាចផ្តល់កន្លែងសម្រាប់ចងក្រងឯកសារ និងការស្រាវជ្រាវ ដូចជា កន្លែងរក្សាទុកប្រវត្តិរឿងរ៉ាវផ្ទាល់មាត់ជាង ១០០ ដែល KDK បានប្រមូលតាមរយៈគម្រោងអន្តរជំនាន់របស់ពួកគេ ដែលអាចឱ្យសាធារណជន សិស្ស និស្សិត និងអ្នកស្រាវជ្រាវចូលមើល។ KDK ផ្តល់យោបល់បន្ថែមថា មជ្ឈមណ្ឌលបែបនេះអាចគាំទ្រអ្នកដទៃក្នុងវិធីសាស្ត្រ និងការអនុវត្តប្រវត្តរឿងរ៉ាវផ្ទាល់មាត់ដោយប្រើឧបករណ៍ និងការអនុវត្តផ្សេងៗ រួមទាំងវិធីសាស្ត្រផ្អែកលើសិល្បៈ និងវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ក្នុងប្រទេសកម្ពុជា។ មជ្ឈមណ្ឌលនេះក៏នឹងក្លាយជាកន្លែងសម្រាប់ការតាំងពិព័រណ៍ និងការរៀនសូត្រ និងជាកន្លែងសម្រាប់ការតាំងពិពណ៌ចល័តរបស់ KDK និងការតាំងបង្ហាញធនធានដោយអង្គការដែលលែងមានវត្តមានទៀតហើយមកដល់ពេលនេះ។ ជាចុងក្រោយ ទីតាំងនឹងត្រូវបានប្រើសម្រាប់ការសន្ទនា និងការឆ្លុះបញ្ចាំងតាមរយៈការងារកិច្ចសន្ទនាអន្តរជំនាន់ ហើយ KDK ចង់ឱ្យមជ្ឈមណ្ឌលចងចាំ និងសិក្សាដែលផ្តល់មូលដ្ឋានសម្រាប់ការសម្របសម្រួលដំណើរការសន្ទនានៅទូទាំងប្រទេស។ ក្រុមមកពីទូទាំងប្រទេសកម្ពុជាអាចទស្សនាមជ្ឈមណ្ឌល និងចូលរួមក្នុងសកម្មភាពសន្ទនាដែលដឹកនាំដោយអ្នកសម្របសម្រួលដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។ មជ្ឈមណ្ឌលចងចាំ និងសិក្សាក៏អាចផ្តល់កន្លែងជួបប្រជុំសម្រាប់អ្នកសម្របសម្រួលការសន្ទនាតាមសហគមន៍ផងដែរ។

ពួកគេបានកំណត់ពេលវេលាគម្រោងរហូតដល់ ០២ឆ្នាំ កម្មវិធីផ្សព្វផ្សាយសម្រាប់រយៈពេល ០៣ ឆ្នាំ និងថវិកាប៉ាន់ស្មានចំនួន ១,៥លានដុល្លារក្នុងរយៈពេល ០៣ឆ្នាំ។

# ០៤

**TSGM បានដាក់សំណើចំនួនប្រាំនៅក្នុងខែឧសភា បន្ទាប់ពីសិក្ខាសាលាជនរងគ្រោះ។ យើងពណ៌នាដោយសង្ខេបនូវសំណើទាំងប្រាំ។**



ប្រជាជនជាង៣០០នាក់ មកពីប៉ៃលិនអតីតតំបន់ឈរជើងរឹងមាំរបស់ខ្មែរក្រហម ធ្វើទស្សនកិច្ចសារៈមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និង អ.វ.ត.ក នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១០។

សំណើទីមួយមានចំណងជើងថា "ការបង្កើតផែនទីទីតាំងខ្មែរក្រហមនៅកម្ពុជា"។ នៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០ សាកលវិទ្យាល័យ Yale និងក្រោយមក DC-Cam បានធ្វើគម្រោងផែនទីរយៈពេលវែង ដើម្បីចងក្រងព័ត៌មានអំពីពន្ធនាគារខ្មែរក្រហម ផ្នូររួម និងកន្លែងរំលឹកវិញ្ញាណក្ខន្ធ។ មូលដ្ឋានទិន្នន័យនេះមិនត្រូវបានធ្វើបច្ចុប្បន្នភាពចាប់តាំងពីឆ្នាំ២០០៥ មក។ អតីតពន្ធនាគារ ឬទីតាំងមួយចំនួនដែលទាក់ទងនឹងខ្មែរក្រហមត្រូវបានស្គាល់ និងយកចិត្តទុកដាក់ដោយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជា DC-Cam (អន្លង់វែង) និង YFP (ក្រាំងតាចាន់)។ MCFA បានសម្រេចបង្កើតផ្នែកមួយនៅក្នុងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដើម្បីមើលការខុសត្រូវទីតាំងប្រវត្តិសាស្ត្រខ្មែរក្រហមនៅទូទាំងប្រទេស។ ទីតាំងល្បីជាងគេគឺអតីតគុក ម-១៣ នៅអមលាំង ខេត្តកំពង់ស្ពឺ។ រដ្ឋាភិបាលបានទទួលស្គាល់សារៈសំខាន់ថ្នាក់ជាតិនៃទីតាំងទាំងនេះ ដោយបានអនុម័តលើការដាក់ពាក្យសុំទទួលស្គាល់ទីតាំងអតីត ម-១៣ (ក្រោម TSGM) សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ដើម្បីចុះបញ្ជីរួមគ្នាជាសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។ ទោះជាយ៉ាងណាក៏ដោយ ថ្មីៗនេះ មិនទាន់មានការព្យាយាមចុះឈ្មោះកន្លែងផ្សេងទៀតទាក់ទងនឹងអតីតខ្មែរក្រហមនោះទេ។ ទីតាំងទាំងនេះជាច្រើនស្ថិតក្នុងសភាពទ្រុឌទ្រោម ហើយមិនអាចមើលស្គាល់បានទៀតទេ។ វិធីសាស្ត្រនាពេលមុនធ្វើការកំណត់ទីតាំងឧក្រិដ្ឋកម្ម និងការសម្លាប់ ត្រូវពង្រីកបន្ថែម។ ដើម្បីជំរុញការយល់ដឹងអំពីសម័យខ្មែរក្រហម កន្លែងផ្សេងទៀតដូចជាទំនប់ទឹក កន្លែងហូបរួម ព្រលានយន្តហោះ និង "កន្លែងផលិត" ចាំបាច់ត្រូវបញ្ចូលជាគំរូ។ ទីតាំងសំខាន់ៗពាក់ព័ន្ធខ្មែរក្រហមចាំបាច់ត្រូវចុះបញ្ជី និងការពារជាទីតាំងបេតិកភណ្ឌជាតិ។ ដូច្នេះគម្រោងដែលបានស្នើឡើងនឹងសហការជាមួយសហគមន៍មូលដ្ឋាននៅក្នុងតំបន់ជុំវិញទីតាំងពាក់ព័ន្ធ សហការជាមួយលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សដែលនៅជិតទីតាំងទាំងនេះ និងអង្គការមិនមែនរដ្ឋាភិបាលដែលចាប់អារម្មណ៍ ដើម្បីចូលរួមក្នុងការគូសផែនទី និងការងារស្រាវជ្រាវ។ TSGM ក៏បានកំណត់អត្តសញ្ញាណដៃគូពាក់ព័ន្ធផ្សេងទៀតដូចជា MCFA គណៈកម្មាធិការជាតិយូណេស្កូ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតដែលធ្វើការក្នុង

វិស័យនេះ ជាពិសេស KDK និង YFP។ ពេលវេលាកំណត់របស់គម្រោងនេះគឺជាការប៉ាន់ប្រមាណរយៈពេលប្រាំមួយខែសម្រាប់ដំណាក់កាលរៀបចំ និងបីឆ្នាំទៀតសម្រាប់ដំណាក់កាលធ្វើផែនទីជាមួយនឹងថវិកាប៉ាន់ស្មានចំនួន $១៥០,០០០ ក្នុងរយៈពេលបីឆ្នាំ។ គោលដៅរយៈពេលវែងគឺមិនត្រឹមតែបង្កើនចំណេះដឹងអំពីសម័យខ្មែរក្រហម និងគាំទ្រចំណេះដឹងតាមមូលដ្ឋានអំពីសម័យកាលនោះនិងបង្កើតបញ្ជីជាតិនៃទីតាំងពាក់ព័ន្ធខ្មែរក្រហម និងគាំទ្រដល់ការអភិរក្សទីតាំង។

សំណើទីពីរមានចំណងជើងថា គម្រោងផ្លូវចងចាំ (Memory Trail Project) ក្នុងគោលបំណងដើម្បីចូលរួមក្នុងការអភិរក្សទីតាំងប្រវត្តិសាស្ត្រដែលបន្សល់ទុកពីរបបខ្មែរក្រហម។ TSGM បានរៀបចំសិក្ខាសាលាមួយក្រោមប្រធានបទ "ផ្លូវចងចាំ" ក្នុងគោលបំណងបំផុសគំនិតយុវជនជំនាន់ក្រោយឱ្យស្វែងយល់អំពីតម្លៃនៃការថែរក្សាកន្លែងឃុំឃាំងដែលឆ្លុះបញ្ចាំងពីភាពឃោរឃៅនៃរបបខ្មែរក្រហម។ គម្រោងនេះគឺជាផ្នែកមួយនៃការលើកទឹកចិត្តដល់ការចូលរួមរបស់ប្រជាជនក្នុងសហគមន៍មូលដ្ឋានក្នុងការអភិរក្សប្រវត្តិសាស្ត្រ។ ទីតាំងអតីតគុក ឬវាលពិឃាត ទទួលស្គាល់ពីសារៈសំខាន់នៃការអភិរក្ស ហើយប្រែក្លាយវាទៅជាវិមានសម្រាប់ការអប់រំរបស់សិស្សានុសិស្សក្នុងសហគមន៍មូលដ្ឋានរបស់ពួកគេ។ គោលបំណងនៃគម្រោងនេះគឺដើម្បីអប់រំយុវជនអំពីអ្វីដែលបានកើតឡើងក្នុងសម័យ DK និងដើម្បីលើកទឹកចិត្តយុវជនឱ្យយល់ពីសារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រនេះ ហើយចូលរួមក្នុងការសិក្សា និងការយល់ដឹងបែបនេះ។ សំណើនេះនឹងផ្តោតលើនិស្សិតសាកលវិទ្យាល័យចំនួន ១៥ មកពីមហាវិទ្យាល័យប្រវត្តិសាស្ត្រ អក្សរសាស្ត្រខ្មែរ និងបុរាណវិទ្យា ជាអ្នករៀបចំសិក្ខាសាលា ហើយក្រុមគោលដៅជានិស្សិតវិទ្យាល័យ។ ដៃគូសំខាន់ៗដែលត្រូវបានកំណត់អត្តសញ្ញាណរួចហើយគឺ អ.វ.ត.ក និង LDC, CKGC និងសាលានិងសាកលវិទ្យាល័យចម្រុះ។ គោលបំណងគម្រោងគឺថា ផ្លូវចងចាំនឹងត្រូវធ្វើឡើងក្នុងអំឡុងពេលវិស្សមកាលសិក្សា ហើយនឹងមានសិក្ខាសាលារយៈពេលពីរថ្ងៃគ្របដណ្តប់ប្រវត្តិសាស្ត្រខ្មែរក្រហម និងមន្ទីរ ស-២១ និងដំណើរទស្សនកិច្ចសិក្សារយៈពេលពីរថ្ងៃទៅកាន់ TSGM ដែលជាវាលពិឃាត នៅជើងឯក អ.វ.ត.ក និង LDC និង ម-១៣។ គោលបំណងនៃគម្រោងគឺធ្វើសិក្ខាសាលាចំនួនបីក្នុងមួយឆ្នាំ ក្នុងរយៈពេលបីឆ្នាំ។ ថវិកាប៉ាន់ស្មានគឺ ១៥០,០០០ដុល្លារអាមេរិក ក្នុងរយៈពេលបីឆ្នាំ។

សំណើទី៣ មានចំណងជើងថា "ការគាំទ្រការស្រាវជ្រាវទាក់ទងមន្ទីរ ស-២១ នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង"។ អ.វ.ត.ក បានបន្ថែមចំណេះដឹងបន្ថែមជាច្រើនអំពី ស-២១ តាមរយៈសំណុំរឿង ០០១ និង ០០២។ ចំណេះដឹងនេះមិនទាន់អាចទទួលបានពេញលេញសម្រាប់ក្រុមនៅ TSGM នៅឡើយទេ។ ថ្វីត្បិតតែបណ្ណសាររបស់សារមន្ទីត្រូវបានបំប្លែងជាឌីជីថល និងផ្សព្វផ្សាយដោយគម្រោងមូលនិធិរបស់អង្គការយូណេស្កូ-KOICA ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២០ ហើយបច្ចុប្បន្នបណ្ណសារអាចចូលមើលតាមអ៊ីនធឺណិតសម្រាប់ក្រុម TSGM ដើម្បីប្រើប្រាស់ផ្ទៃក្នុង ប៉ុន្តែយើងមិនដឹងចំនួនឯកសារសរុបដែលមន្ទីរសន្តិសុខ ស-២១ ផលិត។ ដូច្នេះ គេមិនដឹងថាភាគរយនៃឯកសារបាត់មានកម្រិតណានោះទេ។ រូបថតអ្នកទោសរាប់ពាន់សន្លឹកពី ស-២១ នៅ TSGM មិនទាន់ត្រូវបានពិនិត្យជាមួយជីវប្រវត្តិនៅឡើយ។ រហូតមកដល់ថ្ងៃនេះ TSGM មិនអាចប្រាប់សាច់ញាតិដែលកំពុងស្វែងរកសមាជិកគ្រួសារបានទេបើទោះជាមានរូបថតក្តី។ ទាំង អ.វ.ត.ក និង TSGM មិនអាចរៀបចំគម្រោងស្រាវជ្រាវឯកសារ ស-២១ ដែលបាត់នោះទេ។ ការងារនេះយឺតពេលវេលា ដោយសារសាក្សីកាន់តែចាស់ ឬ ទទួលមរណភាព។ ដើម្បីផ្តល់សិទ្ធិចូលប្រើប្រាស់ឯកសារកាន់តែច្រើន ដំណើរការកោសលុបក៏ចាំបាច់ត្រូវធ្វើឡើងផងដែរ។ ក្រុមនៅ TSGM ខ្វះចំណេះដឹងវិជ្ជាជីវៈអំពីរបៀបវិភាគរូបថត ឬរបៀបស៊ើបអង្កេតបន្ថែម។ ដូច្នេះគម្រោងនេះមានបំណងសហការជាមួយអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ ហើយនឹងដំណើរការក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ គេប៉ាន់ប្រមាណថា ដើម្បីសម្រេចបាននូវគោលដៅគម្រោងទាំងអស់ ក្រុមជាច្រើនដែលមានសមាជិក ២ ទៅ ៤ នាក់ ត្រូវការក្នុងរយៈពេល ០៣ឆ្នាំ។ ដូច្នេះ គម្រោងនេះនឹងរួមចំណែកនូវចំណេះដឹងបន្ថែមសំខាន់ៗ និងអនុញ្ញាតឱ្យកម្រងឯកសារសារមន្ទីត្រូវបានចែករំលែកកាន់តែប្រសើរឡើងជាមួយសាច់ញាតិរបស់ជនរងគ្រោះ ស-២១។ ចំណេះដឹងបន្ថែមនេះ និងការរក្សាទុកបណ្ណសារយូរអង្វែង គឺជាផលប្រយោជន៍ជាតិ និងអន្តរជាតិ។

សំណើទីបួនគឺការបង្កើតទីតាំងទទួលភ្ញៀវទស្សនា និងការិយាល័យនៅខាងក្រៅបរិវេណ TSGM។ សារមន្ទីរកំពុងខ្វះទីតាំងស្វាគមន៍ដ៏សមរម្យមួយសម្រាប់ភ្ញៀវទស្សនាជាតិ និងអន្តរជាតិ (មុនពេលជំងឺរាតត្បាត មានអ្នកទស្សនាប្រហែល ៥០០,០០០ នាក់ក្នុងមួយឆ្នាំ)។ ទីតាំងស្វាគមន៍នៅខាងក្រៅបរិវេណ TSGM បច្ចុប្បន្ន នឹងផ្តល់ឱកាសដើម្បីជូនដំណឹងដល់អ្នកទស្សនាក្នុងទំហំ

ធំជាងអតីតគុក ស-២១ ដើម្បីរៀបចំពួកគេក្នុងដំណើរទស្សនា និងផ្តល់កន្លែងជូនភ្ញៀវគ្រប់គ្រាន់ រួមទាំងហាងលក់សៀវភៅសមរម្យជាមួយឯកសារពាក់ព័ន្ធ។ នៅជាន់ខាងលើ អគារនេះអាចធ្វើជាការិយាល័យសម្រាប់បុគ្គលិក និងបន្ទប់ពិសោធន៍ការងារអភិរក្ស ដើម្បីកាត់បន្ថយការប្រើប្រាស់បន្ទប់អតីតគុកសម្រាប់តម្រូវការសារមន្ទីរ។ អ្នកគ្រប់គ្រង និងបុគ្គលិក TSGM បានធ្វើការនៅខាងក្នុងអតីតបន្ទប់គុកចាប់តាំងពីសារមន្ទីរបានបើកដំណើរការនៅឆ្នាំ១៩៧៩។ បញ្ហានេះមិនត្រឹមតែលំបាកសម្រាប់បុគ្គលិកប៉ុណ្ណោះទេ ប៉ុន្តែរាល់ការប្រើប្រាស់បន្ទប់សម្រាប់ការិយាល័យបច្ចុប្បន្ន ប្រថុយនឹងបំផ្លាញដានប្រវត្តិសាស្ត្រ និងជះឥទ្ធិពលលើសមត្ថភាពរបស់អ្នកទស្សនា អាចស្រមៃមើលសភាពទីតាំងនេះកាលពីសម័យជាគុក។ ដើម្បីដំណើរការសំណើ TSGM ស្នើធ្វើការជាមួយអង្គការយូណេស្កូ ព្រោះថា TSGM កំពុងដាក់ពាក្យស្នើសុំជ្រើសតាំងជាតំបន់បេតិកភណ្ឌពិភពលោក។ គម្រោងនេះក៏បានប៉ាន់ប្រមាណផងដែរនូវពេលវេលាប្រហាក់ប្រហែលរយៈពេល ០៣ឆ្នាំ ហើយតម្រូវឱ្យធ្វើការរួមគ្នាជាមួយអ្នកជិតខាងជុំវិញ TSGM ក្នុងការស្វែងរកដី ការសាងសង់អគារ និងរួមទាំងតំបន់ជិតខាងក្នុងការសម្រេចចិត្ត។ ថវិកាប៉ាន់ស្មានសម្រាប់គម្រោងនេះអាស្រ័យលើតម្លៃដី ទំហំ និងឧបករណ៍ដែលត្រូវការសម្រាប់ការសាងសង់ ប៉ុន្តែតាមការប៉ាន់ស្មាន មានតម្លៃពី ៣ ទៅ ៦លានដុល្លារ។

សំណើទីប្រាំរបស់ TSGM មានចំណងជើងថា "កម្មវិធីជាតិសម្រាប់ស្តីពីការរៀនសូត្រអំពីរបបខ្មែរក្រហម"។ ដោយមើលឃើញកម្ពុជាមានចំនួនយុវជនវ័យក្មេង ប្រជាជនជាច្រើនលែងមានអ្នករស់រានមានជីវិតនៅក្នុងគ្រួសាររបស់ពួកគេដើម្បីនិយាយអំពីអតីតកាល។ សូម្បីតែក្នុងករណីដែលមានក៏ដោយ មិនមែនអ្នករស់រានមានជីវិតទាំងអស់មានឆន្ទៈនិយាយអំពីអ្វីដែលបានកើតឡើងនៅក្រោម DK នោះទេ។ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានកំណត់ត្រឹមតែពីរបីម៉ោងប៉ុណ្ណោះក្នុងកម្មវិធីសិក្សារបស់សាលា។ បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា កំពុងកែសម្រួលសៀវភៅសិក្សាប្រវត្តិសាស្ត្រ ក្នុងគោលបំណងបន្ថែមព័ត៌មានអំពីសម័យខ្មែរក្រហម ប៉ុន្តែនេះជាគម្រោងរយៈពេលវែង។ ដូច្នេះ យុវជនជាច្រើនមិនទទួលបានព័ត៌មានគ្រប់គ្រាន់អំពីសម័យខ្មែរក្រហម រួមទាំងចំណេះដឹងអំពីស-២១ និងប្រព័ន្ធគុកទាំងមូល ឬអំពីដំណើរការតុលាការនៅ អ.វ.ត.ក។ ក្នុងករណីដែលគ្រូចង់ចូលរួមបង្រៀនសិស្សឱ្យបានល្អបំផុតតាមដែលអាចធ្វើបាន ពួកគេខ្វះមធ្យោបាយធ្វើដំណើរ ឬថវិកាក្នុងការរៀបចំការធ្វើដំណើរមកទីក្រុងភ្នំពេញ ដើម្បីទៅទស្សនា TSGM, CKGC និង អ.វ.ត.ក (ឬក្រោយមក LDC ឬមជ្ឈមណ្ឌលសិក្សារបស់ខ្មែរក្រហមនៅរាជធានី ឬ ក្នុងតំបន់)។ ដំណើរទស្សនកិច្ចចាំបាច់ត្រូវរៀបចំឱ្យបានល្អ និងចាត់ចែងក្នុងលក្ខណៈសមស្រប ហើយមិនត្រូវមានពេលខ្លីពេកនៅតាមទីតាំងទាំងនោះ ដែលអាចនាំឱ្យបាត់បង់ការឆ្លុះបញ្ចាំង និងការរៀនសូត្រ។ ដំណើរទស្សនកិច្ចត្រូវតែអមដោយបុគ្គលិកមានបទពិសោធន៍មកពីស្ថាប័នចងចាំ។ ដូច្នេះ សំណើនេះស្នើឱ្យធ្វើការជាមួយគ្រូបង្រៀនប្រវត្តិសាស្ត្រ និងយុវជនមកពីគ្រប់ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា និងសហការជាមួយ CKGC, អ.វ.ត.ក, និង LDC និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតដែលធ្វើការក្នុងវិស័យនេះ ដូចជា KDK និង YFP។ សកម្មភាពកម្មវិធី និងដំណាក់កាលសំខាន់ៗ រួមមាន ការអភិវឌ្ឍ និងរៀបចំផែនការថវិកា ប្រព័ន្ធកម្មវិធីនៅក្នុងក្រសួងអប់រំ បង្កើតគំនិតនៃដំណើរទស្សនកិច្ចនៅទីតាំងបូជនីយដ្ឋាន ជូនដំណឹងដល់សាលារៀនទូទាំងប្រទេសអំពីលទ្ធភាពនៃការដាក់ពាក្យ និងអមដំណើរទស្សនកិច្ចក្នុងដំណាក់កាលសាកល្បងរយៈពេលបីឆ្នាំ។ បន្ទាប់ពីរយៈពេលពីរឆ្នាំ ដំណោះស្រាយគួររំពឹងទុកថា MOEYS នឹងអនុវត្តកម្មវិធីដោយខ្លួនឯង។ ថវិកាប៉ាន់ស្មានត្រូវបានប៉ាន់ប្រមាណចំនួន ៥០.០០០ដុល្លារអាមេរិក ក្នុងមួយឆ្នាំ។

# ០៥

## សំណើដាក់ជូនដោយ YFP ផ្តោតលើការអភិរក្សអតីតទីតាំងខ្មែរក្រហមនៅភូមិភាគពាយ័ព្យ និងផ្តល់កន្លែងសម្រាប់ការផ្សះផ្សាការចងចាំ និងការអប់រំ។



↑ ផ្នែកកិច្ចការសាធារណៈអ.វ.ត.ក ចែកសាលក្រម (៤៥០ទំព័រ) ចំនួន១០ ០០០ ច្បាប់ និង សេចក្តីសង្ខេម (៣៦ ទំព័រ) ចំនួន ១៧ ០០០ ច្បាប់។ ឯកសារទាំងនេះ មាននៅតាមឃុំទាំងអស់ចំនួន ១ ៦២១ ឃុំ នៅកម្ពុជា ព្រមទាំង មាននៅតាម បណ្ណាល័យសាលារៀន និងស្ថាប័នសាធារណៈផ្សេងៗទេទៀត។

ពួកគេបានកំណត់ថា មានភ័ស្តុតាងជាក់ស្តែងតិចតួចបំផុតដែលនៅសេសសល់នៅតាមទីតាំងឧក្រិដ្ឋកម្មខ្មែរក្រហមស្ទើរតែទាំងអស់ រួមទាំងអតីតគុក ជំរុំការងារដោយបង្ខំ និងផ្នូររួម។ ក្នុងចំណោមវត្ថុអនុស្សាវរីយ៍មួយចំនួនដែលត្រូវបានសាងសង់កាលពីអតីតកាល មនុស្សជាច្រើនមិនត្រូវបានបញ្ចូលទៅក្នុងការអនុវត្តនៃការចងចាំរបស់សហគមន៍មូលដ្ឋាន ហើយបានប្រែក្លាយជាមានសភាពពុកផុយ។ អតីតទីតាំងនៃអំពើឃោរឃៅរបស់របបខ្មែរក្រហមភាគច្រើនមិនត្រូវបានគេដាក់អ្វីជាសម្គាល់ ហើយអាចមើលស្គាល់ដោយអ្នករស់រានមានជីវិតក្នុងតំបន់ និងអ្នកស្រុកតែប៉ុណ្ណោះ។ សម្រាប់អ្នកទស្សនាដែលដើរកាត់ទីតាំង និងសំខាន់ជាងនេះ សមាជិកនៃក្មេងជំនាន់ក្រោយដែលកើតក្រោយអំពើឃោរឃៅនៃរបបខ្មែរក្រហម ទីតាំងអំពើហិង្សាកាលពីអតីតកាលនៅតែមើលមិនឃើញ ហើយសក្តានុពលក្នុងការរំលឹកការចងចាំ គ្មានប្រយោជន៍។

YFP ដកស្រង់សំដីអ្នកស្រាវជ្រាវ និងជារដ្ឋលេខាធិការ MOEYS លោក ឌី ខាំបូលី ដែលបាននិពន្ធក្នុងឆ្នាំ២០០៧ ថា នៅទូទាំងប្រទេសកម្ពុជា មានកន្លែងសម្លាប់រង្គាលប្រមាណ ៣៨៨កន្លែង ជាមួយនឹងផ្នូរសម្លាប់រង្គាលចំនួន ១៩.៧៤៤ និងទីតាំងអតីតគុកចំនួន ១៩៦។ កន្លែងខ្លះឃើញមានសង់ស្តូបរំលឹកវិញ្ញាណក្ខន្ធអ្នកស្លាប់ និងទុក្ខលំបាក។ មានស្តូបចំនួន ៨១ ដែលត្រូវបានសាងសង់ឡើងបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម។ ទោះជាយ៉ាងណាក៏ដោយ នៅមានបញ្ហាជាច្រើនទាក់ទងនឹងការរំលឹកវិញ្ញាណក្ខន្ធទាំងនោះ។ ស្ថានភាពនៃគ្រោងរាងកាយ និងឆ្អឹងមិនត្រូវបានថែរក្សាបានល្អ ហើយខ្លះទៀតត្រូវពន្លឺព្រះអាទិត្យ និងភ្លៀង ហើយកំពុងពុកផុយបន្តិចម្តងៗ។ YFP ក៏បានកំណត់ថា ប្រវត្តិនៃកន្លែងរំលឹកវិញ្ញាណក្ខន្ធក្នុងស្រុក និងកន្លែងសម្លាប់រង្គាលមិនត្រូវបានកត់ត្រាទុក ចងក្រងឯកសារ ឬ ចងក្រងនោះទេ ដូច្នេះវានឹងបាត់បង់ក្នុងពេលឆាប់ៗនេះ។ សូម្បីតែអ្នកដែលរស់នៅជុំវិញកន្លែងសម្លាប់រង្គាលទាំងនេះច្រើនតែមិនដឹងអំពីករណីនេះ ហើយរឿងរ៉ាវរបស់អ្នករស់រានមានជីវិត និងវីរបុរសមិនត្រូវបានកត់ត្រាឱ្យបានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យមានដំណើរការព្យាបាលរបួស និងការយល់ដឹងអំពីអតីតកាលនោះទេ។

YFP បានកំណត់ថាមានការខ្វះខាតឱកាស និងកន្លែងដើម្បីភ្ជាប់ទំនាក់ទំនងជាមួយអតីតកាល កាន់ទុក្ខ និងចែករំលែកបទពិសោធន៍។ ពួកគេទទួលស្គាល់តម្រូវការក្នុងការសន្ទនាដោយបើកចំហ និងដើម្បីឱ្យយុវជនចូលរួមជា "ភ្នាក់ងារ" នៃការផ្លាស់ប្តូរសង្គមប្រកបដោយសន្តិភាព។ ដូច្នេះ គោលដៅរួមរបស់គម្រោងគឺលើកកម្ពស់ការផ្សះផ្សាសង្គម និងការផ្លាស់ប្តូរជម្លោះតាមរយៈការដោះស្រាយអតីតកាល ដើម្បីកុំឱ្យកើតឡើងវិញនៃឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងការរំលោភសិទ្ធិមនុស្សនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងលក្ខណៈឱ្យមានការចូលរួម ដើម្បីផ្តល់លទ្ធភាពសម្រាប់ក្មេងជំនាន់ក្រោយ និងមនុស្សចាស់ចូលរួមកិច្ចសន្ទនាអំពីអតីតកាលដ៏ឃោរឃៅ និងធ្វើដំណើរឆ្ពោះទៅរកការអភិរក្សទីតាំងប្រវត្តិសាស្ត្រខ្មែរក្រហម និងបង្កើតសហគមន៍រំលឹកវិញ្ញាណក្ខន្ធ និងការចងចាំតាមរយៈការកសាងសមត្ថភាព ឯកសារ និងការពិគ្រោះយោបល់សហគមន៍សិល្បៈ និងការតាំងពិពណ៌។

YFP បានកំណត់ទីតាំងគោលដៅនៅអតីតភូមិភាគពាយ័ព្យ រួមទាំងខេត្តពោធិសាត់ បាត់ដំបង និងបន្ទាយមានជ័យ ហើយ YFP ប៉ាន់ស្មានថា គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់អ្នកទទួលផលផ្ទាល់ចំនួន ៦០០ (រួមមាន យុវជន ព្រះសង្ឃ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះរស់រានមានជីវិត និងសមាជិកគណៈកម្មាធិការរំលឹកការចងចាំនៅក្នុងសហគមន៍) និងអ្នកទទួលផលដោយប្រយោលចំនួន ១.០០០ (សហគមន៍ទាំងមូល រួមទាំងអាជ្ញាធរមូលដ្ឋាន គ្រូបង្រៀន) ក្នុងរយៈពេលបីឆ្នាំ។

YFP ក៏មានគម្រោងសហការជាមួយ TSGM ដែលបានយល់ព្រមធ្វើការងារអភិរក្សទីតាំងប្រវត្តិសាស្ត្របែបនេះ និងការលើកកម្ពស់ការអប់រំប្រវត្តិសាស្ត្រប្រល័យពូជសាសន៍។ ដំណាក់កាលនៃគម្រោងរួមមាន ការស្រាវជ្រាវ និងការចងក្រងឯកសារដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មាននៅតាមទីតាំងប្រវត្តិសាស្ត្រ បណ្តុះបណ្តាលនិស្សិតឱ្យធ្វើការស្រាវជ្រាវផ្ទាល់ ដើម្បីសម្ភាសជនរងគ្រោះ-អ្នករស់រានមានជីវិត សាក្សី និងសមាជិកសហគមន៍ និងការអភិវឌ្ឍនិងការពិគ្រោះយោបល់ទូទាំងប្រទេសលើ "សៀវភៅចងចាំ" ស្តីពីទីតាំងប្រវត្តិសាស្ត្រខ្មែរក្រហម។ លើសពីនេះ YFP និង TSGM នឹងធ្វើការពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់ខេត្តជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អំពីរបៀបថែរក្សាតំបន់ប្រវត្តិសាស្ត្រទាំងនេះ។ សំណើនេះក៏ស្នើឱ្យសាងសង់វិមានអនុស្សាវរីយ៍ចំនួន ៥ និងការបង្កើតទីតាំងពិពណ៌សម្ភារៈអចិន្ត្រៃយ៍នៅកន្លែងនានាដើម្បីផ្តល់កន្លែងសម្រាប់ការសិក្សា និងការយល់ដឹង។ ទីតាំងទាំងនេះនឹងត្រូវបានអមដោយពិធីបើកសម្ពោធជាសាធារណៈ។ ជាចុងក្រោយ កម្មវិធីអប់រំសាធារណៈនឹងបំពេញបន្ថែមលើគម្រោងនេះ ដោយផ្តោតលើសិក្ខាសាលាស្តីពីប្រវត្តិសាស្ត្រ និងការផ្សះផ្សា ការសន្ទនាអន្តរជំនាន់ ការធ្វើដំណើរទៅកាន់ទីកន្លែងនៃការចងចាំ ការព្យាបាលតាមរយៈសក្ខីកម្ម និងពិធីបង្ហាញការពិត ការកសាងសមត្ថភាពនៃគណៈកម្មាធិការចងចាំ និងក្រុមយុវជន ការធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌលសិក្សាក្នុងស្រុក ការតាំងពិពណ៌ចល័តអំពីប្រវត្តិសាស្ត្រនៃកន្លែងឧក្រិដ្ឋកម្ម និងការទស្សនាដោយសិស្សវិទ្យាល័យ និងអ្នករស់រានមានជីវិតទៅកាន់ទីតាំងប្រវត្តិសាស្ត្រទាំងនេះ។

ពេលវេលាគម្រោងដែលបានស្នើឡើងគឺសម្រាប់រយៈពេលបីឆ្នាំចាប់ពីឆ្នាំ២០២៣ ដល់ ឆ្នាំ២០២៥ ហើយថវិកាប៉ាន់ស្មានចំនួន ៤៥០.០០០ដុល្លារអាមេរិកសម្រាប់រយៈពេលបីឆ្នាំ។

# ០៦

## YRDP បានដាក់សំណើដោយផ្តោតលើនិរន្តរភាពក្នុងអំឡុងពេល និងក្រោយអាណត្តិដែលនៅសេសសល់រយៈពេលបីឆ្នាំរបស់ អ.វ.ត.ក។



ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ធ្វើទស្សនៈកិច្ច និង ធ្វើបឋកថាអំពីការជំនុំជម្រះក្តីខ្មែរក្រហមដែលកំពុងដំណើរការ ដល់សិស្សានុសិស្សចំនួន ៦ ០០០ នាក់ នៅវិទ្យាល័យសាមគ្គី ។

ពួកគេបានស្នើថា ដើម្បីបង្កើតលទ្ធផលដ៏មានតម្លៃសម្រាប់សង្គមស៊ីវិល គួរគិតគូរចក្ខុវិស័យប្រកបដោយនិរន្តរភាព ឱ្យបានហ្មត់ចត់ក្នុងរយៈពេលដប់ឆ្នាំ និងសម្របសម្រួល ពីដំបូងដោយ អ.វ.ត.ក មុននឹងផ្លាស់ប្តូរទៅកាន់ទីភ្នាក់ងារពាក់ព័ន្ធបំផុតណាមួយរបស់អង្គការសហប្រជាជាតិ ដោយទទួលអាណត្តិសម្របសម្រួល នៅពេល អ.វ.ត.ក បញ្ចប់។ ការងារនេះប្រហែលជាអាចតាមរយៈការិយាល័យអ្នកសម្របសម្រួលប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ។ ពួកគេជឿថា សិក្ខាសាលាជនរងគ្រោះនៃ អ.វ.ត.ក គួរតែត្រូវបានគេមើលឃើញថាជាជំហានមួយឆ្ពោះទៅរកការបង្កើត និងអនុវត្តផែនការសកម្មភាពរយៈពេលវែង និងផែនការការងារស្តីពីមរតករបស់អ.វ.ត.ក និងបន្តយុត្តិធម៌អន្តរកាលក្រោមការដឹកនាំរបស់រដ្ឋាភិបាល។ ដំណើរការនេះគួរត្រូវបានគាំទ្រដោយអង្គការសហប្រជាជាតិ និងដឹកនាំដោយគណៈកម្មាធិការរួមទាំងក្រសួងពាក់ព័ន្ធ សង្គមស៊ីវិល អង្គការសហប្រជាជាតិ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។ YRDP ក៏បានស្នើឱ្យពិភាក្សាអំពីរចនាសម្ព័ន្ធមូលនិធិអន្តរកាល រួមទាំងការផ្លាស់ប្តូរថវិកាបន្តិចម្តងៗ និងដោយផ្នែក ជូនទៅ RGC លើប្រធានបទមួយចំនួន។

YRDP ស្នើបង្កើតយន្តការសម្របសម្រួលក្នុងទម្រង់ជាក្រុមការងារបច្ចេកទេសផ្អែកតាមប្រធានបទ (TWGs) ដើម្បីជំរុញការសន្ទនារវាងភាគីពាក់ព័ន្ធ និងសម្របសម្រួលគំនិតផ្តួចផ្តើមដែលបំពេញតម្រូវការរបស់ក្រុមផ្សេងៗក្នុងចំណោមប្រជាជន (ឧទាហរណ៍ យុវជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នករស់រានមានជីវិត និងជនជាតិភាគតិច)។ ដើម្បីឱ្យកង្វល់សំខាន់ៗស្ថិតនៅខាងលើរបៀបវារៈនយោបាយ និងបង្កើតផលចំណេញជាក់ស្តែង TWGs ក្នុងទម្រង់ជាវេទិកាពហុភាគីដែលដឹកនាំដោយអង្គការសហប្រជាជាតិ គួរតែកោះប្រជុំក្នុងចំណោមតំណាងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល សហគមន៍ការទូត និងអង្គការអន្តរជាតិ។ ដើម្បីឱ្យការងារនេះដំណើរការ TWGs ចាំបាច់ត្រូវទទួលកាតព្វកិច្ចបង្កើតផែនការសកម្មភាពផ្អែកតាមប្រធានបទ និងផែនការចំណាយ។

ជាកំណត់ចំណាំចុងក្រោយនៃផ្នែកនេះ ការដាក់សំណើបន្ទាប់ពីសិក្ខាសាលាបង្ហាញច្បាស់ឱ្យឃើញឱកាសជាច្រើនសម្រាប់ឱ្យមានកិច្ចសហការ ហើយសំណើភាគច្រើនបានកំណត់អង្គការដៃគូរួចហើយសម្រាប់កិច្ចសហការ ដែលកសាងចេញពីការសន្ទនាពីមុន អំឡុងពេល និងក្រោយសិក្ខាសាលា។ ជាពិសេស សំណើមួយចំនួនលើកឡើងអំពីប្រធានបទស្រដៀងគ្នានៃការរក្សាទីតាំងក្នុងតំបន់ជាកន្លែងចងចាំ និងការរៀនសូត្រ និងការរួមបញ្ចូលការសន្ទនាអន្តរជំនាន់ជាមួយមនុស្សជំនាន់ក្រោយនៅតាមទីតាំង

ទាំងនេះ។ សំណើភាគច្រើនក៏លើកឡើងអំពីតម្រូវការចូលរួមជាមួយរដ្ឋាភិបាលដើម្បីសហការលើគម្រោងទាំងនេះ ក្នុងគោលបំណងឆ្ពោះទៅរកនិរន្តរភាពយូរអង្វែង និងភាពជាម្ចាស់នៅក្នុងប្រទេសកម្ពុជា។

# ក្រោយសិក្ខាសាលា៖ ការបន្តកិច្ចពិគ្រោះយោបល់បន្ទាប់ពីព្រឹត្តិការណ៍

ប៉ុន្មានសប្តាហ៍បន្ទាប់ពីសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ អ្នកសម្របសម្រួល Daniel Mattes ក៏បានជួបជាមួយអ្នកផ្សេងទៀតជាច្រើនដែលមិនមានលទ្ធភាពចូលរួមសិក្ខាសាលាដោយផ្ទាល់។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវបានធ្វើឡើងលើសពីវិសាលភាពនៃសិក្ខាសាលា ដើម្បីធានាថាការពិគ្រោះយោបល់ជុំវិញព្រឹត្តិការណ៍នេះមានលក្ខណៈទូលំទូលាយ និងលម្អិតតាមដែលអាចធ្វើទៅបានក្នុងរយៈពេលកំណត់ និងក្នុងក្របខ័ណ្ឌសមត្ថភាពដែលមាន។ អ្នកសម្របសម្រួលបានព្យាយាមចែករំលែកព័ត៌មានអំពីសិក្ខាសាលាជាមួយអ្នកចាប់អារម្មណ៍ រួមមាន (១) ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតក្រៅពី ១៥នាក់ ដែលបានចូលរួមក្នុងព្រឹត្តិការណ៍នេះ (២) អ្នកសង្កេតការណ៍អន្តរជាតិ ដែលមួយចំនួនតូចអាចមើលដំណើរការសិក្ខាសាលាពីចម្ងាយតាមរយៈវេទិកា KUDO អនឡាញ ដូចបានពិភាក្សាខាងលើ និង (៣) សហគមន៍កម្ពុជានៅក្រៅប្រទេសដែលតែងតែមើលរំលង ដែលមិនត្រូវបានបញ្ចូលក្នុងការរៀបចំព្រឹត្តិការណ៍នេះ លើការងារត្រួតពិនិត្យ ដែលអ្នកសម្របសម្រួលទទួលស្គាល់។

## ដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមដែលចូលរួមក្នុងវេទិកា VSS-CPLCL ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ០១

ចាប់តាំងពីឆ្នាំ២០០៩ មក VSS និង CPLCLs បានធ្វើសកម្មភាពផ្សព្វផ្សាយព័ត៌មានជាទៀងទាត់ អំពី អ.វ.ត.ក និងការកាត់ក្តីដែលកំពុងបន្តដំណើរការ និងភ្ជាប់ទំនាក់ទំនងដើមបណ្តឹងរដ្ឋប្បវេណីទៅវិញទៅមក និងជាមួយតុលាការ។ VSS បានរៀបចំវេទិកាថ្នាក់តំបន់ជាច្រើនសារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី រួមជាមួយនឹង CPLCLs ឬ តំណាងរបស់ពួកគេ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត នៅទូទាំងប្រទេស។ បន្ទាប់ពីការពន្យារពេលនិងផ្អាករយៈពេលពីរឆ្នាំដោយសារជំងឺរាតត្បាតកូវីដ-១៩ VSS និង CPLCLs មានគម្រោងរៀបចំវេទិកាដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៤ នៅឆ្នាំ២០២២។ វេទិកាទាំងនេះត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុដោយសេវាសន្តិភាពស៊ីវិល GIZ។ វេទិកាលើកដំបូងចាប់តាំងពីឆ្នាំ២០១៩ ត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ គឺមួយសប្តាហ៍បន្ទាប់ពីសិក្ខាសាលាជនរងគ្រោះ។ ជាធម្មតា វេទិកាពីមុនៗបានស្វាគមន៍

ដើមបណ្ដឹងរដ្ឋប្បវេណីរាប់រយនាក់ ប៉ុន្តែដោយសារការបន្តព្រួយបារម្ភអំពីហានិភ័យនៃការរីករាលដាលជំងឺកូវីដ-១៩ VSS បានអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីប្រមាណ ៦០នាក់ នៅក្នុងប្រទេសមករាជធានីភ្នំពេញចូលរួមព្រឹត្តិការណ៍មួយថ្ងៃ។ មានតែដើមបណ្ដឹងរដ្ឋប្បវេណីបីនាក់ប៉ុណ្ណោះនៅក្នុងវេទិកានេះ ដែលបានចូលរួមសិក្ខាសាលាកាលពីមួយសប្ដាហ៍មុន។ ក្រៅពីនេះសុទ្ធតែជាអ្នកចូលរួមថ្មី។ ព្រឹត្តិការណ៍នេះបានផ្ដល់ឱកាសមួយមិនត្រឹមតែចែករំលែកព័ត៌មានថ្មីៗអំពីកិច្ចពិភាក្សាដែលបានធ្វើឡើងនៅក្នុងសិក្ខាសាលាមួយសប្ដាហ៍មុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចឱ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមបានទូលំទូលាយ ដើម្បីស្ដាប់យោបល់ និងគំនិតពួកគេទាក់ទងនឹងអាណត្តិដែលនៅសេសសល់របស់ អ.វ.ត.ក ផងដែរ។

កិច្ចប្រជុំវេទិកា VSS-CPLCL នៅពេលព្រឹកបានផ្ដល់ឱកាសដែលទន្ទឹងរង់ចាំជាយូរមកហើយដល់ CPLCLs លោក ពេជ្រ អង្គ និងលោកស្រី Megan Hirst ជជែកដោយផ្ទាល់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណីដែលចូលរួមជាលើកដំបូងអំពីសំណុំរឿង ០០២/០២ ដោយបានពន្យល់ថា សាលដីកាចុងក្រោយនៅក្នុងសំណុំរឿងនោះរំពឹងថានឹងធ្វើឡើងនៅចុងឆ្នាំ២០២២។ CPLCLs ក៏បានពិភាក្សាអំពីសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ ដោយលើកឡើងអំពីបញ្ហានៃការចាត់ប្រភេទឡើងវិញនូវឯកសារនៅក្នុងសំណុំរឿងរបស់ អ.វ.ត.ក មុនពេលត្រូវបានផ្សព្វផ្សាយជាសាធារណៈទាំងស្រុងនៅពេលបញ្ចប់ដំណើរការកាត់ក្ដី។ បញ្ហានេះក៏ត្រូវបានពិភាក្សាខាងលើនៅក្នុងផ្នែកស្ដីពីការពិគ្រោះយោបល់មុនសិក្ខាសាលានៅក្នុងផ្នែកទី II.២ ខាងលើ។ បន្ទាប់ពីសម្រាកអាហារថ្ងៃត្រង់ លោកប្រធាន VSS លោក ហង្ស វណ្ណៈ បានអញ្ជើញអ្នកសម្របសម្រួលលោក Daniel Mattes ដើម្បីផ្ដល់ព័ត៌មានថ្មីៗដល់ដើមបណ្ដឹងរដ្ឋប្បវេណីដែលចូលរួមសិក្ខាសាលាស្ដីពីជនរងគ្រោះ ហើយឆ្លៀតឱកាសនេះដើម្បីស្នើសុំពួកគេឱ្យចែករំលែកយោបល់ ប្រតិកម្ម ឬសំណួរអំពីអាណត្តិដែលនៅសេសសល់ និងការបង្កើតគម្រោងថ្មី ដើម្បីជួយនិងគាំទ្រតម្រូវការរបស់ជនរងគ្រោះ។ អ្នកសម្របសម្រួលបានបញ្ជាក់យ៉ាងច្បាស់ថា គំនិត ឬ សំណើរបស់ពួកគេនឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍នេះ។ ដើមបណ្ដឹងរដ្ឋប្បវេណី លោក ចាន់ សាត ដែលបានថ្លែងលម្អិតនៅក្នុងសិក្ខាសាលាជនរងគ្រោះក៏បានចូលរួមក្នុងវេទិកា VSS និងបានលើកទឹកចិត្តដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលចូលរួម ឱ្យចែករំលែកគំនិតរបស់ពួកគេដោយស្មោះត្រង់ និងច្បាស់លាស់។

ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើយ៉ាងដដែលថា ការគាំទ្រចំពោះអ្នករស់រានមានជីវិត និងគំនិតផ្ដួចផ្ដើមដែលផ្ដោតលើអ្នករស់រានមានជីវិតមិនបញ្ចប់ត្រឹមសវនាការនៅ អ.វ.ត.ក នោះទេ។ ពួកគេបានរំលឹកឡើងវិញនូវការរងទុក្ខ និងរបួសជាសកលពីរបប DK ហើយបានបង្ហាញអំពីបំណងប្រាថ្នាមិនចង់ឱ្យមានការកើតឡើងវិញ ហើយសង្ឃឹមថាមនុស្សជំនាន់ក្រោយនឹងមិនឱ្យមានអំពើឃោរឃៅបែបនេះកើតឡើងម្ដងទៀតឡើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបបានថ្លែងអំណរគុណមេធាវីរបស់គាត់ និងតុលាការសម្រាប់យុត្តិធម៌ដែលគាត់បានទទួល ដោយកត់សម្គាល់ថាគាត់មានអារម្មណ៍សុខស្រួលចិត្តជាងមុន និងលែងសូវចងកំហឹង និងអាក់អន់ចិត្ត។ អ្នកផ្សេងទៀតបានសង្កេតឃើញថា ដំណើរការយុត្តិធម៌នៅតែដំណើរការ ហើយដំណើរការកាត់ក្ដីគ្រាន់តែជាផ្នែកមួយនៃដំណើរការនេះ ប៉ុន្តែពួកគេមានអារម្មណ៍ថាមានអំណាចក្នុងការនិយាយច្រើនជាងពីមុន។ ភាគច្រើនបានផ្ដោតលើមនុស្សជំនាន់ក្រោយ ដោយសុំឱ្យរឿងរ៉ាវរបស់ពួកគេចែករំលែកទៅកាន់យុវជនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីបង្ហាញការពិត និងពង្រឹងការផ្សះផ្សា។

ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបបានសួរចំៗថា ហេតុអ្វីបានចំណាយពេលយូរម្ល៉េះទម្រាំឃើញស្តូបអនុស្សាវរីយ៍ត្រូវបានសាងសង់ឡើងនៅទូទាំងប្រទេស បន្ទាប់ពីដើមបណ្ដឹងរដ្ឋប្បវេណីមកសុំម្ដងហើយម្ដងទៀត។ លោកបានកត់សម្គាល់ពីស្តូបអនុស្សាវរីយ៍ដែលសាងសង់នៅ TSGM ប៉ុន្តែលោកបានអំពាវនាវឱ្យមានការកសាងអនុស្សាវរីយ៍ "គួរឱ្យស្អាតចាប់អារម្មណ៍ជាងនេះ" ដែលតំណាងឱ្យបទពិសោធន៍នៃជនរងគ្រោះទាំងអស់ មិនត្រឹមតែនៅ ស-២១ ប៉ុណ្ណោះទេ ហើយក៏គួររាយឈ្មោះជនរងគ្រោះបន្ថែមទៀតផងដែរ។ គាត់ក៏គិតគូរដល់មនុស្សជំនាន់ក្រោយផងដែរៈ គាត់បានសង្កត់ធ្ងន់ថាកន្លែងរំលឹកវិញ្ញាណក្ខន្ធណាមួយក៏ដោយគឺត្រូវមានភាព "ទាក់ទាញ" ដល់យុវជនដើម្បីធានាថាពួកគេ "ចាប់អារម្មណ៍" ការចងចាំអំពីទុក្ខវេទនាពីអតីតកាល។

ដើមបណ្ដឹងរដ្ឋប្បវេណី ចាន់ សាត បានឆ្លៀតឱកាសនេះអំពាវនាវឱ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ប្រកាន់ភាពជាម្ចាស់ជាលក្ខណៈបុគ្គលឱ្យបានកាន់តែច្រើនលើការងារនៃការចងចាំ និងការផ្សះផ្សា។ លោកបានពន្យល់ថា ពួកគេម្នាក់ៗអាចធ្វើការងារជាលក្ខណៈបុគ្គលបន្ថែមទៀតនៅក្នុងសហគមន៍របស់ពួកគេ ដើម្បីអភិវឌ្ឍគំនិត និងរៃអង្គាសប្រាក់ដើម្បីផ្ដល់មូលនិធិដល់ការអនុវត្តរបស់ពួកគេ ដោយមិនចាំបាច់រង់ចាំ អ.វ.ត.ក ឬអ្នកផ្សេងទៀតធ្វើដូច្នេះសម្រាប់ពួកគេ។ គាត់បានកត់សម្គាល់ថានៅក្នុងទសវត្សរ៍

ឆ្នាំ១៩៨០ មិនយូរប៉ុន្មានបន្ទាប់ពីការដួលរលំនៃរបប DK សហគមន៍មូលដ្ឋានជាច្រើនបានសាងសង់ចេតិយ និងស្តូបអនុស្សាវរីយ៍ទ្រង់ទ្រាយតូច ហើយគាត់បានសួរថាហេតុអ្វីបានជាមិនធ្វើដូច្នេះទៀតសព្វថ្ងៃនេះ។ ក្រឡេកទៅមើលសហគមន៍ផ្ទាល់ក្នុងខេត្តពោធិសាត់ គាត់នឹកឃើញកន្លែងសម្លាប់រង្គាលទួលពោធិ៍ជ្រៃ ដែលអតីតទាហាន លន់ នល់ ត្រូវបានសម្លាប់ ដូចបានលើកឡើងក្នុងសំណុំរឿង ០០២/០១។ លោកបានស្នើឱ្យសាងសង់ប្រព័ន្ធការពារទឹកជំនន់ ដើម្បីរក្សាទីតាំង និងសាងសង់សាលាសំណាក់ (ជាភាសាខ្មែរ សាលាសំណាក់) ជានិមិត្តរូបនៃសារៈសំខាន់របស់វា។ លោកបញ្ជាក់ថា សាលប្រជុំមិនចាំបាច់ត្រូវគេសម្គាល់ឱ្យច្បាស់ថាជាកន្លែងរំលឹកការចងចាំនោះទេ ដោយលោកលើកឡើងថា ការបង្កើតកន្លែងសម្រាប់សហគមន៍សព្វថ្ងៃនៅលើអតីតទីតាំងនៃអំពើឃោរឃៅនេះ នឹងផ្តល់ប្រយោជន៍ដល់ការផ្សះផ្សាជាតិ។ គាត់បានពន្យល់ថា៖ "សូមទៅមើលសហគមន៍របស់អ្នក... បើអ្នកចង់បានកេរដំណែល វាត្រូវតែចេញមកពីអ្នក។ ការងារនេះ ក៏នឹងជួយឱ្យមានភាពធូរស្រាល និងដំណើរផ្លូវបុគ្គលផងដែរ"។

បន្ទាប់ពីការពិភាក្សាកាន់តែទូលំទូលាយរវាងអ្នកសម្របសម្រួល និងដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមនោះ ដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ ៦០នាក់ បានបំបែកជាបួនក្រុម ដែលដឹកនាំដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូបគឺ ហុង គឹមសួន, ទី ស្រ៊ីណា, វ៉ែន ពៅ និង នួន សុជាតា។ បន្ទាប់មកមេធាវីទាំងនេះបានដាក់សំណើរបស់ក្រុមនីមួយៗសម្រាប់ដំណាក់កាលដែលនៅសេសសល់ទៅលេខាធិការដ្ឋានតាមរយៈ VSS។ សំណើរបស់ក្រុមទាំងបួននេះត្រូវបានសង្ខេបនៅទីនេះ ហើយត្រូវបានបញ្ចូលទាំងស្រុងនៅក្នុងឧបសម្ព័ន្ធ VII។ ក្រុមនីមួយៗបានបំបែកសំណើរបស់ពួកគេទៅជាប្រធានបទចំនួនបួន៖ ការចងចាំ ការស្តារឡើងវិញ ការអប់រំ និងឯកសារ។

ចំពោះការចងចាំក្រុមទាំងនោះបានស្នើសុំសាងសង់ស្តូប និងចេតិយនៅទូទាំងប្រទេសសម្រាប់ជនរងគ្រោះដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ ក្រុមមួយបានស្នើសុំឱ្យសង់យ៉ាងហោចណាស់ស្តូបមួយនៅតាមខេត្តនីមួយៗនៅក្នុងប្រទេស ដោយមានការឆ្លាក់ឈ្មោះ និងរូបថតជនរងគ្រោះតាមដែលអាចធ្វើបាន ចំណែកក្រុមមួយទៀតស្នើសុំយ៉ាងហោចណាស់ស្តូបមួយនៅគ្រប់ឃុំ ឬខេត្ត។ ក្រុមក្រោយៗទៀតក៏បានស្នើឱ្យជួយរៀបចំពិធីសាសនានៅចេតិយទាំងនេះ ស្របនឹងការសាងសង់របស់ពួកគេ។ ក្រុមមួយទៀតដែលស្នើសុំចេតិយក្នុងខេត្តនីមួយៗបញ្ជាក់ថាគួរសាងសង់ដូចៗគ្នាក្នុងទំហំ ១០ គុណនឹង ១០ ម៉ែត្រ។ ក្រុមមួយបានលើកឡើងថា ស្តូបគួរតែត្រូវបានសាងសង់ជូនជនរងគ្រោះជាពិសេសត្រូវបញ្ចូលឈ្មោះជនរងគ្រោះជាខ្មែរ វៀតណាម និងចាម។ ក្រុមទាំងបួន ក៏បានស្នើយកថ្ងៃទី២០ ឧសភា ឬ "អនុម័តកែសម្រួលឡើងវិញ" ជាថ្ងៃបុណ្យជាតិ សម្រាប់ប្រារព្ធពិធីទូទាំងប្រទេស នៅកន្លែងទាំងនេះ ជាការរំលឹកវិញ្ញាណក្ខន្ធដល់ជនរងគ្រោះ ។ ក្រុមទាំងអស់បានស្នើសុំរដ្ឋបាល អ.វ.ត.ក និងរាជរដ្ឋាភិបាល សហការគ្នាសាងសង់បណ្តាញស្តូប ឬ ចេតិយក្នុងអំឡុងពេលដែលនៅសេសសល់។

មានមួយក្រុមបានស្នើសុំឱ្យមាន "កម្មវិធីកិច្ចប្រជុំរួមគ្នា" ដែលធ្វើឡើងជារៀងរាល់ឆ្នាំនៅ TSGM នៅថ្ងៃទី២០ ឧសភា ដោយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី តំណាងរបស់ពួកគេ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ហើយក៏បានស្នើសុំរក្សាទុកទីតាំងឧក្រិដ្ឋកម្មនៅទូទាំងប្រទេស ដើម្បីឱ្យជនរងគ្រោះក្នុងរបបនេះ បានដឹងអំពីទីតាំងដែលសាច់ញាតិរបស់ពួកគេត្រូវបានសម្លាប់ ហើយអាចធ្វើពិធីនៅទីតាំងទាំងនោះ។ យើងក៏ឃើញមានការលើកឡើងជាក់លាក់អំពីទីតាំងសម្លាប់រង្គាលនៅភូមិប្រពៃ និងនៅសាលាស្រុកមេសាង ខេត្តព្រៃវែង។ ក្រុមមួយទៀតក៏បានស្នើឱ្យមានការជួបជុំធំៗចំនួន ០៣ដងក្នុងមួយឆ្នាំនៅតាមតំបន់ទេសចរណ៍ក្នុងខេត្តបាត់ដំបង ឬ ខេត្តសៀមរាប ទោះបីមិនទាន់

[៤៦] ថ្ងៃទី២០ ខែឧសភាត្រូវបានកំណត់ក្រៅផ្លូវការថាជា "ទិវាចងកំហឹង" និងជា "ទិវានៃការចងចាំ" ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ ហើយបានឃើញពិធីប្រចាំឆ្នាំដែលជាធម្មតាប្រារព្ធនៅកន្លែងរំលឹកពលកម្មដោយបង្ខំ ការសម្លាប់ និងការធ្វើទារុណកម្ម (សូមមើល Rachel Hughes, ការចងចាំ ថ្ងៃទី២០ ខែឧសភា ទិវាចងកំហឹង (២០០០) ការស្វែងរកការពិត ១២)។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ "ទិវានៃការចងចាំ" ជាសំណង ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ បានស្នើសុំ (០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E៣១៣ ទំព័រ ៩៥៣។ អាចចូលមើលបានតាមរយៈ៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/២០១៤-០៨-០៧%២០១៧%៣A៥៤/E៣១៣_Trial%២០Chamber%២០Judgement%២០Case%២០០០២_០១_KH.pdf ។ សំណងនេះត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលក្នុងរយៈពេលបីឆ្នាំក្រោយមក នៅពេលនាយករដ្ឋមន្ត្រីបានចុះហត្ថលេខាលើអនុក្រឹត្យមួយនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ ប្រកាសទិវាជាតិនៃការចងចាំ ២០ ឧសភា (សូមមើលរាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៨ ក្នុងទិវាជាតិនៃការចងចាំ)។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីបានប្រារព្ធពិធីឈប់សម្រាកសាធារណៈជាផ្លូវការត្រឹមតែ ២ឆ្នាំ ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ថ្ងៃឈប់សម្រាកសាធារណៈនេះត្រូវបានកាត់បន្ថយ។ ជាទូទៅនៃថ្ងៃឈប់សម្រាកប្រចាំឆ្នាំពី ២៨ថ្ងៃ ក្នុងមួយឆ្នាំមកត្រឹម ២២ថ្ងៃ (សូមមើលរាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១១២ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ លើប្រតិទិនឈប់សម្រាកសាធារណៈមានប្រាក់ឈ្នួលសម្រាប់បុគ្គលិក និងកម្មករសម្រាប់ឆ្នាំ២២០)។

ច្បាស់ថា តើនេះជាពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធ ឬ ជាសកម្មភាពរៀបចំជួបជុំនៅខាងក្រៅសម្រាប់ជនរងគ្រោះចាស់ជរា ដែលនៅរស់រានមានជីវិត។ មានមួយក្រុមក៏បានស្នើឱ្យបង្កើតបណ្ដាញជនរងគ្រោះនៃដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ដើម្បី អ.វ.ត.ក អាចទាក់ទងជាទៀងទាត់ ហើយក្រុមមួយទៀតបានស្នើសុំឱ្យ អ.វ.ត.ក រៀបចំការជួបជុំបន្ថែមទៀតនៅតុលាការ មុនពេលបិទបញ្ចប់នៅ ០៣ឆ្នាំក្រោយ ដើម្បីចែករំលែកព័ត៌មានបន្ថែមអំពីសាលាក្ដី។

ចំពោះការស្ដារនីតិសម្បទា ក្រុមទាំងបួនបានស្នើសុំឱ្យផ្ដល់ "ប័ណ្ណសមធម៌" (ឬ "ប័ណ្ណក្រីក្រ") ដើម្បីឱ្យដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតទាំងអស់អាចទទួលបានសេវាថែទាំសុខភាព និងផ្លូវចិត្តដោយមិនគិតថ្លៃ។ ពួកគេបានស្នើឱ្យរាជរដ្ឋាភិបាលចាប់ផ្ដើមអនុវត្តកម្មវិធីបែបនេះក្នុងអំឡុងពេល ០៣ឆ្នាំ នៃមុខងារដែលនៅសេសសល់។ ក្រុមទាំងនោះក៏បានលើកឡើងអំពី TPO ដោយស្នើឱ្យអង្គការមិនមែនរដ្ឋាភិបាលបន្តជួយព្យាបាលរបួសជនរងគ្រោះដែលរស់រានមានជីវិតពីរបប DK ដោយមានការគាំទ្រពីរដ្ឋាភិបាល។ មានមួយក្រុមបានស្នើឱ្យបង្កើតកម្មវិធីកម្សាន្តដែលអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីឱ្យជួបជុំគ្នាដើម្បីអនុញ្ញាតឱ្យពួកគេបន្ធូរបន្ថយទុក្ខសោក និងផ្សះផ្សាអារម្មណ៍។ មានមួយក្រុមបានស្នើសុំជាក់លាក់ឱ្យរាជរដ្ឋាភិបាលផ្ដល់សិទ្ធិទទួលបានយុត្តិធម៌ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្ដល់ជំនួយផ្នែកច្បាប់ដល់ពួកគេ និងកសាងការគោរពនីតិរដ្ឋ។ មានក្រុមចំនួនពីរបានស្នើឱ្យការិយាល័យរដ្ឋបាល អ.វ.ត.ក ចេញវិញ្ញាបនបត្រលើកទឹកចិត្ត ឬដឹងគុណដល់ដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ។ ការលើកឡើងនេះគឺស្រដៀងគ្នាទៅនឹងសំណើរបស់ក្រុមមួយ ដែលស្នើឱ្យមានការជួបជុំគ្នាដើម្បីប្រារព្ធពិធីដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតទាំងអស់នៅពេលបិទដំណើរការរបស់តុលាការ។

ចំពោះវិស័យអប់រំ ក្រុមទាំងអស់បានស្នើសុំឱ្យបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋដើម្បីឱ្យសិស្សានុសិស្សបានសិក្សារៀនសូត្រ ហើយជាពិសេសបានស្នើសុំឱ្យបញ្ចូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិត និងដើមបណ្ដឹងរដ្ឋប្បវេណីទៅក្នុងកម្មវិធីសិក្សាផងដែរ។ ចំណុចបង្ហាញច្បាស់មួយទៀតគឺថា ពួកគេសង្ឃឹម អ.វ.ត.ក និងរដ្ឋាភិបាល នឹងបំពេញតួនាទីនេះ។ មានមួយក្រុមបានស្នើសុំជាក់លាក់ថា ព្រះសង្ឃពុទ្ធសាសនា និងអ្នកដឹកនាំសាសនាផ្សេងទៀត ទទួលបានការបណ្ដុះបណ្ដាលអំពីប្រវត្តិសាស្ត្រនៃអំពើឃោរឃៅកាលពីអតីតកាលដើម្បីអាច យកទីតាំងសាសនាជួយផ្សព្វផ្សាយព័ត៌មាននោះដល់សាធារណជន។ ក្រុមដដែលក៏បានអំពាវនាវឱ្យ អ.វ.ត.ក បង្ហោះរូបថត និងវីដេអូឃ្លីបដែលទាក់ទងនឹងរបប DK ទៅកាន់ថ្នាលកំសាន្តនានា ដូចជា TikTok និង YouTube ដើម្បីចែករំលែកព័ត៌មានឱ្យក្មេងជំនាន់ក្រោយបានដឹង។ ក្រុមមួយទៀតបានស្នើសុំជាក់លាក់ថា គម្រោងសំណង"អណ្ដើកក្លាហាន" ដែលត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង ០០២/០២ ត្រូវបានអនុវត្តម្ដងទៀតនៅក្នុងដំណាក់កាលមួយទៀត។

ពាក់ព័ន្ធបញ្ហាចុងក្រោយនៃការចងក្រងឯកសារ ក្រុមទាំងនោះបានស្នើសុំឱ្យ អ.វ.ត.ក និងរដ្ឋាភិបាល បោះពុម្ព និងផ្សព្វផ្សាយនូវឯកសារផ្សេងៗសម្រាប់ការរំលឹកឡើងវិញនូវសក្ខីកម្មរបស់ពួកគេ និងការជំនុំជម្រះ និងសម្រាប់មនុស្សជំនាន់ក្រោយ។ ពួកគេបានស្នើជាពិសេសឱ្យរក្សាទុកឯកសារទាក់ទងនឹងជនរងគ្រោះ និងសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជារឿងរ៉ាវលម្អិតអំពីមន្ទីរសន្តិសុខ សម្រាប់ប្រើប្រាស់រយៈពេលយូរ និងចែកចាយដល់បណ្ណាល័យ សាកលវិទ្យាល័យ អនុវិទ្យាល័យ និងសាលាឯកជន។ មានមួយក្រុមបានលើកឡើងជាពិសេសអំពីតម្រូវការក្នុងការផ្ទុកឯកសារទាំងអស់ទៅក្នុងប្រព័ន្ធឌីជីថល ឬអ៊ីនធឺណិត។ មានមួយក្រុមក៏បានស្នើសុំឱ្យបោះពុម្ពសៀវភៅដែលប្រមូលបទពិសោធន៍ឈឺចាប់របស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីក្រោមរបប DK ហើយក៏ស្នើសុំឱ្យផ្សាយសក្ខីកម្មជនរងគ្រោះនៅក្នុងដំណើរការកាត់ក្ដីតាមប៉ុស្ដិ៍ទូរទស្សន៍រដ្ឋ និងឯកជនផងដែរ។ មានមួយក្រុមក៏បានស្នើសុំឱ្យ អ.វ.ត.ក ផ្ដល់ច្បាប់ចម្លងសាលក្រមដល់ពួកគេ ហើយមួយក្រុមទៀតសុំឱ្យចែករំលែកសំណុំរឿង និងឯកសារដើមរបស់បណ្ដឹងរដ្ឋប្បវេណីដល់ពួកគេ។

## ● ការចងចាំ ០១

- ការសាងសង់ស្តូប និងចេតិយនៅទូទាំងប្រទេស
- ការគាំទ្រសម្រាប់ពិធីសាសនានៅកន្លែងទាំងនេះ
- ការថែទាំ ការអភិរក្សទីតាំងឧក្រិដ្ឋកម្មទូទាំងប្រទេស
- ការអនុម័តឡើងវិញនូវថ្ងៃទី២០ ឧសភា ជាថ្ងៃឈប់សម្រាកសាធារណៈ
- ការបង្កើតបណ្តាញជនរងគ្រោះសម្រាប់ការប្រាស្រ័យទាក់ទងទៀងទាត់ និងការជួបជុំដែលដំណើរការដោយ អ.វ.ត.ក

## ● ការស្តារនីតិសម្បទា ០២

- ការផ្តល់ "ប័ណ្ណសមធម៌" ដើម្បីឱ្យលទ្ធភាពទទួលបានការថែទាំសុខភាព និងផ្លូវចិត្តដោយមិនគិតថ្លៃ
- ផ្តល់វិញ្ញាបនបត្រផ្លូវការដល់ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូប
- សិទ្ធិទទួលបានយុត្តិធម៌ និងជំនួយផ្នែកច្បាប់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី
- យកចិត្តទុកដាក់លើរបួស និងការព្យាបាល

## ● ការអប់រំ ០៣

- បញ្ចូលប្រវត្តិ KR ទៅក្នុងកម្មវិធីសិក្សារបស់សាលារដ្ឋទាំងអស់ ហើយផ្តល់ការយកចិត្តទុកដាក់ជាពិសេសចំពោះរឿងរ៉ាវនៃការរស់រានមានជីវិត និង CPs
- អនុវត្តកម្មវិធីសំណង "អណ្តើកក្លាហាន" ថ្មីមួយទៀត
- បង្កើតជនជានប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីកំណត់គោលដៅមនុស្សជំនាន់ក្រោយជាមួយនឹងព័ត៌មានប្រវត្តិសាស្ត្រ

## ● ការចងក្រងឯកសារ ០៤

- បោះពុម្ព និងផ្សព្វផ្សាយសម្ភារសម្រាប់ CPs ដើម្បីពិនិត្យមើលសក្ខីកម្មផ្ទាល់ខ្លួនរបស់ពួកគេ និងសម្រាប់មនុស្សជំនាន់ក្រោយ
- ផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នូវច្បាប់ចម្លងនៃសាលក្រមព្រមទាំងបណ្តឹងដើម និងទម្រង់បែបបទរបស់ពួកគេផងដែរ
- ធ្វើឱ្យឯកសារទាំងនេះមាននៅតាមសាលារៀន បណ្ណាល័យ
- បង្ហោះ និងរក្សាការចូលប្រើឯកសារតាមអ៊ីនធឺណិត

ដូចបានរៀបរាប់ខាងលើក្នុង II.4 ភ្ញៀវមកពីក្រៅចំនួន ៨៦នាក់ បានចូលរួមសិក្ខាសាលាតាមរយៈវេទិកា KUDO អនឡាញ។ ក្នុងនោះមានភ្ញៀវយ៉ាងហោចណាស់ ២៥នាក់ ចូលរួមពីក្រៅប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែពេលវេលាខុសគ្នា មិនមានអ្នកចូលរួមច្រើនក្នុងវគ្គទាំងអស់បានទេ ហើយអ្នកផ្សេងទៀតមិនអាចចូលរួមវគ្គសូម្បីតែមួយបានទាល់តែសោះ។ ចំនួនសំណើដ៏ច្រើន បានធ្វើឡើងនៅក្នុងឆ្លើយតបទៅនឹងការអំពាវនាវនៅខែតុលា ឆ្នាំ២០២១ របស់សហចៅក្រមរបាយការណ៍ ពោលគឺបានមកពីអ្នកស្រាវជ្រាវ និងអ្នកតស៊ូមតិនៅក្រៅប្រទេស។ បុគ្គលទាំងនេះ និងអ្នកផ្សេងទៀតជាច្រើនបានចូលរួមជាយូរមកហើយនៅក្នុងការងារយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា ក្នុងករណីខ្លះមុនពេល អ.វ.ត.ក បានបង្កើតឡើងទៅទៀត។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការស្តាប់គំនិតរបស់ពួកគេ និងអនុញ្ញាតឱ្យពួកគេមានឱកាសពិភាក្សាអំពីសំណួរដូចគ្នាមួយចំនួនដែលបានលើកឡើងនៅក្នុងសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ ទីបំផុត ក្រុមក្រៅប្រទេសត្រូវបានរៀបចំតាមរយៈប្រព័ន្ធ Zoom នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ។ ការរៀបចំនេះបានផ្តល់ពេលវេលាគ្រប់គ្រាន់អាចចែករំលែកការវាយតម្លៃ និងសេចក្តីសង្ខេបនៃសិក្ខាសាលា ជាមួយអ្នកចូលរួមដែលជាក្រុមនៅក្រៅប្រទេស ដើម្បីអាចឱ្យពួកគេឆ្លើយតបទៅនឹងចំណុចជាក់លាក់ណាមួយដែលបានលើកឡើង ឬ ស្របជាមួយនឹងសំណើ និងការពិភាក្សាដែលមាននៅក្នុងក្រុមការងារតូចៗរបស់សិក្ខាសាលា។ បុគ្គលសរុបចំនួន ១២នាក់ ដែលមានមូលដ្ឋាននៅអាមេរិកខាងជើង និងអឺរ៉ុបបានចូលរួមការពិភាក្សានេះ។

បន្ទាប់មក អ្នកចូលរួមបានផ្ញើសំណើជាផ្លូវការជាក្រុម ហើយអ្នកចូលរួម Laura McGrew និង Mychelle Balthazard បានដាក់សំណើបន្ថែមរៀងៗខ្លួន។ លក្ខិណា នូ ដែលបានចូលរួមក្នុងការពិភាក្សាជាក្រុម បានដាក់សំណើដាច់ដោយឡែកមួយ ដែលត្រូវបានយកមកពិភាក្សានៅខាងក្រោមក្នុងផ្នែកបន្តបន្ទាប់អំពីសំឡេងរបស់ប្រជាជននៅក្រៅប្រទេស ក្នុងនាមស្ថាប័នរបស់លោកស្រី គឺ ASRIC។ សំណើទាំងអស់ ត្រូវបានរួមបញ្ចូលផងដែរនៅក្នុងឧបសម្ព័ន្ធ VII។

ក្រុមនៅក្រៅប្រទេសហាក់បីដូចជាបានពិភាក្សាយ៉ាងទូលំទូលាយ ជាហេតុនាំឱ្យមានការដាក់សំណើលម្អិតក្នុងនោះមានអនុសាសន៍ "ពាក់ព័ន្ធគ្នា" ចំនួនប្រាំបី។ សំណើរបស់ពួកគេសង្កត់ធ្ងន់លើការចង់ឱ្យផ្តល់មូលនិធិដល់ដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់អាទិភាពលើគម្រោង និងសេវាជូនដល់ជនរងគ្រោះ-អ្នករស់រានមានជីវិត និងផ្តល់តម្លៃលើជាតុចូលរបស់ពួកគេ។ ឧទាហរណ៍ ក្រុមនៅក្រៅប្រទេសកត់សំគាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំសាងសង់ស្តូបម្តងហើយម្តងទៀត តែមិនទទួលបានផលដូចអ្វីដែលយើងបានឮនៅក្នុងសិក្ខាសាលា និងនៅក្នុងវេទិកា VSS-CPLCL នោះទេ។ ដើម្បីជានាថាគម្រោងបំពេញតាមអាទិភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមនេះផ្តល់អនុសាសន៍ឱ្យបង្កើត "ក្រុមប្រឹក្សាដែលបានជ្រើសរើសដោយប្រុងប្រយ័ត្ន និងប្រកបដោយតម្លាភាព" ដើម្បីជួយជ្រើសរើស

កម្មវិធីសម្រាប់ដំណាក់កាលដែលនៅសេសសល់។ ក្រុមនេះក៏បានសង្កត់ធ្ងន់ផងដែរអំពីតម្រូវការក្នុងការផ្សារភ្ជាប់

សេវាថែទាំសុខភាពជាមួយនឹងសេវាថែទាំសុខភាពផ្លូវចិត្ត ហើយពិចារណាពីវិធីណាមួយដែលអាចអភិវឌ្ឍប្រព័ន្ធនៅកម្ពុជា ដើម្បីព្យាបាលរបួសដែលនៅបន្តដិតដាមរហូតមកដល់សព្វថ្ងៃនេះ ក្នុងចំណោមអ្នករស់រានមានជីវិតទាំងនៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស។ ដូចបានពិភាក្សានៅក្នុងផ្នែកបន្ទាប់ ពួកគេក៏ផ្តល់អនុសាសន៍ថាដើមបណ្តឹង

រដ្ឋប្បវេណី និងជនរងគ្រោះដែលនៅរស់រានមានជីវិតនៅក្រៅប្រទេស គួររួមបញ្ចូលនៅក្នុងការពិគ្រោះយោបល់ ការធ្វើផែនការ និងការអនុវត្តគម្រោងបែបនេះផងដែរ។

ក្រុមជាក់លាក់នេះលើកឡើងអំពីការចាត់វិធានការចាំបាច់ក្នុងការដោះស្រាយបញ្ហាអារម្មណ៍ឯកោរបស់អ្នករស់រានមានជីវិត តាមរយៈការព្យាបាល និងការផ្សះផ្សា។ ពួកគេស្នើកម្មវិធីសក្តានុពលមួយ ដើម្បីផ្តល់ការធ្វើតេស្តហ្សែនដោយឥតគិតថ្លៃ ដើម្បីជួយឱ្យសមាជិកគ្រួសារដែលបែកគ្នាអាចជួបជុំគ្នា ហើយពួកគេផ្តល់ការគាំទ្រដល់សំណើរបស់ GIZ-CPS (ដែលបានដាក់ជូនសហចៅក្រមរបាយការណ៍) ឱ្យបង្កើត "បញ្ជីអ្នកបាត់ខ្លួន"។ ក្រុមនេះសង្កត់ធ្ងន់លើការយកចិត្តទុកដាក់លើតម្រូវការ និងបំណងប្រាថ្នារបស់អ្នករស់រានមានជីវិតពី SGBV និងពង្រីករឿងរ៉ាវដែលប្រមូលបាន ព្រមទាំងបើកទ្វារឱ្យមានការសន្ទនានាពេលអនាគតលើសពីសំអាងហេតុដែល អ.វ.ត.ក បានរកឃើញលើបញ្ហានេះ។ ក្រុមនេះក៏អំពាវនាវផងដែរ អំពីតម្រូវការលើកកម្ពស់ការផ្សះផ្សាជាមួយ

សហគមន៍អតីតខ្មែរក្រហម ដូចជា ប៉ៃលិន និងអន្លង់វែង ដើម្បីបំបាត់ការមាក់ងាយសង្គមជូនជនល្មើសពីមុន និងញាតិមិត្តរបស់ពួកគេ អាចឱ្យពួកគេចូលរួមក្នុងសហគមន៍វិញក្នុងរយៈពេលយូរ។ ក្រុមនេះណែនាំឱ្យមានការចូលរួមពីមនុស្សគ្រប់ជំនាន់ចាប់ពីយុវជនរហូតដល់មនុស្សចាស់ក្នុងដំណើរការនេះ។

ចំណុចនេះជំរុញឱ្យមានការពិភាក្សាលម្អិតនៅក្នុងសំណើអំពីអនាគតនៃបណ្ណសាររបស់ អ.វ.ត.ក និងការចូលមើលបណ្ណសារ ជាពិសេសសម្រាប់រយៈពេលយូរ ដោយពួកគេពន្យល់ថា "បណ្ណសារនឹងជាកេរដំណែលដ៏សំខាន់បំផុត"។ អ្នកចូលរួមម្នាក់ស្នើថា បណ្ណសារជាតិកម្ពុជានឹងជាទីតាំងទទួលស្វាគមន៍សាធារណជនចូលមើលជាសាធារណៈ។ ទោះយ៉ាងណាក៏ដោយ ពួកគេសង្កត់ធ្ងន់សាជាថ្មីថា ប្រជាជនកម្ពុជាខ្លួនឯងគួរតែមានកម្មសិទ្ធិលើបណ្ណសារជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សីដែលបានរៀបរាប់រឿងរ៉ាវនៅក្នុងឯកសារទាំងនោះ។ ពួកគេសង្កត់ធ្ងន់ថា បណ្ណសារចាំបាច់ត្រូវមានលក្ខណៈទូលំទូលាយ និងបើកឱ្យសាធារណជនអាចចូលប្រើប្រាស់បាន។ ក្រុមនេះអំពាវនាវឱ្យ

បណ្ណសាររបស់ អ.វ.ត.ក ភ្ជាប់ជាមួយបណ្ណសារខ្មែរក្រហមផ្សេងទៀតទាំងអស់ រួមទាំងឯកសារនៅស្ថាប័នផ្សេងទៀតក្នុងប្រទេសកម្ពុជា (TSGM, DC-Cam) និងនៅបរទេស (Cornell, Yale Cambodia Genocide Project)។ ក្រុមនេះមិនមែនបង្ហាញការព្រួយបារម្ភចំពោះតែភាគីជាតិលើការងារបណ្ណសារនោះទេ ពួកគេក៏សង្កេតឃើញថា ការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ (OLA) ដែលនឹងចូលរួមនៅក្នុងការសម្រេចចិត្តទាក់ទងនឹងច្បាប់ចម្លងនៃបណ្ណសាររបស់ភាគីអន្តរជាតិ "មិនមានប្រវត្តិធ្លាប់រក្សាទុកបណ្ណសារបើកចំហបែបនេះផងដែរ"។

ជាចុងក្រោយ ក្រុមនេះក៏បានលើកឡើងអំពីកង្វះតម្លាភាព ឬការចែករំលែកព័ត៌មានពី អ.វ.ត.ក ហើយពួកគេលើកឡើង បញ្ហានេះបានធ្វើឱ្យប្រជាជនកម្ពុជាបាត់បង់ទំនុកចិត្ត និងក្តីសង្ឃឹមលើ អ.វ.ត.ក។ ក្រុមនេះក៏បានអំពាវនាវឱ្យ CPLCLs ទទួលបានមូលនិធិពេញលេញ និងចូលរួមក្នុងការពិភាក្សាទាំងអស់ ដើម្បីតស៊ូមតិសម្រាប់កូនក្តីរបស់ពួកគេ ហើយក៏បានផ្តល់យោបល់ថា ការប្រកាសសាលក្រមនៃសំណុំរឿង ០០២/០២ ដែលជិតមកដល់នៅចុងឆ្នាំនេះ អាចជា "ឱកាសដ៏ល្អ" ដើម្បីចែករំលែកព័ត៌មានជាមួយជនរងគ្រោះ-អ្នករស់រានមានជីវិតក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស។ ពួកគេក៏កត់សម្គាល់ផងដែរថា អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវការព័ត៌មានតាមដានអំពីស្ថានភាពនៃពាក្យសុំរបស់ពួកគេ និងសំណុំរឿងទាំងនោះ។

សំណើដាច់ដោយឡែករបស់ Laura McGrew បានលើកឡើងថា ក្នុងអំឡុងពេលទស្សនកិច្ចសិក្សាស្រាវជ្រាវក្រៅផ្លូវការនៅកម្ពុជាកាលពីដើមឆ្នាំ២០២២ លោកស្រីបានរកឃើញមាន "ការថយចុះគួរឱ្យកត់សម្គាល់នៃការយល់ដឹង ការគាំទ្រ និងការពេញចិត្តចំពោះ អ.វ.ត.ក" ពីអ្នកឆ្លើយតបដែលលោកស្រីធ្លាប់បានធ្វើការងារជាមួយជាយូរមកហើយ។ លោកស្រីសង្កេតឃើញថា ថ្មីៗនេះ អ.វ.ត.ក មានសភាពស្ងប់ស្ងាត់ការងារ ដោយមានការផ្សព្វផ្សាយព័ត៌មាន ឬ ធ្វើសកម្មភាពការងារតិចតួចជាមួយជាសាធារណៈ ឬ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ លោកស្រីអំពាវនាវឱ្យ អ.វ.ត.ក និងរាជរដ្ឋាភិបាលផ្សព្វផ្សាយជាសាធារណៈនូវដំណើរការចុងក្រោយរបស់សាលាក្តី និងសកម្មភាពពាក់ព័ន្ធ ឱ្យបានទូលំទូលាយតាមតែអាចធ្វើទៅបានតាមទូរទស្សន៍ វិទ្យុ និងវេទិកាផ្សេងទៀត។ លោកស្រីបានអំពាវនាវឱ្យ "អង្គភាពព័ត៌មានសាធារណៈ ឬអង្គការមិនមែនរដ្ឋាភិបាលដែលខិតខំប្រឹងប្រែងពេញម៉ោង មានបុគ្គលិក និងទទួលបានមូលនិធិពេញលេញ យកចិត្តទុកដាក់ "បង្កើតការងារនេះឡើងវិញ"។ លើសពីនេះ លោកស្រីបានសង្កត់ធ្ងន់លើតម្រូវការឱ្យមានការសម្របសម្រួលជាទៀងទាត់រវាង អ.វ.ត.ក, UNAKRT, LDC, រដ្ឋាភិបាល, ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។

McGrew បង្ហាញការសង្កេតបន្ថែមទៀតនូវសំណើជាហូរហែរបស់អ្នករស់រានមានជីវិតសុំឱ្យមានការផ្តល់សេវាថែទាំសុខភាព និងសេវាសង្គម និងការពង្រីកសក្តានុពលបន្ថែមនៃ "ប័ណ្ណក្រីក្រ"

---

[៤៧] យើងសូមថ្លែងអំណរគុណ Laura McGrew ដែលជាអ្នកស្រាវជ្រាវយូរមកហើយ និងជាអ្នកជំនាញផ្នែកយុត្តិធម៌អន្តរកាលនៅកម្ពុជា សម្រាប់ការគាំទ្រ និងការសម្របសម្រួលដ៏មិនគួរឱ្យជឿ ក្នុងការរៀបចំការពិភាក្សាជាក្រុមតាមអ៊ីនធឺណិតនេះសម្រាប់អ្នកចូលរួមនៅក្រៅប្រទេស។ ការយកចិត្តទុកដាក់របស់លោកស្រីបានជួយលេខាធិការដ្ឋាន អាចស្តាប់នូវទស្សនៈពីអ្នកចូលរួមនៅក្រៅប្រទេស ដើម្បីបំពេញបន្ថែមនូវអ្វីដែលយើងបានពិភាក្សានៅក្នុងសិក្ខាសាលា ហើយលោកស្រីក៏បាននាំយកនូវបណ្តាញចម្រុះនៃភាគីពាក់ព័ន្ធ និងអ្នកជំនាញសំខាន់ៗ រួមទាំងសំឡេងអ្នករស់នៅក្រៅប្រទេសដើម្បីប្រើប្រាស់ឱកាសនេះឱ្យបានច្រើនបំផុតស្តាប់ការចែករំលែករបស់ពួកគេនូវធាតុចូល និងសំណូមពរសម្រាប់ អ.វ.ត.ក នៅពេលចូលដល់ដំណាក់កាលដែលនៅសល់។ លោកស្រីក៏បានផ្តោតសំខាន់ និងលើកស្ទួយសំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិត-ជនរងគ្រោះផ្សេងទៀត ដែលលោកស្រីបានជួបក្នុងអំឡុងពេលបំពេញការងារនៅជនបទភាគពាយ័ព្យនៃប្រទេសកម្ពុជាក្នុងដំណើរទស្សនកិច្ចនាពេលថ្មីៗនេះ។ យើងក៏សូមថ្លែងអំណរគុណចំពោះអ្នកចូលរួមក្រុមនៅក្រៅប្រទេសសម្រាប់ការចូលរួមយ៉ាងសកម្មក្នុងដំណើរការនេះ និងសម្រាប់ការចំណាយពេលនោះដើម្បីជួប និងចែករំលែកទស្សនៈរបស់ពួកគេ។

ដល់អ្នករស់រានមានជីវិត។ លោកស្រីក៏កត់សម្គាល់ផងដែរថា សំណើដែលបានចែករំលែកនៅក្នុងរបាយការណ៍ ប្រឹក្សាយោបល់របស់សហចៅក្រមរបាយការណ៍ គួរបន្តសកម្មភាពពីមុនដែលសម្រេចបាន ដោយបានលើកជាយោបល់ថា "មិនចាំបាច់បង្កើតការងារនេះឡើងវិញនោះទេ"។ លោកស្រីក៏បានអំពាវនាវឱ្យអង្គការសង្គមស៊ីវិលទាក់ទងនឹងសេវាថែទាំសុខភាព ចូលរួមផងដែរ រួមមាន HelpAge និង NGO-Forum ដែលអង្គការទាំងពីរបានចូលរួមសិក្ខាសាលានៅក្នុងខែឧសភា ឆ្នាំ២០២២ ក៏ដូចជាគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលទទួលការអញ្ជើញ ប៉ុន្តែមិនអាចចូលរួមបាន និងជម្មាយាត្រាមង្គលបូរីដ៏មានតម្លៃដែលនឹងខិតចូលមកជិត។

លោកស្រីក៏បានសង្កត់ធ្ងន់ផងដែរអំពីតម្រូវការពង្រឹងតម្លាភាព និងការចែកចាយព័ត៌មានទាំងអស់អំពីដំណើរការដំណាក់កាលដែលនៅសេសសល់ ឱ្យកាន់តែទូលំទូលាយ។ នៅពេលកត់សម្គាល់អំពីការខ្វះខាតព័ត៌មានសាធារណៈ និងព័ត៌មានផ្សព្វផ្សាយអំពីការផ្តល់មូលនិធិ និងផែនការសម្រាប់ដំណាក់កាលដែលនៅសេសសល់ លោកស្រីអំពាវនាវឱ្យមានយន្តការកំណត់ផែនការទាំងនោះដើម្បីអាចចែករំលែកជាសាធារណៈ។ លោកស្រីស្នើឧបករណ៍មួយចំនួនសម្រាប់ការអនុវត្តល្អបំផុតលើការផ្តល់មូលនិធិដល់កម្មវិធីយុត្តិធម៌អន្តរកាល ហើយអំពាវនាវឱ្យបង្កើតគណៈកម្មាធិការប្រឹក្សា ឬ គណៈកម្មាធិកាពិនិត្យសំណើទាំងអស់ត្រួតពិនិត្យកម្មវិធី និងធានាឱ្យមានគណនេយ្យភាព។ លោកស្រីក៏សង្កេតឃើញថា កង្វះព័ត៌មានអំពីការចូលអានបណ្ណសារចាំបាច់ត្រូវដោះស្រាយ ហើយលោកស្រីអំពាវនាវឱ្យមានការរួមបញ្ចូលអង្គការមិនមែនរដ្ឋាភិបាល ដើមបណ្តឹងរដ្ឋប្បវេណី និងស្ថាប័នទាំងអស់របស់ អ.វ.ត.ក ដើម្បីចូលរួមនៅក្នុងការអភិវឌ្ឍគោលនយោបាយចូលប្រើប្រាស់បណ្ណសារ។ លោកស្រីកត់សម្គាល់ថា ត្រូវតែមានការគាំទ្រផ្នែកច្បាប់ច្បាស់លាស់ និងជាអចិន្ត្រៃយ៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី រួមទាំង ការកាត់ក្តី ឬសំណុំរឿងទាំងអស់ ហើយលោកស្រីផ្តល់យោបល់ថា សិទ្ធិជនរងគ្រោះ សិទ្ធិជនជាតិភាគតិច ការដាក់បញ្ចូលអន្តរជំនាន់ ភាពរសើបនៃជម្លោះ និងការយល់ដឹងអំពីយេនឌ័រ ត្រូវតែបញ្ចូលទៅក្នុងសំណើទាំងអស់សម្រាប់ដំណាក់កាលដែលនៅសេសសល់។

ចំណុចចុងក្រោយ លោកស្រីកត់សម្គាល់ថា មិនទាន់មានការស្ទាបស្ទង់មតិទូលំទូលាយ និងរួម ដែលកន្លងមកធ្វើឡើងយូរមកហើយ។ លោកស្រីស្នើឱ្យមានការប្រមូលទិន្នន័យ "ដើម្បីវាយតម្លៃការយល់ឃើញរបស់អ្នករស់រានមានជីវិត" ក៏ដូចជា "ការធ្វើបច្ចុប្បន្នភាពការសិក្សាអំពីឥទ្ធិពលលើជំនាន់ទីពីរ" នៃជនរងគ្រោះ-អ្នករស់រានមានជីវិត និងអតីតខ្មែរក្រហម។ លោកស្រីពន្យល់ថា ការវាយតម្លៃបែបនេះមានសារៈសំខាន់អាចឱ្យយើងយល់ដឹងអំពីការផ្សះផ្សា ឬយុត្តិធម៌។

នៅក្នុងសំណើដាច់ដោយឡែករបស់លោកស្រី Mychelle Balthazard មកពីអង្គការគំនិតផ្តួចផ្តើមមនុស្សធម៌របស់សាកលវិទ្យាល័យ Harvard ក៏បានអំពាវនាវឱ្យមានការវាយតម្លៃលើការចូលរួមចំណែករបស់ អ.វ.ត.ក និងគម្រោងយុត្តិធម៌អន្តរកាលពាក់ព័ន្ធ។ លោកស្រីស្នើឱ្យមានការស្ទាបស្ទង់ គុណវិស័យ និងបរិមាណវិស័យ ដោយផ្តោតលើជនរងគ្រោះ ហើយក្រោយមកទៀតអាចថាប្រជាជនទូទៅនៅក្នុងប្រទេសកម្ពុជា។ លោកស្រីស្នើថា ការវាយតម្លៃត្រឹមត្រូវនឹងអនុញ្ញាតឱ្យមានការប្រៀបធៀបការរកឃើញទៅនឹងការស្រាវជ្រាវមុនដែលបានធ្វើតាំងពីពេលបង្កើត អ.វ.ត.ក ហើយនឹងអាចពិនិត្យមើលតម្រូវការរបស់ជនរងគ្រោះក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង។ ការវាយតម្លៃការស្រាវជ្រាវចាប់ដើមដំបូងរហូតដល់ការផ្សព្វផ្សាយចុងក្រោយ នឹងចំណាយពេលប្រហែលប្រាំមួយខែ។ លោកស្រីពន្យល់ថាទិន្នន័យដែលប្រមូលបាន នឹងជួយក្នុងការផ្តល់ និងការអនុវត្តកម្មវិធីដែលអាចឱ្យយើងពេញចិត្តជាងមុន ចំពោះជនរងគ្រោះ-អ្នកនៅរស់រានមានជីវិត ហើយនឹង "ពង្រីកជាអតិបរិមាផែនការ" ក្នុងដំណាក់កាលដែលនៅសេសសល់។

## ● OVERSEAS FOCUS GROUP (អាមេរិក និងអឺរ៉ុប) ០១

- ការផ្តល់មូលនិធិសម្រាប់គម្រោង CP និងជនរងគ្រោះ/អ្នករស់រានមានជីវិត គួរតែត្រូវបានផ្តល់អាទិភាព តាមរយៈក្រុមប្រឹក្សាប្រឹក្សា ដែលបានជ្រើសរើសដោយប្រុងប្រយ័ត្ន និងប្រកបដោយតម្លាភាព អាចជួយធានាថាគម្រោងត្រូវបានជ្រើសរើសដោយផ្អែកលើកង្វល់ និងផលប្រយោជន៍របស់ប្រជាជនកម្ពុជា
- វាយតម្លៃតម្រូវការនិងបំណងប្រាថ្នារបស់អ្នករស់រានមានជីវិត SGBV
- យកចិត្តទុកដាក់លើការផ្សះផ្សា ជាពិសេសនៅតំបន់អតីតខ្មែរក្រហម
- ដើមបណ្តឹងរដ្ឋប្បវេណីនៅក្រៅប្រទេស (CP) និងជនរងគ្រោះ/អ្នករស់រានមានជីវិត គួរតែត្រូវបានរួមបញ្ចូលនៅក្នុងការពិគ្រោះយោបល់ និងគម្រោង
- ភ្ជាប់សេវាថែទាំសុខភាព និងសុខភាពផ្លូវចិត្ត និងផ្តល់សេវាកម្មជាច្រើនទៀត
- តម្លាភាព និងការចែករំលែកព័ត៌មានពី អ.វ.ត.ក រួមទាំងការផ្តល់មូលនិធិសម្រាប់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

## ● MYCHELLE BALTHAZARD ០២

- អង្កេត/ផ្តោតលើក្រុមដើម្បីវាយតម្លៃការរួមចំណែករបស់ អ.វ.ត.ក គម្រោងពាក់ព័ន្ធលើយុត្តិធម៌ និងការផ្សះផ្សា កំណត់តម្រូវការរបស់ជនរងគ្រោះ វាយតម្លៃផលប៉ះពាល់នៃគម្រោងដែលបានអនុវត្តរួចហើយ និងវាយតម្លៃលទ្ធភាពនៃការដោះស្រាយតម្រូវការជនរងគ្រោះក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង

- ការគាំទ្រសម្រាប់គម្រោងដែលមានស្រាប់ ក៏ដូចជាសំណើបន្ថែម។ សេវាថែទាំសុខភាព និងសេវាសង្គម (រួមទាំងសម្រាប់អ្នករស់រានមានជីវិតពី SGBV) និងជាពិសេស ការផ្តល់ "ប័ណ្ណក្រីក្រ" របស់រដ្ឋាភិបាលក៏ត្រូវបានលើកឡើងជាញឹកញាប់ដោយអ្នករស់រានមានជីវិត ហើយត្រូវបានលើកឡើងនៅក្នុងសំណើមួយចំនួន
- ការផ្សព្វផ្សាយ បណ្តាញ និងការចែករំលែកព័ត៌មានត្រូវតែជាអាទិភាព។ អង្គភាពព័ត៌មានសាធារណៈ ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានបុគ្គលិកពេញម៉ោង និងទទួលបានមូលនិធិ និងមានការយកចិត្តទុកដាក់ ត្រូវតែបង្កើតឡើងវិញ
- ការគាំទ្រផ្នែកច្បាប់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានវចនាសម្ព័ន្ធស្ថាប័នច្បាស់លាស់ និងអចិន្ត្រៃយ៍ ជាមួយនឹងធនធានសមស្រប
- ការដាក់បញ្ចូលក្នុងយន្តការដើម្បីជានាសិទ្ធិជនរងគ្រោះ សិទ្ធិជនជាតិភាគតិច ការដាក់បញ្ចូលទាំងយុវជន និងមនុស្សចាស់ ភាពរសើបនៃជម្លោះ និងការយល់ដឹងអំពីយេនឌ័រ
- បន្តការត្រួតពិនិត្យគម្រោងដើម្បីការពារសិទ្ធិជនរងគ្រោះ
- បានធ្វើបច្ចុប្បន្នភាពការស្ទង់មតិលើការយល់ឃើញអំពីយុត្តិធម៌ ការផ្សះផ្សា និងសំណង
- បណ្ណសារ និងការចូលប្រើប្រាស់ត្រូវតែជានា និងទំនាក់ទំនង
- ដំណើរការផ្តល់មូលនិធិប្រកបដោយតម្លាភាព និងប្រកាន់ខ្ជាប់នូវជម្លោះ



ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក រៀបចំវេទិកាសាធារណៈ នៅសំឡូត អតីតតំបន់ឈរជើងរឹងមាំរបស់ខ្មែរក្រហម។

ក្នុងអំឡុងពេលរៀបចំផែនការ និងការពិគ្រោះយោបល់ទូលំទូលាយសម្រាប់សិក្ខាសាលាខែឧសភា ឆ្នាំ២០២២ ដែលបានពិពណ៌នានៅកន្លែងផ្សេងទៀតនៅក្នុងរបាយការណ៍នេះ ក្រុមសំខាន់មួយត្រូវបានទុកចោល៖ ប្រជាជនកម្ពុជាកំពុងរស់នៅក្រៅប្រទេស ជាពិសេស នៅសហរដ្ឋអាមេរិក បារាំង អូស្ត្រាលី និងកាណាដា។ ចំណុចនេះគឺជាការបង្ហាញថា អ.វ.ត.ក បានគិតគូរប្រជាជនភាគច្រើននៅក្នុងស្ថាប័នប្រវត្តិសាស្ត្ររបស់ខ្លួន នះក្រោយគេ។ ទោះបីមានឧបសគ្គក្នុងការរួមបញ្ចូលក្រុមនេះក្នុងលក្ខណៈប្រកបដោយផ្លែផ្កា និងយុត្តិធម៌ ពីចម្ងាយក៏ដោយ ការខិតខំប្រឹងប្រែងបែបនេះត្រូវតែធ្វើឡើងនាពេលអនាគត។ សហគមន៍ប្រជាជនកម្ពុជាមិនមែនរស់នៅទីនោះដោយឯកឯងដាច់ដោយឡែកពីព្រឹត្តិការណ៍ ឬសហគមន៍ក្នុងប្រទេសកម្ពុជា ឬ សកម្មភាពរបស់ អ.វ.ត.ក និងកម្មវិធីយុត្តិធម៌អន្តរកាលដែលកំពុងដំណើរការនៅក្នុងសង្គមស៊ីវិលកម្ពុជានោះទេ។ សហគមន៍នេះកើតមានជាចម្បងដោយសារតែជម្លោះ របប និងអំពើឃោរឃៅ ដែលចាំបាច់ត្រូវតែបង្កើត អ.វ.ត.ក ជាស្ថាប័នមួយ។ ពួកគេបន្តមានទំនាក់ទំនងខ្លាំងជាមួយប្រទេសកម្ពុជា ជាពិសេសតាមរយៈទំនាក់ទំនងគ្រួសារ និងក្នុងចំណោមយុវជនខ្មែរដែលមានដើមកំណើតនៅបរទេសដែលបានមកតាំងទីលំនៅក្នុងប្រទេសកម្ពុជា ហើយបានកាន់តួនាទីឈានមុខក្នុងវិស័យពាណិជ្ជកម្ម សង្គម និងវប្បធម៌របស់ប្រទេស។

ការខកខានមិនបានបញ្ចូលសំឡេងសហគមន៍នេះនៅក្នុងសិក្ខាសាលា អាចត្រូវបានកែតម្រូវភ្លាមៗតាមរយៈការចូលរួមសកម្មក្នុងការពិគ្រោះយោបល់ និងការរៀបចំផែនការសម្រាប់ដំណាក់កាលដែលនៅសេសសល់នាពេលខាងមុខ។ ទោះបីកម្មវិធីដែលបានស្នើឡើង ដូចជាការពង្រឹករបបសន្តិសុខសង្គម ឧទាហរណ៍ "ប័ណ្ណក្រីក្រ" ប្រហែលជាមិនអនុវត្តចំពោះជនរងគ្រោះ-អ្នកនៅរស់រានមានជីវិតកម្ពុជាដែលរស់នៅក្រៅប្រទេសនោះទេ សហគមន៍ទាំងនោះអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំសកម្មភាពរំលឹកការចងចាំ បង្កើតឧបករណ៍អប់រំ និងការចូលរួមការសន្ទនាអន្តរជំនាន់។ សហគមន៍អ្នករស់រានមានជីវិតនេះ ក៏ទទួលរងនូវរបួសផ្លូវចិត្តធ្ងន់ធ្ងរផងដែរ ជួនកាលអាចអាក្រក់ទៅៗដោយសារភាពឯកោក្នុងអារម្មណ៍ពួកគេដោយសាររស់នៅឆ្ងាយពីប្រទេសកំណើតរាប់ឆ្នាំ ឬរាប់ទសវត្សរ៍ ។ ពួកគេសមនឹងទទួលបានសេរីភាពពីទម្ងន់អតីតកាលដូចអ្នករស់រានមានជីវិតក្នុងប្រទេសកម្ពុជាដែរ។ គោលបំណងទាំងអស់នេះបាននាំឱ្យជនរងគ្រោះ-អ្នករស់រានមានជីវិតរាប់រយនាក់មកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងទាំង០៤ នៅចំពោះមុខ អ.វ.ត.ក ប៉ុន្តែការបន្តការខកខានក្នុងការដាក់បញ្ចូលប្រកបដោយអត្ថន័យ ជាគ្រោះថ្នាក់បង្កការមិនពេញចិត្តកាន់តែខ្លាំងចំពោះដំណើរការរបស់ អ.វ.ត.ក។ វាក៏ជាការប្រថុយប្រថានធ្វើឱ្យអ្នករស់រានមានជីវិតទាំងនេះមានអារម្មណ៍ថា ខ្លួនគ្មានតម្លៃ ឯកោ កុំថាឡើយការបង្ករបួសផ្លូវចិត្តឡើងវិញ។

ការខកខានក្នុងការបញ្ចូលសំឡេងសហគមន៍នេះគឺជាការបាត់ឱកាសមួយ៖ ការដាក់សហគមន៍នេះអាចពង្រីកបណ្តាញ និងលទ្ធភាពនៃការងារយុត្តិធម៌អន្តរកាលដែលកើតចេញពីដំណើរការរបស់ អ.វ.ត.ក និងអាចទាក់ទាញធនធានក្រៅប្រទេសកាន់តែច្រើន ដែលចាប់អារម្មណ៍ក្នុងការឆ្លើយតបទៅនឹងស្ថានភាពដែលពាក់ព័ន្ធ និងតម្រូវការសហគមន៍កម្ពុជានៅក្នុងក្រុងឡុងប៊ិចជាយក្រុងប៉ារីស ឬម៉ែលប៊ន។ តាមរយៈការកសាង និងពឹងផ្អែកលើទំនាក់ទំនងជាធម្មតា និងផ្ទាល់ជាមួយសំឡេងសហគមន៍នៅទូទាំងពិភពលោក អ.វ.ត.ក ក៏អាចពង្រីកសាររបស់ខ្លួន ពោលគឺ ទាំងនៅក្នុងសំអាងហេតុនៃសេចក្តីសម្រេចរបស់តុលាការ និងការងារសេសសល់ដែលខិតជិតមកដល់នៅលើឆាកអន្តរជាតិ។ ការងារផ្សព្វផ្សាយ និងការចូលរួមបែបនេះគឺពាក់ព័ន្ធជាពិសេសចំពោះក្មេងជំនាន់ក្រោយដែលមានទស្សនសាកលភាវូបនីយកម្មកាន់តែខ្លាំងឡើង ដែលបានជំជាត់នៅឆ្ងាយពីមាតុភូមិដូនតារបស់ពួកគេ មិនយល់ច្បាស់អំពីជម្រៅនៃរបួសផ្លូវរបស់ឪពុកម្តាយ

[48] លក្ខិណា នូ, លើសពីការរងទុក្ខស្ងៀមស្ងាត់ និងរបួសផ្លូវចិត្ត នៅឆ្ងាយពាក់កណ្តាលពិភពលោក៖ការចូលរួមរបស់អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ដោយជនភៀសខ្លួននៅក្នុង អ.វ.ត.ក, ពិភពលោកអាស៊ីប៉ាស៊ីហ្វិក ៤(១) (និទាឃរដូវ ២០១៣), ទំព័រ ៥៦-៧៩។

ពួកគេ ហើយជួនកាលទទួលរងពីរបួសផ្លូវចិត្តក្នុងលក្ខណៈប្រយោល។

លេខាធិការដ្ឋានអាចបន្តកិច្ចសន្ទនាជាមួយ បណ្ឌិត លក្ខិណា នូ សាស្ត្រាចារ្យនៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ា ឡុងប៊ិច (CSULB) និងជាស្ថាបនិក ASRIC ដែលបានផ្តល់យោបល់យ៉ាងទូលំទូលាយទាក់ទងនឹងដំណាក់កាលដែលនៅសេសសល់ និងបានដាក់សំណើគម្រោងកម្មវិធីអន្តរជាតិ ដែលរួមបញ្ចូលទាំងស្រុងនៅក្នុងឧបសម្ព័ន្ធ ៧។ លេខាធិការដ្ឋានក៏បានទទួលសំណើបន្ថែមមួយពី បណ្ឌិត សម្ផស្ស ហ៊ុយ ដែលបច្ចុប្បន្នមានមូលដ្ឋាននៅប្រទេសបារាំង បន្ទាប់ពីបម្រើការងារជាច្រើនឆ្នាំនៅសាកលវិទ្យាល័យ Rutgers សហរដ្ឋអាមេរិក និងមុនការងារនេះ បានបម្រើការងារនៅ VSS នៃ អ.វ.ត.ក និងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

តាមរក្សាការពិគ្រោះយោបល់របស់អ្នកសម្របសម្រួលជាមួយ លក្ខិណា នូ និង Sansitny Ruth ដែលជាតំណាងរបស់លោកស្រីមានមូលដ្ឋាននៅប្រទេសកម្ពុជា យើងចាំបាច់ត្រូវយល់អំពីតួនាទីរបស់សហគមន៍ នៅក្នុងដំណើរការ អ.វ.ត.ក។ ចំណុចនេះត្រូវបានសង្ខេបបានយ៉ាងល្អជាមួយនឹងទិន្នន័យនៅក្នុងសំណើរបស់ក្រុមសហគមន៍ក្រៅប្រទេស ដូចបានពិភាក្សាខាងលើ ដែល លក្ខិណា នូ បានចូលរួមផងដែរ៖

---

**ថ្វីត្បិតតែប្រជាជនកម្ពុជានៅក្រៅប្រទេសមានការចូលរួមកម្រិត បើប្រៀបធៀបនឹងអ្នកនៅក្នុងប្រទេសកម្ពុជាដែលមានចំនួនច្រើនគួរឱ្យកត់សម្គាល់ ក៏ប៉ុន្តែតាមការប៉ាន់ស្មាន មានចំនួន ៣៣៩.០០០ នៅសហរដ្ឋអាមេរិកគិតត្រឹមឆ្នាំ២០១៩, ៥០០.០០០ នៅប្រទេសបារាំង និង ៦៦.០០០ នៅអូស្ត្រាលី។ ខណៈពេលដែលមានតែ ៣.៣% នៃ[ដើមបណ្ដឹងរដ្ឋប្បវេណី] និងពាក្យបណ្ដឹងមកពីក្រៅប្រទេសកម្ពុជាក្នុងសំណុំរឿង ០០២ វិទ្យាស្ថាន ASRIC បានជួយប្រជាជនកម្ពុជានៅសហរដ្ឋអាមេរិកដាក់ទម្រង់បែបបទព័ត៌មានជនរងគ្រោះ (VIF) ហើយក្នុងនោះទម្រង់បែបបទចំនួន ១៧០ ត្រូវបានទទួលយក ពាក្យសុំតាំងខ្លួនជា [ដើមបណ្ដឹងរដ្ឋប្បវេណី] ចំនួន ៤១ និងបណ្ដឹងចំនួន ១២៩ (ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ០៤បន្ថែម) បានចូលរួមជាមួយ ASRIC នៅពេលដែលមេធាវីរបស់ពួកគេមិនអាចបន្តតំណាងពួកគេ)។ ដំបូងឡើយ មជ្ឈមណ្ឌលដើម្បីយុត្តិធម៌ និងគណនេយ្យភាព បន្តតំណាងកូនក្តីចំនួន ៤១ [ដើមបណ្ដឹងរដ្ឋប្បវេណី] ដែលត្រូវបានជ្រើសរើសដោយ ASRIC តាមរយៈដំណើរការចូលរួមរបស់សហគមន៍ ហើយឥឡូវនេះតំណាងឱ្យកូនក្តី [ដើមបណ្ដឹងរដ្ឋប្បវេណី] ខ្មែរ-អាមេរិកសរុបចំនួន ១០៥នាក់នៅក្នុងសំណុំរឿង ០០២/១, ០០២ /២, ០០៣, ០០៤ និង ០០៤/២។**

---

នៅក្នុងការពិគ្រោះយោបល់ម្តងហើយម្តងទៀត ចាប់តាំងពីសិក្ខាសាលាខែឧសភា ឆ្នាំ២០២២ លក្ខិណា នូ បានបញ្ជាក់ម្តងហើយម្តងទៀតអំពីតួនាទីរបស់ ASRIC ក្នុងប្រវត្តិដំណើរការ អ.វ.ត.ក ដោយកត់សម្គាល់ថាទម្រង់ព័ត៌មានជនរងគ្រោះចំនួន ១៧៤ ដែលប្រមូលបានក្នុងសំណុំរឿង ០០២ ក្រោមគម្រោងចូលរួមរបស់ជនរងគ្រោះ ដោយសហគមន៍កម្ពុជានៅក្រៅប្រទេស

របស់ ASRIC តំណាងកម្រងសក្ខីកម្មដ៏ច្រើនបំផុតពីប្រទេសក្រៅ។ លោកស្រីបានកត់សម្គាល់បន្ថែមទៀតថា ទម្រង់ទាំង ១៧៤ ត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណី ឬ ដើមបណ្ដឹងបរិហារ ឬ "អត្រាជោគជ័យ ១០០% ដែលមិនធ្លាប់មានពីមុនមក"។ ទោះបីជាយ៉ាងណាក៏ដោយ លោកស្រីបានពន្យល់ថា អ្នកនៅរស់រានមានជីវិតមិនបានទទួលនូវអ្វីដែលពួកគេបានស្នើសុំនៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះដំបូងឡើយ ហើយអ្នកនៅរស់រានមានជីវិតជាច្រើនបានបន្តដំណើរទៅមុខទៀត។ លោកស្រីបានពន្យល់ថា លោកស្រី និងជនរងគ្រោះ-អ្នករស់រានមានជីវិតដែលបានចូលរួមក្នុងដំណើរការ អ.វ.ត.ក "លែងមានទំនុកចិត្តទៀតហើយ" ហើយដំណើរការរបស់សាលាក្ដីនេះជារឿយៗបង្កឱ្យមានកំហឹង និងការខកចិត្ត។ លោកស្រីបានសង្ខេបថា "តុលាការលែងមានអត្ថិភាពទៀតហើយសម្រាប់អ្នករស់រានមានជីវិតជាច្រើន"។ លោកស្រីបានពន្យល់ថា តាំងពីដើមដំបូងមក មិនទាន់មានការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពនោះទេ ហើយលោកស្រីបានអំពាវនាវឱ្យមានការវាយតម្លៃអំពីតម្រូវការលម្អិត និងការចូលរួមរបស់យុវជន ឱ្យបានស៊ីជម្រៅជាងមុន ព្រមទាំងផ្សព្វផ្សាយការទទួលខុសត្រូវ និងភាពជាម្ចាស់នៅក្នុងដំណើរការយុត្តិធម៌នេះ ដើម្បីជៀសវាងការកំណត់ដោយបុគ្គលតែមួយចំនួនតូច។ នៅពេលអំពាវនាវឱ្យមានការពិគ្រោះយោបល់ច្រើនជាងមុនជាមួយជនរងគ្រោះ-អ្នករស់រានមានជីវិតពីក្នុងចំណោមសហគមន៍ក្រៅប្រទេស លោកស្រីបានរៀបរាប់អំពីកម្មវិធីជាក់លាក់មួយចំនួនសម្រាប់សំណង និងការផ្សះផ្សា ដែលលើកឡើងដោយជនរងគ្រោះ-អ្នករស់រានមានជីវិត៖

- គំនូរសិល្បៈ ខ្សែភាពយន្ត របាំ និងតន្ត្រី ជាទម្រង់នៃការព្យាបាល ដើម្បីបង្ហាញអំពីរបៀបរបបរស់នៅមុនរបបខ្មែរក្រហម។

- ការចូលរួមកាន់តែច្រើនជាងមុននៅតាមសាកលវិទ្យាល័យ និងក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវ និងការយកចិត្តទុកដាក់កាន់តែខ្លាំងលើយុវជន។

- ការយកចិត្តទុកដាក់ជាពិសេសលើកូនចៅរបស់ចារី ដោយលើកឡើងអំពីការស្រាវជ្រាវដែលលោកស្រីបានចូលរួមជាមួយកូនប្រុសរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលទទួលរងការមាក់ងាយ និងរបួសផ្លូវចិត្តដោយប្រយោលដោយសារការរួមរស់ជាមួយឪពុកដែលត្រូវបានតុលាការផ្ដន្ទាទោស ។[៥០]

- ការពិគ្រោះយោបល់ជាទៀងទាត់ជាមួយអ្នករស់រានមានជីវិតនៅក្នុងទីកន្លែងមានផាសុខភាព ជាធម្មតាមណ្ឌលសាសនាដូចជាវត្តអារាម ឬ វិហារអ៊ីស្លាម។ និង,

- វិធីសាស្ត្ររួមចំពោះសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដែលអាចជៀសវាងការមាក់ងាយ។

ភាគច្រើននៃសំណើទាំងនេះនៅក្នុងការពិគ្រោះយោបល់របស់យើងត្រូវបានបញ្ចូលជាប្រធានបទទៅក្នុងសំណើគម្រោងស៊ីជម្រៅ និងលម្អិតរបស់ ASRIC នៅក្នុងសំណើរបស់ពួកគេដូចបានរួមបញ្ចូលនៅក្នុងឧបសម្ព័ន្ធ VII។ ASRIC អំពាវនាវឱ្យមានការបង្កើតកម្មវិធីពហុបំណង ហៅថា "គម្រោងការវិវត្តកម្ពុជា" (KEP)។ វារួមបញ្ចូលទាំងកម្មវិធីសិក្សាឆ្លងព្រំជាតិស្ដីពីការសិក្សាវប្បធម៌ខ្មែរ ដែលផ្អែកលើបណ្ដាញ និងធនធានស្ថាប័នសិក្សានៅសហរដ្ឋអាមេរិក (ដូចជា CSULB) និងអ្នកសិក្សាខ្មែរ-អាមេរិកក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យយុវជនខ្មែរជំនាន់ក្រោយ ដែលជំនឹងក្ដីនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស ចូលរួមស្វែងយល់អំពីអត្តសញ្ញាណវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ពួកគេ។ ក្នុងការបង្កើតកម្មវិធីអន្តរវប្បធម៌ និងអន្តរជាតិនេះ ASRIC បានភ្ជាប់ការខ្វះការយល់ដឹងអំពីវប្បធម៌កម្ពុជា ឬ អារម្មណ៍វិជ្ជមាននៃអត្តសញ្ញាណជាមួយការខ្វះការយល់ដឹងអំពីខ្លួនឯង និងអារម្មណ៍នៃភាពគ្មានទីពឹងកើតឡើងសុះសាយក្នុងចំណោមយុវជនកម្ពុជា។ Sansitny Ruth ជនជាតិខ្មែរ-កាណាដា ដែលតំណាងឱ្យ ASRIC នៅទីក្រុងភ្នំពេញ បានយកបទពិសោធន៍ផ្ទាល់ខ្លួនមកពន្យល់អំពីតម្រូវការសម្រាប់កម្មវិធីប្រភេទនេះ។ គាត់មានអារម្មណ៍ថាបាន

[៤៩] លក្ខិណា នូ, ការរស់នៅក្នុងស្រមោលឪពុក៖ ការស្វែងយល់ពីយុត្តិធម៌នៃការព្យាបាល និងការផ្សះផ្សានៅកម្ពុជាជាមួយកូនប្រុសរបស់ឌុច, ទិនានុប្បវត្តិវិទ្យាសាស្ត្រសង្គមអាស៊ី ៤១(១) (មករា ២០១៣), ទំព័រ ៥៦-៧៩។

[៥០] លក្ខិណា នូ, ការរស់នៅក្នុងស្រមោលឪពុក៖ ការស្វែងយល់ពីយុត្តិធម៌នៃការព្យាបាល និងការផ្សះផ្សានៅកម្ពុជាជាមួយកូនប្រុសរបស់ឌុច, ទិនានុប្បវត្តិវិទ្យាសាស្ត្រសង្គមអាស៊ី ៤១(១) (មករា ២០១៣), ទំព័រ ៥៦-៧៩។



ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក រៀបចំវេទិកាសាធារណៈសម្រាប់ព្រះសង្ឃចំនួន៤០០អង្គ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ។

ទទួលរងផលប៉ះពាល់ពីអំពើឃោរឃៅកាលពីអតីតកាលនៅក្នុងប្រទេសកម្ពុជា ក្នុងលក្ខណៈមួយមិនអាចពន្យល់បានតាំងពីក្មេងមក៖ អារម្មណ៍សោកសៅ ឬ សម្ពាធដែលមើលមិនឃើញនៅពេលចូលផ្ទះសហគមន៍រស់នៅក្រៅប្រទេស អារម្មណ៍ជនបរទេសជារៀងរហូត កង្វះអ្នកផ្តល់ការណែនាំ ឬ ឧទាហរណ៍នៃភាពជោគជ័យក្នុងចំណោមសហគមន៍កម្ពុជាដែលធំដឹងក្តីនៅក្រៅប្រទេស ហើយអារម្មណ៍នូវការបាត់បង់អ្វីមួយនៅជាប់ជាមួយរហូតមក ដែលអាចជួយក្នុងដំណើរការព្យាបាលរបួសផ្លូវចិត្ត។ ដូច្នេះ ASRIC បានស្នើឱ្យមានការវាយតម្លៃអំពីតម្រូវការ និងការបង្កើតកម្មវិធីសិក្សា និងធនធានអប់រំដែលប្រើប្រាស់វប្បធម៌សម្រាប់ការព្យាបាលរបួសផ្លូវចិត្ត ដោយកសាងចេញពី និងផ្អែកមូលដ្ឋានគ្រឹះលើទំនាក់ទំនងឆ្លងព្រំដែនរបស់សហគមន៍នៅក្រៅប្រទេស និងដែលឆ្លើយតបទៅនឹងនឹងរបួសផ្លូវចិត្តអន្តរជំនាន់ដោយសាររបបខ្មែរក្រហម។ សំណើក្នុងកម្មវិធី KEP ក៏មានគោលបំណងគាំទ្រដល់ការទទួលបានសេវាថែទាំសុខភាពទូទៅ និងសេវាថែទាំសុខភាពផ្លូវចិត្តកាន់តែច្រើនឡើងដើម្បីជាយន្តការអន្តរាគមន៍ និងការបង្ការការពារ។ សំណើនេះក៏មានគម្រោងបង្កើតថ្នាលគេហទំព័រដែលអាចចូលប្រើប្រាស់សេវា និងកំណត់គោលដៅជាពិសេសលើយុវជនកម្ពុជាជំនាន់ក្រោយនៅទូទាំងពិភពលោក តាមរយៈការបង្ហាញអំពីការចូលរួមចំណែកផ្នែកសិល្បៈ ក៏ដូចជាឧបករណ៍សិក្សាប្រកបដោយវិជ្ជាជីវៈ និងបច្ចេកទេសផងដែរ។ សំណើរបស់ពួកគេរួមមានស្ថាប័ន និងអាចជាដៃគូសិក្សា ទាំងនៅក្នុងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា រួមទាំងទំនាក់ទំនងដែលត្រូវបានបង្កើតឡើងជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងចំណោមស្ថាប័នផ្សេងទៀត។ គម្រោងនេះ និងការងារដ៏ច្រើនដែលមានរយៈពេលជាច្រើនឆ្នាំនៅពីក្រោយសំណើររបស់ខ្លួនបង្ហាញអំពីធនធាន និងអត្ថប្រយោជន៍ដែលបង្ហាញថា ការចូលរួមកាន់ច្រើនជាមួយសហគមន៍ក្រៅប្រទេសអាចផ្តល់ដល់ភាពជោគជ័យនៃដំណាក់កាលដែលនៅសេសសល់របស់ អ.វ.ត.ក។ គម្រោងនេះក៏ជានាដំណើរការនេះឱ្យទទួលបានផ្លែផ្ការយៈពេលយូរ ដែលនឹងកើតឡើងឆ្លងព្រំដែន និងឆ្លងជំនាន់។

បន្ថែមពីលើការពិភាក្សាយ៉ាងទូលំទូលាយដែលបានធ្វើឡើងចាប់តាំងពីសិក្ខាសាលាជាមួយ ASRIC អ្នកសម្របសម្រួលក៏បានទទួលសំណើពីបណ្ឌិត សម្ផស្ស ហ៊ុយ ដែលជាអ្នកសិក្សាស្រាវជ្រាវមានដើមកំណើតនៅប្រទេសកម្ពុជា និងបច្ចុប្បន្ន រស់នៅប្រទេសបារាំង។ ជាមួយនឹងបទពិសោធន៍ពីមុនរបស់លោកស្រីបណ្ឌិត ដែលធ្លាប់ធ្វើការនៅ VSS របស់ អ.វ.ត.ក សំណើរបស់លោកស្រី ដែលបានកត់សម្គាល់អំពីការពិភាក្សាជាមួយអ្នកផ្ដល់ព័ត៌មានជាដើមបណ្ដឹងរដ្ឋប្បវេណីមានមូលដ្ឋាននៅប្រទេសបារាំងផ្ដោតលើតម្រូវការប្រែក្លាយ VSS ទៅជាស្ថាប័ន ដែលបង្កើតឡើងដើម្បីតស៊ូមតិទាមទារតម្រូវការជូនជនរងគ្រោះ-អ្នករស់រានមានជីវិត និងមនុស្សជំនាន់ក្រោយសម្រាប់រយៈពេលវែង។ សំណើរបស់លោកស្រីបញ្ជាក់ម្ដងហើយម្ដងទៀតអំពីតម្រូវការបង្កើតស្ថាប័ន VSS ឱ្យឯករាជ្យពេញលេញពីរដ្ឋាភិបាល បើទោះបីជាស្នើសុំការការគាំទ្រពីរាជរដ្ឋាភិបាល ដូចជា ទីតាំងសម្រាប់ជាការិយាល័យ បរិក្ខារផ្សេងទៀត ឬ អាចថាមូលនិធិ។ លោកស្រីបញ្ជាក់អំពីតម្រូវការចង់ឱ្យ VSS ជាយន្តការអចិន្ត្រៃយ៍ សហការជាមួយសមាគមជនរងគ្រោះនៅបរទេស ហើយថែមទាំងផ្ដល់យោបល់ថា VSS អាចបើកសាខានៅតាមខេត្តនានាក្នុងប្រទេសកម្ពុជា។ សំណើសុំនេះ ពាក់ព័ន្ធទៅនឹងសំណើមួយចំនួនដែលបានបង្ហាញនៅក្នុងពេលសិក្ខាសាលា ក្នុងពេលនោះដើមបណ្ដឹងរដ្ឋប្បវេណីនិងអ្នកពាក់ព័ន្ធបានអំពាវនាវឱ្យមានការរៀបចំស្ថាប័នរយៈពេលវែងជាយន្តការតស៊ូមតិសម្រាប់ជនរងគ្រោះ។

តារាងខាងក្រោមសង្ខេបសំណើ ចំនួនពីរមកពីសហគមន៍អ្នកនៅក្រៅប្រទេស។

## ASRIC ០១

- សំឡេងអ្នកនៅក្រៅប្រទេស មានសារៈសំខាន់សម្រាប់ អ.វ.ត.ក ដោយមានដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកឥវារាប់រយនាក់មកពីសហគមន៍ក្រៅប្រទេសចែករំលែកបទពិសោធន៍របស់ពួកគេជាមួយនឹងទម្រង់ព័ត៌មានជនរងគ្រោះចំនួន ១៧៤ ដែលត្រូវបានប្រមូលដោយ ASRIC នៅក្នុងសហរដ្ឋអាមេរិក
- ការពិគ្រោះយោបល់ជាទៀងទាត់ និងចាំបាច់ជាមួយអ្នករស់រានមានជីវិតចាំ
- ការចូលរួមកាន់តែច្រើននៅក្នុងសាកលវិទ្យាល័យ និងអ្នកសិក្សាស្រាវជ្រាវ និងការផ្ដោតអារម្មណ៍របស់យុវជនគឺចាំបាច់ទាំងនៅក្នុងប្រទេសកម្ពុជា និងសម្រាប់ក្រុមជនពិការនៅសហរដ្ឋអាមេរិក និងកន្លែងផ្សេងទៀត
- គម្រោង Kambuja Evolution (KEP) បង្កើតទំនាក់ទំនងសិក្សាឆ្លងជាតិលើការសិក្សាវប្បធម៌ខ្មែរទាំងនៅសហរដ្ឋអាមេរិក និងកម្ពុជា ដើម្បីគាំទ្រដល់ការរីកចម្រើននៃការសិក្សាវប្បធម៌ និងការអភិវឌ្ឍអត្តសញ្ញាណខ្មែរដ៏វិជ្ជមាន ធ្វើឱ្យយុវជនកម្ពុជាបានរៀនសូត្រពីជំនាន់មុន និង ស្វែងរកការបំផុសគំនិត តម្លៃ ការបង្ហាត់បង្រៀន និងជួយសម្រួលដល់វប្បធម៌នៃការព្យាបាល និងដោះស្រាយការប៉ះទង្គិចគ្នារវាងជំនាន់ដែលបានកន្លងផុតទៅ

## DR. HUY SAMPHOAS ០២

- ប្រែក្លាយ VSS ទៅជាស្ថាប័នឯករាជ្យមួយដែលបានបង្កើតឡើងដើម្បីតស៊ូមតិសម្រាប់តម្រូវការរបស់អ្នករស់រានមានជីវិត-ជនរងគ្រោះ និងមនុស្សជំនាន់ក្រោយសម្រាប់រយៈពេលវែង

# IV.

# សេចក្តីសង្កេត ប្រធានបទរួម និងអនុសាសន៍


190 ស្ថានភាពជនរងគ្រោះ

193 "មិនបង្កការឈឺចាប់" និងជៀសវាងរបួសផ្លូវចិត្ត ជាថ្មីដល់ជនរងគ្រោះ

195 ភាពជាម្ចាស់នៅថ្នាក់មូលដ្ឋាន និងជាបុគ្គល សមាហរណកម្ម និងចីរភាព

198 ប្រធានបទរួម គោលការណ៍ និងចំណុចព្រមព្រៀង

203 ផែនការយុទ្ធសាស្ត្រសម្រាប់គំនិតផ្តួចផ្តើមផ្តោតលើ ជនរងគ្រោះក្នុងដំណាក់កាលដែលនៅសេសសល់



ប៉ុន្មានខែចុងក្រោយនេះ លេខាធិការដ្ឋានមានឱកាសចូលរួមជាមួយភាគីពាក់ព័ន្ធជាច្រើន ដែលពោរពេញដោយការគិតគូគ្រប់ជ្រុងជ្រោយ និងជាមួយអ្នកនៅរស់រានមានជីវិត ដែលបានបន្តអភិវឌ្ឍ និងចែករំលែកគំនិត និងសំណើជាច្រើនទម្រង់។ ទស្សនៈអំពីគម្រោងទាំងនេះត្រូវបានគ្រោងទុកសម្រាប់គ្រប់បណ្តាខេត្តក្នុងប្រទេសកម្ពុជា ហើយខ្លះមានទំនាក់ទំនងជាអន្តរជាតិខ្លាំងណាស់ដែរ។ ការសរសេរកម្មវិធីសក្តានុពលហាក់ដូចជាមានលក្ខណៈចម្រុះរួម ដោយយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នចំពោះបញ្ហានៃការបង្កការឈឺចាប់ទាក់ទងនឹងយេនឌ័រ ស្ថានភាពជនជាតិភាគតិច ឬសុខភាពផ្លូវចិត្ត។ បន្ទាប់ពីបានពិនិត្យឡើងវិញលើកម្មវិធីសិក្ខាសាលាកាលពីខែឧសភា ឆ្នាំ២០២២ និង

សេចក្តីសង្ខេបលម្អិតនៃសំណើរាប់សិបដែលបានចែករំលែកចាប់តាំងពីការអំពាវនាវរបស់សហចៅក្រមរបាយការណ៍កាលពីខែតុលា ឆ្នាំ២០២១ ឱ្យដាក់សំណើ យើងក៏បានងាកទៅពិនិត្យមើលប្រធានបទ និងចំណុចសំខាន់ៗមួយចំនួនដែលយើងសង្កេតឃើញថាមានលក្ខណៈរួមគ្នា។ បន្ទាប់មក យើងព្យាយាមដាក់ចេញកិច្ចខិតខំប្រឹងប្រែងបង្កើតក្របខ័ណ្ឌដំណាក់កាលដែលនៅសេសសល់សម្រាប់រយៈពេលបីឆ្នាំបន្ទាប់ ដោយពិពណ៌នាអំពីគំរូសក្តានុពលសម្រាប់ អ.វ.ត.ក អនុវត្តគម្រោង ដែលបានពិភាក្សានៅក្នុងរបាយការណ៍រហូតមកដល់ពេលនេះ។

← សាធារណជនអានសៀវភៅព័ត៌មានអំពី អ.វ.ត.ក ខណៈរង់ចាំចូលរួម ការប្រកាសសាលក្រម ក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤។

# ស្ថានភាពជនរងគ្រោះ

ដូចបានកត់សម្គាល់ខាងលើ របាយការណ៍របស់សហចៅក្រមរបាយការណ៍បានគិតគូរអំពីបុគ្គលជាច្រើនប្រភេទ ដែលនឹងទទួលបានអត្ថប្រយោជន៍ពីសកម្មភាពទាក់ទងនឹងជនរងគ្រោះ ជាងអ្វីដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ។ សហចៅក្រមបានអំពាវនាវឱ្យមានសំណើ "ដែលមានអត្ថន័យ និងអាចជួយយូរអង្វែងដល់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះនៃរបបខ្មែរក្រហម និងសាធារណជនទូទៅ" ។ នៅពេល អ.វ.ត.ក ឈានចូលដំណាក់កាលដែលនៅសេសសល់ ជាសមស្របដែលយើងគួរពិចារណាឡើងវិញអំពីប្រភេទបុគ្គលដែលយើងត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេនៅក្រោមទម្រង់ "សកម្មភាពទាក់ទងនឹងជនរងគ្រោះ"។ ដូចបានបញ្ជាក់ច្បាស់នៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍ សហចៅក្រមយល់ច្បាស់ថា សម្រាប់គោលបំណងនៃសកម្មភាពក្នុងដំណាក់កាលដែលនៅសេសសល់ ទស្សនទានអំពី "ជនរងគ្រោះ" មិនគួរកម្រិតត្រឹមអ្នកដែលត្រូវបានកំណត់តាមនីតិវិធីតុលាការនៃ អ.វ.ត.ក ដែលត្រូវបានពិពណ៌នាខាងលើនៅក្នុង I.២។ បន្ថែមលើបុគ្គលទាំងនោះដែលរងទុក្ខដោយផ្ទាល់ក្រោមកណ្តាប់ដៃខ្មែរក្រហម មិនថាជាមនុស្សពេញវ័យ ឬ កុមារ សំណើដែលបានដាក់ជូនសហចៅក្រមរបាយការណ៍ ចែករំលែក និងបង្កើតនៅសិក្ខាសាលាជនរងគ្រោះ ហើយដាក់ជូនមកយើងខ្ញុំនៅពេលក្រោយមកបញ្ជាក់យ៉ាងច្បាស់ថា ទិដ្ឋភាពអន្តរជំនាន់នៃស្ថានភាពជនរងគ្រោះ ត្រូវតែឆ្លើយតបឱ្យបានពេញលេញ ដើម្បីសម្រេចបាននូវគោលដៅសមស្របទៅនឹងដំណាក់កាលដែលនៅសេសសល់នៃសកម្មភាពទាក់ទងនឹងជនរងគ្រោះ។ ទិដ្ឋភាពអន្តរជំនាន់ទាំងនេះរួមមានរបួសផ្លូវចិត្តដែលបន្តប៉ះពាល់ដល់គ្រួសារកម្ពុជា និងបុគ្គលជាច្រើនក្នុងនោះប្រមាណ ៧០% នៃប្រជាជនដែលកើតក្រោយរបបខ្មែរក្រហម។ តម្រូវការនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងពេលសិក្ខាសាលាថាមានសារៈសំខាន់ខ្លាំង និងត្រូវបានគូសបញ្ជាក់ជាកការងារអាទិភាពសម្រាប់ដំណាក់កាលដែលនៅសេសសល់។

ទិដ្ឋភាពមួយទៀតនៃស្ថានភាពជនរងគ្រោះ ដែលលេចចេញម្តងហើយម្តងទៀតពីការពិភាក្សានៅក្នុងសិក្ខាសាលា ក៏ដូចជាសំណើ គឺស្ថានភាពសហគមន៍មូលដ្ឋាន ដែលអតីតខ្មែរក្រហម ជនរងគ្រោះ និងជនដៃដល់ ដែលបានក្លាយជាជនរងគ្រោះរស់នៅក្បែរគ្នា។ ការរួមចំណែកជាច្រើនក្នុងការពិភាក្សា និងសំណើ ដែលដោះស្រាយស្ថានការណ៍នេះ បានបញ្ជាក់យ៉ាងច្បាស់ថា នៅក្នុងករណីទាំងនេះ សហគមន៍ទាំងមូលរងផលប៉ះពាល់ដោយកេរដំណែលនៃអំពើឃោរឃៅរបស់ខ្មែរក្រហម។ អាស្រ័យហេតុនេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានពិពណ៌នាអំពីផលប៉ះពាល់នៃរបួសផ្លូវចិត្តលើជីវិតរបស់ពួកគេ និងការខឹងសម្បារ ដែលមិនទាន់អាចដោះស្រាយបាន បានអំពាវនាវឱ្យបង្កើតមជ្ឈមណ្ឌលនៃការចងចាំ ដែលជារឿយៗត្រូវបានផ្សារភ្ជាប់ជាមួយនឹងស្តូប មិនមែន "បូជនីយដ្ឋាន" ប៉ុន្តែជាកន្លែងដែលសហគមន៍អាច

៥១ អ.វ.ត.ក សហចៅក្រមរបាយការណ៍ស្តីពីជនរងគ្រោះ៖ ការអំពាវនាវឱ្យមានការចូលរួមជាគំនិត ទំព័រ ១១។

ផ្លាស់ចេញពីភាពស្ងៀមស្ងាត់ និងទទួលយកអតីតកាល។ តម្រូវការក្នុងការបង្កើតទីតាំងក្នុងស្រុកបែបនេះមានការគាំទ្រពីសង្គមស៊ីវិលជាច្រើនដែលបានចូលរួមក្នុងសិក្ខាសាលា ហើយក៏បានលើកឡើងក្នុងសំណើជូនសហចៅក្រមរបាយការណ៍ផងដែរ។ តាមទស្សនៈនេះ សហគមន៍ទាំងអស់នេះអាចចាត់ទុកថាជាសហគមន៍ជនរងគ្រោះ ពីព្រោះមិនថាជាអតីតជនល្មើស ជនរងគ្រោះ ឬ ជនល្មើស-ជនរងគ្រោះ ជីវិតរបស់ពួកគេ និងកូនៗរបស់ពួកគេ ត្រូវបានកំណត់ទៅតាមជោគវាសនាសហគមន៍ ដែលផលនៃរបបខ្មែរក្រហម និងផលវិបាកដ៏យូរអង្វែង ដែលប្រជាជនកម្ពុជាជាច្រើនលាននាក់នៅតែទទួលរងអារម្មណ៍នេះដូចសព្វថ្ងៃនេះ រួមទាំងនៅក្នុងចំណោមសហគមន៍ក្រៅប្រទេសផងដែរ។

គេក៏អាចនៅចងចាំផងដែរអំពីមរតកនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ។ ដូចបានបញ្ជាក់នៅក្នុងកិច្ចពិភាក្សាសិក្ខាសាលា និងសុន្ទរកថាសំខាន់ៗរបស់លោកស្រី យឹម និង Dato' Alagendra អំពើនេះត្រឹមតែប៉ះពាល់ដល់ជនរងគ្រោះផ្ទាល់ប៉ុណ្ណោះទេ រួមទាំងកូនៗរបស់ពួកគេផងដែរ។ ដូចវិសាលភាពនៃសំណុំរឿង ០០១ និង ០០២ បានបង្ហាញ វាក្តោបរួមទាំងទុក្ខវេទនាដែលកើតមានលើប្រជាជនកម្ពុជានៅគ្រប់ទីកន្លែងក្នុងនៃប្រទេស ទុក្ខវេទនានៅតែទទួលរងដោយជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេសព្វថ្ងៃ។ នៅពេល អ.វ.ត.ក បិទដំណើរការប្រតិបត្តិការតុលាការ តើមានអ្វីជាយុត្តិកម្មសម្រាប់ការកំណត់វិសាលភាពនៃ "ជនរងគ្រោះ" ចំពោះបុគ្គលមួយចំនួន ដែលត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការថាជាដើមបណ្តឹងបរិហារ ឬដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការចូលរួមក្នុងសំណុំរឿងទាំងនោះ? ដូចបានទទួលស្គាល់នៅក្នុងបទបង្ហាញគន្លឹះ យោងតាមពាក្យពេចន៍របស់ជនរងគ្រោះដែលបាននិយាយក្នុងសិក្ខាសាលា និងអ្នកចូលរួមផ្សេងទៀត នៅពេលភ្ជាប់ "សកម្មភាពទាក់ទងនឹងជនរងគ្រោះ" ជាមួយដំណាក់កាលសកម្មភាពដែលនៅសេសសល់ ប្រាកដជាបានបដិសេធបុគ្គលជាច្រើន ដែលសមនឹងទទួលងារជាជនរងគ្រោះ ការទទួលស្គាល់ និងយុត្តិធម៌ដែលពួកគេសមនឹងទទួលបាន។

តម្រូវការសម្រាប់ការកំណត់ទស្សនទាន "ជនរងគ្រោះ" ឡើងវិញ ក៏លេចឡើងចេញពីការពិចារណាលើគោលដៅរបស់ អ.វ.ត.ក ជាស្ថាប័នមួយ និងជាពិសេសដំណាក់កាលការងារដែលនៅសេសសល់។ ប្រសិនបើចង់បានការផ្សះផ្សា ការព្យាបាលរបួសផ្លូវចិត្ត និងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកដែលបានប៉ះពាល់ផ្លូវចិត្ត និងរូបកាយ នៃរបបខ្មែរក្រហម តើវាអាចសម្រេចបានយ៉ាងដូចម្តេច ប្រសិនបើកម្មវិធីពាក់ព័ន្ធនឹងជនរងគ្រោះ មិនផ្តោតលើសង្គមកម្ពុជាទាំងមូល ទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ? ដូចបានគូសបញ្ជាក់នៅក្នុងសំណើ និងអន្តរាគមន៍ជាច្រើននៅក្នុងការពិភាក្សានេះ យើងត្រូវការកម្មវិធី "ទូទាំងប្រទេស" ហើយទស្សនទាននៃ "ក្របខ័ណ្ឌជាតិ" ត្រូវតែរួមបញ្ចូលផងដែរ។ ដូចបានបញ្ជាក់ នៅក្នុងសុន្ទរកថាគន្លឹះ ក្រុមទាំងអស់ត្រូវទទួលអត្ថប្រយោជន៍ពីកម្មវិធីបែបនេះ ការស្វែងរកការពិត ការផ្សះផ្សា និងសកម្មភាពពាក់ព័ន្ធត្រូវតែ "ធ្វើមូលដ្ឋានីយកម្ម" ប្រសិនបើមានប្រសិទ្ធភាព។ ទាំងនេះគឺជាបុរេលក្ខខណ្ឌសម្រាប់ "ដំណើរផ្លូវព្យាបាលរបួសផ្លូវចិត្ត" ដែលស្នើឡើងដោយលោកស្រី យឹម សុជារី ហើយការផ្តល់ធនធានដែលនឹងជួយជនរងគ្រោះកុំឱ្យ "ជាប់គាំង" នៅក្នុងស្ថានភាពជាជនរងគ្រោះ ដូចដែលបានស្នើឡើងដោយ Dato' Shyamala Alagendra។

# "មិនបង្កការឈឺចាប់" និងជៀសវាងរបួសផ្លូវចិត្តជាថ្មីដល់ជនរងគ្រោះ

ដូចបានកត់សម្គាល់ពីខាងដើម អនុសាសន៍របស់សហចៅក្រមរបាយការណ៍ រួមបញ្ចូលការទទួលស្គាល់គោលការណ៍ថា "គំនិតផ្តួចផ្តើមណាមួយត្រូវតែផ្តល់អាទិភាពលើគោលការណ៍ "មិនបង្កការឈឺចាប់"។ ចំណុចនេះបានធ្វើឡើងនៅក្នុងឯកសារមួយចំនួនដែលបានដាក់ជូនសហចៅក្រមរបាយការណ៍ ហើយត្រូវបានរំលេចនៅក្នុងសុន្ទរកថាគន្លឹះ និងនៅក្នុងការពិភាក្សា និងបទបង្ហាញរបស់ក្រុមពិភាក្សា។ ការព្រួយបារម្ភនៅទីនេះ កើតចេញពីការណ៍ដែលថា អន្តរាគមន៍ប្រកបដោយអត្ថន័យរបស់បុគ្គល ឬអង្គការដែលពុំបានយល់ដឹងជាមុន មិនមានការបណ្តុះបណ្តាល និងបទពិសោធន៍ អាចធ្វើឱ្យជនរងគ្រោះ ឬសហគមន៍ ចូលរួមក្នុងកម្មវិធីជាចុងក្រោយបង្កផលវិបាក និងព្យសនកម្មដល់ពួកគេ ដោយអចេតនា។ ការព្រួយបារម្ភមួយទៀត គឺស្ថាប័នធំៗ ដូចជា អ.វ.ត.ក អាចសន្យាច្រើនពេក ឬ កំណត់ការរំពឹងទុកខ្ពស់ពេក នៅពេលដែលស្ថាប័ននេះឆ្លើយតបដោយផ្ទាល់ទៅនឹងតម្រូវការ ឬសំណើរបស់ជនរងគ្រោះ ប៉ុន្តែបែរជាធ្វើឱ្យពួកគេខកចិត្តនៅពេលក្រោយទៅវិញ។ ការខកចិត្តនេះអាចនាំឱ្យមានកើតមានភាពឯកោកាន់តែខ្លាំង ឬ ភាពអស់សង្ឃឹមសម្រាប់ជនរងគ្រោះដែលមានក្តីសង្ឃឹមច្រើនពីតុលាការ និងដំណាក់កាលដែលនៅសេសសល់។ ចំណុចពាក់ព័ន្ធដែលបានលើកឡើងនៅក្នុងអនុសាសន៍របស់សហចៅក្រមរបាយការណ៍គឺដើម្បីជៀសវាងការប៉ះទង្គិចផ្លូវចិត្តជាថ្មី ដែលជាផលវិបាកទំនងកើតចេញពីការធ្វើអន្តរាគមន៍ដោយបុគ្គលដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមួយបុគ្គល ឬ ក្រុមដែលធ្លាប់មានរបួស ឬ បញ្ហាផ្លូវចិត្តពាក់ព័ន្ធដូចបានពិពណ៌នាដោយលោកស្រី យឹម សុជារី។

សហចៅក្រមរបាយការណ៍ បានគូសបញ្ជាក់នៅក្នុងសេចក្តីអំពាវនាវឱ្យជៀសវាងការប៉ះទង្គិចផ្លូវចិត្តជាថ្មី ដោយត្រូវគោរពឯកជនភាពជនរងគ្រោះ ឬអ្នកផ្សេងទៀតដែលធ្លាប់មានរបួសផ្លូវចិត្ត។ ព្យសនកម្មនេះអាចបង្កឡើងដោយការរំលោភបំពានលក្ខខណ្ឌតឹងរឹងនៃការរក្សាការសម្ងាត់ ឯកជនភាពទិន្នន័យ និងពិធីសារពាក់ព័ន្ធ បើទោះបីជាអចេតនាក៏ដោយ។ ការជៀសវាងទម្រង់នៃព្យសនកម្មទាំងនេះក៏ទាមទារការបណ្តុះបណ្តាល ការបំពាក់បំប៉នចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់ផងដែរ។ ដូចបានចង្អុលបង្ហាញដោយ Dato' Shyamala Alagendra យើងមិនអាចសន្មត់ថា ក្រុមទាំងអស់ ឬ បុគ្គលដែលបានទទួលរងទម្រង់នៃអំពើហិង្សាស្រដៀងគ្នា អាចត្រូវបានគេធ្វើមកលើតាមរបៀបដូចគ្នានោះទេ។ ចំណុចដែលលោកស្រីលើកឡើងគឺថា អ្នកអនុវត្តត្រូវដោះស្រាយស្ថានភាពមួយដោយមិនធ្វើបុរេសន្មត់ថា វិធីសាស្ត្រដែលពួកគេបានប្រើប្រាស់ដោយជោគជ័យនៅកន្លែងផ្សេងទៀត នឹងស្តែង

ចេញលទ្ធផលដូចគ្នានៅក្នុងបរិបទផ្សេង។ ដូចបានចង្អុលបញ្ជាក់ ការត្រៀមរៀបចំសមស្រប ចំណេះដឹង និងការវាយតម្លៃស្ថានភាពនីមួយៗ ត្រូវធ្វើឡើងដើម្បីជៀសវាង "មិនបង្កការឈឺចាប់"។

ទស្សនៈទាំងនេះក៏បានជម្រាបជូនអង្គពិភាក្សានៅក្នុងសិក្ខាសាលា ហើយជាពិសេសត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសុន្ទរកថា និងសំណើរបស់អង្គការនានា ដូចជា TPO ដែលមានបទពិសោធន៍ស៊ីជម្រៅ និងទូលំទូលាយលើការងារក្នុងបរិបទកម្ពុជា ដើម្បីដោះស្រាយតម្រូវការផ្លូវចិត្តរបស់សាក្សី ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងសហគមន៍។ ASRIC ក៏បានបង្ហាញមូលដ្ឋាននៅក្នុងសំណើដែលបានដាក់ជូនទាក់ទងនឹងការសិក្សាអំពីជាតិពិន្ទុ និងវប្បធម៌ឆ្លងដែន និងការចូលរួមរបស់យុវជនក្នុងការស្រាវជ្រាវយ៉ាងទូលំទូលាយរបស់បណ្ឌិត លក្ខិណា នូ អំពីភាពតានតឹង និងរបួសផ្លូវចិត្តនៅក្នុងចំណោមប្រជាជនកម្ពុជា និងខ្មែរអាមេរិកាំង។ បញ្ហានេះក៏បានកើតឡើងដដែលៗទាក់ទងនឹងការប្រើប្រាស់ប្រកបដោយភាពច្នៃប្រឌិតនៃធនធានបណ្ណសារដ៏ច្រើនរបស់តុលាការ ដែលក្នុងនោះ ការផ្សព្វផ្សាយ និងការចូលរួមកាន់តែទូលំទូលាយជាមួយទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះដែលបានរក្សាទុកអាចបង្ហាញព័ត៌មានដែលជនរងគ្រោះទាំងនោះមិនមានបំណងផ្សព្វផ្សាយជាសាធារណៈ។ ចំណុចនេះហើយជាមូលហេតុដែលការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្នលើកំណត់ហេតុ និងឯកសារទាក់ទងនឹងជនរងគ្រោះទាំងអស់មានសារៈសំខាន់ណាស់ ហើយហេតុអ្វីបានជាវាត្រូវធ្វើឡើងដោយមានការចូលរួមពីជនរងគ្រោះ ឬ សិទ្ធិវ័ន្ត និងមេធាវីរបស់ពួកគេ។

លោកស្រី យឹម សុជារី បានផ្តល់ឧទាហរណ៍អំពីវិធីដែលព្យសនកម្មអាចកើតឡើងនៅពេលដែលជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានលើកទឹកចិត្តឱ្យលើកឡើងអំពីអ្វីដែលពួកគេបានរងទុក្ខ ដើម្បីជាផ្លូវឆ្ពោះទៅរក "ការព្យាបាលផ្លូវចិត្ត" ប៉ុន្តែលទ្ធផលគឺទទួលបានការមាក់ងាយមកវិញ។ ដូចលោកស្រីបានលើកឡើង ពួកគេត្រូវទទួលបាន "បរិយាកាសសុវត្ថិភាពក្នុងការលើកឡើង" ហើយករណីនេះអាចកើតឡើងបានលុះត្រាតែអ្នកសម្របសម្រួលដែលមានជំនាញ និងបទពិសោធន៍ បានបំពេញលក្ខខណ្ឌជាមុន និងការត្រៀមរៀបចំដែលត្រូវការសម្រាប់ធានាសុវត្ថិភាពបែបនេះ។ ទោះបីជាយ៉ាងនេះក្តី ទោះបីជានៅពេលមានបរិយាកាសសុវត្ថិភាពក្នុងការលើកឡើងក៏ដោយ យើងក៏ត្រូវតែមានពិធីសារសមស្រប ការបណ្តុះបណ្តាល និងធនធានគ្រប់គ្រាន់ ដើម្បីធានាថាអត្តសញ្ញាណ និងពាក្យពេចន៍របស់ពួក មានសុវត្ថិភាពនៅពេលបម្លែងចេញជាទម្រង់អត្ថបទលាយលក្ខណ៍អក្សរ មិនថានៅក្នុងបណ្ណសារដ្ឋាន ប្រព័ន្ធមូលដ្ឋានទិន្នន័យ ឯកសារស្រាវជ្រាវដែលបានបោះពុម្ពផ្សាយ ឬ របាយការណ៍។

# ភាពជាម្ចាស់នៅថ្នាក់មូលដ្ឋាន និងជាបុគ្គល សមាហរណកម្ម និងចីរភាព

ដូចបានពិភាក្សាខាងលើ អ្នកចូលរួមជាច្រើនបានសង្កត់ធ្ងន់លើតម្រូវការក្នុងការបញ្ចូលកម្មវិធីទាក់ទងនឹងជនរងគ្រោះទៅក្នុងសហគមន៍មូលដ្ឋានដោយផ្ទាល់។ មជ្ឈមណ្ឌលបូជនីយដ្ឋាន និងចងចាំក្នុងរាជធានីភ្នំពេញ ក៏មានតួនាទីដោយឡែករបស់ខ្លួន ហើយមានសក្តានុពលក្នុងការប្រែក្លាយជាមជ្ឈមណ្ឌលជាតិសម្រាប់ការងារប្រវត្តិសាស្ត្រដែលទាក់ទងនឹងការចងចាំ ប៉ុន្តែ ទំនងជាមិនអាចដោះស្រាយតម្រូវការរបស់សហគមន៍មូលដ្ឋានបានទេ។ តំរូវការនេះហើយ ទំនងជាបានឃើញមានការលើកឡើងញឹកញាប់បំផុតនៅក្នុងការអំពាវនាវឱ្យមានចេតិយ ដែលត្រូវបានយល់ថាមិនមែនគ្រាន់តែជា "បូជនីយដ្ឋាន" រូបវ័ន្តប៉ុណ្ណោះទេ វាក៏អាចជាទីតាំងប្រសព្វ អាចថានៅជិតមជ្ឈមណ្ឌលសហគមន៍ ដែលនៅទីនោះការពិភាក្សា យន្តការស្វែងរកការពិត និងការចងចាំ អាចកើតឡើងក្នុងចំណោមអ្នករស់នៅ "ឃើញមុខគ្នារាល់ថ្ងៃ" នៅក្នុងសហគមន៍ ជាជាងនៅតាមទីតាំងនៅរាជធានីភ្នំពេញ ដែលពួកគេទំនងមិនស្គាល់។ យើងត្រូវបញ្ជាក់ច្បាស់ថា៖ គ្រប់ក្រុមការងារពិភាក្សានៅក្នុងសិក្ខាសាលា គ្រប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីក្នុងនាមអ្នកតំណាងរបស់ពួកគេ ហើយគ្រប់ឯកសារដែលបានដាក់ជូនចាប់ពីវេទិកា VSS-CPLCL កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ បានអំពាវនាវឱ្យមានការសាងសង់ចេតិយ និងស្តូបអនុស្សាវរីយ៍នៅថ្នាក់មូលដ្ឋានទូទាំងប្រទេស។ ការខិតជិតភាពឯកច្ឆ័ន្ទនេះមានសារៈសំខាន់ ហើយគួរតែត្រូវបានទទួលស្គាល់ និងចាត់ទុកថាជាការឆ្លើយតបមួយ។

ដូចបានបញ្ជាក់ម្តងទៀតនៅក្នុងផ្នែកមុន ការធ្វើមូលដ្ឋានីយកម្មមិនគួរធ្វើតាមគំរូ "លក្ខខណ្ឌមួយត្រូវគ្រប់ស្ថានភាពនោះទេ" ប៉ុន្តែត្រូវតែឆ្លើយតបទៅតាមតម្រូវការ និងលទ្ធភាពនៃបរិបទនីមួយៗ។ អ្វីដែលយើងត្រូវការចាំបាច់គឺ ដូចវាគ្មិនកត្តិយស និងអ្នកចូលរួមដទៃទៀតបានចង្អុលបង្ហាញថា ការចូលរួមពីសហគមន៍ខ្លួនឯងក្នុងការរចនា និងអនុវត្តកម្មវិធី មិនថាជាទម្រង់ការអប់រំ ការចងចាំ ការរំលឹកវិញ្ញាណខណ្ឌ ឬការផ្សះផ្សាគ្នា។ ជាឧទាហរណ៍ ក្រុមពិភាក្សានៅក្នុងសិក្ខាសាលាស្តីពីទីតាំងប្រវត្តិសាស្ត្រ និងទីកន្លែងរំលឹកការចងចាំ បានអំពាវនាវឱ្យបង្កើតគណៈកម្មការថ្នាក់ភូមិ ឬ ឃុំ-សង្កាត់ ដើម្បីសហការក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬ ស្ថាប័នណាមួយដែលបង្កើតទីកន្លែងរំលឹកវិញ្ញាណក្ខន្ធនៅអតីតទីតាំងឧក្រិដ្ឋកម្ម។ ក្រុមពិភាក្សាស្តីពីការថែទាំសុខភាពបានលើកឡើងថា អ្នករស់រានមានជីវិត-ជនរងគ្រោះ គួរអាចផ្តល់យោបល់ខ្លះលើថវិកា និងយុទ្ធសាស្ត្រសម្រាប់ការអនុវត្តកម្មវិធីទាំងនេះដែលកំពុងបង្កើតឡើងជំនួសមុខឱ្យខ្លួន។ បណ្ឌិត Sperfeldt បានសង្កត់ធ្ងន់នៅក្នុងសុន្ទរកថា

របស់លោកថា អ្នករស់រានមានជីវិត និងដើមបណ្ដឹងរដ្ឋប្បវេណី ដាច់ខាតត្រូវឱ្យចូលរួមក្នុងនាមជាភាគីពាក់ព័ន្ធ និងដៃគូ មិនមែនគ្រាន់តែជាអ្នកចូលរួមអកម្មនោះទេ។ តួនាទីសូ្វលរបស់បុគ្គលទាំងនេះនៅក្នុងសិក្ខាសាលាបង្ហាញអំពីសារៈសំខាន់នៃការរួមចំណែករបស់ពួកគេ ប្រសិនបើពាក្យសម្ដីរបស់ពួកគេត្រូវបានទទួលស្គាល់ទៅតាមអ្វីដែលពួកគេសមនឹងទទួលបាន។

ដូចបានលើកឡើងជាឱឡារិកដោយដើមបណ្ដឹងរដ្ឋប្បវេណីអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងសិក្ខាសាលា ភាពជាម្ចាស់នៅតាមមូលដ្ឋានមានសារៈសំខាន់ណាស់ ប្រសិនបើចង់ឱ្យកម្មវិធីនេះ ទទួលបានជោគជ័យ។ ដូចបានគូសបញ្ជាក់ច្បាស់នៅក្នុងចំណាប់អារម្មណ៍របស់ពួកគេ ភាពជាម្ចាស់កើតចេញពីការស្ដាប់យោបល់ពួកគេ និងរួមបញ្ចូលពួកគេជាដៃគូនៅក្នុងដំណើរការ។ របៀបនៃដំណើរការនេះក៏ជាកត្តាសំខាន់មួយឈានទៅសម្រេចបានចីរភាពផងដែរ។ ដូចអ្នកចូលរួមនៅក្នុងសិក្ខាសាលាបានបញ្ជាក់យ៉ាងច្បាស់ ការងារក្នុងដំណាក់កាលដែលនៅសេសសល់នឹងឥតប្រយោជន៍ ប្រសិនបើមិនថែទ្រទ្រង់លើសរយៈពេលបីឆ្នាំដូចបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងបន្ថែម។ មិនថាលក្ខខណ្ឌរយៈពេលនៃដំណាក់កាលដែលនៅសេសសល់វែងយ៉ាងម៉េចនោះឡើយ ចីរភាពតម្រូវឱ្យមានភាពជាម្ចាស់ និងការកសាងសមត្ថភាព ប្រសិនបើចង់ឱ្យលទ្ធផលយូរអង្វែង។ ប្រធានបទនេះត្រូវបានលើកឡើងស៊ីជម្រៅក្នុងសុន្ទរកថារបស់បណ្ឌិត Sperfeldt ពាក់ព័ន្ធនឹងចំណុចសំខាន់ដែលថា ក្នុងកម្មវិធីដែលមានការចូលរួមពីអន្តរជាតិ ត្រូវមានចំណុចណាមួយថែងអំពីការផ្ទេរការដឹកនាំ និងការទទួលខុសត្រូវមកឱ្យដៃគូកម្ពុជា ដែលជាអ្នកធានានូវចីរភាពនាពេលខាងមុខ។ លោកបានកត់សម្គាល់ថា យើងក៏ត្រូវមានកម្មវិធីជាបន្តបន្ទាប់ដើម្បីបង្កើនចំនួន និងសមត្ថភាពអ្នកជំនាញកម្ពុជា។ ចំណុចនេះក៏ត្រូវបានស្នើឡើងនៅក្នុងឯកសារលម្អិតដែល YRDP បានដាក់ជូនបន្ទាប់ពីការបញ្ចប់សិក្ខាសាលា ក្នុងនោះលើកឡើងផែនការរយៈពេលដប់ឆ្នាំចាប់ផ្ដើមពីពេល អ.វ.ត.ក ឈានទៅបញ្ចប់ការងារ ក្នុងដំណាក់កាលដែលនៅសេសសល់ និងការកើនឡើងបន្តិចម្ដងៗនូវការទទួលខុសត្រូវ និងភាពជាម្ចាស់របស់ជនរងគ្រោះ លើកម្មវិធីបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមយ៉ាងជិតស្និទ្ធពីជនរងគ្រោះ-អ្នករស់រានមានជីវិត យុវជន និងតំណាងសង្គមស៊ីវិលតាមរយៈក្រុមការងារបច្ចេកទេស។

ជាតុផ្សំមួយទៀតនៃចីរភាព គឺពាក់ព័ន្ធនឹងការប្រចាប់បញ្ចូលកម្មវិធី និងការកសាងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ។ តម្រូវការនេះបានបញ្ជាក់ច្បាស់ដោយបណ្ឌិត Sperfeldt និងលើកជាឧទាហរណ៍នៅក្នុងពេលរៀបចំសិក្ខាសាលា ដែលបានប្រមូលផ្ដុំបុគ្គលមកពីក្រុមផ្សេងគ្នា សំដៅរួមគ្នាកំណត់គោលដៅរួម និងគំនិតផ្ដួចផ្ដើមសម្រាប់ដំណាក់កាលដែលនៅសេសសល់។ ការជជែកពិភាក្សាអ៊ូរអរនៅក្នុងសាលសន្និសីទរយៈពេលបីថ្ងៃ បង្ហាញឱ្យឃើញអំពីបំណងប្រាថ្នាពិតប្រាកដត្រលប់ទៅរកការផ្លាស់ប្ដូរយោបល់នៅលើផ្ទាំងក្ដាខៀន ការជួបជុំគ្នា និងបង្កើតឧត្តមានុវត្តន៍ និងកម្មវិធីលម្អិត ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបំណងប្រាថ្នារបស់ជនរងគ្រោះ។ ស្មារតីនៃការសហការនេះត្រូវចាប់យកឱ្យជាប់។

សមាហរណកម្មបង្ហាញឱ្យឃើញក្នុងពីរទម្រង់៖ ទីមួយ វាកំណត់សមាហរណកម្មកម្មវិធីស្រដៀងគ្នា ឬពាក់ព័ន្ធគ្នាក្នុងចំណោម CSOs និងស្ថាប័នដែលកំពុងធ្វើការលើបញ្ហា និងប្រធានបទពាក់ព័ន្ធ ឬវិស័យនានានៅក្នុងកម្មវិធី ដើម្បីគាំទ្រកិច្ចសហការ និងជៀសវាងការងារគម្រោងជាន់គ្នា ឬ ដូចគ្នា។ ទីពីរ សមាហរណកម្មជាមួយស្ថាប័ន ឬ កម្មវិធីពាក់ព័ន្ធនឹងរដ្ឋ អាចធ្វើឱ្យមានការយកចិត្តទុកដាក់ប្រកបដោយចីរភាពលើបញ្ហាទាំងនេះក្នុងរយៈពេលវែង។

ឧទាហរណ៍ទីមួយ នៃទម្រង់ការងារសមាហរណកម្ម អាចជាកិច្ចខិតខំប្រឹងប្រែងដោយ អង្គការក្ដីករុណា ដើម្បីបង្កើតមជ្ឈមណ្ឌលចងចាំ និងសិក្សាធិកា ដែលបានស្នើឡើងនៅក្នុងសំណើដាក់ជូនក្រោយសិក្ខាសាលា (សូមមើល ឧបសម្ព័ន្ធ ៧) ហើយអាចបម្រើសេចក្ដីត្រូវការរបស់អង្គការជាច្រើន ដែលបានចូលរួមក្នុងការពិគ្រោះយោបល់តាំងពីពេលអភិវឌ្ឍសំណើតាំងពីដំបូង។ ស្រដៀងគ្នានេះដែរ KDK សង្ឃឹមថានឹងផ្ដល់ជាទីតាំង និងអង្គភាពកណ្ដាល រួមបញ្ចូល និងប្រមូលការងារទាំងអស់របស់ CSOs ដែលកំពុងផ្ដោតការងារលើប្រវត្តិសាស្ត្រផ្ទាល់មាត់ កិច្ចសន្ទនាអន្តរជំនាន់ និងការកត់ត្រាការចងចាំ។

ឧទាហរណ៍ទី២ ទម្រង់សមាហរណកម្ម គឺភាពចាំបាច់ត្រូវបង្កើតទំនាក់ទំនងជាមួយ MOEYS បង្កើតលទ្ធផលស្រាវជ្រាវ ឬ ម៉ូឌុលកម្មវិធីសិក្សាទៅក្នុងកម្មវិធីសិក្សាផ្លូវការ ដើម្បីប្រើប្រាស់រួមសម្រាប់អប់រំសិស្ស និស្សិតនៅសាកលវិទ្យាល័យ ឬអនុវិទ្យាល័យ។ ឧទាហរណ៍មួយដែលរួមបញ្ចូលទិដ្ឋភាពសមាហរណកម្មទាំងពីរទម្រង់ អាចពិនិត្យមើលការងាររបស់អង្គការយុវសន្តិភាព ដែលចាប់អារម្មណ៍លើការងារសហការជាមួយ TSGM ដើម្បីទាញយកចំណេះដឹង និងសមត្ថភាពលើការងារថែរក្សាទីតាំងប្រវត្តិសាស្ត្រ និងដើម្បីបង្កើតបណ្ដាញទំនាក់ទំនងគ្នាលើទីតាំងប្រវត្តិសាស្ត្រក្រៅពី TSGM ឬ ជើងឯក ដោយរាប់បញ្ចូលទាំងទីតាំងឧក្រិដ្ឋកម្មនានានៅតាមខេត្តនានាទូទាំងប្រទេស ដែលត្រូវត្រួតពិនិត្យមើលឡើងវិញ រៀបចំ និងបន្តមើលថែរក្សា។ YFP បានរក្សាទីតាំងចងចាំទាំងនេះរួចហើយ នៅទីតាំងចំនួនពីរដូចបានលើកឡើងក្នុងសំណុំរឿង ០០២៖ មន្ទីរសន្តិសុខក្រាំងតាចាន់ ខេត្តតាកែវ និងសំរោងក្នុង ខេត្តបាត់ដំបង។ គួរកត់សំគាល់ផងដែរថា ក្នុងករណីខ្លះ សមាហរណកម្មអាចរួមបញ្ចូលការកសាងទំនាក់ទំនងសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិជាជាងជាមួយស្ថាប័ន RGC ប៉ុន្តែករណីនេះគឺអាស្រ័យលើស្ថានភាព ឬ ប្រធានបទពាក់ព័ន្ធ។

# ប្រធានបទរួម គោលការណ៍ និង ចំណុចព្រមព្រៀង

យោងតាមការបញ្ជាក់របស់ ឯកឧត្តម ក្រាញ់ តូនី នៅក្នុងសុន្ទរកថាបើក គោលដៅនៃសិក្ខាសាលាគឺជានាំឱ្យជនរងគ្រោះ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត ចូលរួមឱ្យបានច្រើនជាអតិបរិមាក្នុងការអភិវឌ្ឍសកម្មភាពទាក់ទងនឹងជនរងគ្រោះសម្រាប់ដំណាក់កាលដែលនៅសេសសល់។ ឯកឧត្តម បានបន្ថែមទៀតថា "ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី គឺជាសំឡេងដែលយើងត្រូវស្តាប់"។ សញ្ចេតនាបែបនេះក៏បានលើកឡើងដូចគ្នាដោយឯកអគ្គរដ្ឋទូតបារាំង និងវាគ្មិនផ្សេងទៀត នៅក្នុងពិធីបើកសិក្ខាសាលា ហើយត្រូវបានលើកយកមកសំអាងក្នុងអង្គសិក្ខាសាលាទាំងមូល។

ដូចបណ្ឌិត Sperfeldt និងវាគ្មិនផ្សេងទៀតបានគូសបញ្ជាក់ ចំណុចសំខាន់នោះគឺការទទួលស្គាល់នូវសកម្មភាពដែលបានធ្វើរួចហើយ ឬ កំពុងដំណើរការ ហើយការពង្រឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះថែមទៀត ដើម្បីជៀសវាងយកការងារដដែលទៅ "បង្កើតជាការងារថ្មី"។ ចំណុចដូចគ្នានេះបានលើកឡើងនៅក្នុងអនុសាសន៍ក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍ និងនៅក្នុងសំណើរបស់ Laura McGrew និងក្រុមជាក់លាក់មួយចំនួននៅក្រៅប្រទេស ដែលលោកស្រីបានចងក្រង។ ចំណុចនេះបង្ហាញអំពីតម្រូវការឱ្យមានក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ តួយ៉ាងដូចជា សិក្ខាសាលា និងរំលឹកឡើងវិញនូវអនុសាសន៍របស់សហចៅក្រមរបាយការណ៍ដែលលើកឡើងថា កិច្ចសន្ទនា និងជួបប្រជុំបែបនេះត្រូវធ្វើឡើងជាទៀងទាត់ អាចថារៀងរាល់បីខែម្តង។ ចំណុចនេះក៏បានលើកឡើងក្នុងវគ្គពេញអង្គក្នុងពេលធ្វើសិក្ខាសាលាថ្ងៃទី២ ដោយដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សាត ដែលបានបញ្ជាក់ក្នុងនាមក្រុមដើមបណ្តឹងរដ្ឋប្បវេណីថា ដើមបណ្តឹងរដ្ឋប្បវេណីចង់ចូលរួមព្រឹត្តិការណ៍បែបនេះ ២ ទៅ ៣ដងក្នុងមួយឆ្នាំ។ ក៏ប៉ុន្តែ ដោយសារធនធានថវិកាមានកំណត់សម្រាប់សកម្មភាពដែលនៅសេសសល់ និងវិសាលភាពមហិច្ឆិតាការងារជំពេងដូចបានបង្ហាញនៅក្នុងបទបង្ហាញក្នុងពេលសិក្ខាសាលា និងឯកសារដែលបានទទួល ការប្រកួតប្រជែងក្នុងចំណោមភាគីពាក់ព័ន្ធនឹងជះឥទ្ធិពលអវិជ្ជមានលើឱកាសរួម ហើយទំនងជានាំឱ្យមានការបែកខ្ញែកកម្មវិធីផងដែរ ដែលនឹងធ្វើឱ្យខូចដល់ចីរភាពរយៈពេលយូរ។ ដូចក្រុមទី ៧ បានបញ្ជាក់ នៅក្នុងកិច្ចប្រជុំពេញអង្គ ភាគីពាក់ព័ន្ធទាំងអស់ ក៏ដូចប្រជាពលរដ្ឋដែលខ្លួនផ្តល់សេវា នឹងទទួលប្រយោជន៍ពីការរួបរួមចំណេះដឹង បទពិសោធន៍ និងធនធាននៅក្នុងគំនិតផ្តួចផ្តើម ដោយសារតែចំណុចខ្លាំងប្រទាក់ក្រឡាគ្នារបស់អ្នកចូលរួមទាំងអស់។ ពួកគេបានអំពាវនាវឱ្យបង្កើតថ្នាល

មួយដើម្បីសហការគ្នា ដោយរួមបញ្ចូលសង្គមស៊ីវិល និងស្ថាប័នរដ្ឋ សំដៅលើកកម្ពស់ចីរភាពរយៈពេលវែង។

ប្រធានបទមួយទៀតដែលទទួលបានការព្រមព្រៀងជំជេងដែលគឺពាក់ព័ន្ធនឹងវិធីផ្ដល់សេវាដល់ជនរងគ្រោះនៅតាមមូលដ្ឋាន។ ដូច្នេះ ក្រុមទី១ បានស្នើថា សមាគមជនរងគ្រោះនៅថ្នាក់មូលដ្ឋានត្រូវបង្កើនប្រសិទ្ធភាព ហើយគួរបង្កើតឡើងនៅទូទាំងប្រទេសដើម្បីជំរុញឱ្យ "អ្នកនៅមូលដ្ឋានចូលរួម"។ ក្រុមទី២ បានលើកឡើងបញ្ហាដូចគ្នានេះទាក់ទងនឹងតម្រូវការបន្ទាន់របស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់អំពីការថែទាំសុខភាព (ផ្លូវចិត្ត និងផ្លូវកាយ) សម្រាប់មនុស្សចាស់នៅក្នុងសហគមន៍មូលដ្ឋានរបស់ពួកគេ។ ក្រុមទី ៤ បានស្នើថា សកម្មភាពនៃការចងចាំ និងការរំលឹកវិញ្ញាណក្ខន្ធត្រូវធ្វើមូលដ្ឋានីយកម្មតាមរយៈការបង្កើតមជ្ឈមណ្ឌលសម្រាប់ជនរងគ្រោះ និងទីកន្លែងរក្សាទុកការចងចាំ ដោយរៀបចំតាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល និងសហគមន៍នៅមូលដ្ឋាន។ ក្រុមទី៥ (ក៏មានការគាំទ្រពីក្រុមទី២) បានធ្វើសំណើស្រដៀងគ្នាមួយទាក់ទងនឹងតម្រូវការរបស់ជនជាតិភាគតិច ដោយគួរតែចងក្រងបទពិសោធន៍របស់ពួកគេ ជាឯកសារនៅមជ្ឈមណ្ឌលចងចាំនៅក្នុងសហគមន៍ និងនៅទីតាំងឧក្រិដ្ឋកម្ម ដែលអាចរក្សាទុកប្រវត្តិសាស្ត្រដែលពួកគេបានរៀបរាប់ដោយផ្ទាល់មាត់ ដើម្បីទុកយកទៅអប់រំសន្តិភាពអន្តរជំនាន់ និងសម្រាប់រំលឹកការចងចាំ។ ក្រុមទី៦ បានតស៊ូមតិទាមទារឱ្យសាងសង់ចេតិយមួយនៅតាមសហគមន៍កម្ពុជាគ្រប់ទីកន្លែង ដើម្បីទុកកន្លែងចងចាំ និងសម្រាប់បម្រើតម្រូវការសុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់ជនរងគ្រោះ នៅកម្រិតសហគមន៍។

ភាពចាំបាច់ត្រូវរក្សាការចងចាំ និងដាក់ឱ្យប្រើប្រាស់សម្រាប់អប់រំមនុស្សជំនាន់នេះ និងជំនាន់ក្រោយតាមរយៈកម្មវិធីអប់រំ សារមន្ទីរ និងមធ្យោបាយផ្សេងទៀត បានលើកឡើងដោយក្រុម និងវាគ្មិនជាច្រើន ក៏ដូចជានៅក្នុងឯកសារដែលទទួលបាន។ ក្រុមទី៤ បានអំពាវនាវឱ្យបង្កើតបណ្ដាញឱ្យបានច្រើនដើម្បីរក្សាទីតាំងប្រវត្តិសាស្ត្រឧក្រិដ្ឋកម្ម នៅទូទាំងប្រទេស ចំណែកក្រុមទី៦ បានលើកឡើងថា ការជំនុំជម្រះរបស់ អ.វ.ត.ក ត្រូវតែជាយានសម្រាប់ការចងចាំ និងការអប់រំមនុស្សជំនាន់ក្រោយ។ ក្រុមទី៧ បានលើកចំណុចនេះក្នុងន័យលើកកម្ពស់កិច្ចសន្ទនាគ្រប់ជំនាន់ និងប្រើប្រាស់ការអប់រំដើម្បីឱ្យការចងចាំអំពីរបបខ្មែរក្រហម កាន់តែជឿជាក់ និងមានអត្ថន័យដល់ជំនាន់នីមួយៗ ដែលជារឿយៗមិនជឿរឿងរ៉ាវដែលបានរៀបរាប់ដោយសាច់ញាតិ និងអ្នកដទៃ។ ក្រុមទី៨ បានផ្ដោតបញ្ហានេះក្នុងបរិបទនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ រួមទាំងការរៀបការដោយបង្ខំ។ អ្នកដែលធ្លាប់ឆ្លងកាត់អំពើហិង្សាបែបនេះ ចង់ឱ្យមានការរក្សាទុក និងឱ្យគេជឿលើរឿងរ៉ាវរបស់ពួកគេ។ ឯកសាររបស់ YFP, TSGM, និងមជ្ឈមណ្ឌលបុប្ផាណា ដែលបានដាក់ជូនបន្ទាប់ពីសិក្ខាសាលា បានយកមកសំអាង ជាមួយនឹងសំណើគម្រោងជាក់លាក់ជាច្រើនទៀតទាក់ទងនឹងការចងក្រងឯកសារលម្អិតអំពីអតីតកាល និងការផ្សព្វផ្សាយការងារប្រវត្តិសាស្ត្រតាមរយៈមធ្យោបាយផ្សេងៗ មិនថាក្នុងពិព័រណ៍ ការរក្សាទុកកំណត់ហេតុ ភាពយន្តឯកសារ សិក្ខាសាលា ឬនៅក្នុងការគាំទ្រឱ្យមានកម្មវិធីអប់រំតាមទូរស័ព្ទ។

ចំណុចរួមមួយទៀតដែលបានលើកឡើងគឺវិធីដោះស្រាយស្ថានភាពដែលកើតឡើងនៅក្នុងសហគមន៍ជាច្រើន ដែលជនរងគ្រោះ និងជនល្មើសរស់នៅជាមួយគ្នា ប៉ុន្តែមិនចុះសម្រុងនឹងគ្នា ដូចក្រុមទី៨បានលើកឡើង។ ចំណុចនេះជាការពិតណាស់គឺទាក់ទងនឹងប្រធានបទនៃការធ្វើមូលដ្ឋានីយកម្មដូចបានរៀបរាប់ខាងលើ ប៉ុន្តែក៏លើកឡើងនូវបញ្ហាកាន់តែ

ស៊ីជម្រៅអំពីវិធីដែលអាចសម្រេចបានល្អបំផុត។ ប្រធាន VSS លោក ហង្ស វណ្ណៈ ស្នើថា ការអប់រំអាចផ្តោតលើការបង្កើតអត្តសញ្ញាណខ្មែរក្រោយរបបខ្មែរក្រហម នឹងជួយលើកកម្ពស់សុខដុមរមនា និងទប់ស្កាត់កុំឱ្យអំពើហិង្សាកើតឡើងវិញ។ ចំណុចនេះស្របទៅនឹងការសិក្សាវប្បធម៌ និងអត្តសញ្ញាណវិជ្ជមាន ដែល ASRIC អំពាវនាវនៅក្នុងសំណើដែលបានសហគមន៍នៅក្រៅប្រទេសបានដាក់ជូន។ ដូចលោក ហង្ស វណ្ណៈ បានបញ្ជាក់ បើយុវជនមិនទទួលបានការអប់រំគ្រប់គ្រាន់ទេនោះ "ប្រវត្តិសាស្ត្ររបស់យើងនឹងក្លាយជារឿងនិទាន" ដែលគ្មាននរណាម្នាក់នឹងជឿយើង។

តម្រូវការ ដែលទំនងជាបង្ហាញទូទៅបំផុតដោយក្រុមពិភាក្សា ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើជាច្រើនគឺជាតម្រូវការចាំបាច់បំផុតមួយគឺការថែទាំជនរងគ្រោះដែលមានវ័យចំណាស់ តម្រូវការដែលត្រូវការខ្លាំងឡើងៗជារៀងរាល់ឆ្នាំ។ តម្រូវការនេះត្រូវបានគូសបញ្ជាក់យ៉ាងខ្លាំងនៅក្នុងសុន្ទរកថាបិទរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសិក្ខាសាលា។ ពួកគេបានអំពាវនាវឱ្យបង្កើតសមាគមជនរងគ្រោះវ័យចំណាស់ ដែលសហការគ្នាជាមួយដៃគូដើម្បីដាក់ចេញកម្មវិធីមួយឈានទៅបង្កើតមជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍នីមួយៗ និងឱ្យវត្តអារាមនៅតាមមូលដ្ឋានដើរតួយ៉ាងសំខាន់លើការងារនេះ ព្រមទាំង រួមបញ្ចូលជនរងគ្រោះ ដែលមិនត្រូវបានទទួលស្គាល់ដោយ ឬចូលរួមដោយផ្ទាល់ជាមួយ អ.វ.ត.ក និងផ្តល់ការថែទាំសុខភាព និងបើកឱ្យមានការផ្ទេរចំណេះដឹង និងអប់រំយុវជនជំនាន់ក្រោយដែលមិនជឿរឿងរ៉ាវអំពីខ្មែរក្រហមដែលពួកគេបានឮ។ សំណើចំនួនពីរដែលបានពិភាក្សានៅក្នុងរបាយការណ៍នេះ ផ្តល់ជាតម្រាយផ្លូវជាក់ស្តែងសម្រាប់ឆ្លើយតបទៅនឹងតម្រូវការជាក់លាក់នេះ និងការទាមទារចង់បានពីអ្នករស់រានមានជីវិត។ ទីមួយ បទបង្ហាញរបស់ក្រុមទី២ រៀបចំផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិលសំខាន់ៗ ដូចជា TPO និង HelpAge Cambodia ក៏ដូចជាស្ថាប័នរដ្ឋ ដូចជាក្រុមប្រឹក្សាជាតិគាំពារសង្គម ជាដើម។ បទបង្ហាញទីពីរអំពីដំណោះស្រាយសម្រាប់បញ្ហានេះ ឃើញលើកឡើងនៅក្នុងឯកសាររបស់ Michael Karnavas ដែល DC-Cam បានដាក់ជូនលេខាធិការដ្ឋានប៉ុន្មានថ្ងៃក្រោយសិក្ខាសាលា។

ចំណុចចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណី ជាក្រុម និងជាបុគ្គល ទទួលបានលទ្ធភាពច្រើន។ ពួកគេត្រូវបានគោរព និងកោតសរសើរសុះសាយ ហើយគោលជំហរដ៏មុតស្រួចរបស់ពួកគេក្នុងការសម្តែងមតិ និងចែករំលែកការពិតអំពីទុក្ខលំបាករបស់ពួកគេ បានផ្តល់ឱ្យពួកគេនូវអំណាចសីលធម៌ និងបញ្ចុះបញ្ចូលយ៉ាងខ្លាំង។ ចំណុចនេះគួររៀបចំបង្កើតចេញជារូបរាង។ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមទី២ ស្នើឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអភិបាលខេត្តគាំទ្រលើកម្មវិធីជាក់លាក់។ អង្គការ ឬសមាគមតស៊ូមតិជនរងគ្រោះពិតប្រាកដ អាចធ្វើការតស៊ូមតិយ៉ាងខ្លាំងក្លាទាមទារតម្រូវការសម្រាប់ជនរងគ្រោះ ដូចជា ការផ្តល់ប័ណ្ណសុខភាពសមធម៌ស្រដៀងទៅនឹង "ប័ណ្ណក្រីក្រ" ដែលអ្នកចូលរួមជាច្រើននាក់បានស្នើក្នុងអំឡុងពេលសិក្ខាសាលា និងការពិគ្រោះយោបល់ជុំវិញករណីនេះ។ ជនរងគ្រោះ-អ្នករស់រានមានជីវិតក៏បានស្នើសុំឱ្យ អ.វ.ត.ក អនុវត្តសកម្មភាពជាក់លាក់ចុងក្រោយចំនួនពីរក្នុងការទទួលស្គាល់បទពិសោធន៍របស់ពួកគេៈ ទីមួយ ការផ្តល់វិញ្ញាបនបត្របញ្ជាក់ពីការចូលរួមរបស់ពួកគេក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី និងទីពីរ ពិធីថ្នាក់ជាតិកម្រិតខ្ពស់ជាមួយពួកគេ ក្រោម

អធិបតីភាពព្រះមហាក្សត្រកម្ពុជា។ លើសពីសំណើជាក់លាក់ទាំងនេះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវការអ្នកតស៊ូមតិដើម្បីជួយរៀបចំ និងសម្របសម្រួលដំណើរការនោះ ឬដើម្បីបង្កើតសមាគមជនរងគ្រោះ។ នេះពិតជាអាចជាតួនាទីមួយសម្រាប់ VSS ក្នុងទម្រង់អនាគតដូចដែលបានពិភាក្សានៅក្នុងសិក្ខាសាលា និងនៅក្នុងការបញ្ជូនដោយលោកបណ្ឌិត ហ៊ុយ សម្ផស្ស។

ជាការពិត តើ VSS របស់ អ.វ.ត.ក អាចផ្លាស់ប្តូរទៅជាស្ថាប័នតស៊ូមតិអចិន្ត្រៃយ៍សម្រាប់ជនរងគ្រោះដែរឬទេ? មិនមានអង្គការសង្គមស៊ីវិលណាមួយ ដែលអាចទទួលយកបេសកកម្មនេះដោយខ្លួនឯងបានទេ ដោយសារហេតុផលថវិកា និងបញ្ហាភ័ស្តុភារ និងដោយសារកង្វះឆន្ទៈជាសកលរបស់សង្គមស៊ីវិល។ ទោះជាយ៉ាងណាក៏ដោយ VSS អាចដើរតួនាទីនេះ ដោយសារសារៈតារក្នុងនាមជា "ស្ថាប័នគេស្គាល់" ទាំងរដ្ឋ និងសង្គមស៊ីវិលដូចគ្នា បទពិសោធន៍ការងារលើកម្មវិធីដែលទទួលបានមូលនិធិអន្តរជាតិ និងកេរ៏ឈ្មោះទទួលស្គាល់ក្នុងចំណោមជនរងគ្រោះ និងអ្នកតស៊ូមតិ។ ស្ថាប័ននាពេលអនាគតអាចត្រូវបានចាត់ទុកជាអ្នកតស៊ូមតិសាធារណៈ ឬ ជាស្ថាប័នត្រួតពិនិត្យ ដែលបំពេញការងារជំនួសជនរងគ្រោះនៅគ្រប់វិស័យសាធារណៈ និងឯកជន។ ស្ថាប័ននេះនឹងត្រូវរក្សាភាពឯករាជ្យផ្នែកនយោបាយ ក៏ប៉ុន្តែក្នុងពេលតែមួយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល ហើយអាចមានលទ្ធភាពទទួលលថវិការដ្ឋមួយចំនួនផងដែរ។ ចំណុចចុងក្រោយ ស្ថាប័ននេះគួរតែមានការិយាល័យសាខានៅគ្រប់ខេត្តក្នុងប្រទេស។ មូលនិធិបន្ថែមទៀតអាចរៃអង្គាសតាមថវិកាសប្បុរសធម៌ក្នុងស្រុក និងអន្តរជាតិ ក៏ដូចជាការផ្តល់មូលនិធិពីម្ចាស់ជំនួយអន្តរជាតិនៅក្នុងដំណាក់កាលដំបូងរបស់ខ្លួន។ ដើម្បីអាចប្រែក្លាយដូច្នេះបាន VSS ត្រូវការធនធានកាន់តែច្រើននាពេលនេះ រួមទាំងបុគ្គលិកដែលមានធនធានពេញលេញ និងបេសកកម្មបច្ចុប្បន្នភាព និងវិសាលភាពនៃការងារ។ រយៈពេលដែលនៅសេសសល់គួរតែត្រូវបានប្រើប្រាស់ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ស្ថាប័នតស៊ូមតិជនរងគ្រោះអចិន្ត្រៃយ៍ ដែលនឹងបន្តវត្តមានដោយឯករាជ្យពី អ.វ.ត.ក បន្ទាប់ពីដំណាក់កាលដែលនៅសេសសល់បានបញ្ចប់។

ប្រធានបទទូទៅ និងចំណុចព្រមព្រៀងគ្នា អាចសង្ខេបនៅក្នុងប្រភេទតម្រូវការ និងគោលដៅដូចខាងក្រោម៖

- ស្តាប់ និងរួមបញ្ចូលសំលេងរបស់ជនរងគ្រោះ និងឱ្យពួកគេចូលរួមជាដៃគូអភិវឌ្ឍន៍កម្មវិធីដំណាក់កាលដែលនៅសេសសល់។

- អភិរក្សសំឡេងរបស់ពួកគេសម្រាប់មនុស្សជំនាន់ក្រោយ និងការអប់រំនាពេលបច្ចុប្បន្នតាមរយៈប្រវត្តិរឿងរ៉ាវផ្ទាល់មាត់ និងមធ្យោបាយផ្សេងទៀត និងលើកកម្ពស់ការសន្ទនាអន្តរជំនាន់។

- បង្កើតកម្មវិធីអប់រំនៅតាមសាលារៀន និងសាកលវិទ្យាល័យដោយដាក់បញ្ចូលធនធាន LDC, TSGM, អង្គការសង្គមស៊ីវិលល្បីៗ និងមជ្ឈមណ្ឌលរំលឹកការចងចាំ។;

- លើកកម្ពស់ការចូលរួមជាមួយសហគមន៍មូលដ្ឋាន និងឱ្យមានមន្ត្រីបង្គោលសម្រាប់ការសន្ទនា ការចងចាំ និងការផ្សះផ្សា។

- ពង្រីកវិសាលភាពនៃស្ថានភាពជាជនរងគ្រោះ ដោយគិតគូរពីរបួសផ្លូវចិត្តប្រយោលចំពោះ ប្រជាជនវ័យក្មេង រួមទាំងកូនៗរបស់អតីតចារី និងរំលឹកឡើងវិញនូវរបួសផ្លូវចិត្តដែលជាសម្ពាធលើសហគមន៍នៅក្រៅប្រទេស។

- ទទួលស្គាល់ និងឆ្លើយតបទៅនឹងបទពិសោធន៍ និងតម្រូវការជាក់លាក់របស់ជនរងគ្រោះ-អ្នករស់រានមានជីវិតងាយរងគ្រោះ រាប់តាំងពីអ្នករស់រានមានជីវិតពី SGBV រហូតដល់សមាជិកក្រុមជនមានពិការភាព ដូចជា ជនជាតិភាគតិច សាសនា ផ្លូវភេទ។

- ឆ្លើយតបភាពចាំបាច់ដែលបន្តត្រូវការសម្រាប់សេវាផ្លូវចិត្ត និងការថែទាំសុខភាពជនរងគ្រោះ-អ្នករស់រានមានជីវិតចាស់ៗ និង

- លើកកម្ពស់ចីរភាព តាមរយៈការអភិវឌ្ឍវេទិកាសហការ ការរៀបចំកម្មវិធីសំខាន់ៗ ការកសាងសមត្ថភាព និងការប្រមូលផ្តុំធនធាន ដើម្បីបម្រើកម្មវិធីរយៈពេលវែងសម្រាប់ជនរងគ្រោះ ក៏ដូចជាតម្រូវឆ្លងជំនាន់។

# ផែនការយុទ្ធសាស្ត្រសម្រាប់គំនិតផ្ដួចផ្ដើមផ្ដោតលើជនរងគ្រោះក្នុងដំណាក់កាលដែលនៅសេសសល់

យើងមើលឃើញច្បាស់ណាស់ថា ជនរងគ្រោះ អ្នកពាក់ព័ន្ធ និងអ្នកតំណាង ចង់ចូលរួមនៅក្នុងដំណើរការចាំបាច់ក្នុងការកំណត់ថាតើកម្មវិធីណាមួយនឹងត្រូវបានគាំទ្រ និងអនុវត្តជាផ្នែកមួយនៅក្នុងដំណាក់កាលដែលនៅសេសសល់ នៃ អ.វ.ត.ក។ ទស្សនៈរបស់ពួកគេត្រូវបានប្រមូលរួចហើយ ហើយបច្ចុប្បន្នមានបណ្ដាញដែលមានស្រាប់ ដើម្បីជានាឱ្យមានការបន្តពិគ្រោះយោបល់បន្តឈានទៅអភិវឌ្ឍកម្មវិធីពាក់ព័ន្ធ។ កិច្ចការដែលមិនសូវច្បាស់នៅឡើយគឺផែនការផ្ដល់មូលនិធិ និងគ្រប់គ្រងសកម្មភាព និងកម្មវិធីដែលសក្ដិសម ដូចបានស្នើឡើងក្នុងទំព័រទាំងនេះ ដែលសង្ខេបសិក្ខាសាលា និងសំណើមុន និងក្រោយព្រឹត្តិការណ៍សិក្ខាសាលា។ សំឡេងជនរងគ្រោះ និងអ្នកពាក់ព័ន្ធ គួររួមបញ្ចូលនៅក្នុងចំណុចពិភាក្សាទាំងនេះ។ អ.វ.ត.ក គួររៀបចំផែនការរបស់ខ្លួនដោយផ្ទាល់ និងតម្លាភាព។ ដំណើរការថវិកាសម្រាប់ដំណាក់កាលដែលនៅសេសសល់ អាចផ្អែកលើធនធានដែលជាថវិកាត្រៀមសម្រាប់ការចូលរួមកិច្ចការទូទៅ ហើយជាពិសេស ក៏ជាការមគ្គុទេសក៍សម្រាប់ការផ្ដល់មូលនិធិដល់កម្មវិធីយុត្តិធម៌អន្តរកាលផងដែរ។[៥២]

៥២ Paige Arthur និង Christalla Yakinthou, ការផ្ដល់មូលនិធិយុត្តិធម៌អន្តរកាល: មគ្គុទ្ទេសក៍សម្រាប់ការចូលរួមរបស់សង្គមស៊ីវិល, ការស្រាវជ្រាវសកម្មភាពសាធារណៈ:, ឆ្នាំ ២០១៥។ សូមមើលផងដែរ Laura McGrew, "កម្ពុជា," ជំពូកនៅក្នុងយុត្តិធម៌អន្តរកាល ជំនួយអន្តរជាតិ និងសង្គមស៊ីវិល៖ ការតភ្ជាប់ដែលខកខាន, Eds. Paige Arthur, P និង Christalla Yakinthou, Cambridge University Press, ឆ្នាំ២០១៨។

# មធ្យោបាយទាំង៣ ដែលអាចប្រើប្រាស់រួម

ដោយហេតុថា យើងបានចូលរួមក្នុងដំណើរការពិគ្រោះយោបល់ និងសិក្ខាសាលារហូតមកដល់ពេលនេះ លេខាធិការដ្ឋានបានយល់ច្បាស់ថា ទំនងអាចមានវិធីសាស្ត្រសក្តានុពលចំនួន ០៣ សម្រាប់ការត្រៀមរៀបចំ និងផ្តល់មូលនិធិដល់កម្មវិធីនៃដំណាក់កាលដែលនៅសេសសល់របស់ អ.វ.ត.ក។ លទ្ធផលជាក់ស្តែងនៅក្នុងដំណាក់កាលដែលនៅសេសសល់ទំនងនឹងត្រូវបានរៀបចំឡើង ដោយផ្អែកលើគំរូម៉ូឌុលជាច្រើន ហើយមិនមែនលើតែក្រឹត្យក្រមមួយសម្រាប់ប្រើលើកម្មវិធីទាំងអស់នៃមុខងារដែលនៅសេសសល់នោះទេ។ មធ្យោបាយទាំង ០៣ ដែលអាចប្រើប្រាស់រួមមានដូចខាងក្រោម៖

## ● គំរូ "ផ្ទៃក្នុង"

ដែល អ.វ.ត.ក គ្រប់គ្រង និងផ្តល់មូលនិធិដល់កម្មវិធីទាំងអស់ដោយផ្ទាល់។ គំរូនេះមិនអាចប្រើប្រាស់សម្រាប់កម្មវិធីស្ទើរតែទាំងអស់ ដូចបានពិភាក្សានៅក្នុងរបាយការណ៍នេះទេ ដោយសារបុគ្គលិក អ.វ.ត.ក មានចំនួនកម្រិតក្នុងដំណាក់កាលដែលនៅសេសសល់ ហើយសង្គមស៊ីវិល និងដៃគូរដ្ឋត្រូវការមានជំនាញកាន់តែច្រើនក្នុងការអនុវត្តគម្រោងបែបនេះ។ លើសពីនេះ អ.វ.ត.ក ទទួលថវិកាមួយផ្នែកពីថវិកាបដិភាគកម្ពុជា និងដោយថវិកាស្ម័គ្រចិត្តពីអន្តរជាតិ ដូច្នេះ អ.វ.ត.ក ពឹងផ្អែកលើថវិកា និងមូលនិធិ ដែលខ្លួនទទួលបានពីតួអង្គខាងក្រៅ និងអ្នកធ្វើសេចក្តីសម្រេច។ ដំណាក់កាលដែលនៅសេសសល់ ត្រូវបានគេរំពឹងថានឹងឃើញថយចុះសកម្មភាព ដែលដំណើរការ ទទួលមូលនិធិ និងគ្រប់គ្រងផ្ទាល់ដោយ អ.វ.ត.ក ដូច្នេះ គំរូនេះហាក់ដូចជាមិនជោគជ័យក្នុងកម្មវិធីភាគច្រើនទេ។

## ● គំរូ "សហប្រតិបត្តិការ"

ដែល អ.វ.ត.ក ធ្វើការរួមគ្នាជាមួយអង្គការដៃគូក្នុងស្រុក ឬ ស្ថាប័នដៃគូអនុវត្ត ដែល អ.វ.ត.ក ជាអ្នកផ្តល់ការគាំទ្រជាយន្តការផ្តល់មូលនិធិ និង/ឬផ្នែកធនធានមនុស្ស សម្ភារៈ ឬការចូលប្រើមើលឯកសារ និងបណ្តាញ។ ការងារនេះអាចរាប់បញ្ចូលទាំងការបណ្តុះបណ្តាលបុគ្គលិក អ.វ.ត.ក ដើម្បីសហការសកម្មលើគម្រោងដែលត្រូវបានអនុវត្តនៅក្នុងមុខងារដែលនៅសេសសល់ជាមួយអង្គការដៃគូ ឬ ការងារនេះអាចជាការផ្តល់ធនធានសំខាន់ៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍបណ្ណសារ ឬសមត្ថភាពបច្ចេកទេសរបស់ដៃគូ។ វាក៏អាចរួមបញ្ចូលការអនុវត្តកម្មវិធីទាំងស្រុងដោយអង្គការដៃគូ ប៉ុន្តែដោយមានការផ្តល់មូលនិធិតាមរយៈយន្តការ អ.វ.ត.ក។ ទោះបីជាការងារនេះអាចត្រូវការចំណាយបន្ថែមពីអង្គការសហប្រជាជាតិ វាអាចមានហានិភ័យតិចតួចសម្រាប់ម្ចាស់ជំនួយ ប្រសិនបើមូលនិធិឆ្លងកាត់ស្ថាប័នអង្គការសហប្រជាជាតិស្របច្បាប់ ជាជាងដោយផ្ទាល់ទៅកាន់អង្គការអនុវត្ត។

## ● គំរូ "ទទួលការយល់ព្រម"

ដែល អ.វ.ត.ក រៀបរាប់ គាំទ្រ និងទទួលស្គាល់គម្រោង ឬកម្មវិធីដែលសមស្របទៅនឹងបេសកកម្មនៅក្នុងដំណាក់កាលដែលនៅសេសសល់ ជាសាធារណៈ។ អ.វ.ត.ក ជួយស្វែងរកស្ពានទំនាក់ទំនងសម្រាប់ការផ្តល់មូលនិធិ ឬ ការគាំទ្រ ហើយ អ.វ.ត.ក ក៏ផ្តល់សម្ភារៈទាំងឡាយដែលខ្លួនអាចផ្តល់ជូននៅក្នុងបណ្ណសាររបស់ខ្លួន ផ្តល់ទីតាំងនៅក្នុងបរិវេណសាលារបស់ខ្លួន ឬ ការចូលរួមរបស់បុគ្គលិកតិចតួចបំផុតក្នុងការងារផ្សព្វផ្សាយ និងជំរុញគម្រោង ប៉ុន្តែមិនផ្តល់ហិរញ្ញប្បទានដល់អ្នកអនុវត្ត ឬ ចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីនោះឡើយ។ អ.វ.ត.ក នឹងប្រើប្រាស់អំណាចកោះប្រជុំ និងបណ្តាញរបស់ខ្លួននៅក្នុង RGC និងក្នុងចំណោមម្ចាស់ជំនួយអន្តរជាតិ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីទាំងនេះ។ ទម្រង់បែបបទនេះក៏អាចចាត់ទុកថាជាការពង្រីកវិធីដែល អ.វ.ត.ក គ្រប់គ្រងគម្រោងសំណងក្នុងសំណុំរឿង ០០២ ដែលគម្រោងនានាត្រូវបានគាំទ្រជានិមិត្តរូបដោយតុលាការឧបត្ថម្ភថវិកាទាំងស្រុងដោយម្ចាស់ជំនួយពីខាងក្រៅ និងអនុវត្តដោយដៃគូខាងក្រៅក្រោមឆ័ត្រនៃគម្រោងសំណង។ ទោះបីជាយ៉ាងនេះក្តី យើងសូមស្នើឱ្យ អ.វ.ត.ក ខិតខំប្រឹងចូលរួមសកម្មថែមទៀតក្នុងការអនុវត្តកម្មវិធីទាំងនេះជាងការផ្តល់សំណង។



លោក ពេជ អង្គ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កំពុងស្តាប់ការធ្វើបទបង្ហាញ ក្នុងពិធីបិទសិក្ខាសាលា នៅថ្ងៃទី៣នៃសិក្ខាលសាលា ។



ឯ.ឧ មីកាមី ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតជប៉ុន និងសហប្រធានប្រទេសជាមិត្ត អ.វ.ត.ក កំពុងថ្លែងសុន្ទរកឋាបិទនៅថ្ងៃទី៣ នៃសិក្ខាលសាលា ។



លោក សឹម សុរិយ៉ា មន្ត្រីច្បាប់អ.វ.ត.ក និងអ្នកសម្របសម្រួលក្រុម ចូលរួមពិភាក្សា ជាមួយសិក្ខាកាម នៅថ្ងៃទី១ នៃសិក្ខាសាលា ។

ក្រុមទី ៣ នៅក្នុងវគ្គសិក្ខាសាលា ក៏បានលើកឡើងអំពីតម្រូវការដើម្បីចៀសវាង "ការជ្រៀតជ្រែកបេសកកម្ម" ហើយបានស្នើថា តួនាទីដ៏ល្អបំផុតរបស់ អ.វ.ត.ក នៅក្នុងគម្រោងជាច្រើននេះ អាចការតស៊ូមតិសុំជំនួយថវិកាពីរាជរដ្ឋាភិបាល ឬម្ចាស់ជំនួយអន្តរជាតិ និងការពង្រីកសកម្មភាពរបស់អង្គភាពផ្សេងទៀត។ សំណើរបស់ YRDP បន្ទាប់ពីសិក្ខាសាលា បានបង្ហាញឱ្យឃើញជាថ្មីម្តងទៀតអំពីការចាំបាច់ឱ្យ អ.វ.ត.ក រៀបចំផែនការចាកចេញចុងក្រោយរបស់ខ្លួន ក្នុងពេលខ្លួនចូលដល់ដំណាក់កាលដែលនៅសេសសល់។ សមាហរណកម្ម និងភាពស៊ីសង្វាក់គ្នានៅទូទាំងស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋាភិបាល គួរតែផ្តល់ព័ត៌មានអំពីបញ្ហានៃការផ្តល់មូលនិធិ និងការគ្រប់គ្រង។

យើងមិនគាំទ្រ ឬ បដិសេធវិធីណាមួយខាងលើនោះទេ ប៉ុន្តែយើងបង្ហាញវិធីទាំងនេះក្នុងរបាយការណ៍ ប្រកបដោយតម្លាភាព ដើម្បីឱ្យអ្នកពាក់ព័ន្ធទាំងអស់ចាប់ផ្តើមពិចារណាឱ្យបានហ្មត់ចត់ក្នុងការរៀបចំផែនការសម្រាប់ដំណាក់កាលដែលនៅសេសសល់ មិនមែនគ្រាន់តែថាតើខ្លួននឹងគាំទ្រកម្មវិធីទាំងនេះប៉ុណ្ណោះទេ គឺត្រូវគិតថានឹងធ្វើដូចម្តេចផងដែរ។ ដូចបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ មិនមានវិធីសាស្ត្រ "មួយត្រូវគ្រប់ស្ថានភាព" នោះទេ ហើយវិធីសាស្ត្រដ៏ល្អបំផុតនឹងត្រូវកំណត់សម្រាប់កម្មវិធីមួយៗ។ អង្គការ និងស្ថាប័នអនុវត្ត ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់ជំនួយពីខាងក្រៅ រាជរដ្ឋាភិបាល និង អ.វ.ត.ក គួរពិចារណាដោយបើកចំហនូវមធ្យោបាយដ៏ល្អបំផុត ដើម្បីបម្រើសេចក្តីត្រូវការរបស់ជនរងគ្រោះ។ តម្លាភាព និងគណនេយ្យភាពគួរបង្កើតឡើងនៅក្នុងដំណើរការនេះ។ យើងគាំទ្រឱ្យមានការចូលរួមពីជនរងគ្រោះ និងអ្នកតំណាងរបស់ពួកគេនៅក្នុងដំណើរការរៀបចំផែនការ ដូចបានរៀបរាប់ខាងលើ និងដូចបានលើកជាឧទាហរណ៍នៅក្នុងការរៀបចំសិក្ខាសាលាជនរងគ្រោះ។ យើងក៏កត់សម្គាល់ផងដែរនូវសំណូមពរជាច្រើននៅក្នុងសិក្ខាសាលា និងនៅក្នុងសំណើរបស់ក្រុមនៅក្រៅប្រទេសថា គួរតែមានស្ថាប័នត្រួតពិនិត្យចូលរួមដំណើរការធ្វើសេចក្តីសម្រេចលើបញ្ហាចោទនៃការផ្តល់មូលនិធិនៅក្នុងដំណាក់កាលដែលនៅសេសសល់។

យើងក៏ស្នើឱ្យភាគីពាក់ព័ន្ធទាំងអស់មកពីសង្គមស៊ីវិល ស្ថាប័នរដ្ឋ និង អ.វ.ត.ក សំអាងលើសុទិដ្ឋិនិយម និងលទ្ធផលនៃសិក្ខាសាលាដ៏មមាញឹកកាលពីខែឧសភា ឆ្នាំ២០២២។ ព្រឹត្តិការណ៍នោះបានបង្ហាញពីថាមពលដែលនៅបន្តមាន បន្ទាប់ពី អ.វ.ត.ក ដំណើរការងាររយៈពេលជាង ១៥ឆ្នាំក៏ដោយ ហើយវាបង្ហាញឱ្យឃើញថា ការច្នៃប្រឌិត កើតចេញពីកិច្ចសហការ និងការបើកចំហ និងការជួបជុំញឹកញាប់ជាងមុន។ វាហាក់ដូចបង្ហាញថា អ.វ.ត.ក ទទួលស្គាល់ដែនកំណត់នៃសមត្ថភាពរបស់ខ្លួន ហើយមានបំណងបន្តស្វែងរកអ្នកជំនាញកម្ពុជា និងអន្តរជាតិ យោងតាមភ័ស្តុតាងនៅក្នុងការអំពាវនាវនាពេលថ្មីៗដើម្បីបង្ហាញពីចំណាប់អារម្មណ៍ ដើម្បីរួមចំណែកដល់គំនិតផ្តួចផ្តើមដែលនៅសេសសល់របស់ អ.វ.ត.ក ដែលមានបំណងបន្តប្រមូលធាតុចូលពីអ្នកជំនាញដែលមានសាវតារការងារចម្រុះ។ យើងលើកទឹកចិត្តជនរងគ្រោះ និងអ្នកតំណាងរបស់ពួកគេឱ្យទាញអត្ថប្រយោជន៍ពីឱកាសទាំងនេះ ដើម្បីផ្តល់ធាតុចូល និងឱ្យមានការចូលរួមកាន់តែច្រើន និងដើម្បីចូលដំណាក់កាលដែលនៅសេសសល់ ដោយសម្រេចលទ្ធផលដូចគ្នា ដូចនៅក្នុងសិក្ខាសាលា។

UNAKRT, "Expressions of interest to contribute to ECCC residual initiatives" (២៨ June ២០២២), accessible as of ១៥ July ២០២២ at: <http://www.unakrt-online.org/sites/default/files/EOICMS២០២២០២_ 0.pdf>.

ដើម្បីធានាថា ថាមពល និងសុទិដ្ឋិនិយមនេះអាចអនុវត្តទៅមុខ ចាំបាច់ត្រូវមានក្របខ័ណ្ឌកិច្ចសហការ ការពិគ្រោះយោបល់ និងការឯកភាពគ្នាតាមដែលអាចធ្វើទៅបាន។ ដូចបានលើកឡើងនៅក្នុងសំណើនៃក្រុមនៅក្រៅប្រទេសនៅក្នុងឧបសម្ព័ន្ធ ៧ "ក្រុមប្រឹក្សា

ប្រឹក្សាយោបល់ដែលបានជ្រើសរើសដោយប្រុងប្រយ័ត្ន និងប្រកបដោយតម្លាភាព អាចជួយធានាថា គម្រោងត្រូវបានជ្រើសរើសដោយផ្អែកលើការបារម្ភ និងផលប្រយោជន៍របស់ប្រជាជនកម្ពុជា"។ ក្របខ័ណ្ឌណាមួយក៏ដោយគួរផ្ដល់អាទិភាពដំបូងលើការធ្វើផែនការ និងការត្រួតពិនិត្យលើការចូលរួមនៅក្នុងមុខងារដែលនៅសេសសល់របស់ អ.វ.ត.ក ជាមួយជនរងគ្រោះ និងអ្នកពាក់ព័ន្ធ ប៉ុន្តែក្នុងរយៈពេលវែង យើងអាចបង្កើតស្ថាប័នតស៊ូមតិរបស់ជនរងគ្រោះជាអចិន្ត្រៃយ៍ និងឯករាជ្យ ដែលជាអ្នកត្រួតពិនិត្យឯករាជ្យធ្វើជាតំណាងជនរងគ្រោះ-អ្នករស់រានមានជីវិតដែលមានវ័យចំណាស់ និងដែលមានបណ្ដាញការិយាល័យនៅទូទាំងប្រទេស។ ស្ថាប័នត្រួតពិនិត្យនេះក៏អាចរួមចំណែកដល់ការបង្កើតស្ថាប័នតស៊ូមតិជនរងគ្រោះជាអចិន្ត្រៃយ៍ ក្នុងនាមជាក្រុមប្រឹក្សាភិបាល ឬទីប្រឹក្សា។ ប្រសិនបើបង្កើតក្របខ័ណ្ឌពិគ្រោះយោបល់បើកចំហពិតប្រាកដ នោះដំណាក់កាលដែលនៅសេសសល់នេះអាចពង្រឹងស្មារតីនៃកិច្ចសហការ ការចូលរួម និងសាមគ្គីភាព ដូចអ្នកចូលរួមសិក្ខាសាលាបានស្នើសុំ។ ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងនេះ និងការខិតខំប្រឹងប្រែងរបស់អង្គការសង្គមស៊ីវិល និងស្ថាប័នទាំងឡាយដែលព្យាយាមឆ្លើយតបទៅនឹងសំណើ និងតម្រូវការរបស់ជនរងគ្រោះ អ.វ.ត.ក អាចពឹងផ្អែកលើអំណាចកោះប្រជុំ និងតួនាទីនយោបាយតែមួយគត់របស់ខ្លួនក្នុងការប្រមូលផ្ដុំទាំងរាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ។

មុនពេលប្រកាសសាលដីកាចុងក្រោយក្នុងសំណុំរឿង ០០២/០២ និងការបញ្ចប់ដំណាក់កាលតុលាការរបស់ អ.វ.ត.ក សំខាន់នោះគឺ អ.វ.ត.ក ចាប់ផ្ដើមគូសវាស និងរៀបចំកម្មវិធីដែលបានពិភាក្សានៅក្នុងរបាយការណ៍ និងឯកសារផ្សេងទៀត។ អ.វ.ត.ក និងម្ចាស់ជំនួយត្រូវពិនិត្យមើលថាតើកម្មវិធីណាខ្លះដែលត្រៀមរួចជាស្រេចដើម្បីអនុវត្តភ្លាមៗ ហើយកម្មវិធីណាខ្លះដែលត្រូវការពេលបន្តស្រាវជ្រាវ ឬ រៀបចំផែនការបន្ត។ កម្មវិធីជាច្រើនដែលបានបង្ហាញនៅក្នុងសិក្ខាសាលា និងនៅក្នុងការសំណើបន្ថែមរួមមានដំណាក់កាលសាកល្បងដែលអាចចាប់ផ្ដើមភ្លាមៗនៅពេលដែលដំណាក់កាលដែលនៅសេសសល់ចាប់ផ្ដើម នៅដើមឆ្នាំ២០២៣ ហើយបន្ទាប់មកមានបំណងពង្រីកទៅជាកម្មវិធីដែលអាចអនុវត្តទូទាំងប្រទេសនៅក្នុងឆ្នាំទីពីរ និងទីបី នៃដំណាក់កាលដែលនៅសេសសល់។ ទម្រង់បែបបទដែលបានពិពណ៌នាខាងលើត្រូវតែយកមកពិចារណា ដើម្បីកំណត់ថាតើថវិកា ឬ គំរូរដ្ឋបាលណាដែលសមស្របបំផុតសម្រាប់ការអនុវត្ត គម្រោងបច្ចុប្បន្នភ្លាមៗ និងបានលឿនជាគម្រោងសាកល្បង ឬ គម្រោងជាក់ស្ដែងនៅពេលចាប់ផ្ដើមដំណាក់កាលដែលនៅសេសសល់នៅដើមឆ្នាំ២០២៣។ ប្រសិនបើវដ្តនៃការផ្ដល់មូលនិធិសម្រាប់គម្រោងដ៏សំខាន់មួយត្រូវការពេលវេលា ឬ មិនត្រូវជាមួយនឹងការចាប់ផ្ដើមនៃដំណាក់កាលដែលនៅសេសសល់ អ.វ.ត.ក គួរតែស្វែងរកវិធីណាខ្លះ តាមរយៈ RGC បណ្ដាញនៃម្ចាស់ជំនួយអន្តរជាតិ ឬតាមរយៈថវិកាដែលខ្លួនមានដើម្បីធានាថាគម្រោងជនរងគ្រោះអាចចាប់ផ្ដើមក្នុងពេលនេះ ឬ ក្នុងពេលឆាប់ៗបន្ទាប់ពីដំណាក់កាលដែលនៅសេសសល់បានចាប់ផ្ដើមជាផ្លូវការ។

បន្ថែមពីលើអនុសាសន៍ ដែលបានលើកឡើងនៅក្នុងឯកសារផ្សេងទៀតរហូតមកដល់ពេលនេះ យើងសូមលើកឡើងតម្រូវការបន្ទាន់ជាក់លាក់ចំនួនពីរ ដែលបានលេចឡើងនៅក្នុងសិក្ខាសាលា និងនៅក្នុងសំណើមុន និងក្រោយសិក្ខាសាលា ហើយដែលមានឥទ្ធិពលលើកម្មវិធីផ្សេងទៀត។ ចំណុចនេះគ្រាន់តែជាឧទាហរណ៍ពីរនៃកិច្ចការចាំបាច់ដែលត្រូវតែ

ធ្វើឡើងក្នុងពេលឆាប់ៗខាងមុខ ប្រសិនបើចង់ឱ្យដំណាក់កាលដែលនៅសេសសល់មានប្រសិទ្ធភាពបំផុត។

ទីមួយ អ.វ.ត.ក តាមរយៈ VSS និង CPLCLs ត្រូវតែធ្វើយុទ្ធនាការដ៏ទូលំទូលាយមួយ ដើម្បីតាមដានរាល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង ០០១ និង ០០២ និងអ្នកដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣, ០០៤, ០០៤/០១, និង ០០៤/០២។ អ្នកទាំងនេះត្រូវទទួលបានការជូនដំណឹងអំពីលទ្ធផលនៅក្នុងដំណើរការនីតិវិធីទាំងនោះ និងគម្រោងសំណងដែលបានធ្វើឡើងរហូតមកដល់ពេលនេះ ហើយគួរតែត្រូវបានផ្តល់ឱកាសចូលរួមសម្រេចចិត្តណាមួយលើព័ត៌មានឯកជនរបស់ពួកគេ នៅពេលធ្វើចំណាត់ប្រភេទឡើងវិញជាចុងក្រោយលើឯកសារសំណុំរឿង។ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ និង ០០២ គួរទទួលបានដំណឹងលម្អិតអំពីលទ្ធផលចុងក្រោយនៃសំណុំរឿងរបស់ពួកគេ។ ជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ និង ០០៤ គួរតែទទួលបានការជូនដំណឹងថា សក្ខីកម្ម និងភ័ស្តុតាងរបស់ពួកគេត្រូវបានស្តាប់ ពួកគេត្រូវបានទទួលស្គាល់នៅក្នុងសំអាងហេតុក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងតម្កល់ដោយចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ហើយបទពិសោធន៍របស់ពួកគេត្រូវបានស្តាប់ និងទទួលស្គាល់ ទោះបីជាសំណុំរឿងទាំងនោះមិនដំណើរការទៅជំនុំជម្រះក្តីក៏ដោយ។ កិច្ចការនេះមិនមែនជាកិច្ចការតូចតាចនោះទេ ហើយគួរតែចាប់ផ្តើមភ្លាមៗ ជាជាងរង់ចាំការចាប់ផ្តើមនៃដំណាក់កាលដែលនៅសេសសល់។ កិច្ចការនេះគួរធ្វើឡើងដូចគ្នានេះចំពោះអ្នកដាក់បណ្តឹងតវ៉ា។ ការចងក្រងព័ត៌មានជនរងគ្រោះទាំងអស់គួរចាប់ផ្តើមឱ្យរួចហើយ ដោយសារលេខទូរស័ព្ទ ឬអាសយដ្ឋានរបស់អ្នកនៅរស់រានមានជីវិតជាច្រើនបានផ្លាស់ប្តូរ។ ប្រសិនបើ VSS និង CPLCLs ត្រូវការធនធានបន្ថែមទៀតដើម្បីអនុវត្តកិច្ចខិតខំប្រឹងប្រែងនេះ ធនធានទាំងនោះគួរតែត្រូវបានផ្តល់ជូន។ ជាមួយនឹងការលាឈប់នាពេលថ្មីៗរបស់ Megan Hirst CPLCL អន្តរជាតិ អ.វ.ត.ក ត្រូវបង្ហាញឱ្យឃើញថា ខ្លួននៅតែមានបំណងបំពេញតួនាទីនេះ បើទោះបីជា អ.វ.ត.ក ឈានជិតដល់ពេលបិទបញ្ចប់សកម្មភាពតុលាការ និងចាប់ផ្តើមនៃដំណាក់កាលដែលនៅសេសសល់ក៏ដោយ។ សេចក្តីថ្លែងការណ៍របស់លោកស្រីដែលថា អ.វ.ត.ក រហូតមកដល់ពេលនេះ មិនទាន់បានផ្តល់ការគាំទ្រជាចាំបាច់ដល់ក្រុមលោកស្រី លើការងារចូលរួមជាមួយដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែដោះស្រាយដោយតម្លាភាពជាងមុន និងត្រូវមានយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈឱ្យបានសុះសាយឡើង។ CPLCL ថ្មី នឹងត្រូវត្រៀមខ្លួនដើម្បីធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មានសាធារណៈ ទូទាំងប្រទេសឱ្យបានទូលំទូលាយ ដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់អតិថិជនរបស់ខ្លួនអំពីការរកឃើញ និងលទ្ធផលផ្លូវច្បាប់។ កិច្ចខិតខំប្រឹងប្រែងនេះគឺចាំបាច់ត្រូវធ្វើឡើងដើម្បីគោរពសិទ្ធិរបស់ជនរងគ្រោះដែលបានចូលរួមក្នុងដំណើរការនីតិវិធី ហើយក៏ដើម្បីបង្ហាញដល់ពួកគេថា ការចូលរួម និងបទពិសោធន៍របស់ពួកគេមិនត្រូវបានបំភ្លេចចោលនោះឡើយ។ នេះគឺជាជំហានចាំបាច់មួយ មុនពេល អ.វ.ត.ក ពង្រីកបេសកកម្មរបស់ខ្លួនឆ្ពោះទៅរកសកម្មភាព ឬកិច្ចខិតខំប្រឹងប្រែងដែលផ្តោតលើជនរងគ្រោះ ក្នុងគោលបំណងដើម្បីផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត។

៥៤ UNAKRT, "សេចក្តីប្រកាសព័ត៌មានអំពីមុខតំណែងទំនេរ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ" (ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២) ចូលមើលនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ នៅលើគេហទំព័រ៖ http://www.unakrt-online.org/sites/default/files/VA-CPLC-២០២២-០២.pdf

៥៥ លិខិតដកខ្លួនរបស់ CPLCL អន្តរជាតិ Megan Hirst ដែលបានដាក់ជូនអង្គជំនុំជម្រះតុលាការកំពូល អ.វ.ត.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ និងចូលមើលជាសាធារណៈថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ តាមរយៈវិទ្យុសម្លេងអាមេរិក សូមមើល៖ https://docs.voanews.eu/en-US/២០២២/០៧/០៨/២f៣efa៣១-៤៩d១-៤៨១៥-៩c៩f-៥e៩៣fd៦bf៧៣៨.pdf

ទីពីរ ដំណាក់កាលដែលនៅសេសសល់ ដែលមានប្រសិទ្ធភាព និងមានន័យជាងនេះ អាចកើតឡើងតាមរយៈទិន្នន័យដើមគ្រាអំពីការយល់ឃើញរបស់ អ.វ.ត.ក និងដំណើរការយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យនេះគួរតែកំណត់គោលដៅមិនត្រឹមតែផ្តោតលើជនរងគ្រោះ-អ្នករស់រានមានជីវិត ឬដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះទេ ប៉ុន្តែក៏គួរសំដៅលើយុវជនផងដែរ។ សំណើពីសាកលវិទ្យាល័យ La Trobe និង Marie Wilmet នៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍ ក៏ដូចជាសំណើរបស់ Mychelle Balthazard និងក្រុមនៅក្រៅប្រទេស ផ្តល់ព័ត៌មានលម្អិតមួយចំនួនអំពីឱកាសដែលអាចឱ្យកិច្ចខិតខំប្រឹងប្រែងបែបនេះកើតឡើង។ ការស្ទាបស្ទង់មតិពីប្រជាពលរដ្ឋមិនបានធ្វើឡើងជាច្រើនឆ្នាំមកហើយ ហើយ អ.វ.ត.ក និងភាគីពាក់ព័ន្ធសង្គមស៊ីវិល នឹងទទួលបានអត្ថប្រយោជន៍ពីទិន្នន័យដែលខ្លួនមាន។ កិច្ចខិតខំប្រឹងប្រែងបែបនេះក៏អាចធ្វើឡើងដើម្បីសាកសួរសាធារណជនអំពីកម្មវិធី ឬគោលការណ៍ដែលពួកគេចង់ឃើញអនុវត្តក្នុងដំណាក់កាលដែលនៅសេសសល់។ កិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវដែលចាប់ផ្តើមនៅចុងឆ្នាំ២០២២ អាចបង្ហាញនូវរបកគំហើញនៅពាក់កណ្តាលឆ្នាំ២០២៣ ដែលតាមរយៈលទ្ធផលនៃរបកគំហើញ អាចបង្កើតកម្មវិធីថ្មី ឬ កែសម្រួលកម្មវិធីដែលមានស្រាប់នៅដើមឆ្នាំ២០២៤ ពោលគឺនៅពេលចាប់ផ្តើមអាណត្តិដែលនៅសេសសល់ក្នុងឆ្នាំទី២។

ក្នុងពេលដំណាលគ្នានេះ ដំណើរការពិគ្រោះយោបល់ដោយបើកចំហ ដែលបន្តឱ្យមានការចូលរួមពីជនរងគ្រោះ និងតំណាងរបស់ពួកគេ ដើម្បីលើកឡើងសំណើរបស់ពួកគេដែលអាចកើតចេញពីការសម្រេចអំពីទម្រង់ការផ្តល់មូលនិធិ និងកម្មវិធីជាបន្តបន្ទាប់ នឹងពង្រឹងកម្មវិធីចុងក្រោយ និងធានាបាននូវ "ឆន្ទៈនយោបាយ និងសង្គម"។ ការសម្រេចចិត្តកាន់តែច្រើននឹងត្រូវធ្វើឡើងនាពេលក្រោយ ដែលនេះជាហេតុផលត្រូវរៀបចំសិក្ខាសាលាក្រុមការងារបច្ចេកទេស ឬការពិគ្រោះយោបល់បន្ថែម។ នៅទីបំផុត វាអាស្រ័យលើអង្គការសង្គមស៊ីវិលជាអ្នកកំណត់នូវអ្វីដែលពួកគេចង់អនុវត្ត និងរបៀបដែលពួកគេនឹងអនុវត្ត។ ការជួបជុំគ្នា ដែលផ្តួចផ្តើមដោយ អ.វ.ត.ក និងផ្តោតសំខាន់លើទស្សនៈរបស់ជនរងគ្រោះ នឹងជាប្រយោជន៍ដល់អង្គការទាំងអស់ កាន់តែប្រសើរជាងមុន ព្រមទាំងនឹងជំរុញឱ្យមានកិច្ចសហការជាជាងការប្រកួតប្រជែង ហើយនឹងរៀបចំរចនាសម្ព័ន្ធការងារដែលនៅសេសសល់នៅ អ.វ.ត.ក រយៈពេលបីឆ្នាំប្រកបដោយជោគជ័យ និងផ្លែផ្កា។

# V.

# សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់


E.C.C.C * C.E.T.C

សេចក្ដីសង្ខេបនៃចំណុចសំខាន់ៗនៅក្នុងរបាយការណ៍នេះអាចមើលនៅក្នុងសេចក្ដីសង្ខេបនៅដើមទំព័រ ពោលគឺ ទំព័រ vii។ ជៀសវាងការលើកឡើងដដែលនូវអ្វីដែលបានបញ្ជាក់រួចហើយ យើងសូមផ្ដល់ជូននូវការសង្កេត និងការសន្និដ្ឋានរបស់យើងអំពីការចូលរួមនៅក្នុងសិក្ខាសាលា និងដំណើរការដែលនាំឱ្យមានសិក្ខាសាលានេះ។

អ្វីដែលបានលេចឡើងក្នុងរយៈពេលប៉ុន្មានខែកន្លងទៅនេះពាក់ព័ន្ធនឹងការចូលរួមពីភាគីពាក់ព័ន្ធនៅក្នុងសកម្មភាពទាក់ទងនឹងជនរងគ្រោះ គឺជាលទ្ធភាពដ៏វិសេសវិសាលមួយឈានទៅកសាងកេរដំណែលរបស់ អ.វ.ត.ក។ នៅពេលដែលតុលាការឈានចូលដំណាក់កាលដែលនៅសេសសល់ វាជាឱកាសដែលយើងត្រូវប្រមូលកម្លាំង ការប្ដេជ្ញាចិត្ត និងជំនាញ ដែលឃើញលើកឡើងនៅក្នុងដំណើរការដែលកើតចេញពីការអំពាវនាវរបស់សហចៅក្រមរបាយការណ៍ឱ្យដាក់សំណើសុំជូនសិក្ខាសាលា។ ការដាក់សំណើជូនសហចៅក្រមរបាយការណ៍ គំនិតផ្ដួចផ្ដើមដែលបានពិភាក្សានៅក្នុងសិក្ខាសាលា និងសំណើ និងសំណូមពរដែលបង្កើតឡើងក្នុងអំឡុងពេល និងក្រោយសិក្ខាសាលា តំណាងឱ្យលទ្ធផលនៃការចូលរួមរបស់សង្គមស៊ីវិលជាមួយតុលាការ និងជាមួយស្ថាប័នរាជរដ្ឋាភិបាល ក្នុងរយៈពេល ១៦ឆ្នាំមកនេះ។ នៅពេលឆ្លុះបញ្ចាំងលើអ្វីដែលយើងបានរៀន និងសង្កេតនាពេលកន្លងមក អាចឱ្យយើងយល់ច្បាស់នូវអ្វីដែលអាចសម្រេចបាន ប្រសិនបើបទពិសោធន៍ដ៏សម្បូរបែបនេះអាចត្រូវបានប្រមូលយ៉ាងមានប្រសិទ្ធភាពដើម្បីដោះស្រាយតម្រូវការ គោលដៅ និងប្រធានបទសំខាន់ៗដែលបានកំណត់នៅក្នុងសិក្ខាសាលា។ បញ្ហាប្រឈមគឺធ្វើដូចម្ដេចដើម្បីឱ្យសក្ដានុពលនេះចេញជាផ្លែផ្កា។ សិក្ខាសាលានេះគ្រាន់តែជាការចាប់ផ្ដើមតែប៉ុណ្ណោះ ប៉ុន្តែដោយមើលឃើញការចូលរួមផុសផុល និងស្មារតីនៃកិច្ចសហការពីអ្នកចូលរួម វាជាការសន្យាអំពីជំហានបន្ទាប់ ដែលយើងអាចបញ្ចូលដំណាក់កាលដែលនៅសេសសល់ជាមួយនឹងកម្មវិធី សំដៅជានាផលប្រយោជន៍ដល់សង្គមកម្ពុជាដែលនឹងបន្តដំណើរទៅមុខៗ។ ចំណុចបង្ហាញច្បាស់ គឺថាមានបញ្ហាប្រឈមដែលត្រូវជំនះ ប្រសិនបើចង់សម្រេចគោលដៅ និងកិច្ចការដ៏មហិច្ឆតា ដូចបានលើកឡើងក្នុងសិក្ខាសាលា។ នៅក្នុងផ្នែកស្ដីពីសេចក្ដីសន្និដ្ឋាន យើងសូមជូនជាយោបល់មួយចំនួនទាក់ទងនឹងតម្រូវការនៅក្នុងជំហានបន្តបន្ទាប់ ដើម្បីអនុវត្តចេញជាផ្លែផ្កា។

ទីមួយ កម្លាំងដែលប្រមូលបានក្នុងរយៈពេលប៉ុន្មានខែកន្លងមក មិនត្រូវឱ្យរលាយសាបសូន្យទៅវិញនោះឡើយ។ ដូចសហចៅក្រមរបាយការណ៍ជូនជាអនុសាសន៍ និងមិនខុសពីអ្នកចូលរួមក្នុងសិក្ខាសាលា ត្រូវតែមានកិច្ចប្រជុំបន្តជាប្រចាំ ដើម្បីផ្ដល់វេទិកាបន្តការពិភាក្សា និងសម្រេចបាននូវកិច្ចសហការ និងគំនិតផ្ដួចផ្ដើមដែលពួកគេបានស្នើឡើង។ ប្រធានបទនៅក្នុងសិក្ខាសាលា និងការចូលរួមជាមួយសហចៅក្រមរបាយការណ៍ គឺអំពីចីរភាពដែលទាមទារឱ្យមានការចូលរួមជាបន្តបន្ទាប់ក្នុងចំណោមក្រុមពាក់ព័ន្ធផ្សេងៗដែលតំណាងនៅក្នុងសិក្ខាសាលា។ អ.វ.ត.ក ត្រូវមាននាទីធ្វើយ៉ាងណាឱ្យដំណាក់កាលដែលនៅសេសសល់បន្តនិរន្តភាព ដោយត្រូវបំពេញមុខងារជាអង្គភាពរៀបចំដូចទើបបានអនុវត្តនាពេលថ្មីៗ។

ទីពីរ យើងមិនអាចទុកឱ្យភាគីពាក់ព័ន្ធនីមួយៗជាអ្នកជំរុញការឆ្លើយតបសំណើនោះទេ។ ប្រធានបទដ៏សំខាន់បំផុតមួយដែលបានលើកឡើងក្នុងអង្គសិក្ខាសាលាគឺការចង់បានវេទិកាសហការ ដើម្បីជៀសវាងការងារជាន់គ្នា និងការប្រកួតប្រជែងក្នុងចំណោមភាគីពាក់ព័ន្ធ និងជួយសម្រួលដល់ដំណើរការដែលពួកគេអាចសហការរួមគ្នាដើម្បីអភិវឌ្ឍ និងអនុវត្តគម្រោង។ វិសាលភាពមហិច្ឆតារបស់បុគ្គលជាច្រើន បើទោះមិនទាំងអស់ក៏ដោយ ដែលបានស្នើគម្រោង

← អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសវនាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ប្រឆាំងនឹង ខៀវ សំផន នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០១៥។

ឡើង តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាតាមរយៈការប្រើប្រាស់បណ្តាញ បទពិសោធន៍ និងសមត្ថភាពផ្សេងៗគ្នា ដែលអង្គការចូលរួមមាន។ ក្នុងដំណើរការនេះ ចាប់ផ្តើមពីពេលដាក់សំណើជូនសហចៅក្រមរបាយការណ៍រហូតមកដល់ថ្ងៃនេះ យើងឃើញមានការទទួលស្គាល់ដដែលៗអំពីតម្រូវការឱ្យមានការចូលរួមទូទាំងប្រទេសនៅក្នុងការងារសំខាន់ៗទាក់ទងនឹងជនរងគ្រោះ។ វិសាលភាពបែបនេះតម្រូវឱ្យមានកិច្ចសហការ ហើយបុរេលក្ខខណ្ឌនៃកិច្ចសហការគឺត្រូវមានយន្តការដ៏មានប្រសិទ្ធភាព ដែលអាចអនុញ្ញាត និងសម្រួលដល់ដំណើរការនេះ។ ការបង្កើតវេទិកាសិក្ខាសាលាជាបន្តបន្ទាប់ជាប្រចាំ នឹងផ្តល់មូលដ្ឋានសម្រាប់ការអភិវឌ្ឍវេទិកាកិច្ចសហប្រតិបត្តិការបែបនេះ ហើយអាចធានាឱ្យចាប់ផ្តើមការពិភាក្សា និងលទ្ធផលទទួលបានផ្លែផ្កា។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាសិក្ខាសាលាបានអំពាវនាវឱ្យជំរុញកិច្ចសហការបន្ថែមរវាងអ្នកសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ន RGC និងអ្នកពាក់ព័ន្ធដទៃទៀត។ ក្រុមទាំងនេះមិនត្រូវការធ្វើអន្តរកម្មក្នុងដំណើរការជម្មតានោះទេ ប៉ុន្តែសិក្ខាសាលាបានបង្ហាញថាពួកគេនឹងចូលរួមដោយសស្រាក់សស្រាំជាមួយគ្នា ប្រសិនបើបានផ្តល់កន្លែង និងឱកាសត្រឹមត្រូវសម្រាប់ការងារ។

ទីបី ការបន្តដំណើរការសិក្ខាសាលាគួរធ្វើឡើងតាមវិធីណាមួយដែលជំរុញឱ្យមានការចូលរួមពីអង្គការដែលមានផលប្រយោជន៍ ជំនាញ និងគោលដៅរួម។ ការងារនេះនឹងតម្រូវឱ្យមានការកំណត់វិស័យអាទិភាពសម្រាប់ការផ្តួចផ្តើមគំនិត និងការរៀបចំក្រុមតូចៗ និងការប្រជុំដែលផ្តោតលើគោលបំណងនៃការបង្កើត ការផ្តល់មូលនិធិ ការអនុវត្ត និងវាយតម្លៃសំណើ និងគម្រោងនៅក្នុងវិស័យទាំងនោះ។ សំណូមពរដែលចង់ស្នើឡើង គឺមិនមែនចង់ឱ្យរៀបចំសិក្ខាសាលាដដែលៗម្តងហើយម្តងទៀតនោះទេ ប៉ុន្តែត្រូវបង្កើតផែនការការងារជាប្រព័ន្ធដោយត្រូវរៀបចំសិក្ខាសាលាតាមប្រធានបទតូចៗ ដើម្បីប្រមូលផ្តុំភាគីពាក់ព័ន្ធដែលបានកំណត់ថាមានផលប្រយោជន៍រួមនៅក្នុងវិស័យតែមួយ។ ដូចបានកត់សម្គាល់ក្នុងចំណុចខាងលើនៅក្នុងរបាយការណ៍នេះ យើងឃើញមានចំណុចទាក់ទងគ្នាច្រើន និងចំណុចត្រួតគ្នារវាងប្រធានបទ និងគំនិតផ្តួចផ្តើម។ អាស្រ័យហេតុនេះ ក្រុមជំនាញគួររាយការណ៍ត្រឡប់ទៅ "សហគមន៍សិក្ខាសាលា" ក្រុមធំ រៀងរាល់ ២ ទៅ ៤ ដងក្នុងមួយឆ្នាំ ដើម្បីសម្របសម្រួលគំនិតផ្តួចផ្តើម កំណត់ការរួមការងារ និងឱកាសពង្រីកសមិទ្ធផល និងការតភ្ជាប់ និងបង្កើតយុទ្ធសាស្ត្រសម្រាប់ការផ្តល់មូលនិធិគម្រោង។

ទីបួន ប្រសិនបើចង់បំពេញតាមការសន្យាដែលបានបង្ហាញនៅក្នុងសំណើ និងមានកម្លាំងសហប្រតិបត្តិការដែលបានបង្កើតឡើងនៅក្នុងសិក្ខាសាលា ត្រូវមានយន្តការផ្តល់មូលនិធិគ្រប់គ្រាន់។ ផ្នែកទី IV.៥ ខាងលើ បង្ហាញទិដ្ឋភាពនៃគំរូមួយចំនួន។ ទោះជាយ៉ាងនេះក្តី ចំណុចសំខាន់ គឺឆន្ទៈនយោបាយនៅក្នុងចំណោមសហគមន៍ម្ចាស់ជំនួយ រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យអ្វីដែលបង្ហាញនៅទីនេះមិនបាត់បង់។ ប្រសិនបើអង្គការសង្គមស៊ីវិលនីមួយៗត្រូវបានទុកចោលឱ្យប្រើប្រាស់យន្តការផ្ទាល់ខ្លួនដើម្បីស្វែងរកមូលនិធិ ឱកាសជំរុញឱ្យមានវិធីសាស្ត្រជាប្រព័ន្ធ និងកិច្ចសហប្រតិបត្តិការក្នុងការកសាងកេរដំណែលរបស់ អ.វ.ត.ក នឹងត្រូវបាត់បង់។ វេទិកាសហការដែលបានពិភាក្សាខាងលើ និងចីរភាពដែលវិធីសាស្ត្រជាប្រព័ន្ធអាចកើតចេញ ទាមទារការប្តេជ្ញាចិត្តជារចនាសម្ព័ន្ធក្នុងការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុដែលត្រូវការដើម្បីសម្រេចបានគំនិតផ្តួចផ្តើមដ៏សំខាន់បំផុត ដូចស្នើឡើង។

ទីប្រាំ ដូចបានសង្កត់ធ្ងន់នៅក្នុងរបាយការណ៍នេះ សំឡេងជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីមានសារៈសំខាន់ ត្រូវកំណត់ និងអនុវត្តកម្មវិធីទាក់ទងនឹងជនរងគ្រោះដែលបានពិភាក្សាខាងលើ។ ដោយមើលឃើញអំពីឱកាសចូលរួមប្រកបដោយអត្ថន័យនៅក្នុងសិក្ខាសាលាពួកគេបានលើកឡើងជាឧទ្បារិក និងគូសបញ្ជាក់តម្រូវការរបស់សហគមន៍របស់ពួកគេ។ ការស្តាប់ពួកគេ និងការឱ្យពួកគេចូលរួម មិនត្រឹមតែមានសារៈសំខាន់ វាក៏ជាមធ្យោបាយដ៏ល្អបំផុតដើម្បីធានាថាតម្រូវការកម្មវិធីត្រូវបានបង្កើតយ៉ាងត្រឹមត្រូវ និងដោះស្រាយប្រកបដោយប្រសិទ្ធភាព។ វិធីសាស្រ្ត "តាមបែបពីលើចុះក្រោម" ដែលត្រូវបានប្រើប្រាស់ជាញឹកញាប់នៅក្នុងការងារអភិវឌ្ឍន៍អន្តរជាតិជាច្រើន ទំនងជាការខ្ជះខ្ជាយធនធានដ៏មានតម្លៃ និងពុំទទួលបានលទ្ធផលដែលយើងចង់បាន។ តម្រូវការរួមមួយសំខាន់គឺធ្វើយ៉ាងណាទាញប្រយោជន៍ពីជំនាញដែលកំពុងមាននៅក្នុងដៃក្នុងសង្គមស៊ីវិលកម្ពុជា ដោយសារការចូលរួមជាមួយ អ.វ.ត.ក រយៈពេល ១៦ ឆ្នាំកន្លងមកនេះ និងផ្តល់ការគាំទ្រជាបន្តបន្ទាប់ ដើម្បីធ្វើយ៉ាងណានៅពេលណាដែលដំណាក់កាលដែលនៅសេសសល់ឈានដល់ទីបញ្ចប់ វាបានបន្សល់ទុកសហគមន៍អង្គការ ដែលបានចាប់ផ្តើមអនុវត្តការងារ បន្តដំណើរទៅមុខ។

នៅចុងបញ្ចប់សិក្ខាសាលាខែឧសភា ឆ្នាំ២០២២ ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ពេជ្រ ស្រីផល បានសម្តែងចំណាប់អារម្មណ៍បញ្ចប់ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ-អ្នករស់រានមានជីវិត។ លោកស្រីបានលើកឡើងអំពីសុទិដ្ឋិនិយម និងសង្ឃឹមថាបីឆ្នាំទៀតអាចធានាបាននូវកម្មវិធីដែលមាននិរន្តរភាព និងយូរអង្វែង អាចឆ្លើយតបទៅនឹងសំណើរបស់ជនរងគ្រោះ និងមានការចូលរួមពីសង្គមស៊ីវិល និងស្ថាប័នរដ្ឋដូចគ្នា។ លោកស្រីបានពន្យល់ថា ប្រសិនបើដំណាក់កាលដែលនៅសេសសល់របស់ អ.វ.ត.ក មានប្រសិទ្ធភាព "នោះអ្នកនៅរស់រានមានជីវិតអាចនាំគ្នាលើកថ្មដែលសង្កត់ដើមទ្រូងពួកគេអស់រយៈពេល ៤០ឆ្នាំមកហើយ។ ពួកគាត់មិនដែលបានដកបន្ទាការឈឺចាប់ និងទុក្ខសោកចេញពីទ្រូងអស់រយៈពេល ៤០ឆ្នាំចុងក្រោយនេះ [...] ពួកគេមានអារម្មណ៍កក់ក្តៅ ហើយគិតថាយើងទាំងអស់គ្នាមិនបានបោះបង់ពួកគេចោលនោះទេ។ យើងនៅតែគាំទ្រពួកគេ ហើយជួយពួកគេបន្តទៀត"។ អ.វ.ត.ក រាជរដ្ឋាភិបាល និងម្ចាស់ជំនួយអន្តរជាតិ បច្ចុប្បន្ន មានគំនិត ឧបករណ៍ ធនធាន និងបណ្តាញនៅចំពោះមុខ ដើម្បីធានាថាដំណាក់កាលដែលនៅសេសសល់នេះមានប្រសិទ្ធភាពបំផុតក្នុងការលើកកម្ពស់ និងបង្កើតកម្មវិធីដែលបានពិភាក្សានៅក្នុងរបាយការណ៍ និងសំណើដែលបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធ។ នេះជាឱកាសមួយដែលយើងត្រូវចាប់យកក្នុងនាមជនរងគ្រោះ-អ្នកនៅរស់រានមានជីវិត និងអ្នកជំនាន់ក្រោយ។

ជាសេចក្តីសន្និដ្ឋាន របាយការណ៍នេះនឹងបញ្ជូនទៅការិយាល័យរដ្ឋបាល អ.វ.ត.ក ដើម្បីបោះពុម្ព និងផ្សព្វផ្សាយដល់អ្នកចូលរួមសិក្ខាសាលា និងអ្នកពាក់ព័ន្ធទាំងអស់ ហើយយើងសង្ឃឹមថា វានឹងជាផែនទីបង្ហាញផ្លូវសម្រាប់ អ.វ.ត.ក ក្នុងដំណាក់កាលដែលនៅសេសសល់ និងក្របខ័ណ្ឌជាក់ស្តែងសម្រាប់អ្នកផ្តល់មូលនិធិដើម្បីផ្តល់ការគាំទ្រក្នុងការកសាងនូវអ្វីដែលបានសម្រេចបានរួចមកហើយ សំដៅបង្កើតកេរដំណែលអ.វ.ត.ក ពិតប្រាកដដ៏មានតម្លៃមួយសម្រាប់កម្ពុជា។

# បញ្ជីឧបសម្ព័ន្ធ

I. អត្ថបទកិច្ចព្រមព្រៀងបន្ថែមនៃកិច្ចព្រមព្រៀង UN-RGC

II. សេចក្តីអំពាវនាវបង្ហាញចំណាប់អារម្មណ៍បំពេញមុខងារជាអ្នកសម្របសម្រួល អ្នកចាត់ចែង និងអ្នកជួយសម្រួលការងារ

III. របៀបវារៈចុងក្រោយសម្រាប់សិក្ខាសាលាខែឧសភា ឆ្នាំ២០២២

IV. សេចក្តីប្រកាសសារព័ត៌មានចំនួនពីរ (ទាំងពីរភាសា) សម្រាប់សិក្ខាសាលាខែឧសភា ឆ្នាំ២០២២

V. ប្រតិចារឹកនៃសុន្ទរកថាក្នុងវគ្គសាធារណៈនៃសិក្ខាសាលាខែឧសភា ឆ្នាំ២០២២

VI. សំណើទាំងអស់ឆ្លើយតបទៅនឹងសេចក្តីអំពាវនាវខែតុលា ឆ្នាំ២០២១ របស់សហចៅក្រមរបាយការណ៍

VII. សំណើទាំងអស់ដែលបានដាក់ជូនលេខាធិការដ្ឋានក្រោយសិក្ខាសាលាខែឧសភា ឆ្នាំ២០២២

របាយការណ៍ជាភាសាខ្មែរ
ISBN-13: 978-9924-9747-0-3

9 789924 974703 >